
ភគ្គលសន្ទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែមករា លេខ ១

ព. ស. ២៤៨៣ — គ. ស. ១៩៤១



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	បញ្ញើរឿង	ទំព័រ
ប្រវត្តិសាស្ត្រនៃស៊ីវិល្ហៃខ្មែរបុរាណ(តចប់)	លោក វ៉ាយ - ប៊ុក	៣
សព្ទចាត់ថ្នែក្រែងខ្មែរ (តមក)	– ម៉ឹញ - ឆាំត្រី	១០
រឿងត្រែងភូមា (តមក)	– សាង - សាវ៉ាត	១៤
រឿងសាមកុក (តមក)	– ខ្លូ - កន	២៣
ព្រះរាជពង្សាវតារអប្រទេសកម្ពុជា (តមក)	– ឈឹម - ក្រសែម	៣៥
សាវតារវត្តចាប៉ាសាម (តចប់)	ព្រះវិនយធរគណ	៤៣
ប្រវត្តិអេសុប (តចប់)	លោក ផេង - ដ្រីវ	៥២
ផ្នែកសាសនា		
ពន្ធីអាស៊ីទ្វីប (តមក)	លោក វ៉ាយ - ប៊ុក	៦២
ឱបក្តីលេស ១៦ ពាក្យកាព្យ	– យូរ - អ៊ុន	៦៧
កំណត់ទឹងប្រវត្តិការណ៍		
ពិធីទទួលសម្តេចសង្ឃនាយក ដូច-ណាត នៅវត្តដំណាក់ (សៀមរាប)	ព្រះមហាកែ - អ៊ឿន	៧៤
បញ្ជីរាយនាមចៅអធិការតាំងថ្មី (តមក)	ក្រសួងធម្មការ	៧៩

មួយឆ្នាំមាន ១២ សៀវភៅ ជាំខ្សែដាវ ១៤,៥០

KAMBUJASURIYA

Revu religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE LITTERAIRE

		Pages
Histoire de l'ancienne civilisation Khmère (suite et fin)	M. RAY-BUC	3
Recueil des mots traduits par la Commission Culturelle (suite) .	M. MENH-NAKRY	10
Contes birmans	M. SANG-SAVAT	14
Histoire de SAMROK (suite)	M. NOU-KAN	23
Histoire du Royaume du Cambodge (suite	M. CHHIM-KRASEM	35
Nolice historique de la pagode de Pacinarama (suite et fin)	PREAH VINAYADHARA GANA	43
Biographie d'ESOPE (suite et fin)	M. PHENG-CHRIEU	52

PARTIE RELIGIEUSE

La Lumière de l'Asie (suite)	M. RAY-BUC	62
Seize Upakilesa (Poème)...	M. YOU-OUN	67

NOTES ET CHRONIQUES

Réception de SON EMINENCE le Chef de la Secte Mohanikay à la pagode de Damnak (Siemreap)	PREAH MOHA KER-CŒUN ...	74
Nomination des nouveaux Chau-Athicar (suite)	MINISTERE DES CULTES	79

Prix d'un abonnement annuel comprenant 12 numéros: 145$00

លោក ស៊ីរស៍-ស៊ីដែស តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(៣ ០ប់)

ពួកស្ត្រីមិនមែនបោះបង់ការសិក្សាទេ ហើយមានស្ត្រីខ្លះព្យាយាមរៀនសូត្រជាងគេក៏មាន ។ នៅបុង្គសតវត្សទី ១២ មានសិលាចារឹកមួយថ្លែងថា "មានព្រះអង្គម្ចាស់ក្សត្រីមួយអង្គ មានប្រាជ្ញាចេះដែរដែនជាងចំណេះពួកទស្សនវិទូទៅទៀត ហើយព្រះមហាក្សត្រិយ៍បានតែងតាំងព្រះនាងជាសាស្ត្រាចារ្យនាយិកានៅវត្តព្រះពុទ្ធសាសនាមួយ ដែលមានកិត្តិនាមល្បីល្បាញអស្ចារ្យ មានមុខងារនោះតិបង្ហាត់បង្រៀនពួកនារីទាំងអស់ ។ កន្លងបន្តិចមកព្រះនាងបានឡើងឋានន្តរស័ក្តិជាព្រះអគ្គជាយាមួយអង្គ, តែព្រះនាងខត្តិយានី មិនបានបោះបង់ចោលពួកនិស្សិតដែលព្រះនាងធ្លាប់បង្ហាត់ពីពេលមុនមកទេ ។ តាមសិលាចារឹកពោលថា "ចំពោះបណ្តាពួកស្ត្រីដែលពេញចិត្តខាងរៀនវិទ្យា, ព្រះនាងបានផ្សាយព្រះកិត្តិសព្ទព្រះមហាក្សត្រិយ៍ពង្រីកគ្រប់ភូមិភាគជនបទ ដោយព្រះនាងប្រើប្រាជ្ញា ដែលគេប្រៀបដូចជាទឹកអម្រឹត្យ មានឫទ្ធានុភាពវិសេសវិសាលពន់ពេក" ។ គេបានឃើញនូវស្នាព្រះហស្តរបស់ព្រះនាងគឺពាក្យទំនាយវែង ដែលជាងបានឆ្លាក់កងវែនសិលាមួយ ដែលគេបានរកឃើញនៅខាងកងព្រះបរម-

រាជវាំងអង្គរធំ, និពន្ធនោះ ព្រះនាងបានតែងជាពាក្យកាព្យអក្សរសំស្ក្រឹត ពីកេះចាប់ចិត្តណាស់ ។

ដើម្បីទំងន់ពន្យល់អំពីលក្ខណៈឥណ្ឌានៃសុរិយាក្នុងពេលនោះ ដែលខ្ញុំបានពណ៌នាតែងគោលសំខាន់ៗ គេបានព្រមព្រៀងគ្នាថាប្រជារស្ត្រខ្មែរដើម មកពីប្រទេសឥណ្ឌា ។ បើពិនិត្យតាមចរិតប្លែកលក្ខណៈនៃរូបភាពទំងកាសាជាតិ, ជាតិខ្មែរដែលជាអ្នកស្ថាបនាប្រាសាទអង្គរព្រមទាំងពលរដ្ឋប្រទេសកម្ពុជាសម័យបច្ចុប្បន្ន គឺជាជាតិក្នុងវង្សប្រជាជាតិ ដែលនៅក្នុងឧបទ្វីបឥណ្ឌូចិន តាំងពីសម័យបុរាណ, ហើយបើទុកណាជាក្នុងកំឡុងដែលពួកជាតិឥណ្ឌូបានចូលមកតាំងនៅក្នុងប្រទេសនេះ តាំងពីសតវត្សទីមួយនៃគ្រិស្តសករាជ, ក៏អកដនខ្មែរនោះមានលោហិតជាតិឥណ្ឌូខ្លះមកលាយជាមួយតាំងពីសម័យអង្គរ ។ គេមិនត្រូវយល់ថាថ្នាក់ប្រជាជាតិដែលត្រួតត្រានៅពីនេះ (ឥស្សរជន) ជាប្រជាជាតិដោយខ្មែរកពីពួកពលរដ្ឋនោះឡើយ ។ តាមរូបចំឡាក់ គេបានឃើញភាពខ្ពង់ច្រាយមុខជាខ្មែរ ហើយមានឈ្មោះជាខ្មែរដូចគ្នា ។

គេអាចពោលបានថា សុរិយាខ្មែរបុរាណជាសុរិយាមួយដែលកើតមកពីសុរិយាឥណ្ឌាប្រថម ហើយមានសភាពលាយឡំគ្នានឹងសុរិយានៃពលរដ្ឋឥណ្ឌូចិន ។ សុរិយានោះជាឥណ្ឌូ ដូចសុរិយាចាវ៉ាជាឡាឥន (គឺមកពីជាតិរ៉ូម៉ាំង) ដោយមានលក្ខណៈប្លែកគ្នា តែចម្ងាយនៃសុរិយា

ឥណ្ឌូនីស៊ីវិទ្យាខ្មែរជាន់ដើមនោះ មានសក្ខាភស្តុយជាធំស៊ីវិទ្យា"អ៊ូម៉ាំង ដែលផ្សាយទៅកាន់ស៊ីវិទ្យាកូល្យា" ។ គេអាចយល់បានច្បាស់សេចក្តីសំខាន់ចំពោះពាលវង្សខ្មែរក្នុងកម្ចិកភាពនៃស៊ីវិទ្យាប្រទេសឥណ្ឌា ដោយបានសង្កេតការណ៍ដែលខ្ញុំបានពណ៌នាក្នុងសៀវភៅខ្ញុំ ឈ្មោះប្រវត្តិសាស្ត្រសម័យបុរាណនៃវង្សជាតិឥណ្ឌា (Histoire ancienne des Etas hindouisés) ។ បើតាមលក្ខណៈនៃរូបនិយម, អ្នកក្បែតភាវខ្មែរមិនខុសគ្នាពីជាតិឆ្នង ឬជាតិសំរែទេ តែជាតិឆ្នងដូចជាតិម៉ាយនៅប្រទេសយួននៅខាងថ្ងាក់នៃអង្គការកុលសម្ព័ន្ធ; ជាតិនេះបានផ្សះផ្សារឿងឈ្មោះទាស់ទែងគ្នាតាមទំនៀមទម្លាប់ដែលនិយាយគ្នាមក, ពួកកុលសម្ព័ន្ធនេះកាន់សាសនាអនិស្សមានកាយលទ្ធីគឺដើរកូតបិសាច (Animisne); លោកជាតុវិន័យគឺការយល់ឮរបៀបញ្ញត្តិដែលសត្វលោកនៅក្នុងចក្រវាឡត្រូវប្រតិបត្តិតាម (Cosmologie) នោះតិចតួចស្ទួចស្តើងណាស់; ជាតិទាំងនេះមិនមានអក្សរសម្រាប់សរសេរគោសាខ្លួនទុកឡើយ ។ តែភាវដែលនៅរាត្តន៍អន់ខ្សោយក៏ដោយ បានចូលមកជាច្រើនសតវត្សៗមក ក្នុងគ្រឿងចក្រនៃវង្សតាមថ្នាក់តាមជាន់; ខ្មែរទាំងនោះ បើត្រូវគេចោទក្នុងរឿងក្តីនីមួយៗ មានសាលាកាត់សេចក្តីតាមច្បាប់ដែលមានអក្សរសរសេរស្រាប់ ហើយបានកាន់យ៉ាងមាំមួននូវសាសនាដែលមានឡាក់គោលច្បាស់លាស់, មានគម្ពីរ មានទាំងព្រះសង្ឃដែលជាអ្នកបង្ហាត់បង្រៀននូវវិទ្យាលោក

វិទ្យានឹងបរលោក ព្រមទាំងរឿងរ៉ាវដែលទាក់ទងនៅក្នុងចំណោមនៃមនុស្សធម្មិកនៅអាស៊ីទ្វីប ។ ក្រៅពីនោះ ជាតិខ្មែរមានរបៀបអក្សរដែលជាហេតុឲ្យកើតមានអក្សរសាស្ត្រ អាចឲ្យមានផ្លូវគមនាគមន៍ប្រស័យគ្នាចំពោះប្រទេសជិតខាង ។ កិច្ចការទាំងអស់នេះ កើតឡើងដោយសារបានផ្ទេរស៊ីវិល័យមកពីប្រទេសឥណ្ឌា ។

បឋមហេតុនៃស៊ីវិល័យខ្មែរ យើងស្រាវជ្រាវបានយល់ខ្លះ ។ ការណ៍ដែលខ្មែរទ្លាក់ចុះអាប់ស្មីពីកាលសតវត្សរ៍ទី ១៤, គេបានស្មាននូវហេតុនោះដោយពោលពាក្យមិនគប្បីនឹងឲ្យជឿបាន គេថាមកពីកន្លាប់ប្រថពីឬមកពីទុកភ័យ ឬក៏មកពីប្រែប្រួលអាកាសធាតុដែលនាំឲ្យប្រទេសកម្ពុជាគោកទឹក ។ បើតាមពិនិត្យ, កុងសតវត្សរ៍ទី ១៣ មានគណៈប្រតិភូចិនម្នាក់ដែលបានមកទស្សនាការប្រទេសកម្ពុជា បានកត់ត្រាទុកថាមានហេតុពីពេលនោះ គួរសំគាល់បាននូវហាយនភាពនៃជាតិខ្មែរកន្លងកាលជាអនាគត ។ ប្រតិភូចិនបានកត់ត្រាថា: កុងសង្គ្រាមចំពោះប្រទេសសៀម, ស្តេចខ្មែរបានបង្កាប់ទៅពលរដ្ឋទាំងអស់ឲ្យចូលតស៊ូ ហើយថាប្រទេសខ្មែរកុងពេលនោះត្រូវសៀមមកលុកលុយជាច្រើន ។ សង្គ្រាមនោះ មានកុងរយៈវេលាមិនដល់មួយសតវត្ស គិតតាំងពីការកសាងនូវប្រាសាទសម្រាប់បញ្ចុះព្រះសពមានប្រាសាទអង្គរ (នគរ) ជាដើមនៃមហាឧជាតិសតវត្សទី ១២ ។

មានការកេណ្ឌប្រជាពលស្ត្រ ដើម្បីនឹងកសាងនូវព្រះស្តូបចេតិយ (ច្រាសាខ) ទាំងនោះ, រួចមានសង្គ្រាមជាច្រើនលើក នាំឲ្យពលរដ្ឋខ្មែរត្រូវលំបាកជាខ្លាំង ហើយបច្ចាមិត្តដែលមានដោតជ័យកងសង្គ្រាមនេះ បានធ្វើឲ្យចំនួនប្រជាជនខ្មែរអន់ថយចុះ ដោយនាំយកទៅជាឈ្លើយច្រើននាក់, ការខ្ពូលភាពនូវពាជការកណ្តាល ដោយហេតុមកពីការមិនថែទាំនូវធាតុសាស្ត្រនៃប្រទេស, ហើយចុងក្រោយបង្អស់ មានការបោះបង់ចោលនូវព្រះរាជធានីកងសតវត្សទី ១៥, នេះជាឡាក់គោលដែលពន្យល់អំពីការមានពាសចុះអាប់ស៊ីវិឡៃសម័យអង្គរ ។ ស៊ីវិឡៃនៃប្រទេសកម្ពុជាសម័យទំនើបនេះ គឺផ្តិតយកពីស៊ីវិឡៃអង្គរ ហើយកិច្ចការដែលធ្វើឲ្យយើងកាន់តែក្តីកងរឿងនេះ ដោយបានអានូវសារណា (mémoire) នៃទំនៀមទម្លាប់ប្រទេសកម្ពុជាដែលអ្នកដំណើរចិនបានតែង ទៅឃើញមានពិពណ៌នាខ្លះ នឹងយោបល់ខ្លះ ល្មមយកមកអនុវត្តន៍នូវស្ថានការណ៍នៃប្រទេសកម្ពុជាកងសតវត្សទី ២០ នេះបានដែរ ។

ស៊ីវិឡៃសៀមដែលមានតាំងពី គ. ស. ១២៩០ ឬ ១៣៩០ សុទ្ធតែបានមកពីស៊ីវិឡៃសម័យអង្គរទាំងអស់ ។ ប្រទេសកម្ពុជា ដែលជានាយកលើប្រទេសសៀមជាច្រើនសតវត្ស, ជាតិសៀមបានផ្ទេរយកអង្គការនយោបាយអក្សរដែលបានមកពីអក្សរហិណ្ឌូ, ទឹងពាក្យខ្មែរជាច្រើន; ពួកសិល្បករសៀមបានផ្ទេរយកវិទ្យាសិល្បករពីខ្មែរ ហើយយកទៅរចនាតាមច្បាប់របស់ខ្លួន ។

ប្រទេសកម្ពុជាបានផ្សាយឥទ្ធិពលទៅដល់ប្រទេសលាវ ដោយសារព្រះពុទ្ធសាសនា ។ ព្រះពជអាណាចក្រលាវបានស្ថាបនាឡើងក្នុងលោកពី គ. ស. ១៣៥៣ មានរាជជនកគឺព្រះអង្គម្ចាស់ ហ្វា-ង៉ឺ ដែលមហារាជសម័យអង្គរបានយកមកបីបាច់រក្សានៅក្នុងព្រះបរមរាជវាំង ដោយមានព្រះបិតានៃព្រះអង្គម្ចាស់នេះ ទ្រង់បានចាកចេញពីប្រទេសចូលមកសុំពំនាក់អាស្រ័យនៅទីនោះ ។ ព្រោះហេតុដូចនេះ បានជាមានបញ្ចូលស៊ីវិល្ហែរទៅឯទន្លេមេគង្គខាងលើ ។ ដល់សោយរាជ្យបានយូរបន្តិច, ព្រះមហាក្សត្រិយ៍លាវនេះបានចាត់ នូវបេសៈកម្មមួយ ដែលមានកិច្ចមួយអង្គជាអាចារ្យរបស់ទ្រង់ឲ្យចេញពីប្រទេសកម្ពុជា ហើយមានព្រះសង្ឃនឹងពួកជាងរចនាគូឆ្ងាក់ទៅជាមួយផង ដើម្បីនឹងផ្សាយនូវពុទ្ធសាសនានឹងសិល្បកម្មចំពោះប្រទេសនេះ ។

លុះដល់ជាតិខ្មែរបានឃើញអំណាចរបស់ខ្លួនថយចុះ មិនបានស្ថិតនៅក្នុងភូមិភាគទន្លេមេណាមនឹងទន្លេមេគង្គខាងលើ ក៏បានទុកឲ្យដល់ជាតិសៀមនឹងលាវនូវក្តីដំណែលនៃវប្បធម៌ហិណ្ឌូ ដែលជាវប្បធម៌ជាប់ទាក់ទងពីស៊ីវិល្ហែបុពណ្ណនៃប្រទេសមេសូប៉ូតាមី, ជាឫសគល់វប្បធម៌នៃបច្ចិមប្រទេស ។

បើពោលពាក្យកុំឲ្យហួសហេតុ, គេអាចពោលថាក្នុងសហរដ្ឋ-ឥណ្ឌចិន, ចំពោះប្រទេសយៀកណាមយកវប្បធម៌ចិនមកប្រើ, ប្រទេស

កម្ពុជា ទឹងប្រទេសលាវជាគណៈប្រតិភូនៃវប្បធម៌ដែលមានសភាពដូចគ្នា
នឹងវប្បធម៌របស់យើង ។ ឯភាសាយួនដែលនឹងចំរើនបានដោយខ្លឹអក្សរ
សាស្ត្រចិនយកមកប្រើខ្លះ ។ ចំណែកខាងភាសាខ្មែរហើយនឹងលាវបាន
យកភាសានៃប្រទេសឥណ្ឌា គឺភាសាសំស្ក្រឹតនឹងបាលីដែលចូលក្នុង
វង្សភាសាឥណ្ឌូ — អើរ៉ូប ដូចជាភាសាឡាតាំងនឹងក្រែកដែរ ។

ចំពោះការជាប់វង្សត្រកូលខាងភាសា ដែលប្រវត្តិសាស្ត្រនឹងភាសា
សាស្ត្របានបំភ្លឺក្នុងរឿងនេះ គេអាចយល់បានថាបញ្ហានេះយ៉ាងចាស់
ក៏មានសភាពដូចគ្នា ដូចមានព្រឹត្តិការណ៍សម័យបច្ចុប្បន្នបានបញ្ជាក់ឲ្យ
ឃើញក៏ស្តែងស្រាប់ ។

ចប់

មែនឬទេ ?

ទង់ជ័យកើតឡើងអំពីពាហារសាសនា តែប្រជាជាតិត្រូវ
រក្សាទង់ជ័យនោះឲ្យជ្រួបជាដួងវិញ្ញាណរាល់រូប ព្រោះ
ទង់ជ័យរលត់ ជាតិក៏រលត់ ។ យូរ-អ៊ិន

ស័ព្ទចាក់ផ្តែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

លោក ម៉ិញ - ង៉ាគ្រី រួបរួម

(ពមក)

Délégué de Sa Majesté à Siemréap = ភាជប្រតិភូនៅសៀមរាប

Délégué de Sa Majesté Commandant le Secteur autonome à Siemréap = ភាជប្រតិភូអ្នកបង្គាប់ការក្នុងតំបន់ស្វ័យភាពនៅសៀមរាប

Le rêve = ការយល់សប្តិ, សុបិន, វិតក្កៈ

Membre souscripteur = សមាជិកចុះស្នើគ្រែ

Droit d'entrée = ជម្លៃចូល

Cotisation = ថ្លៃចាក់អង្គាស

Subvention = ថ្លៃចាក់បន្ថែម

Service d'Enregistrement et des Timbres = ក្រុមទុកបញ្ជីទ្រព្យភាជការនិងតែម

Enthousiasme = សាទរ

Coup d'Etat = រដ្ឋប្រហារ

Coup de théâtre = ប្រវត្តិប្រហារ

Coup de force = ពលប្រហារ

Commando de contre-guérilla = កងពិសេសលប់ចំពាក់ព្រៃ

Acte de préméditation = អំពើដែលគិតទុកជាមុន

Indécision = ការណ៍មិនដាច់ស្រេច

(៦ - ៦ - ៥០)

Fidèle = ភក្តី

Fidélité = ភក្តីភាព

(៣០ - ៦ - ៥១)

Titre d'identité = អត្តសញ្ញាណប័ណ្ណ

Carte d'identité = ប័ណ្ណសំគាល់ខ្លួន

Rapport = សេចក្តីរាយការ

Rapporteur = អ្នករាយការ - អ្នកនាំការ

Signaler = ធ្វើសញ្ញាប្រាន

(៣ - ៣ - ៥០)

Durée = កំឡុងពេល (ថិរវេលា)

Automatique = ស្វ័យប្រវត្តិ

Assurer = ការពារ

L'ostréiculture = សិប្បវប្បកម្ម (ការចិញ្ចឹមគ្រែ)

La sylviculture = វុក្ខវប្បកម្ម (ការបណ្តុះបណ្តាលព្រៃ)

La sériciculture = កោសេយ្យវប្បកម្ម (ការចិញ្ចឹមនាង)

(១១ - ៣ - ៥១)

L'aviculture = បក្សីវប្បកម្ម (ការចិញ្ចឹមសត្វស្លាប)

L'horticulture = អាពាមវប្បកម្ម (ការដាំសួន)

L'apiculture = មធុវប្បកម្ម (ការចិញ្ចឹមឃ្មុំ)

La puériculture = ទារកវប្បកម្ម (វិធីចិញ្ចឹមទារក)

La pisciculture = មច្ឆវប្បកម្ម (ការចិញ្ចឹមត្រី)

L'ostréiculteur = សិប្បិវប្បករ

Le sylviculteur = វនវប្បករ

Le sériciculteur = គោសេយ្យវប្បករ

L'horticulteur = អាពាមវប្បករ

L'aviculteur = បក្សីវប្បករ

Un automate = ស្វ័យប្រវត្តិ៍ (ដែលប្រព្រឹត្តទៅខ្លួនឯង, មនុស្សដែលធ្វើការដោយមិនបាច់គិត)

Robot = ស្វ័យគម (ដែលទៅខ្លួនឯង)

Avion téléguidé = យន្តហោះទូរណាំត្តិ (យន្តហោះដែលប្រើពីចម្ងាយ) (๒๑ - ๓ - ๔๐)

Nom posthume = មរណនាម, នាមបច្ឆាមរណៈ

Livre posthume = សៀវភៅបច្ឆាមរណៈ

Fils posthume = បុត្របច្ឆាមរណៈ

Enfant posthume = កូនបច្ឆាមរណៈ

A titre posthume = ជាកិច្ចបច្ឆាមរណៈ

Lâche = កំសាក

Lâchement = ដោយកំសាក

La lâcheté = សេចក្តីកំសាក

Hélicoptère = ទុន្ធីគាមបក្ស

(២៥ - ៣ - ៥០)

Administrer = គ្រប់គ្រង

Carte administrative = ផែនទីរដ្ឋបាល

Carte provinciale = ផែនទីខេត្ត

Carte routière = ផែនទីគមនាគមន៍

Carte politique = ផែនទីប្រជាគណន៍

Carte physique = ផែនទីរូបនិយម

Carte économique = ផែនទីសេដ្ឋកិច្ច

Route nationale = ថ្នល់ជាតិ

Route provinciale = ថ្នល់ខេត្ត

Route communale = ថ្នល់ឃុំ

(៤ - ៨ - ៥០)

(អាខត)

លោក សាង - សារ៉ាត លេខាធិការក្រសួងវប្បធម៌

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

នាយសួនក្រាបបង្គំទូលថា «សូមទ្រង់ព្រះមេត្តាប្រោស! ព្រោះកាលពីថ្ងៃមុនមិនសូវមានសត្វដូចសព្វថ្ងៃនេះ, ឥឡូវនេះមានសត្វសេកមួយរុកកន់បំផ្លាញពេកណាស់, ទូលព្រះបង្គំដេញចាប់វាពុំបានសោះ" ។ ស្តេចក៏មានព្រះពាក្យសួរទៀតថា «មែនឬ? បើមែនអញនឹងប្រមូលពួកព្រាន ដែលនៅកងកំដាំងប៉ុន្មានមកដើម្បីឲ្យធ្វើអន្ទាក់ចាប់វាឲ្យបានកងពេលនាប់ៗនេះ" ។

មិនយូរប៉ុន្មានទេ បក្សាកំសត់នោះក៏ត្រូវគេចាប់បានមែន ។ ប៉ុន្តែអស់ពួកព្រានឃើញសេកនេះល្អ ក្អែកវាលង ពណិស្រស់ក៏មានចិត្តមេត្តាករុណាជាក្រៃពេកដល់បក្សា ហើយបានយកទាំងរស់ទៅថ្វាយព្រះរាជា ។ លុះទ្រង់ទតឃើញជាសេកនេះល្អ ស្តេចក៏យកទៅប្រទានដល់ព្រះរាជបុត្រីព្រះអង្គ ។ ឯព្រះរាជធីតាមានព្រះរាជហឫទ័យស្រឡាញ់សេកនោះពន់ពេក ហើយព្រះនាងយកទៅថែរក្សាផ្ទាល់ព្រះអង្គ ។ មួយថ្ងៃៗ ព្រះនាងតែងលេងជាមួយ កាន់អង្អែលមិនឈប់មិនឈរឡើយ ។ មានថ្ងៃមួយ ព្រះនាងយកសេកនោះទៅជាក់

លើក្បាលដង្កូងព្រះនាង ស្រាប់តែនាងឃើញខ្សែសូត្រតូចធ្នាររុំនៅក, ព្រះនាងខ្វាចបក្សាអង្រួកក៏ស្រាយខ្សែនោះចេញ ។

លុះស្រាយរួចក្លាម បក្សាក៏ក្លាយកេទទៅជាបុរសមួយយ៉ាងស្អាត មុខមាត់សមសួន ពាក់ឈៅឆើតឆាយ ។ ព្រះនាងនឹកឆ្ងល់ណាស់ ហើយព្រះនាងដើរទៅជិតបុរស យកខ្សែនោះទៅចងកឲ្យវិញដូចពីមុន ។ ស្រាប់តែបុរសក្លាយខ្លួនជាសត្វសេកវិញក្លាម ។ លុះដឹងរឿងនេះសព្វគ្រប់កាលណា ព្រះនាងញញឹម ហើយមានព្រះហឫទ័យស្នេហ៍ស៊ប់លើរូបបុរសនោះពន់ពេក ។ ព្រះនាងនឹកទៀតថា មុខជាបានរួមសេរួមរាសនាទឹងបុរសនេះដោយឥតស្ទើស្ទាំណាមួយដងឡើយ ។

កាលពីព្រះនាងស្រាយខ្សែសូត្រ ហើយនៅរួមសេមេត្រីជាមួយទឹងបុរសយ៉ាងក្សេមក្សាន្ត ។ លុះភ្ញើឡើងព្រះនាងចងខ្សែនោះទៅវិញ ។ ព្រះនាងអង្វែលសេកនោះលេងមិនចេះអស់ព្រះទ័យឡើយ ។

ជនពាំងពីរនេះនៅជាមួយគ្នាយ៉ាងសប្បាយអស់កាលជាច្រើនឆ្នាំ ។ ប៉ុន្តែមនុស្សសត្វនៅនាលោកនេះ បើមានសុខហើយ តែងមានទុក្ខផងគ្មានអ្វីស្ថិតស្ថេរយូរអង្វែងទេ ។ ថ្ងៃមួយនោះ គេបានសង្កេតឃើញរូបកាយព្រះនាងដែលស្តើងតូច ក្លាយទៅជាទុសធម្មតាស្ត្រីព្រហ្មចារី បីដូចបុប្ផាដែលត្រកំដៅព្រះអាទិត្យ ប៉ុន្តែគ្មានអ្នកណាមួយអាចដឹងដល់ការណ៍អាថកំបាំងនេះឡើយ ។

រឿងនេះបានផ្សាយដល់ព្រះមហាក្សត្រ ស្តេចមានព្រះហឫទ័យ
ធ្ងៀងធ្ងល់ ហើយឱ្យសេអៀនជាពន់ពេក ។ ព្រះអង្គទ្រង់គ្រាស់បង្គាប់
ឱ្យលោកចៅក្រមអង្កេតមើលភ្លាម (ព្រោះកាលនោះគេនិយមធ្វើអង្កេត
ដូចសព្វថ្ងៃនេះដែរ) ឯក្នុងសម័យនេះមានតែការផ្តេសផ្តាសទេដែលនាំ
ឱ្យគេឃើញការណ៍ពិតនោះ ។

រីឯសត្វសេក លុះកាលណាឮថាគេធ្វើសង្កេតដូច្នោះ មានចិត្ត
តិតភ័យជាខ្លាំង ហើយស្ទុះហើរពីបង្អួចចុះទៅក្នុងសួនច្បារដែលនៅជិត
នោះ ។ ក្នុងពេលនោះ សរសៃអាំបោះក៏របូតចេញពីក ដោយសារ
ទំប្រឹងស្ទុះនេះ ។

បក្សាក៏ក្លាយខ្លួនទៅជាមនុស្សវិញ ហើយទំរន់យ៉ាងប្រញាប់ចញពីផ្ទះ
រាំង ។ បន្តិចក្រោយមក បុរសឃានទៅដល់ផ្ទះមហាសេដ្ឋីមាក់ដែលកំពុង
បរិភោគអាហារជាមួយភរិយានឹងបុត្រី នៅលើកន្ទេលមួយយ៉ាងស្អាត ។

ដំបូងមហាសេដ្ឋីនេះតិតភ័យជាខ្លាំង ប៉ុន្តែក្រោយមក មានចិត្ត
សង្ស័យថា បុរសនេះមិនមែនជាចោរទេ ប្រហែលមានរឿងអ្វីផ្សេងៗ
យ៉ាងប្លែកហើយៗលោកក៏សាកសួរអំពីដើមហេតុ ដែលនាំឱ្យបុរសនេះ
រត់ចូលមកក្នុងផ្ទះរបស់លោកយ៉ាងប្រញាប់ដូច្នេះ ។

បុរសនឹកថាមុខតែខ្លួនស្លាប់ហើយ, រួចក៏រៀបរាប់ប្រាប់មហាសេដ្ឋី
តាមដំណើរតាំងពីដើមដល់ចុងឥតចន្ទោះកន្លែងណាមួយ ។

រីឯបុត្រីរបស់លោកមហាសេដ្ឋីស្តាប់បុរសនិយាយផង ក្អែកលួចមើលផង ។

លុះបុរសនិយាយចប់ហើយ លោកមហាសេដ្ឋីមានចិត្តមេត្តាជាពន់ពេក ហើយបានហៅបុរសនេះឲ្យចូលមកបរិភោគបាយជាមួយដូចក្រុមញាតិរបស់លោក ។ ព្រោះសេចក្តីខ្មៀចហត់នឿយសេចក្តីខ្វាចស្តាប់ពន់ពេក បុរសមិនចាំបាច់ឲ្យគេហៅយូរ ចូលបរិភោគជាមួយភ្លាមទៅ ។

ចំណែកខាងពួកកងក្រវែល លុះកាលណាបានឃើញបុរសនេះរត់យ៉ាងលឿនដូច្នោះ ទឹកស្មានថាជាចោរលួចតព៌ាន់ធ្ងន់គេ ក៏ដាំគ្នាដេញចាប់តបង្អង់ខ្លាំង ។ ប៉ុន្តែបិតារបស់ស្ត្រីដែលមានសតិវង្វាងគេហើយដែលមានគំនិតមួយលាក់ទុកក្នុងខ្លួនផង ក៏បាននិយាយការទៅពួកកងក្រវែលថា "តើលោកមកនេះមានការអ្វីនៅទីនេះ មានកែវុំ, កូនស្រីវុំនឹងកូនប្រសាវុំប៉ុណ្ណោះ ដូចលោកឃើញស្រាប់ហើយ, យើងទាំងអស់គ្នាកំពុងបរិភោគអាហារ, ប៉ុន្តែបើលោកស្មានថាមានចោរវត់ចូលមកកងផ្ទះរបស់វុំ សូមលោកអញ្ជើញរកមើលចុះ", ថាហើយលោកមហាសេដ្ឋីក៏បើកឲ្យពួកកងក្រវែលឆែកឆេរផ្ទះរបស់លោកគ្រប់កន្លែង ។ លុះរកមើលសព្វគ្រប់ហើយ ពួកកងក្រវែលក៏សុំទោស រួចថយខ្លួនចេញអស់ទៅ ។ ឯបុរសក៏បានរួចខ្លួនកងពេលនោះ ។

លុះកាលណាផុតអំពីរឿងដ៏លំបាកនេះហើយ មហាសេដ្ឋអង្គុយ
លួចមើលមុខបុរស ឃើញកិរិយានឹងមារយាទល្អៗ ក៏ដុំនុំនឹងកិរិយា
របស់លោក សម្រេចឲ្យបុត្រីទៅបុរសនោះទៅ ។

ក្នុងពេលនោះ បុត្រីរបស់ព្រះមហាក្សត្រទ្រង់អាពាធជាទម្ងន់ ដោយ
សេចក្តីនឹករលឹកដល់បុរស ។ កាលថ្ងៃព្រះនាងនៅសន្ធឹកសន្ធៃស្រោន
ស្រពន់ នាំឲ្យលោកគ្រូពេទ្យទាំងប៉ុន្មានព្រួយចិត្តពន់ពេក ។ ព្រះមហា-
ក្សត្រទាល់តំនិតក៏ធ្វើមិនដឹងខ្លួន ស្តេចទៅសួរព្រះរាជបុត្រីឲ្យព្រះនាងមាន
បន្ទូលដោយត្រង់តាមទំនងហេតុដែលទាំងឲ្យកើតទុក្ខឈឺទាំងខ្លួននេះ ។
ព្រះនាងក៏បានទូលព្រះបិតាតាមដំណើរ ហើយអង្វរព្រះអង្គឲ្យរកបុរស
ដែលព្រះនាងស្រឡាញ់ពេញចិត្តនេះឲ្យឃើញវិញ ។

ឯព្រះមហាក្សត្រដោយសារសេចក្តីស្រឡាញ់បុត្រីពេក ក៏ភ្លេច
សេចក្តីក្រែវក្រោធ ហើយបានទាំងចាត់ចែងឲ្យអស់ពលរេហ៍រកបុរសវិញ
គ្រប់ជំបន់ផង ។ មួយទៀតស្តេចបានតាំងព្រះទ័យថា ទ្រង់នឹងលើក
លែងទោសឲ្យបុរសនោះថែមទៀត ។ ប៉ុន្តែបុរសនោះគេរកមិនឃើញ
សោះ ។ ក្រោយមកព្រះអង្គទ្រង់ធ្វើទុក្ខាយមួយ គឺធ្វើបុណ្យយ៉ាងធំ
ក្នុងព្រះរាជវាំង ហើយស្តេចទ្រង់បង្គាប់ឲ្យអស់នាហ្នឹងមុខមន្ត្រីឲ្យចូលមក
មើលបុណ្យនោះ ដោយខានមិនបានទាំងក្រុមញាតិវៀរាល់គ្នាផង ។

អាស្រ័យហេតុនេះក្នុងទីក្រុងនោះគ្មានអ្នកណាមួយខាងឡើយ ។ បណ្តាពួកអ្នកទៅមើលបុណ្យ បុរសនឹងកំរិយាក៏បានទៅមើលដែរ ។ ឯព្រះពោធិបុត្រដែលទំសំឡឹងមើលមិនដាក់ព្រះនេត្រក៏ស្រែកឡើងថា "នុ៎ះ ប្តីខ្ញុំ" ។ ក្នុងពេលនោះ មានស្ត្រីម្នាក់ទៀតស្លៀកពាក់ស្អាតបាតចេញអំពីចំណោមមកប្រកែកជាមួយព្រះពោធិបុត្រថា, នាងនេះជាកំរិយាដើមរបស់បុរសដែលបានគ្នាកាលមុនពស់ចឹក, នាងនិយាយថា "ខ្ញុំសូមបញ្ជាក់ថា បុរសនេះជាប្តីខ្ញុំបានរៀបការពេញច្បាប់, កាលដែលពស់ចឹកគាត់ស្លាប់ទៅនោះ ខ្ញុំបានយកបូគាត់ទៅចងនៅលើក្បូនមួយតាមពាក្យរបស់គាត់ រួចខ្ញុំបណ្តែតក្បូននោះទៅតាមទឹកទៅ, ឥឡូវនេះដោយសារបុណ្យព្រៃឆអស្ចារ្យនេះគាត់រស់ឡើងវិញ ខ្ញុំសូមប្រកាសថាគាត់ជាប្តីខ្ញុំទេ" ។

ដោយសារនាងនិយាយយ៉ាងច្បាស់លាស់យ៉ាងនេះ បណ្តាជនដែលចាំស្តាប់នោះក៏ចូលចិត្តពាល់គ្នា ។ ប៉ុន្តែស្រីពីរនាក់ទៀតមិនចង់និយាយឲ្យវែងឆ្ងាយឡើយ ។ ការចោទប្រកែកគ្នានេះក៏ផុតរលត់ត្រឹមនោះទៅ ។ ឯព្រះមហាក្សត្រមិនព្រមកាត់សេចក្តីនេះ ព្រោះព្រះអង្គសព្វព្រះទ័យលើព្រះពោធិបុត្រតែពេក ព្រះអង្គទ្រាបស្តេចនឹងសេចក្តីយុត្តិធម៌ ក៏ទ្រង់ត្រាស់បង្គាប់ឲ្យស្រីទាំងបីអង្គាទៅទូលដល់ព្រះនាងទត្តិយានីធូដាម្ប៉ាសារី (Thoudamna sari) ដែលមានប្រាជ្ញាឈ្លាសវៃជាខ្លាំងនោះ ។

គ្រាន់តែឮឈ្មោះមួយនេះ ការខាស់ខែងក៏ជាត់ស្ងាត់ទៅ ។ គឺថា ស្រីទាំង ៣ នាក់ព្រមព្រៀងតាមព្រះរាជតម្រាស់ ហើយនាំគ្នាត្រសង់ទៅកាន់ប្រាសាទមួយដែលសង់នៅជិតទីក្រែងនោះ ។

ឯព្រះនាងខត្តិយានីក៏តាំងសាកសួរឿងនេះ តាំងពីដើមដល់ចុងគ្មានចន្លោះកន្លែងណាមួយឡើយ ។

នាងប្រពន្ធដើមលុះនិយាយអំពីរឿងក្បួន រួចថា "បើប្តីខ្ញុំមិនស្លាប់យ៉ាងនេះឲ្យខ្ញុំចោលគាត់ម្តេចបាន" ។

ឯព្រះរាជបុត្រីនៃស្តេច ដែលមានព្រះនេត្រថ្លាយង់ក៏តាំងមានព្រះបន្ទូលហូរដូចទឹកថា "ដោយសារសិល្បសាស្ត្រគួរណា មួយខ្ញុំមិនស្គាល់ឈ្មោះ ឯបុរសនេះកាលពីមុនក្លាយខ្លួនជាសត្វស្វាប ។ ពួកព្រានព្រៃក៏បានចាប់សត្វនោះយកមកថ្វាយព្រះបិតាខ្ញុំ ។ មានតែសេចក្តីស្លាប់ទេដែលធើចំគាត់ ។ ខ្ញុំបានជួយជីវិតគាត់ដោយបានយកគាត់មកចុកជិតខ្លួនជាប ។ ខ្ញុំបានដឹងការណ៍អាថ៌កំបាំងរបស់គាត់ រួចខ្ញុំស្រឡាញ់គាត់ទៅ ។ ខ្ញុំស្រឡាញ់នេះគឺស្រឡាញ់ណាស់គ្មានរបស់អ្វីប្រៀបបានឡើយ គាល់តែដល់ពេលដែលបិតាខ្ញុំបើកអង្គតរកចាប់ ។ គាត់តំយុខ្លាំងពេក គាត់រត់គាល់តែងាប់ខ្សែសិល្បក្លាយខ្លួនជាមនុស្សទៅ ។ ខ្ញុំមានចិត្តនឹកគាត់ស្ទើរស្លាប់ខ្លួន ។ ខ្ញុំក៏បាននិយាយត្រង់ប្រាប់ព្រះបិតាខ្ញុំ ។ ឯព្រះបិតាក៏ទ្រង់ប្រាសឲ្យគេរកគាល់តែឃើញគាត់មកវិញនេះ ហេតុដូច្នេះ គាត់គង់ជីវិត

នេះដោយសារខ្ញុំនៅស្ងៀម ។ ថ្ងៃនេះព្រះបិតាខ្ញុំទ្រង់លើកលែងទោសឲ្យគាត់ទាំងអស់ដោយសារខ្ញុំអង្វរព្រះអង្គពេក ។ ឯស្តេចក៏មានព្រះហឫទ័យសន្តោសចង់ឲ្យខ្ញុំនឹងគាត់ឃាន់គ្នាជាប្តីប្រពន្ធវែរ ។ ទ្រព្រះនាង! បើយ៉ាងនេះគាត់ត្រូវព្រាត់ប្រាសពីខ្ញុំវិញឬយ៉ាងណា?" ។

ចំណែកខាងកូនស្រីមហាសេដ្ឋី គ្រាន់តែនិយាយថា "លុះកាលណារត់ផុតពីកំងហើយ បុរសនេះមានគ្រោះថ្នាក់ដល់ស្លាប់ខ្លួន ព្រោះពួកកងក្រវែលដេញតាមជាប់ពីក្រោយ ។ គាត់កិតក័យតក់ស្លុតជាខ្លាំងណាស់ ហើយរត់ចូលមកក្នុងផ្ទះរបស់ខ្ញុំ ។ ឯឪពុកម្តាយរបស់ខ្ញុំក៏បានដួយយោងជីវិតដោយបានប្រើមធ្យោបាយមួយប្រភេទណាស់ រួចលោកបានរៀបការខ្ញុំឲ្យទៅបុរសនេះទៅ ។ ហេតុយ៉ាងនេះ គាត់ទឹងត្រឡប់ទៅជាមិនមែនប្តីរបស់ខ្ញុំវិញឬយ៉ាងណា?" ។

ព្រះនាងវត្តិយានីធូជាម្ចាស់ លុះគិតយូរបន្តិចទ្រង់មានព្រះបន្ទូលថា "ព្រះនាង! អស់ទាំងនាង! ចូរចាំស្តាប់សេចក្តីនេះ ខ្ញុំនឹងកាត់ឥឡូវនេះ" ។ រួចអ្នកទាំងអស់គ្នាក៏នៅក្បាលចាំស្តាប់ ។

ព្រះនាងថា "នាងកវិយាទី ๑ បានចងបុរសទៅលើក្បូន ហើយបានបណ្តែតចោលទៅតាមទឹក ។ ធ្វើយ៉ាងនេះក៏ដូចគ្នានឹងយកបុរសនោះទៅបូជាឬទៅកប់ក្នុងព្រៃធរណីដែរ ។ ប៉ុន្តែថ្ងៃនេះអស្ចារ្យណាស់ បុរសនេះរស់ឡើងវិញ ។ ឯនាងគ្មានបា្រប់អ្វីនឹងបានបុរសនេះវិញទេ ។

ឯចំណែកខាងបុត្រីរបស់ស្តេច បើសិនណាពួកគង្គែរំលែចាប់បាន, គ្មានទឹកភ្នែកឯណា គ្មានសេចក្តីមេត្តាឯណា គ្មានពាក្យអង្វរឯណា គ្មានមុខតាចិត្តឯណា អាចទប់ទឹកការពិរោធស្តេចបានឡើយ នាងមុខជាទានដួបនឹងបុរសនេះរហូតមិនខាន ។ អាស្រ័យហេតុនេះ នាងគ្មានច្បាប់ត្រូវបានបុរសនេះវិញឡើយ ។ ពីព្រោះបុរសនេះមុខតែពីស្លាប់ បើសិនណាមាតាបិតារបស់នាងដែលត្រូវជាប្រពន្ធគេសព្វថ្ងៃនេះ មិនបានដួយដោយបានប្រើតំរិះនឹងឧបាយទាំងប៉ុន្មាននោះ ។ បើដូច្នេះគឺរូបនាងក្រោយបង្អស់នេះទេ ដែលត្រូវបានបុរសនេះដោយពេញច្បាប់ ។ សូមឲ្យនាងបានសុខជាមួយគ្នាដល់ផុតជីវិតរៀងខ្លួនទៅហោង" ។

លុះព្រះនាងខត្តិយានីមានព្រះបន្ទូលរួចហើយ អ្នកទាំងអស់គ្នាទទួលសុខចិត្តរៀងខ្លួន ។

សុភានឹងសង្ឃរាទាំងឡាយ ! អ្នកគោងមើលរឿងនេះឲ្យជាក់ ។

(មានត)

លុះតែមានគុណធម៌ ២ ប្រការក្នុងចិត្ត :

១ - សេចក្តីស្នេហាចំពោះមាតុភូមិ

២ - សេចក្តីព្យាយាមដោយមិនខ្ជិលច្រអូស

ទើបរក្សាស្វ័យរាជ្យបាន ។

យួរ - អ៊ុន

កណ្ដាទី ៣

អ្នកឧកញ៉ាបែុលរាជសេនា នូ - កង ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ទំងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

អង់អ៊ុនតបថា ខ្ញុំនអ្កជាសែលី តាំងតុ:ជាសែតាំង នឹងពប់ថាជាអាពុកកូន យ៉ាងម្តេច, បើតាំងតុ:ពប់អានអ្កជាកូនប្រាកដ ចុះកាលកាន់ខ្លួនដេញតាប់ នោះ តើនឹកថាជាកូនដែរឬទេ? ដែលអ្កនឹងខ្លាចគេនិន្ទានោះមិនគួរទេ ។ លីប៉ោ"បានស្តាប់ស្រាប់តែភ្ញាក់គំនិតគិតឃើញឡើង ទើបឆ្លើយតបថា សេចក្តីខ្មែនេះកុំបានតែលោកវិលឹកទាន់ ខ្ញុំគ្មានដីវ័នឹងគិតឃើញសោះ ។

អង់អ៊ុនគិតឃើញថា លីប៉ោ"ប្រាកដជាប្រែចិត្តចេញពីតាំងតុ:ពិតណាស់ ក៏ជាស់សតិលីប៉ោ"ថា សព្វថ្ងៃនេះតាំងតុ:ជាសត្រូវនឹងពួកសម្ព័ត្តិ អ្នកក៏ល្មមដឹងច្បាស់ប្រាកដក្នុងចិត្តហើយ, ដែលអ្នកបានមកនៅធ្វើពួកការ

ជាមួយនឹងតាំងតុ:នេះ ក៏មានសេចក្តីគាប់ប្រសើរជាច្រើនដង តើតាំងតុ: បានឲ្យបំណាច់រង្វាន់ឡើងយសស័ក្តិជានាហ្មឺនតំណែងអ្វីខ្លះដែរឬទេ? បើអ្នកតាំងចិត្តសុចរិតត្រង់នឹងព្រះមហាក្សត្រជាម្ចាស់ផែនដីវិញ សូម្បីអ្នកនឹងយកចិត្តទុកជាក់ជួយទំនុកបំរុងផែនដីតែម្តង គឺកំចាត់ពួកសត្រូវរាជ-ស្មម្បត្តិចេញបាន អ្នកនឹងឡើងទីជានាហ្មឺនធំមានកេរ្តិ៍ឈ្មោះខ្ចរខ្ចាយជាប់កង ព្រះរាជពង្សាវតារតទៅ ។

លីហ៊ោបានឮដូច្នោះ ក៏លុតជង្គង់គំនាប់អង្អ៊ុនហើយថា ខ្ញុំបាទនឹងសូមយកអាសាផែនដីសង សឹកសម្ងាប់អាតាំងតុ:ចេញឲ្យបាន លោកកុំមានសេចក្តីសង្ស័យនឹងខ្ញុំបាទឡើយ ។ អង្អ៊ុនតបថា អ្នកគិតទំនុកបំរុងដល់ផែនដីដូច្នេះ ក៏ជាការគាប់ប្រសើរហើយ តែក្រែងអ្នកនឹងខ្ញុំគិតរួមគំនិតគ្នាទៅមិនបានយូរ បែរជានាំគ្នាស្លាប់ចោលបង្រ្គែតទៅវិញទេដឹង ! ។ លីហ៊ោឮភ្លាយកគ្រឿងមកចាក់កដៃ, សម្រែកលោហិតជាក់ក្នុងពែងស្រាហើយស្បថសច្ចាន់ថា "បើខ្ញុំមិនបានសម្ងាប់តាំងតុ:ចេញដូចពាក្យថានេះទេ សូមឲ្យទេវតាបណ្តាលឲ្យអាវុធផ្សែង។ ប្រហារខ្លួនខ្ញុំបាទឲ្យវិនាសចុះ" ហើយលើកពែងស្រានោះធឹកអស់ទៅ ។ អង្អ៊ុនឃើញដូច្នោះក៏ក្រោកឡើងគំនាប់លីហ៊ោហើយថា ពេលនេះព្រះមហាក្សត្រនឹងអាណាប្រជានុ-រាស្ត្របានសេចក្តីសុខក្សេមក្សាន្តព្រោះសតិប្បញ្ញារបស់អ្នក បើអ្នកនឹងចាប់ផ្តើមធ្វើការនេះវេលាណាខ្ញុំនឹងពន្យល់ឲ្យដឹង ។ លីហ៊ោក៏លាអង្អ៊ុនត្រឡប់ទៅផ្ទះវិញ ។

ចំណែកអង្គអ៊ុនបង្គាប់ឲ្យហៅស៊ុនស៊ុយនឹងអ៊ុយអ៊ួនដែលជាទីប្រឹក្សាមកជុំប់ហេតុ ដែលបានគិតនឹងលើប៉ោឲ្យសម្លាប់តាំងតុ: ។ អ៊ុយអ៊ួនជំពប់ថា ព្រះចៅហៀនតេទ្រង់ព្រះឈ្មួនខ្លោះ តាំងតុ:ក៏បានដឹងច្បាស់ដែរ តែឥឡូវព្រះអាពាធធូរស្រាលបាន ២ ថ្ងៃហើយ តាំងតុ:មិនទាន់បានដឹងដំណឹងនេះទេ បើដូច្នេះសូមលោកវេកអ្នកមានសតិប្បញ្ញាទៅអញ្ជើញតាំងតុ:ថា "មានព្រះរាជឧង្ការឲ្យហៅទៅគាល់នឹងបានប្រឹក្សារាជការជាធំ", ហើយឲ្យតែងសំបុត្រសម្លាត់ទៅឲ្យលីប៉ោ ជាសេចក្តីព្រះតម្រាស់ ឲ្យលីប៉ោលើកភាហានទៅបង្កប់នៅទីស្តេចចេញ បើតាំងតុ:ចូលមក ឲ្យមានសញ្ញាគ្នា ទើបការដែលគិតនោះនឹងធ្វើបានដោយស្រួល ។ ស៊ុនស៊ុយធ្វើយថា ដែលគិតដូច្នេះក៏ត្រូវហើយ តែនឹងកេនណាជាបំរើកាន់សំបុត្រព្រះតម្រាស់ចេញទៅដល់តាំងតុ:នោះ? ។ អ៊ុយអ៊ួនតបថា លើសុកធ្វើរាជការមានសេចក្តីគាប់ប្រសើរស្រួល តាំងតុ:មិនបានពិតទូលឲ្យឡើងយសស័ក្តិឡើយ លើសុកក៏មានសេចក្តីទោមនស្សតូចចិត្តពន់ពេកបើឲ្យលីសុកកាន់ព្រះត្រាម្រាស់ទៅឲ្យ ប្រហែលតាំងតុ:មិនមានសេចក្តីសង្ស័យ ។ អង្គអ៊ុនក៏យល់ព្រមតាមពាក្យលីសុក ហើយឲ្យហៅលីប៉ោទៅជួប ហើយប្រាប់សេចក្តីដែលប្រឹក្សាគ្នានោះឲ្យស្តាប់គ្រប់ប្រការ ។ លីប៉ោយល់ព្រមហើយនិយាយថា លីសុកនោះបានទៅនិយាយល្បួងបញ្ចុះបញ្ចូលខ្ញុំបានកាលដែលនៅធ្វើការជាមួយគ្នានឹងតេងដួន បើលីសុក

មិនត្រមៅ ហើយបែកការដែលយើងគិតនេះទៅថ្ងៃមុខ ខ្ញុំនឹងធានាសម្ងាប់លីសុកចេញ ។ អង់អ៊ុនទឹងលីចោ"បង្គាប់ឲ្យទៅហៅលីសុកមកជួប ហើយលីចោ"និយាយថា កាលដែលខ្ញុំនៅទឹងតេងង្ហួននោះ អ្នកបានទៅ-ល្បងបញ្ចុះបញ្ចូលខ្ញុំ។ សម្ងាប់តេងង្ហួនយកក្បាលមកឲ្យតាំងតុ: ឥឡូវនេះខ្ញុំឃើញតាំងតុ:ធ្វើការអាក្រែកក្បាថផែនដី ទើបត្រមត្រៀងគ្នាគិតរំលងតាំងតុ:ចេញវេលានេះ យើងត្រូវការប្រើអ្នកឲ្យកាន់ព្រះតម្រាស់ទៅហៅតាំងតុ:ឲ្យចូលមកគាល់ ហើយយើងនឹងសម្ងាប់តាំងតុ:ចេញ តើអ្នកនឹងត្រមៅឬមិនទៅ? ។

លីសុកបានស្តាប់ហើយធ្វើយតបថា សព្វថ្ងៃនេះខ្ញុំគិតរកឧបាយនឹងសម្ងាប់តាំងតុ:ជាជាងប តែថាខ្ញុំនៅអាម្តែព្រោះអ្នកជារូប ១ ចិត្ត ១ នឹងតាំងតុ: ទើបគិតធ្វើការនោះមិនបានសម្រេច ឥឡូវបើអ្នកប្រាកដជាប្រើខ្ញុំទៅហៅតាំងតុ:ឲ្យចូលមកគាល់ដោយឧបាយមែន ខ្ញុំមានសេចក្តីពេញចិត្តណាស់ សុំទទួលយកអាសាទៅហៅតាំងតុ:ឲ្យចូលមកបាន ។ ពេលនោះលីសុកយកព្រួញធ្នូមកកាច់ជា ២ កំណាត់ ហើយស្បថសច្ចាន់តម្រង់ខ្លួនថា បើខ្ញុំមិនបានធ្វើតាមពាក្យប្តេជ្ញានេះទេ នឹងត្រូវប់នាំសេចក្តីនេះទៅបំបែកឲ្យតាំងតុ:ដឹងការណ៍វិញនោះ សូមឲ្យខ្លួនខ្ញុំដាច់ទៅជា ២ កំណាត់ដូចព្រួញដែលកាច់នេះចុះ ។ អង់អ៊ុនបានស្តាប់លីសុកនិយាយដូច្នោះក៏អស់សេចក្តីសង្ស័យ ហើយបែរជាមានសេចក្តីត្រេកអរជាពន្លឹក ទើប-

ក្រែកឡើងគំនាប់លើសុកហើយថា ៖ អ្នកតាំងចិត្តសុចរិតត្រង់ទឹងផែនដី
ដូច្នេះ បើសម្រេចសេចក្តីប្ដូរកាលណា អ្នកនឹងបានជានាហ្មឺនធំតទៅ ។

លុះដល់ព្រឹកឡើង អង្គអ៊ុនតែងសំបុត្រព្រះតម្រាស់ ហើយឲ្យកេណ្ឌ
ពាហានស្មេះ ๒๐ ប្រគល់ឲ្យលើសុក។ ក៏ចេញទៅដល់ទីក្រុងថ្មី, ពាហាន
ម្នាក់នាំយកសេចក្តីជំរាបតាំងតុ:។ បានដឹងចេញមកទទួលព្រះតម្រាស់
ហើយនាំលើសុកចូលទៅក្នុងក្រុងថ្មី ។ លើសុកជំរាបតាំងតុ:ថា ឥឡូវ
នេះព្រះចៅហៀនតេទង់ព្រះឈ្មួនជាទម្ងន់ នឹងរកអ្នកឯណានិយាយការ
ពាជការគ្មាន នាហ្មឺនតាំងពួងប្រឹក្សាគ្នាយល់ព្រមឲ្យមកអញ្ជើញមហា-
ឧបពាជចូលទៅនឹងប្រគល់ដួងពាជសម្បត្តិ ។ តាំងតុ:សួរលើសុកថា ដែល
នាហ្មឺនតាំងពួងប្រឹក្សាគ្នាដូច្នេះ អ្នកបានឮអង្គអ៊ុននិយាយដូចម្តេចខ្លះ ។
លើសុកទូលថា ដែលនឹងប្រគល់ពាជការនៅពាជសម្បត្តិដួងដល់លោក
នេះ អង្គអ៊ុនជាដើមគំនិតស្មើនឹងមន្ត្រីតាំងពួង។ ក៏យល់ព្រម ឥឡូវនេះ
អង្គអ៊ុនចាត់ចែងត្រាសម្រាប់ពាជ្យទុកដួងលោកជាស្រេចហើយ ។ តាំងតុ:
បានស្តាប់ដូច្នេះ ក៏មានចិត្តសោមនស្សហើយប្រាប់លើសុកថា កាល
ពីយប់មិញយើងមានសុបិននិមិត្តឃើញថា មានសត្វមក ๑ មករុំព័ទ្ធជុំ
វិញខ្លួនយើង ដល់ព្រឹកឡើងស្រាប់តែមានដំណឹងនេះមកដល់យើង
បើដូច្នេះចាំយើងនឹងទៅស្រុកក្រុង ដែលអ្នកបានកាន់ព្រះតម្រាស់មកនេះ
យើងក៏មានសេចក្តីត្រេកអរណាស់ហើយ បើបានពាជសម្បត្តិពិតប្រាកដ

មែន យើងនឹងតាំងអ្នកឲ្យធ្វើជានាហ្មឺនធំ គឺទីអគ្គមហាសេនា ។ លំសុក ធ្វើហាក់ដូចជាទទួលប្រសាសន៍តាំងតុ:ជាប្រាកដណាស់ ទើបបង្គាប់ឲ្យលីឈុយ គុយគី តៀវចេ នឹងហួនតៀវ កេណ្ឌកងសេនាទាហានបាន ៣ ពាន់ឲ្យទៅរក្សាក្រុងថ្មី ។ ឯតាំងតុ:ចូលទៅគេមាតាហើយជំរាបថា ឥឡូវនេះខ្ញុំនឹងទៅទទួលរាជសម្បត្តិហើយ អ្នកម្តាយមុខជានឹងបានជាហង់ថៃហ គឺជាសម្តេចព្រះវររាជជននី ។ មាតាតបថា ខ្លួនម្តាយក៏ចាស់ជរាអាយុជាង ៤០ ឆ្នាំយហើយ ម្តាយបានពឹងបុណ្យកូនក៏ល្មមបានសេចក្តីសុខប៉ុណ្ណេះហើយ ពេលនេះមាកាមានសេចក្តីពិការលំក្នុងចិត្តណាស់ ព្រោះចេះតែកម្រើកញ័រខ្លួនទាំងសព៌ាង្គកាយ ហើយក្នុងចិត្តក៏ចេះតែភ្ញាក់តក់ស្លុតមកជាច្រើនវេលាហើយ បើកូននឹងចូលទៅក្រុងនោះ ត្រូវគិតប្រយ័ត្នរក៏ងខ្លួនឲ្យល្អកុំធ្វេសប្រហែស ។

តាំងតុ:តបថា "ដែលអ្នកម្តាយមានអាកេរក្នុងខ្លួននោះ ព្រោះបុណ្យកូននឹងដល់ហើយ បានជាបណ្តាលឲ្យកើតមានអាកេរដូច្នេះ" ហើយលាមាតាចូលទៅរកនាងតៀវសៀន ហើយនិយាយដំណាលសេចក្តីទាំងនោះឲ្យនាងស្តាប់ថា បើយើងបានគ្រងរាជសម្បត្តិវេលាណា យើងនឹងលើកនាងឲ្យធ្វើជាអគ្គមហេសីទាំងឆ្នូង ។ នាងតៀវសៀនបានស្តាប់ក៏គិតឃើញថា ប្រហែលជានាហ្មឺនទាំងពួងឲ្យមកនិយាយដូច្នេះ ប្រាថ្នានឹងសម្លាប់តាំងតុ:ជាប្រាកដ ។ នាងតៀវសៀនគំនាប់ហើយធ្វើជាអរពេរពាយ ។

តាំងតុ:ឲ្យរៀបចាត់ចែងសេនាគហាន ហើយឡើងជិះរថលើកក្បួនហែចេញទៅតាមផ្លូវប្រមាណបាន ៣០ សិន ក្លែរថដែលតាំងតុ:ជិះនោះបាក់ជាច់ជា ២ ចំណែក, តាំងតុ:ឡើងជិះសេះតទៅទៀតបានប្រមាណ ១០០-សិន ស្រាប់តែសេះផ្ដើលជាច់បង្ហើរអំពីដៃ ។ តាំងតុ:ងាកមកសួរលីសុកថា ដែលបាក់ក្លែរថនឹងសេះផ្ដើលជាច់បង្ហើរដូច្នេះ អ្នកយល់ឃើញថាល្អឬអាក្រក់ប្រការម្ដេច? ។ លីសុកជំរាបថា ដែលកើតហេតុទាំងពីរនេះ ជាបុព្វហេតុត្រមុះមហាឧបភដនឹងបានត្រង់ភជសម្បត្តិ ហើយនឹងបានទ្រង់រថប្រដាប់ដោយគ្រឿងចម្ការចនា ព្រមទាំងសេះព្រះទីនាំង ។ តាំងតុ:បានស្ដាប់ក៏ជឿជាក់ក្នុងចិត្ត ព្រោះមិនបានដឹងកលឧបាយដោយប្រការផ្សេង ។ លុះទៅដល់ទ្វារក្រុង បណ្ដានាហ៊ឺនតូច-ធំចេញទៅគំនាប់ទទួលតាំងតុ:ឈ្បះធេរ ។ ឯលីយូមានជម្ងឺឈឺមិនសប្បាយមិនបានចេញទៅទទួល ។ តាំងតុ:ក៏ចូលទៅកន្លែងលំនៅរបស់ខ្លួន; ពេលនោះលីចោ"ក៏ឈរគំនាប់តាំងតុ:។ និយាយថា បើយើងបានភជសម្បត្តិ យើងនឹងតាំងអ្នកឲ្យធ្វើជាធំត្រួតសេនាគហានទាំងអស់ ។ លីចោ"ធ្វើជាត្រេកអរទទួលពាក្យតាំងតុ: ហើយលាចេញមកវិញ ។

លុះដល់ពេលយប់កន្លងទៅមិនសូវ ពួកកូនក្មេងអ្នកស្រុក ៣០ នាក់ បបួលគ្នាទៅលេងមុខផ្ទះតាំងតុ: ហើយច្រៀងពាយទំនុកថា «ស្មៅតាំងអស់មានស្លឹកទៀវស្រស់ ដុះលេចឡើងមិនបានយូរប៉ុន្មាន ៥ ឬ ១០ ថ្ងៃ

កំនឹងស្លាប់" ។ តាំងតុ:ឃានឮសំឡេងក្មេងច្រៀងដូចគេយំ កំសម្លឹងមើល ស្គាប់ ទឹកមុខកក្នុងចិត្តណាស់ ទើបឲ្យហៅលីសុកទៅសួរថា ដែលក្មេងច្រៀងឮសំឡេងរហឹងដូចយំនេះតើ អ្នកនឹងយល់ឃើញប្រការម្តេច? ។ លីសុកតបថា សំឡេងក្មេងដូច្នេះជាបុព្វនិមិត្តរបស់លោកធំវិសេសណាស់ ព្រោះសេចក្តីនឹងសាបសូន្យហើយសេតាំងនឹងរុងរឿងតទៅ ។ តាំងតុ: កំមានសេចក្តីត្រេកអរណាស់ លុះដល់ព្រឹកឡើងក៏តែងខ្លួនពេញយស ហើយឡើងរថនឹងចូលទៅក្នុងព្រះរាជវាំង ។

លុះទៅដល់កណ្តាលផ្លូវ ទទួលជួបនឹងគូយិន ។ នោះពាក់អាវខៀវ មួកស ដៃកាន់ឈើច្រត់ ហើយយកសំពត់ស្តើងប្រវែង ៨ ហត្ថបង់ធ្វើទង់ មានអក្សរនៅដើមទង់ ១ តួថា "ទៅ" ចុងទង់ ១ តួថា "ទៅ" គាំង ២ តួនោះផ្សំគ្នាហៅថា "លី" ប្រែថា "សេលី" ។ សំពត់សនោះគាសាចិនហៅថា "ចៅ" ។ ប្រស្នាដែលគូយិនធ្វើនេះបានសេចក្តីថា លីចៅ" នឹងសម្លាប់តាំងតុ: ។ ឯតាំងតុ:មិនយល់សេចក្តីកងប្រស្នានោះ កំមានសេចក្តីសង្ស័យទើបសួរលីសុកថា ដែលគូយិនធ្វើដូច្នេះ តើអ្នកណានឹងយល់ឃើញដូចម្តេច? ។ លីសុកដឹងច្បាស់ក្នុងប្រស្នាតែភ្លេងច្រៀងថា:ថា: 'គូយិនធ្វើដូច្នេះព្រោះខ្លួចចរិតទេ នឹងកាន់យកថាល្អឬអាក្រក់នោះមិនបាន" ហើយលីសុកក៏ប្រែតាមានបណ្តេញគូយិនចេញឆ្ងាយពីផ្លូវ ។ លុះតាំងតុ:ចូលទៅដល់ទ្វារវាំង, លីសុកប្រែៗថាយ ឲ្យតាំងតុ:ឃាត់

តាហានមុកខាងក្រៅ, ហើយលីសុកនាំវេតាំងតុ:ចូលទៅកន្លែងកំចាំងពីទីគាល់ ។ តាំងតុ:ក្រេកឃើញនាហ្នឹនកាន់គ្រប់ឈរដៀបគ្នា ក៏មានសេចក្តីភ័យជាមួក ហើយសួរលីសុកថា ហេតុដូចម្តេចបានជាពួកនាហ្នឹនឈរកាន់គ្រប់ដូច្នេះ? ។ លីសុកមិនបានតបសោះ បង្ខំឲ្យបរវេចូលទៅក្នុងទីព្រះរាជវាំងរម្យ ។

អង្គអ៊ុនឃើញដូច្នោះ ក៏ស្រែកប្រកាសថា សត្រូវរាជសម្បត្តិមកដល់ហើយ ចុះតាហានយើងហេតុម្តេចក៏មិនពិឃាដបង់ទៅ? ។ ឯតាហានដែលបង្គប់ទៅទីនោះ ក៏សុះស្រេចញ្ចេមកយកខ្លួនចាក់តាំងតុ:។ ក៏ក្រាបទៅក្នុងវេ ហើយស្រែកហៅលីចោ៉ឲ្យជួយ ។ លីចោ៉សុះចេញមកហើយស្រែកថា ខ្លួនជាសត្រូវរាជសម្បត្តិ ហេតុម្តេចស្រែកឲ្យយើងជួយ" ថាហើយក៏យកខ្លួនចាក់ត្រូវត្រង់កតាំងតុ:ផ្អាក់ពីលើវេស្ងាប់ ។ លីសុកក៏កាត់ក្បាលតាំងតុ:ហើយស្រែកប្រកាសថា អាសត្រូវរាជសម្បត្តិស្ងាប់ហើយ ។ បណ្តានាហ្នឹនតូច ធំតាំងអស់ដល់បានឃើញដូច្នោះ ក៏មានចិត្តត្រេកអរគ្រប់គ្នា ។ លីចោ៉ស្រែកថា ដែលតាំងតុ:ធ្វើការអាក្រក់ដូច្នេះព្រោះស្តាប់ពាក្យលីយូ នរណានឹងអាចយកអាសាទៅចាប់លីយូឲ្យយើងបាន ។ លីសុកធ្វើយទទួលយកអាសា ហើយក៏នាំតាហានទៅព័ទ្ធចាប់លីយូនឹងពួកបក្សប្រជាប្អូនមកតាំងអស់ ។ អង្គអ៊ុនបង្គាប់ឲ្យនាំបុត្រកុរិយានឹងបក្សពួកត្រមតាំងខ្លួនលីយូទៅសម្លាប់គ្មានសល់ ។ សម័យនោះ

អាណាប្រជានុរាស្ត្រតាំងពួនក្នុងទីក្រុង ដែលមានចិត្តស្អប់តាំងតុ:បបួលគ្នាទៅដេរប្រទេចខ្មោច ហើយយកដៃចង្អុលត្បាកក្បាលខ្លះ យកដើងជាក់ចិញ្ចៀះ ទាល់តែសពនោះខ្លួចខ្លីពុះពោរទៅ ។ អង់អ៊ុនបានឲ្យនាំសពនោះទៅចោះចោលក្រៅព្រំខែត្រ ដោតក្បាលផ្ចាលទុកត្រង់ផ្លូវបែកឲ្យមានមនុស្សនៅចាំរក្សា ។ ឯអ្នកចាំនោះរះពន្ធុះយកសាច់សពតាំងតុ:ចេញ ហើយជាក់ប្រឆេះប្រឆេងក្នុងលលាដ៍ក្បាល យកក្លើងអុជជូសតាងចង្កៀងរៀងរាល់ថ្ងៃតទៅ ។

ចំណែកអង់អ៊ុនឲ្យលីហ្គោ" លីសុក ទឹងហង់ហ្គូគោ តាំង ៣ នាយ នេះលើកទាហាន ៥ ម៉ឺន ទៅសម្លាប់ប័ក្សពួកតាំងតុ:ឯស្រុកក្រុងថ្មីតាំងប្រុស តាំងស្រីអស់គ្មានសល់ ហើយរឹបយកទ្រព្យរបស់នាំមកជាក់ឃ្លាំងៗ ឯលីឈុយ គុយគី ទៀវចេនឹងហួនតៀវ ដែលតាំងតុ:ឲ្យនៅរក្សាស្រុកក្រុងថ្មី កាលដឹងសេចក្តីដូច្នោះហើយ ក៏នាំទាហាន ៣ ពាន់តេទៅនៅស្រុកសៀងសៃ ។

កាលលីហ្គោ" លីសុក ហង់ហ្គូគោ សម្លាប់ប័ក្សពួកតាំងតុ:នឹងមាតាសាច់ញាតិអស់ហើយ លីហ្គោ"ក៏ចូលទៅយកនាងតៀវសៀនមកទុកនឹងខ្លួន ។ ឯពួកស្រី ៨០០ នាក់ក៏បាត់ឲ្យមាតាបិតានាំយកខ្លួនតាំងអស់ទៅវិញ ។ បណ្តាទ្រព្យរបស់តាំងប៉ុន្មានក៏ឲ្យទាហានជញ្ជូនជាក់រះនាំទៅឲ្យអង់អ៊ុនក្នុងទីក្រុង ។ អង់អ៊ុនក៏យករបស់តាំងនោះចែករំលែក


ឲ្យ ឪ ហាន ចាំ ធ្លឹ តាម សម គួរ ហើយ ប្រជុំ អស់ នា ហ្នឹ ន មុ ខ ម ន្ត្រី ភូ ច ចំ ប្រឹក្សា ថា "ឥ ឡូ វ នេះ សត្រូ វ ពាជ សម្បត្តិ ស្ងាប់ ចាត់ អស់ ហើយ ផែ ន ដី ក៏ ចាន សេច ក្តី សុ ខ ក្សេម ក្សាន្ត យើ ង ត្រូ វ បបួ ល គ្នា លេង ឲ្យ ស ប្បាយ ចុះ" ថា ហើយ ចាត់ ចែ ង រៀ ប លៀ ង គោ ជ នា ហា រ នា ហ្នឹ ន ចាំ ធ្លឹ ត ។

ពេ ល នោះ មាន បំ រើ ម ក ប្រាប់ អង្គ អ៊ុ ន ថា មាន នា ហ្នឹ ន ម្នាក់ ឈ្មោះ សួ យ៉ុ ង មក អង្គុ យ យំ ស្រែ ណោះ ខ្មោ ច តាំ ង តុ: ។ អង្គ អ៊ុ ន ខឹ ង ណា ស់ ឲ្យ ឪ ហាន ទៅ ចាប់ យក ខ្លួ ន មក សួ រ ពិ ចា រ ណា ថា ហេ តុ អ្វី ខ្លួ ន ជា នា ហ្នឹ ន ក្នុ ង ពាជ ការ មក សោ កា អា ឡោះ អា ល័ យ តាំ ង តុ: ក្រែ ង ខ្លួ ន ចូ ល គំ និ ត នឹ ង តាំ ង តុ: ជា ស ត្រូ វ ពាជ សម្បត្តិ ឬ? ។ សួ យ៉ុ ង គំ នាប់ ហើ យ ឆ្លើ យ ថា ខ្ញុំ ចា ន នឹ ង ចាន ចូ ល គំ និ ត ដោ យ គិ ត ខុ ស ដូ ច្នោ ះ ក៏ ទេ តែ ចាន ជា ម ក យំ សោ ក ស្រែ ណោ ះ នោ ះ ពី ព្រោ ះ នឹ ក រលឹ ក ដល់ គុ ណ តាំ ង តុ: ដែ ល ចាន យក ខ្លួ ន ខ្ញុំ ចា ន មក ធ្វើ ជា នា-ហ្នឹ ន ក្នុ ង ពាជ ការ ទោ ស ខ្ញុំ ប៉ុ ន្តែ ខុ ស ត្រង់ នេះ សូ ម ដឹ ង តែ ឲ្យ ស ន់ នឹ ង ចាន ជួ យ ធ្វើ ពាជ ការ រក្សា ផែ ន ដី តែ ៗ ។ នា ហ្នឹ ន ចាំ ធ្លឹ ត ដែ ល ចាន ស្គាល់ ជា សួ យ៉ុ ង ទៀ ង ត្រង់ សុ ច រិ ត កំ ប ប្លួ ល គ្នា សុំ ទោ ស ចាំ ធ្លឹ ត អស់ ។ មា ឃិ ត នុ ន ខ្យឹ ប អង្គ អ៊ុ ន ថា សួ យ៉ុ ង នេះ ជា ម នុ ស្ស សុ ច រិ ត ពិ ត ត្រង់ ណា ស់ តំ រេ ះ ប្រាប់ ក៏ មាន ។ ម នុ ស្ស ប្រ ច់ អាន ស្រ ឡាញ់ ក៏ ច្រើ ន ទោ ស ដែ ល ល្មើ ស នោ ះ បើ នឹ ង សម្ងាប់ ចេ ញ ក៏ គួ រ តែ ថា ក្រែ ង ប ណ្តា ព ស្តេ ច នឹ ង មាន ពា ក្យ គ ហា និ ន្ទ ។ អង្គ អ៊ុ ន ត ប ថា ស្រុ ក ទេ ស កើ ត ច ឡា ច ល ទើ ប នឹ ង សូ ប់ ព ច ព ក្នុ ង ថ្ងៃ នេះ ព្រះ ច

ហៀនតេក៏នៅទ្រង់ព្រះកុមារណាស់ ទោះបីសួយ៉ុងជាមនុស្សមានសតិ-ប្បញ្ញាក៏ពិត តែខ្ញុំមិនត្រូវការនឹងយកឲ្យធ្វើជានាហ្មឺនទីប្រឹក្សាយើងបានទេ ដោយហេតុថា បើយើងនឹងបណ្តាយឲ្យមនុស្សធ្វើល្មើសនឹងព្រះរាជ-សម្បត្តិហើយចេះតែលើកទោសទៅនោះ ច្បាប់សម្រាប់ផែនដីនឹងត្រឡប់ត្រឡិនខូចទៅ ។ ម៉ាយិតបានឮដូច្នោះ ក៏ថយចេញទៅហើយនិយាយនឹងនាហ្មឺនទាំងពួងថា ធម្មតាផែនដីនីមួយៗបើមិនរកមនុស្សជាអ្នកមានសតិប្បញ្ញាទុកទេ ប្រទេសនោះក៏មិនបិតថេរចេរកាលតទៅទៀតបាន ។

គ្រានោះ អង្គអ៊ុនបង្គាប់ឲ្យចាប់យកខ្លួនសួយ៉ុងទៅដាក់គុក ហើយលះបង្គាប់ឲ្យនាយកូឃុំដាក់ច្រវាក់ខ្នោះឃ្លាំតែរួតត្រាតែស្ងាប់ ។ បណ្តានាហ្មឺនទាំងអស់ដែលបានដឹងថាសួយ៉ុងស្លាប់ហើយក៏មានសេចក្តីបរិទេវនាការគ្រប់គ្នា ។

(មានត)



ភាគទី ២

សម័យនគរធំ

អ្នកឧកញ៉ាទេពពិទូរ ឈឹម - គ្រសេម រៀបរៀង

(ត)

ព្រះអង្គមានព្រះអគ្គមហេសី ព្រះនាមដូចម្តេចមិនប្រាកដ, ប្រាកដតែថា ព្រះអង្គមានព្រះរាជធីតាច្បង ១ អង្គ ព្រះនាម "នរេន្ទ្រលក្ស្មី" មានព្រះរាជស្វាមីព្រះនាម "ក្សត្រិន្ទ្រាទិត្យ" ត្រូវជាព្រះអនុជនៃព្រះហិរណ្យវ័ន្ត ។ មានព្រះរាជឱរស ១ អង្គព្រះនាមព្រះមហេន្ទ្រាទិត្យ ។ មានព្រះរាជធីតាយ៉ាព្រះនាម "រាជបតិន្ទ្រលក្ស្មី" តែមិនបានដឹងច្បាស់ថា ជាធីតាក្សត្រិយ៍អង្គណាទេ ។

អានឋកថាថា: — ព្រះធរណេន្ទ្រវ័ន្ត ជាព្រះជេដ្ឋា គួរតែបានសោយរាជសម្បត្តិមុនព្រះបាទជយវ័ន្ត ដ៏ជាព្រះអនុជ, នេះហេតុម្តេចព្រះអនុជបានសោយរាជ្យមុនព្រះរៀមទៅវិញ ? ។ មានបរិហារថា: ការសោយរាជ្យរបស់ព្រះបាទជយវ័ន្តទី ៦ នោះ មិនបានប្រព្រឹត្តទៅតាមលំដាប់នៃច្បាប់រាជសន្តតិវង្សទេ គឺកាលពេលនោះ មានការណ៍បះបោរកើតឡើងនគរ, ព្រះបាទជយវ័ន្តទី ៦ ស្តេចចេញក្រមាបង្គាប់តែរាបចាបទៅវិញ, ដូច្នេះរាជសម្បត្តិទើបបានទៅព្រះអង្គដូចពោលមក, កាលទ្រង់សោយ

ទិវង្គតហើយ គ្មានព្រះរាជវរសេនីយ៍ទទួលរាជសម្បត្តិស្នង គេទើបអញ្ជើញព្រះជង្ហាធិរាជដែលជាព្រះរាជវង្សានុវង្ស ឲ្យទទួលគ្រងរាជសម្បត្តិតមក ។

ការផែនដី :- ព្រះបាទធរណេន្ទ្រវរ្ម័នទី ១ ទ្រង់ទទួលគ្រងរាជសម្បត្តិកន្លងវ័យជរាណាស់ទៅហើយ ។ តាមប្រកែតីអំពីដើមមក ទ្រង់មានកិរិយាសុភាពជាសប្បុរស សព្វព្រះរាជហឫទ័យនិងពន្លាក្យកាព្យ តែពាក្យកាព្យរបស់ព្រះអង្គតាំងប៉ុន្មាននោះ មិនបានប្រាកដមានទៅមកដល់វេលានេះទេ ។ មកក្នុងបច្ចុប្បន្នវ័យនេះព្រះរាជហឫទ័យរបស់ព្រះអង្គដេកដួលទៅតែកន្លងផ្លូវធម៌ ។ ការផែនដី ទ្រង់គ្រាន់តែថូរបុក មិនឲ្យលិចលង់ទៅហួសពេក, ការកសាងរបស់សំខាន់ៗ ដែលព្រះមហាក្សត្រិយ៍មុនៗធ្លាប់ធ្វើមក នឹងការគ្រប់គ្រងបំរុងទៅតាមបច្ចុប្បន្នរដ្ឋ ដូចយ៉ាងពួកថៃតាំងឥស្សរភាពនៅយោនកជៀងសែននោះ ទ្រង់មិនបានសំដែងស្នាព្រះហស្តទុកទេ ប្រាកដតែថា ទ្រង់បានបន្ទរបន្ទុយដំឡៃមុខពន្លាវក្នុងព្រះនគរឲ្យតិចចុះ ជាហេតុឲ្យធូរស្រួលដល់បណ្តាជនស្ត្រីអ្នកត្រូវបង់ពន្ធ ដោយអំណាចសេចក្តីសប្បុរសរបស់ព្រះអង្គ ។

ព្រះបាទធរណេន្ទ្រវរ្ម័នទី ១ ស្តេចស្ថិតនៅក្នុងរាជសម្បត្តិបានតែត្រឹម ៥ ឆ្នាំក៏ស្តេចសោយទិវង្គតទៅតាមយថាកម្ម, រាជបណ្ឌិតថ្វាយព្រះនាមព្រះបរមសពថា "ព្រះបាទបរមនិស្កលបទ" ។

ព្រះចាន្ទសូរ្យវរ្ម័ន ទី ២

ព.ស. ១៦៥៦ - ១៦៨៨, គ.ស. ១១១៣ - ១១៤៥ (១)

ព្រះមហាក្សត្រិយ៍អង្គនេះ ជាព្រះនរសិង្ហក្សត្រិន្ទ្រាទិត្យ (ដែលជាប់តំណាវង្សមកអំពីព្រះហិរណ្យវរ្ម័ន) នឹងព្រះនាងនរេន្ទ្រលក្ស្មី (ដ៏ជាព្រះពជធីតាព្រះបាទធរណេន្ទ្រវរ្ម័នទី ១), ទ្រង់មានព្រះរូបនោមល្អ ជាមជ្ឈិមបុរស. ព្រះបរមរូបរបស់ព្រះអង្គ គេបានសាងទុកនៅព្រះវិហារប្រាសាទនគរវត្តបែកខាងត្បូង នៅដល់សព្វថ្ងៃនេះ ។

ក្រោយដែលព្រះបាទធរណេន្ទ្រវរ្ម័នទី ១ សោយទិវង្គតហើយ ប្រទេសកម្ពុជាបែកជា ២ ដោយមានព្រះពជវង្ស ២ អង្គ ឬ ២ ពួក រាជដណ្តើមរាជសម្បត្តិគ្នា តែមិនប្រាកដព្រះនាមដូចម្តេច ។ ក្នុងនោះព្រះសូរ្យវរ្ម័នទ្រង់នៅក្នុងឋបមវ័យ (កំឡោះ) តែជាអ្នកមានព្រះប្រាជ្ញាតាំងវៃទ្រង់យល់ហេតុផលបានវែងឆ្ងាយ ទ្រង់ព្រះចិន្តាថា បើនឹងបណ្តោយឲ្យសង្គ្រាមកើតនៅក្នុងព្រះនគរដូច្នេះទៅ មិនយូរប៉ុន្មានទេមុខជានឹងមានប្រទេសដទៃ ដែលមានឥទ្ធិពលដូចយ៉ាងចាម្ប៉ាជាដើម លើកទ័ពមកសង្គ្រោះយកផ្ទួនទៀតជាមិនខាន ដូចដែលធ្លាប់ប្រាកដមានក្នុងប្រវត្តិសាស្ត្រមុនៗនេះមកហើយ ។ លំដាប់នោះ ព្រះអង្គក៏រួបរួមកងទ័ពមួយ

---

១ សាស្ត្រាចារ្យ ហ្សក សុដេស សរសេរថា ព្រះមហាក្សត្រិយ៍អង្គនេះ សោយរាជ្យពីក្នុងឆ្នាំ ១១១៣ ដល់ ១១៤១ រួមជា ៥១ ឆ្នាំ ។

ផ្នែកខ្វែតជាពួកទី ៣ នៅភ្នំមណ្ឌរៈ ហើយទ្រង់លើកទៅវាយក្បត្រិយ៍អ្នកបះបោរទាំង ២ ពួក ទាល់តែបរាជ័យរាបទៅ ទើបទ្រង់ឡើងគ្រងពិភពផែនដីតមក មានព្រះបរមនាមថា «សូរ្យវរ្ម័ន» ឬ «ស្រីសូរ្យវរ្ម័ន» រាប់ជាទី ២ ស្តេចគង់នៅក្រុងស្រីយសោធរបុរៈ ។ ព្រះអគ្គមហេសីប្រហែលជាទ្រង់មានដែរតាមរាជប្រពៃណី តែព្រះនាមដូចម្តេចមិនច្បាស់ក្នុងប្រវត្តិសាស្ត្រ ។ ឯព្រះរាជនុរសព្រះរាជធីតាប្រហែលជាគ្មានទេ ទើបមិនច្បាស់ពេលដែលព្រះអង្គសោយទិវង្គត ។

ការផែនដីៈ — ព្រះបាទសូរ្យវរ្ម័នក្រោយដែលទ្រង់បានឡើងគ្រងពិភពហើយក្នុងរវាង ៣ - ៤ ឆ្នាំនោះ ទ្រង់ក៏បានចាត់ការគ្រប់គ្រងផ្នែកមធ្យមរដ្ឋឲ្យបានរៀបរយតាមដើម នឹងទ្រង់ចាត់ការកសាងគ្រឿងអាវុធយុទ្ធភណ្ឌ នឹងបង្ហាត់សេនាឲ្យហានក្លាយ៉ាងច្រើនសម្រាប់ការពារប្រទេសកុំឲ្យមានការណ៍បះបោរដូចក្នុងរជ្ជកាលមុនៗ នេះទៀត ។

និយាយពីពួកសៀមដែលមានព្រះព្រហ្មរាជាប្រមុខនោះ មកក្នុងឆ្នាំ ព.ស. ១៦៦០ ប្រហែលជាគិតថា ព្រះបាទសូរ្យវរ្ម័នទី ២ ដែលទើបសោយរាជ្យថ្មី គង់ទន់ខ្សោយបែបយ៉ាងព្រះបាទធរណេន្ទ្រវរ្ម័នទី ១ ទើបរួបរួមទ័ពបានប្រហែល ៨០.០០០ នាក់ លើកចុះមកសង្កត់សង្កិនពួករាស្ត្រខ្មែរនៅតាមជាយព្រះរាជអាណាចក្រគាគខាងលិច ហើយលុកចូលមកដល់នគរកំពែងពេជ្រ ដែលមានមហាឧបរាជខ្មែរព្រះនាម

"ព្រះពមពជ" ឈរគ្រប់គ្រងទៅទីនោះ ដោយព្រះពមពជមិនដឹងខ្លួនជាមុន ។ កាលលើកទ័ពទៅដល់ដាយក្រុងកំពេងពេជ្រ ព្រះព្រហ្មពជ ក៏ចូលទៅជួបនឹងព្រះពមពជ ទទួលក្រឡេកទៅឃើញព្រះកែវមរកតនៅក្នុងព្រះវិហារក្នុងក្រុងនោះក៏ទូលសុំយកទៅ ព្រះពមពជទើសទាល់ ក៏លើកឲ្យទៅតាំងមិនស្មុគ ។ ព្រះព្រហ្មពជកាលបានព្រះកែវមរកតទៅហើយ ក៏គិតព្រួយបារម្ភក្រែងខ្មែរលើកទ័ពទៅដណ្តើមយកមកវិញ ទើបគិតធ្វើឧបាយក្រែឲ្យព្រះកែវមរកតបំបាត់ជានកុំឲ្យខ្មែរឃើញ គឺយកឋាយអមកបូកស្រោបព្រះកែវមរកត ឲ្យមើលឃើញហាក់ដូចជាព្រះពុទ្ធរូបធម្មតា ហើយយកទៅលាក់ទុកយ៉ាងគត់មត់ ។

រឿងសៀមតាំងឥស្សរភាពទៅក្នុងខែត្រចំណូននៃព្រះពជអាណាចក្រនោះ មិនបានផុតទៅអំពីព្រះការណ៍របស់ព្រះបាទសុរ្យវរ្ម័នទេ កាលទ្រង់ជាបហើយ ក៏គ្រាស់ឲ្យកងទ័ពលើកទៅកម្ចាប់ពួកសៀមនោះ ឲ្យត្រឡប់ទៅក្រោមម្លប់ព្រះបរមពោធិសម្ភារដូចដើមវិញ ។ សៀមគោងទៅក្រោមអាក្នាខ្មែរតមកទៀត ដរាបដល់សតវត្សទី ១៨ ទើបអាចតាំងឥស្សរភាពបាន ដូចជានឹងមានពោលក្នុងរយៈតទៅ ។

ឯព្រះកែវមរកតមិនបានត្រឡប់មកនគរវិញ ទៅគង់ជាប់ក្នុងស្រុកយោនកជៀងសែនតមក ។ ការដែលមិនបានត្រឡប់មកវិញ ប្រហែលជាដោយហេតុព្រះបាទសុរ្យវរ្ម័នទី ២ ទ្រង់និយមកចាប់អានលទ្ធិវៃស្ណវៈ ។

រឿងព្រះកែវមរកត ទើបមិនបានមកដំណាក់កងព្រះរាជហ្លួងយ៉ាងនេះ
ម្តុំ គួរឲ្យស្តាយ ។

ក្នុងឆ្នាំ ព.ស. ១៦៦០ ក្រោយដែលទ្រង់សោយរាជ្យបាន ៤ ឆ្នាំ
បានស្តេចតែងរាជទូត ឲ្យនាំរាជសារទៅសូមចងសម្ពន្ធមេត្រីភាពនឹង
ប្រទេសចិន ហើយនឹងប្រទេសចាម្ប៉ា ដើម្បីជាប្រយោជន៍កងផ្លូវរដ្ឋប-
សាសនោបាយ ។ ប្រទេសទាំងពីរនេះ ក៏ព្រមទទួលសម្ពន្ធមេត្រីភាពដង
ដោយរីករាយ ហើយតែងរាជទូតឲ្យនាំរាជសារមកតបវិញតាមសមគួរ ។
ប្រទេសកម្ពុជាបានចងសម្ពន្ធមេត្រីភាពនឹងប្រទេសចិន ពាក់ជាគ្រាទី ៧
ក្នុងរដ្ឋកាលនេះ ។

ចំណែកឯប្រទេសចាម្ប៉ា សូម្បីមានព្រំប្រទល់ជាប់គ្នានឹងប្រទេស
កម្ពុជាជាយ៉ាងវែង តែក៏មិនបានជាមិត្តជិតជិតគ្នាប៉ុន្មាន ច្រើនតែជាអរិ
នឹងគ្នាតាំងអំពីដើមមក ទើបតែនឹងមកប្រាកដក្នុងរដ្ឋកាលនេះថា បានចង
មេត្រីភាពនឹងគ្នា តែនេះក៏ដោយកុសលោបាយរបស់ព្រះបាទសូរ្យវរ្ម័ន
ដូចជានឹងមានប្រាកដទៅខាងក្រោយ ។

កាលចងសម្ពន្ធមេត្រីភាពហើយ ទ្រង់បានលើកទ័ពហ្លួង សឹង
មានសេនាដំរីជាយ៉ាងច្រើន ទៅវាយប្រទេសកៅដី (យួន) ដែលចេះតែ
រុករានទន្ទ្រានយកជាយព្រះរាជអាណាខេត្តខ្មែរ ម៉ែកខាងលើជាញឹក-
ញាយ ។ កាលកងទ័ពខ្មែរលើកទៅដល់ ទ័ពយួនក៏លើកចេញមកច្បាំងត

ទល់ តែទប់ឥទ្ធិពលកងទ័ពខ្មែរពុំបាន កងទ័ពខ្មែរបានវាយលុករហូតទៅ
ដល់ស្រុកដែ"អាន ទើបលើកទ័ពត្រឡប់មកព្រះនគរវិញ ។

កន្ទងមក ៤ ឆ្នាំ(១) ទ្រង់លើកទ័ពទៅវាយកៅដីម្តងទៀត ដោយហេតុ
កៅដីមិនព្រមចាល ។ សង្គ្រាមគ្រានេះទ្រង់វាយរហូតដល់ស្រុកតាន់ហួ
ទ្រង់ប្រកាសឲ្យស្រុកដែលវាយបានតាំងប៉ុន្មាន ជាចំណុះប្រទេសកម្ពុជា
ហើយស្តេចលើកទ័ពត្រឡប់មកព្រះនគរ ។

កន្លងវេលានោះ ដែនដីដែលជាប្រទេសលាវ ដូចយ"ងហ្នឹងព្រះបាង
នឹងវៀងច័ន្ទនំជាដើម ក៏ជាអាណាខ្មែរតែរបស់ខ្មែរដែរ ។

កាលស្រែចសង្គ្រាមកៅដីហើយ ព្រះបាទសូរ្យវ៉ង្សទ្រង់លើកទ័ព
ហ្នឹងទៅវាយប្រទេសចម្ប៉ា ជាការសងសឹកចាម្ប៉ា ដែលមានគំនិតខូច
បានលើកទ័ពដើងទឹកមកលុកក្រុងស្រីយសោធរបុរៈ កន្លងកាលចុងរដ្ឋកាល
ព្រះបាទហស៊ីវ៉ង្សទី ៣ ដែលក្នុងពេលនោះប្រទេសកម្ពុជាបានទទួលគ្រោះ
ថ្នាក់យ"ងធ្ងន់ ដោយត្រូវទឹកធំលិចយ"ងខ្លាំង ដូចមានពោលហើយ ។
កងទ័ពខ្មែរវាយលុកចូលដល់ក្រុងវិជ័យ ចាប់ព្រះកជាចាម្ប៉ា ទ្រង់ព្រះ
នាមស្រីជយឥន្ទ្រវ៉ង្សបាន ។ តែកងទីខ្លះថា ព្រះកជាអង្គនេះរត់ចោលព្រះ

---

១ ក្នុងប្រវត្តិសាស្ត្រសាកល (សៀម) ភាគ ៥ ថា ព្រះបាទសូរ្យវ៉ង្សទី ២ លើកទ័ពទៅវាយ
កៅដី ក្នុងឆ្នាំ ព.ស. ១៦៣១, ដល់មកឆ្នាំ ព. ស. ១៦៣៥ ទៅវាយម្តងទៀត ។ ដល់ឆ្នាំ
ព. ស. ១៦៤៨ ទៅវាយក្រុងវិជ័យ ។ តាមសាកលដីខែះឃើញថ្ងៃលទៅមុខពេក ។

នគរបាត់ទៅ ។ ព្រះបាទសូរ្យវរ្ម័ន កាលទ្រង់មានជ័យជំនះដូច្នេះហើយ, ទើបត្រាស់ប្រកាសរួមប្រទេសចម្ប៉ា" ចូលជាអាណាខែត្របស់កម្ពុជរដ្ឋ ទ្រង់តាំងព្រះរាជវង្ស ១ អង្គ ព្រះនាម "ហរិទេត" សឹងត្រូវជាព្រះអនុជនៃព្រះអគ្គមហេសីរបស់ព្រះអង្គ ឲ្យទៅគ្រប់គ្រងរដ្ឋចម្ប៉ា" ហើយស្តេចលើកទ័ពត្រឡប់ព្រះនគរ ។ ប្រទេសកម្ពុជាក្នុងរជ្ជកាលនេះ មានព្រំប្រទល់ដ៏ធំទូលាយយ៉ាងអស្ចារ្យម្តងទៀត ។ ឥស្សរជនរបស់ខ្មែរបានឡើងដល់កម្រិតខ្ពស់បំផុត ។

ផ្នែកគ្រប់គ្រង:- ព្រះបាទសូរ្យវរ្ម័នទី ២ ទ្រង់បានតាំងព្រះមហាឧបរាជឲ្យទៅគ្រប់គ្រងបច្ចន្តរដ្ឋ ដូចក្នុងរជ្ជកាលមុនៗ តែក្នុងរជ្ជកាលនេះ ព្រះមហាឧបរាជមានដល់ទៅ ៧ អង្គ គឺនៅស្រែធម្មនគរ ១ អង្គ, នៅកំពែងពេជ្រឬកោសម្ពី ១ អង្គ, នៅលវបុរៈ ឬស្រីអយុធ្យា ១ អង្គ, ហរិកុញ្ជ័យ ឬហៅហរិបុញ្ជ័យ ១ អង្គ, នៅនគរកុំ ភាគខាងលើ ១ អង្គ, នៅឃ្លាំងក្នុងដែនកូស័ងស៊ីន ក្នុងបច្ចុប្បន្ននេះ ១ អង្គ, នៅវិជ័យ ក្នុងចម្ប៉ារដ្ឋ ១ អង្គ ។

ផ្នែកកសាង:- កាលស្រែចព្រះរាជសង្គ្រាមហើយ ព្រះបាទសូរ្យវរ្ម័នទី ២ ទ្រង់ឲ្យសាងប្រាសាទវៃស្ណាន ១ ដ៏ហើយដោយសិលាសឹងមានទំហំធំមហិមា មានថ្នាក់ ៣ ថ្នាក់ នឹងមានលក្ខណៈល្អអស្ចារ្យនឹងរកប្រាសាទឯណាក្នុងលោកនេះ ដែលមានទំហំនឹងលំអស្មើដូចគ្មាន ឲ្យឈ្មោះថា "វិស្ណុលោក" ។

(មានត)

សាវតារវត្តកំពង់ចាចជាមុន

នៅឃុំពោធ៍ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

ព្រះវិនយធរគណៈ បៅអធិការវត្តនេះ រៀបរៀង

ឥឡូវនេះ

(រង្វាន់លេខ ៣)

លោកគ្រូបៅអធិការទី ៣ នេះ យកព្រះទ័យទុកដាក់ឲ្យវត្តអារាម ចំរើនណាស់ដែរ តែកិច្ចការរបស់លោកមិនទាន់សម្រេច លោកក៏ទទួលអនិច្ចធម្មទៅ ។

ដល់មកឆ្នាំចចត្វាស័ក ព. ស. ២៤៦៥ គ. ស. ១៩២៣ ក្នុងពេលព្រះករុណាស៊ីសុវត្ថិ លោកគ្រូព្រះនាម "អាម-លី" ព្រះជន្ម ២៤ ឆ្នាំ វស្សាគំរប់ ៤ ធ្វើជាបៅអធិការទី ៤ តមកទៀត, លោកគង់បាន ៧ វស្សា កន្លងឆ្នាំឆ្លូវ សប្តស័ក ១០ ពេចវែងល្អិត ព. ស ២៤៦៨ គ. ស. ១៩២៦ បានកសាងព្រះវិហារថ្មី ១ ធ្វើពីស៊ីម៉ង់ត៍ ប្រកបគ្រឿងឈើ ជាប់ហើយស្រេច ។ ដល់ឆ្នាំច្រកាញសំរឹទ្ធិស័ក ព. ស. ២៤៨០ គ. ស. ១៩៣៨ បានកសាងសាលាធំ ១ ខ្នង ធ្វើពីស៊ីម៉ង់ត៍មកដល់ឆ្នាំវកទើបហើយស្រេច ។ ដល់មកឆ្នាំចអដ្ឋស័ក ព. ស. ២៤៨៩ គ. ស. ១៩៤៧ ចាប់កសាងសាលាសំពាប់ប្រជុំជន ១ ខ្នង ដល់ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ គ. ស. ១៩៤៩ ទើបហើយស្រេច ។

តាំងពីព្រះជន្មគំរប់ ២៧ ឆ្នាំរៀងមក គ្រែពីកសាងវេបស់ធំៗ លោកកសាងកុដីតូចៗនឹងចេតិយនឹងសាលាបង្រៀនជាដើម ដម្កល់ទុកក្នុងវត្តដរាបដល់បច្ចុប្បន្ននេះ ។

ពិធីធ្វើមកសាងវត្តជាដំបូង

ដើមឡើយព្រឹទ្ធាចារ្យក្នុងស្រុកត្រូវស្វែងរកលោកអ្នកចេះដឹងតាំងឡាយ ទោះជាបព្វជិតក្តីគ្រហស្ថក្តី មកជួយពិចារណាមើលកន្លែង បើឃើញថាទីកន្លែងណាសមគួរហើយ ត្រូវធ្វើពាក្យសុំច្បាប់សុំអនុញ្ញាត អំពីព្រះករុណាជាម្ចាស់ជីវិតលើត្បូង លុះបានអនុញ្ញាតហើយទើបបោះគោលចារិកទទឹងបណ្តាយទីវត្ត តូចប្តូរតាមកូមិភាគផែនទីដី ។ ដល់ពេលកសាងព្រះវិហារថ្មី មុនដំបូង មានរៀបពិធីបូលភូមិ (ឬពិធីមង្គលឫក្ស), ពួកជាងដែលជាអ្នកឈ្លាសវៃ ក្នុងកិច្ចកសាងព្រះវិហារ មកវាស់វែងបែងចត់ខ្នាតទទឹងបណ្តាយព្រះវិហារ បោះបួសគ្រប់ទិសទាំង ៨ ហើយរៀបធ្វើពនទេវតា ១ ពនព្រះយមពាជ ១ ក្នុងទីខាងមុខវិហារ ហើយធ្វើស្វាធ័រជាតគ្រប់ទិស (ដូនឃើញធ្វើពនទេវតាគ្រប់ទិស) ។ ពនទិសនេះមានដាក់វត្ថុតាមទំនៀមទម្លាប់ដាក់ មានស្វាធ័រ ១ គូ នឹងស្វាបារីជាដើម ។ ពនធំខាងមុខមានដាក់ប្រាយស៊ី ៥ ថ្នាក់ ១ គូ ។ នឹងមានទៀន ៥ ធូប ៥ ជាដើម, ហើយមានដាក់សម្ពត់អាវពណ៌ខៀវ-លឿង-ក្រហម នឹងវត្ថុមានគ្រឿងមាសប្រាក់ជាដើមផង, ទើបព្រឹទ្ធាចារ្យអ្នកចេះដឹងឲ្យដឹករណ្តៅ ១

ចំកណ្តាលព្រះវិហារថ្មី ដំកៅប្រមាណជា ៧ឬ ៨ តឹក ហើយអុជអប់រណ្តៅ ដោយទៀនធំធូប រួចយកតាង ១ តូចល្មមអប់ទឹកជាក់ពេញ លើកជាក់ទៅកន្លែងរណ្តៅនោះ ។ ដល់ពេលម៉ោង ៦-៧ល្ងាច រៀបពិធីសំដែងព្រះបរិត្ត, អាចារ្យអាពធនាសីល រួចសូត្របកាសទៅតា ។ ឯព្រះសង្ឃសំដែងព្រះបរិត្តតាមសមគួរដល់កាលវេលា ។

លុះព្រឹកព្រហាមឡើងជាថ្ងៃដយមង្គល ព្រះថេរានុត្ថេរព្រមទាំងពួកឧបាសកឧបាសិកាត្រូវទៅប្រជុំនៅទីព្រះវិហារថ្មី ឈរជុំវិញរណ្តៅនោះ ទើបអាចារ្យសូត្របាឡីបូលកូមិថា :

អយំ ភូមិប្បទេសោ ។ល។ ឧម្ពុធីបេ ឯកាសេ តិដ្ឋាមិ ។ បីចប់ ។ រួចអាចារ្យបួងសួងឧទ្ទិសដល់គុណព្រះរតនត្រ័យព្រមទាំងទេវតា សុំឲ្យទីវត្តថ្មីនេះប្រកបដោយសេចក្តីសុខ-ចំរើនជាបដល់ ៥០០០ ព្រះវស្សា, រួចយកដុំអិដ្ឋធំគ្របមាត់ពាងឲ្យជិត លុបដីពីលើ ស្រែចកិច្ចតែប៉ុណ្ណេះ ។

ន័យមួយទៀតគេមិនជាក់ពាងទឹកទេ, គឺយកថ្ម ១ ដុំល្មមលើកម្នាក់រួច មកចង់ស្រាក់ឲ្យមានទៀក្រាន់, លុះដល់ពេលវេលាហើយ ព្រះថេរជាប្រធានាធិបតី ព្រមទាំងពួកពុទ្ធបរិស័ទនិមន្តទឹងអញ្ជើញទៅកាន់ទីសន្និបាត, ព្រះថេរជាប្រធានាធិបតីពោលព្រះបាឡីថា អយំ ភូមិប្បទេសោ វិសុំ តាមោ ហោតុ ។ បីចប់ ។ រួចលោកលើកដុំថ្មជាក់ទៅ

កន្ទរណ្តៅនោះ ហើយមានថេរាចារ្យអធិប្បាយអំពីដីវត្តនឹងថ្មនេះតាមន័យផ្សេងៗ រួចលោកបួងសួងដូចសេចក្តីខាងលើនោះដែរ, ហើយលុបដីពេញរណ្តៅនោះទៅវិញ ស្រេចកិច្ចតែប៉ុណ្ណេះ ។

ពិធីបញ្ចុះសីមានឹងឆ្លងបុណ្យ

តាមទំនៀមទម្លាប់ស្រុកខ្មែរពីបុរាណរាល់វេនមក កាលបើការកសាងព្រះវិហារថ្មីរួចហើយ គេតែងរៀបពិធីបញ្ចុះសីមានឹងឆ្លងបុណ្យ ។ តែបើវត្តណាជាវត្តចាស់មានសីមាពីបុរាណដោយត្រឹមត្រូវល្អហើយ ទាំងសង្ឃមិនមានសេចក្តីរង្គើសវត្តនោះគេមិនចាប់បញ្ចុះសីមាថ្មីទៀតក៏បាន។ កិច្ចរៀបពិធីបញ្ចុះសីមា ដើមឡើយត្រូវលោកជាប្រធានាធិបតី រកថ្មជានិមិត្តសីមា ឬសសីមា ៨ ដុំឲ្យល្អស្អាតកុំឲ្យប្រែះធា សំណុំ ២ ហត្ថ១ចំអាមគោះហោចទៅសំណុំតែ២ហត្ថក៏បាន, បើតូចជាងនេះពុំឡើងជាសីមា ។ ឯសន្ធឹកសីមាសម្រាប់ជាក់ខាងលើ ចង់យកឥដ្ឋ - ថ្មមកវចនាដូចបុរាណផ្ទាប់ធ្លីរៀងៗមកក៏បានឥតថាស់ ។ ឯទីដុំវិញព្រះវិហារនោះត្រូវបោសសំអាតឲ្យស្អាតល្អ ទើបលោកប្រធានាធិបតី (អាចារ្យ) យកខ្សែមកវាស់បោះបួស់រណ្តៅសីមា គឺវាស់អំពីសំយាបព្រះវិហារចេញទៅគ្រា ៤ ហត្ថ, ហើយបោះបួស់គ្រប់ទិសទាំង ៨ ។ បើទីព្រះវិហារធំ នឹងចង់បញ្ចុះឲ្យធំទៅទៀតក៏បាន តែកុំឲ្យលើសអំពី ៣ យោជន៍ ។ បើព្រះវិហារតូចឲ្យបញ្ចុះល្មមព្រះសង្ឃ ២១ អង្គគង់ហត្ថបាសបាន, បើតូចឬធំហួស

កំណត់នេះមិនឡើងជាសីមាឡើយ ។ លោកប្រធានាធិបតីត្រូវពិចារណាមើលក្រែងមានសីមាចាស់ពីបុរាណ បើមានឲ្យបញ្ចុះសីមាថ្មីក្រៅសីមាចាស់ ទើបឡើងជាសីមាហោង ។

ឯសីមាខុសមាន ១១ បំពួក គឺ

១ – ភូមិសីមាតូចពុំបុះភិក្ខុ ២១ អង្គ, ២ – សីមាធំកន្លងលើស ៣ យោជន៍, ៣ – សីមាមាននិមិត្តជាប់, ៤ – យកស្រមោលភ្នំ-ឈើជានិមិត្ត, ៥ – គ្មានយកវត្ថុអ្វីជានិមិត្ត, ៦ – ភិក្ខុហត្ថបាសឈរខាងក្រៅសីមាហើយសន្មតសីមា, ៧ – យកស្ទឹងសន្មតជាសីមា, ៨ – សន្មតសមុទ្ទជាសីមា, ៩ – សន្មតសីមាក្នុងជាតស្រះ (ស្រះកើតឯង), ១០ – យកសីមាលោកមុន មកធ្វើយជានិមិត្តសីមាឯក្រោយ, ១១ – យកសីមាឯក្រោយទៅបញ្ចុះគ្រប់លើសីមាមុន ឬចូលក្នុងសីមាមុន ។ សីមាខុសទាំង ១១ នេះពុំឡើងជាសីមាឡើយ ។

ឯសីមាត្រូវតោះមាន ៣ គឺ

១ – យកថ្មឈើខ្ទឹមខ្ជាប់ជិតថេរយកមកធ្វើជានិមិត្តសីមា ។

២ – កាលបញ្ចុះសីមានោះឲ្យនិមន្តភិក្ខុមានសីលធម៌ល្អស្រេចត្រូវគំមកហត្ថបាស បើក្រែហោចណាស់ទៅឲ្យបាន ២ អង្គ បើច្រើនលើសនេះទៅជាមហាប្រសើរ ។

៣ - លោកជាវិនយធរ-ធម្ម-អ្នកសូត្របញ្ចុះសីមានោះ គេត្រូវរក លោកដែលស្ទាត់ក្នុងវិធីអក្ខរៈ មានគុណហ៊ុជាដើម ។

លោកអាចារ្យត្រូវបង្គាប់ឲ្យទាយកជីករណ្តៅសីមាឥន្ទខីលចំពោះមុខ ព្រះកត្តុព្រះ ឲ្យវាស់អំពីសីមាទិសបូពាទៅទិសបស្ចឹម បត់ពាក់កណ្តាលស្មើគ្នា ឲ្យវាស់អំពីសីមាទិសទក្សិណាទៅទិសឧត្តរបត់ពាក់កណ្តាលស្មើ, ហើយចោះប្បស់ជីករណ្តៅឥន្ទខីល ជំរៅ ៤ ហត្ថកំបាន ២ ហត្ថកំបាន, ហើយឲ្យវាស់អំពីសីមាគ្រប់ទិសចេញទៅ ៤ ហត្ថទៀត, ឲ្យធ្វើកជវ័តិ ជោតធ័ត្រវួតជុំវិញព្រះវិហារ ហើយធ្វើពន្ធទេព្ពាតាំង ៨ ទិស ត្រមតាំងដង់ទង់ គ្រប់ទិសតាំង ៨ ។ ដល់ពេលសំដែងព្រះបរិត្ត ឲ្យរៀបបណ្ណាការបូជាទេព្ពា បង្គតគោមពល់ដងទង់, រួចនិមន្តព្រះសង្ឃសំដែងព្រះបរិត្ត អញ្ជើញអស់ទេព្ពា, ឯបុរសសីមានឹងសន្ធឹកសីមានោះឲ្យយកទៅជាក់កង់ព្រះវិហារទាំងអស់ ។ លុះសូត្រមន្តជាគំរប់ថ្ងៃ ៣ ហើយ អាចារ្យអាចធនាសីល រួចឲ្យអស់ទាយកតាំងប៉ុន្មាននៅអ្នកដើមការវេរទីជាវិសុំគាមថា ឧមោ តស្ស ភគវតោ ។ ល ។ សង្ឃស្ស ទុណោដេម ។ ទុតិយម្បិ ។ តតិយម្បិ ។

ព្រះសង្ឃទទួលសាធុ ។ រួចវេរបញ្ចុះឥន្ទខីលនិមិត្តថា សារីបុត្តមោគ្គល្លានាធយោ ។ ល ។ តំ សព្ពំ អម្ហាកំ វិហារស្ស ទុណោដេម ។ ទុតិយម្បិ ។ តតិយម្បិ ។

រួចនិមន្តព្រះសង្ឃសំដែងព្រះបរិត្ត ចប់ហើយអញ្ជើញអស់សីមា ទៅជាក់គ្រប់ទិសទាំង ៨ ហើយឲ្យទុកវៀសនៅចុះឲ្យស់អមសង្ឃទាង មាត់រណ្តៅសីមាជុំវិញ ។

លុះព្រឹកឡើង អស់ព្រះសង្ឃថ្វាយបង្គំព្រះបើកអរុណរួចហើយ, អស់ ពាយកដើមការ បញ្ចុះសីមាឥន្ទ្រីល, ទិសបូព៌, អគ្នេយ៍, ទក្សិណ, និរតី, បស្ចឹម, ពាយ័ព្យ, ឧត្តរ, ឦសាន ។ លុះស្រែចកិច្ចបញ្ចុះហើយ ពាយក ចេញមកក្រៅពាដវ៉តិ ប្រយ័ត្នកុំឲ្យមានឆ្កែ ឆ្មា-មាន់-ទា ជាដើមចូល ក្នុងពាដវ៉តិឬហើរមូង ប្រយ័ត្នកុំឲ្យព្រះសង្ឃនិមន្តចេញចូលទៅទៀប ទាងក្រៅពាដវ៉តិនោះឡើយ, បើមានហេតុដូច្នេះ ឲ្យពាយកប្តឹងព្រះសង្ឃ រើសូត្រញត្តិជាថ្មីទៀត ។ ឯព្រះកិក្ខុសង្ឃត្រូវសម្តែងអាបត្តិ។ រួចហើយឲ្យ សូត្រថា សព្វេ ពុទ្ធា ពលប្បត្តា ។ល។ ឥជ្ឈាមិ សព្វសោ។ រួចសូត្រ អាកាសដ្ឋាចក្ខុមដ្ឋា ។ល។ សោត្ថឹ ភវន្តុ ទេវតា ។ ហើយឲ្យកិក្ខុ ១ អង្គសូត្រថា អយំ ភូមិប្បទេសោ វិសុំតាមោយេវ ហោតុ (៣ចប់) ។ រួចព្រះសង្ឃរៀបឈរ ហត្ថបាសជុំវិញសីមាឥន្ទ្រីលឲ្យត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិ, រួចសូត្រដក សីមាឥន្ទ្រីលថា: សុណាតុ មេ ភន្តេ សង្ឃោ ។ ល។ ឯវមេតំ ធារយាមិ ។ រួចសូត្រដកសីមាទិសបូព៌-អគ្នេយ៍-ទក្សិណ-និរតី-បស្ចឹម-ពាយ័ព្យ-ឧត្តរ-ឦសាន រួចសូត្រដកសីមាទិសបូព៌ត្រួត

ម្ពង់ទៀត ហើយចូលទៅក្នុងព្រះវិហារវិញ, ទើបលោកទានាធិបតី ចាត់លោកវិនយធរ - ធម្ម ២ អង្គ ឲ្យចេញទៅដណ្តឹងនិមិត្តសីមាទិសបូព៌ ជាដើមថា បុរត្ថិមាយ ទិសាយ កឹ ឯមិត្តំ ។ អាចារ្យធ្វើយថា ចាសាណោ កន្តេ ។ ទើបព្រះវិនយធរ - ធម្ម - សូត្របណ្តឹងព្រះ ឧបជ្ឈាយ៍ថា ឯសោ ចាសាណោ ឯមិត្តំ រួចសូត្រដណ្តឹងទៅ ទិសអគ្នេយ៍ - ទក្សិណ - និរតី - បស្ចិម - ពាយព្យ - ឧត្តរ - ឦសាន រួច សូត្រដណ្តឹងទិសបូព៌ត្រួតម្ពង់ទៀត ។ ឯបាឡីត្រូវផ្ទាស់តាមឈ្មោះទិស ទាំង ៨ ដូចរបៀបខាងលើ ។

រួចក្រុមដំនុំសង្ឃនិមន្តរៀបហត្ថបាស ឈរជុំវិញសីមាឥន្ទ្រខីល, សូត្រញត្តិសីមាដោយព្រះចៅឡីថា សុណាតុ មេ ភន្តេ សង្ឃោ យាវតា សមន្តា ឯមិត្តា កតិត្តា ។ ល ។ ឯមតំ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

ស្រេចហើយប្រគេនទេយ្យទាន ដែលខ្លួនប្រឹងទុកបូជាព្រះសង្ឃ ។

ពេលល្ងាចសូត្រព្រះពុទ្ធមន្ត, ព្រឹកឡើងនិមន្តលោកសូត្រធម្មឆ័ត្រ កុសល, ពេលថ្ងៃរសៀលនិមន្តលោកទេសនាអានិសង្សសីមា, ទេស្នាចប់ ហើយនិមន្តព្រះសង្ឃមកជួបជុំក្នុងព្រះវិហារ រួចវេរដោយព្រះចៅឡីថា ឥមស្មឹ វិហារេ ឥមានិ ទ្វេ ឆ្នាសីមានិ ឧភោសង្ឃបរិវេ-ណាសង្ឃកម្មការណត្ថាយ ភាគុដ្ឋិំសស្ស សង្ឃស្ស

ខុណោ ដេម អត្ថាយ ហិតាយ សុខាយ ទីឃរត្តំ ។
ទុតិយម្បិ ។ តតិយម្បិ ។ ព្រះសង្ឃទទួល សាធុ ។

ពិធីបញ្ចុះសីមាចប់

សេចក្តីបញ្ជាក់អំពីតែងរឿងនេះ

១– រឿងសាវតារវត្ត យើងតែងតាមសេចក្តីកត់ហេតុ ដែលហៅអធិការមុនៗ សរសេរទុកមក ព្រមទាំងបានហៅចាស់ៗ មកសួរបញ្ជាក់ថែមទៀត ដើម្បីធៀបគ្នានឹងសេចក្តីយល់របស់យើងខ្ញុំៗ ដោយកន្លែងដូចអំពីរឿងប្តល់ឱ្យចាប់ផ្តើម ។

២– រឿងផ្តើមកសាងវត្តជាដំបូង (ឬពិធីបូលភូមិ) យើងតែងតាមបានឃើញគេធ្វើ ទាំងតែងតាមអាចារ្យវត្តជាន់ចាស់ម្នាក់ឈ្មោះ "អ៊ូ" ដែលបានអធិប្បាយប្រាប់សព្វគ្រប់ តែអាចារ្យនេះអនិច្ចកម្មជាយូរឆ្នាំហើយ ។

៣– រឿងបញ្ចុះសីមា នឹងធ្វើបុណ្យ យើងតែងតាមក្បួនបញ្ចុះសីមាពីបុរាណ ។ តែដំបូងដែលដកសីមាចាស់ នឹងបាឡីសូត្រញត្តិសីមាថ្មី ព្រមទាំងបាឡីវេរ សុទ្ធតែមានពិស្តារបស់គេ តែដែលយើងតែងនោះ បំប្លែងចុះកុំឲ្យច្រើនទំព័រ ព្រោះយល់ថាមានក្នុងព្រះត្រៃបិដកហើយ ។

ចប់សាវតារវត្តប្រាចិនរោម

លោក ផេង - ជ្រីវ សាស្ត្រាចារ្យ នៅអគ្គិទ្យាល័យតារីភ្នំពេញ

ប្រែពីជាភាសាបារាំងមកជាខ្មែរ

(ភាគ ៣)

ពេលនោះ អេសុបមានប្រពន្ធហើយ តែគ្មានកូន, លោកបានសុំមាណពម្នាក់ឈ្មោះអេន្នុះ (Ennus) ធ្វើជាកូនចិញ្ចឹម, អ្នកនេះជាអ្នកមានភូជអម្បូរគ្រាន់បើដែរ តែជាបុគ្គលអកតញ្ញូ, លុះអេសុបដំណើរនេះក៏ដេញចេញពីផ្ទះ ។ ដើម្បីសង៍សឹកអេន្នុះក៏ធ្វើសំបុត្រក្លែងមួយ ហើយយកទៅថ្វាយព្រះចៅលីសេរុះ ។ សេចក្តីក្នុងសំបុត្រនោះថា: "អេសុបមានចិត្តអាក្រក់ទៅចូលដៃ ជាមួយនឹងស្តេចជាគូដៃដែលចង់ប្រឆាំងវាស្មានឹងព្រះអង្គ" ។ ព្រះរាជា លុះទ្រង់ជ្រាបតាមគ្រានឹងស៊ីញើរឈ្មោះក៏ទ្រង់ខ្ញាល់ ហើយបង្គាប់សេនាបតីម្នាក់ឈ្មោះ ហេរ៉ិព្ពុះ (Hernippus) ដែលជាសម្ងាញ់របស់លោក ឲ្យយកលោកទៅសម្លាប់ចោល កុំដំរះរកខុសត្រូវឡើយ ។ តែហេរ៉ិព្ពុះស្រឡាំងដំរែរបស់អេសុបគ្មានឲ្យនរណាដឹង ហើយយកលោកទៅចិញ្ចឹមទុកក្នុងទម្ងន់មួយ រហូតដល់ព្រះរាជាព្រះនាមណិក្តេណាបូ ឃានទ្រង់ជ្រាបថាលោកស្លាប់ហើយ ក៏នឹកស្មានក្នុងព្រះរាជហឫទ័យថា មុខជាយកព្រះចាខលីសេរុះឲ្យជាអ្នកថ្វាយសួយដល់ព្រះអង្គជាមិនខាន ។ ម្ល៉ោះហើយព្រះអង្គហ៊ានលេងក្តាល់នឹងព្រះចាខ

លើសេះទៀត ហើយធ្វើសារទៅឲ្យព្រះកុណាអង្គនេះ ឲ្យបញ្ជូនទូវជាងចាំងឡាយដែលចេះសង់ប្រាសាទនៅលើអាកាស ទឹងមនុស្សម្នាក់សម្រាប់ដោះប្រស្នាទៅឲ្យខ្លែង ។ ព្រះបាទលើសេះកាលខ្លែងតសារសព្វគ្រប់ហើយ ក៏បញ្ជូនទៅឲ្យសេនាបតីទឹងអ្នកប្រាជ្ញចាំងឡាយដែលកងវៃជាងគេក្នុងព្រះនគរពិចារណាមើល តែរកឈ្មោះណាមួយទឹងអាចដោះស្រាយទូវប្រស្នានោះពុំបាន ។ ព្រះរាជាដែលបានខ្លែងប្រាប់ថាគ្មានអ្នកណាទឹងអាចដោះស្រាយបានដូច្នោះ ក៏ខ្លែងទឹកស្ពាយអេសុបពេក ។ ទើបហៅវិញ្ញុះក្រាបបង្គំទូលថា អេសុបនៅរស់នៅឡើយទេ ។ ព្រះរាជាខ្លែងបង្គាប់ឲ្យគេហៅលោកមក ។ លុះលោកមកដល់ ព្រះរាជាអង្គនេះខ្លែងធ្វើបដិសណ្ឋារកិច្ចយ៉ាងពេរពាយ, ចំណែករឿងកំហុសលោកដឹងច្បាស់ថា អេន្នុះធ្វើសំបុត្រក្លែង តែលោកអត់ទោសឲ្យ ។ ចំណែកខាងប្រស្នារបស់ស្តេចនគរអេស៊ីប្ត៍ (Egypte អេសុបឃើញហើយសើចញឹមៗប្រាប់ថា ចាំដល់វស្សានរដូវទើបបញ្ជូនជាងទឹងវិសេដ្ឋនបុគ្គលទៅ ។ ព្រះបាទលើសេះខ្លែងប្រទានទ្រព្យសម្បត្តិចាំងប៉ុន្មានរបស់លោកត្រឡប់ឲ្យមកវិញអស់ រួចខ្លែងបើកអេន្នុះឲ្យទៅនៅជាមួយទឹងលោកទៀតតាមតែលោកចង់ធ្វើអ្វី ចូរប្រើប្រាស់ឲ្យធ្វើតាមចិត្តចុះ ។ អេសុបក៏ព្រមទទួលយកអេន្នុះទុកជាកូនចិញ្ចឹមវិញ តែត្រូវដាក់ឈ្មោះកម្មបន្តិច គឺត្រូវស្តីប្រដៅដូច្នេះ: "ត្រូវគោតខ្ចាចព្រះជាម្ចាស់ទឹងព្រះមហាក្សត្រិយ៍របស់

ខ្លួន, ត្រូវធ្វើឲ្យវែងវែងនៅមុខសត្រូវ, ធ្វើឲ្យស្រួល ចេះគួរសមដល់អ្នកដទៃ, ត្រូវថ្នមបែបពន្លៃតែកុំជ្រាប់ការណ៍សម្ងាត់, ត្រូវនិយាយតិច, ត្រូវបណ្តេញចេញពីផ្ទះ នូវមនុស្សណាដែលនិយាយច្រើនឥតប្រយោជន៍នឹងមនុស្សមិនចេះយល់ទាស់, កុំបណ្តោយឲ្យសេចក្តីខ្វះខ្វែងញាំញីបាន, ចូរប្រយ័ត្នទៅថ្ងៃស្អែកជានិច្ច ព្រោះថាសូវចាំយើងស្អប់សិន សិមឲ្យបំភ្លេចតែនៃយើងមានកម្លាំងល្អជាជាងយើងធ្វើឲ្យវេល ឲ្យទើសទែងដល់មិត្រយសរបស់យើង កងវេលាដែលយើងរស់នៅ, ការណ៍ដែលត្រូវកុំឲ្យមានសោះ គឺកុំឲ្យមានអកិដ្ឋានូវព្រៃងសំណាងនឹងសេចក្តីសុចរិតនៃជនដទៃ ដ្បិតថាបើកាន់ឫកបែបនេះ ដូចជាធ្វើបាបតែខ្លួនឯង" ។ ការប្រែនប្រជៅនឹងចិត្តល្អនៃអំសុច ហាក់ដូចជាដែកមួយយ៉ាងស្រួចចូលទៅចាក់ចំតួបេះដូងរបស់អេន្ទះ ។ មិនយូរថ្ងៃប៉ុន្មាន គាត់នេះក៏ធ្វើនូវកាលកិរិយាទៅ ដោយការក្តៅក្រហាយនឹងអកុសលកម្មនៃអាត្មា ។

អំពីរឿងក្មាល់នឹងព្រះចៅព្រះនាមណាក្តេណាបូ អេសុបចាប់យកសត្វតន្ទ្រិយមកបង្រៀនឲ្យចេះពាក្យ ហើយក្នុងកញ្ជើនោះមានជាក់កូនក្មេងម្នាក់ ។

លុះវស្សានរដូវមកដល់ លោកអញ្ជើញទៅប្រទេសអេសុប៊្តជាមួយសត្វតន្ទ្រិយនឹងក្មេងតាំងពីឆ្ងាយ ។ ចំណែកអ្នកស្រុកអេសុប៊្តនៅចាំទទួលពាក្យចម្រើយនឹងអ្នកដោះប្រស្នាឥតកោតញញើតអ្វីសោះ កងពេលដែល

លោកអញ្ជើញទៅដល់ ។ ព្រះបាទណាគ្គេណាបូដែលហ៊ានបញ្ជូន
បញ្ជោទៅ ដោយនឹកក្នុងព្រះទ័យថា: អេសុបស្ងាប់មែន, តែលុះលោក
ទៅដល់ ស្រាប់តែទ្រង់ភ្ញាក់ព្រះអង្គព្រឺត ។ បើប្រសិនជាទ្រង់ជ្រាបថា
លោកនៅរស់ ទ្រង់ប្រាកដជាមិនហ៊ានលេងក្បាល់នឹងព្រះករុណាលើសេរៈ
ឡើយ ។ ព្រះករុណាណាគ្គេណាបូ មានព្រះពាក្យទន្ទឹងត្រាស់សួរទៅ
អេសុបថា តើឯងមានទាំងឆន្ទឹងអ្នកដោះប្រែស្នាមកឬទេ? ។ លោក
ក្រាបបង្គំទូលស្នងថា វិសជ្ជនបុគ្គលគឺខ្ញុំទូលព្រះបង្គំនេះឯង ឯងជាង
សង់ប្រាសាទ ទូលព្រះបង្គំនឹងនាំយកមកថ្វាយត្រង់កន្លែងណាដែលទ្រង់
ត្រូវការសង់ប្រាសាទ ។ លុះចរចារួចស្រេចកាលណា លោកលែង
សត្វឥន្ទ្រីយដែលពាំកញ្ជើ ក្នុងកញ្ជើនោះមានក្មេងម្នាក់ស្រែកឪពីលើ
អាកាសមកថា ឲ្យបាយអមក ឲ្យថ្នឹងឈើមក ។ លោកក្រាបបង្គំទូល
ព្រះចៅណាគ្គេណាបូថា: "សូមទ្រង់ព្រះមេត្តាប្រោស! សូមឲ្យគេយក
គ្រឿងទ្រូសម្ភារៈទាំងឡាយមក ដ្បិតជាងមកដល់ហើយ"។ ព្រះពាក
ក៏ទ្រង់ព្រមទទួលសុំចិត្តចាញ់មួយៗ ។ ព្រះអង្គទ្រង់ចោទមួយៗទៀត
ថា: "យើងមានមេសេះមួយអាចស្តាប់ពុទ្ធូវសំរែករបស់សេះឈ្មោល
ដែលនៅឯស្រុកឫប៉ីឡូនបាន តើឯងត្រូវធ្វើយថាដូចម្តេច?" ។ លោក
សុំអង្វរទុកពេលនេះនឹងធ្វើយថ្វាយដល់ថ្ងៃស្អែក ហើយលោកត្រឡប់មក
កាន់ផ្ទះសំណាក់វិញ ។ លោកឲ្យក្មេងម្នាក់ចាប់ឆ្នាមួយបណ្តើរវាយតាម

ផ្លូវ ។ ពួកអ្នកប្រទេសអេស៊ីប្ដីដែលជាអ្នកគោរពសំពះឆ្មា លុះឃើញក្មេងធ្វើការមិនគួរគប្បីដូច្នោះ ក៏កើតចលាចលហើយនាំគ្នាកន្ត្រាក់ឆ្មាយកពីដៃក្មេង រួចទៅគ្រាបបង្គំទូលនូវរឿងនេះចំពោះព្រះចៅផែនដី ។ ព្រះបាទណាក្ដែណាបូ ទ្រង់បង្គាប់ឲ្យគេហៅអេសុបមកមួយរំពេច ហើយត្រាស់សួរថា: "ឯងមិនដឹងសត្វឆ្មា គឺសត្វជាទីគោរពរបស់យើងទេឬ? ហេតុអ្វីក៏ឯងធ្វើនូវកំហុសដូច្នេះ? ។ លោកធ្វើយតបទៅវិញថា: "សូមទ្រង់ព្រះមេត្តាប្រទានទោស! ដ្បិតឆ្មាហ្នឹងមានកំហុសចំពោះព្រះករុណាលើសេរុះ ព្រោះយប់មិញ វាទៅស៊ីមាន់មួយរបស់ព្រះអង្គ គឺជាមាន់ល្អអស្ចារ្យដែលទ្រង់ទុកសម្រាប់ឲ្យរងាវាល់ព្រឹក" ។ ព្រះចៅណាក្ដែណាបូ ទ្រង់មានព្រះបន្ទូលត្រាស់ថា: ឯងនិយាយកុហក សត្វឆ្មាណាក្នុងមួយយប់អាចដើរបានឆ្ងាយម្ល៉េះ? ។ អេសុបធ្វើយតបទៅវិញភ្លាមថា មិនដែលមាន មេសេះណាអាចស្ដាប់នូវសំរែករបស់សេះឈ្មោលបានឆ្ងាយម្ល៉េះ! ។

តមក, ព្រះចៅដដែលមានព្រះរាជឫង្ការបង្គាប់ឲ្យគេអញ្ជើញនូវអ្នកប្រាជ្ញទាំងឡាយមានបញ្ញាយ៉ាងឆើត ។ ដែលចេះខាងចំណេះយ៉ាងពូកែពីក្រុងហេលីយូប៉ូលិសមក ហើយប្រជុំគ្នាស៊ើលឿងព្រមទាំងអេសុបផង ។ ក្នុងកាលដ៏ឆ្ងាវឆ្ងៃនោះ គេចោទលោកថាដូច្នេះថា "មានព្រះវិហារមួយប្រតិស្ឋានលើសសរមួយ ដែលមានក្រុងជាប់ពីរព័ទ្ធជុំវិញ,

ក្រែងមួយៗ មានចន្លុះសាមសិបនៅដុំវិញ, ចន្លុះមួយៗ មានស្រែក្រមុំ ពីនាក់ មួយស មួយឱ្យ ដែលដើរលេងមួយមុខ មួយក្រោយជា បក្រែត" ។ អេសុបឆ្លើយថា: "ប្រស្នាបែបហ្នឹង តែក្មេងក្នុងស្រុក របស់យើងក៏ចេះគេដែរ: ព្រះវិហារគឺលោកតាំងមូល, សសរគឺធ្មាំ, ក្រែងតាំង ១២ គឺខែតាំង ១២, ចន្លុះ ៣០ គឺថ្ងៃតាំង ៣០, ឯស្រែក្រមុំ ពីនាក់ដែលដើរលេងមុខ - ក្រោយ គឺព្រះអាទិត្យនឹងព្រះច័ន្ទ ។

ពីកឡើង, ព្រះបាទណាក្តេណាបូ ទ្រង់ប្រជុំអស់នាម៉ឺនមន្ត្រីតូចធំនឹង មិត្តភ័ក្តិតាំងប៉ុន្មានហើយមានព្រះរាជឱង្ការថា: "ចូរអ្នកតាំងឡាយមើល ចុះ មនុស្សមានរូបវិកលវិការ មុខមាត់ស្ទើរតែមិនមែនជាមនុស្សដូចគេផង តាំងពួង មិនគួរសោះឡើយ ព្រោះតែមនុស្សបែបហ្នឹងមកឱ្យព្រះចៅ លីសេរុនមានជ័យលើយើង អញគិតសព្វៗ ទៅដូចជាតប់ប៉ាមល់ក្នុងចិត្ត អីម្ល៉េះ អំពីរឿងជំនះនេះ" ។ ក្នុងណៈនោះ មានម៉ុនស្សម្នាក់ចោទ អេសុបមួយប្រស្នាទៀតថា: "ចូរអ្នកឯងចោទសួរមកយើងម្ចងមើល តែត្រូវអ្នកចោទចំពោះតែប្រស្នាណាដែលយើងមិនដែលដឹងមិនដែលឮ" ។

អេសុបចាប់សរសេរសំបុត្រមួយច្បាប់ ក្នុងសំបុត្រនោះលោកជាក់ថា: "ព្រះបាទណាក្តេណាបូទូលសុខចិត្តជំពាក់ចំពោះព្រះចៅលីសេរុន ប្រាក់ចំនួនប្រាំរយហាសិបវៀល (៥៥០វ,០០)," រួចក៏យកជាក់ក្នុង

ស្រែមមួយបិទយ៉ាងស្អាត ហើយយកទៅប្រគល់ជាក់លើព្រះហស្ត
របស់ព្រះចុតណិក្តេណាបូមានទាំងចោះត្រាផង ។ មុននឹងបើកសំបុត្រ
មើល, ពួកមិត្តភក្តិនៃព្រះរាជអង្គនេះនិយាយមត់គ្នាថា គោងយើងថា
ធ្លាប់ដឹងធ្លាប់ឮទាំងអស់គ្នា ។ លុះបើកសំបុត្រឡើងកាលណា ព្រះ
រាជាស្រែកឡើងថា នេះហើយបានចំពេញជាកំហុសយ៉ាងធ្ងន់ក្នុងលោក,
ខ្ញុំយកអ្នកពាល់គ្នាធ្វើជាសាក្សី ។ ទើបអ្នកទាំងនោះទទួលព្រមគ្នាថា យើង
ប្រាកដជាមិនដែលដឹងមិនដែលឮសោះឡើយ ។ អេសុបសួរថា: "ម៉េច
ត្រូវចិត្តរបស់អស់លោកគ្រប់គ្នាឬទេ? ដែលលោកចង់ដឹងនូវប្រស្នាដែល
មិនដែលដឹងមិនដែលឮ" ។ ព្រះចុតណិក្តេណាបូ បញ្ជូនលោក
ត្រឡប់ទៅនគរវិញ ព្រមទាំងសួយសារអាករសម្រាប់យកទៅថ្វាយ
ចំពោះព្រះចៅលីសេរុះ នឹងរង្វាន់ទាន់ខ្លួនរបស់លោកផង យកស្មើរតែ
មិនរួច ។

លុះអេសុបត្រឡប់មកដល់នគរវិញកាលណា ព្រះចុតលីសេរុះ
ស្តេចទ្រង់ចាត់ឲ្យរៀបទទួលជាអ៊ឹកអធឹក ហើយទ្រង់សំដែងព្រះហឫទ័យ
រីករាយនឹងសេចក្តីល្អជាពន្លឹក ។ រួចទើបទ្រង់ចាត់ឲ្យជាងធ្វើក់រូបអេសុប
មួយដំកល់ទុកគ្រាន់ជាអនុស្សាវរីយ៍ទៅថ្ងៃក្រោយ ។ ការចង់ឃើញចង់
ដឹងនឹងចង់រៀន នាំឲ្យលោកលះបង់នឹងមិនត្រូវការនូវសេចក្តីសុខក្នុង
ទ្រព្យសម្បត្តិនឹងការរាប់អាន ។ លោកចេញពីព្រះចុតលីសេរុះ ដើម្បី

វិលទៅកាន់នគរក្រិកម្តងទៀត ។ ព្រះរាជាអង្គនេះទ្រង់ស្រណោះសោក ស្តាយនូវលោកពន់ពេក ហើយទ្រង់ផ្តាំថា: ចូរឯងត្រឡប់មកបង្ហើយ នូវថ្លៃរបស់ឯងនៅជិតយើងជាកុំខាន ។

បណ្តាទីក្រុងទាំងឡាយ ដែលអេសុបបានអាស្រ័យនៅជាយូរជាង នេះគឺក្រុងដែល្ហូ (Delphes) ។ អ្នកស្រុកដែល្ហូចូលចិត្តស្តាប់សុភាសិតរបស់ លោកដែរ តែគ្មាននរណាមួយគោរពកោតក្រែងដល់លោកសោះ ។ លោកតូចចិត្តនឹងគេមើលងាយពេក ទើបនិយាយប្រៀបថា អ្នកស្រុក ដែល្ហូ ដូចជាកំណាត់ឈើដែលអណ្តែតតាមទឹក, មុនដំបូង កាលនៅឆ្ងាយ គេស្មានថាជាវត្ថុអ្វីមួយដ៏មានដំឡៃណាស់ដែរ តែលុះមកដល់ជិតក៏ត្រឡប់ ជាវត្ថុរកខ្លឹមសារគ្មាន ។ សេចក្តីឧបមានេះ ធ្វើឲ្យលោកមានគ្រោះថ្នាក់ យ៉ាងធំបំផុត ។ អ្នកស្រុកដែល្ហូមានគំនុំយ៉ាងមាំ ហើយមានបំណងនឹង ធ្វើការសងសឹក ព្រោះភ្ញៀវក្រែងអេសុបយករឿងខ្លួនទៅដើរនិយាយ ច្បាប់គេដឹងឆ្ងាយ ម្ល៉ោះហើយក៏នាំគ្នាគិតសម្លាប់លោកចោល ។ ដើម្បី ញុំាងថេយ្យកិច្ចនេះឲ្យសម្រេច ក៏យកធ្នឹលច្បាក់មួយទៅលាក់បង្កប់ក្នុង សម្ពាយទោ - អាវរបស់លោក ដើម្បីនឹងក្លែងចោទប្រកាន់ថាលោកលួច ទ្រព្យគេរុក៏ណ្ឋា ទោសនេះឯងត្រូវសម្លាប់ខ្លួនចោល ។

លុះអេសុបដើរចេញពីក្រុងដែល្ហូកាលណា ហើយសំដៅទៅកាន់ ក្រុងហ្វូស៊ីត (Phocide) ពួកអ្នកស្រុកតែតាមនូវលោកឈប់ឆន៍និយាយចោទ

ប្រកាន់ថាលោកលួចផ្តិលរបស់គេ លោកស្បថស្បែរថាគ្មានយកទេ ។ លុះគេឆែកឆេរក្នុងសំពាយ ក៏ឃើញផ្តិលទៅខាងក្នុងរុំនឹងខោអាវ ។ លោកនិយាយយ៉ាងដូចម្តេចក៏គេមិនស្តាប់ ។ ពួកអាកំណាចចាប់លោកដាក់ច្រវាក់ ហើយនាំទៅដាក់គុកឯងឆឹត ទើបគាត់គោសថាត្រូវសម្លាប់ដោយគាត់ក ។ ពេលនោះគ្មានអ្នកមកជួយលោកបានឡើយ សូម្បីអាវុធធម្មតារបស់លោកក៏ឥតបានការ តែលោកនិយាយកាលណា គេចេះតែចំអកឲ្យត្រឡប់មកលោកវិញ ។ ដូចជាលោកនិយាយថា: "មានកង្កែបមួយ ទៅបបួលកណ្តុរមកលេងឯផ្ទះរបស់ខ្លួន ដើម្បីបញ្ឆោតយកកណ្តុរទៅក្នុងទឹកឲ្យបាន កង្កែបក៏តាំងចងដើងរបស់ខ្លួនភ្ជាប់នឹងដើងនៃកណ្តុរ ។ លុះដល់កងទឹក កង្កែបមុជទាញកណ្តុរឲ្យឈ្លក់ទឹកស្ទាប់អង្គាលនឹងយកធ្វើជាអាហារ ។ កណ្តុរឈ្លក់ទឹកខំប្រឹងទាញងើបឡើងវិញ ។ មួយស្របក់កង្កែបក៏ទាញត្រឡប់ចុះទៅវិញ ។ កំពុងតែទាញចុះទាញឡើងក្លែងមួយត្រឡែកឃើញកណ្តុរ ហើយនាំយកទៅដោយទាំងកង្កែបទៅផង សត្វទាំងពីរបានទៅជាចំណីរបស់សត្វខ្លែង ។ ម្នាលអ្នកទាំងឡាយសេចក្តីកំណាចរបស់អស់អ្នក មិនលែងមនុស្សណាមួយមានបុព្វហេតុសង្សឹកនូវខ្លួនទេ កាលណាអញស្ទាប់ទៅ អ្នកឯងពាល់គ្នាមុខជានឹងស្ទាប់ដូចអញវិញជាមិនខាន" ។

រំលេចដែលគេនាំលោកយកទៅធ្វើគត់ លោករត់រួចទៅជ្រកក្នុងភូនព្រះវិហារមួយ ។ មនុស្សទាំងអស់ទៅតាមចាប់លោកទាញចេញពីក្នុងព្រះ

វិហារមកវិញ ។ អេសុបនិយាយទៀតថា: "អ្នកឯងពាល់គ្នាមិនមានសេចក្តីគោតក្រែងដល់ទីនេះសោះ គឺទីនេះហើយជាព្រំរបស់ ។ មានថ្ងៃណាមួយគង់អ្នកពាល់គ្នានឹងរកសេចក្តីសុខគ្មាន សូម្បីទៅជ្រកក្នុងព្រះវិហារក៏ដោយ ។ អ្នកខាំឡាយមុខជាដូចសត្វតន្ទ្រីយដែលដេញធាបសត្វទន្សាយ សត្វនេះរត់ទៅជ្រកក្នុងរូងកញ្ចែ។ អង្វរសុំទោសក៏សត្វតន្ទ្រីយមិនស្តាប់ ។ តាំងពីពេលនោះមក ពួកសត្វតន្ទ្រីយហីនហោចអស់គ្មានសល់" ។ ពួកមនុស្សខាំនោះមិនវាល់អើពើនឹងសំដីរបស់លោក ហើយនាំគ្នាចាប់លោកចោះទៅក្នុងជ្រោះស្ងាប់ទៅ ។

មិនយូរមកបានប៉ុន្មានថ្ងៃ ខាងក្រោយដែលអេសុបស្លាប់ មានកើតជម្ងឺប៉ះស្តយ៉ាងសម្បើម អ្នកស្រុកស្លាប់ហីនហោចជាច្រើន ។ អ្នកនគរនាំគ្នាទៅបញ្ជាន់អ្នកតាសួរមើល តើធ្វើដូចម្តេច ដើម្បីនឹងរម្ងាប់ទុរ្ភេកនេះបាន? ។ អាស៊ែរ្យប្រាប់ថា បើចង់ឲ្យភេគនេះរម្ងាប់ លុះត្រាតែអ្នកពាល់គ្នាធ្វើបុណ្យមួយ ដើម្បីលន់តួសុំទោសចំពោះព្រលឹងរបស់អេសុបដែលខ្លួនបានជាខុសទៅសម្លាប់ទុរ្ភេលោក ហើយអង្វរសុំឲ្យព្រលឹងនោះទទួលសុខចិត្តអត់ទោសឲ្យទើបបាន ។ ពួកជ្រោះអ្នកនគរខាំឡាយនាំគ្នាសង់ព្រះវិតយមួយថ្វាយចំពោះដួងវិញ្ញាណរបស់អេសុប ។ ការសម្លាប់អ្នកប្រាជ្ញនេះ មិនក្តៅក្រហាយតែតឹមទេតាឡើយ សូម្បីពួកមនុស្សក៏ក្តៅក្រហាយដែរ ។ នគរក្រឹកបញ្ជូនកងក្រវែលមកស៊ើបសួរចាប់យកមនុស្សខាំនោះទៅធ្វើទោសជាទម្ងន់ត្រង់ៗគ្នា ។

រឿងទី ៦

La Lumière de l'Asie

លោក ស៊ីរ - អេតវ៉ាំងអារណូលដ៍ តែង

លោក វ៉ាយ ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

(តមក)

បើយើងចង់ឃើញទីកន្លែង ដែលព្រះអង្គបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ សូមអ្នកអញ្ជើញទៅទិសតាយ័ព្យ នៃបាវនុខ្យានមួយពាន់នៅតាមជ្រោះភ្នំនេគង្គា ដែលនៅជើងភ្នំមានវត្តាជុះស្រោង, ស្រោងមានស្វឹកខៀវខ្ចីដែលជាប្រភពនៃស្ទឹងនិលញ្ជន (Niladjan) នឹងមោហាន: (Mohâna); បើដើរតាមមាត់ស្ទឹងចាំងពីរដែលមានវត្តាមហូអាស៍ mahouas) មានស្វឹកធំៗ ចោលម្លប់ត្រសុំសាខាត្រជាក់នឹងគុម្ពោតនៃព្រឹក្សជាតិសង្សារ (Sansar) នឹងបីរ (bir) ។

រួចទើបអ្នកទៅត្រង់កន្លែង ដែលស្ទឹងចាំងពីរមានទៀកហូរភ្ជាំចាំងចែងជួបគ្នានៅកំពង់ផល្គុ (Phalgou) ដែលហូរកាត់ផែនសិលាទៅដំបន់តយានឹងគីរីក្រហមនៃបរាបារ (Barabar) ។ នៅជិតស្ទឹងនោះ មានដីទំនេរមួយឥតមានវត្តាជុះសោះឡើយ គេឃើញមានដុះតែឈើមានបន្លា

បន្តិចបន្តួចនឹងផ្លូវឡូចដែលពីដើមគេហៅថា ឧរុវេល (Ourouvelaya), នៅខាងចុងបំផុត មានអដ្ឋនបទេសដែលមានភាយោបក់គ្រីគ្រេកត់រុក្ខា-លតាវល្លិ ព្រមទាំងស្លឹកត្រសុំសាខាមានពណ៌ខៀវខ្ចី លាយខៀវផ្ទៃមេឃ ដែលដុះឡើងចាំឆ៍នកាល័យដិត ហើយនៅខាងត្រើមព្រៃប្លោះនោះមាន ស្ទឹងមួយ ដែលទឹកហូរស្រួលហើយមានបុប្ផាបទុមពណ៌ខៀវផ្ទៃមេឃ ដុះពាសពេញ ព្រមទាំងមច្ឆាជាតិហែលច្រកត់ហើយនឹងអណ្តើក ។ នៅជិតនោះមានភូមិមួយហៅថា សេនានី (ប្រហែលជាសេនានិគម) មានគេហ៍ដ្ឋានប្រក់ស្បូវភ្ញាំងនៅកណ្តាលតាលវ័ន ហើយមានប្រជាជនជាអ្នកសុភាពធ្វើរបរកសិកម្ម ។

នៅទីនោះប្រកបដោយរមនីយដ្ឋាន ព្រះបរមពោធិសត្វបានពិចារណា នូវសេចក្តីទុក្ខរបស់មនុស្សជាតិកងសកលលោក នូវវិសុទ្ធិមគ្គ គឺផ្លូវបរិសុទ្ធនៃសត្វ នូវលទ្ធិដែលមានកងសៀវភៅគម្ពីរចាំងប៉ុន្មាន នូវហេតុផលដែលសត្វផ្សេង ។ រស់នៅកងព្រៃ នូវរឿងអាថ៌កំបាំងនៃសេចក្តីស្លាប់ស្វាត់ដែលធម្មជាតិចាំងអស់បជាសន្ធិមក នូវការស្វាត់កំបាំងនៃសមន្ធការ (tenèbre) ដែលសត្វលោកវិនាសទៅវិញ នូវដីវភាពុដែលមានសភាពជាក់ទង្គិចគ្នាជួបជាតន្ធនូ ដែលចុះមកវាងពពកពីរបៃបដែលមេឃចុះអ័ព្ទ ឬានក្លាប់នៅលើអដ្ឋជាកាសហើយមានចំហាយគគ្នាហុយចេញ ស្រាប់តែពណ៌ខៀវសុទ្ធីស្រស់នៃតន្ធនូនោះលាយ

ចាត់សាបសូន្យនៅកណ្តាលនគរយ ។ ព្រះបរមពោធិសត្វបានគង់នៅក្នុងព្រៃដាច្រើនខែ ដើម្បីនឹងធ្វើសមាធិកម្មដ្ឋាន, ដួនកាលក្តៅចសោយព្រះក្រយាហារក៏មាន, ទ្រង់ដួនកាលដល់ចាកចេញពីសមាធិ ពិចារណាតាំងពីបច្ចូសសម័យរហូតដល់អធិទិវា, ព្រះអង្គទ្រង់បានទតឃើញនូវអំបែងដែលសូមទាននោះទទេគ្មានម្ហូបអាហារ ហើយទ្រង់បានសោយផ្ទៃលេបដែលស្អាប្តសេកមានពណ៌ក្រហមឆ្អៅបានបេះទំលាក់មកលើទ្រង់ ។ ព្រោះហេតុដូចនេះ កាយពលរបស់ទ្រង់ក៏អន់ខន់ខ្សោយ, ព្រះរូបដែលទំព្យាមយាមដោយក្លាហានរកធម៌ ទៅជាស្តាំងស្គម ចាត់អាការៈ ៣២ ដែលជាលក្ខណៈរូបនៃព្រះពុទ្ធ, ហើយព្រះរូបទ្រង់មិនបានដូចជាព្រះអង្គមាស់ កាលដែលនៅក្នុងតរុណវ័យទេ តែឡប់ទៅជាដូចស្នឹកសាលព្រឹក្សក្រៀមស្វិតស្រពោន ដែលជ្រុះទៅដីតព្រះជាតារបស់ទ្រង់, មិនមែនដូចជាពន្លកនៃរុក្ខជាតិមានពណ៌ខៀវខ្ចីដុះក្នុងនិទាឃៈរដូវនោះឡើយ ។

មានមួយថ្ងៃ ព្រះអង្គម្ចាស់មានព្រះកាយពលអន់ខន់ខ្សោយរហូតដល់ដួលសន្លប់ចាត់ព្រះស្មារតីនៅលើប្រថពី គេស្មានថាសោយព្រះទិវង្គត ដូចជាមនុស្សដែលត្រូវគេពិឃាត, មិនមានខ្យល់អស្សាសៈ-បស្សាសៈ, ហើយព្រះលោហិតឈប់ហូរក្នុងព្រះកាយព្រះអង្គ ដោយគេយល់ឃើញព្រះរូបនោះមានសភាពស្លឹតស្វាំងពន់ពេក ហើយ

ស្ងៀមឥតកម្រើក ។ តែមានន័យមេសចាលម្នាក់ទទួលមកដល់ទីនោះ ហើយបានឃើញព្រះសិទ្ធត្ថជ្ងូមានត្រចកព្រះនេត្រចំទជិត, បបូរព្រះនាសូ ជ្រួញដោយមានទុក្ខជាទម្ងន់ ហើយកន៏ពេលនោះទទួលកានុវង្ស្បែរញ្ជោញ ចំហាយក្តៅអធិទ្ធាវៅលើព្រះសិរ, កំកាច់មែកក្បាប៉ូមីយេរ (pommier) ដែលមានសំបុកកុឡាបស្រស់ប្រមូលរចនាជាក្បាច់ចុំជ៏ព្រះកំភ្លុ មានឆត្តណ្ណវង្ស្បែរប្រកបដោយអច្ឆរិយភាព ។ រួចនាយមេសចាលនោះ បានយកទឹកដោះពពែ ដែលជាក់ក្នុងថូស្បែកចាក់ទៅកន៏ព្រះនាសូព្រះពោធិសត្វ ដោយក្រែងខ្លួនជាវណ្ណៈទាប ខំប្រយ័ត្នមិនឲ្យប៉ះពាល់ដល់អរិយបុគ្គល ដែលប្រកបដោយអភិជនភាពនឹងសន្តុលក្ខណៈគួរឲ្យជ្រះថ្លាពន់ពេក ។ តែមានគម្ពីរសំដែងថា មែកឈើ សាប៉ូន៏យេរ (Jablonnier) ដែលយកទៅដោតជុំវិញព្រះកំភ្លុព្រះបរមពោធិសត្វ ទៅជាមានដីវិតរស់មួយរំពេច មានសន្ធឹកផ្កាជាច្រើន ព្រមទាំងមានផ្លែសំបុកភ្លឺហើយប្រមូលជាចង្កោមគួរឲ្យអស្ចារ្យពន់ពេក, សំណុំរុក្ខជាតិនោះទៅដូចជាតែនត៍ (tente) នៃសំពត់ព្រៃ មានដរដោយពណ៌សដូចជាប្រាក់ នឹងវត្ថុមូលមានពណ៌ក្រហមផ្លេ ដែលគេសន៏សម្រាប់ព្រះមហាក្សត្រិយ៍ កាលស្តេចយាន៏ទៅក្រសាលបរបាញ់សត្វដូច្នោះឯង ។ ហើយបុគ្គលនោះក៏ក្រាបទូលព្រះបរមពោធិសត្វដោយស្មានកន៏ចិត្តថា ព្រះអង្គជាព្រះអាទិទេព (Dieu), តែបន្តិចទៀត ព្រះបរមពោធិសត្វក៏ក្សាត់ឡើង ទ្រង់

ចានសូមថ្វាយស្បែកនៃនាយមេសចាលដែលមានទឹកដោះពពែមកសោយ ។ នាយមេសចាលក្រាបបង្គំទូលតបមកព្រះអង្គវិញថា "ទ្រង់ព្រះអង្គ ! ខ្ញុំព្រះករុណាមិនអាចថ្វាយថ្វាយស្បែកនេះទៅព្រះអង្គទេ ព្រោះខ្ញុំព្រះករុណាមានវណ្ណៈជាពួកសុទ្រ, ហើយការប៉ះពាល់នេះនាំឲ្យមន្ទិលសៅហ្មងដល់ព្រះអង្គ" ។ ព្រះអង្គតបទៅកាន់នាយមេសចាលថា: "សេចក្តីមេត្តានឹងកិច្ចដែលត្រូវការ តែងមានហេតុផលខាក់ខែងគ្នាច់ពោះសត្វលោកទាំងអស់ ដែលគេទុកជាបងប្អូនមានសាច់លោហិតជាមួយគ្នា ។ វណ្ណៈមិនមានកង់លោហិត ដែលហូរមានពណ៌ដូចគ្នាឬកង់សរសៃទេ, វណ្ណៈមិនមានទេកង់ទឹកទេគ្រាដែលហូរចេញពីចក្ខុគ្រប់ៗសត្វ ជាវត្ថុមានរុជារសប្លែក; ហើយមនុស្សយើងមិនមែនតាំងពីចាប់បដិសន្ធិមកយកតាំងសញ្ញា "ទិលុ:" លើថ្ងាសនឹងខ្សែពិសិដ្ឋជាប់នឹងកមកជាមួយផងទេ ។ អ្នកណាសុចរិត អ្នកនោះគេទុកជាអ្នកទ្វិជ: (អ្នកមានកំណើតពីរដង) ហើយអ្នកណាប្រព្រឹត្តបាបអកុសលលាមក អ្នកនោះគេទុកជាបុគ្គលហីនកាត ។ ព្រោះហេតុដូចនេះ ចូរអ្នកឲ្យទឹកថ្លៃនេះមកខ្ញុំអាស្រ័យផង; បើកាលណាខ្ញុំរកធម៌ដែលខ្ញុំមានធន្ទ:ស្មើរកនោះឃើញ, អ្នកឯងមុខជានឹងបានទទួលនូវសុភផលមិនខាន" ។ ឮវាចានៃព្រះបរមពោធិសត្វនេះនាំឲ្យនាយមេសចាលនោះ មានបីតិព្រួចសព្វអង្គា ហើយក៏យកថ្វាយស្បែកនោះថ្វាយទៅព្រះអង្គ ។

(មានត)

ឧបត្ថម្ភលេខដប់ក្រាំមួយ

ពាក្យកាព្យ

ឃុនសុវត្ថិវេទី យួរ-អ៊ុន ជៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ថ្ងៃទី ៣ នៃកញ្ញា ឆ្នាំ គ.ស.
មួយពាន់ប្រាំបួនរយកួយហាសិប
យួរ-អ៊ុនឱ្យសូមសំដែងតែងកាត់ច្រៀប
ពីគ្រឿងត្រៃគីកិលេសដប់ប្រាំមួយ ។
ដែលជាស្នឹមរុំស្រោបឧបដ្ឋងចិត្ត
សូមស្មាញស្ងួតជាប់ស្អិតត់តរលួយ
បើមានហេតុសុះក្លែតងើបរង្គួយ
រួចតួមួយចេញមុខរងអារម្មណ៍ ។
ឯតួចិត្តបើឥតធម៌ទម័ក
មកជួយស្អាត់ជាញាក់ក្រែកបង្ខំ
តែងដោយតាមកិលេសច្រែះស្រោចស្រំ
ហើយស៊ូផ្ទុំទ្រាំក្នុងក្អកក្អើងខ្ទុក ។
តែបើយើងយល់ដើងនៃកិលេស
រួចមិនធ្វេសចំពប់សព្វកល្យុគ

គង់បានស្រាលស្រាកស្រន់គ្រាន់រាំកមុខ
មិនសូវទុក្ខក្រៃមក្រៃជាំខ្លួន ។
ចេះគួរប្រៀនរៀនឲ្យចាំជាក់ពិត
ហើយត្រូវគិតរាំងគាំងចិត្តា
ថាយកឈ្នះតំលៃសង្គាំងនេះណា
ឲ្យលុះត្រាអស្តង្គតរលត់ឃ្លាត ។
តពីនេះខ្ញុំនឹងរៃរាប់ចំនួន
ជាបទពាក្យប្រាំបួនទុកជូនញាតិ
តែសំខ្យាមាតិការៃនលើសលាត
សូមពួកញាតិអានកុំក្តក់ហ៊ក់កុំខាន ។

១ - អតិជ្ឈា ការលោភធនជនជាតិ
ដោយរាំពៃលែកងចិត្តគិតចង់បាន
ទឹកវីរក់ឈ្លក់ខ្ចល់វិនាសកង្ខ្ជាណ
ថាម្តេចបានជាអំរស់របស់ខ្លួន ។

២ - ធម្មិទោសៈ ការថ្នាំងថ្នាក់ព្រោះអារម្មណ៍
ណាមិនសមនាំសន្តានបានមួយមួន
តែងនឹកខ្ចាញ់ពេញក្នុងពោះឈ្លោះក្នុងខ្លួន
តែសំនួនអាការក្រៅនៅមិនចេញ ។

៣ – ធម៌កោធៈ ការខឹងជាក់ចេញអាការ
កាយវាចាតាមហេតុការណ៍ដែលគោម្ចាញ
ឲ្យឃើញស្តែងដល់គេឯងស្ងែងពាសពេញ
ខាងក្រោយវិញទើបវែងក្រែងអា ។

៤ – ឧបនាហ៌ ការគុំគួនមួនកង់ចិត្ត
ចង់តំនិតគិតក្លួចកាន់ខ្ជែក្រោធក្លា
ដោយបំណងនឹងសងសឹកទៅវិញ៉ា
តែមិនថាការមិនធ្លើទៅលើគេ ។

៥ – ធម៌មក្ខៈ ការលុបលាក់គុណប្រពៃ
ជនដទៃដោយបំភ្លៃគៃវាសវៃ
ពោលបង្អាប់ចាប់ថ្នាក់ថ្លល់ផ្តល់ឲ្យគេ
ពុំនោះទេគេមេខ្លួនថាកូនវិញ ។

៦ – បលាសៈ ការគៃកាសវាសវៃឫក
ដោយធ្វើទឹកមុខមាត់ខ្លួនសួនបញ្ចេញ
ឲ្យត្រឹមស្មើឬលើសលើលោកដុំវិញ
ឲ្យគេជ្រាបឃើញមិនពេញតាមការណ៍ពិត ។

៧ – ធម៌ឥស្សា ការច្រណែនកេណ្ឌឈ្នានីស
ព្រោះតែរិះឃើញគេមានគុណពិសិដ្ឋ

ប្រកាន់ចិត្តមិនស្មើតគោតជោតស្នេហ៍ស្និទ្ធ
ប៉ងក្នុងចិត្តឲ្យតែគេជ្រែអន្ធការ ។

៨ — មច្ឆរិយៈ ក្តីកំណាញ់កាញ៉ូវទ្រព្យទុក
ដោយលាក់មុខពុំចែកចាយពាយតាមការណ៍
ស៊ូធ្វើខ្លួនហោចទុគតយ៉ាងអស្ចារ្យ
ធ្វើអាការឲ្យគេថាអ្នកក្រណាស់ ។

៩ — ធម្មិមាយា ការពុំជាពុតលាមក
បាបគម្រក់ដូចគម្រងក្នុងអង្កាស
ស៊ូលាក់ខ្វិតស្មើតបញ្ឆេញដោយមានខ្មាស
ពុំប្រកាសឲ្យពួចច្បាស់ក្រែងសាយភៅ ។

១០ — សាថេយ្យៈ ប៉ែអំនួតអួតថាគ្រាន់
គ្មានអ្វីអន់មានតែជាន់ខ្ពស់ពេកក្បៅ
ទោះសំដីថ្លៃគំនិតគិតរាក់ជ្រៅ
ទ្រព្យពង្រផ្សាសឹងសន្ធៅគ្មានគេដល់ ។

១១ — ធម្មិថម្ភៈ ការរឹងត្អឹងទ្រឹងវាហ៊ី
គ្មានសេចក្តីលៃធ្វើពួកឫទ្ធាយខ្វល់
ដោយវាចាដែលគេហាថាមកដល់
កោងសែនសល់រឹងនឹងថ្ពល់ដូចបង្គោល ។

១២ — សារម្ភៈ ការប្រែដែងវែងសេចក្តី
គេពោលខ្លីឯងបំភ្លៃពាក្យពាលៃ
គេថាត្រូវត្រូវតាមផ្លូវគួរស្តួរពោល
ឯងទំនើលចោលសំអុយទៅតាំងច្រើន ។

១៣ — ធម្មិមានៈ ការកាន់ខ្លួនសុទ្ធតែឯកុក
គេមើលមុខឬពុំមើលឯងត្រើលខឹង
ដោយកាន់ថាយ៉ាងអាត្មាធុនម្ចឹងៗ
ហ៊ានសំឡឹងពុំធ្លើដងពុំរាប់អាន ។

១៤ — អតិមានៈ មាក់ងាយគេថាគេអន់
ថោកពេកពន់យកជាគ្នាវាអាប់ប្រាណ
មិនរាប់មុខតាំងធ្លើទុក្ខឲ្យរំខាន
ឲ្យគេបានក្តីលំបាកយ៉ាកចិត្តា ។

១៥ — ធម្មិមទៈ ការវង្វេងស្រែងវ័យ
ជាប់អាល័យអំពើពាលលាមកា
វ័យធ្មេញបាក់ថ្ពាក់គេហៅពូឬតា
ហ៊ានផឹកស្រាធ្លាដៃអួតល្បែងពុំល្អ ។

១៦ — បមាទៈ ការធ្វេសល់ធំផុងស្មារតី
បំភ្លេចក្តីរក្សាខ្លួនសុទ្ធធម៌ស

បណ្តាយឲ្យអកុសលខ្វល់ដល់ក

អាសន្នក្រែជិតនឹងមរណ៍ទើបវិលក្អែក ។

ឧបក្លិសដែលពោលនេះជាមន្ទិល

នាំចិត្តវិលផ្តិលក្តីសុខទុក្ខអនេក

ឲ្យក្តិចក្តក់តរល្អក់ឈ្មោះប្រែកែក

ជាហេតុបែកសាមគ្គីពីសង្គម ។

ទាំងនាំឲ្យអន់ខន់ខ្សោយផ្លោយគំនិត

មិនមានគិតពិនិត្យធ្វើការទុត្តម

ដែលជាទ្រព្យជាប់ខ្មៅមុខទុកឧបត្តម្ភ

ឲ្យសន្សំតែសាងទាងសៅហ្មង ។

សូមលោកអ្នកមើលឲ្យជាក់កិលេសនេះ

រួចសូមរិះត្រិះកងចិត្តសង្កេតផង

គង់ឃើញថាកិលេសណាដូចណាហោង

សឹងនាំហ្មងនាំឲ្យមៅក្តៅសន្ធាន ។

យើងបុថុជ្ជនទៅធ្ងន់ដោយកិលេស

បើចេះមិនខំបេះប្រលេះច្រាន

នឹងបង់ក្តីដែលកើតទាន់ឥតទាន

ដំបូន្មាននៃព្រះពុទ្ធបញ្ញាការ ។

អើបងប្អូនខមរៈកម្មដរដ្ឋ

ជាប់ពូជពង្សនគរវត្តរដ្ឋអស្ចារ្យ
សូមអ្នកផ្តន៍តម្រង់ខ្លួនកងធម៌អាថ៌
ជាបុញ្ញាភិសង្ខារជាតិទៅមុខ ។
តែកុំក្លេចកសាងផ្លូវឲ្យកូនចៅ
ដែលគ្នានៅខាងក្រោយឲ្យបានសុខ
ដោយសារថ្វីការពិសីដែលធ្វើទុក
ឲ្យថ្កើងមុខកុំបីជាអាយ័តគេ ។
ជនខាងក្រោយសុខទុក្ខដោយសារជនមុន
ជនខាងក្រោយនឹកព្រះគុណពុំក្លេចខេ
បើជនមុនទុកកេរ្តិ៍គុណប៉ុនសាគរ,
តែបើគ្មានគុណកោះកេរ្តិ៍តែសូន្យឈឹង ។
ខ្មែរទាំងជាតិបើមានយោធាចតែស្ងាប់
ខ្មែរនឹងអាប់ស័ព្ទនឹងហិនគ្មានគេដឹង
តែបើខ្មែរប្រថុយស្លាប់រួចចាប់ប្រឹង
តស៊ូនឹងឧបស័គ្គដោយវិជ្ជា ។
ខ្មែរគង់រស់មានកំពស់ដូចជាតិគេ
ប្លុះខ្មែរមេឬមានធនមានប្រាជ្ញា
នាំខ្មែរតូចកសាងពូជឲ្យថាវរ
កងឥទ្ធិវត្តិឥទ្ធិវណា, សូមលាអើយ ! ។

តំណែងទទួលសម្តេចសង្ឃនាយក

នៅវត្តដំណាក់ សៀមរាប

ព្រះមហា កែ - អឿន រៀបរៀង

ដោយបានទទួលបើរបញ្ជាការ ពីព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យមេគណ

កាលពីថ្ងៃចន្ទ ៤ រោចខែអស្សុជឆ្នាំខាលចត្វាស័ក ព. ស. ២៤៨៣ ត្រូវនឹងថ្ងៃទី ៣០ តុលា គ. ស. ១៩៤០ នេះ នៅវត្តដំណាក់ខែត្រសៀមរាប មានពិធីរៀបទទួលបដិសណ្ឋារៈសម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត សង្ឃនាយកគណៈមហានិកាយ ទឹងព្រះតេជព្រះគុណព្រះពោធិវង្ស ហួត - តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ដែលនិមន្តទៅសំដែងព្រះសទ្ធម្មទេសនា ក្នុងទុកាសបុណ្យកឋិនរបស់ឧបាសកសួស - ឆេង ឧបាសិកាវ៉ាង - គីម ដែលដង្ហែពីក្នុងទីក្រុងមកដល់វត្តដំណាក់ សៀមរាប ដូចមានពិធីបុណ្យខាងក្រោមនេះ :

សុំទៅខាងមុខវត្ត

មានសុំខ្លោងទ្វារនៅចំកណ្តាលជ្រុងមុខវត្តពីរ គឺខាងជើង ១ ខាងត្បូង ១, សុំនេះគេតាក់តែងរចនាដោយរបៀបរៀបរយល្អដ៏វិចិត្រដូចគ្នាទាំងពីរកន្លែង, សសរសុំសុទ្ធតែស្រោបដោយស្លឹកដែលត្រឹមតែងរចនាដោយជាន់ជួន ដាបដល់កំពូល, មានផ្ទាំងតួអក្សរតូចធំដែលកាត់ក្រដាសពណ៌ខៀវ - ក្រហមចងសន្ធឹងនៅមុខសុំទ្វារ ។ សុំទ្វារខាងជើងចារឹកអក្សរថា "សួស្តី សម្តេចព្រះសង្ឃនាយក!", សុំទ្វារខាងត្បូងចារឹកអក្សរថា

"បុណ្យកឋិនទុបាសក សួស - ធេង ទុបាសិកាវ៉ន - គីម" ។ កំពូលស៊ុំទាំងពីរនោះមានដោតទង់ជាតិតូចធំព្រោនព្រាត, ខ្ទោងទ្វារដែលចូលទៅក្នុងវត្តមានស៊ុំ ១ ទៀតដោតទង់ជាតិតូចធំ ជាច្រើនដូចៗគ្នាដែរ ។

រោងនៅមុខឧបដ្ឋានសាលា

នៅខាងមុខឧបដ្ឋានសាលា មានធ្វើកេងធំពីរខ្នង, ត្រង់កណ្តាលគេធ្វើកេងតូចកាត់ខទឹងកេងធំទាំងពីរ ។ ក្នុងកេងទាំងនោះមានរៀបចំដោយតម្រង់ផ្កាឈើ - ស្លឹកដែលក្រមៗភ្នាត់ខ្ញែង ជាគ្រឿងលំអដ៏ត្រកាល ។ នៅខាងយ៉ាមុខឧបដ្ឋានសាលា មានធ្វើបុស្បក ១ កំពស់ប្រមាណ ៥ ម៉ែត្រ, ខាងលើបុស្បកនោះ ដាក់ដម្កល់គ្រែធម្មាសន: សម្រាប់សម្តេចព្រះសង្ឃនាយកសំដែងព្រះសទ្ធម្មទេសនា ប្រដាប់រចនាដ៏វិចិត្រផ្សេងៗ មានអំពូលភ្លើងអគ្គិសនីធំ - តូច - វែង - ខ្លី បញ្ចេញពណ៌ស្មើ ខៀវ - ស - ក្រហម ចំឡែងចំញ្រាចក្នុងវេលាយប់ ។ នៅមុខកេងមានមន្ទីរ ១ តូច បំខ្ទេរូបថតដែលសម្តេចបានមកពីប្រទេសឥណ្ឌូ ឲ្យជនានុជនមើល, គួរឲ្យអ្នកផង ជ្រះថ្លាជាប់ចិត្តចង់មើលហើយមើលទៀត ក្រឡេកមើលពីចម្ងាយទៅគួរឲ្យមានចិត្តជ្រះថ្លា ទឹងមានទៅកាន់កន្លែងបុណ្យនោះមិនកើត ។ តាំងពីខ្ទោងទ្វារកំពែងមុខព្រះវិហារទៅ មានធ្វើជាពដែតិព័ទ្ធសងខាងមគ្គាភ្នាត់ខ្ញែង តែងរចនាវិចិត្រដោយធាងដូង, ស្លឹកដែលក្រម, ទង់ជាតិតូច - ធំនឹងទង់រលកវែងៗ អមសងខាងពដែតិដរបដល់ព្រះវិហារគួរជាទីទស្សនាការដល់ជនានុជនដែលគមនាការទៅមកក្នុងពេលនោះ ។

ថ្ងៃទី ១ គឺថ្ងៃបន្ទួ ៤ រោចខែអស្សុជ

ម៉ោង ៤ រសៀលពួកពុទ្ធបរិស័ទ្ធទាំងបព្វជិតទាំងគ្រហស្ថមានចំនួនច្រើនមកប្រជុំនៅវត្តដំណាក់ ។ ផ្នែកបព្វជិតទាំងក្នុងវត្តនេះទាំងនិមន្តពីវត្តនានាក្នុងខែត្រជាង ៣០០ រូប មានព្រះសុមង្គលសិលាចារ្យមេគណនិងព្រះគ្រូបញ្ញាវិជ្ជាអនុគណជាប្រធាន; ផ្នែកគ្រហស្ថមានចំនួនជាង ១.០០០ នាក់ ត្រៀមចាំទទួលសម្តេច ឈរជំរៀបគ្នាជាពីរជួរតាំងពីមុខវត្តដំណាក់ជាបជល់មុខផ្សារសៀមាប ។ តទៅវិច័ខាងដើងផ្សារដល់ស្ពានថ្ម មានពុទ្ធបរិស័ទ្ធឈរជំរៀបគ្នា ១ ក្រុម ។ ក្បែរចិញ្ចើមថ្នល់សងខាង ។ តាំងពីចុងស្ពានថ្មខាងកើតមកដល់គ្រឹស្ថានព្រះពជ្រប្រតិកូ មានពួកកុមារកុមារី សិស្សសាលាពជការ ឈរជាពីរជួរតាមចិញ្ចើមថ្នល់ មានហត្ថាកាន់ទង់ជាតិគ្រប់ៗ គ្នា ដោយក្រុម។, ក្នុងក្រុមនីមួយ។ មានគ្រូម្នាក់។ ជាមេបញ្ជាការ, ពួកសិស្សទាំងនេះលោកអធិការ ម៉ែន - ឈុំ ជាន់ចាត់ការរៀបចំរង់ចាំទទួល ។ មានរថយន្តភ្លូច។ ៣ បរទៅរង់ចាំទទួលសម្តេចនៅខាងកើតស្ពានថ្មចំនួនជាង ១ គ្រឿម៉ែត្រ, រថយន្តទាំងនោះគេឃើញលោកពជការខ្លះ។ មានព្រះពជ្រប្រតិកូជាដើមដំរ, មានរថយន្ត ៣ ទៀតឃើញលោកគ្រូមេគណ អនុគណ លោកគ្រូចៅអធិការខ្លះ។ និងលោកមហា ៤-៥ អង្គគង់, មានរថយន្ត ១ ទៀតជាក់ក្តេងពិណពាទ្យនិង។ ជាសកខ្លះដំរ ។ ម៉ោង ៥ កន្លះ រថយន្តសម្តេចមកដល់ ប៉ុន្តែមិនទាន់

ចានហែកងពេលនោះក្តាមទេ, សម្តេចឲ្យវេន៍ចាំវេយន្តអង្កតចិនមកនឹងដង្កែ ជាមួយគ្នា ។ លុះវេន៍ចាំកន្ទុះមោ៉ង យើញវេយន្តមកដល់ខ្លះៗ តែមិនទាន់ជួបជុំគ្នា, ពេលនោះគេឲ្យវេយន្តសម្តេចនៅពីខាងមុខបង្អស់ ឯវេយន្តតូច-ធំ រៀបជាលំដាប់ៗ តាមក្រោយ បរទៅដល់ចុងស្ពានថ្មខាងកើត, កុមារាកុមារីគ្រីវែងជាតិព្រាតៗ ឡើង ស្រែកហ៊ោកញ្ជ្រៀវជាកិត្តិយសទទួលសម្តេច ។ តាំងពីត្រឹមនេះទៅ វេយន្តក៏បរបន្តិចៗ, ពួកសិស្សសាលានឹងពុទ្ធបរិសទ្យដើរអមសងខាង, វេយន្តដង្កែសម្តេចទៅរហូតដល់ផ្សារសៀមពប រួចហែចំទ្វេផ្សារ ១ ដុំ ឆ្លងស្ពានមុខផ្សារបត់ចូលទៅកងវត្ត ។

មោ៉ង ៧ ហែទៅដល់វត្តដំណាក់, លោកគាន់ជិបតីនិមន្តសម្តេចឡើងគង់លើបុស្សក សម្តេចថ្លែងការទទួលអំណានឹងជូនពរដល់ពុទ្ធបរិសទ្យ ចាំងបព្វជិតចាំងគ្រហស្ថ ដែលបានមកទទួលបដិសណ្ឋារៈដល់សម្តេច ។ ទីបំផុតសេចក្តីទទួលអំណរ សម្តេចមានព្រះពុទ្ធដីកាថា "បដិសណ្ឋារៈនេះមិនមែនពុទ្ធបរិសទ្យធ្វើឡើងដោយសេចក្តីគោរពចំពោះរូបខ្ញុំទេ, តាមដែលពិតនោះ កិច្ចនេះអ្នកកាន់ព្រះពុទ្ធសាសនាធ្វើឡើងដោយការប្រតិបត្តិតាមគារវធម៌ ចាំងជាកិត្តិយសដល់ប្រទេស" ។

រួចពីនេះសម្តេចទ្រង់សំដែងអំពីបដិសណ្ឋារៈ ២ យ៉ាងគឺ: អាមិសបដិសណ្ឋារៈ = ការពាក់ព័ន្ធទទួលគ្នាដោយអាមិស គឺវាទនីយភោជ-

ន័យហារផ្សេងៗ មានបង្អែមនឹងចំអាបជាដើម ១; ធម្មប្បដិសណ្ឋារៈ= ការ
ពាក់ទាក់ទទួលគ្នាដោយធម៌ គឺសំដែងធម៌ជាស់តឿនគ្នាឬឲ្យនុវ៉ាទដល់គ្នា,
រហូតដល់ ការសំដែងអាការគោរពរាប់អានឲ្យសមហានៈនៃបុគ្គលជា
ឥស្សរៈ មានការក្រោកឡើងទទួលនិងនិមន្តអញ្ជើញឲ្យឡើងកាន់អាសនៈ
ដ៏សមគួរជាដើម ។ ការធ្វើបដិសណ្ឋារៈនេះរាប់បញ្ចូលក្នុងគារវតាទាំង ៦
ហៅថា "បដិសណ្ឋារគារវតា" ។

សម្តេចថ្លែងអំណារនេះចំនួនកន្លះមោង លុះចប់ហើយ គេនិមន្ត
សម្តេចឲ្យទៅសម្រាក ក្នុងកន្លែងដែលរៀបចំទុកបំរុងប្រគេន ។

តាំងពីមោង ៧ កន្លះទៅ គេអង្គាសភោជនាហារដល់ពុទ្ធបរិសទ្យ
ដែលហែកបិនមកពីក្រុងភ្នំពេញ ។

មោង ៩ កន្លះ លោកវរសេនីយត្រី (ឈួនម្លូរពេជ្រ) នាំកង
ឯកទេសខ្មែរចំនួន ៥ រថយន្ត មកកាន់ធម្មស្សវនដ្ឋាន ទ្រូចលេងនូវភ្លេង
ជាតិនឹកំរាំជូនបងប្អូនរួមជាតិស្តាប់មើល ។

មោង ១០ កន្លះ និមន្តព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត
សំដែងធម៌ទេសនាដោយខ្មែរគ្លាសនសព្ទ ។ លុះចប់ធម៌ទេសនាហើយ
កងឯកទេសចាប់ផ្តើមលេងភ្លេងពាំរាំតទៀត រហូតដល់មោង ១ យប់
ទើបចប់ ។

(មានត)

បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

របស់គ្រូសូរិធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៧១៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ច័ន្ទ-ញឹម នាមធាយា វជ្ជីរប្បញ្ញោ កើតឆ្នាំឆ្លូវ អាយុ ២៥ វស្សា ៥ ជាចៅអធិការវត្តអង្គរំដួល ឃុំខ្សែត ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧១៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-វន់ នាមធាយា ធម្មជោតោ កើតឆ្នាំវក អាយុ ២៩ វស្សា ១ ជាចៅអធិការវត្តខ្សែត ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧១៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញ៉ែ-ញឹម នាមធាយា សុវណ្ណសរោ កើតឆ្នាំខាល អាយុ ២៤ វស្សា ៤ ជាចៅអធិការវត្តត្រពាំងជា ឃុំពជមន្ទីរ ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧១៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ រ៉ុក-ឃុន នាមធាយា ព្រហ្មត្តេរសរោ កើតឆ្នាំកុរ អាយុ ២៧ វស្សា ៧ ជាចៅអធិការវត្តអង្គស្វាយ ឃុំស្វាយរំពា ស្រុករំដួល ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧២០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ-ពុត នាមធាយា ព្រហ្មសត្តា កើតឆ្នាំជូត អាយុ ៦២ វស្សា ៤១ ជាចៅអធិការវត្តរវៀង ឃុំចាក់ក្តោង ស្រុករវៀង ខេត្តកំពង់ធំ ។-

សញ្ញាប័ត្រលេខ ៧២១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ថោង គិម នាមធាយា ធម្មប្បញ្ញោ កើតឆ្នាំពេង អាយុ ៤៦ វស្សា ២៥ ជាគ្រូសូត្រស្តាំ វត្ត ឃុំ - ស្រុកខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧២៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ិន - ហ៊ី នាមធាយា បញ្ញាវេរ កើតឆ្នាំច អាយុ ២៨ វស្សា ៨ ជាចៅអធិការ វត្តអម្ពវនារាម ឃុំស្វាយជ្រះ ស្រុកស្ទឹង ខែត្រក្រចេះ ។

សញ្ញាប័ត្រលេខ ៧២៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កែ - ជឿត នាមធាយា កសុត្តត្ថេរ កើតឆ្នាំច អាយុ ៣៩ វស្សា ១៩ ជាគ្រូ សូត្រស្តាំ វត្តសិរីសុន្ទរវង្សារាម ឃុំក្រចេះ ស្រុកក្រចេះ ខែត្រដដែល ។.


សញ្ញាប័ត្រលេខ ៧២៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន - សុខ នាមធាយា សុវណ្ណត្ថេរប្បញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៣៣ វស្សា ១២ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧៣៤ ចុះថ្ងៃពុធ ៣ កើតខែមិគសិរឆ្នាំឆ្លូវឯកស័ក ព.ស. ២៤៨២ តាំងលោកគ្រូ សួស - ម៉ី នាមធាយា ព្រហ្មសរោ កើតឆ្នាំថោះ អាយុ ៥៩ វស្សា ៣៩ ជាចៅអធិការ វត្តសុវណ្ណមោលី ឃុំបឹងកន្ធួត ស្រុកក្រគរ ខែត្រពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ៧៣៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ុល - ឡា នាមធាយា ធម្មជោតោ កើតឆ្នាំឆ្លូវ អាយុ ៤៩ វស្សា ២៧ ជាគ្រូសូត្រស្តាំ វត្ត - ឃុំ - ស្រុក - ខែត្រដដែល ។ (មានត)

ភ្នំពេញសន្ទេយ្យា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែកុម្ភៈ លេខ ២

ព. ស. ២៤៨៣ — គ. ស. ១៩៤១



ទស្សនាវដ្តី ផ្សាយដំណឹងខាងអក្សរសាស្ត្រ និងសាសនា
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	បញ្ជីរឿង	ទំព័រ
ការបណ្តុះនិស្ស័យ	ព្រះមហា ប៊ុង ប៉ម	៨៣
សព្ទជាភាសាខ្មែរ (តមក)	លោក ម៉ៃញ - ឆាំត្រី	៨១
រឿងត្រែងភូមា (តមក)	– សាង - សាភ័ត	៩៥
រឿងសាមកុក(តមក)	– ឆួ - កន	១០៣
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)	– ឈឹម - ក្រសែម	១១២
ផ្នែកសាសនា		
ពុទ្ធសាសនានិងគ្រឹស្តសាសនា (សន្ទនា លោកវេដ្ឋបណ្ឌិតមីតូត)	លោក ភ័យ - ប៊ុក	១១៨
ពន្ធអាស៊ីទ្វីប (តមក)	លោក ភ័យ - ប៊ុក	១២២
ចំដ្ឋធម្មិកត្ថកថា	ព្រះទេពសត្ថា សួរ - ហាយ	១២៦
កំណាត់ទំនៃប្រវត្តិការណ៍		
តំណែទូលសម្តេចសង្ឃនាយក ដូន - ណាត នៅវត្តដំណាក់ (សៀមរាប) (តបមក)	ព្រះមហាកែ - អឿន	១៣៩
អនុសាវរីយ៍ព្រះមហាសន្ថាត	ពុទ្ធសាសនបណ្ឌិត្យ	១៥១

មួយឆ្នាំមាន ១២ សៀវភៅ ជាំប្លែងជាវ ..... ១៤^{រ},០០

KAMBUJASURIYA

Revu littéraire et religieuse et éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE LITTERAIRE — Pages

Education morale	*PREAH MOHA PEUNG-PAM* . .	83
Recueil des mots traduits par la Commission Culturelle (sutie) .	*M. MENH-NAKRY*	91
Contes birmans (suite et fin) . . .	*M. SANG-SAVAT*	95
Histoire de SAMROK (suite)	*OKNHA NOU-KAN*	103
Histoire du Royaume du Cambodge (suite	*OKNHA CHHIM-KRASEM* . . .	112

PARTIE RELIGIEUSE

Bouddhisme et Christianisme (Conférence du Docteur Migot)...	*M. RAY-BUC*	118
La Lumière de l'Asie (suite)	*M. RAY-BUC*	122
Dithadhammikathakatha	*PREAH DEBASATTHA SO-HAY*	126

NOTES ET CHRONIQUES

Réception de SON EMINENCE le Chef de la Secte Mohanikay à la pagode de Damnak (Siemreap) (suite et fin).....	*PREAH MOHA KER-ŒUN* . . .	138
Réunion annuelle des religieux du Cambodge.....	*INSTITUT BOUDDHIQUE*	151

Prix d'un abonnement annuel comprenant 12 numéros: 145800

ព្រះមហាឧត្តមវិជ្ជា ជិលញ្ញាណោ ប៊ុង-ប៊ុម
អាចារ្យសាលាចាលីវង្សវត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណាន្តរក្សប្ប ប៊ូនៅពុទ្ធសាសនបណ្ឌិត្យ ពិនត្យកែ

ពាក្យផ្តើម

លោកអ្នកនិទ្ទុក្ខទាំងឡាយ! មុនដំបូង សូមអញ្ជើញអស់លោកប្រមើលមើលពួកមនុស្ស តាមក្រសែពន្ធនឹងក្រសែជាតិ ។ ដ្បិតខ្សែសម្ព័ន្ធនេះ ក្នុងបច្ចាប់សង្គមវិទ្យា មានពោលថា: "មនុស្សយើងជាសង្ឃភូតិ គឺជាសត្វស្រុកដែលត្រូវនៅរួមគ្នាជាពួកជាក្រុម តាំងអំពីជាគ្រួសារ ជាភូមិ ជាស្រុក ជាប្រទេស ហើយត្រូវជាប់ទាក់ទងគ្នាក្នុងការបន្តសមាគមផង, ទំនាក់ទំនងឲ្យនៅតែម្នាក់ឯង ដោយមិនរួមគ្នា ឬមិនជាប់ទាក់ទងគ្នាពុំបាន" ។

មួយទៀត តាមក្រសែជាតិ ដែលអ្នកប្រវត្តិសាស្ត្រសំដែងទុកមកមានគោលថា: "មនុស្សយើងត្រូវជាប់តគ្នាដោយខ្សែលោហិត ឬដោយពន្ធ នឹងដោយលទ្ធិប្រពៃណី ព្រមទាំងទំនៀមទំលាប់ សមគួរនឹងនៅរួមគ្នាជាពួកជាគណៈបាន ដែលហៅថា "ជាតិ", ប៉ើទុកជាបែក

ខ្វែកគ្នាទៅនៅក្នុងទីយ៉ាន់ឆ្ងាយចំផុតក៏ដោយ គង់តែមានលក្ខណៈពាក្យ
សម្បុរនឹងភាសាពាក្យនិយាយ សំដែងឲ្យដឹងថាមានក្រសែជាតិជាប់
លោហិតជាមួយគ្នាដែរ” ។

មនុស្សយើង ជាសត្វប្រសើរ មានលក្ខណៈផ្សេងអំពីសត្វតិរច្ឆាន,
សូម្បីមានការបរិភោគ ការដេក ការសេពមេថុន នឹងការខ្លាចជាធម្មតា
ដូចសត្វតិរច្ឆានក៏ដោយ ក៏គង់តែមានចំណែកពិសេសជាងគ្នាបានទៀត ។
ការបរិភោគមានធម៌, ដេកមានធម៌, សេពមេថុនមានធម៌, ខ្លាចមានធម៌,
នេះឯងជាគុណប្រសើរបស់មនុស្ស ដែលធ្វើមនុស្សឲ្យមានហានៈខ្ពង់ខ្ពស់
ជាងសត្វតិរច្ឆាន ដោយមានគុណធម៌ សេចក្តីគិត សតិប្បញ្ញា ល្អឧឡារ
ខ្ពង់ខ្ពស់លើសជាងសត្វតិរច្ឆាន ព្រោះបេះតាំងខ្លួនឲ្យមានចិត្តបរិសុទ្ធស្អាត
ប្រាសចាកគំនិតថោកទាប, មានចេតនាចង់បានសេចក្តីចំរើនដល់ខ្លួននឹង
មិត្តភ័ក្តិពេញលោក, រៀរាកការចិញ្ចឹមជីវិតដោយបៀតបៀនគ្នា, មិន
ហាន់សាច់ឈាមរបស់មនុស្សផងគ្នា, បេះសម្រាលទម្ងន់, យកចិត្តគេ
មកប្រៀបនឹងចិត្តយើង, យកចិត្តយើងទៅប្រៀបនឹងចិត្តគេ, បន្ទែមហានៈ,
បន្ទែមការពឹងពាក់អាស្រ័យគ្នា, មិនប្រទូសរ៉ាយ, មិនបៀតបៀនគ្នា
ដូចសត្វតិរច្ឆាន ទើបសមនឹងឈ្មោះថាជា “សត្វប្រសើរ” ។

សូម្បីមនុស្សយើង ចូលចិត្តនៅរួមគ្នាជាពួកគណៈ ពាំងចូលចិត្តធ្វើផ្ទះ
ធ្វើភូមិនៅជាមួយជាអនេកអនន្តក៏ដោយ គង់មានមនុស្សខ្លះដែលមាន

ខ្ញុំនឹងនឹងទៅជាមនុស្សល្អប្រពៃត្តសុចរិត មានសង្គមចរិយាចំពោះគ្នានឹងគ្នា ហើយអាចត្រឡប់ប្រពៃត្តទៅជាមនុស្សថោកទាប មិនមានមនុស្សធម៌, គ្រាច់តែទៅបៀតបៀនមិត្តភ័ក្តិផងគ្នាវិញក៏មានខ្លះដែរ, អ្នកខ្លះបង្កជម្លោះជាដែកទាស់ចែងគ្នា ដែលជាហេតុបំបាត់នូវសន្តិសុខនៃពួកគណៈ: មិនគិតបណ្តុះនិស្ស័យល្អទុកជាគ្រឿងការពារខ្លួន បែរជាបណ្តោយចិត្តឲ្យប្រព្រឹត្តបៀតបៀនជនដទៃ ប្រព្រឹត្តកិរិយាមារយាទតាមតំនិតដ៏ថោកទាប, គិតតែប្រយោជន៍ផ្ទាល់ខ្លួន, មិនរមិលមើលទៅខ្លួនអ្នកដទៃផង ។

មនុស្សអាក្រក់ ច្រើនតែនិយាយញុះញង់ ចោកប្រាស ប្រទូសរ៉ាយ បៀតបៀនមិត្តភ័ក្តិផងគ្នានោះ មិនមានគោលអ្វីជាគ្រឿងសំដែងឲ្យយើញថា ផ្សេងអំពីសត្វតិរច្ឆានឡើយ ផ្សេងគ្នាតែរូបកាយប៉ុណ្ណោះ ទើបតាត់ថាជាមនុស្សពេញលីក៏មិនបាន ចាន់ត្រឹមតែថាជាកាកមនុស្សឬមនុស្សអង្គាមប៉ុណ្ណោះ ។ សូមកុំភ្លេចថា "ការខំលាយគោលធម៌សម្រាប់មនុស្សក៏គឺការខំលាយខ្លួនឯង, ព្រោះមនុស្សធម៌ជាគុណដែលមនុស្សគ្រប់រូបមិនត្រូវលះបង់ឡើយ កាលបើនរជនណាមួយ លះបង់មនុស្សធម៌ចេញហើយ សូម្បីក្នុងវេលាណាក៏ដោយ អ្នកនោះ ឈ្មោះថា លះបង់ខ្លួនឯងដែរ" ។ ហេតុនេះ ដើម្បីកុំឲ្យហាន:ជាសត្វដ៏ប្រសើរវេសខ្លួនខុក ជាតិមនុស្សត្រូវតែបណ្តុះនិស្ស័យ ។

និស្ស័យគឺអ្វី? បញ្ហានេះជារឿងដែលយើងគួរដឹងជាដំបូង ។ និស្ស័យនោះជានាមធម៌ ពាក់ព័ន្ធជាសកាពកើតឡើងជាមួយនឹងចិត្ត សឹងស្ថិតនៅ

ក្នុងសន្តានរបស់បុគ្គលឥតមានរូបច្រាកដឡើយ ហើយទៅជាតខាងខ្លួនយើង។ មិនងាយនឹងដឹង សូម្បីយ៉ាងនោះ យើងក៏អាចដឹងបានដោយការសង្កេតនូវសេចក្តីប្រព្រឹត្តផ្សេងៗរបស់មនុស្សជាលក្ខណៈព្រោះកាយនឹងវាចាជារូបធម៌ មានខ្លួនច្រាកដឡើងបាន ។ និស្ស័យរបស់មនុស្ស ដែលយើងនឹងដឹងច្រាកដថា ល្អឬអាក្រក់ ហើយប្រព្រឹត្តក្នុងសណ្ឋានណានោះ រមែងកើតឡើងអំពីការប្រព្រឹត្តផ្សេងៗកាយនឹងវាចារបស់ខ្លួនគេ ដោយមានចិត្តជាអ្នកបង្គាប់ឲ្យកាយវាចាបញ្ចេញនិស្ស័យក្នុងការប្រព្រឹត្តនោះ ។ ចុះអ្វីឈ្មោះថានិស្ស័យ ? គឺយោ អាការរបស់បុគ្គលដែលប្រែប្រួលទៅដោយប្រការផ្សេង ។ នោះឯង ឈ្មោះថា និស្ស័យ ។

ការគិតល្អការធ្វើល្អនឹងការនិយាយល្អ ដែលទៅរកបន្ទៃនៃបុគ្គលក្នុងសន្តានតែងជាសស់តឿនរាល់ថ្ងៃឲ្យមនុស្សគិត ធ្វើ និយាយ តែក្នុងវត្តដែលខ្លួនគាប់ចិត្ត ជាបដល់ការគិត ការធ្វើ នឹងការនិយាយនោះ ក្លាយទៅជាទំលាប់ជាប់ទៅក្នុងសន្តានអស់មួយជីវិត ។ គឺយោបញ្ចេញលក្ខណាការរមែងចង្អុលឲ្យមនុស្សដទៃដឹង - ឃើញបានថា អ្នកនោះធ្លាប់និយាយមានអធ្យាស្រ័យបូលចិត្តទៅក្នុងផ្លូវនោះ។ ជាប្រក្រតី នេះឯង ហៅថានិស្ស័យ ។ តាមគោលក្នុងចិត្តវិទ្យាសាស្ត្រថា: "យើងបណ្តុះការធ្វើយើងនឹងបានផលគឺនិស្ស័យ, យើងបណ្តុះនិស្ស័យ យើងនឹងបានផលគឺ

លក្ខណៈ" ។ នេះសំដែងឲ្យយើញថា: "និស្ស័យនោះកើតមកពីចំលាប់ធ្វើការផ្សេង ។ តែបើធ្វើការតាំងនោះតែមួយដង ក៏មិនទាន់ទៅជានិស្ស័យដែរ លុះតែយើងធ្វើញយ ។ រហូតដល់ភ្ជាប់ ទើបក្លាយទៅជានិស្ស័យបាន ។ ពិតមែន! ចំលាប់ដែលកើតអំពីការធ្វើញយ ។ ដដែល ។ នោះ រមែងកឲ្យកើតជានិស្ស័យតែម្តងបាន ។ និស្ស័យនេះឯង រមែងក្លាយមកជាលក្ខណាភាពរបស់បុគ្គលិក: ។ លក្ខណៈអាក្រក់ល្អរបស់បុគ្គល បានកើតមកអំពីនិស្ស័យអាក្រក់ល្អដែលគេធ្លាប់ណុះឡើង ខុកកន្លងមកជាលំដែតភ្ជាប់ ។ និស្ស័យរបស់មនុស្សយើង គោលដោយកំណើត មានពីរយ៉ាងគឺ:

ពន្ធកម្ម និង បរិវារកម្ម

និស្ស័យដែលមានមកតាមពន្ធកម្ម ជានិស្ស័យជាប់មក អំពីផ្ទុកផ្តាយតាមខ្សែឈាមត្រង់ តឹងជាប់តគ្នាមកតាមលំដាប់ អំពីជីដូនជីតា មាមីង ដែលរួមសែស្រឡាយជាមួយគ្នា, បើជីដូនជីតា មាតាបិតា មាមីង ចោកគាប កូនចៅក៏ចោកគាបទៅតាម បើមេបាជាមនុស្សល្អ កូនចៅក៏ល្អទៅតាមដែរ ដូចគាថាតក្កឯលោកនីតិបករណ៍ថា:

"បើមាតាហិនជាតិកើតបុត្រា បុត្រនោះមានឥឋាការាគាប
បើបិតាហីនជាតិមាត្រទុរភាព បុត្រនោះគាបកិរិយាអាក្រក់ទៅ ។
បើមែ"ម៉ុហីនជាតិតាំងពីនោក់ កូននោះអប់ល្អក្នុងតាំងពីផ្ទៃ
តាំងកិរិយាមារយាទកំហ្មង់សៅ តាមតន្ធង់មែ"ម៉ុផ្ទៃដូចគ្នា ។

ចើមាតាប្រសើរកើតបុត្រា បុត្រនោះមានកាសាពាក្យពីកេះ
ចើមាតាប្រសើរឥតហ្មងមោះ ឯបុត្តនោះប្រែកបកិរិយាពិត ។
ចើម៉ែឧត្តមចាំងពីរពេង្រ កូននោះប្រែកបត្រង់អ្នកសុចរិត
ចាំងកាសាកិរិយាកាពបណ្ឌិត ជានជាមិត្តសប្បុរសក្នុងលោកិយ" ។

និស្ស័យដែលកើតមកអំពីបរិវារកម្មនោះ គឺនិស្ស័យដែលអាស្រ័យដោយការសេពគប់ជាធំ ហើយកើតឡើងជាខាងក្រោយ ។ ការច្រឡូកច្រឡំគ្នាវិកវរ, ការសេពគប់នឹងគ្នាខាល់តែស្មាលស្មិទ្ធ ហើយប្រព្រឹត្តតាម ជាបជាល់ធ្លាប់ស្គាត់ជំនាញក្នុងហេតុនោះ ។ ដែលធ្វើងចូលមកក្នុងជីវិតរបស់ខ្លួន ដោយបានប្រទះឃើញកិរិយាវាចារបស់មនុស្សដទៃ ឃើញបៃបទំនៀមទំលាប់ ច្បាប់ ប្រវេណី មាត្រារបៀប វិន័យរបស់ពួកគណៈ: ព្រមទាំងធ្វើគំនិត សេចក្តីចេះដឹង ការចូលចិត្តរបស់ខ្លួន ដែលមានញយ ។ រឿយ ។ ជាដែល ។ នោះឯង ធ្វើឲ្យកើតជានិស្ស័យ មានឥទ្ធិពលក្នុងជីវិតទៅអនាគត ។

រឿង "ការបណ្តុះនិស្ស័យ" ក្នុងទំនេះ ខ្ញុំមិនបានពោលដល់ទៅការបណ្តុះនិស្ស័យដែលជាឥទ្ធិកម្មទេ សូមពោលសំដៅយកតែការបណ្តុះនិស្ស័យដែលមានមកអំពីវត្តុចោមរោម (បរិវារកម្ម) ម្យ៉ាងប៉ុណ្ណោះ ព្រោះវត្តុចោមរោមដែលបុគ្គលអាចមើលឃើញបាន ហិតបាន លិទ្ធបាន ចាប់កាន់បាន រមែងមានហេតុផលសំខាន់ក្រៃលែងក្នុងផ្លូវបណ្តុះនិស្ស័យ

អាចបណ្តុះមនុស្សឲ្យមានសេចក្តីខ្ជាំងក្លាឡើងបាន, ព្រោះការសមាគម
សេពគប់ ជាបច្ច័យដ៏មានឥទ្ធិពលក្រៃលែងក្នុងកិច្ចការក៏ជាញឹកញាំការ
ប្រព្រឹត្តិទង្វើអធ្យាស្រ័យព្រមទាំងគំនិតចិត្តឲ្យផ្លៀងទៅបានទាំងចំណែកល្អ
ទាំងចំណែកអាក្រក់, សូម្បីអ្នកប្រាជ្ញខាងចិត្តវិទ្យាសាស្ត្រ ក៏បាន
ពន្យល់ថា: "និស្ស័យរបស់មនុស្ស ប្រែប្រួលទៅបាន ដោយអំណាច
វត្ថុដែលនៅជុំវិញខ្លួនច្រើនជាងការដែលជាប់ពន្ធកម្មមកអំពីកំណើត ។

មើលចុះ! ការកើតអំពីបុគ្គលជាន់ខ្ពស់ តែមាតាបិតា
បណ្តាយឲ្យមនុស្សថោកទាប មើលថែទាំអប់រំក្សា, ក៏ពុំជាមនុស្សល្អ
ដែលទទួលជាប់តមកអំពីផ្លូវពន្ធកម្ម មុខជារលាយបាត់អស់ទៅមិនមាន
នៅសល់ឡើយ; សូម្បីបុរាណក៏ពោលទុកថា "ចើលោក - អ្នកឲ្យទាស:
ចំញឹមកូនរបស់ខ្លួនហើយ, ក្នុងទីបំផុត លោក - អ្នកនឹងមានទាស:នៅ
ក្នុងផ្ទះដល់ទៅពីរបួប" ។ ដូច្នេះការសេពគប់មនុស្សអាក្រក់ទើបជាពិជ
បណ្តុះជីវិតក្នុងនិស្ស័យអាក្រក់ ឈ្មោះថាស្រោចជីវិតដោយទឹកក្តៅ
ការសេពគប់មនុស្សល្អ ជាពិជបណ្តុះជីវិតក្នុងនិស្ស័យល្អ ឈ្មោះថា
ស្រោចស្រង់ជីវិតដោយទឹកត្រជាក់ ។

ព្រះពុទ្ធជាម្ចាស់ ទ្រង់សរសើរការសេពគប់មនុស្សល្អថាជាផ្លូវនៃ
សន្តិសុខដ៏ថ្លៃថ្លា, ទ្រង់តិះដៀលការសេពគប់មនុស្សអាក្រក់ថា ជា
គន្ធនៃសេចក្តីវិនាសហិនហោច, ហើយទ្រង់ណែនាំយើងឲ្យស្វាលស្ងួ

ទៅរកតែមនុស្សល្អ ព្រមទាំងឲ្យយកគេជាគំរូ ព្រោះមនុស្សល្អ កាល
យើងសេពគប់ហើយតែងតែដឹកនាំយើងទៅក្នុងផ្លូវល្អ, ទ្រង់ណែនាំយើង
ឲ្យចៀសវាងពីមនុស្សអាក្រក់ ទាំងទ្រង់ហាមប្រាមមិនឲ្យយកគេជា
គួយ៉ាង ព្រោះមនុស្សអាក្រក់នោះ រមែងមានចំណងតែនឹងដឹកនាំយើង
ទៅក្នុងផ្លូវអាក្រក់តែម្យ៉ាង ព្រះនឹងសុភាសិតថា: "គប់ពាលៗ នាំទៅ
រកទុស គប់សប្បុរសៗ នាំទៅរកផល" ។

ពាក្យដែលព្រះ ទូន្មាន ឲ្យផ្តាច់ថា
"បើគប់ប្រាជ្ញ ក្លៀវក្លា គង់ប្រាជ្ញបាន
បើគប់ពាល គង់ពាល នាំសាមាន្យ"
ពោលមកនេះប៉ុន្មាន ពិតឥតឃ្លាត ។

កាលបើនិស្ស័យកើតមកអំពីចំលាប់ធ្លាប់សន្សំខ្លួនហើយ និស្ស័យនោះ
ក៏មានទាំងល្អទាំងអាក្រក់ ។ ការធ្វើសេចក្តីល្អរឿយៗ រហូតដល់ឆ្ងាប់
ដូចជាចំលាប់ក្នុងកាពជាមនុស្សល្អសុភាពទន់ល្អោនស្មោះត្រង់សុចរិត
ធឹងកតញ្ញូជាដើម ក៏បង្កឲ្យកើតជានិស្ស័យល្អតាមចំលាប់នោះ ។ បើ
ចំលាប់ក្នុងផ្លូវអាក្រក់ ដូចជាចំលាប់ក្នុងកាពជាមនុស្សចោកគាប អាក្រក់
រឹងរូស មិនស្មោះត្រង់ ខុច្ចិតនឹងលុបគុណគេជាដើម ក៏បង្កឲ្យកើតទៅ
ជានិស្ស័យអាក្រក់ឡើង តាមប្រែបនៃចំលាប់នោះ ។

អាចបណ្តុះមនុស្សឲ្យមានសេចក្តីខ្លាំងក្លាឡើងបាន, ព្រោះការសមាគម
សេពគប់ ជាបច្ច័យដ៏មានឥទ្ធិពលក្រៃលែងក្នុងកិច្ចខាត់ខាញដឹកនាំការ
ប្រព្រឹត្តិទង្វើអធ្យាស្រ័យត្រមាំងគំនិតចិត្តឲ្យផ្អៀងទៅបានខាំងចំណែកល្អ
ខាំងចំណែកអាក្រក់, សូម្បីអ្នកប្រាជ្ញខាងចិត្តវិទ្យាសាស្ត្រ ក៏បាន
ពន្យល់ថា: "និស្ស័យរបស់មនុស្ស ប្រែប្រួលទៅបាន ដោយអំណាច
វត្តុដែលនៅជុំវិញខ្លួនច្រើនជាងការដែលជាប់ពាក់ព័ន្ធកម្មមកអំពីកំណើត ។

មើលចុះ! ពាក្យដែលកើតអំពីបុគ្គលជាន់ខ្ពស់ តែមាតាបិតា
បណ្តាយឲ្យមនុស្សថោកទាប មើលថែទាំអប់រំក្សា, ភាពជាមនុស្សល្អ
ដែលទទួលជាប់តមកអំពីផ្លូវពន្ធកម្ម មុខជារលាយបាត់អស់ទៅមិនមាន
នៅសល់ឡើយ; សូម្បីបុរាណក៏ពោលទុកថា "បើលោក - អ្នកឲ្យទាស:
ចាញ់មកូនរបស់ខ្លួនហើយ, ក្នុងទីបំផុត លោក - អ្នកនឹងមានទាស:នៅ
ក្នុងផ្ទះដល់ទៅពីរបួ" ។ ដូច្នេះការសេពគប់មនុស្សអាក្រក់ទើបជាពិធី
បណ្តុះជីវិតក្នុងនិស្ស័យអាក្រក់ ឈ្មោះថាស្រោចជីវិតដោយទឹកក្តៅ
ការសេពគប់មនុស្សល្អ ជាពិធីបណ្តុះជីវិតក្នុងនិស្ស័យល្អ ឈ្មោះថា
ស្រោចស្រង់ជីវិតដោយទឹកត្រជាក់ ។

ព្រះពុទ្ធជាម្ចាស់ ទ្រង់សរសើរការសេពគប់មនុស្សល្អថាជាផ្លូវនៃ
សន្តិសុខដ៏ថ្លៃថ្លា, ទ្រង់តិះដៀលការសេពគប់មនុស្សអាក្រក់ថា ជា
គន្ធនៃសេចក្តីវិនាសហិនហោច, ហើយទ្រង់ណែនាំយើងឲ្យស្វាលស្វែ

Blocus = ការចាំទប់ទល់ផ្លូវមិនឲ្យចេញចូល

(១៨ - ៨ - ៥០)

Ministère des Affaires Etrangères = ក្រសួងការបរទេស

Office du Crédit Populaire = មន្ទីរបង្កាសម្រាប់ប្រជាជន

(៥ - ៩ - ៥០)

Discours = សុន្ទរកថា

Causerie = ឆាឆកថា

Allocution = សង្ខ្ចិថា

Conférance = សន្ទិសិទ

Un explorateur = អ្នករុករក (អ្នករុករកអ្វីៗ ដែលមិនទាន់បានស្គាល់)

Le prix de revient = តម្លៃសរុប (ថ្លៃដើមនឹងថ្លៃជាប់បន្ថែមគ្នា)

Résolution = ការសំរេចចិត្ត

(៨ - ៩ - ៥០)

Office National du Tourisme = ជាតិមន្ទីរទេសចរណ៍, ក្រុមការងារបស់ជាតិសម្រាប់ចាត់ការទាក់ទងភ្ញៀវទេសចរ

(១៦ - ៩ - ៥០)

Séisme, Tremblement de terre = រញ្ជួយផែនដីភូមិឆាល

លោកម៉ុញ - ង៉ាគ្រី អតីតតំណាងរាស្ត្រ រួបរួម

(ត១ក)

Otage = ចំណាប់ខ្មាំង

Rançon = តម្លៃលោះ

Rançonner = ចារតម្លៃលោះ

(៨ - ១១ - ៥០)

Tête de pont = ក្បាលស្ពាន (ក្បាលកងទ័ពដែលចាក់ធ្វើនៅត្រើយម្ខាងហើយ)

Couvre-feu = បម្រាមគោចរ (បម្រាមមានកំណែពេលមិនឲ្យដើរទៅមកកងទីដែលត្រូវបែយ័ត្ន)

L'objectif = ទីដៅ(ទីប្រតិបត្តិការដែលអ្នកបញ្ជាការកំណត់ឲ្យ)

Poche = ទ័ពជាប់ចំណោម (ទ័ពដែលជាប់នៅកន្លែងចំណោមរបស់បច្ចាមិត្ត)

Etat satellite = រដ្ឋរណប (រដ្ឋដែលនៅក្រោមឥទ្ធិពលនៃរដ្ឋណាមួយ)

Ministre Résident = អគ្គរាជទូតប្រចាំទី

Chargé d'affaires = ការជារី(ឥ.ការជារិណី)អ្នកទទួលបន្ទុកកាន់កិច្ចការជំនួសទូត
(៣ - ១០ - ៥០)

Valise diplomatique = ហិបទូត (សំបុត្រស្មាមជាដើមដែលផ្ញើទៅតាមផ្លូវទូត)

Valise des diplomates = ហិបអ្នកការទូត (ហិបដែលអ្នកការទូតប្រើប្រាស់ផ្ទាល់ខ្លួន)

Consul marchant = កុងស៊ុលគោចរ (កុងស៊ុលដែលមានស្ថានមិនទៀងទាត់)

Consul de carrière = កុងស៊ុលអាជីព (កុងស៊ុលដែលកាន់ការក្នុងតំណែងកុងស៊ុលជានិច្ចកាល)
(៦ - ១០ ៥០)

Modus Vivendi = កិច្ចសញ្ញាបណ្តោះអាសន្ន

Veto = ទំនាស់

Incompatibilité = ការមិនចុះសំរុង

Symptôme = និមិត្តហេតុ
(១៣ - ១១ - ៥០)

Rénovation = ប្រែក្លាយ (ធ្វើឲ្យបានដាច់ថ្មីឡើងវិញ)

(១៩-៩-៥)

Arboriculture = វប្បកម្ម (ការញ៉ាំងឈើឲ្យចំរើន)

Secours = ជំនួយ (បម្រុងការ)

Aide = ការជួយ, ជំនួយ

Assistance = ការសង្គ្រោះ

Régime = បែប, វិធី, របៀបគ្រប់គ្រង

(២៩-៩-៥០)

Rafle = ការព័ទ្ធចាប់

Amphibie = ថលជលិក: (អ្វីៗដែលប្រព្រឹត្តទៅបាន តាំងលើគោក តាំងក្នុងទឹក) ។

Lettre d'agrément = សារអនុលោម (សារដែលប្រមុខរដ្ឋធ្វើយ៉ាយល់ព្រមឲ្យតាំងទូតបរទេសនៅក្នុងរដ្ឋរបស់ខ្លួន)

Lettre de créance = សារតាំង (សារដែលប្រមុខរដ្ឋតាំងឲ្យទូតកាន់ទៅប្រគល់ចំពោះប្រមុខបរទេស)

Lettre d'exéquatur = សារឧត្តាសនាន (សារដែលប្រមុខរដ្ឋបើកឧត្តាសឲ្យក្នុងស៊ុលបរទេសបំពេញការងារ)

Envoyé extraordinaire = ទ្រែសិតវិសាម័ញ (អ្នកដែលគេបញ្ជូនទៅដើម្បីបំពេញការពិសេសណាមួយ)

ជារឿងនាំឲ្យអ្នកអានចាំងឡាយ អាចជ្រាបបានខ្លះក្នុងជាតិរបស់ព្រះនាង ធម្មជាម្ចាស់សារី ។

រឿងដែលអាចារ្យធំទាន ឲ្យសិស្សស្លាប់

កុងកាលក្រោយនៃដើមសតវត្សនេះបន្តិច នៅក្នុងស្រុកគហបតី (Gahapâti) មានមនុស្សប្លន់នាក់ បរិបូណ៌ទៅដោយកោតសម្បត្តិទ្រព្យធំធេងបញ្ញា ។ ជនចាំង ៤ រូបនេះ ចង់ស្គាលមានមេត្រីនឹងគ្នាយ៉ាងស្មោះស្ម័គ្រហើយយ៉ាងមាំមួនជាទីបំផុត មិនតែប៉ុណ្ណោះ ថែមទាំងបានជួយជ្រោមជ្រែងគ្នាទៅវិញទៅមកយ៉ាងវិសេសវិសាលសព្វខ្លួនផង ។

លុះដល់កាលជាខាងក្រោយមក មិត្តម្នាក់ក៏ស្លាប់ចាត់ចង់ជីវិតទៅ តែបុរសនេះមានកូនប្រុសមួយទៅជាមួយនឹងភរិយារបស់គាត់ម្នាក់ ។ ថ្ងៃមួយស្ត្រីមេម៉ាយនេះនិយាយទៅកាន់បុត្រថា : "កូនស្ងួនសំឡាញ់មាសម្តាយអើយ! ឪពុកអ្នកស្លាប់ចាត់ចង់ជីវិតទៅហើយ ហេតុដូច្នេះមានតែកូនទេ ដែលអាចនឹងកាន់កាប់ការដំនួសជាមេផ្ទះនេះបាន; ចាប់តាំងពីថ្ងៃស្អែកទៅ កូននឹងមានអំណាចពេញលើទ្រព្យសម្បត្តិទាំងអស់, ប៉ុន្តែកូននៅក្មេងសេចក្តីណាស់ កូនមិនទាន់មានសន្តិចរិយានឹងស្មារតី ដែលជាវត្តមួយយ៉ាងសំខាន់នៅនាលោកនេះនៅឡើយទេ, ហេតុដូច្នេះ គាង កូនទៅរកមិត្តសំឡាញ់ទាំងបីនាក់របស់ឪពុកកូន ដើម្បីសុំរៀនដំរេវិជ្ជាពីគេឲ្យបានយូរបន្តិចទៅ"; ថាហើយនាងជាក់ប្រាក់បីរយណែនក្នុងបាតដៃ

កុមារ, លុះចប់ក្រសោចបុត្រយ៉ាងស្និទ្ធស្នាលហើយ នាងឈរមើលកូនដែលដើរចេញទៅ ជាមួយពួកស្រីចាំព្រាវតាមហានៈរបស់នាងជាអ្នកមានទ្រព្យនោះ ។

លុះព្រឹកឡើង កុមារចាន់ជួបនឹងមនុស្សម្នាក់ដឹកឆ្កែតាមផ្លូវ ក៏សួរថា "នែលោកពូ! តើសុខចិត្តលក់ឆ្កែនេះឲ្យខ្ញុំឬទេ? ខ្ញុំមានចិត្តស្រឡាញ់ឆ្កែនេះណាស់" ។ បុរសដឹកឆ្កែតបថា "លក់ បើកយចង់ជាវ ដំឡៃក៏មួយរយណែន" ។ កុមារគ្មានគិតថា "ឆ្កែសំគមនេះថ្លៃលើសប្រមាណ" ដូច្នោះទេ ចានប្រគល់ប្រាក់គ្រប់ចំនួន គ្មានចេញស្តីអ្វីមួយម៉ាត់សោះ ហើយបង្គាប់ចាវម្នាក់ឲ្យយកឆ្កែនោះមកប្រគល់ឲ្យមាតា ។ រីឯមាតាឃើញឆ្កែដំបូងកាន់ស្អាតតើ ប៉ុន្តែដល់គិតឃើញថា "ប្រហែលជាមិត្តភ័ក្តិរបស់ប្តីនាងបានជួយទិញជូរផង" នាងក៏ទុំយកចិត្តទុកជាក់ចិញ្ចឹមឆ្កែនេះយ៉ាងម៉ត់ចត់ជាទីបំផុត ។

ថ្ងៃក្រោយមកទៀត លុះបរិភោគបាយរួច កុមារដើរលេងម្នាក់ឯងតាមផ្លូវ បានជួបនឹងមនុស្សម្នាក់ដែលមានកូនឆ្មាតូចមួយ ក៏សួរថា "នាយលក់ឆ្មាខ្ទុះឬទេ? ។ គេឆ្លើយថា "ខ្ញុំចង់លក់ណាស់ ខ្ញុំលក់ថ្លៃមួយរយណែនច្រាក់" ។ កុមារក៏ទិញជូចកាលពីមុន រួចបញ្ជូនឆ្មានោះមកឲ្យម្តាយឯផ្ទះ ។ នារីចេះតែនឹកស្មានថា "បុត្រទិញជូរនេះ ដោយមានមិត្តរបស់ស្វាមីនាងជួយមើលការខុសត្រូវផង" ហើយនាងក៏បានថែរក្សាឆ្មានោះដោយយកចិត្តទុកជាក់ជូចឆ្កែដែរ ។

នៅចុងក្រោយបង្អស់ ក្នុងថ្ងៃមួយនោះ ម្ចាស់នេះគឺសត្វក្រមៀត ដែលកុមារបានជួបប្រទះក៏សួរដូចមុន គេឆ្លើយក៏ដូចមុនថា "ថ្ងៃមួយរយណែន" ។ កុមារក៏ទិញបញ្ជូនក្រមៀតមកផ្ទះដូចមុន ។ ឯមាតាក៏ចិញ្ចឹមក្រមៀតដូចសត្វទាំងពីរមុននោះទៀត ។

ឯឆ្កែនឹងឆ្មាជាសត្វស្រែក នាងបានយកមកទុកក្នុងផ្ទះ ដោយគ្មានកិតក័យ ។ ប៉ុន្តែក្រមៀជាសត្វរៃ នាងមិនហ៊ានទុកជិតផ្ទះទេ នាងទុកក្នុងសួនច្បារ នាងខ្វាចសត្វនេះណាស់ ថ្ងៃបើវានៅស្ងៀមស៊ីតែស្មៅ ។ នាងខ្វាចទៅជាស្គមខ្លួន ។

ថ្ងៃមួយ មានបព្វជិត (អ្នកបួស) មួយរូបដែលចេះធ្វើគ្រូអាចារ្យ យ៉ាងពិសេស គ្រងចីវរពណ៌លឿងនិមន្តមកបិណ្ឌបាត បានឃើញនាងស្គមដូច្នោះក៏សួរថា: "ញោមសិកាឈឺឬអ្វី? ឯឈឺនេះមកអំពីហេតុអ្វី?" រួចលោកក៏បានរំដោះគ្រោះថ្នាក់ដោយការសូត្រសីលប្រាំឲ្យនាងទទួលតាម គឺសីលស្តីអំពីទ្រព្យសម្បត្តិ, យសស័ក្តិ, កេរ្តិ៍ឈ្មោះ, សេចក្តីសុខ និងសីលទាំងបួនដែលមានន័យផ្ទុយអំពីនេះ ។ ស្ត្រីមេម៉ាយបានបង្គំទូលតបវិញថា: "សូមព្រះគុណាជាម ខ្ញុំព្រះគុណាមិនស្រួលខ្លួននេះ មកអំពីបានឲ្យប្រាក់ចំនួនបីរយណែនទៅកូនប្រុសរបស់ខ្ញុំព្រះគុណា ដើម្បីឲ្យវាទៅរកភ្ជើមាស់របស់ខ្មាចឧត្តុកក ហើយឲ្យវាសុំរៀនវិជ្ជាផ្សេងៗពីគេ ថ្ងៃមួយនោះវាបញ្ជូនឆ្កែមកឲ្យខ្ញុំព្រះគុណា ថ្ងៃមួយទៀត

ឆ្នាំ, ថ្ងៃក្រោយទៀតក្រមីព្រៃ ដាំឡសត្វនីមួយៗ មួយរយណែនថ្កាក់; ឯឆ្អែនឆ្នាជាសត្វស្រុក ខ្ញុំព្រះករុណាមិនខ្វាចទេ, ប៉ុន្តែក្រមីព្រៃជាសត្វកាចសាហាវ ខ្ញុំព្រះករុណាឃើញកាលណា មានចិត្តគិតភ័យញ័រអស់ទាំងខ្លួនថ្កាណ, មួយទៀតដោយសារតែកូនខ្ញុំក៏ស្រឡាញ់សត្វទាំងបីនេះពេកទៅ ខ្ញុំព្រះករុណាក៏ធ្វើព្រងើយមិនកើត" ។

កន្លងពេលនោះ លោកសង្ឃបានខ្ជួនានាឲ្យលែងក្រមីព្រៃ តាមធម៌ព្រះពុទ្ធ ។ នាងក៏បានលែងសត្វនេះឲ្យទៅកន្លែងព្រៃ ហើយបានទាំងឲ្យចំណីដល់ក្រមីព្រៃនេះស៊ីកន្លះពាងមួយធំផង ។

ឯក្រមីព្រៃបានបរណ្តាយឲ្យនាងធ្វើតាមអំពើចិត្ត, លុះទៅដល់កន្លែងព្រៃជ្រៅវេលាណាក៏គិតថា: "កូនមហាសេដ្ឋីបានទិញអញមកថ្ងៃមួយរយណែន, តាំងអំពីអញទៅនៅជាមួយនឹងគេៗបីបាច់ចិញ្ចឹមអញយ៉ាងម៉ត់ចត់; មួយទៀត ដោយសារតែម្តាយគេបានជាអញរួចខ្លួនជាអ្នកជាហេតុជួនេះត្រូវអញរកមធ្យោបាយណាមួយ ដើម្បីសងគុណគេ ព្រោះគេបានធ្វើល្អនឹងអញនេះ" ។

លុះគិតយូរបន្តិចទៅ ក្រមីព្រៃយកមាត់ទាំចិញ្ជើនពេជ្រមួយវង់ទៅជិតគល់ឈើ ដែលទៅគាបានធ្វើឲ្យបាត់កណ្តាលព្រៃ រួចតាំយកមកឲ្យបុរសជាចៅហ្វាយ[1] ហើយនិយាយថា: "លោកចូរយកចិញ្ជើននេះ

---

1 កុមារដែលទិញក្រមីព្រៃអំពីមុន ។

ទៅចុះ ខ្ញុំជូនលោក, ឯចិញ្ចៀននេះមិនដូចអស់ចិញ្ចៀនផងទាំងពួងទេ គឺចិញ្ចៀននេះមានឥទ្ធិវិធីយ៉ាងពូកែណាស់ គ្រាន់តែយកទៅផ្គុតនឹងរបស់អ្វីមួយ អាចកើតរបស់ផ្សេងៗតាមបំណងដល់ម្ចាស់ចិញ្ចៀននេះបាន ចូរទៅហ្វាយម្ចាស់ពាក់ចិញ្ចៀននេះនៅម្រាមដៃទៅចុះ ហើយប្រុងប្រយ័ត្នកុំឲ្យចិញ្ចៀននេះទៅអ្នកឯណាសោះ" ។ ថាហើយក្រមីព្រៃក៏ឆ្លងចូលទៅក្នុងព្រៃជ្រៅវិញបាត់ទៅ ។

លុះបានចិញ្ចៀននោះមក បុរសនោះបានពាក់នៅម្រាមដៃចំពេញបំណងរបស់ខ្លួន, រួចមានភក្តីមួយនោះ បានកូតឲ្យកើតជាប្រាសាទមួយយ៉ាងល្អឆើតឆាយ ប្រកបដោយដំបូលប្រាំពីរជាន់ នៅចំពីមុខគេហដ្ឋានរបស់ខ្លួន ។

បុរសបាននាំទាសាទាសីឡើងទៅនៅក្នុងប្រាសាទនោះ, ក្រោយមកមានអ្នកដឹងខាងផងទាំងពួង មកជុំកុះករមើលវិចិត្រវិចនានៃប្រាសាទនេះ, ក្នុងបណ្តាពួកអ្នកមើលនោះ មានព្រះមហាកសត្រិយ៍ នឹងព្រះពុទ្ធបុត្រីព្រះអង្គផង ។ បុរសបានរៀបចំទទួលព្រះមហាកសត្រិយ៍យ៉ាងឧឡារិក ។ ព្រះរាជាទ្រង់សព្វព្រះពុទ្ធហឫទ័យនឹងបុរសម្ចាស់ប្រាសាទជាខ្លាំងផុត រួចទ្រង់លើកបុត្រីឲ្យមកបុរសនោះធ្វើជាអគ្គមហេសី ។

លុះកន្លងអំពីពេលដ៏ក្សេមក្សាន្តនេះបន្តិចមក លោកសង្ឃដែលជាគ្រូអាចារ្យរបស់ម្តាយបុរសនោះ បានធ្វើទុក្ខយកលថា មកទេសនា

នៅក្នុងប្រាសាទ ។ ព្រោះលោកចង់ដឹងថា: តើបុរសមានគ្រឿងអ្វីមួយក៏ពូកែដល់ម្ល៉េះ អាចបង្កើតជាប្រាសាទមួយយ៉ាងល្អស្អាតស្តុកស្តម្ភភ្លាមៗយ៉ាងដូច្នេះ ។ ឯលោកសង្ឃនេះជាមនុស្សទុច្ចរិតយោរយៅ ស្ទើរតែពាក់តាមបៃបលោកសង្ឃ ដែលគេតែងជួបច្រទេះនៅនាលោកនេះ ។

លោកសង្ឃធ្វើតវកនុកាសដែលបុរសមិននៅ ដើម្បីចូលមកកន្លែងប្រាសាទ ។ លុះបាននុកាសហើយ ក៏ចូលមកនិយាយបញ្ឆោះបញ្ឆោតកិរិយារបស់បុរសអស់កាលជាយូរហើយទើបសួរថា "តើប្តីនាងស្រឡាញ់នាងមែនទែនឬអ្វី?" ។ នាងឆ្លើយថា "ម្តេចព្រះគុណ មានពុទ្ធដីកាយ៉ាងដូច្នោះ? ប្តីខ្ញុំព្រះករុណា គ្រាន់តែជាកូនមហាសេដ្ឋីប៉ុណ្ណោះទេ ឯខ្ញុំព្រះករុណាជាបុត្រីស្តេចផែនដី, ហេតុដូច្នេះ ការណ៍ដែលខ្ញុំព្រះករុណាទទួលធ្វើជាប្រពន្ធនេះ បង្ហាញឲ្យឃើញថា ខ្ញុំព្រះករុណាស្រឡាញ់គេយ៉ាងពេញចិត្តជាទីបំផុត ចំណែកខាងគេជាប្តីនោះ គេក៏ស្រឡាញ់ខ្ញុំព្រះករុណា យ៉ាងខ្លាំងដូចគ្នាដែរ" ។

លោកសង្ឃឆ្លើយថា "បើប្តីញោមស្រឡាញ់ញោមជាទីបំផុតយ៉ាងដូច្នេះ តើគេមានដែលឲ្យញោមពាក់ចិញ្ចៀនម្តងណាឬទេ?" ។ នាងឆ្លើយវិញថា "ទេ គេមិនដែលឲ្យខ្ញុំព្រះករុណាពាក់ទេ ប៉ុន្តែខ្ញុំព្រះករុណាមិនដែលសុំពាក់ផង" ។ លោកសង្ឃលុះបានឮដូច្នោះហើយ ក៏អស់

សង្ឃ័យ ហើយថយខ្លួនទៅវិញភ្លាម ។ ក្នុងកាលណោះគ្រាប់អាសិរពិស
ចាប់ពន្ធកដុះហើយ ។ ព្រះកិក្កីសង្ឃក៏ដឹងចិត្តស្ត្រីជាស្រេច ។

មួយថ្ងៃឬពីរថ្ងៃក្រោយពេលដែលពិភាក្សានេះ នារីបានសុំស្វាមី
ពាក់ចិញ្ចៀនដែលមានត្បូងពេជ្រតាំងគ្រាប់ចាំងចិញ្ចែងខ្លុះម្តង ។ ឯ
ស្វាមីដោយស្រឡាញ់ភរិយាពេក ហើយដោយមិនចង់ឲ្យនាងអាក់ចិត្ត
ក៏ខ្ចីឯណា ក៏បានហូតចិញ្ចៀនពីម្រាមដៃ ហើយយកទៅសិក្សានៅដៃ
នាងហើយផ្តែផ្តាំហាមផ្តាច់ កុំឲ្យទៅអ្នកឯណាមួយឲ្យសោះ គឺឲ្យពាក់
ជាប់នឹងដៃជានិច្ច ។

ថ្ងៃមួយនោះ បុរសមិននៅ លោកសង្ឃចូលមកក្នុងផ្ទះបាសាទម្តង
ទៀត ហើយនិយាយបញ្ចុះបញ្ចូលនាងសព្វគ្រប់ប្រការ ។ ឯនាងក៏
រីករាយក្នុងចិត្តហើយនិយាយថា: "ទានព្រះ! នេះចិញ្ចៀនដែលព្រះ
តេជព្រះគុណមានព្រះពុទ្ធដីកាពីថ្ងៃមុននោះ ខ្ញុំព្រះករុណាយកមកពាក់
នៅម្រាមដៃ" ។ កិក្កីនោះសួរដោយត្រេកអរថា: "ឯណាចិញ្ចៀន
នោះ?" ។ នាងក៏បង្ហាញចិញ្ចៀនដ៏មានត្បូងក្លឹរន្ធាលឲ្យកិក្កីនោះមើល ។

លោកសង្ឃក៏អង្វរនាងឲ្យដកចិញ្ចៀនដ៏វិសេសនោះ ពីម្រាមដៃ
យកមកមើលឲ្យជាក់មួយស្របក់ ព្រោះមានគេតែងសរសើរចិញ្ចៀននេះ
គ្រប់គ្នាក្នុងព្រះរាជអាណាចក្រ ហើយព្រោះគ្មានស្ត្រីឯណាមួយមាន
ពាក់ក្នុងលោកនេះ ។ (មានត)

កណ្ឌទី ៨

អ្នកឧកញ៉ាវិបុលរាជសេនា ទូ-កន ប្រៀបរៀង

(តទៅ)

រឿងសាមកុកទុកជាយទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ទំងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ចាប់តាំងពីលីឈយ, គុយគី, តៀវចេនឹងហួនតៀវ ធ្វើសំបុត្រទៅដាំរបអងអ៊ុន រហូតដល់តៀវយីលើកទាហានទៅសម្ងាប់ចោកៃដាអាពុកចោធោ ។

ឯលីឈុយ, គុយគី, តៀវចេនឹងហួនតៀវជាសេនាតាំងតុះ ដែលតត់ទៅនៅស្រុកសៀងសៃនោះ ប្រឹក្សាគ្នាធ្វើជាសំបុត្រចាត់បំរើឲ្យកាន់ចូលមកដាំរបអងអ៊ុន សេចក្តីថា "យើងខ្ញុំបានទៅនៅជាពួកបក្សតាំងតុះនោះ ដោយសេចក្តីចាំបាច់ មិនបានគិតយកជាទីពឹងអស់ហើយទេ ទោសយើងទាំង ៤ នាក់ដែលយើងធ្វើទៅហើយសូមលោកអភ័យចុះ ឥឡូវនេះយើងខ្ញុំសូមសំអាងខ្លួនឆឹងចូលមកនៅធ្វើជាការឆឹងលោកតទៅ" ។

អង្គអ៊ុនទទួលសំបុត្រមើលដឹងសេចក្តីហើយនិយាយទឹងចំរើថា ដែលតាំងតុ:ធ្វើការអាក្រក់ពីព្រោះតែលីឈុយ គុយតី តៀវចេនឹងហួនតៀវឥឡូវនេះ បើមានព្រះតម្រាស់ឲ្យលើកទោសមនុស្សតាំងអស់បាន យើងត្រូវព្រមតាម តែឯលីឈុយ គុយតី តៀវចេ នឹងហួនតៀវ នោះយើងនឹងទៅសុំអនុញ្ញាតយកខ្លួនមកសម្លាប់ចេញឲ្យបាន" ។ បំរើកាន់សំបុត្រក៏លាត្រឡប់ទៅជ្រាប់លីឈុយ គុយតី តៀវចេ នឹងហួនតៀវតាមពាក្យនោះ ។ ឈ្មោះតាំង ៤ នាក់ប្រឹក្សាគ្នាថា ដែលយើងនឹងទៅចុះចូលទៅនឹងអង្គអ៊ុននោះ មិនសម្រេចតាមប្រថ្នាទេ បើដូច្នេះត្រូវតែយើងជោះខ្លួនរៀងខ្លួនឲ្យរួចទៅចុះ ។

ឯការសៀងជាទីប្រឹក្សាឆ្លើយឡើងថា យើងនឹងគិតរត់ចៀសចេញទៅនោះក៏មិនផុត សុំឲ្យគិតបញ្ចុះបញ្ចូលអ្នកស្រុកសៀងសៃបានជាពួកហើយ លើកកងទ័ពទៅវាយយកស្រុកតៀងហានវិញ បើបានស្រុកនោះហើយត្រូវតែចាប់សម្លាប់អង្គអ៊ុនចេញ លោកតាំងបួននាក់នឹងបានធ្វើរាជការក្នុងស្រុកក្រុងតទៅ បើគិតដូច្នេះហើយមិនសម្រេចដូចគំនិតទេ សុំនាំគ្នារត់ចៀសចេញទៅចុះ ។ លីឈុយ គុយតី តៀវចេនឹងហួនតៀវស្តាប់ហើយឃើញត្រូវផង ក៏ទៅចាត់ចែងរើសទាហានដែលមានសតិបញ្ញាឲ្យចេញទៅបញ្ចុះបញ្ចូលពួកអ្នកស្រុកសៀងសៃថា ឥឡូវនេះអង្គអ៊ុនបានជាធំក្នុងស្រុកក្រុងហើយ ប៉ងនឹងលើកទាហានមកសម្លាប់អ្នកស្រុកនេះ ដែល

ជាអ្នកគ្មានកំហុសឲ្យអស់ ដោយឃើញកំហុសដូច្នេះ ទើបលីឈុយឲ្យ
យើងមកបញ្ចុះបញ្ចូលអ្នកស្រុកនឹងក្រៅស្រុកទាំងអស់គ្នា បើអ្នកឯណា
ស្រឡាញ់ជីវិតខ្លាចអង្គអ៊ុននឹងសម្លាប់ ត្រូវប្រញាប់ឲ្យចូលមកនឹងយើង
ទើបរួចភ័យអន្តរាយ ។ ឯអ្នកស្រុកសៀងសៃកាលបានដឹងសេចក្តីដូច្នោះ
ក៏ភ័យជាម្តងខ្លាចស្លាប់ ទើបនាំគ្នាប្រញាប់ចុះចូលមកជាពួកលីឈុយ
គុយតី តែវិលចេនឹងហួនតែវិលក៏ជាបួនកង លុះទៅដល់កណ្តាលផ្លូវ
ប្រទះនឹងនីវហ៊ូជាកូនប្រសាគាំងតុ: លើកទាហាន ៥០០ នឹងចូលទៅ
សង្គ្រាមអង្គអ៊ុន ។ នាយទ័ពទាំង ៤ កងចាត់ឲ្យនីវហ៊ូជាមេទ័ពស្លួច
ហើយលើកទៅដិតដល់ស្រុកតៀងហាន់ ។

ឯអង្គអ៊ុនកាលបើបានដឹងដំណឹង ជាមានកងទ័ពលើកទៅដិតទីក្រុង
ហើយប្រឹក្សានឹងលីចាំ"ថា ដែលលីឈុយ គុយតី លើកទ័ពមកគ្រានេះ
តើយើងនឹងគិតការដូចម្តេច? ។ លីចាំ"តបថា "លីឈុយ គុយតី
លើកមកនេះ លោកកុំរវីតក្តីឡើយ ការនេះជាធុរៈលើខ្ញុំ" ហើយ
ឲ្យលីសុកលើកទាហានចេញទៅតទល់ ។ កាលលីសុកលើកទ័ពទៅនោះ
បានជួបប្រទះនឹងទ័ពនីវហ៊ូ បានតយុទ្ធគ្នាជាមាំមួន ។ នីវហ៊ូឃើញកំឡាំង
នឹងតទល់ពុំបាន ក៏នាំទាហានថយទ័ពត្រឡប់ទៅក្រោយវិញ ។ លីសុក
ក៏មានចិត្តកំរើកឲ្យទាហានទៅនៅជុំគ្នា មិនបានបំបែកឲ្យត្រួតត្រាតាម
របៀបទ័ព ។ នីវហ៊ូឃើញលីសុកប្រហែសការ, ដល់ពេលយប់យាមពីរ

កំលើកទាហានវាយបំពានទ័ពលីសុក សម្ងាប់ទាហានបានជាច្រើន ។ លីសុកក៏តត់រួចទៅបាន ទើបនាំយកសេចក្តីដែលបានធ្វើសង្គ្រាមនោះ ប្តឹងចូលទៅដល់លីចោ" ។ ដំណើរយ៉ាងណាស់ ក៏បង្គាប់ឲ្យយកខ្លួនលីសុកចូលទៅកាត់ក្បាលដោតនៅមាត់ទ្វារស្រុក ។

លុះវេលាព្រឹកឡើង លីចោ"លើកទាហានទៅតយុទ្ធនឹងនីវហ៊ូ។ បែកទ័ពត្រឡប់តត់រួចទៅ ។ នីវហ៊ូក៏ប្រឹក្សានឹងអៀសុកយីថា លីចោ"នោះមានកំឡាំងខ្លាំងពូកែណាស់ យើងតស៊ូនឹងគេពុំបានទេ បើដូច្នេះត្រូវតែគិតរត់ទៅទៀត ។ អៀសុកយីបានស្តាប់ហើយក៏យល់ព្រមផង, ដល់ពេលអធ្រាត្រស្ងាត់ នីវហ៊ូរៀបចំមូលយកទ្រព្យរបស់ផងខ្លួនដែលមានដំឡៃហើយនាំអៀសុកយីនឹងទាហានដែលស្មគ្គ ៤ - ៥ នាក់រត់ទៅដល់មាត់ស្ទឹង ។ អៀសុកយីប្រែចិត្តក្បត់សម្ងាប់នីវហ៊ូស្ងាប់ ហើយយកទ្រព្យរបស់ទាំងអស់នោះ នាំពួកទាហាន ៤ - ៥ នាក់ទឹងក្បាលនីវហ៊ូទៅឲ្យលីចោ"ក្នុងក្រុងតៀងហាន់ ។ លីចោ"ឃើញដូច្នោះក៏ទឹកសង្ស័យនឹងអៀសុកយីណាស់ ក៏លបសួរមនុស្សដែលទៅជាមួយថា តើតហេតុដាស់ខែងគ្នាដូចម្តេចបានជាអៀសុកយីសម្ងាប់នីវហ៊ូ ។ មនុស្សពួកនោះឆ្លើយឲ្យការតាមដំណើរសព្វគ្រប់ ។

លីចោ"បានស្តាប់ហើយទឹងណាស់ថា "អៀសុកយីជាមនុស្សលោភមិនមានសេចក្តីសុចរិតពិតត្រង់ នឹងចិញ្ចឹមទុកជាគ្នាក៏ពុំបាន" ទើបបង្គាប់

ឲ្យគាហានចាប់អៅសុកយីនាំទៅសម្លាប់ ។ ឯលីចោ"ចាត់ចែងគាហាន កងទ័ពលើកទៅប្រទះនឹងទ័ពលីឈុយ គុយគី តែវាចេនឹងហួនតែវ កំប៉ាសេះនាំពលគាហានចូលច្បាំងតគ្នា ។ កងទ័ពលីឈុយ គុយគី តែវាចេនឹងហួនតែវមិនទាន់ប៉ានត្រៀមខ្លួនក៏បែកភ្ញាក់ភ្ញាយអស់ទៅ រត់តាមផ្លូវប្រហែល ៥០០ សិន (២០ គីឡូម៉ែត្រ) ដល់កំមួយក៏បង្គាប់ឲ្យកបន្ទាយយា"ងមាំមួននៅទីនោះ ។ លីឈុយទើបប្រឹក្សានឹងគុយគី តែវចេនឹងហួនតែវថា "លីចោ"នោះមានថ្វីដៃខ្លាំងពូកែណាស់ តែជាអ្នកមិនមានដំរេះប្រាជ្ញាឆ្លាត យើងនឹងគិតៗបាយឲ្យគុយគីឃុំគាហានទៅចាំស្កាត់ផ្លូវដែលនឹងចូលទៅក្នុងស្រុក បើកាលណាយើញទ័ពលីចោ"យើងត្រូវតយុទ្ធជាកលបញ្ឆោត បើប៉ានឮសំឡេងគង់ឃ្មោះវេលាណាឲ្យបរពលចូលច្បាំង បើឮសំឡេងស្គរវិតឲ្យថយគាហានទៅក្រោយ ឯតែវចេ, ហួនតែវឲ្យលើកគាហានបំបែកគ្នាទៅរយៈលាយស្រុកតែងហាន់ជា ២ ផ្លូវ បើធ្វើដូច្នេះយើញថាលីចោ"នោះនឹងច្បាំងតទល់មុខក្រោយមិនទាន់ការនឹងខ្ចប់អសារដល់ពួកយើងជាប្រាកដ ។ គុយគី តែវចេនឹងហួនតែវយល់ឃើញត្រូវ ក៏លើកគាហានចេញទៅតាមពាក្យលីឈុយ ។

គ្រានោះ លីចោ"លើកទ័ពទៅដល់ប្រហាកច្រកភ្នំប្រទះនឹងកងទ័ពលីឈុយចូលប្រយុទ្ធគ្នាជាកោលាហល ។ លីឈុយឲ្យរ៉ាយស្គរវាយទ័ពត្រឡប់ឡើងទៅលើភ្នំ, លីចោ"បង្ខំដេញចូលទៅ ស្រាប់តែគាហាន

លើឈុយថាញ់ធ្លាចោលដុំថ្មទម្លាក់ចុះមកដូចគ្រាប់ក្រៀង, លើចោ"ក៏ឲ្យ
ពាហានថយមកគ្រោយវិញ ។

ឯទ័ពគុយគីដែលនៅពីគ្រោយបានឃើញដូច្នោះ ឲ្យវាយគងឃ្មោះ
លើកពាហានបង្កើនចូលទៅទៀត, លើចោ"ឲ្យបែមុខទ័ពត្រឡប់មកតទល់,
គុយគីឲ្យវាយស្គរពីលើភ្នំហើយនាំពាហានចុះមកវិញ ដេញពាហានឲ្យ
វាយពីខាងគ្រោយបណ្តាយទៅ, ទ័ពលើចោ"ក៏នៅជាកណ្តាល ។ តាំងពី
កងទ័ពលើឈុយគុយគីខ្លាប់ទ័ពលើចោ"នៅទីនោះ ចំនួន ៣ យប់ ៣ ថ្ងៃ ។
លើចោ"ក៏បែរតទល់ចាំងមុខនឹងគ្រោយវិលទៅដុំវិញមិនដឹងជានឹងវាយចំលុះ
ទៅខាងណាបាន ខ្លួលមានបំរើសេះចេះជ្រែតជ្រែកជែងចូលទៅថ្កាប់
លើចោ"ថា ឥឡូវមានកងទ័ពតៀវចេនឹងហួនតៀវលើកចូលទៅច្បាំងចំ-
លាយយកទីក្រុងតៀងហាន់ ហើយសុំឲ្យលើចោ"លើកទ័ពទៅជួយជាប្រ-
ញាប់ ។ លើចោ"គិតនឹងទៅជួយខាងស្រុកក្រុងទើបឃុំនាំពាហានស្ទុះបំពាន
វាយចំលាយចេញទៅបាន ។ ឯលើឈុយ គុយគីលើកទ័ពតាមទៅទៀត,
លើចោ"មិនមានញាញើតដៃសោះ បែរមកតទល់ទ័ពចាំងអស់ពីគ្រោយ
ហើយស្រុតទៅមុខ លុះទៅដល់ដិតស្រុកក្រុងឃើញពាហានតៀវចេនឹង
ហួនតៀវឡាមព័ទ្ធ, ឯលើចោ"នោះមិញចូលទៅប្រយុទ្ធឥតរួញរា តែ
ពាពាហានលើចោ"វិនាសស្ងាប់ជាច្រើនណាស់ ខ្លះរត់ចូលទៅនៅខាងកង
ទ័ពតៀវចេ ហួនតៀវជាច្រើន លើចោ"ឃើញដូច្នោះនឹកតូចចិត្តណាស់
ទើបនាំពាហានដែលសល់នៅវិលវល់ក្នុងចំណោមទ័ពត្រប់ ២ - ៣ ថ្ងៃ ។

ឯលីបង អង់ហង់តាំង ២ នាក់ជាបក្សពួកតាំងតុ:នៅក្នុងស្រុកតៀង-ហាន់ កំណាន់ចិត្តគិតស្អប់អង់អ៊ុនណាស់ គិត១ថ្ងៃយជាកលសឹកលើកតាហានរបស់ខ្លួនទៅពួនបើកមាត់ទ្វារតាំង ៤ ទិស ទម្លួយកកង់ឡតលើឈុយ គុយគី តៀវចេនឆីហួនតៀវឲ្យចូលទៅបាន ។ លីចុ៉ាក៏ស្ទុះបំពានលឿនទៅមុខតាំងតែចាក់កាប់សម្លាប់កង់ឡតលើឈុយ គុយគីស្លាប់ពីការជាច្រើនណាស់ ហើយត្រឡប់លើកតាហានរបស់ខ្លួនប្រហែល ១០០ ថ្ងៃយពារំលាយចូលទៅដល់ទ្វារព្រះពាជកំង ជួបនឹងអង់អ៊ុនហើយ. និយាយថា សង្គ្រាមម្តងនេះធំលើសលប់ពេកណាស់ បើយើងនឹងនៅតទល់នោះ ឃើញលើសហួសកំឡាំង សូមលោកស្រួតប្រញាប់ឡើងសេះរត់ឲ្យរួចតែខ្លួនទៅសិនចុះ ក្រោយពីនេះសុំគិតការតទៅ ។

អង់អ៊ុនតបថា ពីដើមខ្ញុំនឹងអ្នកគិតគ្នានឹងទំនុកបំរុងផែនដីឲ្យបានសេចក្តីសុខក្សេមក្សាន្ត, សេចក្តីដែលគិតនោះបានសមដូចប្រាថ្នាហើយតែឥឡូវកើតហេតុឡើងទៀតព្រោះពួកតាំងតុ: ដែលយើងនឹងលះបង់ចោលស្រុកក្រុងតែយកតែខ្លួននោះមិនគួរសោះ ទោះនឹងស្លាប់ក៏គួរយកសេចក្តីត្រូវទុកជាខាងមុខ ចំណែកលោកបើនឹងទៅក៏ទៅចុះ តែត្រូវជួយយកសេចក្តីទៅប្រមាណប្រាប់ដល់បណ្តាចៅហ្វាយខែត្រខាងក្រៅថា យើងសូមគំនាប់មក ដ្បិតសម័យនេះកើតហេតុក្នុងស្រុកក្រុងជាច្រើនណាស់ ឲ្យចៅហ្វាយខែត្រខាងអស់យកចិត្តទុកជាក់ជួយទំនុកបំរុងផែនដីលើកកង់ឡត

មកជួយកំចាត់សត្រូវពាជសម្បត្តិឲ្យអស់ចេញ ។ លីចោ"ចានឮដូច្នោះ
ក៏និយាយបញ្ចុះបញ្ចូលបបួលអង្គអ៊ុនជាច្រើនដង អង្គអ៊ុនក៏មិនព្រមទៅ
ទទួលត្រឡែកឃើញពន្ធីភ្លើងឆេះឡើងគ្រប់តំបន់ដែលសត្រូវចូលទៅដុត
លីចោ"ភ័យរន្ធត់រត់ចោលអស់គ្នាសារឡើងដំរះនាំសេនាគាហានប្រ-
ហែល ១០០ ចាយចេញទៅដល់អូនសុតនៅស្រុកឡាំយ"ង, ឯអង្គអ៊ុន
ក៏ចូលទៅក្នុងព្រះពាជវាំង ។

ខណៈនោះ លីឈុយ គុយគី តៀវចេ ហួនតៀវ ដែលហែកទ្វារ
ស្រុកចូលទៅក្នុងទីក្រែងនោះ កាប់សម្លាប់នាហ៊ឺនមុខមន្ត្រីនៅអាណា
ប្រជានុកស្តេរបួសពិការស្លាប់ជាច្រើន ហើយលើកគាហានចូលទៅក្នុង
ព្រះពាជវាំង ។ ខន្ធីទាំងពួងឃើញដូច្នោះសុះចូលទៅអញ្ជើញស្តេចព្រះចៅ
ហៀនតេនឹងអង្គអ៊ុន ឡើងទៅគង់លើដំណាក់ថ្កាក់លើ ។ លីឈុយ
គុយគី ទឹងសេនាគាហានទាំងពួង ក៏ទុនគំនាប់ថ្វាយបង្គំពីខាងក្រោម
ទៅ ព្រះចៅហៀនតេទតព្រះនេត្រមកឃើញហើយ មានព្រះតម្រាស់
ត្រាស់សួរថា ដែលខ្លួនអង្គាចពុំខ្លាចព្រះចេស្តា លើកសេនាគាហាន
ពានព្រះពាជវាំងចូលមកនេះ ទឹងប្លាប្លារបស់អ្វី? ។ លីឈុយ គុយ
គីក្រាបទូលថា ទូលព្រះបង្គំទាំងឡាយ ធ្វើការទាំងនេះទឹងបានគិតក្បត់
ព្រះអង្គក៏ទេ តាលពីដើមតាំងតុះជាមហាឧបពាជបានទំនុកបំរុងឆែនដ
ថ្វាយព្រះករុណាជាសុខរៀងមក តែអង្គអ៊ុនទឹងលីចោ"គប់គិតគ្នាសម្លាប់

មហាឧបាសកចេញដោយអំណាចចិត្ត ខ្ញុំសូមព្រះបង្គំជាខ្ញុំឈឺចំគ្រាណាស់ ចូលមកនេះថ្វាយនឹងសម្ដាប់អង្គុយចេញឲ្យអស់កំហឹង បើព្រះអង្គទ្រង់ព្រះមេត្តាប្រគល់ខ្លួនអង្គុយឲ្យហើយ ខ្ញុំសូមព្រះបង្គំជាខ្ញុំនឹងនាំគាហានចេញទៅវិញ ។

អង្គុយបានស្ដាប់ក៏ត្រាបទូលព្រះចៅហៀនតេថា "ខ្ញុំសូមព្រះបង្គំជាខ្ញុំមានសេចក្ដីពិតត្រង់នឹងផែនដីជាប្រាកដ ទើបសម្ដាប់តាំងតុះដែលក្បត់នឹងព្រះករុណានោះចេញ ឥឡូវលីឈុយ គុយតីចង់សម្ដាប់ខ្ញុំសូមព្រះបង្គំជាខ្ញុំវិញ បើខ្ញុំសូមព្រះបង្គំជាខ្ញុំនៅស្រឡាញ់ជីវិតគិតតែជកពួនដូច្នេះ នឹងកើតអន្តរាយក្នុងព្រះពាជហានច្រើនឡើងទៀត ហេតុនេះសូមយកជីវិតទៅឲ្យលីឈុយ - គុយតីសម្ដាប់ចេញចុះ ចំពោះជាទីតបស្នងគុណព្រះតេជព្រះគុណព្រះករុណា" ថាហើយក៏លោតចុះទៅតាមផ្លូវដើងជណ្ដើរព្រះតំណាក់ស្រែកថា "ខ្ញុំនអញនៅឯណោះ ឯងនឹងចង់ធ្វើប្រការម្ដេចក៏ធ្វើឲ្យស្រេចទៅចុះ" ។ លីឈុយ គុយតីឆ្លើយថា មហាឧបាសកមានទោសកំហុសពីព្រោះអ្វី . ឃានជាឯងគប់គិតចូលគំនិតនឹងលីឆ្ម៉ាសម្ដាប់ចេញ ។ អង្គុយតបថា តាំងតុះជាសត្រូវឧបាសម្ពត្ថិ ធ្វើការអាក្រក់នឹងឧបាសម្ពត្ថិច្រើនណាស់ ឃានជាអញសម្ដាប់វាចេញ នាហ្នឹងនឹងបណ្ដាកស្ដេចតាំងអស់មានសេចក្ដីត្រេកអរលើសលប់ ហេតុម្ដេចឯងមានចិត្តគំនុំគុំគួនជាមួយនឹងពួកអាក្បត់នោះ ។ (មានត)

ភាគទី ២

សម័យនគរធំ

អ្នកទេពញ៉ាទេពពិទូរ ឈ្មោះ - ក្រសែម រៀបរៀង

(តទៅ)

តែប្រាសាទវិស្ណុលោកនេះ តាមសំដីសាម័ញ្ញក្នុងបច្ចុប្បន្នហៅថា នគរវត្ត, នៅខាងត្បូងក្រុងប្រមាណជាង ១ គីឡូម៉ែត្រ ទ្រង់ទុកសម្រាយព្រះវិស្ណុ (នាកយណ៍) ដែលជាព្រះ ១ អង្គក្នុង ៣ អង្គ ក្នុងលទ្ធិវៃយ ។ មិនត្រឹមតែទុកសម្រាយទេ ទ្រង់បានចាំងសាងព្រះរូបព្រះវិស្ណុនោះយ៉ាងធំដ៏ហើយដោយឡូ ប្រតិស្ឋាននៅក្នុងប្រាសាទកណ្តាល នាថ្ងាក់ទី ៣ សម្រាប់ធ្វើសក្ការបូជា[1] ។

ក្រៅពីរូបព្រះវិស្ណុ ទ្រង់បានឲ្យធ្លាក់រូបភាពព្រះនាកយណ៍ (នាកយណ៍អវតារ) បែងភាគ ក្នុងគ្រាផ្សេងៗ នៅនាព្រះរបៀងទី ១ ទី ២ មានរឿងភមាយណៈ (ភមក្តើ), មហាភារតយុទ្ធ, ហរិវង្ស ជាដើម នឹងទ្រង់ធ្លាក់រូបភាពកងទ័ពខ្មែរ ទុកនៅព្រះរបៀងទី ១ ភាគខាងត្បូង បែកខាងលិច ដំណាលការព្រះអង្គធ្វើព្រះពុទ្ធសង្គ្រាម

---

១ ក្រោយមក កាលព្រះពុទ្ធសាសនាលទ្ធិលង្កាឡើងមក គេយករូបព្រះវិស្ណុនោះចេញហើយគេយកដែកថ្មធំៗ ទៅសន្ធប់មាត់ទ្វារទាំង ៤ ហើយធ្លាក់ជាព្រះពុទ្ធរូបឈរធំៗ បែរព្រះភ័ក្ត្រឈរទៅតាមទិសទាំង ៤ ។

នៅក្រុងវិដេយ ទុកជាប្រវត្តិសាស្ត្របស់ព្រះអង្គ នៅខាងក្រោយ
កង់ទំពាមានព្រះបរមរូបរបស់ព្រះអង្គ ប្រកបរឿងនោះផង ។ ក្នុងរូបភាព
កង់ទំពានោះ គេសង្កេតឃើញមានជនជាតិសៀម ជាន់ស្ទុះគ្រងធ្វើតាហាន
ក្នុងកង់ទំពស្រួចនោះ ដោយមានចារឹកជាអក្សរថា "សៀមកុក" នៅ
ទីនោះជាសំគាល់ផង ។

ក្រោយដែលសាងចេតិយស្រួចហើយ ព្រះបាទសូរ្យវរ្ម័ន
ទ្រង់បានកែប្រែលក្ខណៈរូបទង់ជាតិចេញទៅខ្លះ គឺត្រង់កណ្តាលផ្ទៃដែល
ធ្លាប់ប្រើពណ៌សសុទ្ធពីដើមមកនោះ ទ្រង់ឲ្យជាក់រូបប្រាសាទកំពូល ៣
ជំនួសត្រង់នោះ ជាគ្រឿងសំដែងកិត្តិយសជាតិខ្មែរ ដែលមានប្រាសាទ
សិលាល្អបំផុត ធំធ្ងៃជាងគេបំផុត សឹងគ្មានប្រទេសណាក្នុងពិភពលោក
នេះមានដូចទង់រូបប្រាសាទបែបនោះ បានប្រើរហូតមកដល់បច្ចុប្បន្ន ។

ព្រះបាទសូរ្យវរ្ម័នអង្គនេះហើយដែលក្នុងព្រះពុទ្ធសាសនាតាក្រុង
កម្ពុជាហៅថា ព្រះបាទព្រះបរមសុរិយាវង្ស ទ្រង់ជាក្សត្រិយ៍ ១ អង្គ
ដែលមានអភិនិហារធំធ្ងៃព្រះតេជានុភាពជាអស្ចារ្យ យ៉ាងដែលហៅថា
មានបុណ្យកក្រើកផែនដី ជាទីគោតញ្ញូតរបស់នានាប្រទេសដែល
នៅជិតខាង (តែមិនមែនមានព្រះនេត្រទិព្យដូចមានពោលក្នុងព្រះពុទ្ធ-
ពន្ធាវតារក្រុងកម្ពុជានោះទេ) ។ ព្រះអង្គមានព្រះកិត្តិយសជាមហាពុទ្ធ-
ធិពុទ្ធ ១ អង្គ ក្នុងប្រវត្តិសាស្ត្រ ។

កាលទ្រង់សោយទិវង្គតហើយ ពាជបណ្ឌិតថ្វាយព្រះនាមព្រះបរម-
សពថា ព្រះបាទបរមវិស្ណុលោក តាមហេតុដែលទ្រង់រាប់អានលទ្ធិវៃស្ណវៈ។

ព្រះចាន្ទជយវ៌្មន៍ទី ៧

ព. ស. ១៧២៦ - ១៧៤៩ គ. ស. ១១៨១ - ១២០៦

កាលពិះបាទធរណេន្ទ្រវ៌្មន៍ ២ សោយទិវង្គតហើយ

ព្រះជយវ៌្មន ជាព្រះពាជនុរសព្រះបាទធរណេន្ទ្រវ៌្មនទី ២ នឹងព្រះ
នាងបូឌាមណីអគ្គមហេសី ហើយត្រូវជាព្រះអនុជរួមព្រះពាជអយ្យិកា
នឹងព្រះបាទសូរ្យវ៌្មនទី ២. ទ្រង់មានព្រះវគ្គទេពីតាំងពីនៅកុមារ មុន
សោយពាជសម្បត្តិ ព្រះនាមជយពាជទេវី ជាព្រះធីតានៃព្រះបុត្រវ៌្មន
នឹងព្រះនាងពាជេន្ទ្រលក្ស្មី ទ្រង់មានព្រះពាជនុរស ១ អង្គ ព្រះនាម លពៈ-
ទេយស ឬ ឥន្ទ្រវ៌្មន ។

និយាយតាមច្បាប់ពាជសន្តតិវង្ស ពាជសម្បត្តិកាលនោះត្រូវបាន
ទៅព្រះជយវ៌្មន ដ៏ជាព្រះពាជនុរស ព្រោះក្សត្រិយ៍អង្គនេះជារដ្ឋាយាទ
ដោយត្រង់, តែកាលមុនដែលព្រះបាទធរណេន្ទ្រវ៌្មនសោយទិវង្គត
នោះ, (មិនដឹងជាកាលឆ្នាំណា) ព្រះជយវ៌្មនបានស្តេចយាងទៅគង់
នៅក្រុងវិជ័យ ក្នុងដែនចម្ប៉ា គឺនៅស្រុកបិញ្ចិញសព្វថ្ងៃនេះ ពុកព្រះ
ទេវី នឹងព្រះនុរសតូច ១ អង្គ ឲ្យនៅកាន់ព្រះនគរឯណោះ ។ ការ
ដែលព្រះជយវ៌្មនទៅគង់នៅប្រទេសចម្ប៉ា ដោយតាក់តាមដោយរឿង

សង្គ្រាម ឬដោយហេតុការណ៍អ្វី គេមិនអាចដឹងបានដោយច្បាស់លាស់ទេ ។ ក្រោយដែលស្តេចយាងទៅនោះ ព្រះពជបិតាសោយទិវង្គតបន្ទាប់ពីនោះពជសម្បត្តិនៅទំនេរ ។ ព្រះជយវ៉ែនដែលជារដ្ឋាភិបាលនឹងស្តេចយាងមកវិញ ឬមិនយាងមកទេ ក៏មិនអាចដឹងបាន ពជការមុខក្រសួងបានចាត់បំរើឲ្យនាំសារពិតមានអំពីរឿងព្រះពជបិតាសោយទិវង្គតទៅថ្វាយក្តាម តែយឺតយូរក្រៃបានទៅដល់ ព្រោះលំបាកដោយគមនាគមន៍ ។

ជាធម្មតាទេ រឿងពជសម្បត្តិ រមែងជាទីប្រាថ្នាយ៉ាងក្រៃពេកបស់ខត្តិយជាតិចាំងឡាយ (សមដូចសុភាសិតថា "យក្ខទិន្នសាច់ ស្តេចទិន្នរាជ្យ") ពិតដូច្នេះ កាលព្រះបាទធរណេន្ទ្រវ៉ែនទី ២ សោយទិវង្គតហើយ ព្រះជយវ៉ែនក្រយាងមកដល់ក៏ជាទុកាសឲ្យក្សត្រិយ៍ ១ អង្គ ព្រះនាមយសោវ៉ែន តែមិនដឹងជាជាប់អំបូរវង្សអំពីព្រះមហាក្សត្រិយ៍អង្គណាបានព្រមដោយស្ម័គ្រចិត្តពួក លើកចូលទៅក្នុងក្រុងស្រីយសោធរបុរៈ ឡើងគង់លើរាជបល្ល័ង្ក ហើយប្រកាសខ្លួនជាព្រះពជាម្ចាស់ផែនដីតម្កល់ផ្តែតម្ពង ។ ក្នុងពេលនោះ សូម្បីមានពជសេវកាមាត្យនឹងពួកស្តេចដែលមិនចង់ស្ម័គ្រចូលជាចិត្តពួក តែមិនអាចនឹងកំចាត់ចេញបាន ក៏គោងតែព្រមទទួលស្គាល់ ដោយចាំងមិនពេញចិត្តនោះទៅ ប្រកាសព្រះបរមនាមថា ព្រះបាទយសោវ៉ែនកង្វេង ព.ស. ១៦៩៨ - ១៧០៨, គ.ស. ១១៥៥ - ១១៦៥ ដោយហេតុព្រះនាមនេះស្មុនឹងព្រះនាមបស់

ព្រះមហាក្សត្រិយ៍ ១ អង្គដ៏មានមកខាងដើម គេទើបពាប់ជាទី ២ ដើម្បីកុំឲ្យច្រឡំគ្នា ។ ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេច នឹងមានព្រះរាជនុរសព្រះរាជធីតាឬទេ មិនច្បាស់ ។ តាមអាកប្បកិរិយានៃព្រះបាទយសោវរ្ម័នដែលទ្រង់ឡើងសោយរាជ្យនោះ ឈ្មោះថា មិនត្រឹមត្រូវតាមលក្ខណៈបញ្ជាប់រាជសន្តតិវង្ស ត្រូវទុកជាក្បត់ ដែលរាជ្យរបស់ព្រះជយវរ្ម័ន អ្នកដែលក្បត់ - ដែលរាជ្យដោយមិនមានហេតុដ៏សមគួរបែបនេះ មិនត្រូវបានចារឹកនាមពាប់រឿងក្នុងបញ្ជីបុរាពិក្សត្រិយ៍តាំងពួង ដូច្នេះព្រះនាមនៃព្រះបាទយសោវរ្ម័ន ទើបត្រូវសម្រួតមកនៅក្នុងផ្ទៃរឿងទៅវិញ ។

ចំណែកឯព្រះជយវរ្ម័ន កាលទ្រង់ជាបពតិមានរឿងព្រះរាជបិតាសោយទិវង្គតហើយ ទ្រង់ក៏គិតនឹងត្រឡប់ព្រះនគរដោយរួសរាន់, តែតមកមិនយូរ ទ្រង់បានជ្រាបថាមានរាជសត្រូវឡើងគង់លើរាជបល្ង័ង្កទៅហើយ ទ្រង់តុះតុញព្រះហ្ឫទ័យ ដោយទ្រង់ព្រះចិន្តាថា បើតាមករណីត្រូវតែទ្រង់យាងត្រឡប់ភ្លាម តែថាប្រសិនជាត្រឡប់មក វែកឯព្រះបាទយសោវរ្ម័នរកវឿរំលាងដោយបំពាន ទ្រង់មិនទុកព្រះហ្ឫទ័យថា ទ្រង់អាចនឹងការពារព្រះអង្គឯងបាន, បើមិនមក នឹងខូចប្រយោជន៍យ៉ាងធំ ។ ក្នុងទីបំផុត ទ្រង់សម្រេចព្រះហ្ឫទ័យថា ត្រូវបង្អង់សិន រង់ចាំបានឧកាសស្រួលទៅថ្ងៃក្រោយ សឹមយាងមកតវ៉ា ។

ខាងចំណែកព្រះបាទយសោវរ្ម័ន តាំងពីបានឡើងគ្រងរាជបល្ង័ង្ក

ហើយក៏មិនសូវជាបានសុខសាន្តប៉ុន្មាន ដោយមានការណ៍បះបោរកើតឡើងក្នុងប្រទេសជាញឹកញយ ពាំងនេះដោយហេតុនៃការគ្រងរាជសម្បត្តិរបស់ព្រះអង្គមិនប្រកបដោយគន្លងច្បាប់ ឬដោយហេតុប្រកបដោយអយុត្តិធម៌យ៉ាងដូចម្តេចបញ្ហា? ពោលចំពោះតែការណ៍បះបោរយ៉ាងធំៗមានពីរដង:

បះបោរជាដំបូង ធ្វើកដតាមសិលាចារឹក នឹងរូបភាពប្រកបនៅអមវេន្តបុរៈ (បន្ទាយឆ្មារ) ថា មានធម្មជាតិអ្វីមួយដែលកងសិលាចារឹកហៅថា ·ពហុ ឬករតេពហុ មើលទៅរូបភាពក៏ប្រហែលពហុ តែគង់មិនមែនពហុ អសុរិន្ទ្រ ។ ពហុនេះកើតមានចិត្តច្រើសច្រែនឆ៍យឆ៍យឃ្លងគិតដណ្តើមយកព្រះបរមរាជាំងអំពីព្រះជ័យសោវរ្ម័ន, នាថ្ងៃមួយ ពហុបានទៅដល់ព្រះបរមរាជាំង ពួកទាហានរក្សាព្រះពជនវៃសន៍កាលរូបវិកលដួងចិត្តកំតុតភ័យនាំគ្នារត់អស់ទៅ, តែកងវៃលានោះ មានព្រះកុមារដំទង់ ១ អង្គព្រះនាមលវេទយេស ជានុសេព្រះជយវរ្ម័ន (ទី ៧) ជាន់ព្រមដោយសេនាសំខាន់ ២ នាក់ចេញមកតយុទ្ធនឹងពហុ ទ្រង់វាយពហុនោះត្រូវត្រង់ក្បាលចំមុះ ដួលផ្ងារទៅ, ព្រះជ័យសោវរ្ម័ន នឹងព្រះមហានគរក៏រួចផុតអំពីកណ្តាប់ដៃសត្រូវទត្បាត ។

មកក្នុងឆ្នាំទី ១០ ពាប់ពីឆ្នាំសោយរាជ្យមក ព្រះជ័យសោវរ្ម័ន ត្រូវក្បត់ជាទុក្ខដ្ឋិដម្ងន់ទៀត ដោយមានមន្ត្រីធំ ១ នាក់ មិនធ្វើកដឈ្មោះសឹងធ្លាប់ធ្វើរាជការកងរជ្ជកាលព្រះជ័យធរណេន្ទ្រវរ្ម័នទី ២ មានចិត្តលោភយសលើសលន់ ក៏តាំងរួបរួមស្ម័គ្រចិត្តពួកលើកទៅលុកក្រុងស្រីយសោធរបុរៈ ។

ពុទ្ធសាសនា និង គ្រិស្តសាសនា

លោក ភ័យ-ប៊ីក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យកុំពេញ

ប្រែពីទស្សនាវដ្តី "ហ្វ្រង់អាស៊ី" ខែមិថុនាឆ្នាំ ១៩៥០

អារម្ភកថាអ្នកបកប្រែ

រឿងនេះគឺជាសន្ទិសិទដែលលោកវេជ្ជបណ្ឌិត អង់ដ្រែមីគូត៍ (André Migot) ឯតទគ្គបុគ្គលខាងបូរាវិជ្ជានិយម ចានធ្វើពីថ្ងៃទី ១៤ ខែមេសា ឆ្នាំ ១៩៥០ នៅទីក្រុងជាឡាត់ ។ អត្ថបទនៃសន្ទិសិទនេះ លោកអង់-ដ្រែមីគូត៍សំដែងអំពី "ពុទ្ធសាសនានឹងស៊ីវិល្ហៃនៃបច្ចុប្បន្នប្រទេសឲ្យឃើញ ថា តើមានសភាពផ្ទុយគ្នាឬស្របគ្នា" ។ ស្ថេចសង្ឃខាងគ្រិស្តសាសនា នាមហ្វ. ប៉ាវែល (F.Parrel) ចានវិសជ្ជនាតបទៅវិញតាមនិទានកថា គឺ "ពុទ្ធសាសនានឹងស្ថានភាពនៃគ្រិស្តសាសនា" នៅថ្ងៃទី ២៤ ខែមេសា ឆ្នាំដដែល ។ រួចលោកវេជ្ជបណ្ឌិតអង់ដ្រែមីគូត៍ ចានថែមអត្ថាធិប្បាយ មួយគឺ "វិចារណញ្ញាណនិយមលទ្ធិ (dialectique)" ជាពាក្យ អធិប្បាយដ៏ពីរោះពន់ពេក ។

យើងបញ្ជាក់ថា ការបុច្ឆាវិសជ្ជនានៃបណ្ឌិតខាងពុទ្ធសាសនា និង គ្រិស្តសាសនានេះ សឹងប្រកបដោយប្រាជ្ញាសុខុមគម្ភីរភាពខាងបរមត្ថ; ដោយលោកទាំងពីរនេះ ជាឯតទគ្គបុរសចំណានខាងពុទ្ធសាសនានឹង

គ្រិស្តសាសនា ហើយត្រូវយកឡាក់គោលសំខាន។ មកត្រជាងបង្ហាញ
រឿងខ្លួន ប្រកបតាមវិចារណញ្ញាណផង តាមបណ្ដិតភាពផង ដើម្បីនឹង
ផ្ដាញ់គ្នាទៅវិញទៅមកដោយសច្ចវាចា ។ លោកអ្នកអានប្រហែលជាមាន
សេចក្ដីពេញចិត្តត្រង់អត្ថបទសន្និសិទខាងនេះពុំខាន ព្រោះជាយុទ្ធវិធីខាង
សាសនាមួយដែលលោកអ្នកពុំធ្លាប់ចាន់ជាប ។ បុព្វាវិសជ្ជនានេះមាន
ឧជារសជាងព្រះសង្ឃក្នុងពុទ្ធសាសនាទេសនាគ្រែពីរ ដែលយើងធ្លាប់
ឃើញ ធ្លាប់ដឹង ប្រៀបដូចជាមេទ័ពខាងពីរចូលតយុទ្ធនៅទីសមរភូមិ ។

១ – សន្និសីទលោកអង់ដ្រែម៉ក្ស័ត

ពុទ្ធសាសនានឹងស៊ីវិឡៃឌបច្ចុប្បន្នប្រទេលពើមានសភាព ផ្ទុយគ្នា ឬស្រុបគ្នា ?

"ពួកជាតិភ្ញីស្ដាំង(1) ពុំមែនគ្រាន់តែមិនដឹងនូវលក្ខណៈនៃជីវភាព
ប្រជាពស្ត្រ ដែលស្ថិតនៅក្រៅជាតិរបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំង
សុំឲ្យមនុស្សជាតិក្រៅពីជាតិរបស់ខ្លួន រៀបចំក្បួនខ្នាតនឹងរបៀបនៃ
ការរស់នៅ ឲ្យដូចគ្នានឹងជីវភាពនៃជាតិរបស់ខ្លួនទៀត" ។

លោកគីថ (Gœthe)

• ជាតិភ្ញីស្ដាំង ក្រែជាពស្ត្រអាស៊ីពីបុរាណកាល ចាកចេញពីកោះក្រែតមកតាំងកុលសម្ពន្ធនៅ
រាងប្រទេសស៊ីរី, សម្រេចមហិទ្ធិឫទ្ធិណែនាំវប្បធម៌ភាគច្រើនដល់ពិភពលោក ។ ពួកអស្ស៊ីរីយោងថាឧទ្ទេតស្ដង
ជាតិខេះ ពីកាលសតវត្សទី ៧ ជាតិខេះក៏ចាត់តាមពីប្រវត្តិសាស្ត្រលោកតាំងពីកាលខេះមក ។

ខ្ញុំសូមអភ័យទោសអំពីលោកអ្នកគាំងអស់គ្នា ដោយខ្ញុំជាជាតិអ៊ីរុប
សូមថ្លែងអំពីព្រះពុទ្ធសាសនា[1] ចំពោះសវនស្ថាន (auditoire) ដែលមាន
ស្តុកតែពួកពុទ្ធមាមកជនជាតិអាស៊ីដែលជាប្រកតនៃពុទ្ធសាសនានេះ ។
តែខ្ញុំអាចដឹងបានថា "លោកអ្នកជាជាតិបច្ចឹមប្រទេសដែលអញ្ជើញមក
កាន់ទីនេះដែរ លោកច្រើនមានគំនិតយល់ឆ្គងឬកាន់ច្រឡំទៅតាមនិន្នាការ
(tendances) សព្វៗខ្លួនថា ពុទ្ធសាសនាជានិមិត្តស្រែវដោយខ្សែកឬជា
គំនរឆ្កឹតនៃជនមិច្ឆាទិដ្ឋិ (Superstitions) ។ ចំណែកជនជាពុទ្ធមាមក:
ច្រើនមិនបានស្គាល់ជាក់ច្បាស់នូវសាសនារបស់ខ្លួន ហើយមិនដែលគិត
យកន័យខាងវប្បធម៌នឹងសាសនារបស់ខ្លួន ទៅប្រៀបធៀបនឹងន័យខាង
វប្បធម៌នឹងសាសនានៃបច្ចឹមប្រទេសនោះឡើយ" ។

ព្រះពុទ្ធសាសនាគឺជាការណ៍មួយដែលសំខាន់បំផុត ក្នុងចំណោម
ការណ៍ឯទៀតក្នុងប្រវត្តិសាស្ត្រលោក ហើយបានផ្សាយឥទ្ធិពលទៅ
កាន់ប្រទេសខាងបូព៌ាអាស៊ីទ្វីបជាសម្បើមអស្ចារ្យ ហើយជាសាសនា
ដែលប្រជាកស្តូស្ថិតនៅវាងឆប្រទេសឥណ្ឌៀនឹងជប៉ុន បានទិយម
ប្រព្រឹត្តប្រតិបត្តិតាមជាងសាសនាឯទៀត ។ ចំនួនជាយកនឹងជាយិកា

---

[1] អត្ថបទនេះគឺជាអត្ថាធិប្បាយ នៃសន្និសីទដែលបានធ្វើនៅថ្ងៃទី ១៤ ខែមេសា ឆ្នាំ ១៩៥០ ចំពោះសមាគមពុទ្ធសាសនាទៅទីក្រុងដាឡាត់នឹងឡាំងប៊ីយាង ។

ចាំងអស់មានកាំតមួយកន្លះកាតបី នៃមនុស្សជាតិចាំងមួលកន្លះលោកសន្ធំ-
រាសនេះ ។ ពួកជាតិខាងបូពាអាស៊ីទ្វីប ប៉ានផ្លេតំនិតខាងវប្បធម៌,
សិល្បវិជ្ជា, អក្សរសាស្ត្រ អំពីពុទ្ធសាសនា, មួយទៀតពុទ្ធសាសនា
ជារបៀបអារ្យធម៌ដែលប្រៀបធៀបទៅ ប្រហែលនឹងអារ្យធម៌នៃគ្រិស្ត
សាសនានៃបច្ចឹមប្រទេស ។ ការយល់ន្លូវផ្លូវប្រាជ្ញាចាំងពីរបៀបនេះ
ត្រូវតែយើងស្គាល់ខានមិនបាន ព្រោះថាមនុស្សណាមួយដែលមិន
ស្គាល់ន្លូវផ្លូវណាមួយខាងលើនេះ មនុស្សនោះគេចុកជាមនុស្សល្ងង់ខ្លៅ
បំផុត ។ ខ្ញុំមិនបានថ្លែងន្លូវលទ្ធិពុទ្ធសាសនា ឬពុទ្ធប្រវត្តិនោះទេ;
សេចក្តីអួតអាងរបស់ខ្ញុំ ចំពោះមុខលោកអ្នកមានសកាពថយចុះជាងនោះ,
ខ្ញុំបានមានឯកសិទ្ធិរស់នៅជាច្រើនឆ្នាំ នៅប្រទេសដែលនិយមរាប់អាន
ព្រះពុទ្ធសាសនា, ដូនកាលខាងហីនយានគឺប្រទេសសីឡង់ (លង្កាទ្វីប)
កូមា, កម្ពុជា ដូនកាលខាងមហាយាន គឺប្រទេសវៀតណាម, ចិន,
ទីបេត៌នឹងមុងកូលី ។ ព្រោះខ្ញុំមានវត្តបំណងចង់ស្គាល់ឲ្យជាក់ច្បាស់
ន្លូវព្រះពុទ្ធសាសនា ចំពោះលទ្ធិនឹងវិធីប្រតិបត្តិមានការប្រែស្រ័យដោយ
មិត្តភាពនឹងព្រះសង្ឃត្រកាំងពួកលាមា (lamas)[1] ។

(មានត)

---

១ លាមា ព្រះសង្ឃនៅខាងភូមិភាគទីបេត៌ (ប្រទេសចិន) ។

ពន្លឺអាស៊ីទ្វីប

La Lumière de l'Asie

លោក ស៊ីរ-អេតវ៉ាំងអារណូលដ៍ តែន

លោកវ៉ាយ - ប៊ុក ក្រមការ ប្រែរៀបរៀង

(ត ឃក)

ក្នុងថ្ងៃមួយ មានពួកនារីមួយក្រុមត្រាច់ដើរតាមផ្លូវស្ងៀកសំពត់កណ្តាច, គឺជាពួកនាងនាដកាហៅថា (nautch)[1] ដែលជាព្រះវិហារសក្តខេវាជ ក្នុងនគរ, មានពួកប្រុសរចាំតាមមកជាមួយផង ប្រុសម្នាក់វាយស្គរដែលមានស្នាមក្បោកដោតជាលំអសិល្បៈផង, ម្នាក់ទៀតប៉ងស៊ូលី[2] ដែលមានសំពូសំឡេងខ្លាំងហើយម្នាក់ទៀតដេញពិណ (Cithare) មានខ្សែបី ។ នាងទាំងនោះបានត្រាច់ចុះពីលើកំពូច, តាមផ្លូវដើងមួយដើម្បីនឹងទៅលេងសប្បាយឯកន្លែងបុណ្យអ្នកដទៃ; នាងពាក់កូនកណ្តឹងប្រាក់ពួរសូរណ្តុំគ្នាទៅតដើងមានពណ៌ប្រផេះ ហើយមានកងដៃពួរសំពូសូរទង្គិចគ្នាទៅដៃនឹងកដៃធ្វើយឆ្ងល់គ្នាពីកេះអស្ចារ្យ; ចំណែកខាងអ្នកដេញពិណ ខំផ្គាត់ខ្សែស្តាន់ ។ នាងនាដកាម្នាក់ទៅជិតអ្នកដេញពិណក៏តាំងច្រៀងថា:

---

១ (nautch) នាងនាដកាទាំងប៉ុន្មាន គឺទៅនឹងវត្តអារាម ហើយមានមុខការដែលត្រូវបំពេញគឺច្រៀងនឹងរាំចំពោះរូបព្រះឬនាងទេវធីតា។ នាងទាំងនេះគេជួលទៅរាំនៅក្នុងទីកាសបុណ្យជាសាធារណៈឬឯកជន ។

២ ប៉ាងស៊ូលី ជា ពាក្យឥណ្ឌគឺប្រែជាប៉ងភ្លេងដូចជាក្បាលខ្មែរ (Cornemuse)

"ការកំសប្បាយយើងចាប់ផ្តើមហើយ ដូច្នេះគួរតែវៀតណាឲ្យឮសូរ ពីពេះ សូមអ្នកតែវៀតណាកុំឲ្យតឹងពេក ធូរពេក យើងនឹងធ្វើឲ្យរំជួលនូវ ហទយវត្ថុរបស់មនុស្សទាំងអស់" ។

"វៀតណា បើតតឹងពេកនឹងដាច់ ហើយសូរសំឪអណ្តែតបាត់; វៀតណាធូរពេកមិនឮសូរ ហើយសូរក្លេងក៏បាត់ស្ងាត់; ឯអ្នកដេញពិណ សូមតែវៀតណាកុំឲ្យខ្ពស់ពេក ទាបពេក" ។

នេះជាចំរៀងនាងនាងកាក់ឲ្យត្រៃគ្នានឹងសំឡេងក្លេង "ក្សរណីមុស" ផ្សំនឹងវៀក្លេង ហើយនាងកាំតាមចង្វាក់ក្លេង ដូចជាមេអំបៅស្រាលហើរ លើនកាល័យ ពីត្រៃមួយទៅត្រៃមួយ ។ នាងត្រាច់តាមផ្លូវកងវៀ ដោយមិនបានគិតថា បទចំរៀងនោះចេញពីមាត់នាងអណ្តែតត្រសែត ទៅចូលព្រះស្រោតព្រះពោធិសត្វដែលកំពុងគង់ក្រោមអជ្ឈបាលនិគ្រោធ មួយដើម ជិតផ្លូវដើងមួយហើយព្រះទ័យព្រះអង្គចុះទៅកន្លងឈានចិត្ត ។

កន្លងកាលដែលពួកក្រមរចាំនោះមកដល់ទីនោះហើយ ព្រះពោធិ-សត្វងើយនលាដ មានព្រះឧទ្ធារថា: បណ្ឌិតអាចយកអាការរបស់ មនុស្សឆ្កួតមកទូន្មានប្រដៅខ្លួនបាន អាត្មាអញប្រហែលតែវៀតវង្គនៃ ជីវភាពហួសប្រមាណដោយចង់ឲ្យឮសំឪសូរពីពេះគឺធម៌ពិត ដែលអាច ជួយស្រោចស្រង់សត្វលោកបាន, ក្នែកអាត្មាអញប្រែទៅជាឆ្កឹត, ដល់ ពេលដែលនឹងត្រូវឃើញសច្ចធម៌ កាយអាត្មាអញពុំឮលភាពណាស់

ដល់ពេលឥឡូវអាត្មាអញកំពុងត្រូវការខ្លួរកំឡាំង, បើក្នុងពេលនេះ អញមិនមានអ្នកណាមកជួយទេ អាត្មាអញមុខជាមរណៈ: ខ្លួនអាត្មាអញគួរធ្វើឲ្យមានដីរកាពជាទីសង្ឃឹមនៃមនុស្សទាំងអស់តទៅអនាគត ”

ក្នុងពេលនោះ នៅតាមមាត់ស្ទឹង មានបុគ្គលម្នាក់ជាអ្នកពេញចិត្តខាងសាសនា ហើយជាអ្នកមានកោតទ្រព្យសុកសម្ភ មានហ្វូងឥសុសត្វជាច្រើន ហើយជាអ្នកមានចិត្តសប្បុរសជាកល្យាណមិត្តនឹងពួកតំបន់ទុគ្គត, ភូមិនោះ គេហៅថា “សេនានិគម” ដោយយកនាមមកពីវង្សត្រកូលបុគ្គលនោះបានរស់នៅក្នុងភូមិនោះជាសុខសប្បាយ នឹងកិរិយាឈ្មោះនាងសុជាតា ដែលជានារីមានរូបឆោមលោមពណ៌គួរជាទីពេញចិត្តមានក្អែកខ្មៅដូចស្នាមភាពនៃវ័ល, នាងមានកិរិយាស្លូតត្រង់, ចិត្តវាបសាប្រកបដោយប្រិយភាព; ឫកពានាងខ្ជិនខ្ជស់, នាងពោលពាក្យជាប៉ិយវាចា ហើយចោលកន្ទុយក្អែកញញឹមស្រស់ រួមសេចក្តីទៅថា: នាងជាឯកនារី ប្រសើរលើសស្ត្រីទាំងអស់ នាងរស់នៅជាមួយនឹងស្វាមីក្នុងគេហដ្ឋានដោយសុខសប្បាយ; នាងមានព្រួយចារម្ភតែមួយយ៉ាងគឺតាំងពីពេលសមរសមកដល់ឥឡូវនេះនាងគ្មានកូនប្រុសសោះ។ ព្រោះហេតុដូចនេះ ឋានជានាងបន់ព្រះលក្ស្មី[1] ហើយជាច្រើនយប់មកហើយ ក្នុងពេលដែលព្រះចន្ទកំពុងពេញបូណ៌មី នាងបានទៅធ្វើប្រទក្សិណ

---

១ លក្ស្មី ជាអគ្គជាយាទេវ្តា ជាទេវធីតាមានឧសម្ប្បណ៌ភាពជាបដិមា ដូចជាទាងសេរៀសខាងសាសនាក្រឹក ។

ថ្កុំបួនដុំនូវអ្នកតា "លិង្គម" (១) ហើយបានបូជានូវបាយកម្រងផ្កា
ម្ងំ ប្រែងកញ្ជានដើម្បីនឹងសូមឲ្យបានកូនប្រុសមួយ; នាងសុជាតា
បានអធិដ្ឋានកន្លងចិត្តចំពោះ អ្នកតាព្រះដៃ បើបំណងនោះបានសម្រេចដូច
សេចក្តីប្រាថ្នាវេលាណា ទើបនាងថ្វាយនូវមធុបាយាសជាក្រយាហារ
ដែលទេវតាតែងពេញចិត្តនឹងសោយ . នាងដាក់នឹងសុវណ្ណភាជន៍យក
តំកល់នៅក្រោមដើមពោធិព្រឹក្សនោះ ។ បំណងរបស់នាងក៏បានសម្រេច
កន្លងពេលនោះ ដោយនាងបានប្រសូតបុត្រប្រសមួយ ឥឡូវកូននោះ
អាយុបានបីខួបហើយដោយនាងកតញ្ញូគុណក៏គ្រាច់ទៅកាន់ទីទេវតាកន្លង
អញ្ជើប្រទេសនោះ ដៃម្ខាងកាន់សំពត់ព្រៃសារីក្រហមផ្ទៅសម្រាប់ដុំ
ភាក ដែលជាថ្នើមប្រមាត់របស់នាង, ដៃម្ខាងទៀត នាងបន្ទន់ឲ្យតាប
កាន់ទប់នូវភាជន៍ឲ្យនឹងនៅលើក្បាលនាង ដែលជាក់ភោជនាហារដ៏មាន
គុណវិសេសសម្រាប់បូជា ។

តែនាងទាសីឈ្មោះរដ្ឋា (Radba) ដែលនាងបានចាត់ឲ្យទៅបោស
សំអាតក្រោមដើមដៃហើយយកខ្សែក្រហមរុំព័ទ្ធដើមឈើនោះ នាងវិល
ត្រឡប់មកវិញជំពប់នាងសុជាតាថា: គុព្រះនាង! សូមអញ្ជើញទៅ
មើលទេវតានៅកន្លងដៃព្រលង្ហិញរូបឲ្យឃើញជាក់ច្បាស់, គង់នៅទីនោះ,

(មានត)

---

១ លិង្គ ផ្ទៃចង្កេះក្បាក់ទួលវែង ជាបដិមាធំតួលិង្គព្រះឥសូរ ជាតាមធម្មចំពោះពលភាពក្នុងការស្តាបខាលោក ។

ធម្មទេសនាកថា

ព្រះទេពសត្ថា សូរ - ហាយ ក្រុមជំនុំព្រះត្រៃបិដក

ទេសនាដាក់វិទ្យុនៅថ្ងៃ ៨ កេះខែស្រែពណ៌ ព. ស. ២៤៧១ - ៨ - ៧៤

ធម្មត្ថុតន្តុយ សុរ្យ

អស់លោកអ្នកស្តាប់ទាំងឡាយ !

ពេលនេះជាមង្គលមួយដ៏ប្រសើរ ដែលអាត្មាភាពត្រូវនៅមកសំ-ដែងធម៌អំពីប្រយោជន៍បច្ចុប្បន្ន ដើម្បីជាសណ្តាប់នៃអស់លោក - អ្នក ទាំងឡាយដូចសេចក្តីដែលត្រូវសំដែង ព្រមទាំងអធិប្បាយតទៅនេះ :

ប្រយោជន៍បច្ចុប្បន្នខេះមាន ៤ យ៉ាង

១ - ទិដ្ឋធម្មសម្បទា = ការគ្រប់គ្រាន់ដោយការស្រាកស្រឡឹង

២ - អារក្ខសម្បទា = ការគ្រប់គ្រាន់ដោយការរក្សាថែទាំ

៣ - កល្យាណមិត្តតា = ភាពនៃបុគ្គលជាអ្នកមានមិត្តល្អ

៤ - សមជីវិតា = ភាពនៃបុគ្គលជាអ្នកមានការចំញឹមជីវិតសមគួរ ។

អធិប្បាយប្រយោជន៍ទី ១

ការបរិបូណ៌ដោយហេតុដែលគួរប្រកប ដើម្បីឲ្យបានសម្រេចដូចបំណង ហៅថា សម្បទា ។ សម្បទានេះ ប្រែថា "គ្រប់គ្រាន់, ជាគុណជាតជាគ្រឿងផ្តល់ ឬជាគ្រឿងប្រគល់ឲ្យនូវប្រយោជន៍" ។

ឧដ្ឋានសម្បទា ដែលប្រែថា "ការគ្រប់គ្រាន់ដោយការក្រោកឡើង" នោះតើក្រោកឡើងដើម្បីបំពេញការងារដូចម្តេច? ការងារបស់មនុស្សដែលត្រូវបំពេញក្នុងលោកនេះ មានច្រើនយ៉ាងគឺការងារខ្លះធ្ងន់, ខ្លះស្រាល, ខ្លះធំ, ខ្លះតូច; ការងារខ្លះជាប្រយោជន៍ផ្ទាល់ខ្លួន, ខ្លះជាប្រយោជន៍សាធារណៈ; ការងារខ្លះបំពេញដោយទោស, ខ្លះបំបាត់ទោស; ការងារខ្លះបានផលច្រើន, ខ្លះបានផលតិច តាមគ្រោងហេតុរបស់ការងារនោះៗ ។

បណ្តាការងារទាំងអស់ក្នុងលោកនេះ, ការងារណាក៏ដោយ តាំងអំពីការសិក្សារៀនសូត្រ ធ្វើស្រែចំការជួញប្រែជាដើមនោះ សុទ្ធតែត្រូវបំពេញដោយឧដ្ឋាន: គឺការក្រោកឡើងមិនមានរៀសរៃ ប្រញាប់ប្រញាល់កិច្ចការដែលខ្លួនត្រូវធ្វើដោយមិនត់ចត់ទាំងអស់ ទើបសម្រេចផលដូចបំណងទៅបាន, បើមិនច្រើនក៏តិចតាមកំឡាំងនៃការងារនឹងកំឡាំងនៃសេចក្តីព្យាយាម ។

ការងារទាំងឡាយដែលត្រូវបំពេញដោយដៃធ្វើនោះ ច្រើនតែមានហេតុចង្រៃមកពាក់ព័ន្ធខ្លាំងខ្លាស់ឬដែលហៅថាមារជ្រៃក ឬលីហៅថាឧបស័គ្គ ។ បើការងារតូចថោកទាប មានឧបស័គ្គបន្តិចបន្តួច, បើការងារធំខ្ពង់ខ្ពស់មានឧបស័គ្គក៏ច្រើន; ឧបស័គ្គនេះតែងតាមប្រណាំងប្រជែងបៀតបៀនការងារទាំងអស់ធម្មតា ។ សេចក្តីព្យាយាមក្នុងការងារដែលចេះតែក្លាយចេះតែខ្ពស់ខ្ពាន ក៏ព្រោះឧបស័គ្គនេះឯង ។

សេចក្តីប្រឹងប្រែងខ្មីឃ្មាតក្រែកឡើងម្តីមានេះ តាមបាលីហៅថា ឧដ្ឋាន:; ពាក្យថា ឧដ្ឋាន:នេះ ជាឈ្មោះនៃសេចក្តីព្យាយាមដែលមានកំឡាំងក្លៀវក្លា ។

ពាក្យថា ព្យាយាមនេះ ខ្មែរយើង មានពាក្យវោហារសំឌូ គឺសំដីដែលនិយាយផ្ទាស់ប្តូរជាច្រើនយ៉ាង, ភាសាបាលីក៏មានវោហារសំឌូច្រើនយ៉ាងដែរ ។ ដូចឧដ្ឋាន: = ការក្រែកឡើង, វីរិយ: = ប្រាសចាកសេចក្តីរួញរា, វាយាម: = ព្យាយាមប្តូរឈានទៅមុខ, ឧស្សាហ: = ខ្មីឃ្មាត, បរក្កម: = ខ្ជូច, អដ្ឋិតិ = មិនឈប់នៅ, អប្បដិវានី = មិនត្រឡប់ថយក្រោយ, អនិក្ខិត្តធុរតា = មិនបោះបង់សេចក្តីប្រាថ្នា, អសិថិលបរក្កមតា = ចំប្រឹងប្រែងមិនបន្ធូរបន្ធយ, អនិក្ខិត្តធុរតា = មិនដាក់ធុរៈចោល ។

សេចក្តីខ្នះខ្នែងក្រើនក្រតើនកងកិច្ចការ មិនបណ្តែតបណ្តោយមិនធ្វេសប្រហែសតាយងាយ, មិនខ្ជិលច្រអូស គឺមានភាពជាអ្នកស្រាស្រេញស្រឡាញ់ការងារដែលខ្លួនត្រូវធ្វើ, មិនខ្ជាប់លំបាក, មិនគិតពីការហត់នឿយ, ចំប្រឹងកំចាត់នូវកោសជ្ជ:សេចក្តីឆ្កួលច្រអូសចេញចាកខន្ធសន្តាន; ព្រោះថាកោសជ្ជ:នេះជាទំនាស់គ្នានឹងសេចក្តីព្យាយាម; ទោះបីមានឧបសគ្គយ៉ាងណា ក៏មិនត្រូវទំលាក់ការដែលខ្លួនធ្វើនោះចោលឡើយ ។

๑ចំស័ង្គ សេចក្តីចង្រៃខ្លាំងណាស់ ទីឆ្ងាយរលាចរលាយបាត់ទៅ ក៏ព្រោះសេចក្តីព្យាយាម ។ បុគ្គលអ្នកមានសេចក្តីព្យាយាមច្រើនច្រែងទុកដូចជាអ្នកមានថ្នាំទុសចរិសេស សម្រាប់បន្សាបនូវពិសកាច គឺ ๑ចស័ង្គ ទីឆ្ងាយក៏សូន្យឲ្យសូន្យរម្ងាប់ ។ បុគ្គលអ្នកមានព្យាយាម រមែងចំរើនថ្កុំថ្កើងដោយគុណធនធីឆ្ងាយសប្បាយ ប្រសើរលើសជាងបុគ្គលអ្នកខ្ជិលច្រអូសដោយពិត ។

ព្រះសម្ពុទ្ធជាម្ចាស់ ដែលទ្រង់បានសម្រេចសម្មាសម្ពោធិញ្ញាណ ត្រាស់ដឹងវិសេស ព្រោះតែសេចក្តីព្យាយាមនេះឯង ។ សេចក្តីព្យាយាមនេះ ជាបារមី ๑ ដ៏ប្រសើរបស់ព្រះពោធិសត្វ ដែលកំពុងកសាងនៅឡើយ ហៅថា វីរិយបារមី ។ មួយទៀតការព្យាយាមមិនរួញរានេះ ជាកំឡាំងមួយធំបំផុត ហៅថា វីរិយពលៈ ។

ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ដឹងហើយ ๑ស្បាហ៍ប្រោសប្រទានធម៌ទេសនាអំពីសេចក្តីព្យាយាមនេះជាញឹកញាយណាស់ ចំពោះពុទ្ធបរិសទ្យ៍ពាំងត្រហ្ស្ងួនធឹងបព្វជិត ជាស់តឿនមិនឲ្យខ្ជិលច្រអូសដំអក់ទំនេកងកិច្ចការដែលប្ងួនត្រូវធ្វើ ដើម្បីឲ្យបានចំរើនប្រយោជន៍កងបច្ចុប្បន្ន ។

សេចក្តីព្យាយាមនេះឈ្មោះថាជាឥដ្ឋារម្មណ៍ គឺ អារម្មណ៍ជាទីប្រាថ្នា ជាទីស្រឡាញ់របស់អ្នកប្រាជ្ញគ្រប់សម័យ ។ ចំណែកខាងគោសជ្ជៈ សេចក្តីខ្ជិលច្រអូសឈ្មោះថាជាអនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនជាទីប្រាថ្នា

មិនជាទីស្រឡាញ់របស់អ្នកប្រាជ្ញទាំងឡាយ តាំងពីកាលណាមក ។
សាសនាជម្ងឺ គឺពាក្យប្រៀនប្រដៅរបស់អ្នកប្រាជ្ញក្នុងលោកមានព្រះពុទ្ធជាដើម តែងមានការសរសើរសេចក្តីព្យាយាមនេះរឿយៗណាស់ ។

អ្នកប្រាជ្ញទាំងអស់ក្នុងលោកមិនសើរថា អ្នកប្រាជ្ញក្នុងសាសនាណាទេ សុទ្ធតែស្រឡាញ់សេចក្តីព្យាយាម ស្អប់សេចក្តីខ្ជិល, សូម្បីគ្រូអាចារ្យ មាតាបិតារបស់យើង ក៏ស្រឡាញ់អ្នកមានព្យាយាម ស្អប់មនុស្សខ្ជិលដែរ ។ ព្រោះថាសេចក្តីព្យាយាមនេះ ជាគុណនាំឲ្យភ្ញាក់ដឹងខ្លួនទាន់កាលសម័យ ហើយអាចឈោងចាប់យកប្រយោជន៍បានភ្លាមៗ គឺនាំឲ្យចំរើនកោតសម្បទំ, វិជ្ជាសម្បត្តិ នឹងបរិវារសម្បត្តិ, បំណែកខាងសេចក្តីខ្ជិលប្រៀបដូចជាខ្មោចមួយដុំបំផុត ដែលនាំឲ្យប្រទេសជាតិអាប់ឧនលិចលង់ឲ្យលង់ទៅ ឲ្យឃ្លាងចាកប្រយោជន៍ដែលគួរបានតាមកាលសម័យ គឺនាំឲ្យវិនាស ក្រខ្សត់ខ្សោយថោកទាបរហេមរហាមជាងពួកឥណ្ឌាបច្ចុប្បន្ននេះ ។ បុរសស្ត្រីអ្នកមានព្យាយាម តែងបានទូលាភយសឃើញជាក់ច្បាស់ក្នុងបច្ចុប្បន្ន ទោះបីបុគ្គលមិនសូវមានបុណ្យត្រៃងអំពីជាតិមុនច្រើនក៏ដោយ តែបើជាអ្នកប្រកបដោយសេចក្តីព្យាយាមជាប់ល្អហើយ ទៀងតែនឹងបានឋានន្តរទីដំណែងដ៏ប្រសើរ ម៉ែមិនបានដំកុំមិនខាន ។ បុគ្គលអ្នកមានព្យាយាមត្រូវទទួលផលប្រយោជន៍ តគមានទើសទាស់នឹងច្បាប់ពុទ្ធសាសនាឡើយ ។

សេចក្តីព្យាយាមនេះ មានអានិសង្សឲ្យយើញជាក់លាក់ក្នុងលោកខ្លះដូចជាស្នេហ៍មុខមួយសម្រាប់ប្រគល់ឲ្យនូវគុណតឺ លាភយសសរសើរសុខ ដល់បុរសស្ត្រីអ្នកមានព្យាយាមនោះវិញ ។ សមដូចពុទ្ធភាសិតថា **បដិរូបការី ធុរវិនិដ្ឋាតា វិន្ទតេ ធនំ** បុគ្គលអ្នកមានធុរៈទទួលការងារប្រឹងប្រែងរមែងបានទ្រព្យសម្បត្តិ, **វីរិយេន ទុក្ខមច្ចេតិ** បុគ្គលកន្ទងនូវទុក្ខព្រួយបានកំព្រែងព្យាយាម, **វិយមេបេវ បុរិសោ យោវ អត្ថស្ស និប្ផរា** បុគ្គលជាកូនប្រុសគួរប្រឹងប្រែង កុំលែងឲ្យខាតនៃសម្រេចប្រយោជន៍, **ទុប្ផមេនំ បរក្កមេ** ត្រូវប្រឹងប្រែងចំពោះការនោះឲ្យមាំមួន" ។

បុគ្គលអ្នកមានប្រាថ្នាសេចក្តីសុខចំរើនរុងរឿង ត្រូវតែមានព្យាយាមឲ្យស្ងួតស្ងាញក្នុងកិច្ចការទាំងពួង តាមរយៈកាលនៃវ័យទាំង ៣ គឺ បឋមវ័យ ជាកាលត្រូវទទួលធុរៈខាងការសិក្សាអក្សរសាស្ត្រនឹងវិទ្យាសាស្ត្រផ្សេងៗ, មជ្ឈិមវ័យ ជាកាលត្រូវស្វែងរកកោគសម្បទ, បច្ឆិមវ័យ ជាកាលត្រូវប្រព្រឹត្តសីលធម៌ ដើម្បីឲ្យសមតាមថ្នាក់ជាមនុស្សចាស់ទុំ ។ សេចក្តីអធិប្បាយមកនេះហៅថា ឧដ្ឋានសម្បទា ។

អធិប្បាយប្រយោជន៍ ទី ២

ការគ្រប់គ្រាន់បរិបូណ៌ដោយគំនិតមានយោនិដែលចេះរក្សាទ្រព្យធនមិនឲ្យវិនាសបង់ដោយអន្តរាយផ្សេងៗ មានអន្តរាយដោយក្តៅនេះ

ទឹកលិច ចោរលួចជាដើម ។ ការចេះខុកជាក់លាក់រក្សារៀបចំទ្រព្យ
សម្បត្តិទាំងខាងក្នុងផ្ទះទាំងខាងក្រៅផ្ទះដោយការប្រយ័ត្ន មិនភ្លេចគ្រប់
វេលាយប់ថ្ងៃ នេះជាហេតុ ១ ដ៏ប្រសើរដែលនាំឲ្យគង់ទ្រព្យសម្បត្តិ
ចំរើនដល់ខ្លួនទឹងផ្លែត្រកូលរបស់ខ្លួនវែងឆ្ងាយតទៅ ។ បុរសស្ត្រីក្នុង
ត្រកូលណាមួយ ដែលរង្គាប់បានចំរើនមានសម្បត្តិ ហើយត្រឡប់ទៅ
ជាធ្លាក់ខ្លួនថោកទាបត្រកាល់ទៅវិញនោះ ក៏ព្រោះហេតុតែមិនបរិបូណ៌
ដោយការរក្សាថែទាំ ដែលហៅថាអ្នកស្រីហែសភ្លេចស្មារតីឬហៅថា
ខ្វះអារក្ខសម្បទា ។ ដូចបុគ្គលខ្វះកង់លោកនេះ មានទ្រព្យសម្បត្តិត្រឹម
តែមួយដងៗតែខ្លួនក៏មាន មិនដល់មួយដងៗក៏មាន, មានទ្រព្យសម្បត្តិជាប់
ឃ្លាអង្វែងរហូតដល់ច្រើនតំណត្រកូលទៅក៏មាន ។

បុគ្គលដែលមានគោគសម្បត្តិស្តុកស្តម្ភហើយ មិនតាំងនៅឃ្លាំងបាន
ដោយហេតុ ៤ យ៉ាងគឺ ន ឆ្លឹ ង គវេសន្តិ មិនស្វែងរកទ្រព្យធនដែល
វិនាសខូចខាតហើយ ១, ជិណ្ណំ ន បដិសង្ខរោន្តិ មិនជួសជុលអប
សួបរបស់ដែលចាស់គ្រាំគ្រា ១, អបរិមិត្តភោជនា ហោន្តិ ជាអ្នក
ប្រើប្រាស់របស់មិនមានកំណត់ប្រមាណ គឺជាបុគ្គលខ្ជះខ្ជាយហួសហេតុ ១,
ទុស្សីលំ ឥត្ថឺ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ តាំងស្ត្រី ឬ
បុរសទុស្សីល ទុកក្នុងឥណ្ឌាជាអធិបតី គឺជាអ្នកកាន់ការផ្ទះ ១ ។ ត្រកូល

ដែលធ្លាក់ចោកទាបរៀរកេយទៅជាក្រខាល់ ដោយហេតុ ៤ ប្រការនេះឯង ។ ត្រកូលនេះឈ្មោះថាខ្វះអារក្ខសម្បទា ។

ចំណែកត្រកូលអ្នកមានគោគសម្បទ័ស្តុកស្តម្ភជាបយូរអង្វែងច្រើនតំណទៅបាន ក៏ព្រោះតែហេតុ ៤ ប្រការ គឺ ឧដ្ឋិ គវេសនុ ស្វែងរកទ្រព្យធនដែលវិនាសខូចខាត ១, ធិណ្ណំ បដិសង្ខរោនុ ជួសជុលអបស្សុបរបស់ដែលចាស់គ្រាំគ្រា ១, បរិមិតភោជិនា ហោនុ ជាអ្នកប្រើប្រាស់របស់មានកំណត់ប្រមាណមិនខ្ជះខ្ជាយ ១, សីលវានុ ឥត្ថី វា បុរិសោ វា អាធិបច្ចេ ឋបេនុ តាំងស្ត្រី ឬ បុរសមានសីលទុកក្នុងឋានៈជាអធិបតី គឺជាអ្នកគាន់ការផ្ទះ ១ ។

បុគ្គលដែលប្រកបដោយហេតុ ៤ យ៉ាងនេះ ឈ្មោះថាជាអ្នកប្រកបដោយអារក្ខសម្បទាដ៏គ្រប់គ្រាន់ ។

អធិប្បាយប្រយោជន៍ទី ៣

បុរសស្ត្រីដែលកើតមកក្នុងលោកនេះ ទោះជាបុគ្គលជាន់ខ្ពស់ក្តី ជាន់ទាបក្តី នឹងនៅតាមទំនើងខ្លួនឯងម្នាក់ៗ ពុំបានឡើយ ត្រូវតែមានការសេពគប់ពាក់ព័ន្ធលស្គាល់អ្នកដទៃផងជាជាងប ។ បុគ្គលដែលគេសេពគប់ក៏មានច្រើនពួក គឺជាពួកមនុស្សពាលទុច្ចរិតក៏មាន, មនុស្សក្រណាល់ល្មមសេពគប់បានក៏មាន, មនុស្សជាបណ្ឌិតក៏មាន ។ ការសេព

គប់នេះជាការសំខាន់បំផុត គឺជាមូលហេតុជាបច្ច័យនាំឲ្យបានខ្លួលខ្ពុក
ខោសក័មាន, នាំឲ្យបានសុខចំរើនឡើងក័មាន, ព្រោះហេតុនោះការ
សេពគប់នេះ ត្រូវប្រែយ័ត្នឲ្យណាស់ បើប្រទះនឹងបុគ្គលពាលហើយ
គប់រកដោយពេញចិត្ត ចូលគំនិតនឹងបុគ្គលពាល រមែងនាំមកនូវសេចក្តី
វិនាសឃើញជាក់ច្បាស់ក្នុងបច្ចុប្បន្ន ។

ការសេពគប់នឹងបណ្ឌិតដែលជាអ្នកមានសីលធម៌ដ៏ល្អ រមែងនាំមក
នូវសេចក្តីសុខសួស្តី ។ ការសេពគប់មនុស្សពាលឈ្មោះថាជាការសេព
ទុសដែលនាំឲ្យទាត ។ ការសេពគប់បណ្ឌិត ឈ្មោះថាជាការសេពគប់
ត្រូវ ដែលនាំផ្លូវឲ្យបានចំណេញ ឲ្យសុខចំរើនឥតអាក់ដោយពិត ។
ការសេពគប់នេះ ជាដើមផ្លូវនៃការខូចខាតនឹងការចំរើន ហេតុនោះត្រូវ
យើងពិនិត្យសង្កេតមើលឲ្យជាក់លាក់ · ត្រូវសេពគប់ចំពោះតែមនុស្ស
ដែលមានសីលធម៌ដ៏ល្អ ជាកល្យាណមិត្ត ទើបសម្រេចប្រយោជន៍ដូច
បំណងក្នុងបច្ចុប្បន្ននេះបាន ។

អធិប្បាយប្រយោជន៍ទី ៤

ការលែលកបែងចំណែកទ្រព្យសម្បត្តិ ខំនុកបំរុងជីវិតឲ្យសមគួរ
តាមកំឡាំងទ្រព្យសម្បត្តិដែលរកបាន មិនឲ្យខ្ជះខ្ជាយពេក មិនកំណាញ់
រឹតត្បិតពេក ដើម្បីឲ្យជាប្រយោជន៍បានសុខទាំងចំណែកខ្លួននឹងអ្នក
ដទៃ ។ ការចាយវាយខ្ជះខ្ជាយនោះ ជាហេតុឲ្យកើតវិប្បដិសារៈ ក្តៅ

ក្រែហាយស្តាយក្រោយក្នុងកាលដែលខ្លួនអស់ទ្រព្យសម្បត្តិ; ការចាយវាយកំណាញ់ត្អឹតត្អៃតហួសហេតុពេកនោះ ក៏ជាហេតុឲ្យមានគេហាទិន្នា ដែលមិនជាទីស្រឡាញ់មេត្រីពប់អាន នៃពួកជនទាំងឯកងផ្ទះ ទាំងឯងក្រៅផ្ទះ ព្រោះហេតុនោះ ការប្រើប្រាស់ទ្រព្យសម្បត្តិដែលប្រកបដោយលក្ខណៈត្រឹមត្រូវជាប្រយោជន៍ដ៏ប្រសើរ ។

អ្នកមានទ្រព្យសម្បត្តិ ដឹងប្រមាណក្នុងការចាយវាយ ជាហេតុឲ្យកើតសេចក្តីកក់ក្តៅក្នុងចិត្ត, ទ្រព្យសម្បត្តិដែលស្វែងរកបានមកហើយនោះ មិនមែនសម្រាប់ចំពោះតែខ្លួនឯងម្នាក់ទេ ត្រូវតែបែងចំណែកទ្រព្យសម្បត្តិចេញជា ៥ ចំណែក គឺ ចាយវាយដើម្បីឲ្យសុខស្រួលដល់ខ្លួនឯង១ មាតាបិតា បុត្រធីតារបស់ខ្លួន ១, ដើម្បីឲ្យសុខស្រួលដល់ញាតិមិត្តដែលគួរសង្គ្រោះ ១, សំចំយទ្រព្យសម្បត្តិទុកការពារអន្តរាយ ១, ធ្វើទក្ខិណាទានក្នុងសាសនា ១, ធ្វើពលីទាំង ៥ យ៉ាង មានញាតិពលីជាដើម ១ ។

ការបែងចំណែកទ្រព្យសម្បត្តិត្រូវតាមដំណើរ ៥ យ៉ាងនេះ ហៅថាសមជីវិតា ដែលប្រែថា ការចិញ្ចឹមជីវិតដ៏ល្មមសមគួរ គឺមិនខ្ជះខ្ជាយហួសទ្រព្យសម្បត្តិដែលខ្លួនរកបាន មិនរឹតត្អឹតហួសខ្នុសតម្រាពេក ។ បុគ្គលជាគហស្ថប្រសើរ អ្នកដែលប្រាថ្នានឹងតាំងខ្លួនឲ្យបានសុខស្រួលធូរលុយ ដែលហៅថាជាអ្នកយោងខ្លួនរួចនោះ ត្រូវតែមានការរក្សាខ្លួនទុកឲ្យល្អ រៀរចាកអបាយមុខ ដែលជាផ្លូវនាំឲ្យវិនាសចេញឲ្យ

ស្រឡះ គឺជាអ្នកមិនលេងល្បែងក្តាល់ ១, មិនផឹកទឹកស្រវឹងគឺ សុរាមេរ័យ ១, មិនលោភខ្ទាំងក្នុងផ្លូវមាគ៌ាគ្រាម ១, មិនសេពគប់មនុស្សពាល យកជាមិត្ត ១ ។

ការចិញ្ចឹមជីវិតសមគួរ ដែលត្រូវតាមលក្ខណៈសម្បត្តិ ដូចពោលមកនេះ ហៅថា សមជីវិតា ។

ព្រះពុទ្ធសាសនា ជាសាសនាប្រាប់ប្រយោជន៍ទាំងផ្លូវបច្ចុប្បន្ន និងបរលោក ដើម្បីឲ្យប្រជាជនទទួលអំណោយសេចក្តីសុខ ចំរើនសួមដូចសេចក្តីប្រាថ្នា, មិនមែនពន្យល់បំភ្លឺចំពោះតែប្រយោជន៍ទៅបរលោកតែម្យ៉ាង ឬមិនមែនបណ្តោយឲ្យដេកចាំព្រៃងសំណាងនោះឡើយ ។

ព្រះពុទ្ធសាសនាសម្បូណ៌ពាក្យប្រៀនប្រដៅប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ឲ្យប្រជាជនសិក្សាប្រតិបត្តិតាមនោះជាច្រើនន័យណាស់ មិនមែនខ្វះទេ គឺជាពាក្យដំបូន្មានរំលឹកជាស់តឿនេះ មានកន្លែងគម្ពីរព្រះពុទ្ធសាសនាជាច្រើនណាស់, មិនមែនព្រះពុទ្ធសាសនាទាំងឲ្យឱ្យលែងប្រអូសឲ្យរង់ចាំផលទៅអនាគតតែម្យ៉ាងនោះឡើយ ។

ពណ៌នាធម្មកថាអំពីប្រយោជន៍បច្ចុប្បន្ន ៤ យ៉ាង ក៏សូមស្មុនភ្ជាបញ្ចប់តែប៉ុណ្ណេះ ។

សូមជូនពរចំពោះអស់លោកអ្នកស្តាប់ទាំងឡាយ ឲ្យជ្ញានប្រកបដោយឥដ្ឋមនុញ្ញផលគ្រប់ៗ គ្នា ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្ពេបិ បាណិនោ ។

"សព្វសត្វទាំងឡាយ ដែលដល់នូវសេចក្តីទុក្ខ, សូមឲ្យជាអ្នកឥតទុក្ខទៅ! ដែលដល់នូវភ័យ, សូមឲ្យជាអ្នកឥតភ័យទៅ! ដែលដល់នូវសេចក្តីសោក សូមឲ្យជាអ្នកជាត់សោកទៅ!"

រតនត្តយតេជេន ភូម្មោជរដ្ឋវាសិនោ
វុឌ្ឍិំ វិរុឡ្ហិំ បប្បោន្តុ សទ្ធិភាវញ្ច ងាញ្ជា ។

"ដោយតេជៈនៃព្រះរតនត្រ័យ សូមឲ្យប្រជាជនទាំងឡាយអ្នកនៅកងកម្មជរដ្ឋ ដល់នូវការលូតលាស់ចំរើន នឹងសទ្ធិភាព កុំបីឃ្លាតក្បាយទៅជាប្រការៈដទៃឡើយ!" ។

ពិធីទទួលសម្តេចសង្ឃនាយក

នៅវត្តដំណាក់ សៀមរាប

ព្រះមហា កែ - អឿន រៀបរៀង

ដោយបានទទួលថវៈបញ្ជាការ នៃព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យមេគណ

ថ្ងៃទី ២ គឺថ្ងៃអង្គារ ៥ រោចខែអស្សុជ

មោ"ង ៨ ព្រឹក ហែកបិនព័ទ្ធក្រងសៀមរាប

មោ"ង ៩ ពួកពុទ្ធបរិសទ្យជាច្រើនជួបជុំនៅទីព្រះវិហារ; ផ្នែកខាងបព្វជិតមានព្រះសង្ឃក្នុងវត្តដំណាក់ សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក ជួន - ណាត នឹងព្រះតេជព្រះគុណ ព្រះពោធិវង្សហួត - តាត ជាអធិបតី, ផ្នែកគហស្ថពួកពុទ្ធបរិសទ្យក្រុងកំពេញ នឹងពួកពុទ្ធបរិសទ្យខែត្រសៀមរាប មានឆ្លងរាជប្រតិភូ ហ៊ុយ - មោ"ង នឹងលោក វរសេនីយត្រី ឈួនម្ងុលពេជ្រ ជាអធិបតី, វេរកបិនថ្វាយព្រះសង្ឃ មុននឹងវេរកបិនមានថ្លែងសុន្ទរកថាឆ្លើយតួនឹងទៅវិញទៅមក សុន្ទរកថាខាងពុទ្ធបរិសទ្យកុំពេញដូចមានសេចក្តីតទៅនេះ ៖

សម្តេច !

ព្រះតេជព្រះគុណ ព្រះពោធិវង្ស !

ព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យ !

ព្រះករុណា គ្រប់ព្រះអង្គ !

ព្រះតេជព្រះគុណ ព្រះភជប្រតិភូ !

លោកវរសេនីយត្រី កងឯកទេសខ្មែរ !

លោកសប្បុរសទាំងឡាយ !

ខ្ញុំព្រះករុណា ខ្ញុំបាទ ជាតំណាងទាយកសក សួស - ឆេង ទាយិកា ង៉ែង - គីម ម្ចាស់កឋិនទាននេះ សូមថ្វាយសេចក្តីគ្រែកអរចំពោះសម្តេចព្រះតេជព្រះគុណដែលបានមេត្តាអញ្ជើញមកជាកិត្តិយស ទន្ទឹងចំពោះលោកអ្នកសប្បុរសទាំងឡាយ ដែលបានហៅហាមកឋិនទានមកដល់ទីនេះ ព្រមទាំងលោកសប្បុរសទាំងឡាយជាអ្នកដើរវត្តនេះ ការមេត្តានឹងអញ្ជើញនេះ នាំឲ្យបុណ្យកឋិនមានសភាពរុងរឿងជ្រះថ្លា នាំឲ្យកើតសទ្ធាមុះមុតកើតបីតិសោមនស្សដ៏ក្រៃលែង ខ្ញុំព្រះករុណា ខ្ញុំបាទ សូមគ្រាទុកនូវគុណូបការដ៏ប្រសើរនេះទុកក្នុងដួងចិត្ត ជាអនុស្សរណកិច្ច ឆ្លងឧបការព្រះតេជព្រះគុណ ។ ដទៃពីនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអភ័យទោស សូមអនុញ្ញាតឲ្យរៀបរាប់ដំណើរដើមទង បុណ្យកឋិនទាននេះប្រគេន ទន្ទឹងជូនជាសណ្តាប់ដូចសេចក្តីតទៅនេះ ។

សម្តេច ! ព្រះតេជព្រះគុណ ! បុណ្យកឋិននេះ គួរឲ្យលោកសប្បុរសទាំងឡាយឆ្ងល់ដែរ ខ្ញុំព្រះករុណា ខ្ញុំបាទ នៅក្រុងភ្នំពេញ ឆ្ងាយពីវត្តនេះរាប់រយគីឡូម៉ែត្រ ដូចម្តេចបានជាបបួលគ្នាហៅមកវត្តនេះ ដំណើរនេះមកពីខ្ញុំព្រះករុណា ខ្ញុំបាទ ជាអ្នករកទទួលទាន តែងទៅមកកាន់ទីនេះរឿយៗ

ជាន់ជាចូលមកគោរពនមស្សការព្រះរតនត្រ័យ ជាន់ឃើញវត្តនេះមាន
សេចក្តីរុងរឿង មានកុដិសាលាល្អ មានទីសមាធិរហោឋាន មានភិក្ខុ
សាមណេរកុះករអាស្រ័យនៅរៀនសូត្រ ក៏កើតសេចក្តីជ្រះថ្លានឹកមមៃនៅ
ក្នុងចិត្តថា: គួរអាត្មាអញបំពេញកុសលអ្វីហ្នឹង ទុកជាបុញ្ញនិធិក្នុងវត្តនេះ ។
ដើរសរើសកុសលចាំងពួនគៅ ឃើញថាគួរនាំកថិនមកវេរថ្វាយភិក្ខុសង្ឃ
ដែលគង់ចាំវស្សាអស់កំឡុងវៃ្រមាសក្នុងវត្តនេះ ព្រោះស្រុកនេះ មិន
ដែលមានអ្នកតុំពេញហែកថិនមកទេ ទើបជាន់ហែកថិនមកនេះ កថិននេះ
ជាកុសលមួយប្រសើរណាស់ ព្រោះនឹងកើតជាអបាយមរចេតនាកុសលចិត្ត
ជាប់នៅក្នុងចិត្តមិនក្ងេច អស់កាលយូរអង្វែង កើតមកពីដំណើរផ្លូវធ្វើយ
កម្រនឹងមានលោកសប្បុរសណាមួយធ្វើជាន ។

មួយទៀត កាលនេះ ជាកាលជាន គួរតែបំពេញនឹងទានពុំ
ជាន នឹងជាន់ជាទុក្ខិណានុប្បទានកិច្ចសង្គ្រោះដល់បុព្វការីបុគ្គលតាំង-
ឡាយមានមាតាបិតាជាដើម នឹងជាកិច្ចធ្វើអាយុសង្ខារឲ្យជាន់ញយ។
ព្រោះជីវិតសត្វមិនទៀងទាត់ ។ ខ្ញុំព្រះករុណា ខ្ញុំជាន កំឡាប់បំពេញ
កុសលរៀងរាល់ឆ្នាំ មានធ្វើបុណ្យកថិននឹងហែផ្ការនឹងកុសលឯទៀត
ច្រើនប្រការ តាមសណ្តាប់អ្នកតាន់ព្រះពុទ្ធសាសនា ដើម្បីជួយ
កសាងសេនាសនៈក្នុងវត្តអារាមផ្សេង។ ជាច្រើនវត្ត ព្រោះជាន់ស្តាប់
ធម្មទេសនាលោកអ្នកប្រាជ្ញ លោកប្រដៅថា: គួរបំពេញកុសលទុក

ជាបុញ្ញនិធិឲ្យបានរឿយ ។ កុសលនេះហើយជាអាយុទ្យឲ្យយើងពិត
ប្រាកដ ហើយជាឧបនិស្ស័យជួយបន្ទុំបារមីយើងឲ្យចាស់ក្លា ឆាប់បាន
ត្រាស់ដឹងមគ្គផលនិព្វាន កន្ទុំដ៏ផុតសេចក្តីទុក្ខគ្រប់ប្រការក្នុងសង្សារ-
វដ្តនេះ ។ ទ្យសម្បត្តិនេះ បើចេះគិតលែលក ទើបបានជាប្រយោជន៍
បើមិនចេះលែលកទេ ក៏អសារបង់ឥតអំពើ ហើយត្រូវប់ជាមានទោស
ព័ន្ធខ្លួនទាំឲ្យអន្តរាយកំណើត ដូចអានន្ទសេដ្ឋីទៅកើតជាកូនចណ្ឌាល
រូបអាក្រក់ដូចបិសាច កាន់អំបែងដើរសុំទានគេ រហូតដល់ផ្ទុះខ្លួនឯង
ត្រូវកូនខ្លួនឯង ឈ្មោះមូលសិរីស្មានថាជាខ្មោច រាយសម្ងាច់យកទៅ
បោះចោលលើគំនរសម្រាម ។ ទ្យសម្បត្តិដែលយើងខំប្រឹងរក
បានមកនេះ បើមិនបរិភោគខ្លួនឯង ទឹងមិនបរិច្ចាគជាសាធារណៈទានទេ
តើមានប្រយោជន៍អ្វី? បើគ្រាន់តែរកយកមកគរទុកច្រើន ដើម្បីឲ្យបាន
ឈ្មោះថាជាមហាសេដ្ឋី នោះអ្នកគ្រីក្រ ក៏អាចពោលអួតខ្លួនជាមហា
សេដ្ឋីបានដែរ ។ ទ្យសម្បត្តិនេះ កាលរកលំបាកម្តង។ បានហើយ
លំបាករក្សាម្តង វិនាសទៅវិញ ក្តៅក្រហាយចិត្តម្តងទៀត បើដូច្នេះ
ទ្យសម្បត្តិនេះ មានប្រយោជន៍ដូចម្តេចខ្លះ? ។ ព្រោះហេតុនេះហើយ
បានជាលោកពោលថា អ្នកចូរជ្រាកសេចក្តីកំណាញ់ គួរបំពេញ
ទានឲ្យបានរឿយ។ ធ្វើបុណ្យញយ។ បានបុណ្យញយ។ ធ្វើឲ្យស្មូនធ
អ្នកស្រុកល្អញយ។ ព្រោះទ្យដែលបំពេញទានជាកុសល ទើប

ឈ្មោះថាជាទីពឹងរបស់យើងមែនទែន ។ អាស្រ័យហេតុដូចបានពោលមកខ្ញុំៗនេះ ជាដើមទង់ទើបកើតជាកថិនទានក្នុងថ្ងៃនេះឡើង ។ ការហៅកថិនមកនេះ មានហេតុសំខាន់ច្រើនប្រការណាស់ ណាមួយផ្លូវឆ្ងាយជាប់ស្រយាល ណាមួយប្រកបដោយភ័យច្រើនប្រការ ជាហេតុនាំមិនឲ្យមានលោកសប្បុរសចង់មកជួយហែហម តែដោយសេចក្តីខ្ជាប់ខ្ជួនជាកម្លាំងខ្ញុំព្រះករុណា ខ្ញុំបាទ ក្លេចនឹកដល់សេចក្តីលំបាក ទឹងភ័យនេះអស់ គោះជាយ៉ាងណាក៏ចេះតែខំប្រឹងហែមកវេរថ្វាយព្រះសង្ឃឲ្យបានសម្រេចដូចបំណង ។ ឥឡូវនេះគោលបំណងបានសម្រេចហើយ កថិនទានយើងបានហែមកដម្កល់កណ្តាលដំនុំសង្ឃដោយសុវត្ថិភាពហើយ ខ្ញុំព្រះករុណាខ្ញុំបាទ មានសេចក្តីត្រេកអរយ៉ាងក្រៃលែង រកអ្វីប្រៀបមិនបាន យើងខ្ញុំនឹងវេរថ្វាយព្រះសង្ឃក្នុងពេលនេះ មុនវេរ ខ្ញុំសូមជូនកុសលផែលកើតពីកថិនទាននេះ ។

ទី ១ បំពោះបុព្វការីបុគ្គលមានមាតាបិតាជាដើមរបស់យើងខ្ញុំគ្រប់គ្នា គោះអស់លោកទាំងនោះមានជីវិតរស់នៅក្តី លះបង់លោកនេះទៅកាន់បរលោកហើយក្តី សូមឲ្យបានទទួលឥដ្ឋមនុញ្ញផលវិបុលសុខគ្រប់ប្រការ ទាំងនាលោកនេះ នឹងបរលោកកុំបីខានឡើយ ។

ទី ២ សូមជូនកុសលដ៏ប្រសើរនេះ បំពោះសប្បុរសញាតិមិត្តដែលបានចូលចាប់កុសល ហើយបានជួយហែហមកថិនទាននេះរហូតមកដល់

វត្តនេះ នឹងចំពោះលោកសប្បុរសទាំងឡាយក្នុងទីនេះ ដែលបានអញ្ជើញមកជួយអនុមោទនា ដោយកុសលចេតនា នាំឲ្យកថិនទាននេះរុងរឿងជ្រះថ្លា សូមលោកសប្បុរសទាំងឡាយគ្រប់រូប បានទទួលកុសលពាសីដ្ឋឆ៏ន្ទស់ ឲ្យបានសម្រេចសម្បត្តិទាំង ៣ ប្រការ គឺសម្បត្តិមនុស្ស សម្បត្តិទេពតា នឹងសម្បត្តិព្រះនិព្វានកុំបីឃ្លាត ។

ទី ៣ សូមជូនកុសលដល់ពួកទេវបុត្រទេវតាក្នុងសែនកោដិចក្រវាឡ សូមឲ្យបានបុញ្ញាគតក្នុងកថិនទាននេះស្មើភាគគ្នានឹងយើងខ្ញុំ ដោយអំណាចបុញ្ញាគនេះ សូមឲ្យទេវបុត្រទេវតាទាំងឡាយនោះ។ បានសម្រេចសម្បត្តិពិព្វដ៏វិសេសជាកិយ្យាភាព សមតាមសេចក្តីប្រាថ្នា ហើយសូមជួយអភិបាលថែរក្សាអស់លោកសប្បុរសទាំងឡាយ ឲ្យតាំងនៅក្នុងសេចក្តីសុខ សេចក្តីចំរើនគ្រប់ប្រការ ព្រមទាំងការពារឧបទ្ទវច្រៃ សត្រូវកេតាព្យាធិ ឲ្យបរវៀសចៀសចេញឆ្ងាយទៅ កុំបីចៀតបៀនបានឡើយ ។

ទី ៤ - សូមជូនកុសលដល់អស់លោកដែលជួយយានដំនិះកងការយោហាមកថិននេះ គឺ:

ឧបាសក ប៊ុន - តេង	ឧបាសិកា រួច - ម៉ែង
- គី - សេង	- ណៃ - សឹម
- វ៉ែង - យិន	- ណៃ - ហោ

— គីរ៉ែន - យ៉ែត — គិម - ឆេង

— ចាំ៉រ - ផន — លាង គាត

— ឃាង - ហៀត — សុខ - ហេង

— ណៃ - សឿន

— អ៊ីវ - ហៀក

បើមានសេចក្តីច្រឡំយ៉ាងណា សូមឲ្យបានសម្រេចតាមសេចក្តីច្រឡំកុំបីអាក់ខាន ។

ទីបំផុត សូមគ្រែកអរចំពោះបដិសណ្ឋារកិច្ចរៀបចំទទួលយើងខ្ញុំព្រះករុណា ខ្ញុំបាទ ដោយបណ្តិតកោដន្ញីយាហារ នឹងទីសំណាក់អាស្រ័យដ៏ប្រសើរនៃព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យ នឹងអស់លោកសប្បុរសដើងវត្តទាំងអស់ យើងខ្ញុំព្រះករុណា ខ្ញុំបាទ សូមកត់ត្រាទុកជាអនុស្សរណីយវត្ថុដ៏ប្រសើរក្នុងដួងចិត្តយើងគ្រប់គ្នារហូតកល្បាវសាន ។ បើសេចក្តីប្រកាសខ្ញុំព្រះករុណា ខ្ញុំបាទនេះ សមតាមសេចក្តីច្រឡំអស់លោកសប្បុរសទាំងឡាយហើយ សូមអស់លោកសប្បុរសទាំងឡាយអនុមោទនាថា សាធុ ឲ្យត្រមៗគ្នាទៅហោង ។

លុះចប់ហើយ ។ ចាសកនៃងប៊ុនឡឹងជាតំណាងពុទ្ធបរិស័ទ្យវត្តតំណាក់ថ្លែងសុន្ទរកថាតបទៅវិញដូចមានសេចក្តីតទៅនេះ ៖

សូមថ្វាយបង្គំចំពោះសម្តេច !

សូមថ្វាយបង្គំចំពោះព្រះតេជព្រះគុណ ព្រះពោធិវង្ស ព្រមទាំងព្រះ ថេរានុត្ថេរៈ ទាំងឡាយដោយគោរព ;

សូមប្រណិប័តន៍ព្រះតេជព្រះគុណ ព្រះពជប្រតិកូ ទៃត្រសៀមពប !

សូមប្រណិបតន៍ព្រះតេជព្រះគុណវរសេនីយត្រី (ឯកទេស) ទីឆ អស់លោក អ្នកជាពុទ្ធបរិស័ទ្ធទាំងឡាយ មានលោកស្ងួស-ឆេង ឧបាសិកា ង៉ែន-គីម ជាដើម ដែលជាសាមីកម្មឧបាសកជនេះ ដោយគារវភាព !

កិត្តិយសដ៏ប្រសើរកើតឡើងយ៉ាងអស្ចារ្យ ដល់ព្រះពុទ្ធសាសនា នៅនាវត្តដំណាក់កណ្តៀងថ្ងៃនេះ ទាំងយើងខ្ញុំអត់ទ្រាំពុំបាន សូមសរសើរដល់ សទ្ធាបញ្ញាទីឆចិត្តដ៏ក្លាហានរបស់លោកជាទានសាមី ទាំងប្រុសស្រី ដែលចំបូលញាតិមិត្តទាំងជិតឆ្ងាយ ឲ្យជួយខ្វល់ខ្វាយហែហមអមអង្គ ព្រះកឋិនមកកាន់ផ្លូវឆ្ងាយជាច់ស្រយាលចំនួន ៣១៤ គីឡូម៉ែត្រយ៉ាងនេះ ក្មេចគិតពីលំបាកនឿយទីឆគ្រោះថ្នាក់តាមផ្លូវទៅមក ក្មេចគិតពីសេចក្តី ជាច់ខាតធនធានតិចច្រើនសោះឡើយ ; ហើយបានទាំងជួយនិមន្តសម្តេច ព្រះសង្ឃនាយកទីឆព្រះតេជព្រះគុណ ព្រះពោធិវង្ស មកឲ្យទានធម៌ ទេសនាដល់យើងខ្ញុំគ្រប់គ្នានៅទីនេះស្តាប់ទៀតផង ។

លោក ស្ងួស-ឆេង . . . . !

ចូរលោកគ្រែឡែកក្នែកមើលចុះ "វត្តដំណាក់នេះ កាលលោកចូលមកឃើញពីជាន់មុន មិនទាន់ដឹងខ្លួនថាលោកនាំមេបុណ្យធំៗជាអស្ចារ្យយ៉ាងនេះមកទេ លុះដឹងពេលណា ក៏សម្អាតកាយ ហើយប្រដាប់ដោយគ្រឿងលំអប្លែកៗរងំចាំទទួលអនុមោទនាមេបុណ្យរបស់លោក ។ យើងខ្ញុំសូមឲ្យឈ្មោះថា មេបុណ្យ ព្រោះបុណ្យកចិននេះធំប្លែក ហើយចំឡែកអំពីកចិនគេតែងធ្វើធម្មតា នាំឲ្យមានផ្កាដៃច្រើនជាអនេក ដែលកើតកូនពួនជាច្រើនបុណ្យតៗទៅទៀត ដោយសារលោកនាំមេបុណ្យធំមកផ្សាយចំកណ្តាលទីក្រុងសៀមរាបនេះ ។

លោកឃើញស្រាប់ហើយ ! ពួកពុទ្ធបរិសទ្យទាំងគ្រហស្ថទាំងបព្វជិត ដែលចូលមកមើរគ្រៀបត្រាអង្គុយខ្លះ ឈរខ្លះនេះ សុទ្ធតែនៅវត្តនៅភូមិ-ស្រុកជាច្រើនព័ន្ធគ្នាទេ ប៉ុន្តែក្បាក់ឆ្អើលកកកុំកមកច្រើនគគ្រឹកគគ្រែងនេះ ដោយសារពុទ្ធសន្តឹកបុណ្យធំជាច្រើរបស់លោកទេ ដែលហែកចិនទាន. ហើយចេះនិមន្តយកសម្តេចនឹងព្រះតេជព្រះគុណព្រះពោធិវង្សឲ្យបានមកសំដែងធម៌ទេសនា ! ។

ដោយមានសង្ឃឹមជាមាំថា: សម្តេចទើបនឹងត្រឡប់មកពីលង្កាទ្វីប ហើយបាននិមន្តទៅគេឃើញកន្លែងអស្ចារ្យ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់គង់គ្រាស់ ហើយនិព្វានទៅ នៅសល់តែបូជនីយដ្ឋាន មានដើមពោធិ-ព្រឹក្សជាដើមនោះនឹងតំណាលប្រាប់ផង; លោកជាបស្រាប់ហើយ នាយ

ពាណិជគឺពួកឈ្មួញនានា ដែលនាំយកការៈមានទ្រឹមសារទៅដូញនោះ ទោះបីនាំទៅតាមផ្លូវទឹកដោយទូកឬសំពៅក្តី ឬក៏នាំទៅតាមផ្លូវគោកដោយរទេះក្តី ក៏ប្រយោជន៍ដើម្បីតែចំណេញម្យ៉ាងប៉ុណ្ណោះ ។

ឯដំនូញសាសនារបស់លោកនេះក៏ដូចគ្នា ព្រោះថាលោកទំនាំអង្គកថិនទាន នឹងទិមន្តធម្មថិកហ៊ានឯកៗមកជាក់ទានធម៌ ក៏ប្រយោជន៍ដើម្បីយកតែបុណ្យម្យ៉ាង គ្មានគិតយកផលប្រយោជន៍អ្វីដទៃឡើយ; ដំនូញបុណ្យនេះខ្ញុំយល់ថាចំណេញហើយ ដោយមានពុទ្ធបរិស័ទជាច្រើននាក់ ស្ម័គ្រចិត្តស្រឡាញ់សាសនាដ៏ថ្លានោះ ។

សូមធ្វាក់ឈ្នោះលោកព្រមទាំងការិយា ស្លាប់ក្នុងដួងហឫទ័យគ្រប់ៗគ្នា ទុកជាអនុស្សាវរីយ៍ គឺទុកជាទីរលឹកមិនភ្លេចឡើយ ។ ដូចរុក្ខជាតិល្អិជាតិនៅបុងគីម្ហាដូវដែលត្រូវទឹកភ្លៀងធ្លាក់ប៉ុះមក ក៏ដុះលូតលាស់ស្ទឹកខៀវខ្ចីស្រស់យ៉ាងណា? ពុទ្ធមាមក:ពុទ្ធមាមកានៅនាទីនេះ ក៏មុខជានឹងមានសទ្ធាលូតលាស់ដុះដាលឡើងយ៉ាងនោះដែរ; ដោយសារតែទឹកភ្លៀងពោលគឺព្រះធម្មទេសនា ដែលហូរចេញអំពីព្រះឧស្សម្ភេចមិនខាន ទោះបីយូរនាប់ ដោយស្មានមើលតាមកាលរយៈវេលាកន្លងទៅ ២០ ឆ្នាំហើយមកដល់សព្វថ្ងៃនេះ ឃើញថាចំរើនដោយការរៀនសូត្រហូតដល់សេចក្តីប្រតិបត្តិថ្លៃកជាងមុនច្រើនណាស់ទៅហើយ គួរឲ្យសង្ឃឹមថាពីពេលនេះតទៅ មុខជានឹងមានការចំរើនលឿនច្រើនជាងមុនជាកិយ្យាភាព ដោយ

សារបាន១ខមរជនតាំងក្នុងចាស់ តាំងនាមុន-ពស្តែ ចេះស្រឡាញ់សាសនារបស់ជាតិ ចូលខ្លួនមកជួយឧបត្ថម្ភគាំទ្រជ្រោមជ្រែង បីពស់ួយទ្រឡើងស្មើរតែនឹងគ្រប់គ្នា ។

នៅទីបំផុតនេះ យើងខ្ញុំសូមអរគុណដ៏ធំរៃលែង ចំពោះព្រះតេជព្រះគុណព្រះពជ្រតិកូ១ត្រ នឹងព្រះតេជព្រះគុណវរសេនីយត្រី (ឯកទេស) នឹងអស់លោក-អ្នកសប្បុរសតាំងឡាយដែលបានធ្លើកចិនវិហមកមានលោក សួស-ឆេងជាដើម ព្រមតាំងអស់លោកតាំងឡាយដែលបានជួយខ្វល់ខ្វាយរៀបចំទទួលបុណ្យកថិនេះផង ។

សូមឲ្យលោកបានប្រកបដោយសេចក្តីសុ១ · ចំរើន · គ្រប់ ។ គ្នាទៅហោង ។

ស្ស្ស្ស្ស !!! ជយោព្រះពុទ្ធសាសនា

លុះចប់សុន្ទរកថាតាំងពីរហើយវេរកថិនថ្វាយព្រះសង្ឃសម្រេចកិច្ច ។

មៅង ៩ យប់និមន្តសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក សំដែងធម៌ទេសនា ។ នោះសម្តេចទ្រង់សំដែងអំពីប្រវត្តិព្រះពុទ្ធសាសនាក្នុងស្រុកខ្មែរ នឹងសំដែងអំពីដែលសម្តេចទ្រង់និមន្តទៅកាន់លង្កាទ្វីប នឹងប្រទេសតណ្ហៀ ព្រះសទ្ធម្មទេសនានោះជាទីពីរោះជាប់ចិត្តជក់ទៅក្នុងហឫទ័យវត្តនៃពុទ្ធបរិស១គ្រប់ ១រូប! ពុទ្ធបរិស១ខ្លះលាន់មាត់ថា "ពីរោះអ្ហ៊ីម្ល៉ះហ្ន៎ ! អើនេះ ហៅពេញជាពីរោះ" ចំនួន ៤ មៅង៏កន្លះទើបចប់ ។

លុះចប់ធម៌ទេសនាហើយ លោកវរៈសេនីយត្រីថ្លែងទទួលអំណរធម្មទេសនាសម្តេច ចំនួនកន្លះមោង នឹងចាត់ការឲ្យកងឯកទេសសំដែងនូវភ្លេងជាតិ នឹងរាំវង់តទៅទៀត ដរាបដល់ម៉ោង ២ ទើបឈប់ ។

បុណ្យកងខែត្រសៀមរាបក្នុងពេលនេះ ប្រសើរវង្សវឿងអស្ចារ្យជាងកាលណាៗទៅទៀត ព្រោះពុទ្ធបរិស័ទដែលមកពីក្រុងភ្នំពេញ ១២០ រថយន្ត នឹងពុទ្ធបរិស័ទក្នុងខែត្រសៀមរាប ដែលមកពីទិសនានា ច្រើនមិរកុះករណាស់ណាន់តាន់តាប់ ពេញពោរពេត្តដំណាក់ ស្ទើរតែដើរចៀសគ្នាពុំរួច . តាំងបពូជិតតាំងគ្រហស្ថ ។

ដោយតេជានុភាពនៃកុសលពលកងពេលនេះ យើងខ្ញុំព្រះអង្គសូមផ្ទន់ហត្ថាដាក់លើសិរសា ទទួលបង្គំនមស្ការចំពោះព្រះប្រិយមហាក្សត្រិយ៍ព្រមទាំងព្រះពជវង្សានុវង្ស សូមឲ្យទ្រង់គង់នៅក្នុងព្រះសិរីរាជសម្បត្តិខ្ចាត់កយាជាសុខសាន្ត សម្បាន្តក្នុងព្រះកាយពល ដើម្បីសម្រក់ព្រះធាតុព្រះមេត្តាព្រហ្មវិហារគ្របដណ្តប់លើប្រជាជនកងក្នុងព្រះរដ្ឋ កុំបីមានឧបស័គ្គមកពាក់ព័ន្ធព្រះពជហឫទ័យទ្រង់បានឡើយ ។

ម្យ៉ាងទៀត សូមសំបូង សំរួងឲ្យប្រទេសកម្ពុជា ប្រកបដោយសន្តិសុខ នឹងសម្បទា ៣ ប្រការ គឺ :

១ - មុនិសម្បទា សូមឲ្យសម្បូណ៌ដោយអ្នកប្រាជ្ញពជញ្ញតក្នុងផ្លូវលោកផ្លូវធម៌ ;

២ — កោគសម្បទា សូមឲ្យសម្បូណ៌ដោយកោគសម្បត្តិ;

៣— សាមគ្គីសម្បទា សូមឲ្យសម្បូណ៌ដោយសាមគ្គីធម៌ ទាំង
ផ្លូវលោកផ្លូវធម៌ ។

ដើម្បីឲ្យសក្តិសមតាមហាន:ជាប្រទេសឯករាជ្យ

១ ទៀត, សូមឲ្យប្រជាជនក្នុងកម្ពុជរដ្ឋទាំងមូល ប្រកបដោយសេចក្តី
សុខសេចក្តីចំរើន អស់កាលជានិរន្តរ៍តរៀងទៅហោង ។

អនុសាវរៈមហាសន្និបាត លើកទី ៧

នៃមន្ត្រីសង្ឃ ក្នុងព្រះរាជអាណាចក្រ កម្ពុជា

រៀបរៀង

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ



កាលនៅថ្ងៃទី ២៣ ខែមករា ឆ្នាំ ១៩៩១ មន្ត្រីសង្ឃទាំងឡាយក្នុងព្រះរាជអាណាចក្រ បានធ្វើពិធីអនុសាវរៈមហាសន្និបាតឆ្នាំ ទី ៧ នៅវត្តព្រះកែវមរកត ក្រុងភ្នំពេញ ។ ក្នុងវេលាម៉ោង ៩ កន្លះព្រឹកនៃថ្ងៃនោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងខ្ពង់ព្រះពស្ត្រតាមទំនៀម បានខ្ពង់ស្តេចយាងទៅជាព្រះរាជាធិបតីកិត្តិយសក្នុងពិធីមហាសន្និបាតនេះ ។ កាលព្រះបរមរាជវង្សានុវង្សស្តេចដោយរថយន្តដល់ច្រកទ្វារមុខនៃព្រះអារាម, មានក្រុមចៅហ្វាយព្រះអង្គ និងក្រុមភ្ញៀវព្រះរាជទ្រព្យធ្វើគារវកិច្ចតាមទំនៀម ។ នៅទីនោះព្រះអង្គក្រុមហ្លួង នាយករដ្ឋមន្ត្រី, ឯកឧត្តម អ៊ុំ - ស៊ុន - ឈាង ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ, សមាជិក-រដ្ឋាភិបាលជាច្រើននាក់, ឯកឧត្តម សាន - យុន ជាចៅហ្វាយក្រុង និងឥស្សរជនជាច្រើនទៀតជាច្រើនក៏បានចាំបែរព្រះរាជា ។ តពីច្រកទ្វារមុខនៃព្រះអារាមទៅ ព្រះករុណាស្តេចដោយព្រះបាទ ឆ្ពោះទៅកាន់ព្រះធម្មមន្ទីរដែលមានសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ, សម្តេច

ព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ សម្តេចព្រះធម្មលិខិត ទត្តមប្រីក្សា ល្លឹងម ហើយនឹងមន្ត្រីសង្ឃក្នុងព្រះរាជអាណាចក្រទាំងមូលដែលមានចំនួន ១៥០ អង្គ បាននិមន្តទៅជួបជុំយ៉ាងស្មោះសរក្នុងទីនោះ ។ ក្រៅពីមន្ត្រីសង្ឃទាំងនេះ ឃើញមានចៅអធិការមកពីខែត្រក្រៅ ហើយនឹងកិត្តិសាមណេរជនៃខេត្តចំនួនជាង ៥០០ អង្គ គង់ត្រៀបត្រាពេញទាំងថែវខាងត្បូងជាមួយពួកអាចារ្យវត្តនឹងឧបាសកឧបាសិកាទាំងក្នុងទីក្រុងនឹងខែត្រក្រៅ ជាច្រើនរយនាក់ទៀត ដើម្បីរង់ចាំស្តាប់ព្រះបរមពាដនុង្ហានន្ទូវព្រះពាជបន្ទូលសូរសីហនាទ នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលមានឧគ្ឃោសនសព្ទបំពងព្រះសូរសៀង ។

ពិធីនេះបានចាប់ផ្តើមឡើង ក្រោយដែលមានការបង្ហុកូលថ្វាយព្រះបិតរនៅចេតិយខាងមុខព្រះវិហារ ។ ព្រះពាលុះទ្រង់ធ្វើនមស្សការចំពោះព្រះសង្ឃទាំងឡាយរួចហើយ ទើបទ្រង់ថ្លែងព្រះពាជសុន្ទរកថាមួយពន្យល់អំពីរបៀបនៃឯកពាជ្យប្រទេសយើង ដែលយើងសូមយកមកផ្សាយជូនទាំងមូលដូចតទៅនេះ -

ព្រះពាជសុន្ទរកថា

(មហាសន្និបាតប្រជុំលោកមេគណនិងព្រះសង្ឃគណៈ)

នៅឧកាសដែលលោកគ្រូនិមន្តមកប្រជុំអនុសំវច្ឆរៈមហាសន្និបាតសំពាប់ឆ្នាំនេះ, ខ្ញុំករុណាសូមថ្វាយបង្គំលោកគ្រូដោយគោរពជាបំផុត

ហើយសូមថ្លែងសេចក្តីសោមនស្សរីករាយនៃខ្ញុំកុណា ដោយយើញ
លោកគ្រូសុខសប្បាយគ្រប់ព្រះអង្គដូចកាលមុន ហើយនិមន្តមកពីវៃត្រ
ក្រៃជាច្រើនព្រះអង្គផង ។

ខ្ញុំកុណាដឹងណាស់ អំពីដំណើរដែលអាណាវៃត្រយើងនឹងអ្នក
ស្រុក តាំងបព្វជិតនឹងគ្រហស្ថនៅកន្លងអាណាវៃត្រតាំងប៉ុន្មាន វេទនា
ក្នុងវេទនាកន្លងសម័យនេះ ដោយអសន្តិសុខនឹងវិនាសកម្មច្រើន មកពី
អសន្តិសុខនេះយ៉ាងណា ។ ដោយហេតុនេះ បានជាខ្ញុំកុណាតែង
ជាដកបទៅដល់ស្រុកស្រែចំការរបស់យើងពុំដែលអាក់ខាន, បានជា
រដ្ឋាភិបាលនឹងខ្ញុំកុណា ទំប្រឹងទុកចិត្តជាបំផុត ដើម្បីបំរើប្រទេស
ធ្វើឲ្យរបូតរួចពីទុក្ខវេទនាឲ្យខាងតែបានតាមដែលធ្លើទៅកើត ។

ខ្ញុំកុណាដឹងថា មិនគួរនឹងអធិប្បាយអំពីការណ៍នយោបាយពិត
លោកគ្រូទេ តែខ្ញុំកុណាដឹងដែរ អំពីការដែលលោកគ្រូយកព្រះ
ទ័យទុកដាក់យ៉ាងណា នឹងកាសនាប្រទេសយើង ដែលមានព្រះពុទ្ធ-
សាសនាជាទីពឹងពំនាក់ជ្រួសប្រសើរនេះ ។ ដូច្នេះខ្ញុំកុណាត្រូវពិត
ពុទ្ធដីកាលោកគ្រូជាប្រ អំពីស្ថានការណ៍ប្រទេសយើងដោយសង្ខេប ។

ស្ថានការណ៍នេះ មានអសន្តិសុខតែរួបគ្រប់សង្កត់ជុំជិត ។ តើយើង
ចាត់ការបានសម្រេចអ្វីហើយ ដើម្បីនឹងកំចាត់អសន្តិសុខនោះ ។ យើង
ដឹងពាល់រួបទាំងអស់ថា អ្នកដែលបង្កើតអសន្តិសុខនេះ គឺបង្កើតដោយ

យកនាមឯកភាជ្យមកចាំងថា ខ្ញុំនឹងធ្វើឲ្យបានឯកភាជ្យឲ្យប្រទេសកម្ពុជា ។ ខាងវៀតមិញក្តី ខាងឥស្សរៈក្តី ពួកដែលតយុទ្ធនឹងចាក់ តយុទ្ធនឹងកងទ័ពរដ្ឋាភិបាលយើង តែងមានវាចាថា ខ្ញុំធ្វើចម្បាំងដើម្បីនឹងដេញចាក់នេះ ១, ហើយមួយវិញទៀតថា ធ្វើចម្បាំងដើម្បីធ្វើណ្តែកម្អកភាជការទេមរជាតដែលខ្ញុំប្រកាន់ថាជាអ្នកសមគំនិតនឹងចាក់នេះ ២ ។

គឺមកអំពីគិតធ្វើឲ្យលែងមានខ្វែងគំនិតគ្នាដូច្នោះទៀត មកអំពីគិតការពារសន្តិសុខដែលវិនាសទៅ ដោយពួកអ្នកដែលតាំងខ្លួនថាជាអ្នកចេះស្រឡាញ់ជាតិជាងយើង នេះហើយ បានជាកងការដែលបង្ក្រាបអសន្តិសុខនេះ រដ្ឋាភិបាលនឹងខ្ញុំករុណាបានប្តេជ្ញាចិត្តគិតសង្គ្រាត ធ្វើឲ្យបានសម្រេចនូវបំណង ១ ជាបឋមហេតុសិន គឺធ្វើឯកភាជ្យដោយពេញលេញ ។

ឥឡូវនេះ ខ្ញុំករុណា អាចនឹងពិតពុទ្ធដីការលោកគ្រូបានដោយស្មោះថា បំណងរបស់យើងនេះ បានសម្រេចជិតពេញបំណងហើយ ។ ឯកភាជ្យរបស់យើង បានសម្រេចដល់ ៨០ ភាគរយ ។ ក្រៅអំពីកិច្ចការខាងតុលាការ នឹងកិច្ចការខាងសឹកសង្គ្រាម នោះឯកភាជ្យរបស់យើងឥតមានអ្វីជាឧបសគ្គទៀតទេ ។

ឯសន្តិសិទនាក្រុងប៉ូ បានសម្រេចការថា ក្រុមភាជការតាំងប៉ុន្មានដែលនៅខ្វះមិនទាន់បានមកយើង ដើម្បីបំពេញការឯកភាជ្យរបស់យើង

ឲ្យពេញលេញឡើង នោះត្រូវផ្ទេរមកឲ្យប្រទេសយើងទៀត មានក្រុមគយ, ក្រុមប្រៃសនីយ៍ ទឹងឃ្មាងប្រាក់ជាដើម ។ ក្រុមទាំងនេះត្រូមទាំងអំណាចចាត់ការក្នុងក្រុមនេះ ត្រូវបានមកយើងពេញអធិបតេយ្យកងដែនប្រទេសយើងទាំងមូល ។ អំណើះតទៅ លែងមានក្រុមពាជការរួមទៀតហើយ ក្រុមទាំងនេះត្រូវផ្ទេរឲ្យដែនីមួយៗ នៅមានតែក្រុមពាជការរួមគ្នាបីដែលត្រូវជួបជុំ ដំនុំតែវេលាណាដែលអាណាប្រយោជន៍នៃប្រទេសលាវ, ប្រទេសវៀតណាមទឹងប្រទេសកម្ពុជា មានប្រស្រ័យទាក់ទងនឹងគ្នា; ប្រទេសប្រាំងនឹងចូលដំនុំការក្នុងក្រុមកម្មាធិការនេះបានតែកាលណា ដែលត្រូវមានកិច្ចការពារអាណាប្រយោជន៍ប្រទេសប្រាំងប៉ុណ្ណោះ ដែលប្រយោជន៍ដែនដីប្រាំងខាងនាយសមុទ្រនៅប្របវដ្តយើងទាំង ៣ នេះ ។

ជាប្រការដោយឡែក យើញនៅមានអង្គការមួយរួមគ្នា គឺវិជ្ជាស្ថានបោះធនប័ត្រ (ក្រដាសប្រាក់) ព្រោះប្រទេសយើងទាំងអស់ ក្នុងដែនឥណ្ឌូចិន មិនទាន់អាចនឹងលែងត្រូវការប្រើប្រាស់ប្រាក់រៀលរបស់យើងបាននៅឡើយ, តែប្រាក់រៀលនេះត្រូវមានរូបថ្លៃតគ្នា តាមប្រទេសខ្មែរ ប្រទេសវៀតណាម ឬប្រទេសលាវ គឺជាការផ្តើមកិនកាគហិរញ្ញវត្ថុឲ្យថ្លៃតជាប់ពីគ្នាទៅថ្ងៃមុខ ។

ខាងរបៀបការទូត យើងបានអធិបតេយ្យពេញទីហើយ ។ ដើម្បីឲ្យឯកភាពយើងបានពេញលេញឡើង ប្រទេសជាំងបានតាំងត្រមផ្ទាស់សេចក្តីបញ្ជាត្តិមួយទៅយ៉ាងសំខាន់ក្នុងសន្ធិសញ្ញា ។

អំណើះតទៅ អ្នកការទូតបរទេសត្រូវចូលមកផ្ទាល់ព្រះមហាក្សត្រិយ៍ សុំឲ្យទទួលស្គាល់ មិនបាច់ទៅដល់ប្រធានាធិបតីជាំងឡើយ ។ ព្រះមហាក្សត្រិយ៍ ត្រូវជូនអ្នកការទូតផ្ទាល់ទៅប្រមុខរដ្ឋបរទេស ត្រូវចេញសារតាំងដោយអក្ខរឯងនឹងឯកឯង គឺចុះហត្ថលេខាតែមួយព្រះអង្គឯង, ពិតមែនតែកងសន្ធិសញ្ញាមានបញ្ជាត្តិថា ត្រូវឲ្យមានចុះហត្ថលេខាប្រធានាធិបតីជាំង លើសារតាំងនោះផង ។

អធិបតេយ្យរបស់យើង ខាងសឹកសង្គ្រាមនឹងបានមកឯង នៅវេលាណាដែលយើងនឹងដោះស្រាយបញ្ហាវៀតមិញបាន ។

យើងកំពុងខិតខំខ្ញាំងណាស់ ដើម្បីនឹងដកកងទ័ពជាំងបន្តិចម្តងៗ ហើយនឹងពង្រីកអំណាចបញ្ជាការរបស់យើងខ្ញុំទៅក្នុងដែនប្រទេសយើង ។

កងពលរបស់យើង ដែលមានមកក្នុងឆ្នាំ ១៩៥០ ទាំងប៉ុន្មាន ដល់ទៅឆ្នាំ ១៩៥២ នឹងបង្កើតឲ្យមានច្រើនឡើងខ្ញុំមួយដងពីរ ។

ចំណែកខាងតុលាការ យើងចាំដល់ពេលណាធ្វើសញ្ញា ឲ្យបានសម្រេចតាមបំណងនៃប្រជាជាតិបាន ទើបនឹងត្រមចុះហត្ថលេខាជាមួយ

ប្រទេសជាតិ, ក្រែអំពីនេះ អធិបតេយ្យរបស់យើងបានតេញលេញ
តាំងអស់ហើយ ។

ឥឡូវបុគ្គលិកជាតិជាតាំងតាំងប៉ុន្មាន នៅក្រោមបង្គាប់ពួកវៀត
តាំងអស់ ហើយបានទុកឲ្យនៅធ្វើការចំនួនត្រឹមតែយើងត្រួតការប៉ុណ្ណោះ
ឯលោកកុម្មីស្សែរដើម្បាវែតុយពួក នឹងអ្នកតំណាងរបស់គេតាំងប៉ុន្មាន
អំណើះតទៅ មានមុខងារគ្រាន់តែជាអ្នកតំណាងប្រទេសជាតាំងប៉ុណ្ណោះ
ទេ ឯអ្នកតំណាងនៅវៀតក្រៅ ដែលហៅថា កុងស៊ីយោនោះ កាន់តារ
ងារត្រឹមតែជាកុងស៊ុល ។

ខ្ញុំគុណាដឹងថា មានជនរួមជាតិយើងជាច្រើនរូបមិនសប្បាយចិត្ត
ដោយឃើញក្រុមពួកខ្លះ មានជាតាំងធ្វើការប្ដូ ជាតាំងត្រួតត្រា ហើយ
មន្ទិលថា ក្រែងក្រុមតាំងនោះមិនមែនជារបស់វៀត ។ គ្មានអ្វីជាឧបសគ្គទេ
គឺថាបើមានតម្រែវិជ្ជាស្ទើគ្នា យើងនឹងយកជនរួមជាតិឲ្យកាន់កាប់ទី
តំណែងនីមួយៗ ។ ដែលមានទីតំណែងខ្លះ ជាតំណែងតឹកនឹកត្រូវតែ
មានបុគ្គលិកប៉ិនប្រសប់ ទើបកាន់កាប់ជាន ។ បើយើងដាក់ជនណា
ដែលមានតម្រែវិជ្ជាមិនដិតដល់ឲ្យទៅកាន់កាប់តំណែងនោះ វាបៀបការ
កងតំណែងនោះនឹងចាត់ការទៅពុំជានស្រួលល្អ នេះឃើញថា ប្រទេស
ជាតិនឹងការឯកពាជ្ឈនឹងជានផលអាក្រក់ ។

ពួកនិស្សិតជាតិយើង ដែលយើងជួយទំនុកបំរុងពេញទំហឹងនោះ អាចនឹងទទួលការជួសជុលពាំងបានបន្តិចម្តងៗតាមសញ្ញាប័ត្រ នឹងតាមរបៀបដែលធ្លាប់ប្រសប់ការ ព្រោះដែលនឹងកាន់កាប់ក្រុមការនីមួយៗបានស្រួលនោះ លុះត្រាតែធ្លាប់ប្រសប់ការយូរឆ្នាំល្មមផង ទើបបានស្រួល ។

នៅបុរីបង្អស់ គេច្រើនគេចថា ក្រុមការរបស់យើងពាំងប៉ុន្មាននោះមានខ្វះត្រួតត្រាក្តី មានឃ្លាំងត្រួតត្រាក្តី ត្រូវឡើងរដ្ឋមន្ត្រីជាតិយើងពាំងអស់ ។

ដូច្នេះ លោកគ្រូគ្រប់ព្រះអង្គ អាចជ្រាបយល់បានថា ឯកាជ្យរបស់យើងមិនមែនមានតែផ្លូវបើកហើយប៉ុណ្ណោះទេ គឺថាបំណងនៃឯកាជ្យរបស់យើងនេះបានសម្រេចពេញលេញ សឹងតែពាំងអស់ទៅហើយថែមទៀត ។

តាមយោបល់ខ្ញុំកុណា យល់ឃើញថា អំណោះតទៅ អស់មានឧបស័គ្គអ្វីជាធំដុំមកខាំងាំងយើងទៀត មិនបានឲ្យសម្រេចផលឯកាជ្យពេញលេញនោះឡើយ ។ ប្រទេសឃ្លាំងបានពាំងទទួលស្គាល់ថានឹងឲ្យយើងបានឯកាជ្យបរិបូណ៌ ហើយថាគ្មានសុំអ្វីអំពីយើងក្រៅពីសុំឲ្យយើងធ្វើជាសម្ពន្ធមិត្ត ដោយស្មើមុខគ្នានោះទេ ។

ឧបស័គ្គធំតែមួយ ដែលយើងនៅមានខ្លឹងត្រូវបំបាត់នោះ គឺអសន្តិសុខ, គឺមហាភ័យនឹងវៀតមិញ ខ្លឹងមហាភ័យនឹងលន់ណុលសម្បាច់

(កុម្មុនិស្ត) ។ មហាភ័យនឹងខ្វិរួមសម្បាច់ មិនមែនគ្រាន់តែភ័យ
ចំពោះលទ្ធិពជាធិបតេយ្យប៉ុណ្ណោះទេ គឺភ័យចំពោះសាសនារបស់យើង
នឹងចំពោះប្រទេសយើងជាមុនគេ ក្រែងពុំបានគង់នៅឋិតថេរតទៅ ។
ទេមរជាតិច្រើនរូប អាចបានយល់យើញច្បាស់អំពីការភ័យនេះស្រាប់
ហើយ ។ ពួកឥស្សរៈជាច្រើន ក៏បានយល់យើញដូច្នោះដែរ, គឺដោយ
ហេតុនេះហើយបានជាយើងយើញថា ពួកឥស្សរៈខ្លះ រីឯទៀតជាមាន
ប្រតិកម្មខ្លាំងនឹងពួកវៀតមិញ ខ្លះទៀតក៏មានបំណងគិតចូលមករួបរួម
នឹងរាជការជាតិវិញ ។

ក្រុមឥស្សរៈខ្លះនិយាយថា ចង់ជួយពួតដៃជាមួយរដ្ឋាភិបាល នេះ
យើញថាពួកនេះមានចិត្តស្រឡាញ់ជាតិពិតមែន ។ តែខ្ញុំករុណា សូម
ស្តាយមង្កិភាពរបស់ពួកនេះ ក្នុងការដែលចង់ចូលមករួបរួមជូច្នេះណាស់ ។

ខ្លះមានវាចានិយាយ នឹងមានគំនិតគិតថា បើខ្លួននឹងធ្វើកត្តិកាសញ្ញា
នឹងរដ្ឋាភិបាលពេញមុខពេក នឹងនាំឲ្យប្រជារស្តីលេងមានសេចក្តីខ្ពុក
ចិត្តលើខ្លួន ។ បើដូច្នេះ តើប្រជារស្តីមិនសូវស្មោះត្រង់នឹងរដ្ឋាភិបាល
ជាតិប៉ុន្មានទេឬ? តាមការពិត គឺមិនមែនសមប្រកបដូច្នោះទេ ។

តាមយោបល់ខ្ញុំករុណា បើពួកឥស្សរៈនេះចង់ធ្វើប្រយោជន៍ឲ្យ
មាតុភូមិបៃស់យើងពិតមែន ត្រូវតែសំដែងឲ្យប្រជារស្តីយើញថា សម័យ
នេះមិនគោងបែកសាមគ្គីគ្នាទេ ។ មធ្យោបាយដ៏ប្រពៃ ដែលនឹងធ្វើឲ្យ

ប្រជាពស្ត្រ មានសេចក្តីទុកចិត្តដល់ជាតជាតនៃប្រទេសឡើងវិញ គឺ
ត្រូវសំដែងឲ្យប្រជាពស្ត្រយើញថា លែងមានកងទ័ពពីរ គឺកងទ័ពរាជការ
ម្ខាង កងទ័ពឥស្សរៈម្ខាងទៀតហើយ តែមានតែកងទ័ពជាតិមួយ
ប៉ុណ្ណោះ ។ គឺត្រូវសំដែងឲ្យប្រជាពស្ត្រយើញថា គ្មានរាជការ ២ ឬ
រាជការ ៣ ទេ, តែមានតែរាជការតែមួយ គឺ រាជការដែលចេញអំពី
រាជធានីរបស់យើង ។

ខ្ញុំករុណាមានសេចក្តីសង្ឃឹមថា ពួកឥស្សរៈដែលចេះស្រឡាញ់
ជាតិដល់ទៅថ្ងៃណាមួយខាងមុខនាប់ៗ នេះជាមិនខាន នឹងមានគតិបណ្ឌិត
គ្រប់គ្រាន់ នឹងជួយដោះស្រាយទុក្ខឲ្យប្រជាពស្ត្រយើងបាន ដោយ
ចូលមករួបរួមនឹងរដ្ឋាភិបាល ដើម្បីនឹងការពារប្រជាពស្ត្រយើង ។

បណ្តាពស្ត្រខ្លះ នៅស្រែចំការ កើតសេចក្តីភ្លៀកភ្លាយខ្លះមកអំពី
កងទ័ពសហភាពនឹងខ្លួន មិនអាចយល់គ្នាទូគ្នាបាន ។ នេះជាហេតុ
មួយទៀត គួរឲ្យគាហានទៅមរាជាតិចេះប្រមូលគ្នា ដើម្បីនាំគ្នាទៅការពារ
ប្រជាពស្ត្រដោយខ្លួនឯងវិញ ។

បញ្ហាខាងឯកភាពរឿងអសន្តិសុខ សូមអធិប្បាយប្រគេនតែប៉ុណ្ណោះ
សិនចុះ ។

ខ្ញុំករុណា សូមថ្វាយសេចក្តីខ្លះ ពិតលោកគ្រូគ្រប់ព្រះអង្គ អំពីលទ្ធិ
ប្រជាធិបតេយ្យរបស់យើង ។ (មានត)

ពាក្យសន្ទនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែមីនា លេខ ៣

ព. ស. ២៤៩៣ – គ. ស. ១៩៥១



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពុទ្ធសាសនានិងព្រឹទ្ធសាសនា (សន្ទនាលោកបេឌ្ឌិចស្ទិតមីតូត)	លោក ភ័យ - ប៊ុក	១៦៣
ពន្ធអាស៊ីទ្វីប (តមក)	លោក ភ័យ - ប៊ុក	១៦៩
ធម្មបរិយាយ	ព្រះគ្រូកញ្ចាលិទិត កៅ - សុម	១៧៧
ផ្នែកអក្សរសាស្ត្រ		
ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ពុំង - ប៊ម	១៨៥
សត្វចាំងប្រែជាខ្មែរ (តមក)	លោក ម៉ឺញ - ឆាំត្រី	១៩៣
រឿងព្រៃងភូមា (តចប់)	— សាង - សាភិត	១៩៨
រឿងសាមកុក (តមក)	— ឆូ - កន	២០៧
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)	— ឈឹម - ក្រសែម	២២១
កំណត់ទីផ្សាយ		
អនុស្សាវរីយ៍មហាសន្និបាត (តចប់)	ពុទ្ធសាសនបណ្ឌិត្យ	២២៥

មួយឆ្នាំមាន ១២ សៀវភៅ ជាំប្លែងវ៉ែ ១៤៥,០០

KAMBUJASURIYA

Revu religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages

Bouddhisme et Christianisme (Conférence du Docteur André Migot)	M. RAY-BUC	163
La Lumière de l'Asie (suite)	M. RAY-BUC	169
Dhammapariyayakatha.	PRÉAH KROU KAO-SIM	177

PARTIE LITTERAIRE

L'Education morale (suite). . . .	PREAH MOHA PEUNG-PAM . .	185
Recueil des mots traduits par la Commission Culturelle (suite) .	M. MENH-NAKRY	193
Contes birmans (suite et fin) . . .	M. SANG-SAVAT	198
Histoire de SAMKOK (suite)	OKNHA NOU-KAN	207
Histoire du Royaume du Cambodge (suite)	OKNHA CHHIM-KRASEM . . .	221

NOTES ET CHRONIQUES

Réunion annuelle des religieux du Cambodge (suite et fin)	INSTITUT BOUDDHIQUE	225

Prix d'abonnement annuel comprenant 12 numéros: 145800

ពុទ្ធសាសនា និង គ្រិស្តសាសនា

សង្ខេបទំនោរមើលគ្នា

លោក ភ័យ-ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យកុំពេញ

ប្រែពីទស្សនាវដ្តី "ហ្សង់អាស៊ុ" ខែមិថុនាឆ្នាំ ១៩៥០

(តមក)

ខ្ញុំមានក្រិត្យាចង់ពិសោធន៍ត្រង់ការពណ៌នាដោយសង្ខេប នូវព្រះពុទ្ធសាសនាដែលស្ថិតនៅក្នុងសម័យបច្ចុប្បន្ន ព្រមទាំងគោលការណ៍សំខាន់ៗនៃសាសនានោះទើរស្ទើផ្សាយចេញទៅកាន់មនុស្សជាតិ បង្ហាញឲ្យឃើញនូវមតិពុទ្ធសាសនាខាងផ្លូវលោក តើខុសគ្នាយ៉ាងណាខ្លះ ចំពោះមតិខាងផ្លូវលោក ដែលមាននៅបច្ចុប្បន្នសម័យ, ប្រៀបធៀបនូវវិធីការដោះស្រាយពុទ្ធសាសនា ទើងគ្រិស្តសាសនានូវតួតម្លៃបញ្ហានៃមនុស្សជាតិ ព្រមទាំងពិសោធន៍នូវគ្លាក់គោលដែលមានសារៈប្រយោជន៍ទើងប្រពៃណីសំរិទ្ធិសម្រាំងបញ្ចេញឲ្យឃើញជាក់ស្តែង ធម្មិព្រហ្មវិហារដែលជាអាត្ម័នប្រកបដោយចលនភាពទើងកម្ចិកភាពដ៏ក្លាហាននៃសាសនាទាំងពីរ ដែលបានផ្តេរជម្លៃទៅឲ្យជនជាតិមនុស្សព្រមទាំងទៅតាមនូវព្រហ្មទាំងអស់ ។

ខ្ញុំមានបំណងទើងបញ្ជាក់នូវរឿងរ៉ាវមួយដែលលោកអ្នកយល់ថាជាការមិនប្រសើរ តែមិនមែនជាឥតប្រយោជន៍គឺរឿងព្រះពុទ្ធ។ មិនមែនជាបុគ្គលកើតដោយទេវឫទ្ធិ ដែលប្រជាជនខាងបូព៌ាអាស៊ីទូបប្រឌិតរឿងដោយ

មនោគតិនោះទេ ។ តាមដែលពិត ព្រះអង្គជាមហាបុរសមួយដែលប្រែក្លៃ-
សាស្ត្រចាត់ព្រះនាមទុកមក, រស់នៅក្នុងប្រទេសឥណ្ឌាខាងជើង
កងសតវត្សទី ១៦ មុនគ្រិស្តសករាជ, ហើយមានជីវិភាពពិតប្រាកដ
ដូចជាព្រះគ្រិស្ត ឬព្រះមហាម៉ាត់ ។ ជីវិភាពរបស់ព្រះអង្គ បណ្ឌិត
ខាងឡាយបានខិតខំទុកគ្រប់ប្រទេស, បើខ្ញុំពោលជាថ្មីម្តងទៀតជាការមិន
ជាប្រយោជន៍ គឺជីវិភាពបឋមនិទានកណ្តាលនៃព្រះអង្គជាជីវិភាពនៃបណ្ឌិត
ឬជាធម្មកថិកប្រកបដោយសាមញ្ញលក្ខណៈ: គ្រាប់ដើរទេសនាតាមភូមិ
ភាគនិគមជនបទ ប្រៀបដូចជាព្រះគ្រិស្ត ។ ជីវិភាពជាអវសានៃព្រះ
ពុទ្ធនិពន្ធនាដោយឡែកផ្សេងពីនេះ ។ លទ្ធិខាងពីរគឺពុទ្ធសាសនា
និងគ្រិស្តសាសនាពិតមែនមានបុព្វហេតុជាសាមញ្ញ តែជាសាសនាមាន
គេនិយមរាប់អានគោរពតេញលោក ទៅជាសាសនាសកលលោកខាងពីរ
ដែលមានឥទ្ធិពលអាចបែងចែកពិភពលោកសព្វៗខ្លួន ។

ជីវិភាពសាមញ្ញនេះ មិនអាចធ្វើឲ្យមនុស្សលោកមានជាតិខាងបូព៌ា
ប្រទេសជាដើម ដែលមានអធ្យាស្រ័យត្រូវការខាងអច្ឆរិយភាពតេញចិត្ត
ទៅបាន ។ ពួកអ្នកនិពន្ធបាននាំរឿងនេះទៅរចនាដោយនិទានវចនៈ:
ប្រកបដោយឥទ្ធានុភាពអស្ចារ្យ ហើយក្នុងសតវត្សទី ៥ ក្រោយមក
និទានខ្លះទាំងនេះគេបានឃើញយកទៅបញ្ចូលក្នុងរឿងព្រៃងព្រះគ្រិស្ត ។
ការដែលមាតាធម៌ (Saint Esprit) ចុះទៅចាប់បដិសន្ធិក្នុងទ្រនាង

ម៉ារីស្តែព្រហ្មចារិនី ហើយការបដិសន្ធិប្រកបដោយឫទ្ធានុភាពអស្ចារ្យនូវ
ព្រះគ្រិស្ត, បើប្រៀបធៀបទៅដូចគ្នានឹងព្រះពុទ្ធ កាលចុះចាកស្ថានតុសិត
មកចាប់បដិសន្ធិក្នុងទ្រនៃព្រះនាងមហាមាយាទេវីដ៏បរិសុទ្ធិស្អាត ។ ព្រះ
មហាក្សត្រិយ៍នៅប្រទេសម៉ែដ្ស៍ឬប៉ែរ្ស៍ (Médes ou Perses) សរសើរ ព្រះ
គ្រិស្តដែលទើបប្រសូតមកថាដូចគ្នានឹងទេវតាឥន្ទ្រព្រហ្ម ដែលចុះមកធ្វើ
គារវកិច្ចចំពោះព្រះសិទ្ធត្ថកុមារ ។ ពួកអាក្បែបិសាចទៅផ្តាំញ៉ាំព្រះគ្រិស្ត
នៅវាលរហោស្ថាន ក៏ដូចគ្នានឹងពួកមារពាលជាមួយនឹងសេនានៃមារចូល
មកផ្តាំញ៉ាំព្រះបរមពោធិសត្វ មុននឹងបានត្រាស់ទ្បាអនុត្តរសម្មាសម្ពោ-
ធិញ្ញាណ ។ គេអាចតណានាលើកទៅហារណ៍មកប្រៀបធៀបឫទ្ធិព្រះ
ពុទ្ធនឹងឫទ្ធិព្រះគ្រិស្ត ដោយអនេកបរិយាយ តែយើងយល់ថាមិនមែនជា
រឿងមានសារៈសំខាន់អ្វីឡើយក្នុងទីនេះ ។

នេះមិនមែនឲ្យយល់តាមការពិត ថាឫទ្ធិដែលចារឹកទុកក្នុងរឿងព័ត៌ព្រះ
គ្រិស្តជារឿងចំឡងមកពីឫទ្ធិព្រះពុទ្ធនោះទេ ; គឺរឿងព័ត៌ទាំងនេះជាហេតុ
ឲ្យយើងឃើញថាវិតែន៍ខាងផ្លូវប្រាជ្ញាវប៉ស់មនុស្ស មិនថានៅប្រទេសណា
សុទ្ធតែមានសភាពដូចគ្នាទាំងអស់ ។ មនុស្សក្នុងលោកសន្និដ្ឋានេះ
មិនអាចនឹងយល់ច្បាស់ថា បុគ្គលប្រកបដោយសន្តិភាពដូចជាព្រះពុទ្ធ
ឬព្រះគ្រិស្តអាចបដិសន្ធិដូចបុគ្គលសាមញ្ញនោះឡើយ ។

មួយទៀត បើគេត្រូវការនិទានរឿង ដោយហេតុថារឿងនោះជាបឋមវត្ថុជាតុនៃរឿងព្រៃងចាំងអម្បាលម៉ាន រឿងព្រៃងនោះអាចបង្ហាញនូវគំនិតដ៏វិសេស នៃសច្ចធម៌ជាឯនិទានវចនៈប្រកបដោយវិចារណញ្ញាណនោះទៅទៀត ។ តាមការណីនៃជនជាតិឥណ្ឌា ពួកសាសនិកជនយល់ថាវស្ទឹអាទិទេព (divine) ចូលទៅស្ថិតមិនត្រឹមតែស្នាមគំនូសដែលផ្តិតជាប់នៅនឹងខួរក្បាលនៃប្រជាកស្តូ ថែមចាំងផ្តិតជាប់មាំក្នុងសច្ចៈសម្ភារៈនៃការប្រសិទ្ធីឲ្យនាមអាទិទេព ចុះមកចាប់ចងដិសន្ធិក្នុងរូបមនុស្សផងទៀតៈ គំនិតចាំងពីរបៃបនេះមានសភាពពិតដូចគ្នា ព្រោះថាសច្ចធម៌ទូទៅជាអាទិទេព ។

* * *

ពិតមែនតែព្រះពុទ្ធសាសនាបានពណ៌នាទៅតាមន័យជាបឋមត្ថដោយសម្បូណ៌ភាពពិសេស តែគង់មានគតិសំខាន់ ៗ ជាមូលដ្ឋានដែលមានបុព្វហេតុជាស្ថាពរគឺការពិសោធន៍ជាសាកលថា សត្វលោកកើតមកមានទុក្ខ ។ ក្នុងមួយដីរភាពនៃព្រះពុទ្ធ ព្រះអង្គព្យាយាមស្វែងរកហេតុដែលកើតទុក្ខនោះ ដោយព្រះប្រាជ្ញាញាណ; កិច្ចការដែលពិចារណារកហេតុផលគឺកម្ម, អនិច្ចតាធម៌, អនត្តាធម៌មានវិចារណញ្ញាណតែមួយយ៉ាង គឺស្រាវជ្រាវរកដើមកំណើតនៃទុក្ខ ដើម្បីនឹងរកឧបាយណាដែលអាចបំបាត់នូវទុក្ខនោះបាន ។

បញ្ហានេះ ពួកពុទ្ធសាសនិកជនសឹងតែពេញចិត្តស្រាវជ្រាវរកគ្រប់ៗ គ្នា ។ មានពុទ្ធសាសនិកជនខ្លះយល់ថាទុក្ខមិនមាន, ខ្លះថាទុក្ខនោះត្រូវតែទទួលខានមិនបាន ។ ចំណែកពួកគ្រែជាងយល់ថាទុក្ខជាសភាពកើតមកអំពីអាទិទេព ហើយអាទិទេពមានគុណសម្បត្តិដ៏វិសេសវិសាលដើម្បីនឹងធ្វើអានុភាពនៃទុក្ខនោះឲ្យថយចុះ ។ តែកិច្ចការទាំងនេះយើងលំបាកនឹងយល់ពន់ពេក ហើយបើយើងចង់ដឹងថាការណ៍លំបាកដោយពិតនោះយ៉ាងណា យើងត្រូវពិនិត្យសួរដល់ពួកអ្នកជ្រាបខាងអាទិទេព-ភាព (Thèologien) ដែលព្យាយាមរកមធ្យោបាយដោះស្រាយនូវបញ្ហាទុក្ខដែលផុះផុលឡើងជានិរន្តរកាលមិនចេះដាច់ស្រេច ។ ហេតុម្តេចបានជាអាទិទេពមានព្រះទ័យប្រកបដោយមហាសប្បុរសនឹងពលភាព អាចបណ្តាយឲ្យទុក្ខមានដល់បុគ្គលដែលបរិសុទ្ធ ? ហេតុម្តេចបានជាអាទិទេពនោះបង្គាប់ឲ្យមនុស្សទាំងនោះស្តាយនូវបុព្វកម្មដ៏លាមកជាអនន្តកាលដោយមនុស្សនោះគ្មានប្រព្រឹត្តបាបអកុសលសោះឡើយ ? ហេតុម្តេចក៏អាទិទេពនោះអាចប្រើអាកប្បកិរិយាស្រោចស្រង់មនុស្សខ្លះ ឲ្យបានសុខស្រួលជាអនន្តកាល ហើយជាក់ទណ្ឌកម្មមនុស្សខ្លះឲ្យទៅសោយទុក្ខនៅស្ថាននរកជាអនន្តកាលចំពោះបាបបន្តិចបន្តួចដូចនេះ ? ។ ឮក់គោលខាងគ្រិស្តសាសនាដែលពណ៌នានេះ ធ្វើឲ្យពួកពុទ្ធសាសនិកជនមានចិត្តជ្រួលជ្រើមជាខ្លាំង ។ ពួកពុទ្ធសាសនិកជនមិនអាចអនុម័តថា

ពួកក្រុមមនុស្សជាតិខ្លះសោយសម្បត្តិសុខជាអនន្តកាល ហើយមានមនុស្សឯទៀតខ្លះសោយទុក្ខលំបាកជាអនន្តកាលដូចនេះ: ដរាបណាពួកលោកសន្និវាសនេះមានទុក្ខ, ដរាបណាសត្វតាំងអស់មិនទាន់រួចចាកទុក្ខតាំងពួង, ដរាបនោះគ្មានសន្តិភាពគ្មានសុះប្រាកដឡើយ ។

មានតែព្រះពុទ្ធមួយព្រះអង្គទេ ដែលទ្រង់ហ៊ានទតចំពីមុខបច្ចាមិត្ត ហើយទ្រង់ព្យាយាមដោះស្រាយនូវបញ្ហាបាបអកុសល ដែលទ្រង់បានរកឃើញនូវមធ្យោបាយពិតប្រាកដ មានសភាពក្លឹស្វាង់ជាអស្ចារ្យជាអនេក ។ ហេតុដែលកើតបាបនឹងនុសថដែលអាចកំចាត់បង់បាបនោះបាន សឹងមានពណ៌នាជាពិស្តារក្នុងបឋមពុទ្ធោវាទ ដែលព្រះមង្គលបានទេសនានៅទីក្រុងប៉ែណារេះ (ពារាណសី) គឺជាគោលការណ៍សំខាន់នៃព្រះពុទ្ធសាសនា ។ ព្រះសម្មាសម្ពុទ្ធទ្រង់គ្រាស់ទេសនាអំពីចតុរារ្យសច្ចដែលជាមូលដ្ឋាននៃពុទ្ធោវាទ ដូចេះថា :-

"ម្នាលភិក្ខុតាំងឡាយ! ទុក្ខអរិយសច្ចនោះគឺ: ការកើតជាទុក្ខ, សេចក្តីគ្រាំគ្រាជាទុក្ខ, សេចក្តីឈឺចាប់ជាទុក្ខ, សេចក្តីស្លាប់ជាទុក្ខ, ការកប់ប្រសព្វនូវអនិដ្ឋារម្មណ៍ជាទុក្ខ, ការព្រាត់ប្រាសចាកសត្វនឹងសង្ខារដែលជាទីស្រឡាញ់ពេញចិត្តជាទុក្ខ នឹងឧបាទានក្ខន្ធ ៥ ជាទុក្ខ[1] ។

(មានន)

---

១ ឧបាទានក្ខន្ធ ៥ គឺ: រូប (corps), វេទនា (sensations), សញ្ញា (idées), សង្ខារ (Volitions), វិញ្ញាណ (conscience) ។

វគ្គទី ៦

La Lumière de l'Asie

លោកស៊ីរ-អេតវ៉ាំងអារណ្យលជ៌ តែង

លោកព័ឃ-ប៊ុក ក្រមការ បែបរៀបរៀង

(ត្រួត)

ព្រះហត្ថាជាក់នៅលើព្រះជង្គង់; ព្រះនាង, អញ្ជើញមើល! មានវិស្ស័ក្ខ័ស្វាង៉ាវរឿងចេញពីព្រះនលាដ: ហើយព្រះអង្គមានព្រះចរិយាស្ងួតគួរជាទីគោរពត្រមាំង ព្រះចក្ខុថ្លាបរិសុទ្ធស្អាតដូចមហាមេឃ! ព្រះនាងមានកំព្ឫសំណាងល្អបានមកជួបនឹងទេវតាដូចនេះ" ។

ព្រោះហេតុនេះ នាងសុជាតាយល់ថាជាទេវតាពិតប្រាកដ ក៏ថ្វាយបង្គំគោរពលើប្រថពី ហើយនាងឱនមុខ ពោលថា "សន្តបុគ្គលដែលនៅក្នុងគុម្ពោតព្រៃនេះឬ ដែលខ្ញុំបានបន់ស្រន់? ព្រះអង្គមានព្រះទ័យករុណាជាយ៉ាងក្រៃលែងចំពោះខ្ញុំព្រះអង្គដែលជាទាសី ដោយមានព្រះទ័យស្មោះសរនឹងខ្ញុំព្រះអង្គបញ្ចេញព្រះរូបឲ្យឃើញជាក់ច្បាស់, តើព្រះអង្គអាចទទួលនូវដង្វាយនេះ គឺមធុបាយាសដែលមានពណ៌សដូចត្រីលឬក្តុកដែលជាងរចនាដោយវិចិត្រឬ?" ។

លុះនាងពោលដូចនេះហើយ នាងក៏យកព្រះក្រយាហារនេះដាក់ក្នុងស៊ុវណ្ណភាជន៍ ហើយស្រោចទៅលើព្រះហស្តព្រះពោធិសត្វនូវព្រះទឹកៈ ហៅថាអត្តារ (attar) ដែលយកបណ្តាលបុប្ផាកុឡាបមកប្រកបហើយដាក់ក្នុងថូរកែវ ។ ព្រះបរមពោធិសត្វ សោយនូវមធុបាយាសនោះដោយស្រៀមស្ងាត់ ។ ចំណែកនាងអង្គុយដោយគោរពក្នុងទីដ៏សមគួរ ។ ឧជារសនៃព្រះស្ងោយនោះប្លែកអស្ចារ្យ ចានជាព្រះបរមពោធិសត្វសោយក្តាមមានព្រះកាយពលដូចដើម បីដូចយប់ដែលព្រះអង្គទ្រង់ព្រះមិទ្ធៈ ឬថ្ងៃដែលទ្រង់អត់ព្រះក្រយាហារ ឬដូចជានិមិត្តយល់សប្តិ, ហើយព្រះឆ្អាជារបស់ព្រះអង្គ ក៏មានវិទ្ធានុភាពឡើងវិញ ព្រមទាំងព្រះកាយក៏មានកំឡាំងបរិបូណ៌ ដូចជាមានស្ងាបហោះហើរក្តាម ប្រៀបដូចបក្សាមួយ អស់កំឡាំងដោយហើរលើវាលខ្សាច់រហោស្ថានលន្ធឹមលន្ទោចជាច់កន្ទុយក្អែក ហើយមានបីតិរីករាយសប្បាយដោយបានដួបនឹងស្ងឹងមួយ ហើយបានយកកន្ទឹងក្បាលដែលប្រឡាក់ដោយបរមាណូទៅដុតទឹក ។

នាងសុជាតាបានក្រាបសំពះព្រះបរមពោធិសត្វ ដោយបានឃើញព្រះកន្ត្រកព្រះអង្គមានសភាពគួរឲ្យស្រប់ស្រែងពេក ហើយពោលពាក្យខ្សឹបៗ ថាៈ "ព្រះអង្គជាទេវតាឬ? ដង្វាយខ្ញុំព្រះអង្គ តើព្រះអង្គទ្រង់បានទទួលដោយព្រះទ័យស្មោះស្ម័គ្រឬ?" ។ ព្រះបរមពោធិសត្វមានព្រះបន្ទូលតបមកនាងវិញថាៈ "កោដនាហារដែលនាងយកមកឲ្យយើងតើនាងធ្វើដោយអ្វី?" ។

នាងសុជាតាក្រាបទូលព្រះអគ្គវិញថា: "ទុសន្តបុគ្គលដ៏ប្រសើរ! ខ្ញុំព្រះអង្គបានតែយកទឹកដោះគោញីចំនួន ១០០ ដែលទើបនឹងកើតកូន ហើយខ្ញុំព្រះអង្គយកទឹកដោះនោះទៅឲ្យគោញីមានពណ៌សចំនួនហាសិបបរិភោគ ហើយតែយកទឹកដោះគោញីទាំងប៉ុន្មាននោះទៅឲ្យគោញីម្ភៃក្បាលបរិភោគទៀត ទើបខ្ញុំព្រះអង្គតែយកទឹកដោះនេះទៅឲ្យគោញីដប់ពីរអោស្រ័យ ហើយតែយកទឹកដោះនេះទៅឲ្យគោញីក្បាលមួយដែលជាត់ធំល្អជាងគោញីឯទៀតក្នុងហ្វូងនោះបរិភោគ ទើបខ្ញុំព្រះអង្គតែយកទឹកដោះគោញីក្បាលមួយនេះមកជាត់ក្នុងកាជន៍ក្បាក់ អប់ដោយកំញ៉ាន លាយនឹងគ្រឿងទេសយ៉ាងបញ្ចុះ ហើយខ្ញុំព្រះអង្គបានយកអង្កវដែលបានមកពីយកពួជស្រូវ មកជ្រែសដោយហ្មត់ចត់យកទៅព្រោះនឹងដីដែលទើបភ្លូរាស់ថ្មីៗ ហើយយកអង្កវទាំងនោះមកជ្រែសលើសថែមទៀត យកតែគ្រាប់ណាដែលធំក្លី នេះហើយក្រយាហារដែលខ្ញុំព្រះអង្គបានធ្វើដោយចិត្តស្មោះស្ម័គ្រ ព្រោះខ្ញុំព្រះអង្គបានប្តេជ្ញាក្នុងចិត្តថា នឹងយកជង្រាយទាំងនេះមកជាក់ក្រោមពោធិព្រឹក្សដើម្បីនឹងលាបំណន់របស់ខ្ញុំព្រះអង្គ ឥឡូវខ្ញុំព្រះអង្គបានបុត្រប្រសមួយសម្រេចដូចបំណងហើយ ដីវិតខ្ញុំព្រះអង្គតាំងពីថ្ងៃនេះតទៅប្រកបដោយសេចក្តីសុខក្សេមក្សាន្តជាប្រាកដ" ។

ព្រះបរមពោធិសត្វ ទ្រង់បើកស្បែកហមស្រស់ដែលរុំមុខនាងហើយយកព្រះហស្តដែលស្រោចស្រង់សត្វលោកទាំងអស់ ជាក់លើ

ក្សាលនាងសុជាតា ហើយមានព្រះបន្ទូលថា: "សូមឲ្យនាងបានសេចក្តីសុខយូរអង្វែង, ហើយសូមឲ្យការនៃដំរីកាពរបស់ពាក្យនោះឲ្យស្រាលល្មមនាងប្រព្រឹត្តទៅបានដោយស្រួល. ព្រោះនាងបានជួយជីវិតយើង។ មិនមែនជាទេវតាទេ តែទុកដូចជាមនុស្សមួយរបស់នាង; ពីដើមយើងជាព្រះអគ្គមហេសី, ឥឡូវនេះយើងជាអ្នកដំណើរបំពេញទុក្ករកិរិយាអស់ប៉ុន្មានមួយឆ្នាំ ហើយស្វែងរកទូរស្មីដែលក្តីចាំងអស់ទិវាពត្រីនៅទីណាមួយតែយើងមិនទាន់បានដឹងកន្លែងនោះនៅឡើយ, បើមនុស្សណារកយើញ, មនុស្សនោះអាចដេញសកាពងឆឹតលង់ គឺអវិជ្ជានៃមនុស្សនោះចាកចេញពីសន្តានឲ្យមានពន្លឺភ្លឺស្វាងឡើងវិញបាន យើងមុខជានឹងយើញទូរស្មីនោះថ្ងៃណាមួយមិនខាន, រស្មីនោះយើងបានយើញច្បាស់ដោយបញ្ញាចក្ខុគួរជាទីជ្រះថ្លាណាស់, កាលដែលយើងកំពុងខ្សោយ អន់ថយកំលាំងស្ទើរតែនឹងមរណា ទេពួលបាននាងយកកោជនាហារដ៏វិចិត្រនេះដែលផ្សំពីកំលាំងសត្វជាច្រើនមកឲ្យយើង បានជាយើងមានពលភាពអស្ចារ្យដូច្នេះ ប្រៀបដូចជាដីវភាពត្រូវត្រាច់ង្គាត់ក្នុងវដ្តសង្សារជាច្រើនជាតិ មុននឹងបានចំរើនឡើងតាមលំដាប់ទៅកាន់សុគតិ ហើយលះបង់នូវកម្មអកុសលបាន; តើនាងយល់ថាដីវភាពនេះឲ្យសុខឬ?" ។

នាងសុជាតាទូលតបទៅព្រះពោធិសត្វវិញថា: "ឧព្រះអគ្គជាទីគោរព! ហេតុយវត្ថុខ្ញុំព្រះអង្គតូចណាស់ ប្រៀបដូចដំណក់ទឹកក្នុងមហាសមុទ្រ

ដែលមិនអាចធ្វើឲ្យសើមដាំលង់ផង អាចដក់ពេញក្នុងស្រទាប់បុប្ផលិស (lys) បាន ។ ខ្ញុំព្រះអង្គស្រាប់តែឃើញព្រះសុរិយានៃជីវិតភ្លឺសប្បាយ រីកឡើងនៅលើមុខស្វាមី គាត់ញញឹម ចេញពីបបូរមាត់នៃបុត្រាដែលជាទីពេញចិត្ត, រក្សានូវសេចក្តីស្នេហាអណ្តែតត្រសែតក្នុងគេហដ្ឋាន; កាយរបស់ខ្ញុំព្រះអង្គហូរដូចទឹក, សុខស្រួលសប្បាយក្នុងការធ្វើអាហារព្រមទាំងថែទាំសំអាតផ្ទះសំបែង ក្នុងពេលបច្ចុសសម័យ, ខ្ញុំព្រះអង្គក្រោកឡើង សូត្រធម៌ថ្វាយបង្គំព្រះហើយបូជានូវគ្រាប់ឈើ បីបាច់ថែរក្សារុក្ខជាតិហៅថា តុលស៊ី (toulsi) ហើយចែកកិច្ចការដែលត្រូវធ្វើឲ្យទៅពួកទាសី, ក្នុងពេលអធិទិវា (au milieu du jour) ក្បាលស្វាមីខ្ញុំព្រះអង្គកើយលើភ្លៅខ្ញុំព្រះអង្គហើយនិទ្រាលក់ និមិត្តសប្បាយក្នុងមនោទ្វារ, មានទាសីបក់ជូតឲ្យរហើយត្រជាក់ស្រួល, លុះដល់ពេលថ្ងាយស្បែកក្នុងសាយណ្ហសម័យ ខ្ញុំព្រះអង្គទៅអង្គុយជិតស្វាមី យកនំជូនលោកពីសារ, រួចបានជូនតាកបញ្ចេញរស្មីមានពណ៌សដូចជាក្រចក់ ជាសត្វឱនខ្ញុំព្រះអង្គឲ្យចូលដំណេក គ្រោយដែលបានទៅសូត្រធម៌ទៅព្រះវិហារនិងសន្ទនាការតាមកំសាន្តចំពោះញាតិមិត្ត ។ បើយ៉ាងដូចនេះ ម្តេចក៏ខ្ញុំព្រះអង្គមិនសប្បាយរីករាយ ចិត្តដែលថ្នាថ្នាំងអម្បាលម៉ានសម្រេចដូចបំណងហើយ ថែមទាំងមានបុត្រប្រុសមួយដែលមានដៃតូចសម្រាប់បិទភ្នែកស្វាមីខ្ញុំព្រះអង្គនាំវិញ្ញាណក្ខន្ធទៅកាន់ស្ថានសួគ៌ ដល់ពេលមច្ចុរាជមក

ដល់, ព្រោះគម្ពីរសាស្ត្រាថ្លែងថា: "បើមានមនុស្សម្នាក់ជាំដើមលេចមួយ ដើមដើម្បីឲ្យម្ចាស់ដល់អ្នកដំណើរជ្រក ឬបានដីកអណ្តូងមួយជាសាធារណៈ ប្រយោជន៍ដល់ប្រជាជនហើយមានបុត្រប្រុស មនុស្សនោះលុះធ្វើកាលកិរិយាទៅកាន់បរលោក ឋានសុគតិកតមិនខាន" ។ ខ្ញុំព្រះអង្គមានសទ្ធាជឿជាក់នូវគម្ពីរទាំងនោះ ដោយខ្ញុំព្រះអង្គមិនមានគុណសម្បត្តិស្មើនឹងពួកសន្តបុគ្គលពីបុរាណកាល ដែលលោកអាចបរបាជាមួយពពួកទេវតា ហើយលោកចេះសូត្រធម៌ចេះធ្វើឲ្យគេពេញចិត្ត ស្គាល់ផ្លូវនៃគុណធម៌គ្រប់យ៉ាងព្រមទាំងសន្តិសុខ ។ ខ្ញុំព្រះអង្គយល់ឃើញថា កុសលកើតមកពីចិត្តល្អ, អកុសលកើតមកពីចិត្តលាមកចំពោះវត្ថុទាំងអស់កង់លោកមិនថានៅទីកន្លែងណា កង់ពេលណាគ្មានកំណត់ឡើយ; ព្រោះខ្ញុំព្រះអង្គបានឃើញថា ផលដែលមានឧជារសធ្វាញ់ពិសារដុះនៅលើរុក្ខា ដែលមានសុខភាពដ៏បរិបូណ៌, ឯផ្លែដែលមានជាតិល្វីងដុះនៅលើរុក្ខាដែលមានរសជាតិពុល; ខ្ញុំព្រះអង្គឃើញថាកង់ជីវភាពនេះ ចិត្តកាចនាំឲ្យទៅកាន់សេចក្តីស្អប់ខ្ពើម, ចិត្តល្អនាំទៅកាន់កល្យាណមិត្តភាព, ចិត្តខន្តីនាំទៅកាន់សន្តិសុខ; បើកាលណាបុគ្គលចូលកាន់មរណសញ្ញាហើយតើយើងនឹងបានសេចក្តីសុខតទៅអនាគតជាងសុខក្នុងបច្ចុប្បន្ននេះឬ? ប្រសិនជាបានសេចក្តីសុខជាងនោះទៅទៀត; ព្រោះថា ស្រូវមួយគ្រាប់បានឲ្យកើតធញ្ញជាតិមួយដើមមានពពាលខ្ចីស្រងាត់ ហើយចំរើនបានផ្លែហាសិប

គ្រាប់រលោងក្លឹងដូចខ្លួនមុតា ហើយបុប្ផាដែលមានទ្រង់ទ្រាយដូចតាវបស់ព្រឹក្សជាតិចំបក់ (Champaks) មានសម្បុរមាសជ្រុះភ្លាក់ទៅពួនកង់គុម្ពោតវៃដែលមានពណ៌ប្រផេះឯណោះ ។ ឧព្រះអង្គ ! ខ្ញុំព្រះអង្គជឹងថាគេអាចស៊ូទ្រាំនូវទុក្ខលំបាក ។ ដែលអាចផ្លូវធម៌ខ្ពង់ខ្ពស់បានទៅលើធូលីដីដែលនៅតាមផ្លូវគ្នា ។ បើកូនប្រុសខ្ញុំព្រះអង្គទទួលអនិច្ចកម្មមុនខ្ញុំព្រះអង្គ ។ គិតថាហាទយវត្តុខ្ញុំព្រះអង្គនឹងបែកប្រែក្លាយ ហើយខ្ញុំព្រះអង្គពេញចិត្តទុកជាមុនថាហាទយវត្តុនោះនឹងប្រែក្លាយដូចបំណងបុះ ឲ្យតែខ្ញុំព្រះអង្គបានឧបបត្តិមកូនប្រុសដែលកន្ល៉ែងជន្មាទៅ, ហើយខ្ញុំព្រះអង្គមុខជានឹងបានទៅកាន់សុគតិភព គឺភពដែលជាផលសម្រាប់ការិយាដែលមានចិត្តត្រង់ទឹងស្វាមី រង់ចាំស្វាមីខ្ញុំព្រះអង្គលុះត្រាតែលោកទទួលមរណភាពជាបរិយោសាន ។ តែបើស្វាមីខ្ញុំព្រះអង្គទទួលអនិច្ចកម្មទៅក្នុងមិសេនាទិមុនខ្ញុំព្រះអង្គ។ សូមបួលទៅស្ថិតនៅកង់ដើងក្ប ហើយខ្ញុំព្រះអង្គជាក់ក្បាលស្វាមីលើភ្លៅ ដូចខ្ញុំព្រះអង្គធ្លាប់ធ្វើសព្វថ្ងៃ, ហើយខ្ញុំព្រះអង្គសំដែងទឹកចិត្តប្រកបដោយចីតិជាខ្លាំង បើកាលណាខ្ញុំព្រះអង្គបានឃើញអណ្តាតភ្លើងឆាបឆេះរលាយទៅជាផេះជាមួយស្វាមី ព្រោះមានថាកែទុកកង់គម្ពីរថា បើស្ត្រីជាតិឥណ្ឌៀស៊ូធ្វើពលិកម្មនូវជីវិតបែបនេះ សេចក្តីស្នេហានោះឲ្យផលដ៏ល្អផលអាត្មនៃស្វាមី អាចទៅសោយសម្បត្តិទៅស្ថានសួគ៌ទៅលោកចំនួនមួយកោដិធំ គិតកង់សក់មួយសរសៃ។ ព្រោះហេតុដូចនេះ

ជាន់ជាខ្ញុំព្រះអង្គគ្មានភ័យខ្លាចអ្វីឡើយហើយដីវភាពខ្ញុំព្រះអង្គ ក៏ប្រព្រឹត្ត
ជាសុខសប្បាយតរៀងមក, ពិតមែនតែខ្ញុំព្រះអង្គមិនជាន់ក្រួចនូវដីវិត
ឯទៀតជាច្រើន ដែលកើតមកវង្វេងទុក្ខលំបាកគ្រប់យ៉ាង គឺកែ ទុព្វលភាព,
ហើយទុរភិក្សអត់ឃ្លាន ដែលទេវតាឥន្ទ្រព្រហ្ម ឬអសេក្ខបុគ្គលមានព្រះទ័យ
ករុណាពន់ពេកនោះឡើយ ; តែចំណែកខ្ញុំព្រះអង្គខំស្វែងរកបំពេញ
ករណីយកិច្ច តាមជនសាមំញាដែលខ្ញុំព្រះអង្គយល់ថាជាកិច្ចប្រសើរហើយ
ខ្ញុំព្រះអង្គរស់នៅប្រតិបត្តិតាមច្បាប់ ដោយសង្ឃឹមខុតជាមុនថាកម្មផល
ដែលខ្ញុំព្រះអង្គខ្លួល ឬមានមកក្នុងកាលជាអនាគតជាសោភណផល " ។

ព្រះបរមពោធិសត្វ ទ្រង់មានព្រះបន្ទូលតបទៅនាងសុជាតាវិញថា:
" នាងចេះខ្លួនានប្រដៅពួកគ្រូអាចារ្យ ។ ប្រាជ្ញានាងពិតមែនតែសាមញ្ញ
តែគួរឲ្យសរសើរ ព្រោះមានសភាពវិសេសវិថ្លៃថ្លាលើសវិជ្ជាទាំងពួង ។
ចូរនាងនៅជាសុខចុះ ដោយនាងដឹងច្បាស់ថាខ្លួននាងល្ងង់ព្រោះនាងបាន
ស្គាល់ផ្លូវនៃយុត្តិធម៌ ទើងករណីយកិច្ចរបស់នាង ; ចូរនាងនៅដូចបុប្ផាដុះ
ហើយឲ្យម្ចាស់ទៅបុត្រប្រុសជ្រកតាមប្រាថ្នា ; រស្មីនៃសច្ចធម៌ក្លឹងក្លាំងពេក
មិនមែនបញ្ចាំងសម្រាប់ស្ងឹកព្រឹក្សាជាតិមានសភាពទន់ខ្សោវដែលទើងអាច
ចំរើនទូវដីវភាពបានទៅក្រោមព្រះសុរិយាដែនោះឡើយ ឬដែលទើង
បញ្ចេញទូវដីវភាពប្រកបដោយហេតុបច្ច័យ ប្រៀបដូចជាបុប្ផាក្រអូប
ឈ្ងុយឈ្ងប់ឆើយស្រាប់ទៅពាន់មហាមេឃដូចនោះ ។ (មានត)

ធម្មបរិយាយកថា

ព្រះគ្រូបញ្ញាលិទ្ធិត កៅ - សឹម សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់

ទេសនាជាភាសាខ្មែរ ក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ថ្ងៃទី ២២ ខែកញ្ញា គ. ស. ១៩៤៧

ធម្មំ រតនត្តយំ

លំដាប់តទៅនេះ, សូមសំដែងធម្មទេសនា ជាធម្មបរិយាយផ្សាយតាមខ្យែ ដោយសេចក្តីសង្ខេប ដើម្បីនឹងញុំាងទឹកចិត្តនៃសាធុជន ជាសប្បុរស អ្នកដែលមានសទ្ធានឹងសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ឲ្យចុះស៊ប់កាន់ធម៌ទេសនាតាមនិពន្ធគាថា ដូចតទៅនេះ :-

យថាបិ ភាម ឧក្កន្ទោ ឧភោ អបរិណាយកោ
ឯកកា យាតិ មក្កដេ ទុម្មក្កេនាបិ ឯកកា
សំសារេ សំសរំ ពាលោ តថា អបរិណាយកោ
កកេកតិ ឯកកា បុញ្ញំ អបុញ្ញម្បិ ឯកកា
យថា ច ញត្វា សោ ធម្មំ សច្ចានិ អភិសមេស្សតិ
តថា អរិដ្ឋបសមា ឧបសន្តោ ចរិស្សតិ ។

ប្រែថា : "មនុស្សខ្វាក់អំពីកំណើត (គ្រាច់ចរលើផែនដី) បើមិនមានគេដឹកដៃនាំមុខទេ ជួនដើរត្រង់ផ្លូវ ជួនដើរខុសផ្លូវ យ៉ាងណាមិញ;

មនុស្សពាលនោតល្ងង់ខ្លៅ ។ កាលបរិគ្រោចរង្គាត់ទៅក្នុងវាលវដ្តសង្សារ បើមិនមានបណ្ឌិតដឹកនាំមុខទេ ដួនធ្វើបុណ្យ ដួនធ្វើបាប ក៏យ៉ាងនោះដែរ; លុះតែមនុស្សពាលនោះ យល់ធម៌ច្បាស់លាស់ គ្រាស់ដឹងនូវអរិយសច្ច ๔ ប្រការពេលណា នឹងជាបុគ្គលប្រព្រឹត្តសន្តិសុខស្ងប់ស្ងាត់ពេលនោះ ព្រោះបានរម្ងាប់នូវអវិជ្ជា" ។

តពីនេះ នឹងអធិប្បាយព្រះពុទ្ធភាសិតខាងលើនេះតទៅ :—

ព្រះសម្ពុទ្ធវិសុទ្ធិគុណទ្រង់ជ្រាបច្បាស់ថា ពួកសត្តនិករាំងឡាយដែលលិចលង់ផុងក្នុងអំណាចអវិជ្ជាគ្រែកអរក្នុងសង្សារវដ្ត តែងមានគំនិតត្រិះរិះពិចារណាយល់ឆ្គង គាត់តែងគ្រឿងផ្សំជាបុណ្យក៏មាន ជាបាបក៏មាន មិនច្បាកដ ដូចមនុស្សខ្វាក់ដើរព្រាវលើផែនដី ដួនចំផ្លូវ ដួនខុសផ្លូវ ពានទៅលើទីខ្ពស់ ទីទាប មិនរាបមិនស្មើ ជាហេតុឲ្យបានសេចក្តីទុក្ខលំបាកច្រើន ។ ឯសព្វសត្តក្នុងលោកសន្និវាសនេះ សុទ្ធសឹងតែប្រាថ្នារកសេចក្តីសុខចំរើនគ្រប់ៗគ្នា តែដួនពារពានទៅលើទុក្ខក៏មាន ដួនពារពានទៅលើសុខក៏មាន ដោយហេតុមកពីគំនិតយល់ត្រូវ នឹងយល់ខុស, កាលបើគិតត្រូវ យល់ត្រូវ ប្រកបកិច្ចការងារត្រូវ ក៏បានសេចក្តីសុខចំរើន, បើគិតខុស យល់ខុស ប្រកបកិច្ចការងារខុស ក៏បានសេចក្តីទុក្ខមិនបានចំរើន ព្រោះមកពីមានប្រាជ្ញា និងខ្វះប្រាជ្ញាជាបុព្វហេតុ ។

គំនិតមនុស្សដែលយល់ឆ្គង មិនត្រូវតាមហេតុ ស្មានហ៊ាយផ្សំយកគ្មានខ្លឹងចំណេះវិជ្ជាអ្វីយកមកពិចារណាពិនិត្យពិច័យឲ្យច្បាស់លាស់ជា

មុនសិន ស្រាប់តែប្រកបកិច្ចការងារនោះ ធ្វើទៅតាំងស្មាន ភាប់អាន
គោរពបូជាទៅតាំងបំពាន ក្នុងពេលដែលខ្លួនបានសេចក្តីទុក្ខលំបាក មាន
ខ្លះទៅបន់ស្រន់នៅទីកន្លែងណាមួយ មានដើមឈើជាដើម ដោយយល់
ឃុសថា : ដើមឈើនោះៗឲ្យសិរីសួស្តីមង្គលដល់ខ្លួន នឹងគ្រួសាររបស់
ខ្លួន ។ មិនតែប៉ុណ្ណោះថែមតាំងធ្វើទៀវដ្ឋានអាស្រមរួម-ពោធិសាធ៍ទៀរបូ
ជារូបអ្នកតាឃ្លាំងមឿងប្រចាំស្រុក រូបដុំថ្មជាក់ដំកល់ក្នុងទៀវដ្ឋាននោះៗ
សម្រាប់ទុកគោរពភាប់អានបូជាគោតខ្លាច គ្រប់ស្រុកគ្រប់ភូមិពាល់ឆ្នាំ ពួក
អ្នកស្រុកតាំងប្រុសស្រីចាស់-ក្មេងប្រជុំគ្នាទៅបូជាយិដ ហៅថាឡើង
អ្នកតា មានចាប់សត្វក្រពើ-ស្វា-មាន់-ពា នឹងផ្លែឈូកជាដើម តាមចំណូល
អ្នកតាយកទៅបូជា ដោយធ្វើពិធីសម្លាប់ពន្លាត់ស្បែកដោតធ្នាងត្រជាង
ថ្វាយនៅមុខអ្នកតា ធំកស្រា-ស៊ីសាច់-សែនពែរផ្លែចេក-អុជធាវហ៊ឹ
កញ្ជ្រៃ-លេងក្មេង-បញ្ឆាន់រូបអាក្បែ សូមសិរីសួស្តីតប:តេជ:អំពី
អ្នកតាថា : សូមធ្វើស្រែស្រូវអង្គរ-ល្ង-សណ្តែក-ជាំចេក-អំពៅកង់ឆ្នាំ
នេះឲ្យបានផ្កាផ្លែបរិបូណ៌, សូមឲ្យទឹកភ្លៀងធ្លាក់ចុះមកបរិបូណ៌, សូមឲ្យ
សប្បាយដល់គ្រួសារគ្រប់ៗគ្នាកុំឲ្យវេទនា ដូច្នេះក៏មាន ។ ចួនកាលប្រើ
គំនិតព្រាវទៅលើទីវត្តអារាម ដែលជាទីគួរជៀងថ្វាគោរពបូជារបស់អ្នកកាន
ព្រះពុទ្ធសាសនា ថាជាទីនៅអាស្រ័យនៃខ្មោចល្បាក់សា បិសាចចំបួរដួរ
ប្តុយាយទេព្យ ដែលធ្វើខ្លួនទឹងគ្រួសារឲ្យបានទុក្ខលំបាក ហើយក៏លន់តួ

ខ្ញុំសូមបន់ប្លងសួងសូមសេចក្តីសុខសប្បាយដល់ខ្លួនទឹងគ្រួសារ សូមលេងក្តៀងថ្វាយបួងបាយសីស្វាធំរ - ស្វាដម - បួងចេក - ថ្វាយស្រា - ថ្វាយមាន់ - ថ្វាយខ្ញា ក្បាលថ្វាយ ទឹងបួស ១ សំកាំងដំរីថ្វាយដូច្នេះក៏មាន ។

ហេតុនេះយើងជាតិមនុស្សបុថុជ្ជន ក្នុងពេលដែលបានទុក្ខលំបាកហើយ កុំអាលប្រញាប់ដាក់ទោសទៅលើខ្មោចល្អាក់សាចំបួរដួរនោះពេក គួរតែតពិចារណាពាក្យឲ្យឃើញហេតុផលសិនសឹមធ្លើទើបល្អ ។ ឯចំនែកអពមង្គលដល់ទុក្ខលំបាកនោះ មិនមែនដើមឈើដុំថ្មឲ្យទេ គឺមនោះគឺអវិជ្ជាធ្វើឲ្យបានទុក្ខវេទនា ។

មនុស្សអ្នកដឿហេតុខាងក្រៅ បងំសេចផលកម្មរបស់ខ្លួនចោលទឹងឲ្យឈ្មោះថាជាមនុស្សគិតត្រូវ យល់ត្រូវ ធ្វើការងារត្រូវឯណាកើត? ធ្វើម្តេចទឹងបានសេចក្តីសុខចំរើន? ព្រោះជាអ្នកកាន់ច្រឡំ លុះក្នុងអំណាចអវិជ្ជាគ្របសង្កត់ជាប់ ទ្រឹនចូលចិត្តផ្សំថា: បើមនុស្សយើងបរិភោគវត្ថុយ៉ាងណា ខ្មោចឬទេវតា ក្តៀង ក៏គង់ចូលចិត្តបរិភោគវត្ថុយ៉ាងនោះដែរ; ក្តួយ៉ាងគេនាំគ្នាពាប់អានធ្វើពិធីបួងក្តៀង គឺគេនាំគ្នាជីករណ្តៅទៅទីតន្លែងណាមួយ ហើយយកក្តៀងទៅបង្កាត់កងរណ្តៅនោះឲ្យឆេះសន្ធោរឡើងទើបយកសត្វគរឬបាន ឬមនុស្សទៅសម្លាប់សំឡេះយកសាច់ទំលាក់បង់ទៅកន្លែងក្តៀងឲ្យក្តៀងបរិភោគសាច់នោះ ដើម្បីសូមសុខសួស្តីឲ្យកើតឡើងដោយកម្មសិទ្ធិនេះ ។

ព្រះសម្ពុទ្ធទ្រង់បានជ្រាបច្បាស់ថាពួកសត្វ នាំគ្នាធ្វើពលិកម្មបូជាពាក់អាទន្ធវៈទៅរបូនឹងការបូជាក្តៅឆ្ងាំងនេះ ដោយដើរផ្លូវខុសទំនងមិនសមហេតុផលទេ ទើបទ្រង់ប្រែនយោបាយផ្ងាស់ផ្លូវកម្មសិទ្ធបែបសត្វពាំងនោះ ទ្រង់ដឹកនាំផ្លូវជាធម្មសិទ្ធដោយសំដែងប្រាប់ពលិកម្ម ៥ យ៉ាង ជាគ្រឿងបំភ្លឺឲ្យផ្ងាស់គំនិតឈ្លងយល់ខុសនោះ ទៅជាគំនិតត្រូវវិញ ។ ឯពលិកម្ម ៥ នោះដូចតទៅនេះ :

๑ – ញាតិពលិ = សង្គ្រោះញាតិសន្តានដែលស្លាប់ទៅ,

๒ – អតិថិពលិ = ទទួលភ្ញៀវដែលមកដល់ទីលំនៅខ្លួន,

๓ – បុព្វប្បេតពលិ = ធ្វើបុណ្យទុទ្ទិសផលបញ្ជូនទៅបុព្វបុរស, មានមាតាបិតាជាដើម ដែលបែកធានទៅហើយ,

๔ – រាជពលិ = បង់ពន្ធជារដូនការផែនដី,

๕ – ទេវតាពលិ = ធ្វើបុណ្យទុទ្ទិសផលដល់ពួកទេវតា ។

ពលិកម្ម ៥ នេះហើយ ជាផ្លូវនាំឲ្យបានសេចក្តីសុខចំរើនទាំងលោកនេះនឹងលោកខាងមុខ ជាដំណើរចៀសវាងអំពីផ្លូវនោតលង់ខ្ទាំកាន់ច្រឡំរបស់មនុស្សដែលឥតគំនិតឥតប្រាជ្ញាមិនបានការនោះ ។

គំនិតដែលកាន់ច្រឡំយ៉ាងនេះមុខជានឹងច្រឡំដោយពៀរគ្រប់សាមកលើខ្លួនអ្នកធ្វើវិញមិនខាន សមដូចព្រះសម្ពុទ្ធទ្រង់ពោលទុកមកថា :

បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ
វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។

" អ្នកណាស្រាប់ថ្នាសុខចំពោះខ្លួន ដោយការបំពេញទុក្ខទៅលើអ្នកដទៃ អ្នកនោះឈ្មោះថាជាប់ចំពាក់ធ្ងាក់ដោយពៀរ រមែងដោះខ្លួនមិនរួចផុតស្រឡះចាកពៀរឡើយ " ។

ការទំលាក់ទុក្ខស្រោចទោសទៅលើអ្នកឯទៀតនោះ គួរជ្រាបថា : ត្រូវប់ឲ្យផលសងសឹកមកខ្លួនវិញ ត្រូវតាមដំណើរដើមដែលខ្លួនធ្វើទៅលើគេ ឬក៏ឲ្យផលខុសពីស្ថានដើម តែត្រូវគេពិន័យជាបទអាជ្ញា ត្រូវជាប់គុកច្រវាក់ ឬក៏ក្វាយឲ្យផលត្រូវទទួលវេគៈថ្នាក់ ១០ យ៉ាងផ្តន្ទាបណ្តាលឡើង គឺ: ១ - ត្រូវវេទនាយ៉ាងខ្លាំង ; ២ - ត្រូវវិនាសសាបសូន្យចាកយសស័ក្តិ ; ៣ - ត្រូវបែកធ្លាយសរីរៈពងកាយ ; ៤ - ត្រូវមានជម្ងឺឈឺជាទម្ងន់ ; ៥ - ត្រូវបាន់សេចក្តីក្រឡុកចិត្តឆ្គួត ; ៦ - ត្រូវស្តេចរំបាន់ ; ៧ - ត្រូវគេពោលបង្កាច់យ៉ាងអាក្រក់ ; ៨ - ត្រូវនឹកស្រាត់ស្រាសចាកពួកញាតិសន្តាន ; ៩ - ត្រូវហិនហោចខូចខាតទ្រព្យសម្បត្តិ ; ១០ - ត្រូវភ្លើងឆេះផ្ទះ (អន្ទះបាញ់បំផ្លាញអ្នកនោះ) លុះបែកធ្លាយពងកាយទៅ អ្នកដែលមានគំនិតយល់ឆ្គងឥតប្រាជ្ញា អវិជ្ជាគាត់តែងត្រឹងផ្សំសង្ខារឲ្យទៅកើតក្នុងកន្លែងនរក ។ នេះហើយជាផលក្វាយខុសចាកស្ថានដើម ជាផលដែលដេញតាន់ជាន់តែងដូចសំដែងមកនេះ ។

ធម្មតាមនុស្សធោតល្ងង់ប្រកាន់ទិដ្ឋិ ទំលាក់គ្រាញគំនិតអាក្រក់ គំនិតញាប់ខឹងច្រើនជាងមនុស្សដទៃ តែងមិនរួចផុតអំពីចំណង ៧ យ៉ាងជាគ្រឿងចងធ្ងន់របស់អវិជ្ជា ឲ្យជាប់កើតស្លាប់ត្រៀបត្រាក្នុងវដ្តសង្សារនេះគឺ

១ – រាគពន្ធន: អវិជ្ជាចងធ្ងន់ដោយកាមគុណ ៥ គឺឲ្យសម្លាញ់ដោយរូប- សំឡេង- ក្លិន- រស- សម្ផស្ស ;

២ – ទោសពន្ធន: អវិជ្ជាចងធ្ងន់ដោយបដិឃៈ គឺឲ្យសម្លាញ់ដោយទោសៈ សេចក្តីក្រោធពិរោធខឹងវាយដំច្រឹងឆាក់ កាប់សម្លាប់គ្នាបៀតបៀនគ្នា ញាប់ខ្ញាល់តែនិងសម្លាប់ខ្លួន ;

៣ – មោហពន្ធន: អវិជ្ជាចងធ្ងន់ដោយមោហៈ គឺឲ្យសម្លាញ់ដោយសេចក្តីវង្វេង កាន់ច្រឡំ ធោតល្ងង់ខ្លៅ ;

៤ – ទិដ្ឋិពន្ធន: អវិជ្ជាចងធ្ងន់ដោយទិដ្ឋិ គឺឲ្យសម្លាញ់តែខាងឃើញខុស យល់ខុសប្រកាន់ខុសថាជាត្រូវៗថាជាខុសដោយផ្លូវសស្សតទិដ្ឋិ គឺយល់ឃើញទៀងថា: សត្វលោកដែលស្លាប់កើតយ៉ាងណា ស្លាប់ទៅវិញក៏ទៅកើតជាយ៉ាងនោះដដែលមិនប្រែប្រួល, ឯទុច្ឆេទិដ្ឋិយល់ឃើញថា : សត្វលោកស្លាប់ហើយសូន្យ មិនមានអ្វីនាំឲ្យទៅកើតទៀតទេ ;

៥ -មានពន្ធន: អវិជ្ជាចង់ធ្វើដោយមាន: គឺឲ្យសម្លាប់ដោយវែងគ្នឹងលើកខ្លួនឲ្យខ្ពស់ប្រសើរជាងគេ មិនត្រមជឿស្តាប់បង្គាប់អ្នកណាចេះសយកឈ្នះតែម្នាក់ឯង ;

៦- កិលេសពន្ធន: អវិជ្ជាចង់ធ្វើដោយកិលេសជាគ្រឿងរឹតរុំ គឺឲ្យសម្លាប់ដោយសំយោជនក្លិសទាំង ១០ ដែលធ្វើចិត្តសត្វឲ្យសៅហ្មង រិលស្អាបរិលកើតកង់វដ្តទុក្ខ ;

៧- ទុច្ចរិតពន្ធន: អវិជ្ជាចង់ធ្វើដោយទុច្ចរិតទាំង ៣ គឺឲ្យសម្លាប់ដោយសេចក្តីប្រព្រឹត្តិអាក្រក់ ដោយកាយ-វាចា-ចិត្ត ។

ភាពមនុស្សពាល ដែលអវិជ្ជាចង់ធ្វើដោយចំណង់ទាំង ៧ នេះតែងបាននូវសេចក្តីវិនាស សេចក្តីទុក្ខ ហេតុនោះ សាធុជនអ្នកដែលប្រាថ្នាសេចក្តីសុខចំរើន គួរខ្លាចចៀសវាងឲ្យផុតកុំឲ្យជួបប្រទះនឹងចំណង់ទាំងនេះ ។ សំដែងមកក្នុងធម្មបរិយាយកថាដោយសេចក្តីសង្ខេបតែប៉ុណ្ណោះ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា កិលេសប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា សុទ្ធិ បច្ចាត្ថ សាធវោ ។

សូមសាធុជនអ្នកស្តាប់ធម៌ទាំងឡាយ (ដែលផ្សាយតាមវិទ្យុនេះ) ជនណាដែលដល់ហើយនូវទុក្ខ សូមកុំឲ្យមានទុក្ខ, ជនណាដែលដល់ហើយនូវសេចក្តីភ័យ សូមកុំឲ្យមានភ័យ, ជនណាដែលដល់ហើយនូវសេចក្តីសោក សូមកុំឲ្យមានសោក, សូមឲ្យបានសម្រេចនូវសេចក្តីស្អាតបរិសុទ្ធគ្រប់ៗគ្នាឡើង ។

ការបណ្តុះឯសុវ័យ

ព្រះមហាឧត្តមវិជ្ជា ជលញ្ជាណោ ប៊ុង-ប៊ម

អាចារ្យសាលាចាលីវង់ វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌានុរក្ស ប៊ូ-ប៊ូ នៅពន្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

តែនិស្ស័យរបស់មនុស្សយើង សូម្បីបែបណាក៏ដោយ ក៏គង់ជាវត្ថុដែលនឹងអាចកែទៅឬបណ្តុះឡើងបាន ហើយនឹងប្លែថ្មី ស្វែងរកថ្មី ចំពោះតែងហាន:ដែលខ្លួនមិនធ្លាប់មានមកពីដើមបានតាំងអស់, ដូចជានិស្ស័យគាក់ក៏គង់តែកែប្រែឲ្យត្រឡប់ទៅជាល្អបាន ។ ចូរមើលមនុស្សពាល់ក្លែមនុស្សថោកទាប តាំងខ្លួនឲ្យជាមនុស្សមាំតាំ ឬលើកហាន:របស់ខ្លួនឲ្យខ្ពស់ឡើង ដែលយើងឃើញគ្រានេះជាតំស្ដូតាង ដូចជាដង្កូវ ថៅកែ គហបតី ឬអ្នកមានសិល្បវិជ្ជា មានយសសក្តា មានតំណែងនាទី តាំងអំពីពាហកជល់ខ្ពស់ សុទ្ធតែបានបណ្តុះខ្លួនឲ្យមានឧស្ស័យល្អតាំងអស់ មិនមែនជាមិនធ្វើសេចក្តីល្អអ្វីមួយ ហើយស្រាប់តែក្លាយទៅជាមនុស្សល្អឡើយ ។

ពិតមែន ! ជីវិតរបស់មនុស្សយើងនេះ វាមែនជាបច្ច័យដើម្បីឲ្យឆ្ងាន់គុណ សេចក្តីល្អ ឲ្យសម្បត្តិ សុខសម្រាន្តនឹងសេចក្តីបរិសុទ្ធិ ជាបជល់ផុតចាកកិលេសជាបធម៌តាំងពួង ។ កាលបើជីវិតគ្មានសារៈហើយ

វត្ថុទាំងអស់ក៏គ្មានសារៈដែរ, កាលបើជីវិតមានសារៈហើយ វត្ថុទាំងអស់ក៏ត្រូវតែមានសារៈដែរ តែជីវិតរបស់យើងនឹងបានជាបច្ច័យដើម្បីជាតិតាំងនៅនៃគុណវត្ថុដែលជាសារៈតាំងឡាយ រមែងមានប្រាកដឡើងក្នុងការងារដែលយើងធ្វើខ្លួនឯង ដោយបានអប់រំខ្លួនទុកមកពីមុនជាហេតុ ។ សូម្បីការអប់រំខ្លួននោះ ក៏មិនមែនដទៃឆ្ងាយ គឺការបណ្តុះនិស្ស័យនេះឯង បើយើងប្រាថ្នាប្រយោជន៍ជាសំខាន់ យើងត្រូវតែខំបណ្តុះនិស្ស័យ ព្រោះយើងនឹងទៅជាមនុស្សល្អបាន ដោយសារតែការបណ្តុះនិស្ស័យឲ្យល្អ សូម្បីនឹងទៅជាមនុស្សអាក្រក់ ក៏ដោយសារតែការអប់រំខ្លួនឲ្យច្រឡូកច្រឡំទៅក្នុងផ្លូវអាក្រក់ ។ មនុស្សមានន័ស្ស័យអាក្រក់ បែរមុខទៅរកតែទីទាប ព្រោះត្រូវអំណាចខាងទាបប្រទាញឲ្យធ្លាក់ចុះទៅកាន់ថ្នាក់ទាប មិនមានឧកាសដែលនឹងព្យាយាមធ្វើចិត្តឲ្យឡើងទៅកាន់ថ្នាក់ខ្ពស់បានទេ មានជីវិតដូចជាទូកដើរក្នុងទន្លេឬសមុទ្រ ដែលឥតចង្កូតនឹងត្រវិស័យ មិនមានអ្វីជាគ្រឿងដម្រង់សោះ, គឺជាមនុស្សដែលគ្មានច្បាប់ជាគ្រឿងបង្គាប់ ។ បើឥតច្បាប់ ក៏ឥតរបៀប, បើឥតរបៀបហើយ ក៏ឥតមានសេចក្តីល្អសោះឡើយ ។

ចំណែកមនុស្សដែលមានន័ស្ស័យល្អ រមែងមានលក្ខណៈល្អៗ ដែលរកបានត្រទៅក្នុងខ្លួនច្រើនយ៉ាង ជាកំពូលនៃសេចក្តីល្អ ជាសិរីសម្រាប់រូបមនុស្ស ។ តាមពិត ការមានន័ស្ស័យល្អ គឺមតែមួយក្តាប់ប៉ុណ្ណោះ

គង់ល្អលើសជាងការដែលមានសេចក្តីចេះដឹងល្អច្រើនទាំងកញ្ជើ ព្រោះ
ហេតុអ្វី? ព្រោះហេតុថា មនុស្សដែលមានចំណេះល្អនោះ សូម្បីជាអ្នក
ឈ្លាសវាងវៃ រៀនអ្វីបានចេះឆាប់ភ្លាមៗ ក៏ដោយ តែបើនិស្ស័យអាក្រក់
ហើយ ក៏នឹងកើតសេចក្តីចេះដឹងហួសប្រមាណ ក្លាយទៅជាមនុស្ស
ឃ្មោងអួតខ្លួន លើកខ្លួនឯង មើលងាយអ្នកដទៃដែលអន់ជាងខ្លួនក្នុង
រឿងបញ្ញានឹងសេចក្តីឈ្លាសវាងវៃ ហេតុនេះ ត្រូវតែបណ្តុះនិស្ស័យឲ្យល្អ
ដែលគួរសំដែងទៅកមនុស្សដទៃទៀត ។

បុគ្គលគ្រប់រូប សុទ្ធតែមាននិស្ស័យជាគ្រឿងពិសោធន៍ឲ្យឃើញ
ច្បាស់ថា ល្អឬអាក្រក់ ឥតមានលក្ខណៈអ្វីដទៃឡើយ ។ និស្ស័យរមែង
យោងលក្ខណៈដទៃៗ ទាំងអស់ឲ្យអណ្តែតឡើងមកនៅលើសីសៈ ដូច
ជានិស្ស័យខាងសុភាពនឹងច្រឡែសបែស, ខូឈាយនឹងស្ងៀតស្ងាញ, ខន
លំគោននឹងរឹងត្អឹង, ស្មោះត្រង់នឹងរៀចរៅជាដើម ជារបស់គឺយើងអាច
ដឹងច្បាស់បាន ក្នុងកាលដែលគេសំដែងឡើងចំពោះមនុស្សដទៃ តាម
លំនាំអាការដែលគេប្រព្រឹត្តជានិច្ចសម្រាប់ជីវិត នឹងតាមសម្ផស្សនៃពាក្យ
និយាយគ្រប់ៗម៉ាត់ ព្រមទាំងតាមដំណើរការងារគ្រប់ៗចំណែករបស់ខ្លួន។

និស្ស័យល្អ ជាលក្ខណៈមានគុណតែម្យ៉ាង, កាលបើមាននៅក្នុង
ខ្លួនអ្នកណាហើយ នឹងធ្វើអ្នកនោះឲ្យជាមនុស្សល្អរៀបរយ មានកិត្តិយស
នឹងឈ្មោះសំឡេង ហើយអាចពាប់ថាជាគោលធម៌ជាប់ទាក់ទងគ្នានឹង

ប្រជាគមព្រមទាំងមនុស្សទូទៅ អាចការពារសមាគមរបស់ពួកមនុស្សឲ្យ
ផុតចាកសេចក្តីអាក្រក់ នឹងការមិនមានរបៀបរៀបរយដែលជាសត្រូវបាន
ផង ព្រោះមនុស្សមានទិស្សយល្អ សូម្បីជាអ្នកមិនមានជោគវាសនា
ខ្សត់ខ្សែឮសម្បត្តិក៏ដោយ ក៏គង់អាចប្រើទិស្សយល្អរបស់ខ្លួន សម្រាប់
ជាគ្រឿងបន្ថយទឹកចិត្តរបស់អ្នកដែលមកសមាគមបាន បើទុកជាអ្នក
នោះមានទិស្សយអាក្រក់ ក៏អាចឲ្យកេតការគោរពនិយមរាប់អានដ៏ថ្លា
ក្នុងខ្លួន នឹងកាន់យកជាទិដ្ឋានុគតិបានដែរ ។

ការបណ្តុះទិស្សយ គឺការតាំងខ្លួន ។ ការតាំងខ្លួន ទៅជាការ
សាងជាតិ ។ សូម្បីការសាងជាតិ ក៏ត្រូវតែតាំងខ្លួនជាមុន ។ ឯសេចក្តី
សំខាន់របស់ការតាំងខ្លួន នៅត្រង់ការបណ្តុះទិស្សយ ។ ការបណ្តុះ
ទិស្សយឲ្យល្អនោះ មិនចំពោះតែរូបបុគ្គលមួយៗ ទេ ត្រូវជាប់ទាក់ទង
ដល់ជាតិនឹងប្រទេសផង ព្រោះថាការវាស់តុណភាពរបស់ជាតិប្រទេស
មិនមែនវាស់តែនិស្សយរបស់មនុស្សអ្នកល្អម៉ាំម្លេះ ឬមនុស្សម្នាក់ៗប៉ុណ្ណោះ
ទៀយ យើងត្រូវវាស់ទិស្សយទឹកចិត្តរបស់ពួកជនក្នុងជាតិទាំងអស់ ។
ពិតមែន! អ្នកប្រាជ្ញ ឬរដ្ឋបុរសដែលចេះគ្រប់គ្រងនោះ ជាប្រធាន
នៃកំឡាំងរបស់ប្រជាគម តែសូមកុំភ្លេចថា "សូម្បីពួកពាស្តូ មាន
អ្នកស្រែជាដើម ក៏ជាកំឡាំងនឹងជាទឹកចិត្តរបស់ជាតិឬជាឆ្អឹងខ្នងរបស់
ប្រទេសដែរ" ។

ហានៈរបស់ប្រទេស ជាតិ សាសនា ដែលអាប់ឧន មិនមែនព្រោះការគ្រប់គ្រងទេ, តាមពិត គឺព្រោះនិស្ស័យអាក្រក់របស់ប្រជាជន ។ បើប្រជាជនមិនបានខ្វល់ការអប់រំដោយពេញចិត្តក្នុងការបណ្តុះនិស្ស័យល្អដើម្បីជួយខ្លួនឯងហើយ បើទុកជាការគ្រប់គ្រងនោះវិសេសយ៉ាងណាក៏ដោយ ក៏មិនអាចនឹងញ៉ាំងគេឲ្យអណ្តែតឡើងបានដែរ ។ ពិតមែន, ការគ្រប់គ្រង ទោះបីអាក្រក់យ៉ាងណា ក៏គង់មានផលអាក្រក់មិនស្មើនឹងនិស្ស័យអាក្រក់របស់ប្រជាជនដែលនៅក្រោមការគ្រប់គ្រងនោះឡើយ ព្រោះនិស្ស័យអាក្រក់ដែលគាញប្រជាជនឲ្យចុះទៅកាន់ទីទាបនោះ ជាការអាក្រក់ខ្លាំងក្លាណាស់ ។ ប្រទេស ជាតិ សាសនា ដែលដល់ទ្វារសេចក្តីវិនាសបាត់បង់ទៅ តែងធ្លាក់នៅលើពួកពលរដ្ឋ ដែលមាននិស្ស័យអាក្រក់ដោយច្រើន ដូចជានិស្ស័យខ្ជុយខ្ជាស រៀចវៃ និស្ស័យលួងឡៃ និស្ស័យឱ្យលែងអូស និស្ស័យខាងការឃើញតែប្រយោជន៍ផ្ទាល់ខ្លួននឹងនិស្ស័យខាងការចូលចិត្តបង្កកម្មអាក្រក់ផ្សេងៗជាដើម ។ សូម្បីហានៈរបស់ប្រទេស ជាតិ សាសនា ដែលអណ្តែតខ្ពស់ឡើង ដល់ទីបំផុតតាមបំណង ក៏ព្រោះផលដែលប្រជាជនមាននិស្ស័យល្អជាសំខាន់ ។ សេចក្តីចំរើន សេចក្តីវិវឌ្ឍកៅចន៍ ការឈានទៅមុខ នឹងការមាំមួនរឹងប៉ឹងជំហរ នៃប្រទេស ជាតិ សាសនា មិនថាកង្វាក់ប្តូរណាមួយទេ តែងតែជាផលជាប់មកអំពីនិស្ស័យល្អរបស់ពលរដ្ឋជានិច្ច, តែពលរដ្ឋនឹងមាននិស្ស័យ

និស្ស័យល្អនោះ កំព្រោះបានទទួលការអប់រំឲ្យចេះដឹងក្នុងកិច្ចបណ្តុះនិស្ស័យខ្សែដោយខ្លួនឯង ។ មនុស្សដែលមាននិស្ស័យល្អហើយ រមែងស្គាល់គុណសំដីរបស់ខ្លួនទឹងវត្តផ្សេងៗ ដោយទឹកចិត្តដ៏ជាក់លាក់ ចេះបណ្តុះចិត្តខ្លួនឯង ដូចយ៉ាងឥស្សរជនចេះរក្សាខ្លួនឯងនឹងចេះធ្វើជានាយចៅហ្វាយលើខ្លួនឯងបានទៀត ។

ការបើពលរដ្ឋ មាននិស្ស័យល្អនឹងមានវិញ្ញាគុណជាន់ខ្ពស់ហើយរមែងងាយស្រួលដល់ការគ្រប់គ្រង, សូម្បីរបៀបនៃការគ្រប់គ្រង ក៏ដំណើរទៅតាមផ្លូវដ៏ខ្ពស់ គឺប្រែវិធីការតាមបែបគ្រប់គ្រងរបស់មនុស្សល្អនឹងមនុស្សឈ្លាស ។ បើពលរដ្ឋមាននិស្ស័យអាក្រក់នឹងលូនខ្សៅហើយរមែងជាការលំបាកដល់កិច្ចគ្រប់គ្រង, ច្បាប់ទំលាប់នឹងរបៀបការគ្រប់គ្រងនោះ ក៏ត្រូវប្រែវិធីតាមបែបការគ្រប់គ្រងនៃមនុស្សអាក្រក់ នឹងមនុស្សលូន ។ ដូច្នេះ ការបណ្តុះនិស្ស័យដែលជាកិច្ចធំបំផុត នៅត្រង់ការបណ្តុះពួកជនឲ្យមាននិស្ស័យល្អទូទៅពេញប្រទេស ព្រោះថាគោលចារឹកនៃការឈានដើរទៅកាន់អារ្យធម៌របស់ជាតិនោះ មាននិស្ស័យល្អរបស់ប្រជាជនតាំងអស់ជាបេះដូង ។

និស្ស័យល្អនេះ មានកម្លាំងខ្លាំងក្លាណាស់ លុះតែកម្លាំងកាយ ១០ ទើបស្មើនឹងកម្លាំងនិស្ស័យ ១ ។ សូមឲ្យមើលចុះ! កម្លាំងរឹងប៉ឹង, ការទស្សាហកម្ម នឹងអារ្យធម៌ ឬវឌ្ឍនធម៌របស់ជាតិ សុទ្ធតែ

ត្រូវអាស្រ័យនិស្ស័យល្អរបស់ជនមួយរូប។ ដែលរួមគ្នា ទៅជាពួកមួយ
របស់ជាតិខ្លាំងនោះ ។ សូម្បីសន្តិសុខរៀបរយនឹងការមានសីលធម៌របស់
ពួកជនខាងក្នុងប្រទេស ក៏អាស្រ័យនិស្ស័យល្អរបស់មនុស្សជាសំខាន់
ដែរ ។ ច្បាប់ទំលាប់ទំនៀមរបៀបផ្សេងៗរបស់ប្រទេស មិនមែនជាមូល-
ហេតុនាំឲ្យកើតនិស្ស័យឡើយ គឺជាផលកើតឡើងអំពីនិស្ស័យរបស់
មនុស្សដោយត្រង់ ។ និស្ស័យល្អនេះ កាលខ្លួនបានបណ្តុះឡើងហើយ
រមែងធ្វើឲ្យខ្លួនមានលក្ខណៈល្អ តាមបែបនៃនិស្ស័យដែលខ្លួនបណ្តុះមក
នោះ ដូចជាមនុស្សមានសម្បាគារៈ សុប់ស្ងៀម សុភាព ទន់លំទោន
ស្មោះត្រង់ សុចរិត កតញ្ញូ ស្រឡាញ់កត្តី ចូលចិត្តតែមានរបៀប
រៀបរយ ចេះទទួលខុសត្រូវ ជួយខ្លួនឯង ដំកល់ខ្លួនត្រូវនឹងមានកិរិយា
មារយាទល្អជាដើម ។

គប្បីជ្រាបចុះថា: ការបណ្តុះនិស្ស័យ ជាការបង្ហាត់ទូរអធ្យាស្រ័យ
ឲ្យបរិសុទ្ធពេញលេញ គឺធ្វើអធ្យាស្រ័យឲ្យទន់ទៅក្នុងការធ្វើ និយាយ
ទឹងគិត ដោយសុចរិត ។ ការធ្វើ និយាយ គិត ដោយសុចរិតនោះជា
ខ្លឹមសារសំខាន់របស់និស្ស័យដែលធ្វើឲ្យមនុស្សមានលក្ខណៈល្អ ។ ឯការ
មិនអប់រំនិស្ស័យវិញ ជាការបង្ហាត់អធ្យាស្រ័យទៅក្នុងចំណែកដ៏សាបសូន្យ
គឺធ្វើឲ្យអធ្យាស្រ័យទន់ទៅក្នុងការធ្វើ និយាយ គិត ដោយទុច្ចរិត ។

ការធ្វើជាដើមដោយទុច្ចរិតនោះ ជាកេតយ៉ាងខ្លាំងក្នុងរបស់និស្ស័យដែលធ្វើឲ្យមនុស្សមានលក្ខណៈអាក្រក់ ។

តាមពិត ការសោយសោក តែងកាត់ផ្តាច់នូវសេចក្តីក្រអឺយ, រដូវរដោ តែងកាត់ផ្តាច់នូវលំអក្នុងរដូវក្តៅ, ព្រះអាទិត្យ តែងកំចាត់បង់នូវងងឹត, ទោស តែងបំបាត់នូវគុណ, ការសាងនិស្ស័យឲ្យល្អ តែងកាត់ផ្តាច់នូវសេចក្តីវិបត្តិ, ឯការបណ្តោយឲ្យនិស្ស័យថោកទាប តែងបំផ្លាញនូវសិរីមង្គល ។ គ្រប់មនុស្ស សុទ្ធតែចង់បានល្អចង់បានឲ្យទទឹងយសស័ក្តិ តែអ្នកប្រសប់ទើបបានឲ្យ, អ្នករៀបរបស់ស្អាង ទើបបានសុខសម្រាន្ត, អ្នកមិនមានភេតភ័យឈឺចាប់ ទើបមានសុខភាព, ឯអ្នកដែលសាងនិស្ស័យល្អវិញ តែងសម្បូណ៌ទៅដោយគុណ មាំមួនដោយឲ្យសម្បត្តិទទឹងយសស័ក្តិ ថែមទាំងជាបុគ្គលអាចជួយខ្លួនឯង ទទឹងគ្រួសារបស់ខ្លួនបាន ជាបដល់អាចជួយជាតិ .សាសនា របស់ខ្លួនក្នុងវេលាដែលត្រូវការបានទៀតផង ។

ដូច្នេះ យើងគប្បីតាំងចិត្តសិក្សារឿង "ការបណ្តុះនិស្ស័យ" ហើយចំបណ្តុះនិស្ស័យរបស់ខ្លួនឲ្យល្អតាមរឿងនេះចុះ ព្រោះរឿងនេះ ឥតបានជាប្រយោជន៍ ដល់អ្នកដែលគ្រាន់តែមើលឲ្យចេះដឹងហើយមិនប្រព្រឹត្តតាមនោះទេ លុះតែជនណាមួយ ចេះដឹងហើយចំប្រព្រឹត្តតាមផង ទើបអាចទទួលផលប្រយោជន៍អំពីរឿងនេះបាន ។ (ម.ពត)

សព្ទថាកំនត់ប្រែជាខ្មែរ

របស់

គណៈកម្មការវប្បធម៌

លោកម៉ុញ - ដាំគ្រី អតីតតំណាងរាស្ត្រ រួបរួម

(ត្រមក)

Monôme = ឯកធា

Binôme = ទ្វិធា

Trinôme = ត្រីធា

Polynôme = ពហុធា

Expression algébrique = បទសមោធានពីជគណិត

Rapport = សម្ភាគ

Proportion = សម្ភាមាត្រ

Donnée = ទិន្នន័យ

Commentaire = អត្ថាធិប្បាយ

Développement = អភិវឌ្ឍន៍

Conseil de discipline = ក្រុមប្រឹក្សាវិន័យ

Négociation = ការចរចា

Conseiller-d'Ambassade = ទីប្រឹក្សាស្ថានឯកអគ្គរាជទូត

Conseiller de Légation = ទីប្រឹក្សាស្ថានអគ្គរាជទូត
(๑๓-๑๐-๕๐)

Congrès = សមាជ

Clause = ។

Termes = សំនួន, ខ្លឹមសៀវ

Semi-œuvré = អឌ្ឍកិត (ដែលគេធ្វើហើយឲ្យល្មម
ប្រកបការតទៅទៀតបាន)
(๒๔-๑๐-๕๐)

Coopération = សហប្រតិបត្តិការ
(๒๗-๑๐-๕๐)

Installation = ឋបនកណ្ឌ; ឋបនកម្ម

Entente = ការចុះសម្រុង

Entente cordiale = មិត្តភាពស្និទ្ធជិត

Cordialité = សិនិទ្ធភាព

Alliance = សម្ពន្ធភាព
(๓-๑๑-๕๐)

1°) premièrement = ๑ ខ) ក្រឹងដំបូង ๑

Possibilité = ការអាចប្រព្រឹត្តទៅបាន
(๓-๑๑-๕๐)

Devise (Comptabilité) = រូបិយប័ណ្ណ

Deviser = និយាយគ្នាលេង

Facilité = សេចក្តីស្រួល

En foi de quoi = ជាបន្ទាល់ក្នុងឯកិច្ចនេះ

Chancellerie = ស្ថានអធិការធិបតី

Chancelier = អធិការធិបតី

Homicide = ជនឃាត (ការសម្លាប់មហាជន)

Note verbale = លិខិតវាង (កំណត់ដោយលាយលក្ខណ៍អក្សរ ឥតមានចុះហត្ថលេខាសម្រាប់ប្រើក្នុងការទូត)

Nonce = សមណទូត (ឯកអគ្គរាជទូតរបស់សាសនា)

Légat du Pape = សមណប្រែសិតរបស់ប៉ាប

Accréditement = ការតាំងទូត

Diète = ទិនសភា (សភារបស់ប្រទេសខ្លះមានប្រទេសជប៉ុនជាដើម)

Blindé = រថគ្រែះ

Scout-car = បុរេរថ (រថមើលការមុនគេ)

(១០.១១.៥១)

Exceptionnel = ក្រៅតាមធម្មតា

Compagnie de Quartier Général = កងអន្តរសេនាធំ នៃទីបញ្ជាការ

Caisse provinciale du Crédit Populaire = ហិបប្រាក់ប្រចាំខេត្តសម្រាប់បង្ការឲ្យប្រជាជន

Mécanicien = យន្តការី

Canot-automobile de plaisance = កាណូតយន្តកំសាន្ត

Machine à vapeur = ម៉ាស៊ីនប្រើចំហាយ

Moteur de chaloupe = យន្តកប៉ាល់

(ឧ ៨ ១១-៥០)

Décompte = វិគណនី (ការពេយមុខបរិមាណប្រាក់)

Brigadier de la P. M K. = អ្នកត្រួត ក. ខ. ខ. (អ្នកត្រួតនៃក្រមតម្រួតទាហានខ្មែរ)

(១-១៦-៥០)

Maréchal des Logis de la P. M. K. = ពលបាលនៃ ក. ខ. ខ. (ក្រមតម្រួតទាហានខ្មែរ)

Etude (d'une question) = ការពិនិត្យគ្រោងការណ៍ (នៃបញ្ហា)

Objectif (adj.) = ដោយថាវត្ថុ (ដែលមានដំណើរទៅតាមហេតុ)

Conflit = ចំណោះ

Polémique = សង្គ្រាមជ្រាកកា

Subjectif = ជាអញ្ញថាវត្ថុ (ដែលដំណើរផ្សេងពីយថាវត្ថុ)
(ន-១២-ន១)

Assurer = ការធានា

Affirmer = អះអាង

Garantir = ធានា

Statuer = អារកាត់, សំរេចសេចក្តី

Faire faillite = រំលំ (ខាងដំនួញ)

Dons = ទាន, អំណោយ

Legs = អច្ចយទាន (អំណោយរបស់បុគ្គលស្លាប់)

Spécialisation = ឯកទេសកម្ម
(ន-១២-ន១)

Insigne = លក្ខណសញ្ញា (គ្រឿងសំគាល់)

Tenue militaire = យោធាចរិយា (របៀបសណ្តាប់ធ្នាប់ សំលៀកបំពាក់ទាហាន)

Habillement = សំលៀកបំពាក់, គ្រឿងតែងខ្លួន, ការតែងខ្លួន

Tenue matérielle des nouvelles recrues = សម្ភារៈបរិក្ខារទាហានថ្មី

Galon = ច្បាន់ស័ក្តិ
(១២-១២-ន១) (ម៉ាត)

រឿងព្រៃឥណ្ឌូមា

លោក សាង - សាវ័ត លេខាធិការ ក្រសួងបរិរញ្ញវត្ថុ

ប្រែពីភាសាចាវ៉ាំងមកជាខ្មែរ

(ត)

ក្នុងពេលនោះ យាយមេដោះរបស់នាងចេញមកហើយដោយមិនដឹងរឿងអ្វី ចានិយាយឲ្យនាងដោះចិញ្ចើនមួយក្មេត ដើម្បីឲ្យលោកមើលផង ។

លុះកាលណាកិក្ខុទទួលចិញ្ចើនមកហើយ ចានធ្វើខ្លួនជាសត្វក្អែកខ្មៅមួយយ៉ាងធំ ហើយហើរទៅនៅក្នុងកោះមួយយ៉ាងឆ្ងាយ កណ្តាលមហាសមុទ្រ ដែលគ្មានអ្នកណាមួយអាចទៅតាមបាន ។ រាជាតាំងប្រាសាទមួយយ៉ាងល្អឆើតឆាយ មានដំបូលប្រាំមួយជាន់ ។

លុះដល់បុរសត្រឡប់មកប្រាសាទវិញ ចានដឹងរឿងក៏កើតទុក្ខជាអនេក និយាយទៅកាន់ភរិយាថា "តើហេតុយ៉ាងណាចានជាអ្នកបង្ហាញចិញ្ចើនឲ្យវាមើល? មិនចាំពាក្យបណ្តាំរបស់បងសោះ! ឥឡូវនេះអ្នកឃើញទេ? កិក្ខុចានចិញ្ចើនហើយរត់ទៅនៅកណ្តាលសមុទ្រ ។ កន្លែងនោះគ្មានអ្នកណាទៅដល់ទេ បងអស់សង្ឃឹមហើយពីថ្ងៃនេះតទៅ" ។ បុរសយើញភរិយាយំទឹកភ្នែកហូរហាម ក៏មានចិត្តអាណិតមេត្តានាងជាពន់ពេក ចានលួងលោមបីបម្មថាក់ថ្នមអង្អែលនាង ហើយចានំណាត់ទុក

ក្នុងចិត្តថា : "កាលណាពិតនោះ គឺកំហុសរបស់ខ្លួនឯងដោយហេតុត្រៃលក្ខណ៍ប្រគល់ត្រូវដ៏ថ្លៃថ្លានោះ ទៅស្រីដ៏ទន់ខ្សោយប្លែកជាង, ធ្វើយ៉ាងនេះ គឺបង់ឲ្យចិញ្ចឿនបាត់វិនាសអន្តរាយ" ។ បុរសព្រួយចិត្តពន់ពេក គំនិតនឹងវិញ្ញាណតែងរត់ទៅរកបរស់ដែលបាត់ជានិច្ច ។

ប៉ុន្តែរឿងនេះ អស់លោកអ្នកគង់ជ្រាបក្នុងកាលជាខាងក្រោយវិញទេ ទុក្ខព្រួយរបស់បុរសនេះ មិនមែនបេះតែនៅនឹងដដែល ដូចបុរសបាននឹកស្មានទោះឡើយ ។ ថ្ងៃមួយមានហ្វូងស្រីទេពអប្សរនៅនាស្ថានសួគ៌ចុះមកមុជទឹកលេងសប្បាយក្នុងត្រពាំងមួយ ដ៏មានទឹកថ្លាត្រចះត្រចង់ លំអដោយផ្កាឈូករីករាយនៅជិតទីប្រាសាទរបស់បុរស ។ មុនឡើងចុះមុជទឹកនោះ ស្រីទេពអប្សរទាំងអស់ដោះកងកដាក់លើច្រាំង ។

ឆ្នាំដើរលេងជិតទីនោះ ឃើញកងកល្អប្រសើរក្រៃពេក, មួយទៀតឃើញម្ចាស់របស់ខ្លួនមានទុក្ខព្រួយផង, ឆ្នាំមានគំនិតមួយភ្លាម គឺធ្វើតាមកន្លែងនោះ ដើម្បីធ្វើឲ្យបុរសជាម្ចាស់បានសប្បាយចិត្តវិញ ។ លុះគិតដូច្នោះហើយ ឆ្នាំប្រមូលកងកទាំងអស់យ៉ាងប្រញាប់ប្រញាល់ រួចយកទៅលាក់នៅគល់ឈើមួយកណ្តាលព្រៃធំ ។ កំពុងតែមុជទឹក ស្រីទេពអប្សរ បានឃើញឆ្នាំចោលយ៉ាងលឿនដូច្នោះ ក៏នាំគ្នាឈប់មុជទឹកទាំងអស់ ហើយរត់ទៅសំពះអង្គឆ្នាំ ដែលត្រឡប់មកអង្គុយលើមាត់ច្រាំងវិញ ។

បើសិនណាឆ្នាំជាមនុស្សវិញ មិនអាចទប់ចិត្តបាននឹងសេចក្តីអង្វរ
របស់ស្រីទេពកញ្ញា ដែលមានសក់ចង់ជាកូនវែងៗ ហើយដែលគ្រាប់ភ្នែ
ជាប់នៅក មើលទៅល្អដូចគ្រាប់ត្បូងពេជ្រកែវចរណៃ ជាប់នៅលើស្បែ
ដ៏ស្អាតរិចរិត គួរឲ្យមានចំណង់ចង់មេត្រីណាស់ ។ ប៉ុន្តែនេះ ហេតុតែឆ្នាំ
មានចិត្តខ្ជិលត្រង់ល្អ ហើយគ្មានគោរការណ៍អ្វីមួយច្បាកដកង់ខ្លួន ។
ឆ្នាំអង្គុយនៅទីនោះធ្វើខុយមុយមើលមុខស្រីកញ្ញា ដែលអង្វរដោយសំ-
ឡេងយ៉ាងផ្អែមពីរោះ ដូចមានតទៅនេះ "ខ្ញុំ! អ្នកបង់ឆ្នាំអើយ! កង់ក
អស់នោះសម្រាប់តែទេវតាទេ ឯមនុស្សលោកមិនត្រូវសោះ, ហេតុដូច្នេះ
សូមឲ្យម្ចាស់បង់អាណិតខ្ញុំទៅ ឲ្យខ្ញុំវិញមក" ។ ឆ្នាំឆ្លើយថា "នែស្រីទេព
អប្សរទាំងឡាយ! យើងសុខចិត្តឲ្យកង់កទាំងអស់វិញក្នុងគ្រានេះ យើង
គ្មានត្រូវការទេ ប៉ុន្តែយើងសុំឲ្យអ្នកសំដែងសិល្បវិជ្ជាធ្វើជាថ្លៃមួយ ពីទីនេះ
ទៅដល់កោះតូចមួយដែលនៅកណ្តាលសមុទ្រ ព្រោះព្រាហ្មណ៍ម្នាក់បាន
លួចចិញ្ចៀនរបស់ចៅហ្វាយនៃយើងតែទៅពួននៅទីនោះ, កុំបាច់ដាក
ច្រើន, លុះតែធ្វើដូចពាក្យយើង ទើបយើងសុខចិត្តឲ្យកង់កវិញ" ។

ស្រីទេពអប្សរក៏លើកដៃឡើងធ្វើជាថ្លៃមួយតាមការបុកណ
ពីព្រោះការណោះ គេមិនចាំបាច់ស្ទាន់ទេ ។ លុះធ្វើបានដូចបំណង
ហើយ នាងក៏ត្រឡប់ទៅស្ថានសួគ៌វិញដោយរីករាយ ពីព្រោះនាងបាន
កង់កវិញគ្រប់ៗគ្នា ។

ឆ្នាំដើរយ៉ាងលឿនតាមផ្លូវថ្នល់នោះ, លុះទៅដល់គោះនោះហើយ បានឃើញព្រាហ្មណ៍ដេកលក់នៅក្នុងច្រាសាទ, ឆ្នាំសង្កេតមើលឃើញចិញ្ចៀនដ៏វិសេសនៅក្នុងម្រាមដៃព្រាហ្មណ៍ ។ ឆ្នាំទំអង្គុលដោះចិញ្ចៀននោះបន្តិចម្តងៗ ដោយមិនឲ្យព្រាហ្មណ៍ភ្ញាក់សោះ ។ លុះបានចិញ្ចៀនហើយឆ្នាំត្រឡប់មកវិញភ្លាម ។

ឆ្នាំយកចិញ្ចៀននោះទៅប្រគល់ដល់ដៃបុរសដែលជាចៅហ្វាយរបស់ខ្លួន ដោយក៏មានចិត្តត្រេកអរជាទីបំផុត ហើយនិយាយថា: "ខ្ញុំសូមគុណចៅហ្វាយម្ចាស់ដោយសារចៅហ្វាយម្ចាស់មានគុណនឹងខ្ញុំ, លោកបានចំណាយប្រាក់អស់ជាច្រើនទិញខ្ញុំ, ឯដំឡៃដែលលោកទិញខ្ញុំនោះថ្លៃមួយរយដងជាងដំឡៃពិតរបស់ខ្ញុំ, រួចតាំងពីនោះមក លោកបានបីប្រាប់ថែរក្សាខ្ញុំជានិច្ច" ។

បុរសគេទៅប្រាប់មហេសី ។ ព្រះនាងមានព្រះទ័យត្រេកអរពន់ពេក, ចំណែកខាងកិក្កុលាមកអកុសល ធ្លាក់ក្នុងសមុទ្រលង់ទឹកស្លាប់បាត់ទៅ ។

លុះយូរបន្តិចក្រោយមក មានចោរកំណាចមួយពួកចូលទៅក្នុងច្រាសាទ កណ្តាលរាត្រីងងឹត ដោយមានបំណងចង់សម្លាប់បុរសដើម្បីយកចិញ្ចៀន ។ ប៉ុន្តែក្នុងពេលនោះ ឆ្កែកំពុងឈរយាមល្បាត កាលឃើញពួកចោរក៏លោតទៅខាំមេចោរដួលស្លាប់នៅកន្លែង ហើយអូស

ខ្ញុំចង់ចោលក្នុងអណ្តូងមួយក្នុងសួនច្បារ ។ ឯអស់ពួកកូនចៅរាំងពួន លុះឃើញដូច្នោះ មានចិត្តកិតក័យនាំគ្នារត់ ខ្លះត្រូវបួសនៅដើង ដោយអំណាចបង្គំមនែឆ្កែ ។

លុះព្រឹកឡើង ឆ្កែនិយាយប្រាប់បុរសដែលតែងអង្អែលអ្នកពាល់ព្រឹកថា : "យប់មិញខ្ញុំមិនបានដេកលក់ទេ ពីព្រោះខ្ញុំមានការធ្វើច្រើនណាស់" ។ បុរសក៏ឈ្ងូចសួរ, ឆ្កែក៏និយាយថា: "មានចោរបីនាក់លួចចូលក្នុងសួនច្បារ ដោយបានលោតផ្លោះរំលងកំពែងប្រាសាទ ប្រាថ្នានឹងចង់មកសម្លាប់ម្ចាស់ ប៉ុន្តែខ្ញុំបានខាំសម្លាប់មេវ រួចកូនចោរកិតក័យរត់បែកខ្ចាត់ខ្ចាយរៀងខ្លួន ខ្ញុំក៏បានតាំយកខ្ញុំចង់ចោលក្នុងអណ្តូង មានតាំងស្នាមនៅកនឹងកាំបិតស្រួចជាប់នៅដៃអស់កនោះផង" ។ រួចឆ្កែបន្ថែមសេចក្តីថា : "ខ្ញុំបានជួយសង្រ្គោះចោរហ្វាយនេះ ថ្ងៃក្រោយខ្ញុំជួយទៀតពីព្រោះចៅហ្វាយបានប្រព្រឹត្តល្អនឹងខ្ញុំ" ។ បុរសធ្វើយថា: "អើ! គេចង់ពាក្យបាទខ្ញុំ ដោយខ្ញុំបានជួយប្រាក់មួយរយណែនឲ្យអ្នក, គេចង់លួចទ្រព្យសម្បត្តិខ្ញុំ គេចង់ហូតជីវិតខ្ញុំ ក្នុងពេលដែលខ្ញុំកំពុងក្រែបបីតក្នុងប្រាសាទនេះ, ខ្ញុំអគុណនឹងសត្វតាំងបីដែលបានជួយខ្ញុំនេះ" ។ ថាហើយបុរសចូលទៅក្នុងព្រៃជ្រៅ យកក្រែបព្រៃមកឲ្យនៅគេហស្ថានរបស់អ្នកវិញ ដើម្បីបីបាច់ថែរក្សាដូចសត្វតាំងពីរទៀត ។

ប៉ុន្តែលុះយកមកបំបាច់ក្បាជាមួយគ្នាយូរទៅ សត្វទាំងបីកើតច្រណែនគ្នា ។ ម្នាក់ៗ បង់ឲ្យម្ចាស់របស់ខ្លួនយកទៅជាមួយ កន្ធរសួនច្បារក្តី កន្ធពេលដើរលេងក្តី កន្ធផ្ទះក្តី ឬទៅណាក្តី ។

ក្រមីត្រៃតាមការឲ្យម្ចាស់ក្បាខ្លួនជាធំគេ ដោយសារបានដួនចិញ្ចៀនមួយ ដែលជាដើមកំណើតនៃទ្រព្យធនធានទាំងអស់នោះ ។ ឆ្នាតាមការដួចក្រមីត្រៃដែរ ដោយអាងថាខ្លួនបានប្រឹមធ្យាបាយយ៉ាងបុនប្រសប់ ឲ្យស្រីទេពអប្សរធ្វើផ្លូវឲ្យខ្លួនទៅយកចិញ្ចៀននោះពីបាតដីតលាមកមកវិញ ដោយគ្មានខ្វាចគ្រោះថ្នាក់ទាំងពួងតាមផ្លូវនោះសោះ ។ ឯចំណែកខាងឆ្កែវិញពោលថា: "ការណ៍ដែលពិឃាតចោរ ហើយធ្វើឲ្យកូនចោរតក់ខ្លាតខ្លួយជាការណ៍ឥតប្រយោជន៍ទេឬ? ខ្ញុំមិនមែនការពារត្រឹមតែទ្រព្យសម្បត្តិរបស់ចៅហ្វាយខ្ញុំទេ ខ្ញុំការពារដល់ទៅជីវិតរបស់លោកទៀត, ហេតុដូច្នេះ មានតែខ្ញុំមួយទេ ដែលលោកត្រូវបីបាច់ក្បាជាធំគេទាំងអស់" ។ ការណ៍ដែលប្រកែកប្រណាំងនេះ ចេះតែមានធំរឿងទៅ ។ គ្មានស្រាកស្រាន្តសោះ, ឯសត្វទាំងបី គ្មានអ្នកណាមួយព្រមចុះចាញ់អ្នកណាមួយសោះ ។ ដល់ក្រោយមក ទាំងអស់គ្នាក៏ព្រមព្រៀងគ្នាទៅប្តឹងដល់ព្រះនាងខត្តិយានីធូដាម្ចាសារី "Thoudamna Sâri" ។ ព្រះនាងអង្គនេះ គង់នៅក្នុងស្រុកម៉ាដារី (Madari) ជាមួយនឹងពុករបស់ព្រះនាង នៅក្នុងប្រាសាទមួយយ៉ាងស្អាតស្តុកស្តម្ភ ដែលមានសសរមួយធំនៅចំកណ្តាលដូចប្រាសាទទាំងពួង ដែលគេតែងឲ្យកថ្វាយបុត្រីស្តេចដែរ ។

ព្រះនាងចេះចាំនូវច្បាប់ទាំង ១០ របស់អគ្គក្សត្រិយ៍ ទឹងសីលទាំង
ប្រាំក្នុងគម្ពីរ : ឯច្បាប់ដ្ឋប្បវេណី ច្បាប់ទ្រកិដ្ឋ សៀវភៅបរមត្ថវិជ្ជា
សៀវភៅចរិយាសាស្ត្រ មិនកំប្លាំងពីព្រះនាងឡើយ ។ សន្តិចរិយារបស់
ព្រះនាងឮល្បីសុះសាយគ្រប់ដំបន់ ហើយអ្នកចេះដឹងគ្រប់ជាតិនៅនាំ
លោកនេះតែងនាំគ្នាមករកព្រះនាងគ្រប់ៗគ្នា នៅសាលាដំបូងរបស់ព្រះ
នាង ដើម្បីចង់ដឹងបញ្ហា ដែលចេញហូរភ្លាមៗពីមាត់ព្រះនាង ។

ឯសត្វទាំងបីនោះ ទៅរកព្រះនាងនេះ សូមឲ្យព្រះនាងកាត់
សេចក្តីឲ្យ ។ ក្នុងពេលនោះ ត្រកូវព្រៃនិយាយមុនគេថា : "ចៅហ្វាយ
ខ្ញុំបាទបានទិញខ្ញុំបាទអំពីមនុស្សកំពេលម្នាក់ ថ្ងៃមួយរយណែន; រួច
មាតារបស់ចៅហ្វាយខ្ញុំបាទនេះ បានបីបាច់ចិញ្ចឹមខ្ញុំបាទយ៉ាងហ្មត់ចត់ រួច
លោកបានលែងឲ្យខ្ញុំបាទរួចខ្លួនទៅនៅក្នុងព្រៃផង; ដោយអំពើគុណ
នេះ ខ្ញុំបាទមិនភ្លេចគុណលោកទេ ខ្ញុំបាទបានយកចិញ្ចៀនមួយមកសង
គុណលោក, ដោយសារចិញ្ចៀននេះ ក្នុងពេលភក្តីស្លាប់ លោកបាន
បង្កើតប្រាសាទមួយយ៉ាងល្អឆើតឆាយនៅមុខផ្ទះរបស់លោក រួចបាននៅ
នៅយ៉ាងសុខសប្បាយជាមួយបុត្រីព្រះមហាក្សត្រិយ៍ ដែលលោកបាន
រៀបអាពាហ៍ពិពាហ៍ជាមួយគ្នាយ៉ាងឧឡារិក, អាស្រ័យហេតុនេះ មាន
តែខ្ញុំមួយទេ ដែលចៅហ្វាយខ្ញុំបាទ ត្រូវបីបាច់ជាងគេទាំងអស់" ។ រួច
ដល់វេនឆ្មា ។ ឆ្មាអធិប្បាយយ៉ាងវែងឆ្ងាយជំពាក់ព្រះនាងខត្តិយានី ដែល

ប្រុងស្តាប់យ៉ាងម៉ាមួនអំពីរឿងព្រាហ្មណ៍កំណាច ទឹងដំរៃយ៉ាងប៉ុនប្រៈ
សប់ដែលអ្នកបានប្រើកន្លងពេលនោះ លុះត្រាតែយកចិញ្ចៀនបានមកវិញ។
កន្លងទៅបំផុតន្ទាដំណាលថា "បើសិនណាជាខ្ញុំមិនបានលួចកងកបស់ស្រីទេព-
អប្សរទេ ទ្រព្យសម្បត្តិរបស់ម្ចាស់ខ្ញុំបាទមុខជារលាយសូន្យអស់ពុំខាន"។
លុះមកដល់វេនឆ្កែវិញ ឆ្កែដើរទៅមុខដោយឥតតក់ស្លុត ហើយនិយាយ
ថា: "សូមព្រះនាងជាបង! មានតែខ្ញុំទេដែលមានគុណជាងគេ, ក្រោល
ដែលចោរចូលមកលួចចិញ្ចៀនរបស់ចៅហ្វាយខ្ញុំបាទ ខ្ញុំបាទលោតទៅខាំ
បំពង់កមេចោរ ដែលទទួលមរណភាពភ្លាមៗនៅមួយកន្លែង, ឯពួក
កូនចោរកិតក័យរត់ខ្ចាត់ខ្ចាយទាំងអស់, ហេតុដូច្នោះ ខ្ញុំបាទជួយមិនត្រឹម
តែទ្រព្យសម្បត្តិរបស់ចៅហ្វាយខ្ញុំបាទទេ ខ្ញុំជួយទាំងជីវិតរបស់លោកថែម
ទៀត, ឯទ្រព្យសម្បត្តិអស់នេះ មានប្រយោជន៍អ្វី បើសិនណាជីវិត
រលត់ផុតបាត់ទៅនោះ"។

ការប្តឹងផ្តល់កំផុតប៉ុណ្ណោះ, ព្រះនាងទត្តិយានីយកដៃប្រត់ថ្ងាសដ៏
ល្អឆើតឆាយរបស់ព្រះនាង។ ព្រះនាងគិតយ៉ាងយូរ នេះជាធម្មតា
របស់ព្រះនាង ក្រោលណាមានការលំបាកយ៉ាងដូច្នេះ។ រួចព្រះនាង
ចេញវាចាយ៉ាងទន់ភ្លន់ថា: "ឆ្កែបានជួយជីវិតរបស់ម្ចាស់គេ ដោយបាន
សម្លាប់ពួកចោរកំណាច, ហេតុដូច្នោះ ឆ្កែត្រូវតែបានកន្លែងលេខមួយ,
ប៉ុន្តែខ្ញុំសូមនុកាសយ៉ាងខ្លីខ្លះនៅចំពោះមុខអ្នកទាំងអស់គ្នាថា· ការកាត់

សេចក្តីនេះ គ្មានបន្ទុយបន្ទោកមិត្តរបស់ឆ្កែចាំង ២ ទៀតទេ ព្រោះអ្នកណាក៏មានចិត្តកតញ្ញូដល់ចៅហ្វាយរបស់ខ្លួនដែរ" ។

ឯរឿងដែលលោកគ្រូអាចារ្យនិទានឲ្យសិស្សចាំងបួននាក់ស្តាប់នោះចប់តែប៉ុណ្ណោះ ។ រួចហើយសិស្សចាំងបួននោះចេញចាកពីសាលាទៅកាន់វដ្តសង្សារយើងនេះវិញ។ ខ្ញុំទៅ ។

រឿងនេះជាដំបូន្មានមួយយ៉ាងប្រពៃ ដែលបង្ហាញឲ្យយើញថា មនុស្សយើង ដោយធម្មជាតិនឹងដោយបញ្ញា ជាអ្នកមានហានៈខ្ពង់ខ្ពស់ជាងសត្វ ។ ប៉ុន្តែអំពើដែលយើងប្រព្រឹត្តទៅនឹងសត្វនោះ មិនមែនដូចប្រទេះនឹងសេចក្តីល្អើសគុណទេ ហើយជាការណីយកិច្ចមួយយ៉ាងវិសេសរបស់មនុស្ស ឲ្យរក្សាសត្វដោយមុទុតា និងដោយមេត្តា ។

ចប់

ខ្មែរបន្ទោកខ្មែរ

ការពេញចិត្តប្រើអក្សរនិងភាសានៃបរជាតិឈ្មោះថាបង្អាប់អក្សរនិងភាសារបស់ខ្លួនឯង ទាំងជាហេតុឲ្យបរជាតិមានឥស្សរភាពលើប្រទេសខ្លួនឯង, ឯគួរឲ្យខ្មាសជាតិគេអ្វីម្ល៉េះ ! ។

យ. អ.

កណ្ឌទី ៨

អ្នកឧកញ៉ាវិបុលរាជសេនា ខ្ជូ កន ប្រែរៀបរៀង

(ត ទ ៣)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធំងបេះខបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

លីឈុយ គុយតឺ តបថា មហាឧបាសិកាប្រពឹត្តបទកំហុស ឯងក៏ចុះទោសប្រហារជីវិតទៅហើយ តែយើងទាំង ៤ នាក់មានសំបុត្រមកអង្វរលន់តួខ្លួនសុំចូលធ្វើការជាមួយវិញ ហេតុអ្វីខ្លួនមិនត្រមលើកទោសសន្ដោសប្រណី ត្រឡប់មានសេចក្ដីព្យាបាទឲ្យចាប់យើងសម្លាប់ទៀត តើយើងខុសព្រោះហេតុអ្វី ? ។ អង្គអ៊ុនស្រែកគំហកថា ដែលអញមិនទទួលយកឯងទាំង ៤ នាក់ចុកធ្លើកជការផងនោះ ព្រោះឯងជាបក្សពួកអាក្បត់ផែនដី អញស្រែងឯងធ្វើបំភ្លាត់ឲ្យអន្តរាយផែនដីទៀត ឥឡូវឯងច្រើបាច់ធ្វើអ្វីក៏ធ្វើទាល់ទៅចុះ អញមិនមែនខ្លាចស្លាប់ទេ ។ លីឈុយ

គុយតីខឹងខ្លាំងណាស់ក៏ហូតគ្រឿកាប់អង្អឹនស្លាប់ ហើយឲ្យតាហានទៅចាប់តរៃយាបុត្រញាតិសន្តានសម្លាប់អស់ទៅទៀត។ ឯអាណាប្រជានុករស្តុកក្នុងស្រុកក្រុងវេលានោះ លុះដឹងថាអង្អឹនស្លាប់ហើយ ទើបនាំគ្នាទួញយំដំណាក ដោយសារអាល័យស្រឡាញ់អង្អឹនពន់ប្រមាណណាស់ ។

លីឈុយ គុយតី គិតគ្នាថា យើងធ្វើការចូលមកដល់ទីនេះហើយ ទឹងលះបង់ទៅវិញមិនបានទេ ត្រូវតែគិតយកការជសម្បត្តិហើយសម្លាប់ព្រះចៅហៀនតេចេញទើបស្រួល ។ តៃវេច ហួនតៃវេយាត់ថា លោកទឹងធ្វើឲ្យចលាចលដល់ព្រះចៅហៀនតេនោះ យើងមិនបានយល់ព្រមផងទេ ព្រោះចៅហ្វាយខែត្រ។ ក្រែទាំងអស់ទឹងអាណាប្រជានុករស្តុកមិនមែនចូលចិត្តទឹងឲ្យធ្វើដូច្នេះឡើយ បើយើងធ្វើហើយគង់ទឹងលើកកងទ័ពពីគ្រប់តំបន់ ចូលមកតតាំងច្បាំងទឹងយើងយ៉ាងអធិកអធមមិនខាន យើងមុខជាទឹងរកទីបង្អែកទប់ទល់ពុំបាន បើដូច្នេះត្រូវតែយើងបបួលគ្នាចូលទៅគាបសំពះគាល់ព្រះចៅហៀនតេ ទូលសុំធ្វើរាជការជានាហ្នឹងធំក្នុងក្រុង ទឹងបានគិតកែបព្រះតម្រាស់ឲ្យហៅចៅហ្វាយខែត្រចូលមក ហើយកាប់សម្លាប់ចេញ រាជសម្បត្តិគង់ទឹងបានមកយើងដោយងាយ ។ លីឈុយ គុយតីលុះបានស្តាប់ហើយឃើញថាត្រូវ ទើបនាំតៃវេច ហួនតៃវចូលទៅគាល់ ។

ព្រះចៅហៀនតេទ្រង់ត្រាស់សួរលីឈុយ គុយតីថា ពីថ្ងៃមុនខ្លួនច្បាប់យើងថាទឹងសុំយកខ្លួនអង្អឹន បើបានហើយទឹងត្រឡប់លើកទ័ពទៅ

វិញ ឥឡូវខ្ញុំនសម្រាប់អង្គភ្លុនបានហើយ ហេតុម្តេចមិញ្ញើមិនលើកទ័ព
ចេញទៅ ឯងចង់នៅធ្វើអ្វីទៀត? ។ លីឈុយ គុយតី ក្រាបទូល
ថា កាលពីថ្ងៃមុនទូលព្រះបង្គំជាខ្ញុំបានធ្វើពាជការមានបំណាច់ទ្បើយហាត់
ក្នុងដែនដីព្រះករុណា តែមិនមាននរណានឹងពិតទូលព្រះអង្គឲ្យច្បាស់ជាប
ទើបព្រះអង្គមិនប្រទានយសស័ក្តិដល់យើងខ្ញុំ ឥឡូវនេះ យើងខ្ញុំទាំង ៤
នាក់ សូមចូលមកស្វាមីភក្តិ ធ្វើពាជការជានាហ្មឹនក្រោមល្អងធូលីព្រះបាទ,
បើព្រះអង្គច្បាស់ព្រះពាជានុញ្ញាតច្រៀសព្រះពាជទានតាមច្បាប់ហើយ ទូល
ព្រះបង្គំជាខ្ញុំនឹងលើកទាហានចេញពីព្រះពាជវាំងទៅវិញ ។

ព្រះចៅហៀនតេមានព្រះពាជឫទ្ធារត្រាស់ថា ដែលខ្ញុំនទាំង ៤ នាក់
ចូលចិត្តចង់ធ្វើនាហ្មឹននោះ តើចង់ធ្វើតំណែងអ្វីឲ្យថាមកចុះ ។ លីឈុយ
គុយតី តៀវចេ ហួនតៀវប្រឹក្សាគ្នាហើយ ទើបសរសេរជាសំបុត្រថ្វាយ
ព្រះចៅហៀនតេ។ គេឃើញសេចក្តីសំបុត្រនោះថា លីឈុយសុំជាទី
"គីបុងគុន" គឺសុំជានាយទាហានធំខាងក្នុង ហើយជាអ្នកសម្រេចពាជការ
ផង, គុយតីសុំជាទី "ហបុងគុន" គឺជានាយទាហានធំខាងក្រោយហើយ
ជាទីពាងហ្វាងនាហ្មឹនទាំងភួងផង, តៀវចេនឹងហួនតៀវជានាយទាហាន
ឆ្វេងស្តាំ ។ ព្រះចៅហៀនតេក៏ទ្រង់ច្រេសប្រទានតាមសុំ ។ ឯលីឈុយ
គុយតី លុះបានទទួលព្រះពាជតម្រាស់ហើយ ក៏ចេញមកនៅក្រៅព្រះ
ពាជវាំង ទើបប្រឹក្សាគ្នាថា "ស្រុកហាងឡុងនោះ ជាស្រុកមុខគយនឹងទុក

ចិត្តដល់ពួកសត្រូវមិនបាន" ទើបចាត់ឲ្យគៀវចេនឆីហួនគៀវលើកទាហាន
ទៅទៅរក្សា ។ ឯលីបង់ទឹងអង់ហង់ដែលបើកទ្វារស្រុកឲ្យកងទ័ពចូល
ទៅនោះ ក៏តាំងឲ្យឡើងធ្វើជានាហ្មឺនមានតំណែងក្នុងរាជការ ; បណ្តា
ទាហានដែលមានសតិប្បញ្ញា ក៏តាំងឡើងជានាហ្មឺនទាំងអស់ ហើយឲ្យ
ទាហានទៅស៊ើបពិនិត្យរើសយកឆ្នើងតាំងតុ: មកតែងការសពរបៀបមហា-
ឧបរាជ ហើយឲ្យហៅចេញទៅនឹងកប់សពទុកតាមទំនៀម ។ កងខណៈ
កំពុងរៀបចញ្ចុះសពនោះ ក៏បណ្តាលឲ្យកើតខ្យល់ព្យុះសង្ឃរាជាខ្លាំង
ណាស់ កើតជាផ្គររន្ទះភ្លៀងធ្លាក់ទឹកដោរដន់លិចផែនដី ជំរៅប្រហែល
២ ហ័ត្ថ ហើយថែមមានទាំងរន្ទះបាញ់ច្រសៅលើសព ឯឆ្នើងដែលកប់ខ្ពុត
ខ្ពាត់ចេញអស់, លុះភ្លៀងស្ងប់ហើយ លីឈុយឲ្យរើសប្រមូលឆ្នើងមក
បញ្ចុះទៀត ភ្លៀងរន្ទះក៏បាញ់ច្រសខ្ពាត់ខ្ពាយឆ្នើងអស់ទៅទៀត លីឈុយ
ក៏ឲ្យរើសមកបញ្ចុះទៀតជាច្រើនគ្រា ភ្លៀងក៏បង្អុរចុះមកលិចផែនដី
អស់នឹរន្ទះក៏បាញ់ច្រសឆ្នើងតាំងតុ:នោះពាល់តែខ្លះខ្លីជាធូលីអស់ទៅ ទើ
រើសយកមកទៀតពុំបាន. ។ ដែលកើតហេតុទាំងនេះ ព្រោះតាំងតុ:ធ្វើ
ការអាក្រក់ក្បត់ផែនដី សម្លាប់មនុស្សច្រើនទើសជាច្រើនណាស់ ។
លីឈុយ គុយគី អស់តំរិះច្បាស់ត្រឡប់ចូលទៅក្រុងវិញ ។ តាំងពីនោះ
តមក លីឈុយ គុយគី រឹតតែធ្វើការកំរើតតាមអំពើចិត្ត អាណាប្រជា-
ទុក្ខស្លុកក៏បានសេចក្តីក្តៅក្រហាយខ្លាំង ។ លីឈុយ គុយគី យកមាំស

ក្រាក់ទៅសូកចិត្តខន្ធីដែលរក្សាព្រះចៅហៀនតេហើយផ្តាំថា បើឮព្រះចៅហៀនតេត្រាស់ពីសេចក្តីល្អអាក្រក់ប្រការម្តេច សុំឲ្យនាំសេចក្តីនោះទៅក្រាបទូលឲ្យដឹងផង ។

កុងសម័យនោះ ព្រះចៅហៀនតេទៅជាព្រះកុមារណាស់ ទើបត្រាស់បង្គាប់ការអ្វីជាផ្លូវពាជការក៏តុំស្រែចជាច់ខាត, ពាជការផែនដីក៏ត្រឡប់ត្រឡិនភ័ន្តប្រែទៅ, បណ្តានាហ្មឺនមុខមន្ត្រីក្នុងក្រុង ក៏សឹងនៅក្រោមបង្គាប់បញ្ជាលីឈុយគុយគីទាំងអស់ ។ ឯលីឈុយគុយគីក៏ឲ្យរកផ្លូវដែលជានាហ្មឺនក្រៅពាជការនោះ មកតាំងជានាហ្មឺនក្នុងពាជការជាទីប្រឹក្សាវិញ ។

ចំណែកម៉ាថេងចៅហ្វាយស្រុកសេលៀង ទើងហាន់ស៊ុយចៅហ្វាយស្រុកប៉េងដីវប្រឹក្សាគ្នាថា "ឥឡូវនេះ លីឈុយ ទើងគុយគីបានជានាហ្មឺនធំក្នុងស្រុកក្រុង ធ្វើការខុសច្បាប់ប្រព្រឹត្តអាក្រក់ដូចគ្រាតាំងតុ: បើដូច្នោះចាំយើងទើងកំចាត់វាចេញ ទើបទើងបានសេចក្តីសុខក្នុងស្រុកទេសតទៅ" គិតហើយក៏ធ្វើសំបុត្រ ១ ច្បាប់ទៅដល់ម៉ាហ៊ូ, ១ ច្បាប់ទៅដល់តុងសៀវ, ១ ច្បាប់ទៅដល់ឡៅឈៀវ, អ្នកទាំង ៣ នេះជានាហ្មឺនខ្ពើរពាជការចាស់នៅក្នុងក្រុង ។ សេចក្តីសំបុត្រនោះថា "លីឈុយគុយគីធ្វើការខុសច្បាប់ប្រព្រឹត្តអាក្រក់ សត្វមាសអាណាប្រជានុកស្តេចត្រេកត្អើលក្រហាយដូចគ្រាតាំងតុ: បើដូច្នេះ សុំឲ្យយកសេចក្តីក្រាបបង្គំទូលព្រះចៅ

ហៀនតេឲ្យទ្រង់ជ្រាបថា យើងនឹងលើកកងទ័ពមកព័ទ្ធចាប់លីឈុយគុយតីសម្លាប់ចេញ ឯអ្នកទាំង៣ក៏ត្រូវនៅគិតការខាងក្នុងឲ្យមាំមួនចុះ" ។

ឯម៉ាហ្គី តុងសៀវ ឡៅឈៀ លុះបានដឹងសេចក្តីក្នុងសំបុត្រនោះហើយ ទើបចូលទៅក្រាបបង្គំទូលព្រះចៅហៀនតេ។ ទ្រង់មានព្រះរាជហ្ឫទ័យសោមនស្សណាស់ ទ្រង់ត្រាស់ឲ្យយកក្រដាសទឹកឡៅមកទ្រង់ព្រះសុភអក្សរជាសេចក្តីថា "ដែលម៉ាថេងនឹងហាន់ស៊ុយគិតការដូច្នោះ យើងត្រេកអរណាស់ បើបានសម្រេចដូចសេចក្តីប្រាថ្នាហើយ យើងនឹងតាំងឲ្យធ្វើជានាហ្មឺនធំតទៅ" ស្រេចហើយក៏ប្រគល់ឲ្យបំរើម៉ាថេងហាន់ស៊ុយកាន់ត្រឡប់មកវិញ ។

ម៉ាថេង ហាន់ស៊ុយ ទទួលសុភមក្សរលាមើលឃើញព្រះហត្ថលេខាក៏មានសេចក្តីត្រេកអរណាស់ ទើបរៀបចាត់ថែងកេណ្ឌទាហានទាំង ២ ខែត្រចាប្រវែល ១១ - ១២ ម៉ឺន លើកទៅដល់កណ្តាលផ្លូវហើយឲ្យទាហានស្រែកប្រកាសប្រាប់បណ្តាពួកស្តេតប់ភូមិស្រុកថា យើងលើកទ័ពមកនេះ ដើម្បីនឹងធ្វើការកំចាត់សត្រូវរាជសម្បត្តិចេញ ។

បំរើសេះបានឮច្បាស់ ក៏នាំសេចក្តីនោះទៅប្រាប់គុយតី។ ឲ្យរកតៀវចេហួនតៀវមកប្រឹក្សាថា ម៉ាថេង ហាន់ស៊ុយលើកទ័ពមកនេះយើងនឹងគិតប្រការណា ។ ការសឹងទីប្រឹក្សាតបថា .ម៉ាថេងហាន់ស៊ុយលើកទ័ពមកនេះអស់រយៈផ្លូវឆ្ងាយជាច់ស្រយាលណាស់ យើងត្រូវកូនាទី

ទុកឲ្យគេលើកខ្លាមព័ទ្ធដល់ដើងកំពែងចុះ បើកាលណាខាងគេជាប់ស្បៀងអាហារហើយ សឹមយើងលើកទាហានចេញទៅវាយទំលាយកងទ័ព យើងនឹងចាប់ម៉ាថេងនឹងហាន់ស៊ុយបានដោយងាយ ។ លីបងនឹងអង់ហង់ធ្វើយថា ដែលកាសៀងថានោះខ្ញុំមិនយល់ផងសោះ ខ្ញុំសុំទាហានមួយម៉ឺនលើកទៅចាប់ម៉ាថេងនឹងហាន់ស៊ុយ កាត់យកក្បាលជូនលោកឲ្យបាន ។ កាសៀងតបថា នឹងឲ្យលីបងអង់ហង់លើកទ័ពទៅនោះ មុខជានឹងចាញ់ប្រៀបគេជាក្រុកជ ។ លីបងអង់ហង់ធ្វើយថា បើយើងចេញទៅហើយមិនបានក្បាលម៉ាថេងនឹងហាន់ស៊ុយមកជូនទេ អ្នកចូរកាត់ក្បាលយើងជាចំនួសចុះ បើយើងបានក្បាលនាយទ័ពទាំងពីរចូលមកអ្នកចូលកាត់ក្បាលអ្នកឲ្យយើងវិញ ។

កាសៀងជំរាបទៅលីឈុយនឹងគុយតីថា បើលីបងនឹងអង់ហង់សុំយកអាសាចេញទៅច្បាំងក៏ឲ្យទៅចុះ តែកុំឲ្យវិលត្រលប់នោះ ចម្ងាយផ្លូវពីស្រុកក្រុងនេះប្រហែល ២០០០ សិន ពីខាងលិចមានតែផ្លូវបំពោះដើរតាមច្រកភ្នំចង្អៀតណាស់ បើដូច្នេះសុំឲ្យតៀវចេនឹងហួនតៀវលើកទាហានទៅបង្កប់នៅជំបន់នោះឲ្យច្រើន បើកាលណាលីបងនឹងអង់ហង់ចាញ់ប្រៀបគេចយមកប្រការម្តេចក៏នឹងបានជួយគ្នា ។

លីឈុយ គុយតីធ្វើយថា "ដែលនឹងឲ្យតៀវចេហួនតៀវលើកទាហានទៅតាំងនៅច្រកភ្នំនោះយើងមិនយល់ត្រមផងទេ," ហើយប្រ-

គល់ឥហានមួយម៉ឺនច្រាំពាន់ឲ្យលីបង់នឹងអង់ហង់ លើកចេញទៅតាមផ្លូវប្រវែង ២០០ សិន (៨០ គ.ម.) ទទួលដួបកង់ឥតម៉ាថេង់នឹងហាន់ស៊ុយលើកមកច្រលំគ្នានៅទីនោះ ។ លុះព្រឹកឡើងនាយឥតពាំងសង់ខាង់បញ្ជូញឥហានមកខាង់ក្រៅបន្ទាយ, ម៉ាថេង់នឹងហាន់ស៊ុយស្រែកថា អាលីបង់ អាអង់ហង់ ជាសត្រូវពុសមប្បត្តិ នរណានឹងទទួលអាសាចេញទៅចាប់ឥឲ្យយើង់បាន ។ ម៉ាឈៀវជាកូនម៉ាថេង់អាយុ ១៨ ឆ្នាំ សម្បុរមុខដូចពណ៌ថ្នុក កិរិយារហ័សរហួនកាន់ខ្លួនដ៏រសែបំពោរឥហានចេញទៅទទួលយកអាសា ។ អង់ហង់ឃើញម៉ាឈៀវនៅក្មេង់ណាស់ ក៏មើលងាយមិនសូវប្រយ័ត្ន ឡើង់សេះពាំជាវចេញមកតយុទ្ធនឹងម៉ាឈៀវបាន ៥ ស្នៀត, ម៉ាឈៀវយកខ្លួនចាក់អង់ហង់ធ្លាក់ពីលើសេះស្ទាប់ហើយម៉ាឈៀវក៏ត្រាក់សេះប្រង់នឹងត្រឡប់មកវិញ, លីបង់ខឹង់ណាស់ក៏បរសេះពាំជាវដេញកាប់ម៉ាឈៀវពីក្រោយ, ម៉ាឈៀវក្រឡេកមើលឆ្វេដាមិនឃើញ, ម៉ាថេង់ស្រែកច្រាប់ម៉ាឈៀវថា "សត្រូវតាមពីក្រោយមកជិតហើយឲ្យប្រយ័ត្ន" លីបង់ដេញជិតជិតនឹង៉ាន់យកដាវកាប់ម៉ាឈៀវ។ រង់ជាប់ត្រឡប់ញាក់សេះបែរទៅវិញ លោតចាប់លីបង់បាន ក៏នាំមកដួនម៉ាថេង់ជាបិតា បណ្តាឥហានម៉ាថេង់ពាំង់ប៉ុន្មានបានចំណាប់ក៏ព្រួតគ្នាដេញកាប់ឥហានលីបង់ស្ទាប់ជារច្រើន ។ ម៉ាថេង់នឹងហាន់ស៊ុយ ក៏លើកឥហានចូលទៅតាំង៉បន្ទាយនៅជិតកំពែង៉ស្រុក

តៀងហាន់ ហើយឲ្យយកលិបង៉ៅសម្លាប់កាត់ក្បាលដោតទុកនៅមុខបន្ទាយ ។

មានបំរើសេះចូលទៅប្រាប់លីឈុយ គុយគីថា លិបង៉ិនឹងអង់ហង់ បាដំយក្ស័យតាំង ២ នាក់ទៅហើយ ។ លីឈុយគុយគីប្រឹក្សាគ្នាថា ការសៀងថានោះត្រូវណាស់ យើងមិនធ្វើតាមពាក្យគាត់បានជាខូចខាតមាហានអស់ទៅដូច្នេះ ។ តាំងពីនោះមក លីឈុយគុយគីក៏សរសើរដឿស្រឡាញ់ការសៀងទុកជាទីប្រឹក្សា ហើយឲ្យចាត់ចែងចែងមាហានកបន្ទាយរាយរបាំងតាំងជីតគួលើកកំពែងយ៉ាងមាំមួន រួចកេណ្ឌមាហានឲ្យឡើងលើសែនក្រវែនចាំគយល្បាតប្រយ័ត្នការគ្រែបន្ទាយ ។

ឯម៉ាថេងនឹងហាន់ស៊ុយលើកមាហានទៅសន្ធប់ ផ្ទាប់ដើងកំពែងស្រុកដុំបរិវេណប្រហែល ២ វ៉ែ ។ ឯមាហានក្នុងកងទ័ពនោះក៏ជាប់ស្បៀងអាហារជាយូរថ្ងៃ មានសេចក្តីស្រេកឃ្លានពន់ប្រមាណណាស់ ។ ម៉ាថេងនឹងហាន់ស៊ុយ ឃើញមាហានរបស់ខ្លួនជាប់ស្បៀងអាហារដូច្នោះក៏ប្រឹក្សាគ្នានឹងឲ្យលើកកងទ័ពត្រឡប់ទៅវិញ នៅកំពុងជជែកគ្នា ។

ខណៈនោះមានបំរើស្និទ្ធរបស់ម៉ាហ៊ូ លបនាំពត៌មានទៅប្រាប់លីឈុយគុយគីថា ម៉ាហ៊ូជានាយខ្ញុំបានគប់គិតនឹងតុងសៀវឡៃឈៀខ្លួនធ្វើជាកលសឹក ទើបម៉ាថេងលើកពលមកធ្វើសង្គ្រាម ។ លីឈុយគុយគីឮដូច្នោះខឹងណាស់ ទើបឲ្យមាហានទៅចាប់មាហ៊ូ, តុងសៀវនឹង

ឡើងឈើ ហើយនឹងកវិយាបុត្រញាតិសន្តាន បានហើយឲ្យនាំយកទៅ
សម្លាប់ចាំងអស់ កាត់ក្បាលមេចាំង ៣ នាក់ដោតផ្លាលខុកនៅមុខ សែន
ឲ្យសត្រូវក្រែះឡកឃើញ ។ ម៉ាថេងនឹងហាន់ស៊ុយឃើញដូច្នោះក៏ប្រឹក្សា
គ្នាថា "កលសឹកក្នុងស្រុកក្រុងវៃកខ្លាត់ខ្លួយហើយ គាហានក្នុង
កងខ្លាំងក៏ជាច់ស្បៀងអាហារទៀត បើនឹងឡោមព័ទ្ធក្រុងខុកដូច្នេះ មុខ
ជានឹងខូចខាតគាហានច្រើនណាស់" លុះប្រឹក្សាព្រមព្រៀងគ្នាហើយ
ទើបលើកទ័ពត្រឡប់ទៅវិញ ។

លីឈុយ គុយគីឃើញដូច្នោះ ទើបឲ្យតៀវចេលើកគាហានទៅ
តាមម៉ាថេង ១ កង ឲ្យហួនតៀវលើកគាហានទៅតាមហាន់ស៊ុយ ១ កង
លុះទៅដល់កុំគាន់ឆង ហាន់ស៊ុយក្រឡេកមកឃើញហួនតៀវក៏ស្រែកថា
អ្នកនឹងយើងជាមនុស្សនៅស្រុកជាមួយគ្នាមកពីតូច ហេតុម្តេចក៏ក្លេច
សេចក្តីមេត្រីសោះ ត្រឡប់ជាមកធ្វើអន្តរាយដល់យើង ។ ហួនតៀវ
តបថា សព្វថ្ងៃនេះ ពួកការក្នុងស្រុកក្រុងជាកម្មសិទ្ធិលើលីឈុយគុយគី
បានប្រើយើងលើកគាហានមកតាមអ្នកគ្រានេះ ប្រយោជន៍នឹងប្រហារ
ជីវិតអ្នក ដែលយើងនឹងយល់មុខអ្នកជាអ្វីនោះមិនបានទេ ។ ហាន់ស៊ុយ
តបថា យើងលើកគាហានមកធ្វើសង្គ្រាមគ្រានេះ ក៏ព្រោះតែនឹងជួយ
ខំខុកបំរុងដែនដីឲ្យបានសេចក្តីសុខ បើអ្នកមិនគិតដល់យើងក៏វាហើទៅចុះ
តែត្រូវគិតដល់ព្រះហៅហៀនតជាម្ចាស់ដែនដី ព្រោះអ្នកជាមន្ត្រីស្តេច

ដូចគ្នា ។ ហ្លួនតៀវបានឮហាន់ស៊ុយនិយាយដូច្នោះ ក៏នឹកឃើញសេចក្តី
កតញ្ញូខ្លឹង ក្នុងចិត្តនឹកអាណិតហាន់ស៊ុយ ទើបឲ្យទាហានបង្អង់ឈប់
នៅទីនោះ; ឯហាន់ស៊ុយក៏ស្រែតលើកទាហានទៅស្រុកបេង៉ដរ ។

ឯតៀវចេដែលលើកទាហានទៅតាមម៉ាថេង៉នោះ លុះមិនទាន់ហើយ
ក៏ត្រឡប់ទាហានមកតាំងនៅជាមួយនឹងហ្លួនតៀវ ។ ឯលីចៀតដែល
ជាកូយលីឈុយនៅជាមួយនឹងកងទ័ពហ្លួនតៀវ លុះឃើញហ្លួនតៀវមិន
ចាប់ហាន់ស៊ុយដូច្នោះ ក៏នាំយកសេចក្តីនោះចូលទៅថ្វាយលីឈុយ
ជាមា ។ លីឈុយឮហើយក៏នឹកខឹងណាស់ គិតនឹងប្រើទាហាន
ឲ្យទៅចាប់ហ្លួនតៀវ ។ កាសៀងដឹងដូច្នោះ ក៏ឃាត់លីឈុយថា
ឥឡូវស្រុកទេសកំពុងរឹតវេចលាចល ដែលនឹងប្រើកលទៅចាប់ហ្លួន
តៀវនោះ ឃើញថាហ្លួនតៀវមិនមែនព្រមឲ្យចាប់ដោយងាយទេ មុខ
ជានឹងកើតសឹកសាមសង្គ្រាមដ៏យូរនឹងគ្មានមិនខាន, សុំឲ្យចាត់មនុស្សចេញ
ទៅថ្វាយហ្លួនតៀវ តៀវចេដោយល្អវិញថា ដែលលើកទៅតាមម៉ាថេង
ហាន់ស៊ុយមិនទាន់នោះក៏ពហើទៅចុះ ឥឡូវត្រូវយើងរៀបលៀងអាហារ
អញ្ជើញនាហ្មឺនចាំងអស់មកបរិភោគជាសប្បាយ ហើយឲ្យចំរើទៅហៅ
ហ្លួនតៀវតៀវចេចូលមកបរិភោគអាហារជាមួយ កាលបើចូលមកហើយ
សឹមយើងឲ្យចាប់ហ្លួនតៀវសម្លាប់ចេញ កាលបើធ្វើដូច្នោះទើបមិនមាន
ភ្ញាក់ផ្អើលច្រួលច្របល់ ។ លីឈុយបានស្តាប់យល់ឃើញថាស្រួល

ហើយក៏រៀបចំអាហារគោជនចាត់មនុស្សឲ្យចេញទៅហៅហួនតៀវ ទើង តៀវចេចូលមកបរិភោគអាហារ ។ ឯហួនតៀវនឹងតៀវចេមិនបានដឹងគលនុបាយសោះ ក៏លើកពាហានត្រឡប់ចូលមកកាន់ក្រុងវិញ ហើយចូលទៅបរិភោគអាហារជាមួយនឹងលីឈុយគុយគី ។ កាលកំពុងផឹកស្រាលីឈុយនិយាយនឹងហួនតៀវថា យើងឲ្យលើកពាហានទៅតាមចាប់ហាន់ស៊ុយ ហេតុម្តេចខ្លួនមិនធ្វើតាមពាក្យយើងបង្គាប់ត្រឡប់ប្រែចិត្តទៅអាណិតហាន់ស៊ុយវិញ ខ្លួនទើងគិតគំនិតអាក្រក់ស្អប់យើងឬ? ។ ហួនតៀវឮដូច្នោះ ភ័យណាស់មិនដាន់ឆ្លើយថាប្រការម្តេច ពេជ្ឈឃាដស្ទុះទៅចោមចាប់ខ្លួនហួនតៀវយកទៅមួយរំពេច ហើយកាត់យកក្បាលមកជូនលីឈុយមើល ។

តៀវចេឃើញដូច្នោះ មិនដឹងជាមានហេតុអ្វី ភ័យណាស់ក៏ទុនមុខក្រាបលើតែមតុ ។ លីឈុយក៏ទៅគាប់លើកឡើងហើយថ្កាប់ថា ហួនតៀវប្រែចិត្តក្បត់យើង បែរទៅចូលគំនិតគ្នាទើងហាន់ស៊ុយគិតប្រទូសរ៉ាយយើងវិញ បានជាយើងធ្វើដូច្នេះ ឯចំណែកខ្លួនអ្នកមិនមានរឿងខុសពីអ្វីទេកុំឲ្យភ័យបារម្ភ" ថាហើយក៏ប្រគល់ពួកពលពាហានដែលហួនតៀវនាំមកនោះឲ្យទៅតៀវចេចាំងអស់ ហើយចាត់ប្រើតៀវចេឲ្យលើកពលទៅរក្សាស្រុកហាងឡុងដូចដើម ។

កន្លងសម័យនោះ មនុស្សម្នាបណ្តាដែលមាននៅក្នុងក្រុងតៀងហាន់ ក៏កាន់តែមានសេចក្តីកោតញញើតខ្លាចលើឈុយគុយគី ។ ឯការសៀងនោះក៏ចេះតែនិយាយពន្យល់ លើឈុយ គុយគី ឲ្យយកចិត្តអាណិតស្រឡាញ់នាហ្មឺននឹងពួកស្តុកក្នុងក្រុងឲ្យផុងចិត្តគិតពប់អានមកវិញ, បណ្តានាហ្មឺននឹងពួកស្តុកសឹងនៅក្រោមអំណាចលើឈុយ គុយគី ទាំងអស់ ។

គ្រានោះ មានសំបុត្រមកពីស្រុកសៀងជីវ៉ាថា មានពួកចោរជួតក្បាលលឿងប្រមាណ ៣០ ឬ ៤០ ម៉ឺន គ្រាច់ឆ្ពោះធ្វើទុក្ខបុកម្នេញអាណាប្រជានុពស្តុជាចលាចល ។ លើឈុយ គុយគី បានឃើញសំបុត្រហើយក៏ប្រកាន់ឆន្ទាហ្មឺនទាំងពួងថា ដែលកើតចោរអន្តរាយគ្រប់ខែត្រច័ណ្ឌដូច្នេះ យើងត្រូវគិតយ៉ាងណាទើបនឹងពួកមាបពួកចោរទាំងនោះបាន ។ ដូហ៊ីឆ្លើយថា ដែលកើតចោរកម្រើបជុំនៅក្នុងស្រុកសៀងជីវ៉ានោះ ខ្ញុំបាទឃើញតែចូឆូ ១ នាក់ដែលមានថ្វីដៃខ្លាំងពូកែ បើឆន្ទាតាត់ឲ្យទៅប្រាប់ប្រាមពួកអាចោរ ដែលនៅខាងទិសឯកើតនោះ មុខជានឹងបានសម្រេចដូចបំណង ។ លើឈុយ គុយគី សួរតបទៅវិញថា ចូឆូនោះសព្វថ្ងៃនៅឯណា ? ។ ដូហ៊ីឆ្លើយថា . ចូឆូនោះបានមកធ្វើទ័ពជាមួយនឹងអ្នកសៀវកាលគ្រាចម្បាំងនឹងតាំងតុ: ឥឡូវត្រឡប់ទៅនៅស្រុកបុងគុនមានសេនាពាហនជាច្រើន បើលោកត្រូវការសុំឲ្យមានសំបុត្រព្រះតម្រាស់ព្រះចៅហៀនតេចេញទៅ បង្គាប់ឲ្យចូឆូលើកកងទ័ពទៅបង្ក្រាប

ពួកអាចារក្នុងស្រុកសៀងជីវចុះ ។ លីឈុយ គុយតី យល់ឃើញថាត្រូវ
កំតែងសំបុត្រព្រះតម្រាស់ ២ ច្បាប់ ១ ច្បាប់ចុាប់ទៅចុាំសុំនចៅហ្វាយ
ស្រុកចុាក់បេង, សំបុត្រ ១ ច្បាប់ទៀតចុាប់ទៅចូឆូ ឲ្យលើកទាហានរួម
គ្នាទៅបង្ក្រាបពួកចោរក្នុងដែនស្រុកសៀងជីវ ។

ឯចុាំសុំន ដល់បានទទួលព្រះតម្រាស់ហើយ កំចាត់ចែងកេណ្ឌ
ទាហានលើកទៅរកចូឆូ។ ទទួលសំបុត្រព្រះតម្រាស់ មកមើលដឹងហើយ
មានសេចក្តីត្រេកអរណាស់ តាំងតែកេណ្ឌកងសេនាទាហានបានជាច្រើន
ហើយនាំចុាំសុំនលើកពលទៅតំបន់ស៊ីវសុំនក្នុងដែនស្រុកសៀងជីវ បាន
ជួបប្រទះពួកចោរជួតក្បាលសឿង ១ ពួកតាំងផ្តុំគ្នាជាច្រើន ចុាំសុំនសុំ
យកអាសាចេញទៅតតាំងច្បាំងនឹងពួកចោរ។ ក៏តទល់គ្នាជារបឹងរបាញ
ណាស់; ទាហានចោរលើកគ្នាចោមព័ទ្ធសម្ងាប់ចុាំសុំនស្ងាប់កងទីនោះ ។

ចូឆូឃើញចុាំសុំនស្ងាប់នឹកខឹងណាស់ លើកទាហានចូលទៅកាប់
សម្ងាប់ពួកចោរស្ងាប់ជាច្រើន ហើយដេញទាហានទន្ទ្រានចូលទៅទៀត
ដល់ស្រុកចេចុាក់ស្ពាក់ចាប់បានពួកចោរ។ ត្រឡប់ចុះចូលមូលមកនៅទីង
ចូឆូវិញប្រហែល ៤ - ៥ ម៉ឺននាក់ ហើយចូឆូឲ្យពួកចោរឈ្លើយនោះជា
កងមុខ លើកទៅសង្កត់សង្កិនពួកចោរគ្រប់តំបន់ ។ ចូឆូលើកទ័ពទៅ
បង្ក្រាប់ពួកចោរយូរប្រមាណ ២ ខែ, ពួកចោរក៏ចុះចូលមកជាស្ម័គ្រចិត្ត
ពួកចូឆូ តាំងចាស់តាំងថ្មីបានប្រហែល ៣០ ម៉ឺន ។ (មានត)

ភាគទី ២

សម័យនគរធំ

អ្នកឧកញ៉ាទេពពិទូរ ឈឹម - ក្រសែម រៀបរៀង

(ត្រង)

ព្រះចាន់យសោវរ្ម័ន បានស្តេចចេញតយុទ្ធទល់នឹងបច្ចាមិត្រពេញសមត្ថភាព, តែពុំឈ្នះ សត្រូវបានឆ្លៀតព្រះអង្គបង់ ហើយទៀងត្រង់ជាបល្ល័ង្ក ។ ឯព្រះបរមសពនៃព្រះចាន់យសោវរ្ម័ន គេមិនបានថ្វាយព្រះនាមព្រះកិត្តិយសតាមពាក្យប្រពៃណីទេ ព្រោះព្រះពាក្យថ្មីនោះជាតួសត្រូវទៅហើយ មិនត្រូវការនឹងថ្វាយកិត្តិយសដល់តួសត្រូវរបស់ខ្លួន ។

រជ្ជកាលនៃព្រះត្រីភុវនាទិត្យ = ព្រះត្រីភុវនាទិត្យនេះ គឺជាមន្ត្រីធំម្នាក់ ដែលបានក្បត់ព្រះចាន់យសោវរ្ម័ន (ទី ២) ដូចបានពោលហើយ មន្ត្រីនេះប្រហែលជាមានសមត្ថភាពគ្រាន់បើ ទើបអាចផ្តួលព្រះចាន់យសោវរ្ម័នបាន ។ កាលរំលាងបានហើយ ក៏ទៀងត្រង់ជាបល្ល័ង្ក មានព្រះនាមថា:

ព្រះចាន់ត្រីភុវនាទិត្យ

ព. ស. ១៣០៩ - ១៣២០ គ. ស. ១១៦៥ - ១១៧៧

ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេច នឹង មានព្រះរាជបុត្រព្រះរាជធីតាប៉ុន្មាន មិនច្បាស់ក្នុងប្រវត្តិសាស្ត្រនេះ ។

និយាយពីព្រះជយវ៉ុន = ឯព្រះជយវ៉ុន ដែលទ្រង់រង់ចាំឧកាសនៅក្រៅរិដ្ឋយមកជាយូរដូចមានពោលហើយ, កាលទ្រង់ជ្រាបរឿងមន្ត្រីខុរយសក្សត់ព្រះបាទយសោវ៉ុន ក៏ស្តេចមកដល់ព្រះនគរវិញ ។ ឮកងតាមសិលាចារឹកនៅប្រាសាទវិមានអាកាសថា "ស្តេចយាងមកដើម្បីជួយស្រោចស្រង់ព្រះបាទយសោវ៉ុនដែលត្រូវក្សត់" ។

ក្នុងខនេះ តាមយោបល់ ១ ថា យើងនឹងយល់ថាស្តេចមកដើម្បីស្រោចស្រង់ព្រះបាទយសោវ៉ុនមែន តាមសិលាចារឹកនោះក៏បាន ឬនឹងយល់ថា ព្រះអង្គយាងមកដើម្បីតាមឧកាសសម្បត្តិក៏បាន ព្រោះទ្រង់បានរង់ចាំឧកាសបែបនេះមកយូរហើយ, តែកាលស្តេចយាងមកដល់ព្រះនគរ ក៏ស្រាប់តែឃើញសត្រូវ គឺព្រះគ្រីកវនាទិត្យនៅលើរាជបល្ល័ង្កទៅហើយ ទ្រង់ក៏គ្មើនគាក់ព្រះហ្ឫទ័យ . . . . . តែក្នុងទីបំផុតទ្រង់ក៏បណ្តោះបណ្តែតព្រះហ្ឫទ័យថា ត្រូវតែអត់ធ្មត់ទៅសិន ចាំរកឧកាសជាថ្មីតទៅទៀត ។

ក្នុងគ្រានោះ ព្រះជយវ៉ុនបានដួបនឹងព្រះនាងជយរាជទេវី ជាព្រះអគ្គជាយានឹងព្រះរាជឧសរបស់ព្រះអង្គ ដែលទ្រង់ចាកចោលទៅយូរហើយ ។ វេលានោះព្រះនាងជយរាជទេវីបានទូលញុះញង់ព្រះរាជស្វាមីឲ្យរំលាងរាជសត្រូវចេញអំពីរាជបល្ល័ង្ក ។ ទ្រង់ទទួលថា នឹងធ្វើតាមយ៉ាងនោះ ក្នុងពេលដែលបានឧកាសស្រួល ។ អំពីនោះមកព្រះ

ជយវរ្ម័ន្ទ ទ្រង់គង់នៅក្នុងប្រទេសកម្ពុជា ជាមួយព្រះអគ្គជាយា តែគង់នៅដោយស្ងាត់ស្ងៀម រង់ចាំបានឧកាសល្អតមក ។

និយាយអំពីប្រទេសចាម្ប៉ា = កន្លងពេលដែលប្រទេសកម្ពុជាកំពុងតែបះបោរជូចមានពោលមកហើយនោះ ខាងប្រទេសចម្ប៉ា ក៏មានការបះបោរដែរ គឺកន្លងរាជ្ជាំ គ. ស. ១១៦៦ - ១១៦៧ មានបុរស ១ នាក់ដែលគេមិនដឹងជាមកពីណា បានមកបង្កការណ៍ក្បត់ដណ្តើមយកពជសម្បត្តិ នៃក្រុងចម្ប៉ាបានសម្រេចហើយ ទ្បើងសោយរាជ្យ ប្រកាសព្រះនាមថា "ព្រះបាទស្រីជយឥន្ទ្រវរ្ម័ន" ទំនងបែបយ៉ាងព្រះត្រីភុវនាទិត្យ ។ ក្រោយដែលទ្បើងគ្រងរាជសម្បត្តិហើយ គឺកន្លងឆ្នាំ ព. ស. ១៧១៣ គ. ស. ១១៧០ ស្តេចនេះបានចាត់បញ្ជូនពជទូត ឲ្យនាំពជបណ្ណាការទៅថ្វាយក្សត្រយួន សុំចង់សម្ព័ន្ធមេត្រីភាព, ស្តេចយួនក៏បានទទួលជាសម្ព័ន្ធមេត្រីឆាប់ ។ ការដែលសុំចង់សម្ព័ន្ធមេត្រីភាពទឹងស្តេចយួនជាមុនយ៉ាងនេះ ក៏ដោយបំណងនឹងចិទ្ធរក្សាកុំឲ្យយួនមកជួយខ្មែរ កន្លងពេលដែលខ្លួនលើកទ័ពមកវាយ ប្រទេសខ្មែរកន្លងថ្ងៃ ១ ។ ស្តេចស្រីជយឥន្ទ្រវរ្ម័ននេះ ជាអ្នកអំនួតអួតឫទ្ធិក្លៀវក្លាងហាក់ដូចជាក្រុងពពាល ។

សង្គ្រាមចាម្ប៉ាគ្រាទី ៤

ក្រោយដែលចង់សម្ព័ន្ធមេត្រីភាពនឹងយួន ១ ឆ្នាំ គឺកន្លងឆ្នាំ ព. ស. ១៧១៤ គ. ស. ១១៧១ ព្រះស្រីជយឥន្ទ្រវរ្ម័នបានលើកទ័ព ដោយផ្លូវ

ដើង្គោកមកវាយប្រទេសកម្ពុជា ដែលជាប្រទេសល្អបំផុត ហាក់ដូចជាហានសួគ៌ ប៉ុន្តែគួបដប៏ក្ខ គឺព្រះបាទត្រីកវនាទិត្យក៏មានប្តូន្តិខ្លាំងក្លាណាស់ដែរ ព្រះស្រីជយតន្តូវរ៉ន៌វាយមិនបែក ក៏លើកទ័ពត្រឡប់ទៅវិញ ទាំងសេចក្តីឈឺចិត្តឆ្អិតខ្លួង ។ អំពីនោះមកខ្លង៌ក៏គិតរកឧបាយជានិច្ច ដើម្បីនឹងមកវាយប្រទេសកម្ពុជាជាថ្មីទៀត ។

សង្គ្រាមចាម្ប៉ាគ្រាទី ៥

លុះដល់ឆ្នាំ ព.ស ១៧២០ ព្រះជយតន្តូវរ៉ន៌ គិតឃើញឧបាយថ្មីក៏លើកទ័ពដោយផ្លូវដើង៌ទឹក មកវាយប្រទេសកម្ពុជាម្តង៌ទៀត បានចំនួន ១ នាក់ដែលលង៌សំពៅជាអ្នកនាំផ្លូវ ចូលមកតាមទន្លេមេគង្គ ហើយបត់ចូលទៅតាមទន្លេសាប ។ លុះដល់ហើយក៏លើកទ័ពឡើង៌គោក ចូលលុកព្រះមហានគរក្នុងកង៌ពេលដែលព្រះបាទត្រីកវនាទិត្យមិនបានខ្លង៌ជ្រាបជាមុន ។ ការតស៊ូរបស់ព្រះបាទត្រីកវនាទិត្យដោយទាហានចំនួនតិចនោះ មិនអាចនឹង៌កាំង៌ពួកសត្រូវបាន ពួកទាហានចាម្ប៉ាក៏លុកចូលក្នុងព្រះនគរបាន ព្រះបាទត្រីកវនាទិត្យ ក៏នៅតែស៊ូទាល់តែក្សយព្រះជន្មក្នុងទីរណរង្គ ។ ទាហានចាម្ប៉ាបានវាយកំទេច នឹងដុតផ្ទះព្រះពជនិវេសន៍ ហើយដណ្តើនយកទ្រព្យសម្បត្តិទៅច្រើនជាអនេក ។

(មានត)

នៃមន្ត្រីសង្ឃ ក្នុងព្រះរាជអាណាចក្រ កម្ពុជា

របស់

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

(តចប់)

ក្រោយពីរំលាយរដ្ឋសភានោះមក រដ្ឋាភិបាលបានបង្ហាក់ម៉ឺនប្រោះឆ្នោត ដោយសង្ឃឹមថាក្នុងអនាគតអសន្តិសុខនឹងបានអន់ថយទៅវិញ ។ តែអសន្តិសុខនេះ គ្មានអន់ថយសោះតែតែមានកម្ចាំងខ្លាំងឡើង នាំឲ្យមានសេចក្តីលំបាកឡើង ។ ក្នុងការគិតប្រោះឆ្នោតនេះ ។

ឯប្រជាជាតិទាំងមូល នៅស្រឡាញ់លទ្ធិប្រជាធិបតេយ្យនៅឡើយ ខ្ញុំករុណានេះឯង ក៏ជាអ្នកជានាអះអាងលើបាប់ដ្ឋមន្ត្រីញ នឹងលើលទ្ធិប្រជាធិបតេយ្យនេះផង ។ យើងទាំងអស់ គ្នាថ្នាក់ឲ្យលទ្ធិប្រជាធិបតេយ្យគង់វង់នៅជាដរាប ហើយនឹងតម្រូវឲ្យមានរដ្ឋសភា ជាតំណាងប្រជាពលរដ្ឋនៅអមរដ្ឋាភិបាលផង ។

ការដោះស្រាយបញ្ហានេះ បើតាមយោបល់ខ្ញុំករុណា មានតែពីរផ្លូវទើបសម្រេចទៅកើត គឺគិតប្រោះឆ្នោតតាមពាក្យសុំរបស់គណៈបក្សខ្លះនឹងបណ្តោរស្ត្រីខ្លះ ឬក៏ត្រូវមហាក្សត្រិយ៍តាំងតំណាងរាស្ត្រថ្មី នៃរដ្ឋសភាលើកមុន ធ្វើជារដ្ឋសភា

បណ្តោះអាសន្នសិន ព្រោះតំណាងរាស្ត្រទាងនោះ ទោះបីយ៉ាងណាក្តីក៏ជ្រាបមានបណ្តារាស្ត្របោះឆ្នោតរើសរូបមកហើយដែរ ។

តែការដោះស្រាយទាំងពីរផ្លូវនេះ ដំនុំពុំបានដាច់ស្រេចសោះ, ខ្លះថាការណ៍បោះឆ្នោតនាំឲ្យប្រទេសកើតមានចលាចលដល់នូវសេចក្តីវិនាស, ខ្លះរំលឹកថា បើនឹងហៅរដ្ឋសភាចាស់ឲ្យមកប្រតិបត្តិការឡើងវិញឃើញថាខុសច្បាប់ ឬក៏នឹងនាំឲ្យកើតប្រតិបក្ខគ្នា ដោយការគំនុំស្អប់នឹងការសងសឹក ។

អ្នកទាំងអស់ប្រាថ្នាបង់ឲ្យមានរដ្ឋសភា តែគ្មានអ្នកណាព្រមព្រៀងនឹងសម្រេច ឲ្យបានស្រួលគ្នាសោះ ។

ខ្ញុំករុណាមានសេចក្តីសោមនស្សណាស់ បើសិនណាខែត្រគ្រាអាចនឹងបញ្ជូញយោបល់ឲ្យខ្ញុំករុណាបានភ្លឺខ្លះអំពីចំណងប្រជាភិស្តយើង ។

មុននឹងបញ្ចប់, ខ្ញុំករុណាយល់ឃើញថាគួរពិតពុទ្ធដីកាដោយសង្ខេបប្រគេនលោកគ្រូជ្រាប អំពីស្ថានការណ៍រវាងប្រទេសដែលស្ថានការណ៍នៃប្រទេសយើងតែងប្រែប្រួយទៅតាមស្ថានការណ៍កងសាកលលោក ។

អនាគតនៃពិភពលោកយើងដ៏តៗនេះគួរឲ្យព្រួយច្រើន ។ មុននឹងអស់ព្រួយ អនាគតនោះប្រហែលជានឹងមានការលំបាកច្រើនលើសកងសម័យបច្ចុប្បន្ននេះទៅទៀត ជាពិតប្រាកដ ។

- នៅដុំវិញយើងមានបម្ពាំងជាយ៉ាងខ្លាំង ។ ពួកកាន់លទ្ធិរួមសម្បាច់ បម្ពាំងនឹងអាម៉ើរិកាំងនៅប្រទេសកូរ៉ែ, បម្ពាំងនឹងបាក់ងកង្នែងដែនឥណ្ឌូចិន នៅប្រទេសតុងកឹងជាដើម, បម្ពាំងនឹងអង់គ្លេសនៅប្រទេសម៉ាឡាយូ ។ ពួកកាន់លទ្ធិរួមសម្បាច់បានចូលលុកលុយប្រទេសទីបេហើយ ។ បណ្តាលឲ្យមានភ័យផ្អាល់ចំពោះប្រទេសភូដ្ឋ មានល្បឿនបៃមុខសំដៅមកប្រទេសកូមាផង ដែនឥណ្ឌូចិននឹងប្រទេសសៀមផង ។

នៅទ្វីបអឺរ៉ុប, ជាតិអាម៉ើរិកាំងនឹងជាតិរុស្ស៊ីឃ្លាំគ្នាទៅវិញទៅមកនៅត្រៀមប្រឈមមុខគ្នាក្នុងប្រទេសអល្លឺម៉ាញ ។

គេបារម្ភខ្លាចត្រែងមានបម្ពាំងធំទី ៣ ក្នុងលោក ។ តែបម្ពាំងមាននៅចុងបូព៌ាប្រទេសមកហើយ គឺមានខាងយើង ។

ការយោសនាបញ្ចុះបញ្ចូលរបស់ពួកកាន់លទ្ធិរួមសម្បាច់ ផ្សាយដំណឹងថា លទ្ធិរួមសម្បាច់ចូលមកស្រុកយើង ដើម្បីជោះយើងឲ្យរួចរបូត អំពីការនៅក្នុងចំណុះពួកបស្ចិមប្រទេស ។ តែដោយពិចារណាសព្វគ្រប់ទៅ ខ្ញុំកុណាយល់យើញថា បើពួកកាន់លទ្ធិរួមសម្បាច់មានជ័យជំនះនៅស្រុកយើង នោះជាគុណប្រយោជន៍ចំពោះតែពួកវៀតមិញប៉ុណ្ណោះទេ ។ ឯពួកវៀតមិញដែលមកតាំងនៅក្នុងស្រុកយើងនេះទុកស្មើនឹងការបំបាត់មិនឲ្យមានខ្មែរអធិបតេយ្យ ។

មានតែជ័យជំនះអាម៉ែរកិន្នរនោះទេ ដែលនឹងគាំពារឯករាជ្យ ជាទី
ស្នេហារបស់យើងទាំងមូលនោះឲ្យនៅគង់វង្ស ហើយចំរើនទៅមុខបាន ។
ប្រទេសអាម៉ែរកិបានបង្ហាញឲ្យឃើញច្បាស់ស្អាងសុពុត្រគ្រប់ហើយ អំពីឧត្តម-
គតិរបស់គេ ដែលការពារសេរីភាពនៃប្រជាជាតិនានា ។ ប្រទេសមានិល
នឹងប្រទេសទាំងប៉ុន្មាន នៅក្នុងទ្វីបអឺរុប បែកខាងបស្ចិមទិសនោះឯង
សោត ក៏បានសេរីភាពមកដោយសារជ័យជំនះអាម៉ែរកិនក្នុងសង្គ្រាម
ដំទី ២ ក្នុងលោកនោះដែរ ។

គឺដើម្បីនឹងការពារឯករាជ្យរបស់យើងនេះហើយ បានជាប្រទេស
យើងត្រូវចងមិត្តភាពគ្រីជាមួយពួកលទ្ធិប្រជាធិបតេយ្យ នៅបស្ចិមទិស
មានប្រទេសអាម៉ែរកិនជាដើម ។ នៅក្នុងកំឡុងការលំបាកទាំងនេះ ខ្ញុំ
ករុណាមានសេចក្តីត្រេកអរបានឃើញនូវសាមគ្គីភាពនៃប្រជាជាតិយើងជាជារាប ។

មហិច្ឆតាតែមួយរបស់ខ្ញុំករុណា គឺចង់ឃើញប្រជាជាតិយើងរួច
ផុតអំពីទុក្ខវេទនាទាំងអស់ ។ តែលោកគ្រូគ្រប់ព្រះអង្គជាបសាច់ហើយ
ថា កិច្ចការខ្ញុំករុណានេះពិបាកយ៉ាងណា ។ បើខ្ញុំករុណានឹងសូមរំពឹង
ខ្លះផងលើលោកគ្រូនោះ គឺសូមលោកគ្រូដែលគង់នៅក្នុងអាណាខេត្ត
គឺនៅជិតបណ្តាក្រុងស្តុងទាំងខ្ញុំករុណានេះ សូមមានតុដីការៅបណ្តាក្រុងស្តុង
ថា រដ្ឋាភិបាលនឹងមហាក្សត្រិយ៍មិនដែលភ្លេចបណ្តាក្រុងស្តុងមួយវិលាណា
ទេ ហើយសូមបណ្តាក្រុងស្តុងឲ្យអភ័យទោសអំពីការពិបាកទាំងប៉ុន្មាននោះ

ផង ដែលយើងបានខិតខំធ្វើចង់ឲ្យបណ្ដាក្រុមប្រៀសាងនូវការពិបាកនេះ តែនៅប្រៀសាងពុំទាន់រួច ។ ចំណែកខ្ញុំកុណា ។ ក៏បានខិតខំបំរើជាតិមកតាមសមត្ថភាព ដែលខ្សត់ខ្សោយរបស់ខ្ញុំកុណា ។

នៅទីអាសាន ខ្ញុំកុណា សូមទទួលដោយគោរព សូមឲ្យលោកគ្រូបានប្រកបដោយសេចក្ដីសុខសប្បាយគ្រប់ព្រះអង្គ ! នឹងសូមឲ្យព្រះពុទ្ធសាសនាបានប្រកបដោយកិត្តិគុណតរៀងទៅ ! ។

សុន្ទរកថាឯកឧត្តម សម - ញ្ញា ណ

បន្ទាប់មក ឯកឧត្តម សម - ញ្ញា ណ រដ្ឋមន្ត្រីក្រសួងធម្មការនឹងសិល្បការ បានថ្លែងសុន្ទរកថាពណ៌នាអំពីការចំរើននៃកិច្ចសិក្សាខាងព្រះពុទ្ធសាសនាដូចតទៅនេះ :-

សូមព្រះតេជះដ៏តល់លើត្បូង

សូមព្រះពរជាន់ក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត !

ទូលព្រះបង្គំជាខ្ញុំមានអំណរ ចំពោះល្អងធូលី ដែលស្ដេចយាងមកជាព្រះពរជាធិបតីនៃមហាសន្និបាតនេះ ។ ព្រមទាំងមានសោមនស្សចំពោះទ្រង់, ព្រះតេជព្រះគុណ លោក - អ្នកសប្បុរសទាំងឡាយ ដែលយាងអញ្ជើញមកក្រាបបង្គំគាល់ ជុំវិញព្រះអង្គនេះ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះពរជានុញ្ញាត ដើម្បីប្រែសំយ័នឹងព្រះថេរពន្ធុត្តេរទាំងឡាយ ដោយមានបំណងចង់ឲ្យបានជ្រាបដំណើរកិច្ចការ

ខ្លះ ខាងព្រះពុទ្ធសាសនាដែលគ្រែសួងធម្មការបានបំពេញ ក្រោមអធិបតីភាពនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ។

សូមថ្វាយបង្គំសម្តេច នឹងព្រះថេរានុត្ថេរគ្រប់ព្រះអង្គ ជាមន្ត្រីសង្ឃគ្រប់តំណែងក្នុងព្រះពុទ្ធអាណាចក្រកម្ពុជា ។

ខ្ញុំព្រះករុណាមានចិត្តរីករាយយ៉ាងក្រៃលែង ចំពោះព្រះតេជព្រះគុណទាំងឡាយមានសម្តេចទាំង ៣ ព្រះអង្គជាប្រធាន ដែលបានមិនមកកាន់ទីមហាសន្និបាត ប្រចាំឆ្នាំទី ៧ នេះ ។

ខ្ញុំ! សម្តេច! ព្រះតេជព្រះគុណ! លោក-អ្នកជាពុទ្ធបរិស័ទទាំងឡាយ! ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទជារដ្ឋមន្ត្រីក្រសួងធម្មការសូមនុនាយគោរព ហើយសូមថ្លែងអំពីព្រះពុទ្ធសាសនាដែលមានដំណើរដឿនទៅកាន់សេចក្តីចំរើន ដោយអាស្រ័យច្បាប់លោកនឹងច្បាប់ធម៌ ដូចតទៅនេះ :-

ព្រះពុទ្ធសាសនា ដែលអាស្រ័យនឹងច្បាប់លោកនោះយ៉ាងណា?

អធិប្បាយថា : រដ្ឋធម្មនុញ្ញ មាត្រា ៨ ចែងថា : "សេរីភាពខាងជំនឿ ត្រូវបើកឲ្យមានដោយបរិបូណ៌ ។ សេរីភាពក្នុងការប្រតិបត្តិខាងផ្លូវសាសនាក៏ត្រូវបើកឲ្យមានដូច្នោះដែរ បើនឹងបន្តយ៉ះតែត្រង់ណាដែលវៀរពុំបានដើម្បីកុំឲ្យខូចសេចក្តីសូប៉ៅរៀបរយដល់មហាជន ។ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ" ។ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ

សូមនុកាសអធិប្បាយអំពីចរិយាចិត្តនៃពពួកពុទ្ធបរិស័ទខ្លះប្រកាន់ខ្ជាប់នូវដំនឿ
តាមលទ្ធិរបស់ខ្លួន ហើយអាង៎ទៅលើរដ្ឋធម្មនុញ្ញដោយពាយសេចក្តីផ្សុយ
ពុំសព្វអត្ថរសនៃរដ្ឋធម្មនុញ្ញ ។

ពាយសេចក្តីផ្សុយពុំសនោះដូចម្តេច? ថាស្រែចហើយតែនឹងចិត្ត
ដើរយ៉ាងណាក៏អាចធ្វើយ៉ាងនោះ ព្រោះអាងថារដ្ឋធម្មនុញ្ញបើកឲ្យដើរ
ដោយបរិបូណ៌ហើយ ។

មកពីយល់ពុំសដូច្នេះហើយដឹង? ឃានជាឮថា មានពពួកពុទ្ធ-
បរិស័ទ ខ្លះកេរជាបព្វជិត ខ្លះកេរជាគហស្ថ ប្រព្រឹត្តឃ្លាងពីធម៌នៃយ
របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

ឯអត្ថរសនៃរដ្ឋធម្មនុញ្ញមានគាំទ្រលើនេះបើពាយសេចក្តីឲ្យត្រឹមត្រូវ
ដូចអធិប្បាយតទៅនេះ ៖

សេរីភាពទាំងដំនឿ ត្រូវបើកឲ្យមានដោយបរិបូណ៌ គឺថាបុគ្គល
មានសេរីភាពពេញទីទាំងដំនឿ ។

ន័យមួយទៀតថា បុគ្គលគប្បីរូបមិនថារូបណាចង់ដើរសាសនា
ណាឬមិនដើរសាសនាណាឃានតាមចិត្ត ។ ការដែលបើកឲ្យឃានតាមចិត្ត
យ៉ាងនេះ ព្រោះគំនិតនៃរដ្ឋធម្មនុញ្ញ លោកការពារមិនឲ្យលោកអ្នកកាន់
អំណាចបង្ខំចិត្តមនុស្សឲ្យចូលកាន់សាសនាណាមួយ តាមទំនើងចិត្តរបស់
ខ្លួន ។ តែការនេះដូចជាគ្មាននៅប្រទេសខ្មែរទេ ។ ព្រោះជនជាតិខ្មែរ

មិនដែលបង្ខិំជនណាឲ្យដើរតាមខ្លួនសោះឡើយ ។ ព្រោះព្រះពុទ្ធសាសនា តែងតែផ្សាយសេចក្តីសុចរិតនាំហេតុ - ផលមកពន្យល់ឲ្យមនុស្សស្តាប់បាន ហើយចុះចិត្តចូលកាន់តាមស្ម័គ្រពីចិត្តឯង ។ តែមានសាសនាជាច្រើនមិនដូច្នេះទេ ដូចជាក្នុងប្រទេសពេមសម័យបុព្វណាមនុស្សដែលកាន់គ្រិស្ត-សាសនា ដំបូងត្រូវជាការធ្វើបាបដល់ទៅបែហារដីវិត ។ ក្នុងប្រទេសអ៊ីរ៉ុបអ្នកកាន់សាសនាប្រូតេស្តង់ ក៏ត្រូវជាការសង្កត់សង្កិនធ្វើបាបណាស់ដែរ គ្រាតែកើតចម្បាំងសាសនាឡើងពីសតវត្សទី ១៦ - ១៧ ។

ក្នុងប្រទេសឥណ្ឌៀសម័យមុន មនុស្សដែលកាន់ព្រះពុទ្ធសាសនា ត្រូវពួកហ៊ិនឌូតមហាម៉ាត់សង្កត់សង្កិន តាំងពីឆ្នាំ ៧០០ ដរាបមកឆ្នាំ ៨០០ តទៅ ។ ការប្រើអំណាចសង្កត់សង្កិនលើដំនើរនោះ នាំឲ្យកើតក្តៅគ្រហាយយ៉ាងច្រើន ។

លំដាប់តមក អារ្យធម៌បានចំរើនខ្ពស់ឡើង ។ ទើបតាំងឲ្យមានសេរីភាព ។ សេរីភាពខាងសាសនាមានគ្រាន់តែក្នុងក្នុងរដ្ឋធម្មនុញ្ញ នៃអារ្យ-ប្រទេសនានា ។ ការដែលមានចុះសេរីភាពខាងដំនើរ ក្នុងរដ្ឋធម្មនុញ្ញប្រទេសខ្មែរ ក៏ជាហេតុមួយសំដែងឲ្យឃើញថាជាតិយើងមិនមែនជាជាតិតាបថាកជាតិព្រៃផ្សៃទេ ។

សេចក្តីខាងលើនេះ ប្រាន់ដល់សេរីភាពខាងផ្លូវចិត្ត ចំពោះសាសនា ជាសេរីភាពជាប់ខាត គឺថារដ្ឋមិនអាចតាំងច្បាប់មកបំបាត់ ឬ

បន្ទុយសេរីភាពនេះបានឡើយ ។ ប៉ុន្តែរដ្ឋអាចបន្ទុយសេរីភាពនេះបានខ្លះ កាលបើការប្រតិបត្តិនោះ នាំឲ្យខូចសេចក្តីស្ងប់រៀបរយ ដល់មហាជន ។ ប្រៃសេចក្តីថា កាលបើការប្រតិបត្តិសាសនាណាមួយ អាចនាំឲ្យមានចលាចលក្នុងប្រទេស ហើយប្រសិនណាជារដ្ឋ (ពជការ) យល់ថានឹងបណ្តោយឲ្យប្រតិបត្តិទៅទៀតពុំបាន នោះរដ្ឋអាចហាមមិនឲ្យមានការប្រតិបត្តិសាសនានោះ ។

ឯកម្ពុជរដ្ឋប្រទេសយើងនេះ មានព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ បើលោកអ្នកទាំងឡាយណាមួយ ស្ម័គ្រចិត្តចូលកាន់ព្រះពុទ្ធសាសនា ត្រូវតែប្រតិបត្តិតាមធម៌វិន័យ ដែលសម្តេចព្រះសង្ឃនាយកនឹងថេរសភា សង្ឃជាន់ខ្ពស់ទាំងពីរគណៈ បានផ្សឹងផ្សាត់តាមពុទ្ធប្បញ្ញត្តិ ត្រមត្រៀងជាឯកច្ឆន្ទគ្នាជាត្រឹមត្រូវហើយនោះ ត្រូវតែប្រតិបត្តិតាមជាប់ខាតខានមិនបាន ។ ប៉ដូចជាសាសនិកជនទាំងឡាយណាមួយស្ម័គ្រចិត្តកាន់គ្រិស្តសាសនា ត្រូវតែប្រតិបត្តិតាមធម៌វិន័យ ដែលសម្តេចព្រះសង្ឃ (ប៉ាប) បានពិនិត្យផ្សឹងផ្សាត់តាមច្បាប់បញ្ញត្តិរបស់ព្រះយ៉េស៊ូ (ព្រះម្ចាស់សួគ៌) ទុកជាត្រឹមត្រូវហើយជាក់ឲ្យប្រតិបត្តិតាមយ៉ាងនោះ ។ ប៉ុន្តែសេរីភាពខាងជំនឿ បើកឲ្យជឿបានតាមចិត្ត ។ ប្រៃថាជឿខាងព្រះពុទ្ធសាសនាក៏បាន ឬជឿខាងគ្រិស្តសាសនាក៏បាន ។ តែបើជឿខាងសាសនាណាមួយហើយ ត្រូវតែប្រតិបត្តិតាមធម៌វិន័យរបស់

សាសនានោះ មិនមែនឲ្យមានសេរីភាព ឲ្យប្រតិបត្តិខុសពីធម៌វិន័យ
របស់សាសនានោះ ឬតាមចិត្តឡើយ ។ ន័យយ៉ាងនេះហើយហៅ
ថាច្បាប់លោក ។

អំពីច្បាប់ធម៌, ព្រះពុទ្ធសាសនាដែលអាស្រ័យនឹងច្បាប់ធម៌នោះ
យ៉ាងណា ?

មិនចាប់អធិប្បាយក្នុងទីនេះទៀតទេ ព្រោះពីល្ងាចម្សិលមិញសម្តេច
ព្រះសង្ឃនាយកវត្តបទុមវតី នឹងវត្តខ្ញុំណ្ហាលោមមានព្រះពុទ្ធដីកាពន្យល់
ជូនល្មមរួចហើយ ។ គ្រានេះគ្រាន់តែសូមបញ្ជាក់ តាមសាស្ត្រាច្បាប់ក្រម
កងវត្តមួយថា : "នរអ្នកណា ទោះយកអាត្មា ចូលសាសន៍ពុទ្ធវត័ន
ចូរធ្វើឲ្យត្រង់ ដោយទូរបន្ទាត់ ហៅសែ្វងសម្បត្តិ យកផ្លូវនិព្វាន" ។

បន្ទាត់ពោលគឺព្រះវិន័យ (ច្បាប់), ព្រះវិន័យនេះ យើងទុកជាបុស
គល់នៃព្រះពុទ្ធសាសនា ; អាស្រ័យហេតុនេះហើយបានជាព្រះចៃ្រ
មហាក្សត្រីយ៍ ដ៏ទ្រង់នូវគុណាតិរេកឯកលើស្ត្រីនៃយើង ស្តេចចេញ
ព្រះរាជក្រមលេខ ២១៤ ន. ស. ចុះថ្ងៃទី ២៥ ខែសីហា គ. ស. ១៩៥០
ស្តីអំពីការបង្កើតសាលារៀនធម្មវិន័យ គ្រប់វត្តអារាមទូទៅក្នុងព្រះរាជ-
អាណាចក្រ ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ មានអំណរយ៉ាងក្រៃលែង
ចំពោះព្រះរាជក្រមនោះ ។ អាងនូវព្រោះឃើញសម្តេចព្រះសង្ឃនាយក

វត្តទ្រណ្ណាលោមកំពុងរៀបចំទីកន្លែងនៃសាលាធម្មវិន័យថែមទៀត ។ មុនដំណាច់ឆ្នាំ ១៩៥០ ឮថា: សម្តេចអង្គនេះ ចាននិមន្តទៅជាប្រធានក្នុងការប្រឡងធម្មវិន័យនៅវត្តពិកទូរឡ្ស ។ ព្រះតេជព្រះគុណព្រះមុនីកោសលមេគណខែត្តចាត់ដំបង នៅវត្តពោធិ៍វាលជាប្រធានក្នុងការប្រឡងធម្មវិន័យ ក្នុងខែត្តនេះ ។ ខែត្តសៀមរាប ខែត្តពោធិ៍សាត់ ខែត្តស្វាយរៀង កំសុទ្ធតែមានព្រះសង្ឃប្រឡងធម្មវិន័យ ដោយព្រះពជប្រតិកូខែត្តនឹងលោកចៅហ្វាយខែត្តទាំងនោះ ចានជួយទំនុកបំរុងជាផ្លូវការ ។ រួមព្រះសង្ឃដែលចូលប្រឡងធម្មវិន័យពាល់កន្លែងខាងលើនេះ ចំនួន ២.៥០៧អង្គ ។ ក្នុងចំនួននេះខែត្តចាត់តំបងមាន ២.១០៩ អង្គ, ព្រោះតែព្រះសង្ឃនៅខែត្តចាត់ដំបងទ្រស្បាហ៍រៀនធម្មវិន័យច្រើនព្រះអង្គយ៉ាងនោះហើយដឹង? ចានជាអធិករណ៍ឈ្លោះដណ្តើមលាភសក្ការៈផ្សេងៗ គ្មានកើតឡើងក្នុងខែត្តនោះ ។ គួរឲ្យមានចិត្តត្រឹមត្រូវហើយដែរថ្វាចំពោះព្រះសង្ឃដែលទ្រស្បាហ៍រៀនធម្មវិន័យ តាមព្រះពជក្រមនៃព្រះកុរុណាជាអម្ចាស់ដ៏វិតលើតួង្គឥតអ្វីប្រៀបឡើយ ។ ព្រោះយល់ថាព្រះសង្ឃទាំងនោះហើយ ជាស្រែបុណ្យរបស់លោកអ្នកកាន់ព្រះពុទ្ធសាសនា ។

ម្យ៉ាងទៀត ព្រះបិយមហាក្សត្រិយ៍ព្រះអង្គជាពុទ្ធសាសនូបត្ថម្ភក: មានព្រះពជហឫទ័យគោរពមានព្រះអធ្យាស្រ័យ ដ៏ធ្ងន់ទៅរកព្រះពុទ្ធ-

សាសនា ដូចព្រះករុណាគ្រប់ព្រះអង្គជ្រាបស្រាប់ហើយថា ខ្ញុំមានក្រាបថ្វាយបង្គំឲ្យព្រះពុទ្ធសាសនា មានពន្លឺរស្មីដ៏ភ្លឺរុងរឿង, ទើបខ្ញុំព្រះមេត្តាក្រាបបង្គំទូលសូមព្រះសង្ឃ ក្នុងព្រះរាជអាណាចក្រឲ្យសិក្សាធម្មវិន័យព្រះពុទ្ធសាសនាដោយផាសុកភាព ដូចមានសេចក្តីក្នុងព្រះរាជក្រមខាងលើស្រាប់ ។ មិនត្រឹមតែប៉ុណ្ណោះខ្ញុំក្រាបទូលសូមកិច្ចការក្នុងព្រះពុទ្ធសាសនា បង់ឲ្យព្រះសង្ឃជាបណ្ឌិតមានសិទ្ធិសម្រេចកិច្ចការក្នុងព្រះពុទ្ធសាសនា កុំឲ្យកិច្ចការខាងព្រះពុទ្ធសាសនា ឋិតនៅក្នុងអំណាចនៃរាជការអាណាចក្រឡើយ, ខ្ញុំសូមព្រះរាជហឫទ័យថា រាជរដ្ឋាភិបាល មានព្រះអង្គជាប្រមុខនេះ គ្មានតែជួយឧបត្ថម្ភចំពោះកិច្ចការក្នុងព្រះពុទ្ធសាសនាដែលក្រសួងសង្ឃ ចានចាត់ចែងហើយនោះឲ្យចានសម្រេចប៉ុណ្ណោះ ។ ព្រះរាជយោបល់យ៉ាងនេះ រាប់ថាជាព្រះករុណាគុណដ៏ថ្លៃថ្លាទុកក្នុងប្រវត្តិសាស្ត្រ ។ ក្រសួងធម្មការនឹងចាត់ចែងឲ្យចានសម្រេចតាមព្រះរាជបំណងក្នុងឆ្នាំ ១៩៥១ នេះពុំខាន ។

ខ្ញុំ ! សម្តេច ! ព្រះតេជៈព្រះគុណ ! លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ ! ខ្ញុំលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំចាស សូមអភ័យទោសម្តងទៀតថា សេចក្តីអធិប្បាយអំពីច្បាប់លោក ច្បាប់ធម៌ជាសង្ខេបប៉ុណ្ណោះ ដោយសុទ្ធចិត្តដ៏ល្អឥតមានលំអៀងភ្លាលទោសចំពោះលោកអ្នកទាំងឡាយណាមួយឡើយ ។ ក្រសួងធម្មការសង្ឃឹមថា អស់លោក

អ្នកជាពុទ្ធបរិស័ទ ទាំងបព្វជិតទាំងគហស្ថ មុខជាប្រតិបត្តិតាមច្បាប់លោកច្បាប់ធម៌តទៅ ។ ក្រសួងធម្មការ នឹងយកចិត្តទុកដាក់ជួយឧបត្ថម្ភកាលតែផ្លូវការ ដែលទាក់ទងចំពោះព្រះពុទ្ធសាសនាតទៅអនាគត ។

មុននឹងបញ្ចប់ ខ្ញុំព្រះករុណាសូមនុនកាយគោរព ដោយសោមនស្សចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ មានសម្តេចទាំងបីព្រះអង្គជាប្រធានដែលបាននិមន្តមកកាន់ទីមហាសន្និបាតនេះ, សូមគុណានុភាពព្រះត្រៃរ័ត្នប្រសិទ្ធិពរ ចំពោះព្រះថេរានុត្ថេរៈទាំងឡាយមានសម្តេចជាប្រធានឲ្យបានប្រកបដោយសុខសួស្តី ក្នុងផ្លូវកងផ្លូវព្រះពុទ្ធសាសនា ។

សូមថ្វាយព្រះពរជ័យសួស្តី សូមជូនពរសួស្តី ចំពោះព្រះករុណាជាអម្ចាស់ដ៏វិសេសលើត្បូង ព្រមទាំងអស់លោក - អ្នកសប្បុរសដែលបានបរិច្ចាគព្រះពរជ័យ អំណោយធនធានផ្ញើអាគន្តុកទានចំពោះព្រះសង្ឃក្រុងប៉ារីសក្នុងឱកាសបុណ្យអង្គនាថៃ្ងសុភមង្គលនេះ ។ សូមកុសលពរជ័យអតិបាលរក្សាព្រះអង្គឲ្យបិតនៅកងសិរីរាជសម្បត្តិយ៉ាងក្សេមក្សាន្ត ព្រមទាំងព្រះពរជ័យនូវផ្លែផ្កាបវរជ័យដ៏ប្រសើរ ! ។ សូមផលានិសង្សនេះបង្ហូរនូវសេចក្តីសុខចំរើនគ្រប់ប្រការ ដល់លោក - អ្នកស្រីជាតិទាំងឡាយទូទៅក្នុងព្រះពរជ័យ-ណាចក្រ ! ។

ដោយអំណាចគុណានុភាពនៃព្រះរតនត្រៃ នឹងគុណានុភាពនៃបុណ្យកុសលនេះ សូមឲ្យអស្តង្គតសុខក្នុងប្រទេសយើងវិនាសបាត់ទៅ !

សូមឲ្យសន្តិសុខក្នុងប្រទេសយើងកើតឡើង ! សូមឲ្យព្រះពុទ្ធសាសនាបានរុងរឿងចំរើនឡើង ! សូមព្រះគុណជាអម្ចាស់ជីវិតលើត្បូង បានបំតេជាស្តាពរក្នុងសិរីរាជសម្បត្តិ អស់កាលជាអង្វែង ! សូមរាជរដ្ឋាភិបាលនិងមន្ត្រីគ្រប់ឋាន: ព្រមទាំងប្រជារាស្ត្រគ្រប់ប្រភេទក្នុងប្រទេសបានទទួលនូវសុខភាពនិងវឌ្ឍនភាពគ្រប់ប្រការ តាំងពីក្នុងបច្ចុប្បន្នកាលនេះតរៀងទៅ ! ។

សេចក្តីថ្លែងការណ៍ថ្វាយ
របស់ព្រះតេជព្រះគុណ ទុំ-អ៊ុម

បន្ទាប់ពីនោះមកទៀត ព្រះតេជព្រះគុណ ទុំ-អ៊ុម មេគណវត្តយាយទេពវែតកំពង់ឆ្នាំង បានថ្លែងសុន្ទរកថា ក្នុងនាមនៃមន្ត្រីសង្ឃទាំងឡាយ ដែលមានសេចក្តីប្តេជ្ញាចំពោះព្រះប្រិយមហាក្សត្រថានឹងព្រមធ្វើតាមព្រះរាជឆន្ទារទាំងអស់ ដូចតទៅនេះ ។

សូមថ្វាយព្រះពរព្រះគុណាម្ចាស់ជីវិត

សូមទ្រង់ជ្រាប ។

អាត្មាភាព តាងនាមមន្ត្រីសង្ឃគ្រប់តំណែងដែលបានមកកាន់អនុសំវច្ឆរៈសន្និបាត ជាគំរប់ ៧ ហើយដែលបានមកប្រជុំក្នុងពីនេះ សូមព្រះរាជទានព្រះរាជវរោកាសថ្វាយយោបល់ ដោយសេចក្តីគោរពដ៏ក្រៃលែងចំពោះព្រះពុទ្ធសាសនានិងចំពោះព្រះគុណាជាអម្ចាស់ជីវិត ដោយសេចក្តីថ្លែងការណ៍ថ្វាយដូចខាងក្រោមនេះ ។

អាត្មាភាពទាំងឡាយ ទោះបីសព្វថ្ងៃនេះ ប្រទេសខ្មែរកើតមាន
អសន្តិភាពនៅទីតំបន់ខ្លះ មិនបរិបូណ៌ដោយសន្តិភាពក៏ដោយ តែមាន
ជាកម្រៃចិត្តគំនិត សូម្បីបន្តិចបន្តួច អំពីសេចក្តីជឿកាន់ នឹងសេចក្តី
ស្មោះត្រង់ ព្រមទាំងស្មារតីភក្តី ចំពោះព្រះកុណាជាអម្ចាស់ដ៏វិត នឹង
សេចក្តីគោរព ដោយខ្ជួលជឿស្តាប់តាមព្រះយោបល់នៃព្រះកុណាជា
អម្ចាស់ដ៏វិត អាត្មាភាពទាំងឡាយក៏បានបំពេញហើយ ហើយនឹងខំប្រឹង
បំពេញឲ្យសព្វគ្រប់ តាមកំឡាំងរៀងរាល់រូបតរៀងទៅ ព្រោះតំណឹង
យល់ឃើញហើយដឿចឡាស់ថា ត្រូវតែអាត្មាភាពទាំងឡាយ នាំគ្នា
ហែតាមគ្រោយព្រះកុណាជាអម្ចាស់ដ៏វិត ព្រះប្រិយមហាក្សត្រិយ៍
ដែលមានព្រះយោបល់ នឹងនយោបាយដ៏ផ្សេង។ ពីនោះផ្លុយស្រឡះ
ឆ្ងាយពីគ្នាណាស់ នឹងអាចញ៉ាំងប្រទេសជាតិនឹងព្រះពុទ្ធសាសនាឲ្យ
លូតលាស់ចំរើនទៅមុខពុំបាន ។ បានដឹងពាល់គ្នាថាព្រះកុណាជា
អម្ចាស់ដ៏វិតទ្រង់សាងព្រះពុជហឫទ័យ ទ្រង់ព្រះមេត្តាប្រោសដល់អស់
ប្រជានិករ ដោយតាំងព្រះពុជហឫទ័យប្រកបដោយករុណា ទ្រង់ព្រះ
ស្ថិតនៅជាសុខក្នុងព្រះសិរីពុជសម្បត្តិតទៅ ដោយលះលាកចាកសេចក្តី
ខ្មៀយណាយ ទោះអាត្មាភាពទាំងឡាយព្រមទាំងប្រជាជនពលរដ្ឋមាន
សោមនស្សដ៏ក្រៃលែង ដោយមានសង្ឃឹមពេ៉ងមាំថា កម្ពុជរដ្ឋនឹង
បានរួចចាកគ្រោះថ្នាក់ផុតទុបសគ្គផ្សេង។ ហើយនឹងមានវឌ្ឍនភាពស្ថាពរ

ដោយសារព្រះយោបល់នឹងវិរិយភាពដ៏ប្រសើរ នៃព្រះករុណាជាម្ចាស់ដ៏វិតជាប្រមុខរបស់រដ្ឋ ។ គុណនៃសីលធម៌ណា ដែលអាត្មាភាពរាល់រូប ព្រមទាំងសិស្សគណ នឹងពុទ្ធបរិស័ទទាំងឡាយជាចំណុះវត្តនីមួយៗ ក្នុងកម្ពុជរដ្ឋទាំងមូល ប្រព្រឹត្តប្រតិបត្តិតាមលំអានព្រះពុទ្ធសាសនា, សូមគុណនៃសីលធម៌នោះ ដួយអភិបាលរក្សាព្រះករុណាជាអម្ចាស់ដ៏វិត ព្រមទាំងសម្តេចព្រះបរមរាជបិតា នឹងសម្តេចព្រះវររាជជននីនាថ ទាំងពីរព្រះអង្គ នៅព្រះរាជវង្សានុវង្ស អង្គអគ្គសេវាមាត្យមុខមន្ត្រីគ្រប់តំណែង ! សូមមានសិរីសួស្តីជ័យជំនះគ្រប់ទិសទី ! សូមឲ្យប្រទេសកម្ពុជារុចផុតស្រឡះចាកគ្រោះថ្នាក់ឧបសគ្គទាំងពួង ! ហើយសូមឲ្យបានលូតលាស់ចម្រើនតាមកាលសម័យ ប្រកបដោយសន្តិភាពរៀបរយគ្មានឆ្វែងវែងឆ្ងាយទៅ ! ។

ពិធីនេះបានបញ្ចប់ដោយធម៌ជយន្តោ ដែលពួកមន្ត្រីសង្ឃបានស្វាធ្យាយ, រួចព្រះពាជាទ្រង់បានប្រគេនទូរស៊ែវគៅវិន័យនឹងស៊ែវគៅនិយាយពីរឿងត្រៃចីវរចំពោះព្រះសង្ឃ ។

នៅពេលថ្ងៃត្រង់ មានការលៀងកត្តចំពោះមន្ត្រីសង្ឃនឹងលោកគ្រូចៅអធិការទាំងនោះនៅវត្តឧណ្ណាលោម ដោយការបរិច្ចាគនៃព្រះពជ-ព្យនឹងការបរិច្ចាគនៃមន្ត្រីកសួងធម្មការ ជាមួយនឹងឧបាសកឧបាសិកាទាំងឡាយ ។

— ចប់ —

ព្រឹត្តិសាសនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែមេសា លេខ ៤

ព. ស. ២៤៩៣ — គ. ស. ១៩៥១



ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	មញ្ជើរឿង	ទំព័រ
ពុទ្ធសាសនានិងគ្រឹស្តសាសនា (សន្ទនា លោកវេជ្ជបណ្ឌិតម៉ីគ្លូត) (តមក)	លោក ភ័យ - ប៊ុក	២៤៤
ពត្តូអាស៊ីទ្វីប (តមក)	លោក ភ័យ - ប៊ុក	២៤៩
សង្គហធម៌	ព្រះវិន័យធម្ម ឃួរ - ប៊ុណ	២៥៦
ផ្នែកអក្សរសាស្ត្រ		
សារលិខិតនៃលោកស្វាមីវិវេកានន្ទ	លោក ភ័យ - ប៊ុក	២៦៦
ការបណ្តុះនំស្បូយ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុត - ប៊ម	២៧២
សារវិភារវិត្តកែវនៃពាង្សាវតារ	ព្រះមហា គុយ - ហួត	២៨០
បញ្ហាភាសិតនិងប៉ាតិ	លោក ប៊ូ - ប៊ូ	២៨៧
រឿងសាមកុក (តមក)	— ឆ្ងូ - ពន	២៩៦
ព្រះពាធិតង្សវិភារប្រទេសកម្ពុជា (តមក)	— ឈឹម - ក្រែសេម	៣០៦
កំណត់ទីនិងប្រវត្តិការណ៍		
ពិធីបុណ្យប្រគេនត្រុហ្មទានចំពោះព្រះសង្ឃ ៨៨ រូប . ដើលប្រារព្ធដាប់សញ្ញាប័ត្រ សាលាឧលី ជាន់ខ្ពស់	សមាគមមិត្តសាលាឧលី	៣១០

មួយឆ្នាំមាន ១២ សៀវភៅ ជំនៀងវិ ១៤៥,០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages

Bouddhisme et Christianisme (Conférence du Docteur André Migot)	M. RAY-BUC	244
La Lumière de l'Asie (suite) . . .	M. RAY-BUC	249
SANGAHADHARMA	Préah Vinayadhamma YOU-PONN	256

PARTIE LITTERAIRE

Message du Swami VIVEKANANDA	M.RAY-BUC	266
L'Education morale (suite). . . .	Préah moha PEUNG-PAM . .	272
Historique de la pagode de KEO NABARANSI dite ROKAR . . .	Préah moha KUY-HUOT . . .	280
Douze expressions proverbiales khmères	M.BOU-PO	287
Histoire de SAMKOK (suite)	Oknha NOU-KAN	296
Histoire du Royaume du Cambodge (suite	Oknha CHHIM-KRASEM . . .	306

NOTES ET CHRONIQUES

Fête de la distribution des prix aux 88 bonzes lauréats du concours de sortie de l'Ecole Supérieure de Pâli	Association des Amis de l'Ecole de Pâli	310

Prix l'abonnement annuel comprenant 12 numéros: 145$00

សព្វសាធុការតរដ្ឋាំថោះត្រីស័ក ៣. ស. ២៤៨៥

ក. ស. ១៩៤១

ឆ្នាំថោះត្រីស័កពុទ្ធសកាជ ខ្ញុំ ច័ត្តុ នព្វ ជាចដល់ ចត្វា

គ ស. ឯក នព្វ ប័ញ្ច ឯកា សង្ក្រាន្តខេមកចូលដល់ថ្ងាន ។

ពុទ្ធសាសនបណ្ឌិត្យ ប្រសិទ្ធិពរថ្វាយដូនសព្វថាន

ដល់ជាតិសាស្នាក្សត្រកល្យាណ នៃខ្មែរឲ្យបានក្សាន្តសុខា! ។

សូមព្រះបិយមហាក្សត្រ និរទុក្ខវិបត្តិនិរសោកា!

សូមក្រុមព្រះពជញ្ញាតិវង្សា មានមហេសក្ខាជោគសិរី! ។

សូមក្រុមរាជរដ្ឋាភិបាល ចាត់ការពិសាលកបស្ងួស្តី

បំពេញកិច្ចការគតផែនដី ឲ្យមានសេរីភ្លុំបីធុក! ។

សូមបណ្តាក្រសួកម្ពុជា មានជោគជយាចំរើនសុខ

សាមគ្គីឯកច្ឆន្ទជាប្រមុខ គ្រងរក្សាទុកវង្សវ័ន! ។

ពុទ្ធសាសនានឹងគ្រិស្តសាសនា

សន្ទិសិទលោកមីគូត៍

លោក ព័ឃ-ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យកុំពេញ

ប្រែពីទស្សនាវដ្តី «ហ្វ្រង់អាស៊ី» ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

ម្នាលភិក្ខុទាំងឡាយ ទុក្ខសមុទយអរិយសច្ចនោះ គឺតណ្ហាដែលនឹងធ្វើឲ្យសត្វបដិសន្ធិវិលចុះវិលឡើង កើតស្លាប់ៗកើត ហើយមានសេចក្តីត្រេកត្រអាលនឹងលោក: មានសេចក្តីស្រេកឃ្លានកាមលោក: មានសេចក្តីស្រេកឃ្លានភពកើត មានសេចក្តីស្រេកឃ្លានភពទៅមុខ មានសេចក្តីស្រេកឃ្លានអនិច្ចតាធម៌ ។

ម្នាលភិក្ខុទាំងឡាយ ទុក្ខនិរោធអរិយសច្ចនោះ គឺ កិរិយារំលត់បង់នូវតណ្ហា, ការលះបង់នូវតណ្ហា, កិរិយារួចផុតស្រឡះអំពីតណ្ហាទាំងអស់ ។

ម្នាលភិក្ខុទាំងឡាយ ផ្លូវប្រតិបត្តិដើម្បីនឹងឲ្យដល់នូវកិរិយារំលត់ទុក្ខនោះ គឺ សម្មាទិដ្ឋិ, សម្មាសង្កប្បៈ, សម្មាវាចា, សម្មាកម្មន្តៈ, សម្មាអាជីវៈ, សម្មាវាយាមៈ, សម្មាសតិ, សម្មាសមាធិ[1] ។

ហេតុដែលនាំឲ្យកើតឋាបនៅកន្លែងខ្លួនយើងនេះ គឺ តណ្ហា, តណ្ហានេះកើតមកអំពីអវិជ្ជា ធ្វើឲ្យបើងក័ន្ធច្រឡំយល់ថា លោកដែលមានសភាព

---

១ មហាវគ្គ ។

មិនពិតថាជាពតទៅវិញ ; ត្រូវតែយើងយល់ថា ទុក្ខនេះមិនមែនជាបណ្ដាំដែលត្រូវដោះស្រាយចំពោះបុគ្គលដោយបុគ្គលនេះអាចរកសេចក្ដីសុខឃើញទេ ។ ព្រោះសេចក្ដីសុខច្រើនបានផលជាទុក្ខចំពោះខ្លួនយើង ឬចំពោះអ្នកដទៃ សុខនោះប្រកបដោយចរគាត (fugitif) មានឧសថពុល ឬសភាពពាំងព្រ គឺសេចក្ដីខ្វាចក្រែងសុខនោះបាត់បង់ទៅវិញឬការទស្សនាទូវសេចក្ដីទុក្ខអកដទៃ ដែលនាំមិនឲ្យៈយើងសោយសេចក្ដីសុខចំពោះខ្លួនបានស្រួល ។ ទុក្ខនេះគេត្រូវពិចារណាទៅតាមបញ្ហាជាសាកល; ទុក្ខនេះមិនមែនទុក្ខចំពោះបុគ្គលម្នាក់ៗ គឺទុក្ខចំពោះសាធារណៈខ្លួទៅទាំងអស់ ព្រោះបើតាមពិតគឺជាទុក្ខសាកល ។

ចំពោះពួកបូរាណជាតិ, ការដែលនាំឲ្យស្មានភាពនោះកាន់តែលំបាកយល់ គឺដំនៀតែងវដ្ដសង្សារ (transmigration) ។ ដីវភាពបច្ចុប្បន្នរបស់យើង គឺមិនមែនជាការពិសោធន៍ប្រកបដោយអនិច្ចតា ដែលមានស្មានសូត្រជាផលនោះទេ ព្រោះដីវភាពនោះមានដំណើរជាប់គ្នាទៅកាន់ដីវភាពមួយថ្មីនឹងសេចក្ដីទុក្ខជាថ្មី ។ គេអាចយល់បានថាការខ្វះខ្វែងមានសារៈសំខាន់បំផុតនៃពួកបូរាណប្រទេស គឺមានបំណងចង់ចាកចេញពីវដ្ដដ៏លាមកនោះ ដែលនាំសត្វឲ្យវិលកើតស្លាប់ ចៀសវាងនូវសេចក្ដីកើតដើម្បីកុំឲ្យសោយនូវទុក្ខ ប្រាថ្នាឲ្យផុតស្រឡះពីទុក្ខនោះជាស្ថាពរ គឺព្រះនិព្វានជាអវសានផុតពីវដ្ដ ។

បើតាមពណ៌នាខាងលើនេះ, អ្នកដែលបានឃើញអាកប្បកិរិយាពីរយ៉ាងមានសភាពផ្ទុយគ្នាចំពោះជីវភាព គឺពួកបច្ចឹមជាតិពោលថាជីវភាពជាវត្ថុល្អ ហើយសេចក្តីទុក្ខគឺការបាត់បង់នូវជីវភាពនោះ, ពួកបូពាជាតិថា ជីវភាពជាវត្ថុអាក្រក់ ហើយសេចក្តីសុខគឺការលែងមកកើតទៀត ។ តាមយោបល់, ការយល់ផ្ទុយគ្នាដូចនេះ នាំឲ្យបានផលដ៏សំខាន់បំផុត គឺជាហេតុឲ្យពួកបូពាជាតិចាកចេញពីជីវភាពក្រៅ ពេញចិត្តនឹងជីវភាពក្នុងការស្អប់ខ្ពើមនូវកម្មកាត សម្ភារៈនេះជាហេតុឲ្យពួកបច្ចឹមជាតិមានហាមភាព, ការពេញចិត្តខាងកម្មកាតដែលកើតមកពីវិចារណធម៌ ព្រមទាំងផលដែលបានមកពីការពិចារណា ដោយចក្ខុប្រាសាទនឹងបញ្ញា, សភាវគតិនៃការរំលោភ, គ្មានសេចក្តីសន្តោស, ពេញចិត្តខាងការតស៊ូនឹងធ្លើសផ្លាម ។ យើងនឹងពណ៌នាហេតុមួយទៀតនៃនិន្នាការនោះតទៅខាងក្រោយ ។

ប្បាប់ពុទ្ធសាសនាដែលពណ៌នាពីទុក្ខនោះ នាំឲ្យគេយល់ថាពុទ្ធសាសនាមានលក្ខណៈលាមកបំផុតថា ពួកបូពាជាតិជាពួកអតេកិច្ចបុគ្គល (fataliste) ។ តើជាសភាពលាមកឬដោយបានពិសោធន៍ឃើញវត្ថុនោះមិនពិតគឺយើងដឹងពិតដោយខ្លួនឯងនូវបាបអកុសលទាំងនោះ មិនមែនបណ្តាយឲ្យបាបអកុសលនោះ ចូលមកលុកលុយក្នុងសន្តានចិត្តយើងទេឬបន្ទុំយើងដោយពណ៌នានូវហេតុដ៏សុខុមដែលមិនអាចយកមកពិសោធន៍

ឲ្យយើញជាក់ស្តែង តែដើម្បីនឹងតស៊ូបំផ្លាញសភាពលាមកនោះឲ្យសាបសូន្យ ? តើជាសភាពលាមក ឬគ្រែពេទ្យដែលពិនិត្យសមុដ្ឋាននៃបិហកភេត (tuberculose) ដំបៅ (cancer) ហើយរកមធ្យោបាយ ដើម្បីនឹងតស៊ូដើម្បីរំងាប់នូវភេតនោះ ? គឺជាសភាពផ្ទុយទៅវិញដោយបង្ហាញអាកប្បកិរិយាដូចខាងលើនេះ, គេទុកជាសោភណាភាព (optimisme) ដ៏ត្រៃលែង ដែលមានលក្ខណៈផ្ទុយគ្នានឹងការទទួលទុក្ខដោយខន្តីធម៌ ។

ព្រោះហេតុដូចនេះ, ពួកគ្រែជាង (គ្រិស្តសាសនិកជន) ជាពួកអតេកិច្ចបុគ្គលដែលយល់ដូចលោកសង្ឃខាងគ្រិស្តសាសនា លោកសាំងអូកស្តាំង ឬលុះថែរជាដើមថាដឿជាក់ត្រង់បុព្វាសនា (prédestination) ដែលយល់ថា សេចក្តីសុខនឹងទុក្ខមានអាទិទេពជាក់កំតែសម្រេចជាអនន្តកាល មុនកិច្ចដែលយើងប្រព្រឹត្តល្អនោះទៅទៀត ។ បើដូចនេះ តើមានប្រយោជន៍អ្វីក្នុងការតស៊ូនឹងទុក្ខ បើគ្មានសេចក្តីអនុគ្រោះពីអាទិទេព ។ ជាធ្លើអនុគ្រោះចំពោះបុគ្គលតាមទំនើងចិត្តរបស់លោក ដែលយើងមិនមានសមត្ថភាពអាចទទួលបានដោយការប្រព្រឹត្តល្អចំពោះខ្លួន,[1] យើង

---

១ សញ្ញាណនៃលទ្ធិលោ.សាំង-អាកុសស្តាំងចំពោះសេចក្តីអនុគ្រោះនឹងទទួលបានដោយមិនគិតស្រង់ស្ទើរតែគាខអត្ថបទ ក្នុងសៀវភៅ.បស់លោកប៊ែរក្លីភ័ (Père Pourrat) ឧទាហរណ៍ស្តីពីទុយអាលីតេក្រែបេត, ក្បាលទី ៤ ភាគ ២ ទំព័រ ២-៣ សៀវភៅមានចុះសេចក្តីអនុញ្ញាតឲ្យបោះពុម្ព ហើយជាកិច្ចតែវិគ្គានឹងសម្ថានតែពួកកាតូលិក ។

មិនអាចប្រែប្រួលបុណ្យកុសល ឬមានបំណងចង់ចូលដោយសេរីចំពោះសាសនាណាដែលយើងពេញចិត្ត ឬយើងមិនអាចដោះខ្លួន ។ ឯងចេញពីទុក្ខបាន ។ នេះជាទ្រឹស្តីមួយដែលនាំមនុស្សទៅកាន់អតិកិច្ចលទ្ធិ (fatalisme) ហើយគួរឲ្យធ្ងន់ពេកណាស់ ក្នុងរឿងនេះដោយថា ពួកគ្រិស្តសាសនិកជនពោលពាក្យបន្ទោសនិន្ទាដល់ពួកពុទ្ធសាសនិកជនទៅវិញ ! ចំណែកខាងពួកពុទ្ធមាមកជនមានសេចក្តីទុក្ខលំបាក ដោយជីវភាពក្នុងបច្ចុប្បន្ននេះ ដែលជាលទ្ធផលនៃកម្មកាពរបស់យើងពីដើមជាតិអតីត; យើងមិនអាចឲ្យអ្នកដទៃទទួលការទុក្ខត្រូវក្រៅពីខ្លួនយើង តែយើងអាចប្រែកែទូវាសនារបស់យើងទៅតាមបំណង ព្រោះយើងជាគ្រូលើវាសនារបស់យើងហើយ ។ ជីវភាពអនាគតរបស់យើង ជាផលនៃកម្មកាពដែលយើងធ្វើក្នុងបច្ចុប្បន្នដោយជីវភាពដ៏បរិសុទ្ធិ ព្រោះមិនបានធ្វើដល់សត្វលោកត្រមាំងផ្សាយចិត្តសប្បុរិសជុំវិញយើង, យើងអាចស្នាបនាបានសុវត្ថិភាពក្នុងអនាគតចំពោះខ្លួនយើងនឹងអ្នកដទៃ; ដោយជីវភាពរចនាត ។ ជាច្រើនជាតិ បំណងទៅកាន់សុគតិភាព យើងអាចចាកចេញពីវដ្តសង្សារទៅកាន់ព្រះនិព្វានបាន ។

(មានត)

វគ្គទី ៦

La Lumière de l'Asie

លោក ស៊ីរ - អេតវ៉ាំង អារណូលដ៍ តែង

លោកវ៉ាយ - ប៊ុក ក្រមការ ប្រែរៀបរៀង

(ត)

តែនាងបានគោរពយើង។ សូមគោរពនាងវិញ ដោយនាងមានចិត្តដ៏ថ្លៃថ្នូរមកកាន់យើង ហើយនាងបានស្គាល់នូវផ្លូវដោយសការគតិ ប្រៀបដូចជាសត្វព្រាបញីដែលហើរទៅកាន់សំបុកដោយសេចក្តីស្នេហា ។ នាងបានបង្ហាញថា សេចក្តីសង្ឃឹមនៅកណ្តាលមនុស្សគ្រប់រូបហើយកណ្តាលនៃដីវគាពគឺនៅក្រោមទុក្ខនៃធម្មៈរបស់មនុស្សទាំងអស់ ។ សូមសេចក្តីសុខស្ថិតនៅនឹងនាង ហើយវចនាដីវគាពនាងទៅកាន់សេចក្តីស្រួលសប្បាយចុះ! សូមឲ្យយើងបង្ហើយនូវកណ្តាលកិច្ចរបស់យើងដូចនាងបានបំពេញកណ្តាលកិច្ចរបស់នាង! អ្នកដែលនាងស្មានថាព្រះនោះសូមឲ្យនាងទទួលនូវតទាំងអស់នេះចុះ! ។

នាងសុជាតាទូលតបទៅព្រះបរមពោធិសត្វវិញថា "សូមព្រះអង្គបានសម្រេចនូវព្រះបរមសម្មាសម្ពោធិញ្ញាណ តាមព្រះពជបំណង" ហើយនាងក្រឡេកមើលដោយមុទុតាចិត្តទៅបុត្រនាងដែលលើកដៃតម្រង់

ទៅរកព្រះបរមពោធិសត្វ ; ប្រហែលជាដឹងដូចគាត់ដឹងក្តីជាច្រើនហើយ ជាអាការដែលយើងមិនអាចយល់បាន, ដៃគាត់នោះធ្វើអញ្ជលីគោរពព្រះបរមពោធិសត្វ ។ ព្រះពោធិសត្វទ្រង់តើនឡើង មានព្រះកាយពលបរិបូណ៌ ដោយបានសោយនូវព្រះក្រយាហារដ៏មានរសជាតិ ហើយទ្រង់គ្រាច់តម្រង់ទៅកាន់រុក្ខជាតិមួយដើមធំគឺដើមពោធិ (Bodhi) ១) ព្រឹក្សជាតិនេះតាំងពីនោះមក មិនបានស្ងួតស្រពោន នៅស្ងួតស្រស់ជាដរាប ទុកដូចជាកិត្តិយសរបស់ធម្មជាត ។ គឺនៅក្រោមម្លប់ព្រឹក្សជាតិដែលមានសាខាត្រសុំត្រសាយនេះហើយ ដែលព្រះអង្គបានសម្រេចនូវពុទ្ធនិស្ស័យយើញច្បាស់នូវធម៌អរិយសច្ច ; ក្នុងពេលនោះ ព្រះបរមគ្រូ បានជ្រាបច្បាស់នូវព្រឹត្តិការណ៍ចាំងប៉ុន្មាន ; ព្រោះហេតុដូចនេះព្រះអង្គបានធ្វើពុទ្ធដំណើរទៅខាងមុខ ដោយព្រះជំហានឈានយ៉ាងមាំមួនប្រាកដហើយប្រកបដោយអច្ឆរិយភាពគួរជាទីគោរព, មានព្រះតំណើរឈានទៅកាន់ព្រះពោធិព្រឹក្សនោះ ។ នុលោកសន្និវាសអើយ ! ចូរអ្នកធ្វើចិត្តឲ្យសប្បាយរីករាយចុះ ។ ព្រះបរមពោធិសត្វស្តេចបានយាងទៅដល់ក្រោមព្រះមហាពោធិហើយ, កាលណាព្រះអង្គទ្រង់បានគ្រាច់ចូលទៅក្រោមម្លប់ត្រឈឹងត្រឈៃ, ក្រោមឫសដែលមានសភាពសំយុងវែងនៃ

---

១ Pipal ficus religiosa គេបានឃើញក្នុងសម័យកុប្បន្ន នៅជិតគយា (ខេត្តប៉ិហារ) ។ ព្រឹក្សជាតិនេះហើយដែលព្រះសិទ្ធត្ថទ្រង់គង់នៅទៀបគល់រាត្រីសម្ងាត់ត្រាស់សម្មាសម្ពោធិញ្ញាណ ។

ព័ន្ធចុះមានសភាពមូលវែង ដូចជាសសរគ្រែមស្លឹកក្រូចជាតិនោះ ដែលធម្មជាតរចនាជាសភាពមូលមានពណ៌ខៀវស្រស់ភ្លឺ, ព្រះធរណីហាក់ដូចជាបានជ្រាបនូវព្រះទ័យព្រះអង្គ ឲ្យធ្វើឲ្យតណ្ហាជាតិដុះដូចជាសក់វែងអន្ទាយស្រស់ទឹងបុប្ផារីកស្គុះស្គាយនៅគ្រែមព្រះបាទព្រះអង្គ ។ មែកក្រូចជាតិទាំងនោះនុនទន់ពោរ ដើម្បីទឹងការពារព្រះរូបព្រះអង្គ ; ទេវតាគង្គាបានឲ្យបក់ផាយផាត់គន្ធពិដោរនៃបុប្ផាបទុមក្រអូបឈ្ងុយឈ្ងប់ពីស្ទឹងនោះ មានសភាពត្រជាក់ស្រួលសប្បាយ ។ មានវិនាសីសត្វដូចខ្លាទិន, ជ្រូកព្រៃទឹងប្រើសបើកក្អែកធំ ។ បែបដូចជាធ្លល់ តែរស់នៅជាសុខក្នុងអតិថេសសម័យថ្ងៃនោះ, ហើយឈរពីគុហា ឬគុម្ពោតព្រៃក្បែរមើលទៅព្រះភ័ក្ត្រព្រះពោធិសត្វ ។ ពស់ដែលមានពិសចាកចេញពីរន្ធត្រជាក់, ធ្វើក្បាលងើកចុះឡើងគោរពដល់ព្រះពោធិសត្វ ; មេអំបៅមានពណ៌គ្រប់យ៉ាងហិចហើរសន្ធឹងស្មាបពណ៌ខៀវផ្លែមេឃ ខៀវស្រស់ដូចស្លឹកឈើ ឬសុវណ្ណពណ៌ដើម្បីទឹងបក់ផ្ទឹតកុំឲ្យព្រះអង្គក្តៅ បក្សាសុំងទំលាក់ចោលនូវរំពាហើយស្រែកយំ ។ សត្វកណ្តុរនៅតាលវ័នមានរូបភាពគំនូរឆ្នៃតពណ៌ លោតពីមែកក្រូចមួយទៅមែកក្រូចមួយទៀត ហើយឈ្ងឹងក្អែកមើលចំទៅព្រះអង្គ ; បក្សាចាប (Oiseau tisserand) យំនៅមាត់សំបុក, សត្វបង្គួយរត់, បក្សាកូអិល (Koïl) ប្រហែលជាបក្សាកវែកបញ្ចេញសំឡេងពីរោះអស្ចារ្យ, លលកគ្រាំង

ហើរប្រទក្សិណដុំវិញព្រះអង្គ សូមីតែពួកទេវង្គសត្វ កំមានសណ្ឋានចិត្តសប្បាយរីករាយដែរក្នុងពេលនោះ ។ ព្រះឆវណ៌នឹងព្រះពាយបញ្ចេញសំឡេងពីរោះមួលតែមួយថា "ព្រះអង្គជាទីស្រឡាញ់ពេញចិត្តនៃសត្វលោក, ទ្រង់ជានិយ្យានិកបុគ្គល មានព្រះទ័យអាណិតអាសូរដល់សត្វលោក, ទ្រង់ដែលបានផ្តាញ់នូវទោសៈ, លោភៈ, តណ្ហា, សកាយទិដ្ឋិ វិចិកិច្ឆា, ទ្រង់ដែលបានយកព្រះទ័យព្រះអង្គធ្វើពលិកម្ម ដើម្បីប្រយោជន៍ផ្តាល់ព្រះអង្គនឹងប្រយោជន៍សត្វលោកទាំងអស់ សូមអាពាធនាទ្រង់និមន្តទៅកាន់អដ្ឋបាលនិគ្រោធចុះ ! លោកដែលប្រកបដោយទុក្ខ សូមថ្វាយពរសេពសាធុការ ដល់ទ្រង់ដែលនឹងបានត្រាស់នូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងកាលខាងមុខ ដែលស្រោចស្រង់សត្វនិកររួចផុតពីកំណាប់ដៃនៃតណ្ហា ! ឧទ្រង់ដែលជាទីគោរពដ៏វិសេស, សូមទ្រង់ស្តេចយាងទៅតស៊ូនឹងមារជាធំជាដរាបបានជោគជ័យ ! ឧត្តមាពាធដែលប្រកបដោយទេសនាលញ្ញាណ, ពេលវេលាដល់ហើយ នេះគឺពេលសន្ធិប្រកាសដែលសត្វលោកវង់ចាំ !" ។

ក្នុងពេលនោះ ព្រះបរមពោធិសត្វទ្រង់កំពុងគង់នៅត្រកាមមូលប៉ោធិព្រឹក្ស ។ ចំណែកមារាធិរាជបានត្រាបថា "ព្រះពោធិសត្វទ្រង់គង់នៅទីនោះ, ព្រះអង្គត្រូវដួយស្រោចស្រង់ នូវមនុស្សលោកឲ្យផុតពីតណ្ហាប៉ែនតណ្ហាហើយ, ពេលវេលាដែលព្រះអង្គត្រូវសែងរកធម៌ពិត

ដួយស្រែចស្រង់សត្វលោកដល់ហើយ" ដូច្នេះ ក៏បង្គាប់ទៅសេនា ទាំង
បាបអកុសល ។ ម៉្លេះហើយពួកអារក្សដែលជាសត្រូវនឹងបណ្ឌិត ព្រម
ទាំងធម្មជាតិក្តីស្វាង បានចាកចេញពីបាតាលមកប្រជុំគ្នា គឺ អរតិ, តុស្ណា
(តណ្ហា), ពគ: ហើយនឹងវេហ៍ពលនៃតណ្ហា, ឧត្តាស: (horreur)
អវិជ្ជា, កាម: (Concupiscence) ព្រមទាំងសេនានៃអន្ធការនឹងភ័យ,
ទាំងអស់ព្រួតគ្នាស្អប់ព្រះពោធិសត្វ ហើយរកឧបាយនឹងបំផ្លាញព្រះបារ
មីព្រះអង្គ; ហើយក្នុងចំណោមពួកបណ្ឌិតក៏គ្មានអ្នកណាអាចដឹងបាន តើ
ពួកអារក្សទៅស្ថាននរកនោះនឹងតស៊ូបៃបណា ដើម្បីនឹងបំផ្លាញព្រះបារ
មីព្រះពោធិសត្វ កុំឲ្យរកឃើញសច្ចធម៌នោះ ។ ដូនកាលបណ្តាលកេរវៀតា
ជាឫសេង្ឃ, កងពលនៃអារក្សទាំងនោះ បានអធិស្ឋានបង្កើតជាសត្វ
សូរផ្គរលាន់ភ្លៀងគឹកកងពេញមេឃ ហើយមានផ្លេកបន្ទោរក្តីចាំងចែង
ស្ទើរខ្វាក់ភ្នែក ប្រៀបដូចស្រួរសាលដែលពត់ក្រាយទៅក្នុងភ្លៃ មិនទាន់
ចង់ជាកណ្តាប់ គេយកទោះក្រាយពេញគាល័យមានពណ៌ក្រហម; ដូន
កាលប្រើឫទ្ធិបាយកលអធិស្ឋានជាសត្វសំឡេងពីរោះពីសារគួរឲ្យសវនា;
អារក្សទាំងនោះ បានប្រតិស្ឋានកណ្តាលស្ទឹកក្នុងសៀមសប់ នឹងសំឡេង
ចេញសម្លស្សទូរប្លែកមានលំអគួរឲ្យជាប់ចិត្ត ចេះប្រែងសំឡេងពីរោះ
គួរជាទីអស្ចារ្យគួរស្នេហាហើយខ្សឹបគ្នាពីកាមារម្មណ៍ផ្សេងៗ, សេចក្តី
ត្រែកត្រអាលគ្រប់យ៉ាង; ដូនកាលពួកសេនាមារនោះផ្តើមលលួចថ្វាយ

អំណាចទៅព្រះពោធិសត្វ; ដូនកាលប្រែទុយ្យកលសង្ស័យ, ពួកពលមារបានបង្ហាញឲ្យដាក់ចម្ងាស់ចំពោះព្រះភ័ក្ត្រព្រះអង្គថា សច្ចធម៌ជារបស់គ្មានសារប្រយោជន៍អ្វីឡើយ ។

សង្គ្រាមទាំងនោះ តើជាសភាពខាងក្រៅហើយអាចមើលឃើញដោយមំសចក្ខុ។ ព្រះពោធិសត្វតស៊ូក្នុងព្រះទ័យចំពោះមារនឹងពលមារទាំងនោះ? ។ ត្រូវពិចារណាដូចនេះ ខ្ញុំសូមពិណនារឿងនោះតាមដែលខ្ញុំបានឃើញចារកុកក្នុងគម្ពីរ ។

កិលេសទាំងដប់មកដល់ គឺពួកមិត្តដែលមានវិញ្ញាណភាពរបស់ស្តេចមារធិរាជ មិច្ចាទៅតា ។ ដំបូងគឺអត្តវាទ (ប្រែហៅជាអត្តានុវាទ), ឬបអកុសលខាងអត្តទដ្ឋភាព (le pêché de l'Egoïsme) ដែលមានចិត្តទស្សនាទៅកាន់រូបរបស់ខ្លួនដែលប្រតិស្ឋានក្តីឆ្នះចាំងដូចកញ្ចក់ នៅកណ្តាលចក្រវាឡហើយស្រែកថា: "អញ" ចង់ឲ្យលោកសន្ធិវាសនេះពោលថា: "អញ" ហើយចង់ឃើញសត្វលោកទាំងអស់វិនាស ហើយពោលថា: បើខ្ញុំនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ, ខ្ញុំត្រូវបោះបង់សត្វលោកឲ្យវង្វេងនៅទីងងឹតអន្ធការ; ខ្ញុំត្រាស់ដឹងតែខ្លួនខ្ញុំបានហើយ" ហើយបន្ទូលវិសីហនាទថា: "ខ្ញុំតើនឡើង, ហើយទតនូវសេចក្តីសុខក្នុងទេវលោក, សុខដែលគ្មានប្រែប្រួល, គ្មានកង្វល់, គ្មានសង្គ្រាម" ។ ព្រះបរមពោធិសត្វតបថា: "នែពលមារ! អ្នកឯងស្អប់

ខ្ញុំមយុត្តិធម៌ ប្រគាន់យកអយុត្តិធម៌ដែលឲ្យខ្ញុំក្តៅគោះស្ងួតគប់យ៉ាងវិញ; អ្នកចូរទៅបោកប្រាស់អ្នកស្នេហាចំពោះខ្លួនឯងឯណោះចុះ" ។

តមក វិចិកិច្ឆាមានមុខស្លឹតស្លាំង ជាអកុសលខាងពោលពាក្យសំដីឡកចំអក ស្រែកសំឡេងដូចកញ្ជ្រោរទៅកព្រះបរមពោធិសត្វថា "វត្តខាងអស់សុទ្ធតែមិនទៀង, ជាសភាពទទេគ្មានខ្លឹមសារ ហើយវិជ្ជាដែលបានមកពីសភាពសោះសូន្យដូច្នេះ ក៏គ្មានបានប្រយោជន៍អ្វីឡើយ; ព្រះអង្គស្ងែរកតែស្រមោល; សូមព្រះអង្គតើនឡើងហើយយាងចេញពីទីនេះ; មិនមានមធ្យោបាយអ្វីក្រៅពីទន្លីធម៌, មិនមានអ្វីជាទីសង្ឃឹមចំពោះមនុស្ស ដោយគ្មានអ្នកណាអាចបញ្ឈប់កងច្រកលោកដែលវិលជានិរន្តរកាលបាន" ។ ព្រះបរមពោធិសត្វឆ្លើយតបទៅនឹងវិចិកិច្ឆាវិញថា: "អ្នកមិនត្រូវមកវាល់នឹងយើងក្នុងរឿងនេះទេ, វិចិកិច្ឆាអ្នកបោកប្រាស! អ្នកជាបច្ចាមិត្ត ឬជានីវរណធម៌ដ៏សុខុមចំពោះមនុស្ស" ។

ពាលមានទើបតែ គឺអកុសលដែលប្រគល់ឫទ្ធានុភាពទៅលទ្ធិក្រៅសាសនាឬពាហិរសាសនា ជាលទ្ធិបកបដោយអវិជ្ជា គឺ សីលព្វតបរាមាស: ជាមេអាចបន្ធូរបន្ថយនូវប្រទេសជាច្រើនឲ្យមានសទ្ធាជ្រះថ្លាដោយចិត្តសន្តោសបោកសត្វលោក ឲ្យធ្វើពិធីធ្វេងៗ, សូត្រធម៌គប់យ៉ាងហើយជាអ្នកកាន់កូនសោខ្លួនឯង សម្រាប់បិទទ្វារនរក ហើយបើកទ្វារនៃស្ថានសួគ៌ ។

(មានត)

ព្រះវិន័យធម្ម យ្យរ - ប៉ុណ្ណ

ក្រុមជំនុំព្រះត្រៃយ៌បិដកនៅពុទ្ធសាសនបណ្ឌិត្យ

ទេសនាជាកិច្ចសម្ភោធនសង្គ្រួចនៃប្រទេសកម្ពុជា កាលពីថ្ងៃ ៨ កើតខែភទ្របទ

ឆ្នាំកុរនក្ញស័ក ព. ស. ២៤៩០

ឧមោ តស្ស កកវតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ អាត្មាភាពនឹងសំដែងអំពីសង្គហធម៌ ដែលជាធម៌សម្រាប់សង្គ្រោះដល់គ្នានឹងគ្នា ដូចតទៅនេះ :-

កិច្ចប្បទេយ្យដែលសម្រាប់សង្គ្រោះ ឬស្រោចស្រង់គ្នានឹងគ្នាឲ្យបានមូលមិត្រ ហៅថា សង្គហៈ។ នេះចែកចេញជា ៤ យ៉ាង គឺ :

១ – ទានៈ = ការចែករំលែកឲ្យ,

២ – បេយ្យវជ្ជៈ = ការពោលពាក្យពីរោះគួរឲ្យចាប់ចិត្ត,

៣ – អត្ថចរិយា = ការប្រព្រឹត្តិឲ្យជាប្រយោជន៍ដល់គ្នានឹងគ្នា,

៤ – សមានត្តតា = ភាពជាអ្នកតាំងខ្លួនឲ្យស្មើរចំពោះបុគ្គលផងគ្នា ។

សង្គហធម៌ទាំង ៤ នេះ តែងប្រមូលជនទាំងឡាយឲ្យមូលមិត្រគ្នាក្នុងសកលលោក ។ បើសង្គហធម៌នេះមិនមានហើយ សាមគ្គី គឺការព្រមព្រៀងមូលមិត្រគ្នា ក៏នឹងធ្លាយបែកបាក់ទៅពុំខាន ។ ព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរសង្គហធម៌នេះ ថាជាកិច្ចយ៉ាងប្រសើរបំផុតក្នុងលោក ។

ឯការសង្គ្រោះនេះ ជាប្រពៃណីរបស់បុគ្គលអ្នកស្ថិតនៅក្នុងទីជាបុព្វការី ដូចមាតាបិតាមានការៈខាងសង្គ្រោះបុត្តទាសកម្មករ; ឥស្សរជនមានព្រះពុទ្ធជាដើម មានការៈខាងសង្គ្រោះដល់ប្រជាពលរដ្ឋ ។

ជនដែលបានធ្វើសេចក្តីសង្គ្រោះចំពោះរូបណាមួយហើយ ជននោះឈ្មោះថាជាបុព្វការី, ជនជាបុព្វការីនោះ ក៏គួរទទួលយកកិច្ចដែលគេត្រូវធ្វើមកវិញ ។ សូម្បីតែជនអ្នកតូចមិនគិតប្រយោជន៍ផ្ទាល់ខ្លួន ហើយមានចិត្តមេត្តាសង្គ្រោះដល់ញាតិឯទៀតៗ ក៏គង់មានអ្នកដទៃគេពាប់អានជួយលើកតំកើងឲ្យទៅកាន់ទីជាធំបាន ។ ព្រោះហេតុនោះបានជាព្រះពុទ្ធជាម្ចាស់ ទ្រង់មានបំណងទឹងនាំសត្វឲ្យបានសំរេចគុណសម្បត្តិ គឺការតាំងខ្លួនត្រឹមក្នុងធម៌ ទើបទ្រង់សំដែងនូវសង្គហៈ។ ចាយនេះទុកជាផ្លូវដូចន័យដែលបានពោលមកខាងដើម ។ សង្គហៈនោះ រួមចូលដោយសង្ខេបជា ៤ គឺ : ទានៈ, បេយ្យវជ្ជៈ, អត្ថចរិយា, សមានត្តតា ដូច្នេះ ។

ទានៈ= ការឲ្យ នោះ ចែកចេញជា ២ យ៉ាង គឺឲ្យសំដៅចំពោះរូបបុគ្គលម្នាក់ៗ ហៅថា អសាធារណទាន ១, ឲ្យជាសាធារណ៍ទូទៅមិនសំដៅចំពោះរូបបុគ្គលម្នាក់ៗ ហៅថា សាធារណទាន ១ ។ មាតាបិតាឲ្យអាហារគ្រឿងប្រជាប់ស្បែកពាក់ ដល់បុត្តធីតាក្នុងវេលាដែលនៅកំឡោះក្រមុំ ឬឲ្យទ្រព្យសម្បត្តិធ្វើជាដើមទុន ឲ្យទីឋានផ្ទះសម្បែងក្នុងកាលដែលបុត្រធីតាចំរើនវ័យហើយ; ចៅហ្វាយនាយឲ្យគោគសម្ប័ទ

ដល់ទាសកម្មករ; ញាតិមិត្តចែកចាយគ្រឿងប្រើប្រាស់ទឹងកោជនាហារ ដល់គ្នាគ្នា ។ បុត្រធីតាដែលមានផ្ទះសម្បែងហើយ បានដួងកោជនាហារគ្រឿងស្លៀកពាក់ដល់មាតាបិតាដែលចាស់ជរា, ទាសកម្មករធ្វើការងារឬដួងរបស់ដល់ចៅហ្វាយនាំយជាហេតុសំដែងសេចក្តីចងមេត្រីទៅរកចៅហ្វាយនាយ; យ៉ាងនេះហៅថា អសាធារណទាន គឺបូជាឬតបគុណចំពោះរូបបុគ្គលម្នាក់ៗ ។

តស្សរជន ឬអ្នកមានទ្រព្យសម្បត្តិ ជាអ្នកមានចិត្តផ្សាយមេត្តាអាណិតអាសូរប្រណីដល់មហាជន ហើយលះបង់សេចក្តីកំណាញ់បរិច្ចាគទ្រព្យដួលគេឲ្យលើកថ្ម ជីកព្រែក ធ្វើស្ពាន ដើម្បីជាផ្លូវគមនាគមន៍បានស្រួល, សង់សាលា ដាំដើមឈើ ជីកស្រះ ដើម្បីជាទីសំណាក់អាស្រ័យដល់មនុស្សអាគន្តុក:, តាំងបង្កើតឬទំនុកបម្រុងធ្វើផ្ទះពេទ្យជាទីព្យាបាលរោគសត្វយ៉ាង, តាំងបង្កើតឬទំនុកបម្រុងសាលាបង្រៀនជាទីឲ្យចំណេះវិជ្ជាដល់កុមារកុមារី ។ យ៉ាងនេះហៅថាឲ្យឬសង្គ្រោះជាសាធារណៈមិនចំពោះរូបបុគ្គល ។ ទានមានសភាពយ៉ាងនេះ អាចឲ្យសេចក្តីសុខដ៏ធំទូលាយ ជាងឲ្យចំពោះរូបបុគ្គលម្នាក់ៗ ព្រោះពង្រីកមេត្តាចិត្តផ្សាយទៅក្នុងលោកធាតុមូល ។ ការឲ្យដោយសេចក្តីសង្គ្រោះឬដោយសេចក្តីផ្សាយមេត្តាចិត្តយ៉ាងនេះ ចាត់ជាបារមី១ ហៅថា ទានបារមី ។ ទានបារមីនេះព្រះពុទ្ធជាម្ចាស់ ធ្លាប់បានបំពេញបានសន្សំមកច្រើនជាតិ

តតគណនាឡើយ, លុះព្រះអង្គបានត្រាស់ហើយទ្រង់សំដែងនូវសង្គហ-
ទាននេះថាជាកន្លែងប្តូរដំណើរនៃសេចក្តីសុខក្នុងលោកនេះ នឹងលោកខាង
មុខ ។ ទាននេះជាសង្គហៈទី ១ ។

អ្នកឲ្យទាន បើគ្រាន់តែឲ្យប៉ុណ្ណោះមិនបានពោលពាក្យពីពេះគួរ
ឲ្យចាប់ចិត្តផងទេ, តែដែលឲ្យនោះ បើខុកជាច្រើនយ៉ាងណាក៏ដោយចុះ
ក៏ប្រាកដហាក់ដូចជាតិច, បើពោលពាក្យពីពេះគួរឲ្យស្រណោះចាប់ចិត្ត
ក័ស្តុកាដែលឲ្យនោះសូម្បីតិចតួចសោះ ក៏ប្រាកដហាក់ដូចជាច្រើន
ព្រោះធ្វើឲ្យកើតសេចក្តីស្រឡាញ់ពេញចិត្ត ធ្វើអ្នកដែលមានឧបការៈឲ្យ
ជាទីពាប់អានកែលែងឡើង ។ ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធ
ជាម្ចាស់ទ្រង់ចាត់បេយ្យវជ្ជៈ ថាជាសង្គហៈទី ២ ។

បេយ្យវជ្ជៈ ប្រែថា "ពាក្យដែលពីពេះគួរពេញចិត្តគួរចាប់ចិត្ត" ចែកចេញជា ២ យ៉ាង គឺ **បិយវាចា** = បានខាងវាចាពីពេះទន់ផ្អែមធ្វើអ្នក
និយាយឲ្យជាទីស្រឡាញ់របស់អ្នកស្តាប់ ១, **អត្ថសញ្ជាតវាចា** = វាចា
ប្រកបដោយប្រយោជន៍ ១ ។

បិយវាចា អាចនឹងទាញចិត្តមនុស្សក្នុងលោកឲ្យស្រឡាញ់រាប់រក
គ្នាបាន ដូចមាតាបិតាចរចានឹងបុត្រធីតាដោយពាក្យទន់ផ្អែម, ដូចហៅថា
កូន ថា នាង ដូច្នេះជាដើម ពាក្យនេះគួរឲ្យចាប់ចិត្តដល់បុត្រធីតាពន់ពេក
ធ្វើឲ្យកើតសេចក្តីស្រឡាញ់ ។ បុត្រធីតាដែលចេះនិយាយពាក្យពីពេះ

គួរឲ្យចាប់ចិត្ត, មាតាបិតាក៏ស្រឡាញ់ពេញចិត្ត ។ ជនជាឥស្សរៈដែលឈ្មោះសក្នុងការបដិសន្ធារៈ រោលពាក្យពាក់ព័ន្ធប្រស័យវួសវាយដល់អ្នកតូចទួរទៅគ្រប់ជាន់គ្រប់ថ្នាក់ រមែងធ្វើខ្លួនឲ្យជាទីស្រឡាញ់ពេញចិត្តរបស់មនុស្សទាំងឡាយ ចេះនិយាយដឹកនាំអ្នកតូចឲ្យមានគំនិតធ្វើកិច្ចការដោយសេចក្តីប្រឹងប្រែងហើយឲ្យសុចរិតបានផង ។ ឥឡូវនេះកូនឯង បើទុកជាមនុស្សនោះពីដើមមកធ្លាប់ឱនថ្នមខ្លួនគំនិតគ្នា ដល់ទៅមើលមុខគ្នាមិនត្រង់ក៏ដោយ កាលបើបានឮសំដីពីរោះញាយៗ ក៏អាចនឹងស្រាយកំហឹងនោះបាន ។ ដូចពាក្យបុរាណលោកពោលថា "សំដីជាឯកលេខជាគ្រោ" សំដីនេះលើកទុកជាទីមួយ ចំណេះវិជ្ជាទុកជាទីពីរ ។ អ្នកដែលមានចំណេះយ៉ាងណាក៏ដោយចុះ, ប៉ុន្តែបើពោលវាចាមិនជាទីគាប់ចិត្ត ជាវាចាគំរោះគំរើយមិនពេញចិត្តអ្នកស្តាប់, អ្នកមានចំណេះក៏ទៅជាតតមានគេពាប់រកទៅវិញ ។ ជនអ្នកខ្វត់ខ្វៃយចំណេះវិជ្ជាសោះទេ ប៉ុន្តែបើមានវាចាពីរោះ ចេះនុនលំនោនសុភាពពាក្យសាស្ត្រគួរឲ្យពេញចិត្ត. គង់មានអ្នកដទៃគេពាប់រកគេជួយសង្រ្គោះគេបូជា ឬឲ្យតែនេះនោះពុំខាន ។ ទាំងនេះក៏ដោយសារតែវាចាពីរោះ ។ ប៉ុន្តែមនុស្សម្នាក់ៗ មិនត្រូវធ្វើខ្លួនឲ្យតតំណេះវិជ្ជាទេ. ត្រូវតែខំប្រឹងរៀនសូត្រវិជ្ជាផ្សេងទៀតក្រៅពីធម៌ជាដរាប ។

អត្ថសញ្ជីតា វាចា = វាចាប្រកបដោយប្រយោជន៍នោះ សេចក្តីថាជនអ្នកស្រឡាញ់សេចក្តីសុខ - ចំរើន និយាយតែសំដីណាដែលប្រកប

ដោយប្រយោជន៍ ជាសំដីមានតម្លៃឲ្យអ្នកស្តាប់ចូលចិត្តចង់ស្តាប់, ហើយ
អ្នកស្តាប់នោះយកទៅធ្វើតាមប្រតិបត្តិតាមទៅ ក៏រមែងកើតធលកើត
ប្រយោជន៍ ។ សំដីយ៉ាងនេះ ចាត់ជាសំដីបានការ ជាសំដីអ្នកប្រាជ្ញ ។

ព្រះបរមសាស្តា ទ្រង់ទេសនាដឹកនាំវេនេយ្យសត្វ ឲ្យឃើញ
ដោយបញ្ញាថា យ៉ាងនេះជាធម៌ យ៉ាងនេះមិនមែនជាធម៌. ទ្រង់ពន្យល់
ឲ្យលះអកុសលធម៌ចេញ ហើយឲ្យសមាទានយកកុសលធម៌វិញ ឲ្យអាច
ហានវែកញែកក្នុងកុសលធម៌នោះ។ ទ្រង់បណ្តុះសេចក្តីពាប់អានរបស់មហា-
ជនទាំងគ្រហស្តទាំងបព្វជិតឲ្យមានកម្លាំងតាំងនៅអស់កាលដ៏យូរអង្វែង ។
ព្រះពុទ្ធសាសនា ដែលនឹងអាចតាំងនៅប៉ាន់ហូតមកដល់សព្វថ្ងៃនេះ
ក៏អាស្រ័យព្រះពុទ្ធវចា ជាវចាពិត ជាវចាមានប្រយោជន៍ ។ វចា
មានប្រយោជន៍នេះ ជាសំដីកាត់ថ្លៃពុំបាន ។ ការពោលតាក្យពីរោះ
យ៉ាងនេះចាត់ជាសង្គហៈទី ๒ ។

អត្ថចរិយា កិរិយាប្រព្រឹត្តិជាប្រយោជន៍ដល់គ្នានោះ អធិប្បាយថា
បើប្រសិនជាឲ្យ ឬនិយាយពាក្យពីរោះ ជាគុណចាប់ចិត្តចង់មេត្រីពុំបាន
យ៉ាងណាស្មើក៏ពិត, ប៉ុន្តែបើជាមនុស្សចេះតែមើលបំណាំគ្នាទៅវិញទៅមក
មិនប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា គឺថាមិនហុចប្រយោជន៍ឲ្យ មិន
ប្រាប់ឬបាយឲ្យកើតប្រយោជន៍ឲ្យ គ្រាន់តែឲ្យរបស់ប្លែកប្លាស់ នឹង
និយាយតាមការសម្លុតប៉ុណ្ណោះ ការជិតស្និទ្ធនោះ ក៏នឹងសាបរលោបទៅ

វិញបានដោយងាយ ។ ព្រោះហេតុនោះ អត្ថចរិយា ការប្រព្រឹត្តជាប្រយោជន៍ដល់គ្នានឹងគ្នានេះ ក៏ជាគុណយ៉ាងសំខាន់អាចយឹតយោងគ្នាឲ្យទៅកាន់សេចក្តីសុខ - ចំរើនតរៀងទៅបាន ។

ឯការយឹតយោងឲ្យប្រយោជន៍ដល់គ្នានឹងគ្នានោះ ដូចជាមាតាបិតាខ្វល់ខ្វាយធ្វើប្រយោជន៍ឲ្យបុត្រធីតា គឺទំស្វែងរកទ្រព្យសម្បត្តិ ចំណេះវិជ្ជាផ្តល់ឲ្យបុត្រធីតាតាមជាន់តាមថ្នាក់ ; ចំណែកបុត្រធីតាវិញ ក៏ជួយខ្វល់ខ្វាយក្នុងកិច្ចការរបស់មាតាបិតា គឺថាត្រូវចិញ្ចឹមលោកដោយការតបគុណ ។ ឥស្សរជនជួយធុរៈដល់អ្នកដែលត្រូវការពឹងពាក់ព្យាបាលទំនុកបំរុងឲ្យមានក្តីរុះយោះយសស័ក្តិថ្កាកដក្នុងទីប្រជុំជន, រមែងជាទីនិយមរាប់អានរបស់អ្នកពឹងពាក់, អ្នកដែលពឹងពាក់ទៀតសោត ក៏ត្រូវធ្វើកិច្ចការរបស់លោកឲ្យសមគួរតាមទំនងដែលលោកប៉ុនប៉ង, ធ្វើខ្លួនឲ្យលោកជឿជាក់នឹងទុកចិត្តបាន ឲ្យលោកស្រឡាញ់រឹងរឹតតែខ្លាំងឡើង ។

មិត្រសំឡាញ់ ក៏ត្រូវជួយខ្វល់ខ្វាយកិច្ចធុរៈគ្នាទៅវិញទៅមកដោយកម្លាំងកាយខ្លះ ដោយកម្លាំងវាចាខ្លះ កម្លាំងគំនិតខ្លះ កម្លាំងទ្រព្យខ្លះ ឲ្យសមតាមទំនងពុទ្ធភាសិតថា អត្ថក្ខិ ជាតក្ខិ សុខា សហាយា "មិត្រសំឡាញ់ពាំងឡាយ, កាលបើធុរៈកើតឡើង, រមែងជួយនាំឲ្យបានសេចក្តីសុខ" ទើបមានមេត្រីចិត្តរាប់រកគ្នាយ៉ាងស្និទ្ធ ។ សូម្បីញាតិក៏ដូចគ្នាត្រូវតែជួយធុរៈគ្នា តាមលំដាប់ញាតិ, មិនចាំបាច់ញាតិសាច់សាលោហិត

ដឹតគ្នាទេ ឲ្យតែរួមជាតិជាមួយគ្នា ក៏ត្រូវតែជួយផ្តល់ប្រយោជន៍ឲ្យតាមសមគួរ, យ៉ាងនេះទើបពប់រកគ្នាទៅពេលមុខបានស្រួលល្អ ។ ឯការដឹកនាំកូនផ្លូវធម៌ទៀតសោត ក៏ត្រូវបបួលគ្នាឲ្យបរិច្ចាគជនធានធ្វើកុសលដើម្បីនឹងញ៉ាំងគ្នីគ្នាឲ្យស្រុះស្រួលគំនិតក្នុងការបុណ្យនោះ ឲ្យចេះស្និទ្ធស្នាលគ្នាតទៅ ។ ដូចជនអ្នកមានសីលធម៌ល្អអាចដឹកនាំអ្នកឥតសទ្ធាឲ្យមានសទ្ធា, ឥតសីលឲ្យមានសីល, កំណាញ់ស្វិតស្វាញឲ្យមានចិត្តទូលាយបរិច្ចាគទ្រព្យធ្វើបុណ្យ, អ្នកល្ងង់ខ្លៅ ឲ្យមានប្រាជ្ញ ។ យ៉ាងនេះឈ្មោះថាប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា ពប់ថាជាសង្គហៈទី ៣ ។

សមានត្តតា កាពជាអ្នកតាំងខ្លួនឲ្យស្មោះស្មើទៅរកបុគ្គលផងគ្នានោះអធិប្បាយ. បុគ្គលសូម្បីគ្រាន់តែឲ្យ ឬនិយាយពាក្យពីរោះត្រមតាំងដួយខ្លួនល់ខ្លាយធ្វើប្រយោជន៍ ឬណែនាំប្រាប់ប្រយោជន៍ដល់គ្នានឹងគ្នាតែប៉ុណ្ណោះ, តែបើមិនចេះរៀបចំខ្លួនប្រាណឲ្យសមតាមអត្តភាព គឺមិនស្គាល់ធំ-តូច-ខ្ពស់-ទាប ជាអ្នកប្រកាន់មាន:ក្តេងក្តាង មើលងាយគេធ្វើឫកពាក្រអឺតក្រអោងយ៉ាងនេះទេ, សេចក្តីពប់អានគ្នា ក៏នឹងសាបសោបទៅវិញ ។ លុះតែអាស្រ័យនូវសេចក្តីស្មោះស្មើ ឲ្យសមតាមអត្តភាពខ្លួនផង ទើបសេចក្តីពប់អាននោះនឹងមានកម្លាំងអាចតាំងនៅយូរអង្វែងទៅបាន ។

ជនអ្នកមានវ័យតិច សូម្បីវិសេសជាងដោយយសសក្តិ ដោយអំណាច ដោយភោគសម្ប័ទ ដោយបរិវារប៉ុណ្ណា ក៏ត្រូវតាំងខ្លួនឲ្យសមតាមបែប

ភាពយស្សកិដាដើមប៉ុណ្ណោះ គឺត្រូវតែគំនាប់គាប់គួរដល់ដន្ធអ្នកមានវ័យចំរើនជាង២ខន, ពីដើមមកធ្លាប់រាប់អានយ៉ាងណា· ខាងក្រោយមកក៏ត្រូវរាប់អានយ៉ាងនោះ ។ ដនទាំង២ឡាយដែលបានទទួលសេចក្តីគោរពគោតក្រែងយ៉ាងនេះហើយ ក៏រមែងស្រឡាញ់ពេញចិត្ត សំដែងអាការពប់រកទៅវិញ ។

ពួកញាតិដែលមានវ័យស្មើៗ គ្នាទៀតសោត ក៏ត្រូវសំដែងសេចក្តីរាប់អានគ្នាដោយពេញចិត្តចំពោះញាតិផងគ្នា, ទោះនិយាយស្តីក្តី ធ្វើការងារអ្វីក្តី ដេក ដើរ ឈរ អង្គុយក្តី ក៏ត្រូវបែព្រឹត្ត ត្រូវធ្វើ ត្រូវនិយាយស្តីឲ្យសមតាមអត្តភាពរបស់ខ្លួន ។ ញាតិដែលជាអ្នកធំមានមេត្តារាប់អានញាតិដែលជាអ្នកតូច ស្និទ្ធស្នាលគ្នាទៅវិញទៅមក ជួយគ្នាទៅវិញទៅមក. ដើម្បីគាំពារវង្សត្រកូលរបស់ខ្លួនឲ្យចំរើន; សេចក្តីសាមគ្គីនៃញាតិនេះ រមែងញុំាងសេចក្តីសុខឲ្យកើតមានដល់ទៅសព្វគ្នា; ដូចមានពុទ្ធភាសិតថា ឩភោ ច សុខមេធតិ ញាតីនញ្ច សមាគមោ "អ្នកទាំងពីរដែលមានមនុស្សមកនៅរួមជាមួយហើយ រមែងញុំាងសុខឲ្យកើត ដូចជាការជួបជុំនៃពួកញាតិដូច្នោះដែរ" ។

មួយទៀតជនដែលអាស្រ័យនៅក្នុងគណៈ ដូចជាភិក្ខុសង្ឃដែលអាស្រ័យនៅជាមួយគ្នាបាន ក៏ដោយអំណាចមានធម៌សើគា ។ បើមិនដូច្នោះទេ ក៏មិនអាចនឹងរក្សាសាមគ្គីឲ្យគង់នៅបានឡើយ ។ ព្រោះ

ហេតុនោះ បានជាលោកដែលជាប្រធានទៃនគណៈ ត្រូវបំភ្លឺដើម្បីឲ្យមនុស្សទាំងឡាយក្នុងគណៈ ទិយមដើរតាមសណ្តាប់ធ្នាប់របស់គណៈ កំចាត់បង់នូវមនុស្សដែលល្មើសចេញ ហើយរក្សាសាមគ្គីរបស់គណៈឲ្យតាំងនៅមាំមួនឡើង ។

សមានត្តតានេះ បើធ្វើឲ្យសមដល់ហេតុផលរបស់បុគ្គល ឬគណៈ ហើយ រមែងឃើតយោងបុគ្គលនឹងគណៈនោះ ឲ្យតាំងនៅកងសាមគ្គីធម៌យ៉ាងជាតស្ទឹងបាន ។ នេះចាត់ជាសង្គហៈទី ៤ ។ សំដែងមកក្នុងសង្គហធម៌ទាំង ៤ ចប់តែប៉ុណ្ណេះ ។

កាលបើចប់ធម៌ទេសនាហើយ សូមផ្សាយចំណែកកុសល ដល់អស់លោក-អ្នកទាំងឡាយ ដែលស្ថិតនៅក្នុងកម្ពុជរដ្ឋទាំងមូល សូមឲ្យបានសេចក្តីសុខចំរើនតរៀងទៅ ! ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយេប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្ពេបិ ចាណិនោ ។

សព្វសត្វទាំងឡាយដែលដល់ហើយនូវសេចក្តីទុក្ខ ក៏ឲ្យបាត់ទុក្ខទៅ ! ដែលដល់នូវភ័យ ក៏ឲ្យបាត់ភ័យទៅ ! ដែលដល់នូវសេចក្តីសោក ក៏ឲ្យបាត់សោកទៅ ! (ដោយអំណាចធម្មទេសនានេះ) ។

លោកស្វាមី វិវេកានន្ទ

Message de Swami Vivekananda

ដកស្រង់ពីទស្សនាវដ្តី ហ្ស៊ង់អាស៊ី ថ្ងៃ ១៩ វិច្ឆិកា ១៩៤៦

លោករ៉ាយ-ចុកក្រែមការ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

ឧអ្នក ! ជាទេពនិមិត្តនៅលើប្រថពី, អ្នកទទួលនូវបាបអកុសល, បាបនេះហើយដែលគេសន្មតហៅសភាពនៃមនុស្ស គឺជាទណ្ឌកម្មដែលធម្មជាតិមនុស្សត្រូវឆ្លងទទួល ; គ្រោកឡើងអ្នក, ឧអ្នកដែលជាពូជសត្វសិង្ហ ! ត្រូវអ្នកលះចោលនូវការចាប់អារម្មណ៍ថាជាពួកចៀមនោះចេញឲ្យស្រឡះ, អ្នកជាមនោធម៌ប្រកបដោយអមត្តភាព ជាមនោធម៌មានសេរីភាពវិសេស ហើយមានលក្ខណៈជាអនន្តកាល (éternel); អ្នកមិនមែនជាវត្ថុធាតុឬរូបធាតុទេ ។ ឯវត្ថុធាតុត្រូវនៅក្រោមបង្គាប់បញ្ជាអ្នក មិនមែនអ្នកត្រូវបំរើវត្ថុធាតុនោះទេ ។

បើអ្នកមានអចលនសទ្ធាចំពោះអាទិទេពចំនួន ៣៣ លាន អង្គដែលមានពណ៌នាក្នុងលទ្ធិបូរាណនិងអាទិទេពឯទៀត ដែលបរជាតិបានបញ្ជូនមកក្នុងប្រទេសអ្នក, ហើយអ្នកគ្មានសទ្ធាចំពោះខ្លួនអ្នក, អ្នកមិនអាចរកផ្លូវស្រោចស្រង់ខ្លួនអ្នកបានឡើយ ។ ឲ្យអ្នកមានចិត្តសទ្ធាមួនមាំចំពោះខ្លួនអ្នកហើយអ្នកឈរឲ្យសិប់ត្រង់ពីលើសទ្ធានោះ ។

ប្រវត្តិសាស្ត្រសាសនាលោក គឺប្រវត្តិសាស្ត្រនៃបុគ្គលណាដែលមានសទ្ធាចំពោះខ្លួនដោយខ្លួនឯង ។ គឺចិត្តសទ្ធានោះឯងដែលអាចញ៉ាំងពលភាពនៃអាទិទេវតា (Divinité) ឲ្យកើតឡើងចំពោះអ្នក ។ ដោយការអប់រំនេះ ឋានជាអ្នកធ្វើការអ្វី ។ ឋានសម្រេចដូចបំណងទាំងអស់ ។ អ្នកដែលបរាជ័យក្នុងកិច្ចការទាំងនោះ ព្រោះតែអ្នកមិនបានព្យាយាមបញ្ចេញឲ្យត្រាប់គ្រាន់បរិបូណ៌នូវពលភាពខាងក្នុង ដែលមានមហិទ្ធិឫទ្ធិអស្ចារ្យ ។ បើកាលណាមនុស្សម្នាក់ ។ ឬប្រជាជាតិមួយ ។ លែងមានសទ្ធាចំពោះខ្លួន មនុស្សឬប្រជាជាតិនោះ ។ ត្រូវខ្វះលមរណភាពក្នុងពេលនោះ ។ ព្រោះហេតុដូចនេះ ត្រូវជឿជាក់ចំពោះខ្លួនសិន រួចសឹមជឿអាទិទេព (Dieu) ជាខាងក្រោយ ។

អ្នកណាគ្មានជឿជាក់ចំពោះខ្លួនដោយខ្លួនឯង គេទុកអ្នកនោះជាពួកមិច្ឆាទិដ្ឋិ (Athée) ។ សាសនាពីបូរាណកាលមក ពោលថា អ្នកណាមិនជឿអាទិទេព អ្នកនោះជាមិច្ឆាទិដ្ឋិ ។ សាសនាសម័យថ្មី ពោលថា ពួកមិច្ឆាទិដ្ឋិ គឺបុគ្គលមិនមានជំនឿចំពោះខ្លួន ។

សំឡេងទ្វីបអាស៊ី ជាសំឡេងសាសនា, សំឡេងទ្វីបអឺរុប ជាសំឡេងនយោបាយ ។

ប្រទេសឥណ្ឌានឹងស្ថិតនៅក្នុងអមតភាពបាន លុះត្រាតែប្រទេសនេះនៅតែព្យាយាមស្វែងរកអាទិទេពតទៅអនាគត ។

ខ្ញុំមិនចង់ពោលថា ការពិសោធន៍ខាងផ្លូវនយោបាយ និងសង្គម មិនជាការខានពុំបាន; តែដែលខ្ញុំយល់ចំពោះបញ្ហានេះ ហើយដែលខ្ញុំមានប្រាថ្នាចង់ឲ្យចិត្តអ្នកជ្រាបច្បាស់នូវរឿងខាងលើ គឺថាចំពោះបញ្ហានេះត្រូវចាត់មកតឹមថ្នាក់ទីពីរ, ចំណែកខាងសាសនាជាវត្ថុសំខាន់បំផុត ត្រូវកប់ជាថ្នាក់ទីមួយ ។

គ្មានបុគ្គលណានឹងអាចទប់ទល់នូវប្រទេសតណ្ហាបានឡើយ; ប្រទេសនេះនឹងលែងនិន្ទាលក់ទៀតហើយ; មិនមានបរាជាតិមហាអំណាចណាមួយ អាចមានពលភាពធ្វើឲ្យប្រទេសនេះខន់ខ្សោយថយទៅក្រោយវិញបាន ព្រោះយុគ្គបានក្រោកឈរជាន់ដើងស៊ប់នៅលើផែនដីហើយ ។

បើអ្នកស្វែងរកសង្គហធម៌ចំពោះអ្នក នឹងទៅស្វានរក ។ អ្នកត្រូវស្វែងរកសង្គហធម៌ចំពោះបុគ្គលដទៃ ហើយបើពោះបីអ្នកធ្វើការប្រយោជន៍ជាសាធារណៈ, អ្នកត្រូវទៅស្វានរក, ក៏អ្នកបានផលប្រយោជន៍ច្រើនជាងទៅស្វានសួគ៌ ដោយការស្វែងរកសេចក្តីសង្គ្រោះចំពោះខ្លួន ។

ជាពណ៌ជនជាតិមនុស្សទាំងឡាយនាក់ នឹងត្រូវទទួលអនិច្ចកម្មដោយទុព្ភិក្ខភ័យនឹងអវិជ្ជា, ជាពនោះ ខ្ញុំទុកមនុស្សម្នាក់ៗ ជាអ្នកក្សត់ បើអ្នកនោះត្រូវការចិញ្ចឹមជីវិតដោយប្រសើយគ្មានន័មនុស្សទាំងនោះ ធ្វើចិត្តព្រងើយកន្តើយមិនរវល់កងរឿងនេះ ។

ដកបណាសុនខនៅប្រទេសខ្ញុំអត់ឃ្លានគ្មានអាហារនឹងបរិភោគ, ដកបនោះសាសនាខ្ញុំខ្ជូនខ្ញុំថា ត្រូវតែចិញ្ចឹមនូវសុនខនោះ ។

តើអ្នកត្រូវទៅណា ដើម្បីនឹងស្វែងរកអាទិទេពឲ្យឃើញ? មិនមែនអាទិទេពទេឬ ពួកពុតត: (ឧត្តរទ្វីប), វេទនាច្បាប្ត (រហេម-រហាម), ទុរពល (ខ្សោយ)? ការបម្រុងហេតុដូចម្តេចបានជាមិនទៅបន់ឲ្យជួយពួកទាំងនោះហ្នាះ? ហេតុដូចម្តេចបានជាទៅដឹកអណ្តូងទៅមាត់ទន្លេគង្គា (Ganga) វិញ? ត្រូវអ្នកពុកពួកទាំងប៉ុន្មាននោះជាអាទិទេពរបស់អ្នក, (១) ផ្តងចិត្តគិតទៅអ្នកទាំងនោះ ធ្វើការប្រយោជន៍អ្នកទាំងនោះ បន់គ្រប់ទីកពតឲ្យឧបត្ថម្ភអ្នកទាំងនោះ អាទិទេពមុខជានឹងបង្ហាញផ្លូវអ្នកមិនខាន ។

សាសនាស្ថិតទៅជិតសច្ចធម៌នៃបរលោក· ដូចជាវិទ្យាសាស្ត្រខាងជាតុនិយម (chimie) នឹងខាងធម្មជាតិនិយម (Sciences Naturelles) ឯទៀតស្ថិតទៅជិតសច្ចធម៌នៃលោកបច្ចុប្បន្ន ។

បើប្រសិនជាអ្នកនឹងដកយកសាសនាចេញពីសង្គមមនុស្សជាតិ តើអ្នកនឹងឃើញទៅសល់អ្វីតទៅទៀត? ទៅសល់តែមនុស្សពាលសាមាន្យ

---

๑ កុំឲ្យយល់ថា: "អ្នក" ជាបុរសគុណតាម ជាចំអកហង្គារនោះទៅឡើយ តែត្រូវយល់តាមអត្ថជាពិសេសថា: ឧនុស្សទាំងអស់ ចំពោះបុគ្គលនីមួយ ។ ជាអង្គភាពនៃមួយចំហៀងអាទិទេពដែលស្ថិតខាងក្នុង (Une parcelle de la divinité) ហើយត្រូវជួយឧបត្ថម្ភអ្នកទាំងនោះ ទើបទៅដល់អាទិទេពបាន ។ កំណត់អ្នកបកប្រែ ។

(តិរច្ឆានមនុស្ស) សេចក្តីត្រែកត្រអាលក្នុងកាមគុណ មិនមែនជាវត្ថុបំណងរបស់អារ្យធម៌នៃមនុស្សជាតិទេ គឺគតិបណ្ឌិត (ជ្ញានប្បញ្ញា) ជាវត្ថុបំណងនៃដីវភាពទាំងអស់ ។

វត្ថុបំណងសំខាន់នៃមនុស្សទាំងអស់, បឋមបទនិងអវសានបទនៃសាសនាទាំងអស់វេញ្រមូលចូលទៅតែន័យមួយបែប គឺឯកភាពមូលចូលទៅនឹងអាទិទេពប្តូរបូរមូចូលទៅកាន់អាទិទេវគតិ ដែលស្ថិតនៅក្នុងធម្មជាតិ្រកបដោយសច្ចធម៌នៃមនុស្សនីមួយ។ ដែលមានលក្ខណៈដូចគ្នាខាងលើ ។

បើតាមពិត តើសាសនាអាចបំពេញនូវឧត្តមគតិបានឬ? សាសនាអាចធ្វើកិច្ចការទាំងនេះបាន ។ សាសនានេះតែងនាំមក្រគល់ឲ្យមនុស្សជាតិនូវដីវភាពជាទីយកាល ។ គឺសាសនានេះឯងដែលរចនាមនុស្សឲ្យមានស្ថានភាព, លក្ខណៈ ដូចសម័យបច្ចុប្បន្ន ហើយធ្វើមនុស្សឲ្យ្រប្រែទៅជាអាទិទេពក្នុងកាលជាអនាគត ។ នេះជាកិច្ចដ៏្រប្រសើរដែលសាសនាអាចបំពេញបាន ។

ឧត្តមគតិនៃសាសនានឹងគណៈទាំងអស់ គឺមូលចូលទៅក្នុងឧត្តមគតិតែមួយ្រប្រាថ្នានឹងទៅកាន់សេរីភាព ្រពមទាំងបាត់បង់ពីសេចក្តីទុក្ខ ។

ខ្ញុំ្រប្រកាសថា មិនចាំបាច់ទៅបំផ្លាញសាសនា ដើម្បីនឹងឲ្យសម្រេចនូវសុភមង្គលខាងសង្គមហិណានោះទេ ហើយថាសភាវៈនៃសង្គមនោះអាច

ស្ថិតស្ថេរនៅបាន ដោយជ្រាសចាកសេចក្តីបៀតបៀនដល់សាសនា ។ រឿងនេះគឺមកពីមិនបានយកសាសនាទៅអនុវត្តន៍ក្នុងសង្គម តាមសាសនាដែលគួរការ ។

ក្នុងប្រទេសនីមួយៗ បើមានបុគ្គលដែលមានចិត្តានុភាពដូចសត្វសីហៈ តែដាច់ពីនោក (គឺសត្វសីហៈដែលបានកាច់បំបាក់ខ្លួនវ៉ែកក់ខ្លួនបាន, យល់ឃើញច្បាស់ជ្រាកដដោយបញ្ញាចក្ខុនូវអនន្តមាត្រ (Infini) ដែលអាត្មនបានធ្លើដំណើរទៅដល់ព្រហ្ម (Brahman), ហើយខ្ជាក់ចោលស្រឡះពីសន្តានខ្លួនគ្រឿងអាមិសនឹងអំណាចព្រមទាំងកិត្តិយស) ពិតជាលោកនឹងរំដួលខ្លាំង ។

បើតាមពិត, ខុត្តមគតិរបស់ខ្ញុំគឺគ្រាន់តែយកពាក្យពីរបីម៉ាត់ មកពន្យល់ក៏អាចជ្រាបបានដូច្នេះ : ទេសនាចំពោះមនុស្សជាតិក្នុងលោកសន្និវាសអំពីភាពអាទិទេព ដែលស្ថិតនៅក្នុងខ្លួនគ្រប់ៗគ្នា, ហើយបង្ហាញនូវមធ្យោបាយ ដែលអាទិទេពនោះធ្លើជាតុកិច្ចឲ្យច្បាស់លាស់ក្នុងការចលនានៃជីវភាពនីមួយ ។

អ្នកណាខាំងអស់ ដែលធ្លើពលិកម្មខ្លួនដោយខ្លួនឯងចំពោះព្រះអង្គ, អ្នកអស់ខាំងនោះ អាចធ្លើប្រយោជន៍ឲ្យពិភពលោកនេះបានច្រើនជាងអ្នកដែលធ្លើឫកពាភាំងជាអ្នកបំរើព្រះអង្គតែមតែសំដីពោលប៉ុណ្ណោះ ។

(មានត)

ការបណ្តុះនិស្ស័យ

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាជាតិរងវត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាន្តរក្ស ប៊ូ-ប៊ូ ភៅពុទ្ធសាសនបណ្ឌិត្យ ពិនិត្យកែ

(តមក)

ឧទ្ទាយបណ្តុះនិស្ស័យទី ១

និស្ស័យជាអ្នកល្អ

អស់លោកប្រុសស្រីទាំងឡាយ! មនុស្សល្អគឺនរណា? បើលោកអ្នកចូលចិត្តថាមនុស្សល្អ គឺអ្នកមានទ្រព្យ, មានយសសក្តិ និងមានត្រកូលខ្ពស់ហើយ ក៏មុខជាមានគេជំទាស់ឋាន ។ ព្រោះមនុស្សខ្លាល់ក្រ, មនុស្សគ្មានយសសក្តិនិងមនុស្សត្រកូលទាប ជាមនុស្សល្អក៏មានដែរ ។ មនុស្សស្អុកស្តម្ភមាំមួន មានយសសក្តិ និងមនុស្សត្រកូលខ្ពស់ តែជាមនុស្សអាក្រក់ក៏មានដែរ ។

បើតាមពិត នរណាក៏ដោយ ឲ្យតែជាមនុស្សមានសេចក្តីល្អដំកល់ខ្លួននៅក្នុងធម៌របស់អ្នកល្អ, ប្រព្រឹត្តតាមធម៌ដែលជាសម្បត្តិរបស់អ្នកល្អហើយ ក៏ចាត់ជាមនុស្សល្អឋានទាំងអស់ ព្រោះអ្នកល្អនោះតែងតែប្រព្រឹត្តល្អត្រឹមត្រូវដោយត្រៃទ្វារ ទាំងប្រកបដោយសិល្បវិទ្យាការជាគ្រឿងតែងឲ្យទៅជាមនុស្សល្អ ។ កាលបើមិនមានសេចក្តីល្អជាសម្បត្តិនៅ

កង់ខ្លួនហើយ សូម្បីជាមនុស្សប្រុសល្អ កើតកង់ត្រកូលមហាសាល ឬជាមនុស្សជាន់ណាក៏ដោយ ក៏ជាមនុស្សល្អមិនកើត ហើយមិនជាទីស្រឡាញ់របស់អ្នកប្រាជ្ញផង មិនខុសគ្នាអំពីផ្កាចាខ្ទើយ ព្រោះផ្កាចាមានតែពណ៌ល្អប៉ុណ្ណោះ ឥតក្លិនទេ ទើបមិនជាទីនិយមរីករាយរបស់មនុស្សទូទៅ ។

សូមចាំកុំភ្លេចថា មិនមែនផ្កាឈើ មិនមែនពេជ្រនិលចិន្តាមណី មិនមែនអាករណៈដែលថ្លៃថ្លា មិនមែនគ្រឿងប្រដាប់ប៉ាន់ដទៃទេ ដែលសម្រាប់ធ្វើឲ្យយើងល្អនោះ, សម្បត្តិរបស់អ្នកល្អផ្សេងៗ ដោយឡែកទៀត ។ ប្រសិនបើយើងធ្វើខ្លួនយើងឲ្យជាមនុស្សល្អមែនៗ យើងត្រូវតែមានសម្បត្តិមនុស្សល្អ ។ សម្បត្តិមនុស្សល្អមែងជាសិរីនៃត្រកូលដូចគន់ជ័យជាគ្រឿងសំគាល់នៃជ័យជំនះដូច្នោះ ។ ស្ត្រីមានស្នាមីដែលសម្បូរដោយសម្បត្តិជាមនុស្សល្អ រមែងមានអំណាចស្មើនឹងស្មើព្រះសុរិយាដែលភ្លឺរុងរឿងក្នុងអាកាសវេហាស៍, សូម្បីបុរសមានភរិយាដ៏ប្រកបព្រមដោយសម្បត្តិជាអ្នកល្អ ក៏ជាអ្នកហ៊ឺហានឹងត្រជាក់ត្រដំដូចជាពន្លឺនៃនិសាករះក្នុងរាត្រីកាល ។ ๙

មនុស្សថោកទាប មនុស្សគ្មានយសស័ក្តិនឹងមនុស្សត្រកូលទាបដែលមានឧស្សាហ៍ជាអ្នកល្អ ប្រសើរជាងមនុស្សស្តុកស្តម្ភ មនុស្សមានយសស័ក្តិនឹងមនុស្សត្រកូលខ្ពស់ ដែលមានឧស្សាហ៍ថោកទាបនោះទៅទៀត ។

ពិតមែន យើងតែងនិយមហាន:ជាអ្នកស្តុកស្តម្ភ ទាំងរាប់អានយសសក្តិ ព្រមទាំងបូជាគ្រកូលខ្ពស់ ព្រោះរបស់អម្បាលនេះ អាចឲ្យគុណប្រយោជន៍ដល់គឿនកក្តិផងគ្នាជាច្រើន តែបើម្ចាស់របស់ជាមនុស្សមានវិស្សុយថោកទាបហើយ សូម្បីមានទ្រព្យច្រើន រុងរឿងដោយយសសក្តិកើតក្នុងត្រកូលខ្ពស់ក៏ដោយ ក៏ឥតបានជាប្រយោជន៍ដល់ខ្លួនទឹងអ្នកជាទៃដែរ មិនតែប៉ុណ្ណោះត្រឡប់ទៅជាឲ្យទោសដល់ខ្លួនថែមទៀតផង ។

ភាពល្អរបស់អ្នកល្អ ទៅត្រង់ការកាន់ធម៌ជាគោលចារឹត មានគុណធម៌នៅក្នុងចិត្តពិតៗ កើតអំពីខ្លួនឯងមិនមែនកើតអំពីសម្បត្តិទ្រព្យ ជាតិត្រកូលណាមួយឡើយ ។ អ្នកល្អតែងប្រព្រឹត្តធ្វើតាមសភាវៈពិត ទឹងសភាវៈល្អ មិនប្រព្រឹត្តតាមគាប់ចិត្តរបស់ខ្លួន ឬតាមនិយមរបស់លោកឬក៏ដោយបុព្វនៃលោក ក្រែងវង្វេងទេ, បើទឹងប្រកបកិច្ចការគ្រប់យ៉ាងតែងចង់ត្រួតត្រាឲ្យឃើញខុសត្រូវអាក្រក់ល្អជាមុន តែដើម្បីឲ្យត្រឹមត្រូវតាមលទ្ធិទំនៀមទំលាប់ប្រពៃណីមាត្រាច្បាប់ ទឹងបែបផែនដែលលោកនិយមសូម្បីឃើញខុសត្រូវអាក្រក់ល្អខ្លួនឯង ក៏ត្រូវត្រួតត្រាបង្ហាញឲ្យល្អិតតទៅទៀត, មិនតែប៉ុណ្ណោះឡើយ កាលប្រាថ្នាទឹងឲ្យត្រឹមត្រូវតាមផ្លូវធម៌ បើខុកជាឃើញត្រឹមត្រូវតាមផ្លូវលោកនិយមហើយក៏ដោយ ក៏ត្រូវពិនិត្យពិចារណាឲ្យហ្មត់ចត់ក្នុងផ្លូវខុសត្រូវអាក្រក់ល្អ ដោយពិនិត្យពិច័យទៀត, ទាំងនេះមកពីអ្នកល្អបេះបង្អែរខ្លួនឯងឲ្យសមគួរដល់លោក

ឧដ្ឋធម៌ មិនស្រមើលភ្លាញលោកឲ្យកន្តែបែមកសម្រាប់ហានៈបេះខ្លួនឡើយ ត្រូវឧដ្ឋគតិថា " ការប្រព្រឹត្តិឲ្យត្រឹមត្រូវតាមលោកនិយម គ្រាន់បើជាង ការធ្វើតាមអំណាចចិត្តឯង ឯការប្រព្រឹត្តិឲ្យត្រឹមត្រូវតាមផ្លូវធម៌ រឹងរឹតតែប្រសើរជាងការធ្វើឲ្យត្រូវតាមផ្លូវលោកនិយមតទៅទៀត " ។

និស្ស័យជាអ្នកល្អ ពាប់ថាជាកិត្តិយសខ្ពង់ខ្ពស់បំផុត, ដែលអ្នកមានចិត្តជាធម៌ តែងនិយមពាប់អានមិនចេះឆ្អែត ។ អ្នកដែលមានយសសក្តិខ្ពស់ប្លុមនុស្សដែលរឹងរូស មិនបង្អោនខ្លួនគោរពអ្នកមានបណ្ឌាសក្តិ ក៏ត្រូវតែនុនគោរពចំពោះអ្នកល្អដែរ ទោះបីអ្នកនោះមិនមានយសសក្តិ ឬមានយសសក្តិខាបជាងក៏ដោយ, ព្រោះមនុស្សដែលគួរស្រឡាញ់ គួរគោរព គួរពាប់អាននោះ មិនមែនដោយសារតែអ្នកនោះមានត្រកូលឬមានយសសក្តិខ្ពង់ខ្ពស់ ឬក៏ទៅជាកំឡោះ ក្រមុំ មានអាយុច្រើនជាងឡើយ តាមពិត គឺដោយសារតែអ្នកនោះ មានសម្បត្តិអ្នកល្អទៅក្នុងខ្លួន ជារឿងលើកដំកើង ឲ្យទៅជាមនុស្សគួរស្រឡាញ់គួរគោរព គួរពាប់អានប៉ុណ្ណោះ ។ ម្យ៉ាងទៀត សូម្បីឲ្យសម្បត្តិនឹងត្រកូលដ៏មាំមួន ដែលមាតាបិតាតាំងចិត្តកសាងឡើងដើម្បីទុកឲ្យកូនចៅក៏ដោយ បើកូនចៅជាមនុស្សមាននិស្ស័យអាក្រក់ ក៏រក្សាទុកមិនបានដែរ លុះតែកូនចៅមាននិស្ស័យជាអ្នកល្អផង ទើបអាចថែរក្សាទុកបាន មិនតែប៉ុណ្ណោះ សូម្បីមាតាបិតាមិនបានធ្វើទុកឲ្យ ក៏អ្នកល្អអាចតាំងខ្លួនឲ្យជាមនុស្សឧត្តុង្គឧត្តមសម្បូរឡើងឯងៗ បានដែរ ។

មនុស្សគ្រប់គ្នា សុទ្ធតែចង់បានគាត់ជាមនុស្សល្អទាំងអស់ ហើយ
ក្នុងម្នាក់ៗ សុទ្ធតែព្យាយាមសំដែងអាការកិរិយាលំនាំឲ្យទៅជាមនុស្សល្អ
គ្រប់វិធី ។ តែមនុស្សខ្លះវង្វេងចូលចិត្តខ្លួនថា "ការចរចា ឬ ធ្វើលំនាំ
ឫកពាខ្លួនឲ្យអ្នកដទៃយើញថាខ្លួនជាអ្នកធំ ជាមនុស្សគ្រាន់បើនោះ ជា
ការសមគួរដល់កិរិយារបស់អ្នកល្អ" ។ កាលបើគេប្រព្រឹត្តកិរិយាតាម
ដែលគេយល់យើញខុសយ៉ាងនេះហើយ កុំនឹកសង្ឃឹមថាមានគេសរសើរ
ខ្លួនថាជាអ្នកល្អឡើយ មុខជាត្រូវប៉ះត្រូវពាក្យដំទៀលថាជា "មនុស្ស
វៃ ចំត្រដរធ្វើឫកពាសង្ហាឲ្យគេថាខ្លួនជាអ្នកធំ អ្នកជាន់ខ្ពស់ ហួស
ប្រមាណ" ដូច្នេះពុំខាន ។ ពិតមែនអាកប្បកិរិយាដែលគួរកាប់អាន
គួរឲ្យបូជារបស់ពួកមនុស្ស នៅត្រង់ការធ្វើឬការនិយាយចរចា ដោយរ
មែត្តាចិត្តចំពោះអ្នកដទៃ ។ ឯការធ្វើឬការនិយាយដែលប្រកបដោយ
មេត្តាចិត្តបែបនេះ រមែងបានទទួលផល គឺការសុភាពរាបសា នូន
លំទោន ទទួលអញ្ជើញការប្រស្រ័យសាកសួរ ដោយអធ្យាស្រ័យ
ដ៏ប្រកបព្រមដោយមេត្តាចិត្ត ករុណាចិត្តនឹងចិត្តជាបុណ្យ ជាទីត្រជាក់
ចិត្ត ចាប់ចិត្ត ចាប់ត្រចៀក អំពីសំណាក់មនុស្សដទៃគ្រប់មិនមានមនុស្ស
ដទៃណាមួយស្អប់ខ្ពើម ឬគរហានិន្ទាឡើយ នេះឯងហើយជាអាកប្ប-
កិរិយារបស់អ្នកល្អ ។

ជនណា មាន ជាតិវង្ស ពង្សថោកទាប
តែចំសាធ អត្តភាព យ៉ាងខ្ពាំងក្លា
មិនខ្ចាប់ក្តៅ រងា ជាធម្មតា
ជននោះ កែអាត្មា ឲ្យខ្ពស់ជាន ។
មនុស្សល្អ មានវង្ស ដ៏ស្តុកស្តម្ភ
តែក្រើតក្រើន មិនចំ តាំងខ្លួនជ្រុណា
យូរៗទៅ ផៅពង្ស គង់សាមាន្យ
ភ្លាក់ទៅកាន់ ហីនជ្ជាន តុំខានអើយ ! ។

អ្នកល្អតែងមាននិស្ស័យល្អជាកូមិធម៌ អែបនែបនៅក្នុងសន្តានមិនមែនសំដៅយកថាល្អ ដោយគ្រឿងតែងកាយឬទ្រព្យសម្បត្តិណាមួយឡើយ ។ កាលអ្នកល្អ មាននិស្ស័យល្អជាគ្រោះហ៊ុំខ្លួនហើយ សូម្បីតែងខ្លួនតែល្មមសុភាពរាបសា ហើយចុះទៅក្នុងប្រទេសណា ដែនណា ក៏អាចជាទីញ៉ាំងជនក្នុងប្រទេសនោះដែននោះ ឲ្យស្នេហានឹងមានការរាប់អានយ៉ាងក្រៃលែងចំពោះខ្លួនបានដែរ មិនចាំបាច់ស្រែកកេះលំទៅនឹងសេចក្តីរុងរឿង ថ្កុំថ្កើងអំពីណាទេ ។ យើងអាចកំណត់ដឹងនិស្ស័យល្អរបស់អ្នកល្អបាន ដោយអាស្រ័យការសង្កេតកូមិធម៌ដែលមានទៅប្រចាំក្នុងសន្តានរបស់អ្នកល្អនោះសូម្បីមានចំនួនប៉ុន្មាន ក៏នឹងប្រកាសឲ្យយើងដឹង · យើញបានចំនួនប៉ុណ្ណោះ តាមលំនាំនៃអាការ

កិរិយានឹងវាចា ដែលអ្នកល្អសំដែងចេញមក, ដូចជាសំដែងកិរិយាមារយាទល្អ ចំពោះអ្នកគួរ ឬអ្នកមានកំឡាំងអន់ជាង ឬក៏ប្រព្រឹត្តអាកប្បកិរិយានឹងវាចាល្អ ចំពោះមនុស្សខ្ពស់ជាដើម ព្រោះនិស្ស័យល្អដែលនឹងលេចចេញឡើងបាននោះ រមែងមានប្រាកដឡើងអំពីការប្រព្រឹត្តិតាមផ្លូវកាយផ្លូវវាចារបស់អ្នកល្អ គប្បីសង្កេតដូចតទៅនេះ :-

๑ - **អ្នកល្អ តែងមានមារយាទល្អ.** - កិរិយាមារយាទដែលរឹងប៉ឹង នុនលំទោន ថ្លៃថ្នូរ បន្ទន់ខ្លួន អត់ធន់សុប់សៀម សុភាពរៀបរយ សំដែងសេចក្តីគោរព ប្រណី នឹងពេញតោរតៅដោយមេត្តាជាដើម នេះជាមារយាទល្អ ។ កិរិយាមារយាទដែលរឹងរូស រឹងត្អឹង ឆោតខាប ច្របូកច្របល់ ច្របេងច្របាង មិនពាសា អាក្រក់គ្រោតគ្រាត អួតខ្លួនជាដើម. នេះជាមារយាទអាក្រក់ ។

អ្នកដែលមានមារយាទល្អ តែងមានឫកពា ឧឡារិកវាចាវែងវ៉ែង មិនមែនច្របេងច្របាង តែងនុនលំទោន មិនមែននុនដោយអែបអបខ្ជាយដំណៀរបស់ខ្លួនតែបន្តិចបន្តួច លើកខ្លួនអួតយសសក្តិ អួតគុណវុឌ្ឍិ អួតសមត្ថភាពឲ្យហួសប្រមាណ សូម្បីនឹងធ្វើអ្វីត្រឹមតែបន្តិចបន្តួច ក៏សមល្អគួរមើលគួរព្រឹកពាយបាន ហើយការធ្វើនោះ ជាគ្រឿងលើកស្ទួយសេចក្តីល្អឲ្យអណ្តែតឡើងផង ដូចផ្សាំងមាសដាំពេជ្រអាចក្តីព្រោងព្រាយឡើងបានដូច្នោះ ។ អ្នកមានមារយាទឆោតខាប រមែងសង្កត់ខ្លួនឲ្យធ្លាក់ទៅ

ទំនាប, ខ្ញុំធ្វើអ្វី សូម្បីជាអង្គនៃសេចក្តីល្អ ក៏ធ្វើឲ្យជាទីស្មុគស្មាញគាស់ក្អែក ផ្សាចិត្តរបស់អ្នកដែលបានមកឃើញ បើទំសំដែងចេញទៅត្រឹមណា ក៏ធំតែតែជាទំនាស់ដល់អ្នកជំនែត្រឹមនោះ ។

បើយើងស្រឡាញ់មារយាទល្អ យើងត្រូវក្សាមារយាទឲ្យមានបដិសណ្ឋារៈល្អ មានវាចាពីរោះ មានកិរិយាសមរម្យទុនលំទោនចំពោះអ្នកធំ ឬអ្នកដែលគាបតូចជាងខ្លួន, បើយើងមានបុណ្យសក្តិធំ ក៏ធំតែតែត្រូវមានកិរិយាទុនលំទោនចំពោះមនុស្សទូទៅថែមទៀត ។ កុំសំដែងមារយាទៈថាកគាបកងកូមិកងអាភម កងសង្គមនឹកងសាធារណជ្ញន គឺទីដែលច្រាកដដល់សាធារណជន ។

ក) កុំប្រើអាកប្បកិរិយាថោកគាប ខ្ជិលច្រអូសទៀ ច្រដេងច្រដាងច្រៀតបៀតគេឯង កុំបញ្ចេញអាការៈរៀសដៃទៅមក ចង្អុលនាយអាយនឹងកុំប្រើកិរិយា ធ្វើមាត់បេញមួញ ។

ខ) កុំធ្វើសំឡេងឮឮ នឹងកុំសើចហ៊ោកញ្ជ្រៀវដោយឥតហេតុ កុំប្រើភាសៀតសិកប្តូរមកអាក្រក់ កុំសំដែងកិរិយានឹងវាចាគោសរូសប៉ាច់ប៉ាច់ប៉ោចចំអកចំអន់អ្នកដទៃ កុំនិយាយគំហកគំហិន មើលងាយដៀលត្មះតាក់តែងឲ្យគេគាស់ទែងគ្នា ។

សាវតារវត្តកែវនពវង្សី ហៅវត្តកោ

នៅឃុំលួស ស្រុកសូទ្រនិគម ខែត្រសៀមរាប

ព្រះមហា គុយ - ហួត

សិស្សសាលាបាលីជាន់ខ្ពស់ កំពេញ

រៀបរៀង

(រង្វាន់លេខ ៣)

វត្តកែវនពវង្សីនេះឋិតនៅកង់មណ្ឌលខែត្រសៀមរាប ក្នុងឃុំលួស ស្រុកសូទ្រនិគម ឈៀងអគ្នេយ៍នៃខែត្រសៀមរាប ក្នុងកម្ពុជរដ្ឋ ។ អាចម នេះ កើតឡើងដោយគ្រហស្ថមានឆ្មាសេដ្ឋី ជាចៅហ្វាយស្រុក នឹងបាឡាត់ស្រុក កេទបុរសគឺបិតានឹងបុត្ត ធ្វើពជការក្នុងស្រុកសូទ្រនិគម នោះ បានផ្តើមកសាងមុនគេបាំងអស់ ។

អាចមនេះគេសាងឡើង ក្នុងពាជ្យព្រះបាទសម្តេចព្រះហរិវក្សព្រមា ឥស្សរាធិបតី (ព្រះអង្គដួង), ឯសកពាជមិនច្បាស់ប៉ុន្តែក្នុងសម័យនោះ ខែត្រសៀមរាបនៅក្នុងអំណាចពាជការសៀមនៅឡើយទេ ។

បុព្វហេតុដែលនាំឲ្យកសាងវត្តនេះឡើងនោះ មានរឿងព្រាវជាស្រីងច្បារឮថា: នៅចំពីខាងកើតអាចមនេះ ចំនួន ៩០០ ម៉ែត្រ ពីលួវត្តនេះទៅ មានលួមួយមានដើមពោធិពីរដើមដុះលើលួនោះ គេហៅថាលួពោធិពីរ ។ សម័យមួយមានពួកក្មេងជាច្រើន បាននាំគ្នាទៅឃ្វាល

គោក្រៃ ក្បែរខ្ទួលគោធំពីរនោះកំពុងតែលេងឈូឆរ រត់ចុះរត់ឡើង ស្រាប់តែបានឃើញពស់មួយលូនក្បែរទីនោះ ក៏នាំគ្នាជេញរាយរាស់ ។ ឯពស់ភ័យក៏លូនយ៉ាងលើនទៅចូលរន្ធដើមគោធំនោះ, ក្មេងទាំងអស់ក៏នាំគ្នាចាក់ម្នាងម្នាក់ទៅវិញទៅមក កំពុងតែចាក់ ក៏បានឃើញនាគថ្មមានសណ្ឋានបើកពពារ; ក៏នាំគ្នារត់ទៅជ្រាបម្តាយឪពុកចាស់ៗ ឯភូមិ ។ អ្នកស្រុកក៏បាននាំគ្នាកាន់ចបជ្រនីកជាដើមមកកាន់ទីនោះ ហើយក៏នាំគ្នាដីកកន្ទែងនោះ, លុះដីកបន្តិចទៅ ក៏បានឃើញព្រះពុទ្ធរូបមួយអង្គ គង់លើថ្នែនាគ ពពារនាគជុំងពីលើ ព្រះហស្តទាំងពីរដាំរួតលើគ្នាថែបចូលសមាធិ (ព្រះពុទ្ធរូបនេះប្រហែលជាគេកសាង តំណាងព្រះសម្ពុទ្ធដែលគង់ក្បែរមុចលិនស្រះ) ព្រះពុទ្ធរូបនេះរចនាដោយសិលាម័យ ខាងក្រៅវិចិត្រដោយទឹកមាស (ព្រះពុទ្ធរូបបែបនេះហៅថាព្រះពុទ្ធនាគប្រក់) ។

មហាជនលុះបានឃើញព្រះពុទ្ធរូបនោះ ក៏មានចិត្តជ្រះថ្លា នាំគ្នាធ្វើបុណ្យយ៉ាងច្រើនកុះករ រួចកដង្ហែទៅខ្ទួលមួយនៅចំពីខាងលិចខ្ទួលគោធំពីរនេះ គឺកន្ទែងកសាងវត្តសព្វថ្ងៃនេះ ហៅថា "ខ្ទួលរកា" ព្រោះមានដើមរកាដុះពីលើ ។

នៅស្រុកសូទ្រនិគមក្នុងសម័យនោះ មានចៅហ្វាយស្រុកម្នាក់ឈ្មោះតែវ ព្រមទាំងកូនម្នាក់ ឈ្មោះណុប ធ្វើបាឡាត់ស្រុក ក្នុងស្រុកជាមួយគ្នា បានតាំងផ្តើមជាអធិការកសាងវត្តនេះ ជាដំបូងបំផុត ។

លុះសាងរួចហើយ ក៏ដាក់ឈ្មោះថា កែវនពវន្ធ្យ ដោយឆ្យឈ្មោះខ្លួន នឹងឈ្មោះកូន ជាអ្នកនាំសាងមុនគេនោះ ។

លុះចំណេរជាខាងក្រោយមក អ្នកស្រុកក៏នាំគ្នាហៅថា វត្តរកាព្រៃខ្លួលនោះមានដើមរកាមួយដើម ។ ឯពាក្យថា កែវនពវន្ធ្យ ជានាមកិតេយ្យដំបូង គ្មាននរណាហៅទេ សព្វថ្ងៃតែឈ្មោះថា វត្តរកាទៅវិញ ។

ឯព្រះពុទ្ធរូបនោះ គេបានដំកល់ទុកក្នុងវិហារ ជាបូជនិយដ្ឋានមកដល់សព្វថ្ងៃនេះ ។ វត្តនេះមិនសូវសម្បូណ៌សេនាសនៈទេ វិហារដែលកសាងពីមុនមកក៏ចាក់ទ្រុឌទ្រោមអស់ ឥឡូវកំពុងកសាងម្តងទៀត ។

រៀបរាប់អំពីផែនទីធ្វើវិហារ – វិហារគេត្រូវជ្រើសរើសទីកន្លែងដ៏ពេបស្មើចាក់ដីបុកឲ្យសង្កត់ដោយមធ្យត្ត ហើយត្រូវលើកដីឲ្យខ្ពស់ជាងកន្លែងធ្វើសេនាសនៈតាំងពួង, លុះធ្វើស្ថាវរកិច្ចរួចហើយ ទើបធ្វើវិហារជាខាងក្រោយ ។ ចំណែកខាងវិហារដែលធ្វើបែរមុខទៅខាងកើតនោះ គឺធ្វើតាមប្រវៃណីពីបុរាណមក ដោយគេអាងដល់គម្ពីរបណ្ណាសរពេជ្ឈ អ្នកប្រាជ្ញដែលតែងគម្ពីរនោះពន្យល់ថា " ការដែលធ្វើវិហារបែរមុខទៅខាងកើតនោះទើបមានផលានិសង្សប្រពៃ " ។ ម្យ៉ាងទៀត ប្រាជ្ញាចារ្យខ្លះពោលថា ការធ្វើវិហារបែរមុខទៅទិសខាងកើតនេះ ដើម្បីតម្រូវចំពោះព្រះសម្ពុទ្ធពេលព្រះអង្គប្រទានគ្រាស់ទេសនាបែរព្រះភក្ត្រទៅទិសខាងកើត ។

របៀបសាងកុដិសាលា — កុដិនឹងសាលាគេត្រូវសង់ពីខាងលិចឬខាងជើងនៃវិហារ, នេះតាមគម្ពីរបណ្ដូលសរពេជ្ជដែរ ។ ឬក្ស ពារវេលាដែលត្រូវសាងវិហារនោះដូចឥតមានច្បាកដទេ. ប៉ុន្តែចំនៀមនេះធ្លាប់មានខ្លះ គឺថាបើថ្ងៃដែលលើកវិហារត្រូវឲ្យលោកគ្រូចៅអធិការថយចេញពីវត្ត ល្មមមិនឲ្យភ្លៀងស៊ីឡើងគន់រគាំង ជាបដល់លើកវិហារហើយសឹមត្រឡប់មកវិញ ។ ឯការណ៍ដែលកំណត់យ៉ាងនេះ ព្រោះគេប្រយ័ត្នកុំឲ្យលោកគ្រូចៅអធិការចាញ់អំណាចវិហារ កុំឲ្យមានគ្រោះថ្នាក់កន្ធរថ្ងៃក្រោយ ។

ឯវត្តដែលចាប់រៀបចំថ្មី មិនទាន់សាងវិហារ គេត្រូវធ្វើរោងសម្រាប់ធ្វើឧបោសថសិន គេហៅថា "ឧបោត" ។ មុននឹងសាងវិហារគេយកឈើមានខ្ទឹមទៅបោះធ្វើគោលចំណាំ ដល់ពេលក្រោយបានគេប្រជុំឧបាសកឧបាសិកាដើងវត្ត មានអាចារ្យសម្រាប់វត្តជាប្រធាន ពិនិត្យទីកន្លែងនឹងសាងវិហារហើយ ទើបគេកំណត់ត្រង់កន្លែងណាមួយព្រមគ្នា ហើយចាប់សាងជាវិហារឡើង ។

មុននឹងសាងព្រះវិហារ, គេត្រូវជ្រើសរើសគ្រឿងវិហារបុកណ្ដើតាមចូលចិត្ត ឈើឬស៊ុម៉ង់ត៍តាមធនធានរបស់អ្នកដើងវត្ត ។ មុននឹងលើកវិហារ មានរៀបពិធីសូត្រមន្តហើយមានខ្នះរៀបក្រុងពាលីផង, ព្រឹកឡើងបានលើកគ្រឿងវិហារដែលបានរៀបចំជាស្រេចមកហើយនោះ ។

ឯទីវត្តទាំងមូលគេត្រូវកែតចំណាំតាមតាពតូច-ធំ ឬតាមប្រមាណដី ដែលគេបានវេរប្រគេនសង្ឃ តឹមត្រូវតាមវិនយកម្ម ។

ឯសេនាសនៈដែលធ្វើក្នុងអារាមសាងថ្មីនោះឥតមានកំណត់ទេ តាមសទ្ធា និងកោតសម្បីទ របស់ទាយកទាយិកាដើងវត្ត បើមានលុយសាងកុដីមាំទាំទៅក៏បាន បើគ្មានទេគ្រាន់តែធ្លេកងឹស្មឹកប្រគេនលោកគង់នៅបណ្តោះអាសន្នសិនក៏បានដែរ ។

របៀបកសាងវិហារ ក្នុងពុទ្ធសាសនា សុទ្ធតែធ្វើជារូបនាគ, ហោជាងជារូបទេវតាកាន់គ្រាំង ឬសៀវភៅទាំងអស់តមានប្លែកគ្នា, ឬមួយជារូបព្រះនារាយណ៍តាមគាប់ចិត្តស្រឡាញ់ (មតិរបស់អ្នកតែងរឿងនេះនឹងមតិចាស់ៗ ពីដាន់ដើមខ្លះ) ។

មានសេចក្តីអធិប្បាយថា ដាវជារូបនាគព័ទ្ធព័ទាងលើនោះ គឺបានសេចក្តីថា នាគជាសត្វមានពិសនឹងមានកម្លាំងច្រើន ឯព្រះពុទ្ធសាសនាទាំងមូលមានវិហារ ជាគោលចារឹក, ហេតុនេះនាគគឺពុទ្ធបរិស័ទនេះតោងប្រឹងប្រែងផ្គុំកម្លាំងគ្នាឡើង ថែទាំរក្សាឧបត្ថម្ភគាំទ្រពោះសាសនាដោយពេញកម្លាំង ត្រូវត្រួសត្រាស គឺការប្រឹងផ្សាយពុទ្ធឧវាទរបស់ព្រះសម្ពុទ្ធ ឬក៏ខំប្រឹងកំចាត់បក្ខាមិត្តដែលប៉ងប្រឌូស្យុះស្យុយចំពោះពុទ្ធសាសនាទាំងមូល ឲ្យវិនាសសូន្យាត់ចេញទៅ ដូចជារូបនាគដែលមានសណ្ឋានប្រឹងអើតកដោយពេញកំម្លាំងនោះឯង (នាគនេះជាប្រស្នារបស់អ្នកចាស់ពីមុន នាគកងទីនេះសំដៅដល់ពុទ្ធបរិស័ទទាំងមូល) ។

ឯរូបទេវតាកាន់គ្រឹងនោះ មានអធិប្បាយថា ទេវតាក្នុងទីនេះបាន ដល់ឧបបត្តិទេវ៌ ឬសម្មតិទេវ៌ គាំងពីរផ្នែក គឺសូមឲ្យទេវតាសុទ្ធៗនោះ ជួយពិនិត្យពិចារណាថែទាំព្រះពុទ្ធសាសនាដោយពេញកំឡាំង កុំឲ្យប្រែប្រួលចាកពុទ្ធតំរាស់ទេឡើយ ។ ឯសម្មតិទេវ៌ មានព្រះពាជាដើម ក៏ត្រូវផ្ទៀងផ្ទាត់ឫទ្ធិសាសនា ឲ្យហ្មត់ចត់កុំឲ្យប្រាត់ទៅណា ឲ្យដូចតំរាស់ដែលលិខិតទុកក្នុងគ្រឹង តែងតែមិនប្រែប្រួលចាកច្បាប់ដើម ។ ព្រោះហេតុនោះ បានជារូបទេវតាដែលគេធ្វើនោះ មានសណ្ឋានដូចជាប្រឹងផ្ទៀងគ្រាំងនោះឯង សំនេះជាប្រស្នាទី ២ ។ ឯរូបព្រះនាគាយណ៌នោះ ឥតជាប្រស្នាអ្វីទេ ធ្វើដោយការគ្រប់ឡំ ព្រោះព្រះនាគាយណ៌នេះ ជាព្រះមួយអង្គ ក្នុងសាសនាព្រាហ្មណ៌ ប្រទេសយើងពីដើមធ្លាប់កាន់សាសនាព្រាហ្មណ៌ ម្ល៉ោះហើយក៏ធ្វើទៅតាមនិតិតគួរដល់ប្រស្នាអ្វីឡើយ ឬក៏ចង់ល្អម៉ើល ។

វិហារដែលធ្វើរួចហើយ គេធ្វើបុណ្យជាវត្ថុធ្លាមុន ឬបំពាក់សីមាតែម្តងទៅក៏បាន ។ ឯរបៀបបញ្ចុះសីមានេះគេត្រូវដឹករណ្តៅ ៨ ក្នុងវិហារគ្រប់ទិសទាំង ៨ ហើយយកឫ ៨ ដុំ មកស្ថិតស្ថាធ៌ឲ្យមូលទុកធ្វើជាឫសសីមា ហើយស្រាក់ចង់ដោយអម្បោះស ហើយដំកល់ទុកក្បែរមាត់រណ្តៅ ហើយបាននិមន្តព្រះសង្ឃទាំង ៨ ទិសមកសូត្របញ្ជាន់តាមវិន័យកម្ម លុះបានឫក្បាលស្ពក៌កាត់ដុំឫនោះ ទម្លាក់ទៅក្នុងរណ្តៅទៅ ។

ឯឧបាសកឧបាសិកាដើរវត្ត ឬអ្នកដែលមកពីចំងាយបានធ្វើបុណ្យប្រគេនចង្ហាន់ដល់ព្រះសង្ឃ ដែលបានទិមន្តមកកាន់ទីទិសសីមារបស់ខ្លួន ។ ព្រោះរបៀបបុណ្យនេះ មានគេធ្វើកាន់ទិសសីមា មួយទិសម្នាក់ តាមពួកតាមក្រុមមនុស្សច្រើនតិច ។ ឯកំណត់បុណ្យយូរថ្ងៃ ឬតិចថ្ងៃតតំណាត់ទេ តាមសទ្ធារបស់ពុទ្ធបរិស័ទអ្នកធ្វើ ។ អាវាមដែលសាងដំបូងមានកិកុសង្ឃចំនួន ៤-៥-៦ អង្គប៉ុណ្ណោះ តតមានកំណត់ថា ប៉ុណ្ណេះប៉ុណ្ណោះទៀយ ព្រោះអាវាមថ្មីតតមានកុលបុត្រច្រកបដោយសទ្ធាចង់បួសទេ ។ ឯអាគន្តុកកិកុទៀតក៏គ្មាន មកពីអាវាមកសាងថ្មីគ្មានការរៀនសូត្រពុទ្ធវចនដោយមាំគាំ ម្ល៉ោះហើយទើបមានព្រះសង្ឃតែ ៤-៥-អង្គ ជាអ្នកមេគំនិត កង់កិច្ចកសាងអាវាមថ្មីមុនគេនោះឯង មិនតែប៉ុណ្ណោះអាវាមថ្មី មិនសូវសម្បូណិសេនាសេនៈផង ។

សេចក្តីប៉ុណ្ណោះជាសារតារ អំពីរបៀបសាងអាវាមកង់សាសនា ។

រឿងសារតារវត្តនេះ ជានសូរបញ្ជាក់អំពីអ្នកអាចារ្យ ប៉ែន-ខូត, ជាអាចារ្យសម្រាប់វត្ត ជម្ងឺស្បាវាម ឃុំរលួស ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

ចប់

របស់អ្នកប្រាជ្ញបុរាណដែលបានដំណាលតៗមក

ឃុនបណ្ឌាន់រក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

១ – បរិភោគអ្វីមិនចេះឆ្អែត?

ឆ្លើយថា: សេចក្តីលោភគឺការចង់មាន ចង់បាន ចង់ល្អ ចង់សុខ មិនចេះអស់ មិនចេះផុត បើទុកជានឹងមាននឹងបានដល់ប៉ុន្មានៗក៏នៅតែមិនល្មមមិនគ្រប់គ្រាន់ ត្រូវនឹងពាក្យថា "បរិភោគប៉ុន្មានមិនបាត់ឃ្លាន" ។

២ – ដេកច្រើនមិនចេះភ្ញាក់ បានដល់អ្វី?

ឆ្លើយថា: បានដល់មោហៈគឺសេចក្តីវង្វេង ។ វង្វេងស្រឡាញ់, វង្វេងស្អប់, វង្វេងល្អ, វង្វេងអាក្រក់, វង្វេងលាភ, វង្វេងយស, វង្វេងគេ, វង្វេងយើង ស្រវឹងទៅដោយសេចក្តីវង្វេងតតពេលស្វាង តតពេលភ្ញាក់ ដូចមនុស្សដេកលក់គ្មានវិលានឹងប្រែត្រឡប់ខ្លួនពីមោហៈចេញបាន ។

៣ – ស្រឡាញ់អ្នកដទៃក្រៃលែងជាងស្រឡាញ់ខ្លួនឯងព្រោះអ្វី?

ឆ្លើយថា: ព្រោះមានមោហៈនោះឯង ជាហេតុបណ្តាលឲ្យស្រឡាញ់អ្នកដទៃក្រៃលែងជាងខ្លួនឯង គឺស្រឡាញ់ប្តី ស្រឡាញ់ប្រពន្ធ ស្រឡាញ់កូន ស្រឡាញ់ចៅ ស្រឡាញ់មិត្តភ័ក្តិ ស្រឡាញ់

ថៅហ្វាយនាយ តាល់តែបណ្តាយខ្លួនឲ្យធ្លាក់ចុះទៅក្នុងអំពើអាក្រក់ផ្សេងៗ មានសម្ងាប់សត្វ លួចទ្រព្យគេ និយាយកុហកបោកប្រាស់យកទ្រព្យសម្បត្តិអ្នកដទៃ មកចំនុកបម្រើងំបំពេញចិត្តរបស់ជនពាំងនោះ ខ្លួនឯងក៏ទទួលផលអកុសលនោះតែម្នាក់ឯង ព្រោះតែសេចក្តីស្រឡាញ់គេជាហេតុនាំឲ្យធ្វើអំពើអាក្រក់គ្រប់ប្រការ ។

๔ - របស់គួរខ្ជាប់ខៀរទៅជាហ៊ាន ព្រោះអ្វីជាហេតុ?

ឆ្លើយថា: ព្រោះតែសេចក្តីស្រឡាញ់អ្នកដទៃនោះឯងជាហេតុ ។ អំពើអាក្រក់ជារបស់មនុស្សអ្នកខ្លាច ប៉ុន្តែអ្នកនោះត្រឡប់ទៅជាហ៊ានធ្វើគ្រប់ប្រការវិញ គឺថាមនុស្សមានជាតិស្មើគាក៏ហ៊ានសម្ងាប់ សត្វធំប្តូចមានគុណឬតគុណក៏ហ៊ានសម្ងាប់ពាំងអស់ សូម្បីទ្រព្យសម្បត្តិរបស់អ្នកដទៃក៏ហ៊ានលួចយកដែរ ហ៊ាននិយាយកុហកបោកប្រាស់គេ ហ៊ានកាត់ក្តីខាងចាញ់ឲ្យឈ្នះខាងឈ្នះឲ្យចាញ់វិញ ឈ្មោះថាអំពើអាក្រក់ពាំងអស់ ចេះតែហ៊ានធ្វើគ្រប់មុខតសល់មិនចេះខ្មើសតាល់ ព្រោះតែមោហៈនោះឯងជាហេតុ ។

๕ - របស់ខ្លីសំគាល់ថាជារបស់វែង តើបានដល់អ្វី?

ឆ្លើយថា បានដល់ជីវិតការរស់នៅរបស់សត្វត្រឹម ๖๐ ឆ្នាំឬ ๗๐ ឆ្នាំ ប៉ុណ្ណោះ ត្រូវចាត់ថាខ្លីណាស់តិចណាស់ ពាំងមិនមានមិត្តជាគ្រឿងសំគាល់ថាដល់ត្រឹមណោះត្រឹមណឹងឡើយ ប៉ុន្តែសេចក្តីថ្លែងនោះថា ហាក់

ដូចជានឹងរស់នៅពាប់រយៈពាន់ឆ្នាំ គឺទ្រង់ធ្វើការងារនឹងកូនចៅរបស់
មានវិញ្ញាណឥតវិញ្ញាណមានកូនច្រើនសែនម្ភៃរយដំណាំស្រុកទេស
គេក្រែបជាដើមថា អាត្មាអញនឹងរស់នៅធ្វើជាម្ចាស់គ្រប់គ្រងរក្សាពាប់ម៉ឺន
ឆ្នាំទៅមុខ មិនដឹងថាដីតែជារបស់មានប្រមាណតិចជារបស់ខ្ញីទេឬយ ។

៦ - បកដូងយកមាត់ទាំ ធៀបនឹងអ្វី?

ឆ្លើយថា: ធម្មតាការបកដូងត្រូវតែប្រើកាំបិតឬប៉ូវថៅ ព្រោះជា
របស់ធំ មិនដូច្នោះទៀរជាយកមាត់ទាំដូងវិញ ឃើញថាខុសពីធម្មតា
របស់លោក ដល់ទីបំផុតមុខជាមិនបានបរិភោគសាច់ដូងនោះទេ ប្រៀប
ដូចជាមគ្គផលនិព្វាន ធម្មតាលោកអ្នកបានសម្រេចមគ្គផលនិព្វានទាំងអស់
លោកត្រូវយកសីលសមាធិបញ្ញាជាមគ្គប្រហារកិលេស ប្រៀបដូចជា
កាំបិតប៉ូវថៅសម្រាប់កាប់បកសំបុកដូង ចំណែកខ្ញុំនមិនយកសីលសមាធិ-
បញ្ញាធ្វើជាអាវុធសម្រាប់ប្រហារកិលេសទេ បែរជាទៅយកពេហារមកធ្វើ
ជាគ្រឿងប្រហារកិលេសវិញ អ្នកថាខ្ញុំចេះចាំច្រើនណាស់ឈ្លាសវៃជាង
អ្នក នឹងកាន់យកមគ្គផលនិព្វានដោយមាត់តែប៉ុណ្ណោះ; សម្រេចសេចក្តី
ថានឹងទៅតែប៉ុណ្ណោះឯង្គតបានមគ្គផលនិព្វានទេ ព្រោះខុសពីធម្មតា ?

៧ - បីកូនខ្ញីនុបតែខុកមិនជាក់ គឺអ្វី?

ឆ្លើយថា: រាងកាយនេះប្រៀបដូចកូនខ្ញី ព្រោះកូនខ្ញីជារបស់ដែល
ម្តាយឬអ្នកថែរក្សាថាក់ថ្នមជាទីបំផុត មិនហ៊ានធ្វេសប្រហែសបណ្តែត

បណ្តាយទេ នៅចាំពិភ័ក្តិរក្សាខាំងថ្ងៃខាំងយប់ ចាំបញ្ចុកបាយផ្តួចទឹកឲ្យ
ស្បៀតពាក់សំពត់ខោអាវជានិច្ច ដូចម្តេចមិញ ឯអត្តភាពរាងកាយយើងនេះ
ក៏ដូច្នោះឯង អ្នកជាម្ចាស់ខ្លួនត្រូវតែថែរក្សាថ្នាក់ថ្នម បើឃ្លានត្រូវរកអាហារ
ឲ្យបរិភោគ បើក្តៅឲ្យងូតទឹក បើរងាឲ្យដណ្តប់សំពត់ ទោះដើរទៅទីណាក៏
ចេះតែប្រុងប្រយ័ត្នមានឆ័ត្រចាំងសម្រាប់ការពារកំដៅថ្ងៃនិងទឹកភ្លៀងមាន
ស្បែកដើងពាក់ទៀត បើជាអ្នកជាន់ខ្ពស់មានយសស័ក្តិធំនឹងអ្នកមានទ្រព្យ
សម្បត្តិច្រើនវេលាចេញពីផ្ទះទៅទីណាតែងតែជិះយានជំនិះផ្សង១ថ្នាក់ថ្នម
រាងកាយមិនហ៊ានដើរ ទាល់តែខ្លួចកំឡាំងដើងអស់លែងដើរកើតតាំងពីខ្លួន
នៅក្មេង ក្លាយទៅជាមនុស្សខ្ទិនពិការកែងកង់ តែនឹងធ្វើប្រយោជន៍យ៉ាង
សំខាន់ដល់ខ្លួន គឺរកធម៌ពឹងដល់ខ្លួនដូចជាការរក្សាខុបោសថសីលក៏
មិនកើត ដោយការខ្វាចឃ្លានបាយខ្វាចខ្សត់ចាប់ខ្វាចស្លាប់ពួកមនុស្សអ្នក
ថ្នាក់ថ្នមរាងកាយដូចជាឧបរិតយ៉ាងនេះ ទើងពួកមនុស្សដែលប្រកាន់ថារាង
កាយកើតមកសម្រាប់ប្រើប្រាស់ ដូចជាដើងសម្រាប់ដើរជាដើម ។ ឯ
ខុបោសថសីល បើប្រសិនជាមនុស្សរក្សាមិនបាន១ទេ មុខជាព្រះពុទ្ធអង្គមិន
ទ្រង់អនុញ្ញាតទុកមកឡើយ ពួកអ្នករក្សាមកពីមុនក៏មិនឮដំណឹងថាអ្នកណា
សាប់ក្នុងថ្ងៃរក្សាខុបោសថដែរ គិតឃើញយ៉ាងនេះហើយគួរតែប្រតិបត្តិ
ទៅដោយធម្មតាតាមនាទី អាយុដ៏វែងរបស់មនុស្ស២ពួកនេះ ក៏មិនឃើញ
ថាចាញ់ឈ្នះគ្នាច្រើនប្លែកពីប៉ុន្មាន ហេតុនោះកុំរវល់ធ្វើឧបរិតពេកឡើយ ។

๘ — វង្វេងផ្លូវមិនសាកសួរ តើនឹងដល់ទីបំណងឬទេ?

ឆ្លើយថា: ធម្មតាមនុស្សវង្វេងផ្លូវ បើជួបនឹងអ្នកណាត្រូវតែសាកសួរ ចុះបើមិនសួរគេទេ មុខជាទៅមិនដល់ស្រុកភូមិដែលខ្លួនចង់ទៅចេះតែនៅវង្វេងទុក្ខលំបាកកង្វល់ផ្លូវដែលវង្វេងនោះ មានអត់បាយអត់ទឹកជាដើម ប្រៀបដូចបុគ្គលមិនស្គាល់ផ្លូវនរកផ្លូវសួគ៌ផ្លូវនិព្វានផ្លូវសុខផ្លូវទុក្ខ ចេះតែឆ្ងើបកពាំងគ្នឹងអួតខ្លួនមិនព្រមសួរលោកអ្នកចេះដឹង គង់តែវង្វេងក្លាត់ភ្លាក់ទៅខាងផ្លូវនរកមិនខាន កម្រមនឹងដើរសំដៅឲ្យត្រង់ទៅលើផ្លូវសួគ៌និព្វានណាស់ គួរតែខ្ជាបខ្ជួបជាតិកំណើត បើវង្វេងអស់មួយជីវិតគួរឲ្យស្តាយជាទីបំផុត ព្រោះមានមនុស្សដូចគ្នាជាច្រើនដែលគេចេះដឹងបានកន្លងទៅដល់ស្ថានសុគតិសួគ៌ ចំណែកខ្លួនយើងនៅតែវង្វេងវិលវល់ បែរមុខទៅរកផ្លូវទុគ្គតិ គួរឲ្យស្តុតចិត្តពេកណាស់ ។

๙ — គេចពីក្រពើធំក្លាត់ចុះទឹក តើដូចម្តេច?

ឆ្លើយថា: ក្រពើធំប្រៀបដូចសេចក្តីទុក្ខ មនុស្សខ្លីមទុក្ខ ខ្ជាបទុក្ខ គិតគេចចេញពីទុក្ខ ។ ការគេចចេញពីទុក្ខនេះបែរជាក្លាត់ទៅមានផ្លូវវិញ គឺទៅជាមានប្តីប្រពន្ធ ។ ការត្រៀបត្រង់ផ្លូវគឺមានប្តីប្រពន្ធនេះឯង លោកប្រៀបដូចទឹកដែលទុកជាផ្លូវជាទីលំនៅរបស់ក្រពើ តពីនោះទៅក៏នឹងមានតែទុក្ខតូចទុក្ខធំគឺក្រពើទាំពាំយកទៅ នឹងយកសុខស្អាតមកពីណា ព្រោះតែមិនដឹងផ្លូវសុខនោះឯងជាហេតុ ។

๑๐ - ត្រូវគុកច្រវាក់បែរទៅជាត្រែកអរវិញ តើដូចម្តេច ?

ឆ្លើយថា: ទឹកន្ទែងនឹងត្រីនឹងប្រដាប់សម្រាប់ដាក់ទុកឃុំទាំងអ្នកមានទោសសត្វថ្លៃនេះជារបស់មាំទាំសំខាន់ណាស់ សុទ្ធតែធ្វើពីឥដ្ឋនឹងដែក គឺខ្សែច្រវាក់ក ១ ខ្នោះដៃ ១ ខ្នោះជើង ១ ។ លោកសំដែងក្នុងបាឋខ្លះថា តណ្ហាសេចក្តីស្រឡាញ់កូនទុកដូចច្រវាក់ដែកមកចងក, តណ្ហាសេចក្តីស្រឡាញ់ប្តីស្រឡាញ់ប្រពន្ធទុកដូចខ្នោះដែកមកដាក់កដៃ, តណ្ហាសេចក្តីស្រឡាញ់សម្បត្តិទ្រព្យទុកដូចខ្នោះដែកមកដាក់កជើង តណ្ហា ៣ ប្រការនេះជាចំណងចងសត្វឲ្យវិលវល់នៅក្នុងវដ្តសង្សារ ត្រូវតែអាស្រ័យអរិយមគ្គញាណទើបនឹងកាត់ឲ្យដាច់ឃ្លាន ។ អាស្រ័យន័យនេះយើញត្រូវនឹងឃ្លាថា "ត្រូវគុកច្រវាក់បែរទៅជាត្រែកអរវិញ" ។ ព្រោះថាបុគ្គលខ្លួនឯងបើមានកូនមានប្តីមានប្រពន្ធមានសម្បត្តិទ្រព្យហើយ រមែងត្រែកអរខាំងរស់គ្នាជាច្រើននាក់ ។

๑๑ - តតាំងនឹងសត្រូវមិនរកអាវុធ តើឈ្នះឬទេ ?

ឆ្លើយថា: ធម្មតាសត្រូវ គេតែងតែប្រដាប់ប្រៀបអាវុធយុទ្ធភ័ណ្ឌឲ្យសព្វគ្រប់ ។ បើយើងតយុទ្ធនឹងសត្រូវ យើងក៏ត្រូវតែប្រដាប់ប្រៀបអាវុធយុទ្ធភ័ណ្ឌទុកឲ្យមានសព្វគ្រប់ដែរ ទើបនឹងច្បាំងគ្នាបាន ។ រឿងនេះសំដៅយកចម្បាំងខាងក្រៅ ។ ក្នុងប្រស្នានេះលោកសំដៅយកចម្បាំងខាងក្នុង ។ ឯចម្បាំងខាងក្នុងមានមេសត្រូវតែ ៣ នាក់ប៉ុណ្ណោះ

គឺមេដក ๑ មេព្យាធិ ๑ មេមរណៈ ๑ សុទ្ធតែជាមេកោងកាចអាក្រក់ណាស់ បំផ្លាញជីវិតរបស់មនុស្សនឹងសត្វពេញលោកមិនចៀសវាងមុខឲ្យសល់ដល់ម្នាក់ឡើយ ។ យើងត្រូវតែប្រុងប្រៀបអាវុធខាងក្រៅទុកតវៃនឹងមេសត្រូវទាំង ๒ គឺមេដកនឹងមេព្យាធិ ឯមេដកនោះឲ្យកេអាវុធគឺថ្នាំផ្ទើឲ្យអាយុវែងទុកតនឹងវា ឯមេព្យាធិនោះត្រូវប្រើថ្នាំផ្សេង ។ ព្រោះវាមានអំណាចអាចសំដែងឫទ្ធិបានដល់ ๙๖ ប្រការ ។ បើដុំងថាច្បាំងដោយអាវុធគឺថ្នាំមិនឈ្នះហើយ ត្រូវចូលចិត្តថាសត្រូវរួមកំឡាំងគ្នាបានហើយ គឺមេមរណៈបានមេដកនឹងមេព្យាធិមកជាកំឡាំងពេញទីហើយ អាវុធខាងក្រៅច្បាំងលែងរបើកហើយ ត្រូវតែយកអាវុធខាងក្នុងចេញមកច្បាំង ។ ឯអាវុធខាងក្នុងនោះគឺបញ្ញាវុធ វេលានេះយើងត្រូវយកជ័យជំនះឲ្យទាល់តែបាន ឲ្យត្រួតត្រាមើលកងទ័ពស្បៃង គឺខានដែលយើងបរិច្ចាគបច្ច័យតាំង ๔ ដល់លោកអ្នកមានសីលមានបរិបូណ៌ហើយឬនៅ ? កំឡាំងទ្រព្យរបស់យើងតើដូចម្តេច ? សទ្ធាធនំ = ទ្រព្យគឺសទ្ធាដឿបញ្ញាត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធមានក្នុងខ្លួនយើងហើយឬ ? សីលធនំ = ទ្រព្យគឺសីលមានក្នុងខ្លួនយើងហើយឬ ? សង្ឃោ បសាទោ = សេចក្តីជ្រះថ្លាក្នុងព្រះសង្ឃមានក្នុងខ្លួនយើងហើយឬ ? ទុជ្ជកូតញ្ច ទស្សនំ = សេចក្តីយើញត្រង់ក្នុងធម្មជូរចាវជាគួបញ្ញាធនំកើតឡើងដល់យើងហើយឬ ? ។ កាលបើត្រួតត្រាមើលអរិយទ្រព្យយើញថាមានគ្រប់គ្រាន់ក្នុងខ្លួនដូច្នេះ

ហើយ យើងក៏ដឹងច្បាស់ថា កំឡាំងទ្រព្យកំឡាំងពាហនៈរបស់យើងមានបរិបូណ៌ហើយ កម្លាំងអាវុធគឺបញ្ញាជារបស់សំខាន់យើងក៏មានត្រមហើយ ។ កាលពិនិត្យមើលឃើញកម្លាំងស្បៀង កម្លាំងទ្រព្យ កម្លាំងពាហនៈ កម្លាំងបញ្ញាមានសព្វគ្រប់ដូច្នេះហើយ មិនត្រូវខ្លាចដល់សត្រូវសោះឡើយ ចេញទៅឈរពីមុខកងទ័ពហើយចង្អុលមុខសត្រូវស្រែកប្រាប់ថា វ៉ុយជក ! ព្យាធិ ! មរណៈ ! អញស្គាល់មុខមាត់អាចារ្យស់លាស់ហើយ អាឯងទៅសំដែងបុព្វនិមិត្តឲ្យមនុស្សធោតលង់ខ្លៅឯណាចុះ កុំមកអួតអាងនឹងអញឡើយ ខ្លួនឯងគេគ្រាន់តែសន្មតថាសង្ខារប៉ុណ្ណោះទេ ឯងស្គាល់អញឬទេ បើមិនស្គាល់ អញនឹងប្រាប់ឲ្យដឹង ខ្លួនអញនេះគឺជាម្ចាស់ អមតៈ ជាជាតិកាយសិទ្ធិ គ្មានជរា គ្មានព្យាធិ គ្មានមរណៈ ពួកឯងតាមអញមិនទាន់ទេ ឯងយកតែសំបកនគរទេទៅចុះ" ។ នេះឯងជាអាវុធខាងក្នុងសម្រាប់ធ្វើសង្គ្រាមនឹងសត្រូវ ពួកអ្នកប្រាជ្ញលោកប្រដាប់ប្រៀបខុតគ្រប់គ្នា ។ កាលបើយើងមិនរកអាវុធដូច្នោះខុតសម្រាប់ខ្លួនទេ វេលាសឹកសត្រូវចូលមកដល់ យើងមិនចាញ់ដៃសត្រូវហើយឬ ? ។

๑๒ - អ្នកណាមិនឈប់ មិនដល់ព្រះពុទ្ធ តើយ៉ាងណា ?

ឆ្លើយថា: ពាក្យថា "ឈប់" ក្នុងទីនេះ មិនមែនសំដៅយកឈប់កាយកម្ម ឈប់វចីកម្ម ឈប់មនោកម្មទេ សំដៅយកត្រង់ការ

ឈប់គិត ឈប់នឹក ឈប់រវេតព្រះពុទ្ធខាងក្រៅប៉ុណ្ណោះ ចំណែកកាយកម្ម វចីកម្ម មនោកម្ម ខាងក្នុងត្រូវតែពាញស្ពានចេញមិនឲ្យដើរឲ្យប្រកបតែដោយសុចរិតធម៌ពាល់វេលា - សូម្បីយើងទៅថ្វាយបង្គំព្រះពុទ្ធរូបឬព្រះធាតុចេតិយក្នុងអារាមក៏បាន ប៉ុន្តែឲ្យចូលចិត្តថា មិនមែនទៅរកព្រះពុទ្ធខាងក្រៅមកបំពេញព្រះពុទ្ធខាងក្នុងទេ គឺទៅបំពេញកិច្ចទស្សនានុត្តរិយៈរបស់ខ្លួនទេតើ បើដឹងយ៉ាងនេះហើយ សូម្បីទៅគាំឈ្មោះថាឈប់ឈ្មោះថាទៅជាមួយនឹងព្រះពុទ្ធគ្រប់កាល ។

ការធ្វើប្រស្នាទាំង ១២ យ៉ាងនេះ មិនប្រាថ្នានឹងធ្វើឲ្យត្រូវតាមបំណងរបស់អ្នកសួរទេ ធ្វើតែតាមសេចក្តីយល់ឃើញនឹងសេចក្តីពេញចិត្តរបស់អ្នកធ្វើប៉ុណ្ណោះ នឹងមិនប្រាថ្នាធ្វើឲ្យអ្នកមើលត្រូវចិត្តគ្រប់គ្នាទេ ប្រាថ្នាតែឲ្យអ្នកមើលអ្នកស្តាប់ពួកខ្លះកាន់យកប្រយោជន៍ចំណែកខ្លួនតែប៉ុណ្ណោះ បើឃើញថាជាប្រយោជន៍ចូលកាន់យកចុះ បើឃើញថាឥតប្រយោជន៍ចូរធ្វើចិត្តឲ្យជាកណ្តាលកុំចាប់ទោស ។

ប្រការ ៦ ខុសជាត្រូវ ជាថ្នូរនឹងសជាតិប្រទេស

អក្សរខ្មែរ ភាសាខ្មែរ សំពត់ខ្មែរ គុយទាវខ្មែរ ហាងខ្មែរ ការស្នាដៃខ្មែរ ប្រពន្ធឯង យល់ថាប្រើមិនថ្លៃខ្លួន បរិភោគមិនធ្ងន់ចូលទំញមិនស្ទឹង ។ នេះហៅថាយល់ខុសជាត្រូវ ។

កណ្ដាលី ៨

អ្នកឧកញ៉ាវិបុលរាជសេនា ង្ហួ-កន ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
ធំងបេះខួបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

បណ្ដាស្រីប្រុសចាស់ក្មេង ដែលចេះចាប់ទុកជាពួកម៉ាកគ្រប់តំបន់ប្រហែល ១០០ ម៉ឺន, ចូរឆ្លៀសរើសយកតែរូបណា ដែលគាចសាហាវខ្លាំងពូកែទុកជាសេនាទាហាន ចាន់ប្រហែលជាន ២០ ម៉ឺន, រូបណាដែលចាស់ជរាពិការនឹងស្រី ក៏ឲ្យត្រឡប់ទៅរកស៊ីធ្វើការតាមទីលំនៅវៀងខ្លួនវិញ ។

ចូរយកសំបុត្រចូលទៅគ្រាបបង្គំទូលព្រះចៅហ្វានតេថា "ទូលព្រះបង្គំសូវខ្វះចាន់ប្រាក់ពួកចោរកំណាចពាបពាលអស់ហើយ" ។ លីឈុយគុយតឹ ខ្ញុំលសំបុត្រហើយ នាំឡើងគ្រាបបង្គំទូលព្រះចៅហ្វានតេ។

ទ្រង់មានព្រះតម្រាស់ថា "ចូរឆ្លៀតនេះមានសេចក្តីគាប់ប្រសើរក្នុងភពការ
ច្រើនណាស់" រួចទ្រង់គ្រាស់ឲ្យមានព្រះពរប្រកាសតាំងចូរឆ្លាតទីមន្ត្រីធំ
ជាងហ្វាយខែត្រទិសខាងកើតទាំងអស់ ។ លុយគុយគីមិនបាន
ជាគិតវែងឆ្ងាយ ក៏ធ្វើសំបុត្រតាំងចូរឆ្លូតាមក្រសែព្រះពរទុង្ការ ។ កាល
ចូរឆ្លូបានជាធំតាមព្រះតម្រាស់ហើយ ក៏លើកទ័ពទៅតាំងនៅស្រុកគុនដីវ
ហើយបញ្ជុះបញ្ចូលពួកម៉ាកនឹងរើសរកអ្នកមានតំរិះថ្លាជាទុកជាទីប្រឹក្សា ។
បណ្តាមនុស្សម្នាក់ឯអាណាខែត្រទាំងនោះ សឹងតែចុះចូលមូលមកជាពួក
ម៉ាកចូរឆ្លូច្រើនណាស់ ។

មានថ្ងៃមួយ ស៊ីនហុកជាមាស៊ីនស៊ីវដែលទៅនឹងអ្នកសៀវនោះប្រឹក្សា
គ្នាថា អ្នកសៀវជាមនុស្សខ្ចូលចិតអាក្រក់ យើងនឹងដែកទៅតទៅទៀតមិន
បានទេ; ឥឡូវអាណាខែត្រទិសខាងកើតទាំងអស់ ចូរឆ្លូបានជាធំត្រួតត្រា
អស់ហើយ បណ្តាមនុស្សក៏សឹងចុះចូលជាច្រើន យើងត្រូវតែចូលទៅ
ទៅទីពឹងចូរឆ្លូវិញស្រួលជាង ។ ស៊ីនស៊ីវជាកូយយល់ឃើញត្រូវផង
ក៏នាំគ្នាតេចេញពីអ្នកសៀវទៅទៅនឹងចូរឆ្លូឯស្រុកគុនដីវ ។ ចូរឆ្លូឃើញ
ស៊ីនហុក ស៊ីនស៊ីវ អង្គុយចម្ងាយមាំណាស់ ទំនងដូចជាមានសតិប្បញ្ញា
ខ្លាំងពូកែ ហៅចូលទៅសួរហើយតាំងទុកជាទីប្រឹក្សា ។ ស៊ីនហុក
ជំរាបចូរឆ្លូថា ខ្ញុំបានបានឮគេនិយាយថាឆៀយ៉ុកជាពួកស្រុកគុនគុនោះ
មានសុតិប្បញ្ញាណាស់ ឥឡូវនេះមកទៅស្រុកគុនដីវនេះ ហេតុម្តេចក៏

លោកមិនល្ងង់យកមកផង? ។ ចូរឆ្លូថា "យើងក៏បានឮគេនិយាយល្បីល្បាញមកជាយូរហើយ តែយើងមិនទាន់ដែលឃើញខ្លួនសោះ" ថាហើយក៏ច្រៀមទុស្សឲ្យទៅស៊ើបរកខ្លួនឆ្មៀងកុលល្ងង់នាំបានមក ។ ចូរឆ្លូបានឃើញឆ្មៀងកក៏មានចិត្តស្រឡាញ់ជាពន្លឹក ទើបតាំងឆ្មៀងកទុកជាទីប្រឹក្សា ។

ឯឆ្មៀងកដឹងថា ស៊ុនហុកស្ទើសេចក្តីគុណគាប់របស់ខ្លួនឲ្យចូរឆ្លូដឹងដូច្នោះ ក៏មានសេចក្តីអរគុណនឹងស៊ុនហុកច្រើនហើយថា ខ្លួនខ្ញុំនេះមានសតិប្បញ្ញាតិចណាស់ បើគុយតែដែលនៅស្រុកជាមួយនឹងអ្នកនោះទើបមានសតិប្បញ្ញាច្រើន ហេតុម្តេចអ្នកមិនស្ទើឲ្យយកខ្លួនគុយតែមកធ្វើពជការផង? ។ ស៊ុនហុកឆ្លើយថា ខ្ញុំភ្លេចទៅហើយ គាល់តែអ្នកនាំទឹក ឥឡូវនេះខ្ញុំក៏លើកឡើងបាន ។ ស៊ុនហុកបានយកសេចក្តីនោះទៅជំរាបចូរឆ្លូ ឲ្យទៅយកខ្លួនគុយតែមក ។ គុយតែជំរាបចូរឆ្លូថា ឡៅហ៊ីជាពូជព្រះពជវង្សព្រះចៅហាន់កង៏ប៊ូ ១ ប្អូនថុង៏ពួកអ្នកស្រុកសាន់យ៉ុង៏ ១ លីគៀនពួកអ្នកស្រុកប៊ូសេង ១ ម៉ាយពួកអ្នកស្រុកតាន់លីវ ១ គាំង ៤ នាក់នេះមានសតិប្បញ្ញាច្រើន ។ ចូរឆ្លូចាត់ឲ្យទៅបញ្ចុះបញ្ចូលឈ្មោះគាំង ៤ នាក់នោះបានមកទៀត ហើយតាំងទុកជាទីប្រឹក្សា ។

ឯអ៊ីគិមពួកអ្នកស្រុកគីប៉េង៏ ដែលជាចោរមានបក្សពួកច្រើន ក៏នាំយកបក្សពួកចូលមកនៅជាគាហានចូរឆ្លូគាំងអស់ ។ រៀបហួនគាំងគៀនអ៊ុយ

មកនៅជាពួកចូរួខ្មែត ហើយដំរាបថា តៀនអ៊ុយនេះជាពួកអ្នកស្រុកតាន់លើវមានកំឡាំងខ្លាំងពូកែណាស់ សម្ងាប់ចាវព្រាវតៀវមៅអស់ជាច្រើន ហើយវត់ទៅនៅព្រៃ, ខ្ញុំបាទចេញទៅដើរលេងឃើញតៀនអ៊ុយវាយភ្លាស្ងាប់ ហើយវៃលង្វងសមុទ្រមកជួបនឹងខ្ញុំបាទ។ ឃើញសមគួរជាគាហានណាស់ ក៏ល្បួងលួងលោមឲ្យមកនៅនឹងលោក ។ ចូរួបានស្តាប់ពិនិត្យមើលរូបកាពតៀនអ៊ុយ ឃើញរូបកាងធំធាំមួនសមគួរជាគាហាន ទើបសួរបញ្ជាក់តៀនអ៊ុយថា បើខ្លួនធ្វើគាហាននោះតើនឹងចូលចិត្តកាន់ប្រដាប់អ្វីជាអាវុធ? ។ តៀនអ៊ុយឆ្លើយថា ខ្ញុំបាទភ្ជាប់ចំណានខាងកាន់ខ្លួនផ្លែ ២ ទម្ងន់ ៨០ ជញ្ជីងចិន មានសម្រាប់ខ្លួនខ្ញុំបានហើយ ។ ចូរួបានឮចាត់ឲ្យរកសេះដំនិះ ១ មានថ្នាំដើងពូកែ ឲ្យតៀនអ៊ុយឡើងដំរកំខ្លួនល្បងមើល ។ ចូរួឃើញតៀនអ៊ុយជិះសេះកំខ្លួនរហ័សរហួនយ៉ាងចំណាប់ក្រឡេកមើលទៅឃើញជងគង់ជ័យ សម្រាប់ខ្នែតដែលលើកទុកនៅមុខទ្វារស្រុកត្រូវខ្សល់ព្យុះទ្រេតចុះនឹងលំ មានគាហាន ២៥ នាក់កំពុងច្រានលើកឡើងក៏មិនខាន់កំរើក ចូរួប្រើតៀនអ៊ុយឲ្យទៅជួយលើក ។ តៀនអ៊ុយលោតចុះពីលើសេះវត់ទៅដេញគាហានទាំងនោះឲ្យដើរចេញ តៀនអ៊ុយចូលទៅលើកជងគង់នោះតម្រង់ឈរឡើងដូចដើម ។ ចូរួឃើញដូច្នោះក៏សរសើរតៀនអ៊ុយថាមានកំឡាំងដូចម៉ន្តុសព្រីបុកណា ហើយចាត់គ្រឿងគ្រោះដែក ១ ប្រដាប់ឲ្យតៀនអ៊ុយ តាំងជានាយគាហានសម្រាប់រក្សាខ្លួនចូរួ ។

វិគ្គទី ៩

ខាងពីលើយើងម្ចាស់ចូកូ ហើយអេងតៀរតាំងហាងរត់ភៅនឹងអូនសៀរហើហ្វាយ
ស្រុកគីវ៉ា លុះដល់បីថៅថាត់ច្រៀកូស៊ុន ដុនសុក នឹងហៅសេង លើកទាហានទៅក្បាច
បន្ទាយទី៩ដល់ចយ៉ាងម៉ាមួន ។

កាលដែលចូកូបានបញ្ជូនបញ្ជូលមនុស្ស ជាពួកក្រុមសេនាទាហាន
បានមនុស្សបុរចូលជាច្រើនព្រមទាំងទ័ពប្រឹក្សា ចូកូមានសេចក្តីត្រេកអរ
ពន់ប្រមាណាណាស់ ឲ្យអេងតៀរកាន់សំបុត្រលើកទាហានទៅទទួល
ចូកូជាបិតា ដែលនៅស្រុកតាន់លីវឲ្យមកនៅជាមួយនឹងខ្លួន ។ កាល
អេងតៀរទៅដល់ហើយ ក៏ដួនសំបុត្រទៅចូកូ។ ឃើញសេចក្តីសំបុត្រ
សំគាល់ច្បាកដថាជាពាក្យបុត្ររបស់ខ្លួនមិនមានសង្ស័យ ទើបរៀបប្រមូល
ទ្រព្យរបស់ធូន់ស្រាល បបួលចូតេកនឹងបងប្អូនសាច់ញាតិប្រហែល ២០០
ចាយ លើកទ្រព្យរបស់ទាំងអស់ផ្ទុករះ ១០០ លើកទៅនៅស្រុក
គុនដីវ៉ា ។

លុះទៅដល់ជិតស្រុកគុនដីវ៉ាហើយ ទៅហ្វាយស្រុកឈ្មោះ
តូកៀមជាមនុស្សចិត្តល្អ ឆ្លៀវឆ្លាយរួសរាយពាប់អានអ្នកទាំងពួង គិត
ឃើញថា នឹងចូលទៅនៅនឹងចូកូ លុះដឹងថាចូកូឲ្យទៅទទួលចូកូជាបិតា
មកដល់ជិតស្រុកឈើជីវ៉ាហើយ ក៏មានសេចក្តីត្រេកអរចេញទៅគាប់ចូកូ
ហើយអញ្ជើញឲ្យចូលទៅសំណាក់ក្នុងស្រុកនោះ រួចឲ្យរៀបចាយទឹក

ចំណីអាហារឲ្យចូកូនទឹងក្រមុំគ្រួសាចរិកោគ ។ ចូកូឈប់សម្រាកនៅស្រុកនោះ ៤ ថ្ងៃ រួចត្រូកៀមចាត់ប្រើតៀវយីនឹងតាហាន ៩០០ ឲ្យជូនដំណើរចូកូទៅស្រុកគុនដារ ។ លុះទៅដល់តំបន់វត្តហៃហ៊ុយ ទទួលពេលយប់ធ្លាក់ភ្លៀងធំ ចូកូឲ្យឈប់សំណាក់អស្រ័យក្នុងទីនោះ ហើយឲ្យតៀវយីដែលឃុំតាហានជូនទៅនោះ ពាយតាហានត្រឡប់ទៅមយ៉ាមល្បាតជុំវិញពីក្រៅ លុះពេលកណ្តាលអធ្រាត្រស្ងាត់ តៀវយីប្រឹក្សាទឹងតាហានតាំងពួងថា កាលពីដើមយើងជាពួកចោរជួតក្បាលលឿង លុះមានគេមកប្រាប់ប្រាមយើងលើកលះព្យុហៈអាក្រក់ចេញចូលទៅនៅទឹងភ្លូកៀម ។ មិនមានឲ្យរបស់អ្វីសោះ ដែលយើងនឹងធ្វើពាជាមួយតទៅនោះឃើញថាមិនបានប្រយោជន៍អ្វីឥឡូវត្រូកៀមឲ្យយើងជូនដំណើរចូកូមក ចូកូមានទ្រព្យសម្បត្តិមាសប្រាក់ផ្កុតពេញរទេះច្រើនណាស់ យើងត្រូវតែលបសម្លាប់ចូកូចេញហើយយកទ្រព្យរបស់គាំងអស់ នាំគ្នារត់ទៅនៅចកកុំស្លេលជាង ។ តាហានគាំងអស់យល់ព្រមផង ភ្លៀងសោតក៏នៅពុំឈប់កំង តៀវយីលើកតាហានចូលទៅទឹងសម្លាប់ចូកូ ។ ឃានឮសូរតាហានគឹកកងចូលមក សុទ្ធឡើងដឹកដៃកវិយាតូចរត់ទៅ ។ ទទួលតៀវយីចោមព័ទ្ធពីក្រៅជាប់ សម្លាប់ក្រោកចូកូស្លាប់នៅទីនោះ កាប់គាំងប័ក្សពួកចូកូស្លាប់ដេរជាស ហើយក៏ជញ្ជូនយកទ្រព្យរបស់អស់គ្នានសល់ យកគាំងភ្លើងដុតកុដិអាកមនៅទីនោះឆេះអស់ទៅទៀត ហើយក៏នាំប័ក្សពួកទៅជ្រកពួនក្នុងព្រៃគៀនភ្នំ ។

ឯអេងតៀវកាលឃើញចូកូស្លាប់ហើយ ក៏គិតបារម្ភខ្លាចចូឆួ ទើបវត់
ទៅនៅទឹងអួនសៀវចៅហ្វាយស្រុកគីដីវ ។ ពួកឥហានដែលនៅជាមួយ
ទឹងអេងតៀវ ក៏នាំគ្នាវត់ត្រឡប់ទៅប្រាប់ចូឆួតាមដំណើរដែលមានមកពី
ដើម ហើយថាចូកូបិតាលោកដែលស្លាប់នោះ យើងខ្ញុំឃើញថា
តូកៀមប្រើកលឧបាយឲ្យតៀវឃីនាំឥហានដួនដំណើរមក ហើយក្លែង
លបសម្លាប់បិតាលោក យកទ្រព្យរបស់ទៅឲ្យតូកៀមជាប្រយោជន៍ជា
មួយគ្នា ។ ចូឆួបានឮថាបិតាស្លាប់ក៏ខ្ញាញយំដំណាអាល័យបិតា ពាល់តែ
ដួលធ្លាក់ពីលើគៅអីឋាត់ស្មារតីក្នុងទីនោះ ។ ពួកឥហានបានឃើញដូច្នោះ
ក៏ស៊ុះទៅគ្រាប់តែកងើបឡើងវិញ ។ ចូឆួលុះដឹងស្មារតីហើយ មានសេចក្តី
ខឹងខ្លាំងណាស់ថា "ដែលតូកៀមធ្វើកលឧបាយសម្លាប់បិតាយើង នឹងក្រុម
ញាតិរបស់យើង វេលានេះយើងនឹងលើកពួកពលឥហានទៅសង្កត់យក
ស្រុកឈីដីវឲ្យរាបដូចផែនដី ទើបអស់សេចក្តីក្តៅ" ថាហើយក៏កេណ្ឌ
ប្រមូលពលឥហានបានចំនួន ៣ ម៉ឺនប្រគល់ឲ្យស៊ីនហុកនឹងធៀយ៉ុក ទៅ
រក្សាស្រុកគុនដីវ ។ ឯខ្លួនចូឆួក៏កេណ្ឌឥហានផាច្រើន លើកជាកងទ័ព
ទៅដិតស្រុកឈីដីវ ហើយឲ្យតាំងបន្ទាយរាយទ័ពជុំវិញ ចាត់ប្រៃ
ហៃហ្វូនទឹងអ៊ីគិម, តៀនអ៊ុយ ឲ្យលើកឥហានជាកងមុខ បើវាយបាន
ស្រុកឈីដីវហើយ ឲ្យសម្លាប់ឲ្យអស់ទាំងប្រុសទាំងស្រីកុំឲ្យសល់ទើប
អស់កំហឹង ។

ខណៈនោះពៀនយៀង ចៅហ្វាយស្រុកគីវកាំង ដែលជាមិត្តស្និទ្ធស្នាលនឹងតូកៀម លុះបានដំណឹងថា ចូធូលើកទ័ពមកនឹងវាយយកស្រុកឈីជីវដូច្នោះ ក៏កេណ្ឌទាហាន ៥ ពាន់លើកទៅជួយតូកៀម ។ ចូធូបានដឹងដូច្នោះ ចាត់ប្រៃហៃហ្វូនឲ្យលើកទាហានទៅស្កាត់វាយទ័ពពៀនយៀងបានតទល់គ្នា ហៃហ្វូនក៏ប្រាំងកាប់សម្លាប់ពៀនយៀងនឹងពលទាហានស្លាប់អស់ ។

ឯតាន់កុងដែលលបរត់ចោលចូធូពីគ្រាមុននោះ បានទៅសុំទៅធ្វើពជការជាមួយនឹងចៅហ្វាយស្រុកតង់គុន ខ្លួនតាន់កុងជាមិត្តស្និទ្ធស្នាលនឹងតូកៀមដែរ កាលបើឮដំណឹងថា ចូធូលើកទ័ពទៅវាយស្រុកឈីជីវដូច្នោះ គាំងឮថាបើវាយស្រុកបានហើយ ឲ្យទាហានកាប់សម្លាប់មនុស្សគាំងប្រុសគាំងស្រីឲ្យអស់ តាន់កុងក៏ឡើងសេះតែម្នាក់ឯងស្រួតទៅគាំងយប់គាំងថ្ងៃដើម្បីនឹងហាមឃាត់ចូធូកុំឲ្យធ្វើអន្តរាយតូកៀម លុះទៅដល់មុខបន្ទាយនិយាយប្រាប់ទាហានចូធូថា យើងសុំទៅជួបនឹងចូធូ ទាហានក៏ចូលទៅជំរាបចូធូ ។ ដឹងហើយនឹកក្នុងចិត្តថា "ដែលតាន់កុងមករកយើងគ្រានេះមិនគឺអ្វី ប្រហែលមានការនិយាយពីរឿងតូកៀមជាប្រាកដ បើយើងមិនឲ្យចូលមកក៏បាន តែថាគេមានគុណបូកានឹងយើង កាលយើងរត់ពីគាំងតុ, តាន់កុងនេះចាប់បានហើយមិនបញ្ជូនខ្លួនយើងទៅបានជាយើងរស់រួចជីវិត" គិតហើយឲ្យទាហានហៅខ្លួនតាន់កុងចូលមក ។ ចូធូតំនាប់ហើយ

ស្ទួចថា អ្នកមករកយើងនេះមានត្រូវការរឿងអ្វី? ។ គាន់កុងដាពបថា ខ្ញុំដឹងថាលោកលើកទ័ពមកច្បាំងនឹងតូកៀម ប្រយោជន៍ទឹងសងសឹក ព្រោះបិតាលោកស្លាប់, ឯតូកៀមខេវហ្វាយស្រុកឈើដីវនោះ ខ្ញុំបានស្គាល់ចិត្តនឹងគំនិតមារយោធជាមនុស្សសុចរិតពិតត្រង់ណាស់ ប៉ុន្តែប្រឹតៀវយីឲ្យនាំគាហានដួនដំណើរបិតាលោកទៅដល់តំបន់ហៃហ៊ុយ; ដែលកើតហេតុឡើងក្នុងទីនោះ ព្រោះតៀវយីជាមនុស្សខ្ជិលចិត្តលោភសម្លាប់បិតាលោក យកទ្រព្យរបស់អស់ទៅហើយរត់ទៅពួនក្នុងព្រៃគាល់តែសម័យនេះ តូកៀមទឹងបានរួមគំនិតគិតឧបាយក្លាយក្លែងឲ្យធ្លើដូច្នោះកំរេ, ដែលលោកបង្គាប់គាហានថាបើវាយបានស្រុកឈើដីវហើយ ឲ្យសម្លាប់តាំងប្រុសតាំងស្រីឲ្យអស់នោះ ខ្ញុំយើញថាអ្នកស្រុកនោះគ្មានទោសខុសអ្វីសោះ លោកទឹងឲ្យសម្លាប់នោះមិនគួរ, ដែលខ្ញុំរាបតាំងនេះសូមលោកត្រិះរិះមើលសិនចុះ ។

ប៊ូឆ្ងូរហើយទឹងប្រឡោតឡើងទៀតថា កាលយើងរត់ពីតាំងតុ: មកនោះ អ្នកគិតព្រមល្មមទៅជាមួយយើង ហេតុម្តេចក៏រត់ចោលយើងកណ្តាលផ្លូវ តឡប់ត្រឡប់មករកយើងវិញ; ឯតូកៀមប្រាកដជាប្រើឧបាយឲ្យដួនបិតាយើងទៅ ហើយក្លែងឲ្យសម្លាប់យកទ្រព្យរបស់ជាពិត, ហេតុនេះ ទើបយើងឈឺចិត្តលើកទ័ពមកសងសឹកតូកៀមវិញ ដែលអ្នកទឹងបែរមុខយាត់ហាមយើងនោះ យើងមិនស្តាប់អ្នកទេ ។ គាន់កុងយើញ

ចូរឆ្ងល់ខ្លាំងណាស់ ក៏នៅស្ងៀមហើយលាចូរឆ្លេចញ្ជាតិបន្តាយមកវិញ ហើយនឹកគិតតែក្នុងចិត្តថា "អញមកហាមឃាត់ចូរមិនសម្តីដូចសេចក្តីប្រាថ្នា បើនឹងទៅកេរគូរកៀមក៏ចៀមចិត្តគួរគិតឲ្យអៀនខ្មាសណាស់" គិតហើយក៏ដើរត្រឡប់ទៅរកគៀវមៅនៅស្រុកគាន់លីវ ។

ឯចូរឆ្លើកថាហានទន្លានចូលទៅជិតស្រុកឈើដីវ ប្រទះនឹងមនុស្សប្រុសស្រីតន៏កន្ទែងណាក៏ឲ្យប្រហារឥតញញើតដៃសោះ ហើយឲ្យរើបយកទ្រព្យរបស់មកទុកជាច្រើន ។

ខណៈនោះគូរកៀមចៅហ្វាយស្រុកឈើដីវ ដែលដឹងថាចូរឆ្លើកចំពមកកាប់សម្លាប់អស់អ្នកស្រុកដូច្នោះ ក៏មានសេចក្តីបរិតក្តកើតទុក្ខវេទនាសោកាឈឺញយំអាណិតអាណាប្រជានុកស្តួតន់ប្រមាណ បានប្រជុំពិភ្រក្សាពិចារណាយល់ឃើញថា ការណ៍ដែលកើតហេតុទាំងនេះ ព្រោះអកុសលកម្មរបស់យើងតាមមកទាន់ហើយ បានជាត្រូវអន្តរាយស្លាប់គ្រប់គ្នា ។ ចូរ"ឆ្លើយថាខ្លួនលោកគ្មានសេចក្តីខុសអ្វីសោះ ឥឡូវនេះចូរឆ្លើកចំពមកធ្វើអន្តរាយដូច្នេះ លោកចេះតែនៅស្ងៀមក៏ពុំកើត សត្រូវកាន់តែដួលឡើងទៀត ត្រូវយើងកេណ្ឌកងចំពតឡប់ទៅតតាំងច្បាំងគ្នាវិញទើបបាន ។ គូរកៀមឃើញត្រូវផង ក៏តាំងកេណ្ឌទាហានបានកងខណៈនោះ ដល់ព្រឹកឡើងឲ្យបើកទ្វារស្រុកលើកទាហានចេញទៅក្រៅទៅឃើញកងចំពចូរច្រើនលើសលប់ឧបមាដូចរលកសមុទ្រ ។

(មានត)

ភាគទី ២

សម័យឧត្តរង្គ

ឧកញ៉ាទេពពិទូរ ឈឹម - គ្រែសេម រៀបរៀង

(តមក)

ឱកាសរបស់ព្រះជ័យវរ្ម័ន — វេលានោះពុទ្ធសម្បត្តិទំនេរ ។ ព្រះជ័យវរ្ម័នដែលទ្រង់រង់ចាំឱកាសអស់វេលា ១៨ ឆ្នាំហើយ ទ្រង់ឈ្វេងយល់ថា "វេលានេះ ដល់ពេលដែលទ្រង់ត្រូវចាត់ការស្រោចស្រង់ប្រទេសជាតិ ដែលលិចលង់មកយូរឆ្នាំនោះហើយ" ទើបទ្រង់រួបរួមសេនាពាហន ហើយឡើងគ្រងរាជបល្ល័ង្ក តែពុំទាន់បានធ្វើព្រះពុទ្ធាភិសេកនៅឡើយ ។

ការផែនដី — ក្នុងសម័យដែលចាម្ប៉ាលុកលុយប្រទេសកម្ពុជាក្នុងឆ្នាំ គ. ស. ១១៧៧ នោះ ប្រាកដក្នុងសេចក្តីកត់ហេតុរបស់អ្នកប្រវត្តិសាស្ត្រចិន ១ នាក់ឈ្មោះម៉ាតួនលិនថា ព្រះជ័យវរ្ម័នបានទ្រង់ប្តេជ្ញាក្នុងព្រះហឫទ័យថា នឹងធ្វើការសងសឹកចាម្ប៉ាវិញ ឲ្យល្បីល្បាញ, ហើយសេចក្តីប្តេជ្ញានោះបានសម្រេចយ៉ាងអស្ចារ្យ ក្នុងពេលក្រោយដែលទ្រង់អត់ទ្រាំមកអស់ ១៨ ឆ្នាំ ។

ប៉ុន្តែមុននឹងខ្ញុំប្រតិបត្តិការតាមព្រះពាជបដិញ្ញានោះ ខ្ញុំត្រូវការនឹងរម្លាប់អស្ចារ្យសុខដែលមានទៅក្នុងប្រទេសជាមុនសិន គឺក្នុងពេលនោះមានការណ៍បះបោរនៅតំបន់មលៀង ដែលនៅជាខាងត្បូងខែ្មរតែបាត់ដំបងសព្វថ្ងៃនេះ ។ ខ្ញុំបានចាត់ព្រះពាជវង្សាមួយ ១ អង្គព្រះនាម "វិញ្ញានន្ទន" ដែលបានចូលមកជ្រកកោនក្រោមព្រះបរមពោធិសម្ភារ ឲ្យនាំទៅកែ្មរ ព្រះអង្គម្ចាស់នេះក៏ចាត់ការកែ្មរបានសម្រេច ។

ប្រវត្តិព្រះអង្គវិញ្ញានន្ទន [ចាកជតាមសិលាចារឹកនៅតំបន់មីសឺនថា "ព្រះអង្គម្ចាស់វិញ្ញានន្ទនជាព្រះពាជនុរសក្សត្រិយ៍ចាម្ប៉ា កាលនៅកុមារភូប ក្នុងឆ្នាំ ១១៨២ ខ្ញុំបានចូលមកសុំជ្រកកោនក្រោមព្រះបរមពោធិសម្ភារនៃព្រះមហាក្សត្រិយ៍ខែ្មរ ។ ក្នុងគ្រានោះព្រះពាជាខែ្មរ គឺព្រះបាទជយវរ្ម័នទី ៧ ដែលខ្ញុំទើបនឹងបានគ្រងពិភពកម្ពុជា ខ្ញុំសង្កេតឃើញថា "ព្រះអង្គម្ចាស់នេះប្រកបដោយលក្ខណៈល្អ" ព្រះអង្គក៏ទទួលចិញ្ចឹមខ្ញុំស្មើឪពុកបង្កើតរបស់ព្រះពាជនុរស ខ្ញុំបានបង្រៀនចំណេះវិជ្ជាគ្រប់យ៉ាង ទាំងក្នុងវិទ្យាសាស្ត្រ ទាំងក្នុងយុទ្ធសាស្ត្រ ។

ក្នុងគ្រានោះ នៅតំបន់ស្រុក មលៀង ដែលនៅជាខាងត្បូងខែ្មរតែបាត់តំបង់សព្វថ្ងៃនេះ សង្កែតែជាមនុស្សអាក្រក់អាស្រ័យនៅ តើតបះបោរឡើង ។ ព្រះបាទជយវរ្ម័ន ត្រាស់ចាត់ឲ្យព្រះវិញ្ញានន្ទនដែលនៅចំពង់ឲ្យនាំទ័ពទៅកែ្មរបង្ក្រាបបះបោរនោះ ។ ព្រះវិញ្ញានន្ទនបានចាត់ការ

កម្រាបអរិភាជសត្រូវឲ្យរាបទៅ តាមព្រះរាជបំណងនៃព្រះមហាក្សត្រិយ៍ ហើយនាំទ័ពត្រឡប់ព្រះនគរវិញ ដោយសុវត្ថិភាព ។ កាលព្រះរាជាខ្មែរយើញដំឡៃនឹងស្នាដៃព្រះវិទ្យាធនូធំយ៉ាងនេះហើយ ក៏រីករាត់តែសព្វព្រះរាជហឫទ័យឡើងវិញ, បានត្រង់ព្រះមេត្តាប្រោសព្រះរាជទានយសជាយុវរាជ ព្រមទាំងទ្រព្យសម្បត្តិ និងគ្រឿងសប្បាយគ្រប់យ៉ាង ។ ព្រះវិទ្យាធនូធំបានជាអាវុធដ៏សំខាន់ ក្នុងការសង់សិកស្តេចជយតន្ត្រីវរ៉ែនទៅក្នុងថ្ងៃក្រោយ ។

កាលព្រះចុងជយវរ៉ែនត្រង់ចាត់រៀបចំស្រុកទេស បានសាន្តត្រាណហើយក៏ត្រង់នឹកដល់សេចក្តីប្តេជ្ញាដើម តែមុននឹងត្រង់ចាត់ការតាមប្តេជ្ញានោះ បានត្រង់តែងរាជទូតឲ្យទៅសុំចង សម្ពន្ធមេត្រីភាព នឹងស្តេចអណ្ណាមនៅក្រុងលីការតុង ។ ស្តេចយួនក៏ព្រមទទួលសម្ពន្ធមេត្រីភាពផង ព្រះមហាក្សត្រិយ៍ខ្មែរបានចងសម្ពន្ធមេត្រីភាពនឹងក្សត្រិយ៍យួន ជាគ្រាទី ២ ក្នុងរជ្ជកាលនេះ[1] ។

សង្គ្រាមចាម្ប៉ាគ្រាទី ៦

ក្រោយនោះ ត្រង់ក៏គិតលៃលកវាតុកាសល្អដែលសង់សិកចាម្ប៉ាឲ្យដល់ខ្នាត, តុកាសល្អនេះ បានមានឡើងក្នុងឆ្នាំ ៣. ស. ១៧៣៣ គ. ស. ១១៩០ ។ ដោយក្នុងពេលនោះព្រះជយតន្ត្រីវរ៉ែនដែលយង់ឃ្នង

---

១ ក្នុងរជ្ជកាលព្រះបាទសុរ្យវរ្ម័នទី ២ បានចងសម្ពន្ធមេត្រីភាពជាគ្រាទី ១ ។

ដូចជាក្រុងពពាណ៌ ។ បានលើកទ័ពមកវាយប្រទេសកម្ពុជាម្តងទៀត ជាគ្រាទី ៣ ។ កាលព្រះបាទជយវរ្ម័នទ្រង់ជាបពតិមានសឹកហើយ គ្រាស់ឲ្យព្រះវិញ្ញានន្ទ្ធន៍កាន់កាប់ទ័ពស្តេច ចំណែកព្រះអង្គទ្រង់តំណែងជាមហាក្សត្រិយ៍សឹក កាន់កាប់ទ័ពហួងលើកចេញទៅតទល់នឹងទ័ពព្រះជយឥន្ទ្រវរ្ម័ន ។ កងទ័ពខ្មែរបានដេញទ័ពចាម្ប៉ាត់ខ្លាយ រត់ទៅក្រុងពិជ័យវិញ ។ ទ័ពខ្មែរក៏ដិតដោយតាមទៅដល់ក្រុងវិជ័យ ចាប់បានយក្សជយឥន្ទ្រវរ្ម័នទាំងរស់ ។

កាលស្រេចព្រះពជសង្គ្រាមហើយ ទ្រង់តាំងព្រះពជវង្ស ១ អង្គ ត្រូវជាព្រះអនុជថ្លៃរបស់ព្រះអង្គជាទីមហាឧបពជ ឲ្យទៅគ្រប់គ្រងប្រទេសចាម្ប៉ា នឹង ទ្រង់ព្រះមេត្តាប្រោសតាំងព្រះវិញ្ញានន្ទ្ធន៍ឲ្យទៅគ្រងវៃត្រ បណ្តាវង្ក ទៅខាងត្បូងក្រុងវិជ័យ គឺទៅស្រុកផាងក៉ាងសព្វថ្ងៃនេះរួចហើយស្តេចលើកទ័ពត្រឡប់ព្រះនគរ បានទាំងនាំយកព្រះជយឥន្ទ្រវរ្ម័នមកទុកជាឈ្លើយនៅព្រះនគរផង ។

ក្រោយដែលទ្រង់បានកម្ចាត់អស្ថន្តិសុខក្នុងប្រទេស នឹងក្រៅប្រទេសឲ្យស្ងប់សាន្តគ្រាណាស់រលោ ៤ ឆ្នាំមកហើយ ទើបទ្រង់ឲ្យធ្វើព្រះពជពិធីបរមេកជាពិសេក នៅក្នុងឆ្នាំ ព.ស. ១៧២៤ (គ.ស. ១១៨១) ទ្រង់តាំងព្រះនាងជយពជទេវី ជាអគ្គមហេសី ។

(មានត)

ពិធីបុណ្យប្រគេនព្រហ្មទាន

ចំពោះព្រះសង្ឃ ៨៨ រូបដែលប្រឡងជាប់សញ្ញាប័ត្រ

សាលាចាលីជាន់ខ្ពស់

ផ្សាយពីសមាគមមិត្តសាលាចាលី

កាលពីថ្ងៃទី ២៥ កុម្ភៈ គ.ស. ១៩៩១ នៅទីយ៉ាសាលាចាលីជាន់ខ្ពស់មានពិធីបុណ្យមួយជាឧឡារិក គឺបុណ្យប្រគេនព្រហ្មទានដល់ព្រះសង្ឃ ៨៨ រូប ដែលទើបប្រឡងជាប់សញ្ញាប័ត្រសាលាចាលីជាន់ខ្ពស់ក្នុងឆ្នាំ ១៩៩១ នេះ ដែលកើតឡើងដោយសេចក្តីណែនាំនៃសមាគមមិត្តសាលាចាលី ។

ពិធីបុណ្យនេះ ចាប់ផ្តើមតាំងពីល្ងាចថ្ងៃទី ២៤ កុម្ភៈដោយរៀបចំវេនព្រះបរិត្ត មានព្រះសង្ឃនឹងឥស្សរជនចូលរួមយ៉ាងច្រើនកុះករ ។ ដល់ម៉ោង ២១.៣០ នាទី ព្រះតេជព្រះគុណព្រះពោធិវង្សាចារ្យហ្វាងសាលាចាលីជាន់ខ្ពស់ បានសំដែងធម្មទេសនាសរសើរផលនៃព្រហ្មទានជាដើម ព្រមទាំងពន្យល់អំពីចរិយាសម្បត្តិជាកិច្ចដាស់តឿនរំលឹកដល់ព្រះសង្ឃទាំងនោះ ឲ្យខំធ្វើអាកប្បកិរិយាឲ្យបានសមរម្យគួរជាទីជ្រះថ្លាដល់ពុទ្ធបរិស័ទតទៅអនាគត ។ រួចហើយ, ឯកឧត្តម សម-ញ្ញាណ បានប្រកាសសេចក្តីខ្លួលអំណរគុណចំពោះពុទ្ធបរិស័ទ តាងនាមសមាគមមិត្តសាលាចាលី នឹង អធិប្បាយរៀបរាប់

អំពីបំណងរបស់លោកចង់ពន្លឿកមន្ទីរពុទ្ធសាសនបណ្ណិត្យ ឲ្យបានខូលាយ
ឡើង លុមជាទីទស្សនីយភាពនៃជនទាំងពួង ។

លុះព្រឹកឡើងថ្ងៃទី ២៩ ខែដដែល តាំងពីម៉ោង ១០ ព្រះសង្ឃពាជ
គណៈ ហានានុក្រម ប្រមាណ ៥០០ រូប ព្រមទាំងឥស្សរជនទំងពុទ្ធ-
បរិស័ទ្យបានទិមន្តអញ្ជើញទៅកាន់ពីធីបុណ្យនោះ ។ ចំណែកខាង
ព្រះសង្ឃ មានសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកវត្តបទុមវតីគណៈ
ធម្មយុត្តិ, សម្តេចព្រះធម្មលិខិតទត្តមប្រឹក្សាវត្តលង្កា, សម្តេចព្រះមហា
សុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ នឹងព្រះតេជព្រះគុណព្រះ
ពោធិវង្សជាដើម ។ ប៉ែកខាងឥស្សរជន គឺឯកទត្តម អ៊ុំ-ឈាងស៊ុន
ប្រធានក្រុមប្រឹក្សាព្រះពាជអាណាចក្រ, ឯកទត្តមញឹក-ជូឡង់, ជាជន-
កុក, សម-ញាណ, ក្រៅពីនេះគឺ ឯកទត្តម ស៊ុំហៀង, ក៉ា-កាមុល,
សាន-យុន, ក៉ាយ-លុត នឹង ចាប-ឈឺន ជាដើម ។ យើងសូម
អភ័យទោសដោយមិនបានពយនាមនៃអស់លោកដោយសព្វគ្រប់ ។

ដល់ពេលម៉ោង ៩ ព្រះករុណាជាអម្ចាស់ដ៏វិតលើត្បូង ទ្រង់បាន
ស្តេចយាងទៅដល់ប៉ាសាលាចាលីជាន់ខ្ពស់ ដោយមានបរិពារតាមហែ
ទ្រង់ទៅផង ហើយមានតាហានឹងក្លេងជាតិចាំឆ្លៀតវៃកិច្ច ។ ចំណែក
ព្រះសង្ឃនឹងឥស្សរជនក៏ឆើចាំទទួលព្រះករុណាជាអម្ចាស់ដ៏វិតលើត្បូង ។
លុះទ្រង់ប្រថាប់ហើយ, លោកអធិបតីសមាគមមិត្តសាលាចាលី បានថ្លែង

សុន្ទរកថាមួយខ្លួលអំណរព្រះមហាក្សត្រី នឹងរៀបរាប់អំពីវត្តបំណង របស់សមាគមមិត្តសាលាចាំលី ដែលផ្តួងជួយទុបត្ថម្ភការសិក្សាសាលាចាំលីជាន់ខ្ពស់ ព្រមទាំងរៀបរាប់អំពីកិត្តិគុណនៃសាលានេះ ដោយលើកយកសេចក្តីប្រៀបធៀបជាច្រើនប្រការមកបរិយាយ ។ លំដាប់តមកព្រះគេជព្រះគុណពោធិវង្សបានសូត្រសុន្ទរកថាមួយទៀត សរសើរផលនៃព្រហ្មចរដោយហេតុថាសាលាចាំលីជាន់ខ្ពស់ បានកើតឡើង ៣៦ ឆ្នាំហើយ មិនដែលមានធ្លាប់ពិធីបែបនេះទេ ហើយនឹងប្រគូនត់ដល់ព្រះសង្ឃដែលទើបប្រឡងជាប់នុ៎ះ ឲ្យខំព្យាយាមរៀនសូត្របន្តវិជ្ជាទៅទៀត ព្រមទាំងឲ្យខំអប់រំចរិយាសម្បត្តិឲ្យសមរម្យ គួរជាទីគោរពនឹងជាគំរូនុគតដល់អ្នកពាំងពួន ព្រោះថាមនុស្សពាំងពួន ទោះបីចេះដឹងយ៉ាងណាក៏ដោយ បើប្រាសចាកចរិយាសម្បត្តិហើយ នឹងទៅជាមនុស្សថ្លៃថ្លរពុំបានឡើយ ។

បន្ទាប់មក ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់ប្រគេនសញ្ញាប័ត្រ នឹងព្រហ្មចរបស់ទ្រង់ ដល់ព្រះមហា មាយ - ឩក ដែលប្រឡងជាប់លេខ ១ ។ បន្ទាប់ពីនេះ ទើបអ្នកកាន់អង្គពាំងព្រាយ ព្រមទាំងអស្សរជន បានលើកព្រហ្មចរប្រគេនចំពោះព្រះសង្ឃ ជាលំដាប់ដល់លេខ ៨៨ ។ រួចហើយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ថ្វាយព្រះពរសុន្ទរកថាមួយយ៉ាងសង្ខេប សរសើរអំពីវិរិយភាពនៃព្រះ

សង្ឃជាសិស្សានុសិស្សទាំងនោះ ដែលយើងយកមកចុះទាំងមូលជូនអ្នក អានដូចមានខាងក្រោយ ។

បញ្ជាក់អំពីព្រហ្មទានដែលលើស

ព្រះសង្ឃដែលសមាគមមិត្តសាលាចាលីបានប្រកាសដល់អស់លោក សូមឲ្យជួយកាន់អង្គនោះមានចំនួន ៨៨ រូប, ចំណែកព្រហ្មទានដែលបានមកចំនួន ១០៦ ឃើញលើសខ្សែវត្ត ១៨ ។ រីឯខ្សែវត្តដែលលើសនេះ បានមកដល់ពេលក្រោយដែលគណៈកម្មការរៀបចំជាក់លេខរង្វាន់នោះហើយស្រេច យើងបានវេរខ្សែវត្តទាំងនោះ ទៅប្រគេនលោកគ្រូបង្រៀនធឹងធម្មចឹកសំដែងធម៌ ។ ដូចព្រហ្មទានរបស់ឃុនព្រះមែ៉នាងបុប្ផានរល័ក្ខណ៍ តាត យើងបានប្រគេនទៅលោកគ្រូព្រះពោធិវង្សជាធម្មកថឹក; ព្រហ្មទានពីរបស់លោកស្រីម៉ូះ ១, លោកអ៊ុងឌិនអួន ១ យើងបានប្រគេនទៅលោកគ្រូចាងហ្វាងវេសាលាចាលីជាន់ខ្ពស់ នឹងលោកគ្រូអាចារ្យសុក្រសាស្ត្រាចារ្យចាលី ។ ព្រហ្មទានរបស់លោក អ៊ុច-រស ១ចាសិកាឡង, ឯក១ត្តមមាសឯម, លោកសាម៉ន, ១ចាសិកា ខៃម, លោកយ៉ិប-ឆ្លួន, លោកប៊ុត-នាង, លោកអ៊ីក្រមពន្ធជាតិ, ថៅកែដឹង-ឆ្លួនហួត, លោកសឺនសាន, លោកឌុចអ្នកសយ, លោកម៉ែ-ប៉ាន់, លោកយាយកែវ ទាំងអស់នេះ គណៈកម្មការបានប្រគេនលោកប្រឡងភ្ជាក់ ៣ អង្គ, នឹងសាស្ត្រាចារ្យសាលាចាលីជាន់ខ្ពស់ទាំងឡាយ ។

ឯសៀវភៅ "អស្សុយុជបូជា, មាយបូជា" ចំនួន ១០០ ក្បាល ជាព្រះពរដ៏អំណោយព្រះគុណជាម្ចាស់ជីវិតលើត្បូង សមាគមមិត្តសាលាចាស់ បានយកទៅបញ្ចូលនឹងព្រហ្មទានពីទី ១ រហូតដល់ទី ៨៨ ។ ឯសៀវភៅសល់ ១២ នោះ សមាគមបានយកទៅដាក់បញ្ចូលក្នុងព្រហ្មទានដែលលើស ប្រគេនលោកសង្ឃ ៣ អង្គដែលប្រឡងធ្លាក់នឹងគួបង្រៀន ។

បណ្ណាសៀវភៅរបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ គឺបក្ខគណនាវិធី ៨៨ ក្បាល សុរិយាឡើងសក្ក ៨៨ ក្បាល នឹងពិធីព្រះទសមាស ១០ ក្បាល, សមាគមបានយកសៀវភៅបក្ខគណនាវិធីនឹងសុរិយាឡើងសក្ក មួយៗ ដាក់ក្នុងព្រហ្មទានពីលេខ ១ ដល់លេខ ៨៨, ឯសៀវភៅពិធីព្រះទសមាស ១០ ក្បាល បានយកទៅដាក់ក្នុងព្រហ្មទានតាំងពីទី ១ រហូតដល់ទី ១០ ។ ឯសៀវភៅច្បាប់ក្រមបរិយាយ ៥ ក្បាល របស់លោកមហាមន្ត្រី ញឹក-នូ សមាគមបានយកទៅដាក់ក្នុងព្រហ្មទានទី ១ ដល់ទី ៥ ។ រីឯទៀតរបស់អ្នកម៉ែនាងកៀង, លោកឡាំ-ឯម, ស៊ុន-វ៉ន់, ល.ជុន, សាម៉ន គណៈកម្មការបានយកទៅបញ្ចូលក្នុងព្រហ្មទានក្រៅពីនេះ ។

សុន្ទរកថា

លោក រ៉ាយ-ប៊ុក អធិបតីសមាគមមិត្តសាលាបាលី

ថ្ងៃឆ្លងកឋិនសាមគ្គីប្រគេនព្រះហ្វូងាន ដល់សិស្សសាលាបាលីជាន់ខ្ពស់
នៅថ្ងៃ ២៥ កុម្ភៈ គ.ស. ១៩៥១ ។

សូមព្រះតេជៈដំកល់លើតុង

សូមព្រះពុជ្ឍានព្រះបរមពុជវរោកាសក្រាបបង្គំទូលថ្វាយព្រះករុណា
ជាអម្ចាស់ជីវិត សូមទ្រង់ជ្រាប

ក្រែមលួងធុលីព្រះបាទ ។

សូមថ្វាយបង្គំ សម្តេចព្រះសុធម្មាធិបតី សង្ឃនាយក,

— — សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា,

— — សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក,

— — ព្រះពោធិវង្សាចារ្យហ្វាង៑សាលាបាលីជាស់ខ្ពស់,

— — ព្រះថេរានុត្ថេរៈគាំងឡាយ,

សូមក្រាបទូលទ្រង់គាំងឡាយ,

សូមដំរាប ឯកឧត្តមប្រធានក្រុមប្រឹក្សាព្រះពុជអាណាចក្រ,

— ឯកឧត្តមរដ្ឋមន្ត្រីគាំងឡាយ,

— លោកស្រីគាំងឡាយ,

— លោក-អ្នកគាំងឡាយ,

ទូលព្រះបង្គំជាខ្ញុំ, ខ្ញុំព្រះករុណា, ខ្ញុំប្រថុច, ខ្ញុំថុច តាងនាម សមាគមមិត្តសាលាចាលី ' សូមព្រះពរជាន់អភ័យគោសប្រកាសជា ទឡ្ហារិតចំពោះល្អង់ជូលីព្រះចុច ថាថ្ងៃនេះជាថ្ងៃនក្ខត្តឫក្ស គឺពិធីបុណ្យ ចែកព្រហ្មចាន ដល់សិស្សដែលទើបប្រឡងជាប់សញ្ញាប័ត្រសាលាចាលី ជាន់ខ្ពស់ ក្នុងឆ្នាំ ១៩៥១ ។ ក្នុងឧកាសបុណ្យនេះ, ព្រះករុណាជាអម្ចាស់ ដ៏រឹតត្រង់ចានសំដែងទឹកព្រះទ័យជ្រះថ្លាដ៏ខ្ពង់ខ្ពស់ មកជាព្រះពរជាធិបតី ទុកជាព្រះពរកិត្តិយសដ៏ប្រសើរបំផុត ចំពោះ សមាគមមិត្តសាលាចាលី ដែលខំព្យាយាមបំពេញការណ៍យកិច្ចតាមវត្ត បំណង ដែលមានសំដែងក្នុងប្រការ ៤ នៃលក្ខន្តិក: ថា "ឧបត្ថម្ភអ្នក សិក្សាការសាចាលីនឹងការសាជាតិ ដោយសម្ភារៈនឹងសីលធម៌" ។

វត្ថុបំណងនេះ បើពិចារណាតាមអត្ថន័យព្យញ្ជន: ចានសេចក្តីដែង ឆ្ងាយទូលាយ មានការឧបត្ថម្ភព្រះពុទ្ធសាសនាទូទៅទាំងកម្ពុជរដ្ឋទាំងមូល ឲ្យមានកិត្យានុភាពពេញបរិបូណ៌ រហូតដល់ផ្សាយឥទ្ធិពលទៅនានា ប្រទេសថែមទៀតផង ។ ព្រោះហេតុដូចនេះ ការឧបត្ថម្ភនេះ ទុកជា កិច្ចមួយក្នុងភាគបួន ដែលសមាគមនេះត្រូវបំពេញតទៅទៀត តាមធន ជានដែលគួរនឹងធ្វើបានក្នុងអនាគត ។ បើទុកជាមានឧបសគ្គមកភ័ង្ក យ៉ាងណា ក៏សមាគមនេះខំព្យាយាមធ្វើដំណើរការទៅតាមថ្នាក់តាមជាន់ តស៊ូនឹងឧបសគ្គនោះគ្រប់យ៉ាងដោយសុទ្ធចិត្ត ដើម្បីឲ្យបានសម្រេចទៅ

តាមវត្តបំណង់ខាងលើ ។ តែកិច្ចការនេះដែលនឹងចំរើនទៅបាន លុះតែពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ ទាំងក្នុងក្រុងនឹងខេត្តក្រៅ ក្នុងសាកលកម្ពុជរដ្ឋទាំងមូល មានសាមគ្គីធម៌ព្រមព្រៀងមូលមិត្តគ្នាជាឯកច្ឆន្ទ ជួយឧបត្ថម្ភការៈនេះតាមកម្លាំងទ្រព្យ កម្លាំងសតិបញ្ញាគ្រប់ៗគ្នា ។ ហេតុ នេះគួរទុកសមាគមនេះជាកម្លាំងមួយរបស់សាលាបាលីជាន់ខ្ពស់ ដែលជាព្រះកិត្តិយសនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់មានព្រះវិរិយភាពស្អាងវិជ្ជាស្ថានដ៏ឧត្តម សម្រាប់ផ្សាយកិត្តិស័ព្ទនៃព្រះពុទ្ធសាសនា នឹងអក្សរសាស្ត្រ, អក្ខរបាលក្បាទ្វារភាសាបាលី នឹងភាសាជាតិព្រមទាំងវប្បធម៌ខ្មែរ, ទំនៀមទម្លាប់ខ្មែរ ឲ្យគង់ទ្រង់រហូតមកដល់សម័យបច្ចុប្បន្ននេះ ។ សាលាបាលីជាន់ខ្ពស់មិនមែនមានកិត្តិគុណត្រឹមប៉ុណ្ណេះទេ គឺជាសាលាមួយសម្រាប់អប់រំខាងគរុវិទ្យាផ្នែកសាសនានឹងអក្សរខ្មែរបាលី ដើម្បីនឹងផ្ទេរចំណេះនេះទៅជនជាតិខ្មែរគ្រប់ភូមិស្រុកនិគមជនបទក្នុងក្រមជរដ្ឋ ។ ព្រះសង្ឃទាំងនេះ ជាគ្រូបាអាចារ្យនៃជនជាតិខ្មែរដោយភាគច្រើន ព្រោះលោកតែងនិមន្តទៅទេសនាប្តូរគ្នាន ប្រដៅទ្វារធម៌វិន័យគ្រប់ច្រកល្ហកជានិច្ចរាល ។ ព្រះមហាក្សត្រទុកជាវត្តធាតុដ៏ឧត្តម, សាលាបាលីជាន់ខ្ពស់ទុកជាដើមវុក្ខា, ព្រះសង្ឃជាបុប្ផាក្រអូប, ឧបាសកឧបាសិកា ជាឃ្មុំប្តូរន្ទ្រីដែលតែងជញ្ជក់ទ្វារលំអងបុប្ផាទាំងនោះមកធ្វើសំបុក គឺចំណេះគ្រប់ៗគ្នា ។ បណ្ឌិតសម័យថ្មី

អាចពោលចំពោះកម្ពុជរដ្ឋថា "សាលាចាលីជាន់ខ្ពស់ជាខួរសរីរៈនៃកម្ពុជរដ្ឋ" ដូចជាអ្នកប្រាជ្ញខាងអឺរុបគេធ្លាប់ពោលមកថា "ក្រុងប៉ារីសជាខួរសរីរៈពិភពលោក" ដូចនោះ ។

ការជួយទំនុកបំរុងសមាគមមិត្តសាលាចាលី ឈ្មោះថាជួយទំនុកបំរុងសាលាចាលីជាន់ខ្ពស់នឹងសាលាចាលីរង តាមវត្តនានាក្នុងក្រុងនឹងខេត្តក្រៅផង ឈ្មោះថាអប់រំព្រះសង្ឃ ដែលមានឋានៈជាមហាអាចារ្យ ឲ្យមានកាន់តែទ្វេចំនួនច្រើនឡើងរាល់ៗឆ្នាំផង ឈ្មោះថារចនាខួនឲ្យមានវិជ្ជា ឲ្យមានពន្លឺភ្លឺស្វាងរុងរឿង ដើម្បីឲ្យការសាទឹងអក្សរជាតិវិវត្តន៍ទៅកាន់វឌ្ឍនធម៌បានផង ។

ព្រោះសមាគមមិត្តសាលាចាលីយល់ឃើញថា សាលាចាលីជាន់ខ្ពស់ ជាវិជ្ជាស្ថានមួយដ៏ប្រសើរ អាចបណ្តុះពូជបណ្ឌិតអ្នកប្រាជ្ញបានខើបបានជាផ្តើមធ្វើបុណ្យប្រគេនព្រហ្មចារីនេះ ដើម្បីនឹងញ៉ាំងទឹកព្រះទ័យនៃព្រះសង្ឃដែលខើបបានប្រឡងជាប់នឹងព្រះសង្ឃដែលខើបប្រឡងចូលក្នុងឆ្នាំ ១៩៥១ នេះ ឲ្យមានហ៊ាមភាពប្រកបដោយហសិតុប្បាទចិត្តដ៏ខ្ជាប់ខ្ជួនឡើង ។ ករណីយកិច្ចនេះ ជាប្រពៃណីនិយមដែលជនជាតិខាងបស្ចិមប្រទេសគេធ្លាប់ធ្វើមក ដើម្បីជាវង្វាន់ដ៏វិសេសដល់សេចក្តីព្យាយាមប្រឹងប្រែងនៃសិស្សទាំងនោះ ហើយជាគ្រឿងលើកទឹកចិត្តសម្រាប់ទាក់ចិត្តសិស្សដែលប្រឡងជាប់ ហើយឲ្យខំរៀនវិទ្យាថ្នាក់ខ្ពស់ត

ទៅទៀតនឹងសិស្សដែលប្រឡងចូលទៅរៀន ឲ្យ១សប្តាហ៍រៀនសូត្រ វិទ្យានោះ ទាល់តែបានសម្រេចដូចបំណងគ្រប់ៗគ្នា ដូចជាគ្រឿងឥស្សរិយយស ជាគ្រឿងស្តុចលើកទឹកចិត្តសម្រាប់ទាក់មន្ត្រីនឹងទាហាន ឲ្យបំពេញមុខការកាន់តែមាំមួនតទៅទៀត ។

ថ្ងៃនេះទុកជាថ្ងៃដ៏យមង្គល សម្រាប់ឲ្យសិស្សដែលបានប្រឡងជាប់ នឹករឭកជាអនុស្សាវរីយ៍ ក្នុងមនោទ្វារជ្ឈនៈ ដែលបញ្ចេញនូវសុភនិមិត្ត អាចទស្សនាទៅហើយនាំឲ្យតើតបីតិបាមោជ្ជៈ ប្រកបដោយអច្ឆរិយភាព, ក្លេចទឹកដល់ការព្រួយលំបាកខ្សើយហត់អត់ឃ្លានពីអតីតកាល ថែមទាំងឲ្យសិស្ស ដែលទើបប្រឡងចូលធ្វើមនសិការទុកក្នុងចិត្តដោយខ្ចាយដ៏ប្រពៃថា នឹងព្យាយាមឲ្យពេញកម្លាំងដើម្បីនឹងសម្រេចឥដ្ឋផលនេះ ។

សមាគមមិត្តសាលាបាលី សូមថ្វាយកតញ្ញូកតវេទិចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់មានព្រះពាជហ្ឬទ័យសោមនស្សទុត្តមកិច្ចដែលសមាគមនេះបានធ្វើហើយ ជាជាកិច្ចមានសារៈប្រយោជចំពោះសាលាបាលីជាន់ខ្ពស់ផង ចំពោះពួកសិស្សសាលានេះផង ដោយព្រះពាជហ្ឬទ័យស្មោះស្ម័គ្រនឹងការសិក្សាវិជ្ជាពុទ្ធសាសនា ហើយនឹងដោយព្រះអង្គទ្រង់ជាពុទ្ធសាសនូបត្ថម្ភក៍ពិតៗ ទ្រង់យកព្រះហ្ឬទ័យទុកជាក់គ្រប់ផ្លូវគ្រប់ផ្នែក គ្រប់ថ្នាក់ ដោយព្រះមហាករុណាទិគុណដ៏ពន្ធឹក ។ សូមថ្វាយសេចក្តីអគុណចំពោះសម្តេច, ទ្រង់, ព្រះតេជព្រះគុណ, លោក-អ្នក

ទាំងឡាយ ដែលមានសាមគ្គីធម៌មកជួយទប្ទម្ភការកុសលនេះឲ្យបានសម្រេច ដោយយល់ថា សាលាចាលីជាន់ខ្ពស់ជាឃ្លាំងមួយធំ សម្រាប់តំកល់ទុកនូវវិជ្ជាខាងពុទ្ធសាសនានឹងអក្សរសាស្ត្រខ្មែរ សម្រាប់ប្រជាជនខ្មែរ ត្រូវការសិក្សារៀនសូត្រតាមច្បាប់, ម្យ៉ាងទៀតវិជ្ជានេះចាយណាស់ កាន់តែចំរើនណាស់, បរិភោគមិនចេះឆ្អែតអ្នកស្តាប់, បរិភោគណាស់ឃ្លានណាស់ ។ កិត្តិគុណនៃសាលាចាលីជាន់ខ្ពស់មានជាអនេកបរិយាយមិនអាចយកមកពណ៌នាឲ្យបានចប់សព្វគ្រប់ ព្រោះជាឃ្លាំងវិជ្ជាមិនចេះស្រកស្រុត ដូចទឹកសមុទ្រចេះតែពេញព្រៀបជានិច្ច ។

ក្នុងអវសានេះ សមាគមមិត្តសាលាចាលី សូមទ្វេីសថ្វាយព្រះពរកុសលដែលកើតដោយបុណ្យនេះ ចំពោះព្រះករុណាជាអម្ចាស់ដ៏វិតលើត្បូង ព្រមទាំងសម្តេច, ព្រះតេជព្រះគុណគ្រប់អង្គ, ឧទ្ទេស, ឯកទ្ទគ្គម, លោកអ្នកជាពុទ្ធមាមកជនទាំងឡាយ, ហើយសូមគុណានុភាពព្រះរតនត្តយ ព្រមទាំងវត្ថុសក្តិសិទ្ធិក្នុងសាកលលោក ទឹងផលានិសង្សនៃបុណ្យនេះ ប្រសិទ្ធិពរថ្វាយព្រះបិយមហាក្សត្រិយ៍ ទ្រង់គង់ជាសុខក្នុងសិរីរាជសម្បត្តិ ប្រកបដោយសួស្តីដ៏យមង្គលគ្រប់ដំពូក ព្រមទាំងព្រះរាជវង្សានុវង្សអស់កាលជាយូរអង្វែងតទៅ ! សូមសម្តេច, ព្រះតេជព្រះគុណ, ទ្រង់, លោកអ្នកជាពុទ្ធសាសនិកជនទាំងឡាយ ប្រាន សម្រេចនូវគ្រប់ពិធសម្បត្តិ ជាឥដ្ឋមនុញ្ញផលគឺ សម្បត្តិមនុស្ស ១ សម្បត្តិសួគ៌ ១ សម្បត្តិព្រះនិព្វាន ១ កុំបីឃ្លៀងឃ្លាតឡើយ ! ។

(មានត)

ពន្លឺសាសនា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែឧសភា លេខ ៥

ព. ស. ២៤៩៤ — គ. ស. ១៩៥១



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពុទ្ធសាស្ថានំនត្រីស្តសាសនា (សង្ខិត្តសិទ្ធលោកវជ្ជបណ្ឌិតមីតូត) (តមក)	លោក ភ័យ - ប៊ុក	៣២៣
ពន្ធអាស៊ីទ្វីប (តមក)	លោក ភ័យ - ប៊ុក	៣២៩
បភាកថា	អាចារ្យ ខោល - ច្រាក់	៣៣៤

ផ្នែកអក្សរសាស្ត្រ		
សារលិខិតនៃលោកស្វាមីវិវេកានន្ទ (តបប់)	លោក ភ័ - ប៊ុក	៣៤២
ការបណ្តុះនំស្បៃយ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុត - ប៉ម	៣៤៧
អំឡេណា - សំម្ភ៉ាណា	លោកផេង - ន្រ្ទឹវ	៣៥៩
សព្ទបាភ៉ាតប្រែជាខ្មែរ (តមក)	លោក ម៉ុញ - ត៉ាត្រឹ	៣៦៩
រឿងសាមកុក (តមក)	ឧកញ៉ា គួ - កន	៣៧៣
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)	- ឈឹម - ក្រសែម	៣៨៦

កំណត់ទឹងប្រវត្តិការណ៍		
ពិធីបុណ្យប្រែគេនព្រហ្មទានចំពោះព្រះសង្ឃ ៨៨ រូប ដើលប្រឡងជាប់សញ្ញាប័ត្រ សាលាឧត្តម ជាន់ខ្ពស់ (តបប់)	សមាគមមិត្តសាលាឧត្តម	៣៩៣

ទូយឆ្នាំមាន ១២ សៀវភៅ ជាំឡៃជាវ ..... ១៤៥',០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE		Pages
Bouddhisme et Christianisme (Conférence du Docteur André Migot)	M. RAY-BUC	323
La Lumière de l'Asie (suite)	M. RAY-BUC	328
PABHAKATHA	Achar KHOL PRAK	334
PARTIE LITTERAIRE		
Message du Swami VIVEKANANDA	M. RAY-BUC	342
L'Education morale (suite)	Préah moha PEUNG-PAM .	347
Histoire d'Hélèna-Simiana	M. PHENG-CHRIEU	359
Recueil des mots traduits par la Commission Culturelle « suite » . . .	M. MENH-NAKRY	368
Histoire de SAMKOK (suite)	Oknha NOU-KAN	373
Histoire du Royaume du Cambodge (suite	Oknha CHHIM-KRASEM. . .	386
NOTES ET CHRONIQUES		
Fête de la distribution des prix aux 88 bonzes lauréats du concours de sortie de l'Ecole Supérieure de Pâli suite et fin)	Association des Amis de l'Ecole de Pâli	393

Prix d'abonnement annuel comprenant 12 numéros: 145800

ពុទ្ធសាសនា ជំនួ ក្រិស្តសាសនា

សន្និសិទលោកមីគូត

លោក ភ័យ-ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យកុំពេញ

ប្រែពីទស្សនាវដ្តី « ហ្រ្វង់អាស៊ី » ខែមិថុនាឆ្នាំ ១៩៥០

(តមក)

គេអាចពោលបានថា ពួកពុទ្ធមាមកជនមានបំណងទៅកាន់ព្រះនិព្វាន ដូចជាពួកគ្រិស្តសាសនិកជន មានបំណងទៅកាន់ដីវាតប្រែកបដោយអនន្តកាល តែទន្ទេ:ពួកមីមួយមានពលភាពខ្សោយឡើងបាន ដោយហេតុថា កងកិច្ចការខាងនេះមិនត្រូវខុកចិត្តអ្នកដទៃ ក្រៅពីសេចក្តីព្យាយាមរបស់ខ្លួនទេ ។ ពួកពុទ្ធមាមកជនដឹងថាគ្មានទំនៀមទម្លាប់, ពលិកម្ម, ពិធីណា អាចមកដំនួសកំឡាំងវីរិយភាពនៃអាត្មាបានឡើយ មិនត្រូវរង់ចាំអាទិទេពណាមកជួយទេ; តែអាចយល់បានថា សមប្បជានធម៌ដែលខ្លួនប្រព្រឹត្តនោះមុខជាមានផលក្នុងកាលជាអនាគត ហើយគ្មានបុណ្យាភិសនា (Prédestination) នៃអាទិទេពណា អាចមកកំណត់នូវជោគវាសនានៃខ្លួនបានឡើយ ។

គេបានឃើញច្បាស់ចំពោះលទ្ធិនេះ ត្រង់ខ្លឹមភាពប្រែកបដោយសេចក្តីរីងរួសជាអស្ចារ្យ ត្រង់សុភាពថ្លៃថ្នូរជាយ៉ាងក្រៃលែង ចំពោះមនុស្សជាតិ ព្រមទាំងជាប្រកពនៃសេចក្តីសង្ឃឹមនឹងសុទិដ្ឋិនិយម (Optimisme) ។

បុគ្គលគប្បីជ្រាបថា ព្រះពុទ្ធដែលយើងពណ៌នាខាងលើនេះ មានចរិយាខុសពីព្រះពុទ្ធ ដែលគេថាជាអ្នកមានមនោគតិ (Rêveur) ប្រកបដោយកោសជ្ជៈ ជាអ្នកមជ្ឈត្តនិយម (Sceptique) មានចរិយាមិនប្រកដហើយជាអ្នកទ្វិលច្រអូស ; ដីវភាពរបស់ព្រះអង្គតាំងពីដើមរហូតមក ជាហេតុបញ្ជាក់ឲ្យឃើញផ្ទុយគ្នានឹងគតិដែលពោលមិនពិតនោះ ។ ព្រះអង្គទ្រង់បានតស៊ូនឹងទុក្ខ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ; រួចដល់ព្រះអង្គទ្រង់ចូលកាន់អនុបាទិសេសនិព្វានធាតុ ព្រះជន្មគំរប់ ៨០ ព្រះវស្សា ទ្រង់បានបំពេញពុទ្ធកិច្ច ឥតមានពេលទំនេរ ទេសនាទូន្មានប្រដៅសត្វសត្វឲ្យកាន់តាមសាសនារបស់ព្រះអង្គ ហើយព្រះអង្គឈប់បង្អង់បំពេញតាមពុទ្ធានុស័យ លុះត្រាតែព្រះអង្គហត់ឧឡើយ លំបាកជាខ្លាំង ទ្រង់ឈប់សម្រាកនៅតាមមាត់ផ្លូវ ។ ព្រះអង្គបានទូន្មានសាវ័ករបស់ព្រះអង្គនូវវីរិយភាព នឹងការតស៊ូចំពោះបាបអកុសល រហើយព្រះពុទ្ធសាសនា គឺជាសាលាមួយដែលបង្រៀនឲ្យមនុស្សមានចាមភាពយ៉ាងមោះមុត នឹងញាណប្រកបដោយវិសារទភាព (audacieux) ។ តើជាមនោគតិបុគ្គលឬ? ព្រះអង្គដែលប្រទានពរដល់ពួកសាវ័ករបស់ព្រះអង្គថា យើងដែលបានឲ្យនាមខ្លួនយើងថា "យុទ្ធិកបុរស, យុទ្ធិកបុរស" ដូចនេះ ព្រោះយើងជាអ្នកតស៊ូដើម្បីគុណធម៌យ៉ាងឧត្តម ដើម្បីដំកល់

ទុកខ្លួនវិរិយភាពដ៏ថ្លៃថ្លា ដើម្បីសម្រេចខ្លួនតិបណ្ឌិតដ៏ខ្ពង់ខ្ពស់; ព្រោះ
ហេតុដូចនេះ បានជាយើងឲ្យនាមខ្លួនយើងថា យុទ្ធិកបុរស"[1] ។

ដែលខ្ញុំទើបនឹងពណ៌នាជំពាក់លោកអ្នក នាំឲ្យលោកអ្នកយល់ថា
ព្រះពុទ្ធសាសនាមានលក្ខណៈពិសេស ដែលជាហេតុឲ្យមានសភាព
ផ្សេងគ្នាពីសាសនាដទៃ ។ ដូចជាបញ្ហាខាងសទ្ធា ។

ចំណែកខាងសាសនា ដែលផ្សាយចេញពីគម្ពីរគ្រិស្ត, សាសនា
ស៊ីយជាអ៊ុស (Judaïsme), គ្រិស្តសាសនា, សាសនាឥស្លាម មាន
ន័យដូចគ្នានឹងព្រហ្មញ្ញសាសនា ដែលសិទ្ធិសាសនៈតាំងនៅបានកង
សាក់លោកគឺមកពីការប្រែសិទ្ធិនៃអាទិទេព ដែលមានសំដែងក្នុង
សៀវភៅពិសិដ្ឋ: គម្ពីរគ្រិស្ត (Bible), គម្ពីរមហាម៉ត (Coran), គម្ពីរ
វេទ (Véda) ។ គឺជាសព្ទពោលនៃអាទិទេព ជាពាក្យសច្ចៈដ៏ប្រណិត
ហើយបើទុកជាគំនិតនោះមានសភាពផ្ទុយគ្នានឹងវិចារណញ្ញាណ នឹង
សច្ចៈដែលមានប្រវត្តិសាស្ត្រជាឡាក់គោលសទ្ធិកបុរសមិនអាចនឹងដកចេញ
បាន ។ ពួកកាតូលិកសង្គមអាចយល់វែងឆ្ងាយជាងនេះទៅទៀត ដោយ
សង្គមនេះទុកខ្លួនថាជាអ្នកមានឯកសិទ្ធ ក្នុងកិច្ចបកប្រែគម្ពីរពិសិដ្ឋទាំង
ប៉ុន្មានដោយត្រឹមត្រូវជាប្រណិត ។ ម្យ៉ាងទៀត មានសាសនជនក-
បុរសខ្លះ បានតាំងខ្លួន ឬ មានសារកខ្លួនយល់ថា ខ្លួនជាអវតារនៃ

---

១ អង្គុត្តរនិកាយ ។

អាទិទេព ។ ចំណែកខាងព្រះពុទ្ធសាសនាគ្មានគោលការណ៍បែបខាងលើនេះសោះឡើយ ។

ឯព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មិនដែលតាំងព្រះអង្គជាបេសកបុរស ឬជាព្រះពាជបុត្រដែលអាទិទេពឲ្យមកផ្សាយសាសនានោះឡើយ ; តែព្រះអង្គបានផ្សាយនូវសច្ចជាបបមចំពោះប្រទេសឥណ្ឌា មិនមែនដោយហេតុដំនឿនូវគម្ពីរពិសិដ្ឋ ឬដោយសំឡេងអាទិទេពអង្គណាមួយឡើយ គឺដោយវិចារណញ្ញាណ ទ្រង់ដោយការពិសោធន៍ជាឯកភាពរបស់ព្រះអង្គ ។ ដំនឿពុទ្ធសាសនា គឺជាការដឿជាក់ចំពោះមហាបុរសដែលទ្រង់បានស្វែងរកឃើញមគ្គសច្ច គឺផ្លូវដែលនាំទៅកាន់ទីរំលត់ទុក្ខ ។ ព្រះអង្គជាមគ្គុទ្ទេសក៍គ្រាន់តែជាអ្នកបង្ហាញផ្លូវឲ្យយើងដើរ តែស្រេចនឹងយើងព្យាយាមដើរតាមព្រះអង្គ ដោយប្រើវិធីពិសោធន៍ចំពោះខ្លួននូវវិធានការដែលព្រះអង្គបានបញ្ញត្តទុកមកដើម្បីនឹងសម្រេចនូវលទ្ធផលនោះ ។ ព្រះអង្គទ្រង់មិនបានដាក់កំហិតបង្ខំឲ្យប្រតិបត្តិតាមលទ្ធិណាមួយឡើយ ។ ព្រះអង្គមិនឲ្យយើងដឿដោយឥតពិចារណានូវឧត្តរ ដែលព្រះអង្គបានព្រះពាដ្ឋានដោយអាង៎ថាយើងដឿព្រោះព្រះអង្គបានសំដែងនូវធម៌នោះ ។ យើងត្រូវតែយកពុទ្ធោវាទនោះមកពិសោធន៍មើលខ្លួនយើង, សឹមយើងដឿព្រះអង្គជាខាងក្រោយ ។ ដំនឿនោះគឺជាការព្រមព្រៀងសុខចិត្តពេញលក្ខណៈដែលកើតឡើង មិនមែនដោយការព្យាយាមខាងផ្លូវ

ប្រាជ្ញាបន្តិចបន្តួចទេ គឺដោយសមាធិចិត្តប្រកបដោយវិរិយភាពដ៏សុខុម គឺការពិសោធន៍ពិតប្រាកដខាងធម៌បរមត្ថ ដែលមានសភាពជាលក្ខណៈពន់ពេក ។ ដំនៀងនេះបានដឹកនាំឲ្យពួកខាងបច្ចិមប្រទេសចូលកាន់ព្រះពុទ្ធសាសនា ដោយមានសេចក្តីឆ្ងល់យ៉ាងណាយ៉ាងចំពោះការជាក់កំហិតបង្ខំឲ្យប្រតិបត្តិតាមលទ្ធិនោះ។ ដែលមានសភាពមិនស្របគ្នានឹងវិចារណញ្ញាណប្រមនោគតិរបស់ខ្លួន ហើយមានសភាពសាបរលាបជាច្រើនសតវត្សមកហើយ ។

គេបានសន្ធនាដេញដោលគ្នាដើម្បីនឹងចង់ដឹងច្បាស់ថា ព្រះពុទ្ធសាសនាជាទស្សនវិជ្ជា ឬជាសាសនវិជ្ជា ? ។ បញ្ហានេះនឹងអាចពោលបានចំពោះតែពួកខាងបច្ចិមប្រទេស ។ ឯពួកខាងបូព៌ាប្រទេស បញ្ហានេះ មិនអាចកើតមានឡើយ ។ មានតែពួកខាងបច្ចិមប្រទេសទេ ដែលគេយល់ថាទស្សនវិជ្ជាជាសាខានៃវិជ្ជាដ៏ធំធ្ងាយ ឯទស្សនវិទូជាបុគ្គលសាមញ្ញ ច្រើនជាពួកមន្ត្រីដែលបានសិក្សាខ្លួនឯងក្នុងវិជ្ជាស្ថានហើយដល់វិលត្រឡប់ទៅគេហដ្ឋានវិញ រស់នៅធម្មតាដូចពួកសារការី (notaire) ឬពួកទន្តពេទ្យរបស់ខ្លួនដោយយល់ថាលទ្ធិដែលបានសិក្សានោះមិនអាចជ្រួតជ្រាបដល់ដីរភាពខាងក្នុង ឬប្រែចិត្តគំនិតលោកសោះឡើយ ។ មានតែខាងបច្ចិមប្រទេសទេ ដែលគេទុកសាសនាជាបន្ទប់មួយតូចដែលគេចិទ្ធូរជាមុនទើបឲ្យប្រតិបត្តិការជាខាងក្រោយ ។

(មានត)

ពន្លឺអាស៊ីទ្វីប

វគ្គទី ៦

La Lumière de l'Asie

លោកស៊ីរ - អេតវ៉ាំងអារណ្យាលង់ តែង

លោកព័ន្ធ - ប៊ុក ត្រមការ ប្រែរៀបរៀង

(ត្រមក)

សីលព្ធតបភមាស: ស្រែកទៅកែព្រះបរមពោធិសត្វថា "ម្តេចក៏ព្រះអង្គហ៊ានកេធមិនេះ ព្រះអង្គត្រូវលះបង់នូវគម្ពីរ, បណ្តេញចេញពួកទេវតា ឥន្ទ្រ ព្រហ្ម, បង្គាប់ឲ្យពួកកិក្ខុសង្ឃចេញពីវត្តអារាម ហើយបំបាត់នូវច្បាប់វិន័យដែលប្រកាសឲ្យគេចិញ្ចឹមព្រះសង្ឃ ហើយដែលជាប្រធាននៃព្រះពុទ្ធអាណាចក្រទាំងអស់ក្នុងលោក" ។ ព្រះពោធិសត្វត្រាស់តបទៅសីលព្ធតបភមាស:វិញថា: "ដែលឯងសូមឲ្យយើងបំបាត់នោះ គឺជាទម្រង់នៃសត្វដែលជាអនិច្ចតាធម៌ទេ, តែសច្ចធម៌ស្ថិតនៅជានិច្ច; ឲ្យឯងចូលទៅក្នុងសហភាពអន្តការរបស់ឯងចុះ" ។ រួចមេប្រព័ន្ធយ៉ាងក្លាហានមកដល់ គឺកាម: ជាស្តេចទាំងតណ្ហាដែលមានឫទ្ធានុភាពអាចត្រួតត្រាដល់ទៅពពួកទេវតាឥន្ទ្រព្រហ្មផងទៀត ជានាយកលើកាមគុណក្នុងលោក, ជាមហាក្សត្រិយ៍សោយរាជ្យនៅព្រះពុទ្ធអាណាចក្រនៃកិលេសគ្រប់យ៉ាង ។ កាម: មានគ័ក្តីរីករស់ស្រាយ

ចូលមកក្រែមព្រះមហាភ្លោធិ, ស្ពាយលើស្មាខ្នូវសរលាបលនដោយ
មាសល្អ មានខ្សែក្រងជាប់ជាកិប្បជាក្រហមអស្ចារ្យ ហើយទឹងសរនៃ
តណ្ហាដែលខាងចុងមានអណ្តាតភ្លើងធ្វើសម្រាប់ដុតពេលកាលខ្នូវហាយ-
វត្ត ហើយធ្វើចិត្តឲ្យអន្ទះអន្ទែងដូចជាលំពែងចាក់ ដែលគេលាបស្លាក់
ដោយទុសថពិស ; ហើយនៅជុំវិញកាម: មានរូបនិមិត្តស្ត្រីកាពជា
ច្រើន មានរូបពាងទង់ក្រាយស្អាតស្អំជាទីសន្សើយកាព ហើយមាន
បបូរមាត់ជាទិព្វ បញ្ចេញសព្ទសូរសំឡេងស្នេហាអាឡោះអាល័យជា
ច្រើនប្រការ, ព្រមទាំងថ្លែងអត្ថក្តីន្ទកថាពីកាមភព, មានក្លែងតូរ្យ
តន្ត្រីមានសព្ទពីពោះអស្ចារ្យ ហើយមើលមិនឃើញ ជានាមធម៌ធ្វើឲ្យ
និសា (យប់) ស្ងាត់ស្ងៀម រង់ចាំសរនោសំឡែងទាំងនោះ នឹងធ្វើឲ្យតារា
ឬព្រះចន្ទឈប់សញ្ចរលើអាកាស រង់ចាំស្តាប់សព្ទប្រៀងទំនុកត្រែក
ត្រគាលជាច្រើនប្រការ ចំពោះព្រះបរមពោធិសត្វ ពាក្យពោលពីកាម-
តណ្ហាដែលព្រះអង្គទ្រង់មិនគួរបោះបង់ចោល ព្រោះជាទីនិយមនៃសត្វ
លោកក្នុងត្រៃយ្យភព, គ្មានអ្វីប្រសើរជាងសុជនប្រែប្រាំដោយគន្ធរស
ផ្សាយក្រអូបឈ្ងុយឈ្ងប់ នៃនារីដែលមានរូបពាងស្អាតល្អផូរផង់ត្រចះ
ត្រចង់គួរឲ្យចេតនាពន់ពេក ហើយលះបង់ខ្នូវរូបនោះ ឬជាជាអហំការ
ចំពោះព្រះអង្គតាមព្រះទ័យ ឬ គ្មានវត្ថុអ្វីវិសេសជាងចុងសុជនមានពណ៌
កុម្ភាប ជាទីពេញចិត្តនៃតណ្ហា; មែនហើយនៅកងលោកសន្និវាសនេះ

គ្មានអ្វីយកមកប្រៀបធៀបនឹងខ្លួនឯងដ៏ច្រើនលើសលុប ដែលមានសណ្ឋានកំណាកណាយចំរុះរំលេចពណ៌គួរជាទីមិលមើល តើដោយទស្សន៍យោរម្មណ៍នៃកាយសិល្បៈ ប្រកបតាមក្បាច់ធម្មជាតិរចនាជាកិរិយាកាពរបស់ស្រីដែលជាទីគាប់ចិត្តនោះឡើយ ! ។ កាយសិល្បៈ មានរូបឆោមលោមពណ៌ ដែលបញ្ចេញសព្ទសំឡេងស្ងាត់ពុំញាប់ញ័រពីចិត្តមួយទៅចិត្តមួយ, ធ្វើឲ្យលោហិតហៀរហូរឡើង ព្រមទាំងចិត្តគោរពយ៉ាងមាំប្រកបដោយធន្ទៈយ៉ាងក្លាហាន ដោយយល់ថា នេះជាវត្ថុវិសេស នេះជាស្ថានសួគ៌ដែលសត្វលោកទាំងអស់ តែងពេញចិត្តគ្រែបន្ទូវកាមារម្មណ៍សប្បាយត្រេកត្រអាលជាមួយនឹងពួកទេវតា ។ ទុជនសាងបុរសដ៏ឧត្តមនឹងមហាភជអើយ, នេះជាជង្វាយដ៏ថ្លៃថ្លាលើសជង្វាយទាំងអស់ក្នុងលោកនេះ មានសំភាពផ្សាស់ប្តូរថ្មីជានិច្ច បើទុកជាវត្ថុទាំងនោះឲ្យទុក្ខទោសមួយពាន់ដង ក៏គួរព្រះអង្គទទួលដោយព្រះទ័យរីករាយពេញចិត្ត ។ តើអ្នកណាអាចថាទុក្ខព្រួយយ៉ាងណាកើត បើអាយវៈដ៏ខ្លីខ្លាសមកឆុបរឹតរួត ធ្វើឲ្យជីវិតរបស់ខ្ញុំនឹងលាយបែរមួលទៅជាសព្ទសូរសុខស្រួលគួរស្រើបស្រាលសប្បាយ ព្រមទាំងឮសូរសំឡេងខ្ទរខ្ទើតគគងលាន់រំពងពេញមហាមេឃទាំងមូល នូវការថ្នាក់ថ្នមបីបម្រើបដូច្នេះ ? នេះហើយចំរៀងនៃរូបនិមិត្តរបស់នារីទាំងនោះ ដែលបញ្ចេញអាកប្បកិរិយាអាយវៈបុគ្គលជាអ្នកពេញចិត្តខាងកាមគុណ, ដែលមានចក្ខុភ្ជាំងដោយ

ក្នើងពាគ: ព្រមទាំងបបូរមាត់ញញឹមស្រស់គួរឲ្យចង់ជញ្ជក់ត្រេកត្រអាល ពន់ពេក ; ហើយរូបនិមិត្តទាំងនោះ បានពាក់ព័ន្ធយ៉ាងសប្បាយដោយកិលេសកាម បានបង្ហាញនូវអាការៈនៃត្រគៀកមួយចំហៀង កំពើកជាប់ចុំដូចជាបទចម្រៀងព្រមទាំងសូរសៀង អាយវៈដ៏ទន់ដូចជាក្រពុំផ្កាវៀបនឹងបើកស្រទាបរីកចេញរុងរឿង បញ្ចេញពណ៌សម្បុរស្រស់ស្រីបស្រួល តែលាក់ចិត្តចុំដ៏ន្ទូរទាយក្តៅទៅឡើយ ។ គ្មានវត្ថុអ្វីមានសភាពជាសុភនិមិត្តល្អ ហើយធ្វើឲ្យចក្ខុទស្សនាដោយអារម្មណ៍ជាទីពេញចិត្តជាងនាងចុំកង៏ពេលវាត្រីនោះ ដែលចូលទៅស្ថិតជិតព្រះបរមពោធិសត្វ ។ នាងក្រោយស្អាតល្អជាងនាងមុនពោលទៅកាន់ព្រះអង្គថា: "ទ្រង់ព្រះសិទ្ធត្តដ៏ឧត្តម! ខ្ញុំព្រះអង្គសូមប្រគល់កាយថ្វាយជីវិតចំពោះទ្រង់, សូមទ្រង់មេត្តាជញ្ជប់នូវមាត់ខ្ញុំព្រះអង្គ ព្រមទាំងក្រេបយកនូវឧជារសនៃយុវកោពរបស់ខ្ញុំព្រះអង្គ" ។ ចំណែកខាងព្រះបរមពោធិសត្វ ព្រះអង្គមានព្រះទ័យនឹងឥតកម្រើក ហើយក៏កាម:ជានតម្រើងធម្ម័ពួកស្រីរបាំចៀសចេញពីទីនោះទៅ ។ ស្រាប់តែមានទម្រង់មួយថ្មីជារូបស្រីស្អាតស្រស់ជាងនាងមុននោះទៅទៀត, ចូលទៅក្បែរខ្លួនជាព្រះនាងយសោធរា ។ ចក្ខុទៅហើយទឹកនេត្រហូរស្រស្រាក់ស្រោចស្រពក្តាពោលពាក្យស្នេហាជាពីរោះពិសាទៅកាន់ព្រះអង្គ មានអាយវៈលើកឡើងបញ្ចេញអាកប្បកិរិយាព្រួយទុក្ខលំបាកដ៏ខ្លាំងក្លា សព្វសូរវោហារសៀងថ្លូរ

វង់ ហើយក៏រូបនិមិត្តស័ក្តិសមនោះ ឱនពោលទូវព្រះបរមនាមនៃព្រះពោធិសត្វ ហើយរៀបរាប់ថា: "ទ្រង់ព្រះអង្គម្ចាស់ខ្ញុំអើយ! ខ្ញុំព្រះអង្គមុខជានឹងក្ស័យជីវិត ដោយច្បាសព្រាត់ពីព្រះអង្គកន្លងកាលឥឡូវនេះ; តើព្រះអង្គអាចទ្រង់ព្រះតំរិះថា: មានមេឃឯណាដែលមានសភាពសោភាល្អត្រចះត្រចង់ជាងមេឃា ដែលព្រះអង្គនឹងខ្ញុំព្រះអង្គធ្លាប់ទស្សនាទៅមាត់ស្ទឹងអោហិនី, នៅមហាច្បាសាទដែលជាទីត្រេកត្រអាលនោះឡើយ, ទីច្បាសាទដែលខ្ញុំព្រះអង្គបានខ្ចុកលំបាកជាច្រើនឆ្នាំដោយរង់ចាំព្រះអង្គ។ បោះបង់ចោលខ្ញុំព្រះអង្គស្រឡះ, សូមព្រះអង្គស្តេចយាងត្រឡប់វិលទៅមហាច្បាសាទវិញ, សូមទ្រង់វិលវិញកុំខាន ។ យ៉ាងណាក៏ដោយ សូមព្រះអង្គជញ្ជប់នូវបបូរមាត់ខ្ញុំព្រះអង្គ ហើយសូមទ្រង់ព្រះរាជទុញ្ញាតឲ្យខ្ញុំព្រះអង្គផ្អែកទៅលើព្រះឧកព្រះអង្គ, ចិត្តខ្ញុំព្រះអង្គដែលច្បាថ្នាខោះនឹងសូម្បីស្ងាត់ទៅវិញមិនខាន ។ ទ្រង់ព្រះអង្គ! សូមទ្រង់ឈ្ងៀងព្រះនេត្រមកខ្ញុំព្រះអង្គ, តើខ្ញុំព្រះអង្គ មិនមែនជាព្រះនាងដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យទេឬ? ។ ព្រះបរមពោធិសត្វតបទៅនឹងនាវនិមិត្តនោះវិញថា "ចំពោះសេចក្តីមេត្តាទៅកាន់ព្រះនាងជាអគ្គជយា ដែលនាងប្រសប់ប្រតិស្ថានរូបទ្រង់ទ្រាយឲ្យដូចនេះ, នរូបនិមិត្តអើយ, កលកិច្ចនាងឯងគួរប្រយោជន៍, គ្មានផល; យើងមិនមែនពោលពាក្យលាមកអប្រិយទៅកាន់នាងទេ, នាងចេះនិមិត្តរូបល្អស្អាតម្ល៉ះ ដូចជារូបភាព

គួរជាទីពិតពិលរមិលមើលកង់លោក, ចូលទាំងរលាយទៅកង់អនិច្ចតា-
ភាពនៃលោកចុះ ” ។ រួចមានសព្ទសូរលាន់ឮពីពេងកង់នៃច្រៀងទេស
ហើយពួកនារីនិមិត្តនោះចាកចេញគាន់ទង់ដំយកភ្លើដូចអគ្គី ហើយសំឡូរ
កំច្រៀងរឹងប៉ះសាប់ដូចជាចំហាយត្រចះត្រចង់ព្រោងព្រាត, រលាយចុះត់
សាបសូន្យពីទីនោះទៅ ។

តមក, នៅកណ្តាលមេឃដ៏តចុះអំពូ ហើយទង់សូរសព្ទព្យុះសង្ឃព
យ៉ាងខ្លាំង, កង់ចំណោមពួកអកុសលតាំងជប់ប្រការ មានអកុសលឯទៀត
ជាច្រើនដែលទៅពីក្រោយតទៅទៀត ។ បឋម គឺបដិយៈ (សេចក្តី
ស្អប់) មានដើមទ្រូងតស៊ៃពន់ពេងដុំវិញ ហើយតស៊ៃនោះដញ្ជប់ទូរទឹក
ដោះជាថ្នាំពុលដែលចេញពីដោះតាំងគូ ហើយពោលវាចាដ៏លាមកជា
យ៉ាងកៃលែង ព្រមតាំងសំដែងនូវសេចក្តីក្រោធដ៏ពន្លឹក ។ បដិយៈ
នេះ មិនអាចធ្វើឲ្យព្រះទ័យព្រះពោធិសត្វកម្រើកញាប់ញ័រឡើយ ។
ព្រះពោធិសត្វបានទតទៅចំបដិយៈ។ ក៏ស្ងៀមស្ងាត់, បហូរមាត់ដែលឆ្ងាប់
តែចេញសំដីអសប្បុរសក៏ស្ងប់, ហើយតស៊ៃទៅតាំងនោះក៏បញ្ចូលចង្កឹម
ទៅវិញ ។ រួចតមកបានចេញរូបភាគៈ, ជាបាបអកុសលនាំឲ្យកើតនូវ
កាមារម្មណ៍ ហើយមានច្បាប់ចង់ក្រែបយកវេជ្ជាតិកង់ពិភពលោក,
ក្លែបវេនៃខ្លួនឯង ។

លោកអាចារ្យ ខោល - ប្រាក់ វត្តលង្កា ក្រុងភ្នំពេញ

ទេសនាជាកវិប្បរោសនសព្វនៃប្រែទេសក់ម្តងដា កាលពីថ្ងៃ ៣ កេះ ខែស្រាពណ៍
ឆ្នាំកុរនព្វស័ក ព. ស. ២៤៩ (៣-១០-៤៣)

ធម្មត្ថុ រតនត្តយស្ស

សូមនមស្សការចំពោះព្រះរតនត្រ័យដោយគោរព ។

បន្ទាប់អំពីបទនមស្សការនេះទៅ នឹងសូមសំដែងធម៌ទេសនាតាមសមគួរដល់កាលវេលា ។

ធម្មតាមនុស្សក្នុងលោក ច្រើនណាស់ចូលចិត្តក្តី មិនសូវចូលចិត្តឯងឆឹតទេ, ដោយហេតុនេះ សូម្បីតែមនុស្សមានភ្នែកខ្វាក់ក៏ចូលចិត្តក្តីដែរ; ព្រោះពន្លឺអាចបំភ្លឺឲ្យមើលវត្ថុគ្រប់យ៉ាងបាន ។ ហេតុនោះ បានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងទុកក្នុងគម្ពីរអង្គុត្តរនិកាយចតុក្កនិបាតថា: ពន្លឺនេះជាធម្មជាតិយ៉ាងប្រសើរវិសេសក្នុងលោក អាចញុំាងប្រយោជន៍គ្រប់យ៉ាងឲ្យសម្រេចបាន ។

ពន្លឺនោះមាន ៤ យ៉ាង គឺ:

១ – ពន្លឺព្រះអាទិត្យ;

២ – ពន្លឺព្រះចន្ទ;

៣ – ពន្លឺភ្លើង;

៤ – ពន្លឺគឺប្រាជ្ញា ។

សូមអធិប្បាយអំពីពន្ធទាំង ៤ នេះដោយសង្ខេបថា :

ព្រះអាទិត្យ មានអំណាចធ្វើពន្ធឲ្យក្តៅដោយខ្លួនឯងបានតែក្នុងវេលាថ្ងៃប៉ុណ្ណោះ; មិនអាចធ្វើបំភ្លឺកងវេលាយប់បានឡើយ ។

ព្រះបន្ទូល មានអំណាចធ្វើពន្ធឲ្យភ្លឺបានតែកងវេលាយប់ប៉ុណ្ណោះ មិនអាចនឹងធ្វើបំភ្លឺកងវេលាថ្ងៃបាន ។

ភ្លើង មានអំណាចធ្វើបំភ្លឺ ឬក្តៅបានតែកងពេលដែលគេបង្កាត់ឬអុជប៉ុណ្ណោះ មិនអាចនឹងផ្សាយស្មើឲ្យភ្លឺកងទីដទៃៗ បានឡើយ ។

បណ្តាពន្ធទាំង ៣ ដែលបានពណ៌នាមកនេះ នឹងបញ្ជូញពន្ធស្មើ ឬក្តៅបានតែទីណាដែលមានតុកាសល្មមប៉ុណ្ណោះ តែទីណាដែលជ្រៅកំប៉ាំង ពន្ធទាំង ៣ នេះមិនអាចនឹងផ្សាយឬក្តៅបាន ។

បញ្ញា ជាពន្ធមួយវិសេសជាងពន្ធទាំង ៣ នោះ ព្រោះអាចធ្វើបំភ្លឺ ឬក្តៅកាន់ទីធ្វើយឬទីជិត ទីជ្រៅឬទីកំប៉ាំងបាន ។

តែវិស្ជន៍សម្រាប់សួនទូរបស់ឲ្យដឹងចំនួនថាប៉ុណ្ណោះប៉ុណ្ណោះយ៉ាងណា បញ្ញាសម្រាប់លៃសួនមើលហេតុការណ៍អាក្រក់ល្អបានទាំងអស់, មិនមានទើសទាល់កំយ៉ាងនោះដែរ; តួយ៉ាងដូចជាសម្បត្តិស្ថានសួគ៌ នឹងស្ថានព្រះនិព្វាន បើក្រៃតែអំពីបញ្ញាហើយ មិនអាចនឹងបញ្ជាំងបានឡើយ ។

ធម្មតាមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ មិនថាជាតំណាសាសន៍ណា ឬភាសាណាទេ, សុទ្ធសឹងតែមានសេចក្តីជ្រាថ្នាចង់បានបញ្ញាគ្រប់ៗគ្នា ប៉ុន្តែសេចក្តីជ្រាថ្នានោះ ដួនកាលក៏បានសម្រេច ដួនកាលក៏មិនបានសម្រេច ព្រោះបុគ្គលខ្លះចង់បានបញ្ញា ហើយខំប្រឹងប្រែងបណ្តុះផ្សាំពូជបញ្ញានោះឲ្យកើតឡើង បុគ្គលខ្លះចង់បានបញ្ញាដូចគេឯងដែរ ប៉ុន្តែជាមនុស្សខ្ជិលច្រអូស មិនខំប្រឹងប្រែងផ្សាំពូជបញ្ញានោះឲ្យកើតឡើងនឹងគេទេ ។

ហេតុទាំឲ្យកើតបញ្ញាមាន ៣ យ៉ាង គឺ:

๑ - បញ្ញាកើតអំពីគិត ;

๒ - បញ្ញាកើតអំពីស្តាប់ ;

๓ - បញ្ញាកើតអំពីចំរើនភាវនា ។

បើបានប្រកបព្រមដោយហេតុទាំង ៣ យ៉ាងនេះ បញ្ញាខើបកើតឡើងគ្រប់គ្រាន់មិនខ្វះខាតឡើយ ។

ឯគ្រឿងប្រកបផ្សំនោះលោកពោលទុកមកមាន ๔ យ៉ាង គឺ:

๑ - សេពគប់នឹងលោកដែលប្រព្រឹត្តល្អដោយកាយ - វាចា - ចិត្ត ដែលហៅថា សប្បុរស ;

๒ - ស្តាប់ពាក្យប្រៀនប្រដៅលោកដោយគោរព ;

๓ - ធ្វើទុកក្នុងចិត្តដោយខុបាយនៃបញ្ញា ;

៤ — ប្រតិបត្តិធម៌ឲ្យសមគួរដល់ពាក្យប្រៀនប្រដៅរបស់លោក ។

សេពគប់នឹងសប្បុរស ការសេពគប់ជាកម្លាំងយ៉ាងធំ ដើរគប់ពាល។ នាំឲ្យខ្ពុក គប់សប្បុរសជាហេតុនាំឲ្យកើតផលកើតប្រយោជន៍កន្លងលោកនេះទៅលោកខាងមុខ, ព្រោះលោកប៉ុនប្រសប់ណែនាំប្រៀនប្រដៅបុគ្គលដែលចូលទៅគប់ប្រសព្វនឹងលោកនោះ ឲ្យយល់ច្បាស់ខាងផ្លូវលោកនឹងផ្លូវធម៌ ឲ្យមានស្មារតីនឹកឃើញធម៌ដែលខ្លួនគួរប្រព្រឹត្ត នឹងមិនគួរប្រព្រឹត្តផង, ឲ្យមានប្រាជ្ញាចេះពិចារណាលៃលកឲ្យស្គាល់ថាបបុណ្យគុណទោសផង, ហើយក៏តាំងចិត្តស្តាប់នូវលោកដោយសេចក្តីគោរព · មិនបណ្តែតបណ្តោយចិត្តឲ្យសោត់ទៅកន្លងអារម្មណ៍ផ្សេង។ ដំកល់ចិត្តឲ្យមាំកន្លងនូវបរស់លោកនោះ។, លុះស្តាប់បានហើយក៏ធ្វើខ្ពុកកន្លងចិត្តដោយៗថ្ងាយនៃបញ្ញា ហើយក៏ពិចារណាឲ្យស្គាល់នូវន័យនឹងគុណធម៌នោះ។ នឹងលៃលកទៅតាមទំនងធម៌ថា: ធម៌នេះគួរប្រតិបត្តិ, ធម៌នេះមិនគួរប្រតិបត្តិ, ហើយជ្រើសរើសប្រតិបត្តិឲ្យសមគួរទៅតាមកាលនឹងតាមប្រទេសនឹងភូមិស្នានរបស់ខ្លួន នឹងប្រតិបត្តិឲ្យត្រូវតាមសំនួនរបស់ធម៌មិនឲ្យខុសអំពីកំរិតរបស់ធម៌ឡើយ ។

ម្យ៉ាងទៀតលោកពន្យល់ថា: បណ្តាមនុស្សដែលកើតមកកន្លងលោកនេះ បើមុខណាជាមានកម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញា ជាគ្រឿងជំនួយជួយកន្លងកិច្ចការរកស៊ីចិញ្ចឹមជីវិតអំពីដើមខ្លះក៏ពិតមែនហើយ ប៉ុន្តែ

ទឹងធ្វើការងារនោះ។ ឲ្យសម្រេចដោយងាយ ហើយស្រួលបួលមិនឲ្យ
ខុសខូចខាត ទឹងប្រព្រឹត្តខ្លួនឲ្យតាំងនៅក្នុងសេចក្តីល្អ ដែលជាហេតុនាំ
ឲ្យបានសេចក្តីសុខ - ចំរើននោះ ក៏ត្រូវតែអាស្រ័យសេចក្តីធ្វើវិធ្វាសវាង
វៃស្ងាត់ជំនាញ, ហើយត្រូវដាមនុស្សចេះសង្កេតរកហេតុផល ព្រម
ទាំងធ្លាប់បានជួបប្រទះឃើញបែបផែន ទឹងប្រពៃណីដែលមានមកអំពីដើម
ផង, ទើបការងារដែលទឹងប្រព្រឹត្តនោះបានសម្រេចដោយស្រួលបួល
ធាប់រហ័សរួសរាន់ទាន់ចិត្តប្រាថ្នា ។

ឯសេចក្តីធ្វើវិធ្វាសវាងវៃស្ងាត់ជំនាញក្នុងការងារ ព្រមទាំងកិរិយា
មារយាទទឹងប្រាជ្ញាជាគ្រឿងសង្កេតរកហេតុរកផល ដែលទឹងកើតឡើង
បាននោះ ក៏មកតែអំពីបួលទៅជិតកប់ប្រសព្វទឹងសប្បុរសប៉ុណ្ណោះ ព្រោះ
ហេតុដូច្នោះ សាធុសប្បុរសទាំងឡាយគួរកប់ប្រសព្វទឹងសប្បុរសនេះ
តែម្យ៉ាង ព្រោះលោកអាចនាំឲ្យចំរើនប្រាជ្ញា ។

ការស្តាប់ពាក្យប្រៀនប្រដៅលោកដោយគោរព នោះសេចក្តី
អធិប្បាយថា: បុគ្គលគប្បីសង្រ្គមប្រយ័ត្នចិត្តកុំឲ្យរាយមាយ ឬកំចាត់បង់
នូវចិត្តរវើរវាយរសាប់រសល់កុំឲ្យមាននៅក្នុងសន្ដានបាន, ដំកល់ចិត្តឲ្យ
ទឹងខ្ជួនប្រុងចាំស្តាប់ពាក្យតំនាងរបស់លោកជាសប្បុរស ដើម្បីឲ្យបាន
សម្រេចសម្បត្តិជាលោកិយទឹងលោកុត្តរណាមួយ, ឬដើម្បីឲ្យបានចេះចាំ
ច្រើនជាពហុស្សូតឡើងហើយទឹងសំដែងប្រាប់ដល់អ្នកដទៃដោយសេចក្តី

អនុគ្រោះ ឲ្យអ្នកជវៃឃ្លាតឆ្ងើការកុសលគ្រាន់ជាឧបនិស្ស័យទៅអនាគត។ ម្យ៉ាងទៀត សូមឲ្យនរវៃដែលលោកខ្ជាន់ជ្រៀតប្រដៅឲ្យចំប្រឹងប្រែងកេរស៊ុចិញ្ចឹមជីវិត ឱនឆ្ងើការងារអ្វើៗ ដរៃដែលជារបស់ឥតទោស ឬឲ្យរំរឿនសូត្រចំណេះវិជ្ជាដែលឥតទោស ក៏ត្រូវកុំប្រហែសធ្វេសក្នុងការស្តាប់ឲ្យសោះ ព្រោះការតាំងចិត្តស្តាប់មាំជាគ្រឿងចំរើនប្រាជ្ញា ។

ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា នោះ ហៅឲ្យខ្វៃថា យោនិសោមនសិការៈ គឺកិរិយាត្រិះរិះពិចារណាឲ្យស្គាល់ហេតុនឹងផលអាក្រក់ ល្អ ដោយយោបល់ដ៏ប្រពៃ; អធិប្បាយថា: បណ្តាកិច្ចការគ្រប់ចំពូក ដែលបុគ្គលធ្វើរួចហើយក្តី កុំពុងធ្វើក្តី, បម្រុងនឹងធ្វើក្តី, ក៏ត្រូវតែអាស្រ័យយោនិសោមនសិការៈជាមុនដរាប ទើបការងារទាំងនោះសម្រេចទៅបានដោយស្រួលមិនខ្ជាំគ្នឹងឡើយ; ឯយោនិសោមនសិការៈនោះមិនមែនជាតួបញ្ញាទេ គ្រាន់តែជាឧបាយជួយឧបត្ថម្ភឲ្យមានប្រាជ្ញាធ្វើវាឆ្លាសវាងឆ្ងៃស្មាត់ជំនាញក្នុងការងារនោះៗ ប៉ុណ្ណោះឯង; ព្រោះមនុស្សយើង បើការណាមានដំណើរទៅតាន់ទីដរៃៗ ហើយបានជួបព្រេងនឹងវត្ថុអ្វីៗ ឬវិធីបែបផែនដែលគេតាំងទុកក្នុងទីណាមួយ ឬបានរៀនចំណេះវិជ្ជាណាមួយ, បើមិនខំប្រឹងប្រែងយកចិត្តទុកដាក់ពិចារណាត្រិះរិះដោយយោបល់ ឲ្យស្គាល់ហេតុផលក្នុងវត្ថុ ឬវិជ្ជានោះៗឲ្យសព្វគ្រប់ទេ ការដែលធ្វើវាឆ្លាសវាងឆ្ងៃកិច្ចការនោះៗក៏មិនបានកើតឡើង;

ឯយោនិសោមនសិការៈនេះ ស៊ីសេចក្តីបានភាំងផ្លូវលោកនឹងផ្លូវធម៌ ។ ឯចំណេះវិជ្ជាផ្លូវលោកនោះ គឺត្រូវរៀនឲ្យចេះអក្សរនឹងលេខនព្វន្តគុណហាជាដើម, ឯវិជ្ជាខាងផ្លូវធម៌ គឺត្រូវរៀនឲ្យចេះព្រះបរិយត្តិធម៌ជាដើម, កាលបើបានរៀនសូត្រវិជ្ជាណាមួយហើយ ក៏ត្រូវតែប្រើគំនិតពិនិត្យពិចារណាឲ្យចេះចាំស្ទាត់ជាកដក្នុងចិត្ត ឬបានមើលក្បួនតម្រាដែលអ្នកជ្រាបបានរចនាជាវិធីបែបផែនទុកមក ដូចជាសម័យសព្វថ្ងៃនេះត្រូវតែកត់គូសចំណាំទុកក្នុងចិត្ត នូវសេចក្តីត្រង់ណាដែលវៀកតែកវៀកគំនិត ត្រូវសង្កេតមើលឲ្យឃើញហេតុផល ហើយគិតស្រាវជ្រាវរកឲ្យទាល់តែចូលចិត្តសេចក្តីនោះសិមឈប់, យ៉ាងនេះឯង វិជ្ជាដែលរៀននោះទើបនឹងក្លាយជាវិជ្ជាដ៏ស្អាតរុងរឿងខ្ជៃខ្ជាលំជាប់ៗតទៅ ។ បើនិយាយខាងផ្លូវធម៌វិញ គឺកាលដែលបានដួបប្រទះវត្ថុអ្វីជារបស់មានវិញ្ញាណ ឬឥតវិញ្ញាណ ក៏ត្រូវតែមានគំនិតត្រិះរិះពិចារណាឲ្យឃើញច្បាស់ថាជារបស់មិនទៀងជាទុក្ខ មិនមែនខ្លួនប្តូណា, យ៉ាងនេះទើបប្រាជ្ញាជាន់ខ្ពស់ដែលលោកវាប់បញ្ចូលទៅក្នុងលោកុត្តរបញ្ញានេះកើតឡើងបាន; ហេតុដូច្នេះសាធុសប្បុរសគួរតែបង្កើតយោនិសោមនសិការៈឲ្យមាននៅក្នុងខ្លួនសន្តាន, ព្រោះជាធម៌សំខាន់ខាងធ្វើឲ្យចំរើនប្រាជ្ញា ។

ប្រតិបត្តិនូវធម៌សមគួរដល់ធម៌ – គុណធម៌នេះជាចម្មកតីយោនិសោមនសិការៈ; ព្រោះថាបុគ្គលកាលនឹងប្រតិបត្តិធម៌នោះ លុះតែបានត្រិះរិះពិចារណាឲ្យស្គាល់ហេតុផលសភាវធម៌នោះៗជាមុនសិន ទើប

ទីដែលប្រតិបត្តិឲ្យសមគួរដល់កំរិតធម៌នោះៗ ឋាន, កាលបើបុគ្គលប្រតិបត្តិឲ្យត្រឹមត្រូវតាមកំរិតរបស់ធម៌ហើយ រមែងឋានដួបប្រទះនឹងសេចក្តីសុខ សេចក្តីចំរើនមិនខានឡើយ ។

ចំណែកបុគ្គលដែលប្រតិបត្តិធម៌ ប៉ុន្តែមិនឋានដួបប្រទះនឹងសេចក្តីសុខដោយបរិបូណ៌ ដោយហេតុបុគ្គលនោះឯងប្រតិបត្តិធម៌មិនសមគួរដល់ធម៌ដែលខ្លួនឋានត្រិះរិះឃើញ ព្រោះបុគ្គលខ្លះប្រឹងប្រតិបត្តិធម៌តឹងហួសខ្លះប្រតិបត្តិធម៌ធូរហួសពេក; ព្រោះតែតឹងហួសធូរហួសយ៉ាងនេះ ឋានជាមិនឋានដួបប្រទះនឹងសេចក្តីសុខសេចក្តីចំរើន ដែលជាផលនៃការប្រតិបត្តិនោះៗ ដោយគ្រប់គ្រាន់ឡើយ ។ ឯការដែលប្រតិបត្តិធម៌សមគួរដល់កំរិតរបស់ធម៌នោះ គួរយ៉ាងដូចជាបុគ្គលដែលរក្សាសីល គប្បីសង្កេតប្រយ័ត្នរក៏ងសិក្ខាបទដែលខ្លួនឋានកាន់កាប់ហើយ កុំឲ្យធ្លុះធ្លាយឬសៅហ្មងសិក្ខាបទណាមួយ ដំណាលពីនោះ អ្នកប្រតិបត្តិនឹងកើតសេចក្តីត្រជាក់ចិត្តឥតក្តៅក្រហាយ ។ ឯការប្រតិបត្តិធម៌សមគួរដល់ធម៌ ដូចសំដែងមកនេះ រមែងឋានសេចក្តីសុខ ទាំងកងជាតិនេះនឹងជាតិខាងមុខ ហើយនឹងឋានជាបច្ច័យនៃព្រះនិព្វានជាអសានជាតិមិនឃ្លាតឡើយ ។

កាលបើសាធុសប្បុរសមានសេចក្តីប៉ុនប៉ងចង់ឋានជ្រាជ្រៅ គួរទំបណ្តុះជាំផ្សាំជ្រាជ្រៅឲ្យកើតឡើង ត្រូវប្រែកបធ្យូរធម៌ទាំង ៤ នេះឲ្យកើតមានក្នុងសន្តាន ទើបជ្រាជ្រៅកើតចំរើនឡើងជាលំដាប់ ។

សំដែងមកអំពីធម៌ជាគ្រឿងចំរើនជ្រាជ្រៅចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

លោកស្វាមី វិវេកានន្ទ

Message de Swami Vivekananda

ដកស្រង់ពីទស្សនាវដ្តី ហ្វ្រង់អាស៊ី ថ្ងៃ ១៩ វិច្ឆិកា ១៩៤៦

លោកវ៉ាយ-ប៊ុកក្រែមការ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

(តចប់)

ដែលយើងត្រូវការក្នុងសម័យបច្ចុប្បន្នជាងវត្ថុទាំងអស់ ខានមិនបានគឺយើងដឹងថាមានអាទិទេពមួយ (un Dieu) ហើយយើងអាចយល់ឃើញបាននូវអាទិទេពនោះស្ថិតនៅពាសពេញទាំងអស់ត់តមានកំណត់ ។

ទឹតមួយដំណក់នៅក្នុងសាគរ, រុក្ខានៅក្នុងព្រៃជ្រៅ, នំប៉័ងមួយចំណិតមិនអាចមាននៅក្នុងគេហដ្ឋានៃអាទិទេព ដែលមានភោគទ្រព្យ (សេដ្ឋី) ទេ បើព្រះអង្គមិនមានព្រះទ័យមេត្តាករុណាដល់សត្វសត្វ ។ តាមន័យផ្ទុយគ្នាវិញ, បើមានធនូ:មាំ, ទន្ទេងាំងប៉ុន្មានអាចកើតមានឡើងបាននៅរាល់ខ្សាច់រហោស្ថាន, ហើយពួកសមយោចកនៅជាមានភោគទ្រព្យទៅវិញ ។

តើការដែលពោលនេះគ្រាន់តែវាចាទេត់តមានខ្លឹមសារឬជាដំរៅពិតប្រាកដមែន ? ។

ជីវិតមានសភាពខ្វៀហើយលោកដែលប្រកបដោយអនត្តាធម៌ ក៏ជាវត្តមិនបានស្ថិតស្ថេរចិរកាល តែអ្នកណាដែលមានជីវិតរស់នៅ ដើម្បីប្រយោជន៍ញាតិមិត្ត អ្នកនោះគេហៅថារស់នៅដោយថ្លៃថ្នូ ; ចំណែកអ្នកដែលគ្មានធ្វើប្រយោជន៍ដល់ញាតិមិត្ត ខុកដូចជាស្លាប់ ។

ពួកបច្ចេកទេស្ស "អ្នកឃើញនូវកាលជាអនាគត" (Prophète) មិនមែនមានសភាពដូចគ្នាក្នុងការមើលឃើញនូវអនាគតនោះដោយបញ្ញាចក្ខុទេ ។ គឺជាមនុស្សមានលក្ខណៈដូចអ្នកនឹងខ្ញុំ, តែពួកបច្ចេកទេស្សជាពួកយោគាវចរយ៉ាងចំណានហើយលោកបានហាត់ឈានចិត្ត ដែលអ្នកនឹងខ្ញុំអាចធ្វើបានដូចគ្នា ។ ការដែលបុគ្គលម្នាក់ហ្វឹកហាត់ចិត្តទៅដល់ថ្នាក់ឈានជាពស្តុតាងបញ្ជាក់ឲ្យឃើញជាក់ស្តែងថា មនុស្សឯទៀតក្រៅពីព្រះយោគាវចរនេះ ក៏អាចព្យាយាមហាត់ចិត្តឲ្យដល់ថ្នាក់នោះបានដូចគ្នា ។ ក្នុងរឿងនេះ មិនត្រូវពោលតែត្រឹមសំដីប៉ុណ្ណោះទេ បុគ្គលនីមួយ ។ ត្រូវប្រឹងប្រែងហ្វឹកហាត់ចិត្តឲ្យបានដល់ថ្នាក់នោះផងទើបប្រសើរ នេះហើយដែលគេហៅថាសាសនា ។

ការណ៍យកចិត្តតែមួយហើយពិត គឺការញ៉ាំងខ្លួនឲ្យមានសេរីភាពឡើង, ហើយធ្វើការដូចជាសញ្ញីសត្វសេរី ។ ត្រូវបំពេញការងារដោយអធិដ្ឋានការនោះចំពោះអាទិទេព ។ ព្រោះការណ៍យកចិត្តទាំងអស់នោះត្រូវធ្វើដើម្បីនឹងដោះបំណុលដែលចំពាក់អាទិទេព ។

គ្មានការណាដែលមានន័យត្រឹមតែរកវត្ថុធាតុទេ ។ ការចាំងអស់សុទ្ធតែអតិវាទន៍ ហើយជាការផ្តួងចិត្តចំពោះអាទិទេពចាំងអស់ ។

ដល់ខ្លួនខ្ញុំកាន់តែទោទន់ចាស់ជរា, ខ្ញុំដឹងថា ខ្ញុំបានស្វែងរកកិត្តិយសក្នុងវត្តគួចគាចទៅវិញ ។ មិនថាអ្នកណាទេ ដែលគេអាចធ្វើឲ្យកិត្តិនាមល្បីល្បាញបានដោយសារមានឋានន្តរៈសំខាន់ក្នុងលោក ។ សូម្បីតែអ្នកខ្វាចក៏អាចអប់រំចិត្តឲ្យទៅជាអ្នកក្លាហានបាន ដោយការផ្តួចចិត្តទៅរកស្មីពណ៌ដែលគេរៀបជាដួរហែពីខាងមុខធាកពេងស្លេន. ។ ព្រោះប្រជាជនចាំងអស់ដែលទៅទស្សនា តែងក្រឡេកមើលទៅចំអ្នករបាំនោះ ។ ខ្ញុំកាន់តែយល់បន្តិចម្តងៗថា កិត្តិយសដ៏ប្រសើរនោះ, បើគិតដោយស្មានគឺជាកិត្តិយសនៃដង្វែ ដែលបំពេញការណ៍យកចិត្តរបស់ជាដោយសារចិត្តនឹងនួន ព្រមទាំងសេចក្តីព្យាយាមពីពេលមួយទៅពេលមួយ, ពីមោ"ងមួយទៅមោ"ងមួយ ។

យើងចង់បានចាំងអស់ រៀវលែងតែអាទិទេព ហើយបានជាបំណងដូចនោះ ព្រោះសេចក្តីប្រាថ្នានៃមនុស្សសាមញ្ញជាប់ស្ថិតទៅនឹងពាហិរលោក ។ ដរាបណាសេចក្តីត្រូវការរបស់យើងទៅស្ថិតត្រង់ព្រំដែននៃលោកធាតុ, ដរាបនោះ យើងមិនមានបំណងត្រូវការនឹងអាទិទេពឡើយ ។ លុះត្រាតែជីវភាពរបស់យើងទៅជួបប្រទះនឹងជោគវាសនាអាក្រក់ ព្រមទាំងសេចក្តីលំបាកទុក្ខព្រួយសព្វគ្រប់, ទើបយើងប្រាថ្នារកវត្ថុដ៏ទុក្ខម ក្នុងពេលនោះយើងទើបបែរវិលត្រឡប់ទៅរកអាទិទេពវិញ ។

ជីវភាពតឹការបណ្តាយសត្វលោកឲ្យទៅតស៊ូដោយសេរី ចំពោះទេស:កាល: ដែលមានបំណងនឹងធ្វើជីវិតឲ្យសាបសូន្យ ជាហេតុឲ្យកើតមូរវិឌ្ឍនធម៌ ។

សេចក្តីខ្វាចមិនត្រូវឲ្យមានក្នុងសន្តានឡើយ ។ សភាពស្មុមយាចកក៏មិនត្រូវឲ្យមានដែរ ។ តែត្រូវសូមបំណងទៅតាន់អារ្យធម៌ ។ អ្នកណាដែលជាឧបាសកឧបាសិកានៃមាតាធម៌ (ធម៌ដោយសុកិតភាព), មានចិត្តធ្ងន់ធ្ងៃប្រៃហាលនឹងថ្មពេជ្រ ហើយគ្មានខ្វាចតក់ស្លុតដូចសត្វសង្ឃឡើយ ។ បើទុកជាចក្រភពទាំងមូលរលំរលាយទៅជាបរមាណូម្ល៉ាក់មកជិតដើម, ក៏សេចក្តីក្លាហាននៃអ្នកនោះ តែងស្ថិតស្ថេរចិរកាលជានិច្ចឥតមានប្រែប្រួល ។ អ្នកត្រូវបំពេញការណ៍យកិច្ចធ្វើឲ្យមាតាធម៌ទ្រង់ព្រះសណ្តាប់អ្នក តែកុំឲ្យនុនលំទោនពេក ។ ត្រូវឲ្យអ្នកជ្រាបថា: មាតាធម៌ជាអនន្តពល (Toute Puissance) អាចធ្វើឲ្យថ្មសិលាទៅជាវីរបុរសបាន ។

អាត្មនជាអនន្តពល ព្រោះមានលក្ខណៈដូចអាទិទេព ។ វត្ថុបំណងគឺធ្វើបាតុកម្មបញ្ជូញទូរអាទិទេវតៈ (Divinité) ឪខាងក្នុង ដោយត្រួតត្រាចំពោះខ្លួនដោយខ្លួនឯង ទាំងធម្មជាតិខាងក្នុងខាងក្រៅ ។ ឲ្យអ្នកព្យាយាមដោយធ្វើកិច្ចការផ្សេង។ ឬដោយសេចក្តីរកធម៌ ឬដោយការចំរើននៃចិត្ត ឬដោយទស្សនវិជ្ជា ឬដោយមធ្យោបាយតែមួយ ឬរួបរួមទាំងអស់ដូចពណ៌នាខាងលើហើយ ត្រូវអ្នកប្រតិបត្តិការនេះដោយសេរី ។ ត្រង់នេះ

ហើយដែលហៅថាសាសនាដោយសុត្រិតភាព ។ លទ្ធិឡាក់គោល សាសនា, ទំនៀមទម្លាប់, សៀវភៅ, វត្តអារាម នឹងទម្រង់ផ្សេងៗនេះ ជាវត្ថុមិនសូវមានសារៈសំខាន់ប៉ុន្មានទេ ពាក់ព័ន្ធមកថ្នាក់ទីពីរ ។

អាត្មន៍ជាតារា ហើយតារាទាំងអស់ស្ថិតនៅលើនភាល័យ ដែលមានសភាពជាអនន្តមាត្រ (infini) ។ នៃមហាមេឃជាលក្ខណៈនៃអាទិទេពជាម្ចាស់ ។ នេះហើយជាឫសសច្ចធម៌, ធម៌ពិតដែលស្ថិតនៅក្នុងបុគ្គលនីមួយៗ គ្រប់រូបទាំងអស់, សាសនាបានស្វែងរកជាបឋមនូវតារាខ្លះក្នុងចំណោមតារាជាច្រើន ដែលរះម្ខាងដើងមេឃ ហើយបានបំពេញអាសនកិច្ចបង្ហើយ ដោយបានរកឃើញនូវតារានោះទាំងអស់ ត្រមទាំងខ្លួនយើងរលាយចូលទៅនឹងអាទិទេព ។

ចប់

ស្ងប់ឃើញដឹង ច្រាំងពិតឃើញច្បាស់

ផ្លែចចកនឹងពពែ បានចុះកិច្ចសញ្ញាសន្ធិភាពជាមួយគ្នា តែផ្លែចចកតម្រូវឲ្យពពែដេញផ្លែស្រុកចេញ; លុះអំណោះខាងក្រោយមក ពពែក៏ទៅជាចំណីចចក, ដោយហេតុគ្មានផ្លែការពារ ។

យ. អ.

ព្រះមហាឧត្តមវិជ្ជា ធីលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាជាលីវធ្លាបុទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណាន់រក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ ពិនិត្យកែ

(តមក)

ត) កុំអង្គុយឬឈរនៅបង្អាន់ដៃស្ពាន កុំអង្គុយឬឈរឬក៏ដេកនៅកណ្តាលផ្លូវ កុំអង្គុយគងអន្ទាក់ខ្លា ឬលើកដើងឡើងជាក់លើកន្ទែងអង្គុយឬកន្ទែងដេក ក្នុងពេលដែលជិះយានពាហនៈ ដូចជារថយន្ត រថភ្លើងជាដើមឡើយ ព្រោះជាទីនាំឲ្យទើសខែងដល់អ្នកដែលដើរទៅមកនឹងជាទីបង្អៀត ឬបែកឡាក់សំលៀកបំពាក់ របស់អ្នកដែលជិះជាមួយ ។

ឃ) កុំប្រើកំឡាំងបៀតបៀនបង្ខៀតយកតែឈ្នះនៅក្នុងទីប្រជុំជន ដូចជាក្នុងការជិះយានពាហនៈ ការចូលទិញមូលប័ត្រ ចេញចូលតាមទ្វារជាដើម ឬចូលតាមទ្វារតាមច្រកល្អកនៅក្នុងទីណាមួយ, បើគ្មានហេតុដ៏សមគួរទេ កុំចោមភេមអ្នកជាដៃ នាំឲ្យគេទើសខែងកើតសេចក្តីរំខានចិត្ត, កុំគូស-សរសេរឬចិទសំបុត្រ ឬក៏ជាក់របស់គួរខ្ពើមក្នុងទីមិនគួរធ្វើ, កុំចោលសម្រាមនឹងវត្ថុស្មោកគ្រោក ក្នុងទីមិនគួរចោល ព្រោះជាហេតុនាំឲ្យកើតបដិកូលដល់សាធារណជន ។

ង) ចូរគោរព ចូរអើពើ ចូរទទួល អ្នកដែលមកជាមួយ ដោយមារយាទដ៏សុភាពរាបសា ចូរធ្វើទឹកមុខឲ្យយ៉ាងរីករាយស្រស់ស្រាយ ចូរប្រតិបត្តិចំពោះគ្នាដោយសេចក្តីស្មោះត្រង់ ចូរធ្វើឲ្យគ្នាសប្បាយចិត្តប្រតិបត្តិតាមបំណងរបស់គ្នាដោយល្អ ចូរប្រតិបត្តិខ្ជិនកុំឲ្យជាទីរអ៊ូសដល់គ្នា ដូចយ៉ាង កុំជក់ចាវី កុំបរិភោគគ្រឿងស្រវឹង (ចំពោះកាលដែលមិនសមគួរ) កុំឡឹបខ្សៀវ កុំខាកស្តោះជាដើម ឬក៏ធ្វើអ្វីៗជាទៃទៀតដែលមិនសមគួរចំពោះមុខគេវៃ ។

២ – អ្នកល្អតែងមានចិត្តល្អ – អ្នកល្អតែងប្រកាន់ថា: "មនុស្សលោកនេះ បើមិនមានអ្នកចិត្តល្អហើយ កំភ្លាយទៅជាកពន្លៃអសុរកាយដែលពេញពោរទៅដោយការខុរយស មុខគួរឲ្យខ្ជាចខ្ជៃលែង គឺចេះតែមានមារយាសាថេយ្យ មានចិត្តឫស្យាឈ្នានិសចំពោះសេចក្តីល្អរបស់គ្នាទីងគ្នា" ហើយប្រកាន់ថា: "អ្នកមានចិត្តល្អតែងណែនាំតែកងផ្លូវដ៏ល្អដែលជាហេតុឲ្យកើតសេចក្តីកក់ក្តៅដល់គ្នាទីងគ្នា មិនរើសថាកុងការណីយណាៗឡើយ" ។ អស់លោកចាំងឮយ ចូរជាអ្នកមានចិត្តល្អ ប្រកបដោយមេត្តាករុណា គិតដល់ប្រយោជន៍របស់ពួកគណៈឲ្យបានច្រើនជាងប្រយោជន៍របស់បុគ្គលម្នាក់ឬរបស់ខ្លួនឯង រក្សាប្រយោជន៍របស់សាធារណជនទុក ចេះពិចារណាយើញទ្រង់របស់អ្នកដទៃ ដូចជាមនុស្សដែលមានកំលាំងខ្លាយជាងមនុស្សដែលនៅកងការពិទ្ធ មនុស្សដែល

ស្មើគាប្តូរសំដីជាងខ្លួន ចូរគោរពចំពោះអ្នកដែលគួរគោរពតើ កុំធ្វើចិត្តអាក្រក់ចិត្តខ្មៅ ចូរជួយទុក្ខភ័យដំណាងអ្នកដែលគួរឲ្យ ចេះបន្ទរបន្ទាយ ចេះសម្រាលទុក្ខរបស់អ្នកដែលមានទុក្ខធ្ងន់ ប្តូរត្រីកំត្រា ដែលគ្មានមិនមានឧកាសនឹងផ្សាយសេចក្តីល្អដ៏ខ្ពង់ខ្ពស់ចេញមកឲ្យយើង, ដោយហោចទៅ សូម្បីតែតួកសត្តិតំរូវខ្លាន កំយើងត្រូវមានសេចក្តីមេត្តាករុណាប្រណីដែរ ។

ការអួតកំលាំង អួតអំណាច អួតទ្រព្យសម្បត្តិ ឬសម្ផស្សភាព ដើម្បីកៀរគរយកបរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន អ្នកល្អមិននិយមសោះឡើយ ព្រោះឃើញថា "ការអួតហ៊ានជាសម្បត្តិរបស់អ្នកខ្លាច ការអួតឈ្លាសវៃជាសម្បត្តិរបស់អ្នកល្ងង់ ការអួតមានជាសម្បត្តិអ្នកក្រ" ។ ប៉ុន្តែប្រកាន់តាមគតិថា "ត្រូវមានកំលាំងដូចយក្ស តែមិនត្រូវប្រើកំលាំងការយ៉ាងយក្សឡើយ" ។ អ្នកល្អតែងរាប់អានភាពជាអ្នកមានកំលាំង ទឹងប្តូរចិត្តប្រើកំលាំងក្នុងផ្លូវដែលត្រូវ ។ ហេតុនេះ ប៉ែយើងប្រកាន់ថា ខ្លួនយើងជាមនុស្សល្អហើយកុំគប្បីប្រើកំលាំងការ ធ្វើការុណកម្មចំពោះអ្នកដែលខ្សត់ខ្សោយតតីពីង កុំសំដែងកិរិយានឹងកាច សង្កត់សង្កិនជិះជាន់មើលងាយអ្នកដទៃឡើយ ត្រូវប្រើកំលាំងសម្រាប់ជាគ្រឿងជួយសង្គ្រោះ ការពារកត្តិផង្គាវិញ ដោយមិនត្រូវរើសថាប្រុស ស្រី ក្មេងចាស់ឬជាតិសាសនាណាឡើយ, ក្នុងខណៈដែលគាត់ធ្លាក់ទៅក្នុងសេចក្តីអន្តរាយ ចូរលើកដៃជួយធ្វើកិច្ចគាត្រាម។ កុំគិតខ្លាំយហាត់ ឬសេចក្តីអន្តរាយណាមួយទាំងអស់ ។

៣ - អ្នកល្អតែងមានសេចក្តីស្មោះត្រង់ សេចក្តីស្មោះត្រង់ ជាដួងពន្លឺស្មើដ៏ស្វាងរុងរឿងនៅជុំវិញខ្លួន ធ្វើទឹកមុខរបស់ខ្លួនឲ្យស្រស់បំព្រងបាន ។ ការវៀចវេរ នាំឲ្យទឹកមុខស្រអាប់ ហាក់ដូចជាប្រឡាក់ធូលី ។ សេចក្តីស្មោះត្រង់នេះ ជាគុណធម៌ខាងដើម នឹងខាងចុងនៃវត្តចាំងពួង លោកប្រៀបថា "សេចក្តីស្មោះត្រង់ប្រហែលគ្នានឹងមាតា ការប្រព្រឹត្តត្រង់ធម៌ប្រហែលគ្នានឹងបិតា សេចក្តីករុណាប្រហែលគ្នានឹងភរិយា ការខន្តីសំពោនប្រហែលគ្នានឹងបុត្រ, ឯសេចក្តីអធ់អាចប្រហែលគ្នានឹងមិត្ត" ព្រោះបើយើងមានសេចក្តីស្មោះត្រង់ហើយ សេចក្តីល្អដទៃៗ ក៏កើតមានរឿងបានផង ប្រសិនបើយើងជាមនុស្សវៀចវេរវិញ គុណធម៌ដទៃៗ ក៏មិនមានឡើងដែរ ។

យើងគង់ធ្លាប់បានឃើញ មនុស្សខ្លះដែលសំដែងកិរិយាសុភាព និយាយពីពេះផ្អែមល្ហែមចំពោះមុខក្បៀវ តែលុះក្បៀវត្រឡប់ទៅវិញហើយ ក៏បញ្ចេញកិរិយាអាក្រក់ និយាយដើមក្បៀវ ពោលពាក្យអាក្រក់ៗឲ្យក្បៀវតាមក្រោយ នេះជាមនុស្សមិនស្មោះត្រង់ គឺជាមនុស្សចិត្តវៀចនៅមុខក្បៀវ ចេះធ្វើកិរិយាសុភាព និយាយពាក្យពីពេះផ្អែមល្ហែមប្រចុបប្រចែងលើកដំកើងសរសើរ លុះក្បៀវទៅបាត់ ក៏ត្រឡប់ជានិន្ទា ភ្លែងពោលទោសផ្សេងៗទៅវិញ ចូលក្នុងបទថា "នៅមុខគោរព នៅក្រោយឡក, ចំពោះមុខផ្ញែទន្ទាប់ កំចាំងមុខផ្ញែតាកោ" ។ កិរិយារបស់មនុស្ស

អាសត្យ (មនុស្សវៀច) ជាកិរិយាកូតករ ជាកិរិយាក្លែងក្លាយ ជាកិរិយាកុហក ជាកិរិយានាំឲ្យមានពៀរ មានភ័យជុំទិស គ្មានសេចក្តីសុខឡើយ ។ ពិតមែន អ្នកដែលមានកិរិយាស្វាមីមិនស្មោះត្រង់, អ្នកដែលមានមាតាបិតាជំពាក់បំណុលគេ ទឹងអ្នកដែលមានបុត្រធីតាសន្តានអាក្រក់, មនុស្សទាំង ៣ ពួកនេះ ឥតដែលបានសេចក្តីសុខបន្តិចបន្តួចឡើយ ។

សេចក្តីស្មោះត្រង់ជាតែវិសេសរបស់អ្នកល្អ តែជាថ្នាំពិសដ៏មានពិសយ៉ាងពន្លឹករបស់មនុស្សអាសត្យ ។ ដូច្នេះអ្នកល្អទើបទំរកក្សាតែសេចក្តីស្មោះត្រង់ ប្រព្រឹត្តតែសេចក្តីសុចរិតពិតៗ ទាំងចំពោះមុខទាំងកំបាំងមុខ ដើម្បីឲ្យជាតិបំរើនឡើងបានដោយងាយ ត្រូវនឹងបទថា "សេចក្តីស្មោះត្រង់ជាផ្ទាំងទ្រូលខុសត្រូវនឹងជាគុណធម៌ដ៏ប្រសើរ ចារកនៅជាប់នឹងទឹកមុខរបស់មនុស្សស្មោះត្រង់" ។

លោក - អ្នកដែលជាមនុស្សល្អ ចូរជាមនុស្សស្មោះត្រង់ កុំចង់សប្បាយ ចង់សើចលេងហើយពោលកុហកបញ្ឆោតគ្នាឡើយ ចូរកុំវៀចវេរឆ្មោក បញ្ឆោតប្រវ័ញ្ចន៍ លបលួចរបស់គេដោយសំឡឹងឃើញលាភសក្ការៈ កុំជាមនុស្សប្រើមាយាកូតកិតផ្លូវអួតអាងថាខ្លួនជាអ្នកធំ ទឹងកុំក្រឡះពាក្យសន្យា ដែលខ្លួនបានធ្វើជាមួយអ្នកដទៃចេញហើយ សូម្បីអ្នកនោះជាមនុស្សបែបណាក៏ដោយ, ត្រូវរក្សាពាក្យសន្យាគុក ដើម្បីរក្សា

មិត្តសំឡាញ់ធឹងប្រទេសជាតិ តែត្រូវកុំខ្ជួលពាក្យសន្យាក្នុងវត្តដែលលើសវិស័យនឹងសមត្ថភាព ឬដែលមិនគួរនឹងធ្វើបាន ; មុននឹងខ្ជួលសន្យាអំពីអ្នកណា ចូរត្រិះរិះឲ្យសព្វគ្រប់សិន លុះបានធ្វើពាក្យសន្យានឹងគ្នាហើយចូរកាន់ពាក្យសន្យានោះ ឲ្យជាប់លាប់ដូចជាទំនៀមទំលាប់ដែលត្រូវប្រព្រឹត្តតាម កុំភ្លែងទំលាក់កំហុសលើគេ កុំខ្ជួលធ្វើកងកិច្ចការដែលខ្លួនមិនអាចធ្វើបាន តែត្រូវប្រុងប្រយ័ត្នរក្សាពាក្យសំដី ប្រតិបត្តិតាមពាក្យសន្យាឲ្យត្រឹមត្រង់ ។

៤ – អ្នកល្អតែងមានសេចក្តីសុចរិត – ការប្រព្រឹត្តល្អបរិសុទ្ធិ ប្រាសចាកមន្ទិលទោសទាំងផ្លូវកាយផ្លូវវាចានឹងផ្លូវចិត្ត ហៅជាសេចក្តីសុចរិត, ដោយចំពោះសំដៅយកសុចរិតកងមុខត្រួង សុចរិតកងការងារ នឹងសុចរិតកងការរក្សាវាចា ។ អ្នកល្អរមែងសុចរិតកងមុខត្រួង ដូចជារក្សាមុខត្រួងដោយសុចរិត មិនរៀបរៃធ្វើបាកស្តុបន្ទុយការបស់រាជការ ដោយរត់គយរត់ពន្ធជាដើម, បើខ្លួនជាអ្នកតូចក៏គោរពកោតក្រែងអ្នកធំ បើជាអ្នកធំ ក៏មិនប្រព្រឹត្តរំលោភឬសង្កត់សង្កិនអ្នកតូច ។ ឯសុចរិតកងការងារ ដូចជាធ្វើការងារដោយសុចរិត មិនធ្វើឲ្យខុសស័ល្ធមិនឹងបាប់ទំលាប់ ។ សុចរិតកងការរក្សាវាចា គឺបើខ្លួនជាអ្នកតូច ក៏ស្តាប់បង្គាប់អ្នកធំ បើជាអ្នកនៅក្រោមសេចក្តីបង្គាប់បញ្ជារបស់គេ ក៏ស្តាប់ពាក្យបង្គាប់របស់អ្នកដែលបង្គាប់បញ្ជានោះ ហាក់ដូចជា

ពាក្យបង្គាប់នោះចេញទៅអំពីខ្លួនឯង ឬក៏រក្សាពាក្យសន្យាដែលខ្លួនបានធ្វើនឹងអ្នកណាមួយដោយភ្លាប់ខ្លួន ។ បើជាអ្នកធំវិញ ក៏ត្រូវរក្សាវាចារបស់ខ្លួនឲ្យត្រឹមត្រង់ទៅតាមច្បាប់ នឹងត្រូវប្រែក្លាយនោះឲ្យហ្មត់ចត់ថ្លៃថ្នូរហើយទន់ភ្លន់ផ្អែមល្ហែមសុភាពរាបសាផង ដើម្បីឲ្យអ្នកតូចធ្វើតាមបានដោយងាយ ។

អស់លោកដែលជាអ្នកល្អ ត្រូវសុចរិតចំពោះមុខក្រសួង កុំធ្វើការទុច្ចរិតក្នុងមុខក្រសួង ដូចយ៉ាងកុំវៀចវេរ លបលាក់លួចទ្រព្យរបស់ជាតិជាដើម. កុំទទួលសំណូក ព្រោះអ្នកទទួលសំណូកជាអ្នកលក់ខ្លួនឯងឲ្យដល់អ្នកទិញគឺអ្នកដែលសូក, សូម្បីរបស់កំណាន់ បើមានអ្នកណាមួយឲ្យ ដោយប្រាថ្នានឹងធ្វើកិច្ចរបស់គេឲ្យសម្រេច មិនមែនឲ្យដោយមានចិត្តស្រឡាញ់ ឬដោយសិទ្ធស្មោលទេ បើយើងទទួលរបស់កំណាន់ដូច្នេះ ក៏ឈ្មោះថា បណ្តោយឲ្យខ្សែបន្ទាត់របស់ខ្លួនផ្អៀងទៅខុសប្រក្រតី គឺជាផ្លូវនាំចូលទៅកាន់អំពើអយុត្តិធម៌ ដូចគ្នានឹងសំណូកដែរ ព្រោះមានអំណាចធំខាងស្នាមនៃខ្សែបន្ទាត់ដែលត្រង់ឬសេចក្តីយុត្តិធម៌ ឲ្យផ្អៀងខុសចាកសេចក្តីទៀងត្រង់បានដូចគ្នា ។ អ្នកល្អរមែងប្រកាន់ថា "ការទទួលសំណូកនឹងរបស់កំណាន់នេះ ជាអំពើរបស់មនុស្សចិត្តអាក្រក់" ។

ដូច្នេះ យើងត្រូវកុំទទួលសំណូកនឹងរបស់កំណាន់ឬជំនួន ដោយសំឡឹងលាភផលក្នុងផ្លូវទុច្ចរិតឡើយ ។ យើងមានកិត្តិសព្ទដោយផ្លូវ

ខុសច្បាប់ ទប់ទល់មនុស្សដែលមិនមានកំពូលសព្វគ្រប់បានទេ ព្រោះកំពូលសព្វនោះ នឹងប្រកាសសេចក្តីអាក្រក់របស់យើង ឲ្យស្គុយខ្លួនខ្លាយទៅបាន ហើយយើងមិនត្រូវជួយនរណាមួយ ដោយយល់មុខក្នុងផ្លូវដែលខុសមុខត្រូវទេ ចូរទំប្រព្រឹត្តឲ្យល្អក្នុងមុខត្រូវដោយសុចរិត កុំធ្វើការខុសច្បាប់ក្លែងក្លាយឲ្យខុសចាកសេចក្តីពិតនឹងខ្លួនឯយុត្តិធម៌ឡើយ គឺកុំលំអៀង ព្រោះស្រឡាញ់ស្អប់ ខ្លាចនឹងរង្គុន ដូចជាកាលយើងមានទាំងសាក្សីក៏ចូរជាសាក្សីដ៏សុចរិត កុំជាសាក្សីកុហកក្លែងក្លាយ ខុសសេចក្តីពិតដែលបានដឹងបានឃើញ ; បើមានទាំងជាអ្នកពិភាក្សាក្តី ចូរធ្វើដោយត្រឹមត្រង់ កុំចេះតែជាក់ទោសមនុស្សតាមតែអំណាចរបស់យើង ដែលអាចជាក់បានឡើយ ត្រូវរក្សាសេចក្តីសុចរិតខុកឲ្យខ្លាំងខ្លួន ត្រូវនឹងការសិតថា: "អ្នកពិភាក្សាជាមាតាបិតា ចំណែកតួក្តីខុកជាបុត្រ, បើបុត្រទាស់ទែងគ្នាឯង មាតាបិតាត្រូវប្រៀនប្រដៅនឹងធ្វើទោសទៅតាមសមគួរ ទាំងត្រូវធ្វើទៅដោយសេចក្តីស្រឡាញ់ពាប់អានមេត្តាប្រណីស្មើគ្នាផង ព្រោះមាតាបិតា មិនដែលច្បាច្បាន់ឯក្លែងធ្វើទោសបុត្ររបស់ខ្លួនឡើយ" ។ សូម្បីក្នុងផ្នែកការងារក៏គួរធ្វើដោយត្រឹមត្រូវ កុំគិតធ្វេកគេ កុំបៀតបៀនគេ ។ ឯក្នុងការរក្សាវិញ គឺត្រូវរក្សាពាក្យសន្យាយ៉ាងខ្លាំងខ្លួន រួមសេចក្តីមកថា "អ្នកល្អត្រូវកុំលោភចង់បានឲ្យហួសប្រមាណ ត្រូវកុំធ្វើកុំនិយាយទៅតាមអំណាចទោស:នឹងកុំគិតខុសជាត្រូវ" ។

៥ – អ្នកល្អតែងរក្សាកិត្តិយស – ភាពជាអ្នកមានកិត្តិយសល្បីល្បាញ ព្រោះមនុស្សជ្រៃសរើសលើកដំកើងនឹងគោរពកាន់តាមកាតែងដែលកើតឡើងដោយសារការប្រព្រឹត្តិត្រឹមត្រូវដោយត្រៃទ្វារ មិនប្រព្រឹត្តិបៀតបៀនខ្លួនឯងនឹងមនុស្សជ្រៃឲ្យក្តៅក្រហាយនោះឯង ចាត់ជាកិត្តិយស ។ អ្នកល្អរមែងរក្សាកិត្តិយសរបស់ខ្លួននឹងប្រទេសជាតិ ចេះអៀនខ្មាសកន្លែងការខូចបង់កិត្តិយស ដោយគិតឃើញថា "បើប្រព្រឹត្តិឲ្យខូចកិត្តិយសហើយ មុខជាត្រូវគេសើចចំអកឲ្យថាជាមនុស្សមុខក្រាស់, ដែលជាហេតុនាំឲ្យការខូចបង់កិត្តិយសនោះ មានផ្លែជាប់នៅនឹងខ្លួនមិនចេះរលាយបាត់ ដូចដើមឈើដែលត្រូវគេចោះគល់ឲ្យមានផ្លែច្រើន ត្រង់កន្លែងចោះនោះមិនដែលត្រឡប់ល្អដូចដើមវិញបានទេ" ។ អ្នកល្អនោះទុកជាមានន័យណាយឲ្យគេនោះចោះចោកនឹងធ្វើអាក្រក់ ចំពោះខ្លួនយ៉ាងណាក៏មានតបតដោយផ្លូវអាក្រក់វិញឡើយ តែងធ្វើសេចក្តីល្អតែម្យ៉ាងដើម្បីកិត្តិយសចំពោះមុខក្រសួង ។ បើយើងចង់បានកេរ្តិ៍ឈ្មោះ ប្លែយើងធ្វើខ្លួនជាឲ្យមនុស្សល្អ ដោយការប្រព្រឹត្តិតាមច្បាប់នៃការរក្សាកិត្តិយសដូចតទៅនេះ :–

កុំធ្វើបែរញ្ញើរវៀចវេរ ដូចជា លួច ចោកប្រាស លបលាក់ ឬក្លែងក្លាយជាដើម កុំប្រើវិធីយកមុខយកប្រៀបក្នុងពួកគណៈ ឬប្រទេសជាតិ, កុំធ្វើបាបអ្នកដែលមានកម្លាំងអន់ខ្សោយជាងខ្លួននឹងអ្នកដែលមិនមានអាវុធ

ឬអ្នកដែលគ្មានគ្រឿងការពារខ្លួន; កុំលបឬបួនប្រទូសរ៉ាយមនុស្សពីខាងក្រោយ កុំធ្វើការញុះញង់សៀតស៊ីកឬរករឿងគេ កុំកន្ធរសំបថឬធ្វើឲ្យខុសសន្យា កុំប្រព្រឹត្តទុយ៌សចំពោះកឿនកត្តិឬពួកគណៈឬក៏ជាតិ កុំបង្កការចលាចលដំលោះខាស់ខែងក្នុងពួកគណៈ: កុំប្រព្រឹត្តរំលងច្បាប់បង្គាប់ទំនៀមទំលាប់ប្រពៃណីនិងអំណាចនៃការគ្រប់គ្រងស្រុកភូមិ ។

យើងនឹងទៅជាមនុស្សល្អបាន ត្រូវតែរៀរចោសដែលហាមមកនេះ ហើយត្រូវប្រព្រឹត្តតែតាមច្បាប់ដែលល្អ រក្សាកេរ្តិ៍ឈ្មោះទុកដោយហ្មត់ចត់ កុំធ្វើនិយាយគិតឲ្យប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួននឹងមនុស្សដទៃ ត្រូវតាំងនៅក្នុងសេចក្តីស្មោះត្រង់ឲ្យអស់ពីចិត្ត បើធ្វើប្តូនិយាយទទួលព្រម ឬហាមឃាត់ដូចម្តេច ត្រូវមានសេចក្តីពិតក្នុងចិត្តដូចោះ បើពេលនោះមានសភាពសមគួរនឹងនិយាយហើយ សូម្បីពេលនោះនៅក្រោមមូលហេតុនៃសេចក្តីភ័យ ក៏យើងធ្វើប្តូនិយាយទទួលព្រមឬហាមឃាត់ចានតាមសេចក្តីពិតក្នុងចិត្តរបស់យើងដែរ កុំបង់ចានវត្តុណាដែលមិនមែនជារបស់ខ្លួនកុំធ្វើអំពើណាដែលថោកទាប តាំងនេះគឺដើម្បីរក្សាកិត្តិយសរបស់ខ្លួននឹងជាតិ ។

តាមពិត កាលបើយើងខូចកិត្តិយសហើយ មិនងាយនឹងកែឲ្យត្រឡប់ល្អដូចដើមឡើងវិញចានទេ, ទីណាមិនមានសេចក្តីអៀនខ្មាសទីនោះ ក៏មិនមានកិត្តិយស; ដូច្នេះ អ្នកល្អត្រូវចេះអៀនខ្មាស ព្រោះការចេះអៀនខ្មាសជាឫសគល់នៃសេចក្តីល្អនឹងលក្ខណៈដែលល្អ ព្រមតាំង

ធម្មចរិយាគាំងពួង, ការធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ ព្រោះមិនអៀនខ្មាសនោះ ប្រៀបដូចដើមឈើដែលត្រូវគេចោះគល់ឲ្យផ្លែកាន់ដូច្នោះ ។

៦ – អ្នកល្អតែងស្រឡាញ់សេចក្តីស្ងប់ សេចក្តីស្ងប់នៅត្រង់ចិត្តដែលចេះអត់ធន់ មិនមែននៅត្រង់ការអត់សង្កត់ចិត្តទេ ។ បើចិត្តចេះអត់ធន់មិនធ្វើសេចក្តីអាក្រក់ហើយ កិរិយាទំាងកំសូបតាម ព្រមទាំងលះបង់អំពើអាក្រក់នឹងការនិយាយអាក្រក់ចេញបានទាំងអស់ ។ ការលែងធ្វើអាក្រក់ លែងនិយាយអាក្រក់នោះចាត់ជាសេចក្តីស្ងប់ ។ សេចក្តីស្ងប់នេះជាផលនៃការតាំងនៅក្នុងធម៌, សេចក្តីសុខជាផលនៃការធ្វើកាយ វាចា ចិត្ត ឲ្យស្ងប់, សេចក្តីឆ្អែតចិត្ត ជាផលនៃការមានសេចក្តីសុខ ។ អ្នកមិនប្រព្រឹត្តធម៌ មិនដែលបានសេចក្តីសុខអំពីទីណាឡើយ ។ ដូច្នេះអ្នកល្អតែងស្រឡាញ់សេចក្តីស្ងប់ទើបទំាថែរក្សាតែសេចក្តីស្ងប់រៀបរយ រក្សាតែសាមគ្គីធម៌ មិនបង្កឲ្យកើតការបាក់បែកគ្នាក្នុងរវាងបុគ្គល បុគ្គលៈមិនសំដែងអាការរើងរូស មុខនឹងនិយាយតែងតិះរិះសិនទើបនិយាយ ហើយនិយាយទៅតាមតែរឿងដែលពិត ថែមទាំងធ្វើឲ្យពិតទៅតាមសំដីដែលនិយាយនោះទៀត មិនមែនជាមនុស្សបានតែមាត់ទេ ទាំងមិននិយាយឲ្យនរណាមួយបានខូចខុកខុលំបាក ឬ អៀនខ្មាសឡើយ ។

យើងនឹងទៅជាមនុស្សល្អ ដោយចូលចិត្តនឹងសេចក្តីស្ងប់នោះ ត្រូវមានសតិសម្បជញ្ញៈគ្រប់ពេល កុំនិយាយទំលាក់ទោសលើអ្នកជំទៃ ដើម្បី

ឲ្យខ្លួនរួចពីកំហុស កុំធ្វើកុំនិយាយដោយអំណាច លោភ ក្រោធ វង្វេង ត្រូវមានចិត្តជាប្រក្រតីក្នុងពេលដែលជួបប្រទះនឹងលោកធម៌ទាំង ៨ ប្រការ បើធ្វើការណាមួយបានសម្រេច កុំរីករាយសប្បាយហួសហេតុ កុំរួញរាចិត្តក្នុងពេលដែលធ្វើអ្វីមួយមិនសម្រេច ត្រូវអត់ធន់ចំពោះសេចក្តីឈឺចាប់ នឹងពាក្យសំដីដែលគេពោលចាក់រុក ត្រូវជួយខ្លួនឯង កុំសូមឲ្យគេជួយ កុំខ្វល់ខ្វាយក្នុងការញ៉ាំងអ្នកដទៃឲ្យសរសើរខ្លួន តែកុំចូលចិត្តឲ្យអ្នកដទៃត្រូវគេរហាននិន្ទា កុំត្រេកអរក្នុងលាភយសសម្បត្តិ ដរាបដល់ហួសហេតុ សូម្បីនឹងបានលាភយស ក៏កុំក្តើតក្តើនពេក ទោះបីថ្កុំថ្កើងយសស័ក្តិឫទ្ធាក់ក្រដុនជាប ក៏កុំទោមនស្សតូចចិត្តខូចចិត្តងាយៗដែរ ។

៣– អ្នកណាតែងមានគោលមានទីតាំង – គោលគឺគុណដែលទុកដូចជាសសរ ឬ ខឿមដ៏រឹងប៉ឹង សម្រាប់ទ្រទ្រង់ខ្លួនទុកឲ្យតាំងនៅបាន បានដល់វិជ្ជាល្អដែលប្រៀបដូចពេជ្រនិលចិន្តាមណីដ៏មានដំឡៃ; ទីតាំងគឺគុណដែលទុកដូចជាកន្ទែងទួលរងដ៏មាំធំខ្ពស់ សម្រាប់ទួលទ្រទ្រង់ទុកបាន បានដល់ចរិយាល្អដែលប្រៀបដូចសាច់មាសជាផ្ទាំងរងត្បូងពែជ្រ ។ អ្នកល្អរមែងដំកល់ខ្លួនឲ្យមានឫកហាន ដោយការអប់រំគោលគឺគុណដែលជាសសរ ឬ ខឿមដ៏រឹងប៉ឹងបានដល់វិជ្ជា ទន្ទឹងដោយការអប់រំទីតាំងគឺគុណដែលជាកន្ទែងទួលរងដ៏មាំបានដល់ចរិយាល្អ ។

រឿងព្រៃឆបរទេសរុម៉ានី

លោក ផេង - ជ្រៃ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

ក្នុងកាលដ៏កន្លងទៅហើយ មានព្រះចៅពាជាធិពាជមួយព្រះអង្គ ប្រកបដោយវិទ្ធានុភាពដ៏អស្ចារ្យ ព្រះអង្គបានបំបាក់បំបបស្តេចកងជម្លូចតាំងមូលឲ្យលុះក្នុងអំណាចនៃព្រះអង្គ ហើយស្តេចចំណុះមួយ។ ត្រូវបញ្ជូនព្រះពាជបុត្រមួយអង្គ។ រៀងរួន ឲ្យទៅនៅបំរើព្រះមហាពាជអស់រាល់ជប់។ ឆ្នាំគ្រប់។ គ្នា ។

ប៉ុន្តែក្នុងចំណោមស្តេចបពាជ័យតាំងប៉ុន្មាន មានព្រះពាជាមួយព្រះអង្គ តាំងពីនៅវ័យក្មេងមកទ្រង់មិនដែលបណ្តោយឲ្យព្រះចៅពាជាធិពាជពាយធ្វើបាបបានទេ ទ្រង់ចេះប្រើកលល្បិចគាល់តែជនរបស់ព្រះអង្គផុតស្រឡះពីសេចក្តីអន្តរាយ ។ លុះជាមកដល់ ទ្រង់តែងតែទទួលចំណុះព្រះចៅពាជាធិពាជវិញជាដែល ។ ប៉ុន្តែតើធ្វើដូចម្តេច ដើម្បីបញ្ជូនព្រះពាជបុត្រទៅ? បើទ្រង់មានតែពាជធីតាគ្មានព្រះពាជបុត្រសោះ ។ ព្រះពាជាភ័យបារម្ភតប់ប្រមល់ក្នុងព្រះពាជហ្ឫទ័យ ខ្លាចក្រែងព្រះចៅពាជាធិពាជនឹកស្មានថាព្រះអង្គជាស្តេចខ្ជាំង ហើយមកពាយយកព្រះនគរ ធ្វើឲ្យព្រះអង្គត្រូវតាំងពាជធីតាដល់នូវសេចក្តីទុក្ខវេទនាធំអាប់ក្បើរឈ្មោះ ។

ព្រះពោធិសត្វទាំង ៣ អង្គ កាលបើឃើញព្រះបិតាទុក្ខព្រួយ កំឃុលហេតុមួយរំពេច ហើយនាំគ្នាភេទចុះឡើងៗ ដើម្បីកំចាត់សេចក្តីព្រួយនោះចេញ ប៉ុន្តែមធ្យោបាយទាំងប៉ុន្មានជាការឥតប្រយោជន៍ ។

មានមួយថ្ងៃ ពេលសោយក្រយាស្ងួយ ព្រះពោធិសត្វច្បាំលុតជង្គង់ហើយក្រាបទូលសួរនូវហេតុ នៃសេចក្តីទុក្ខរបស់ព្រះអង្គថា :

– បពិត្រព្រះបិតា ? តើព្រះអង្គមិនសប្បាយព្រះហឫទ័យ មកពីអាការប្រព្រឹត្តនៃទូលព្រះបង្គំទាំងអស់គ្នាមិនសមរម្យឬដូចម្តេច ? ឬមួយអាណាប្រជាពស្តេចតែប្រឈ្លោះគ្នាពេក ធ្វើឲ្យព្រះអង្គព្រួយព្រះហឫទ័យ ? បពិត្រព្រះបិតា ! សូមព្រះអង្គមេត្តាប្រាប់យើងខ្ញុំឲ្យបានដឹងផង តើរឿងអ្វីបំពុលវិញ្ញាណរបស់ព្រះអង្គ ? យើងរាល់រូបជាកូន សូមជានាអះអាងយកខ្លួនបូជាស្នងព្រះអង្គ ឲ្យតែព្រះអង្គបានឆ្ងាយព្រះហឫទ័យ; បពិត្រព្រះបិតា ! ព្រះអង្គគង់ជ្រាបច្បាស់ថា ខ្លាំងជាជួងដ៏វិតនៃទូលព្រះបង្គំគ្រប់គ្នា ហើយយើងខ្ញុំតោងតែគោរពព្រះអង្គជាធម្មតា ឥតមានគិតមុខក្រោយឡើយ ។

– ការណ៍ហ្នឹងពិតមែនហើយ ប៉ុន្តែបិតាមិនមានតូចចិត្តអ្វីនឹងប្រជាពស្តេកទេ, កូនស្រីទាំងអស់គ្នា ក៏មិនបានប្រព្រឹត្តអ្វីឲ្យជាដំណាស់ដល់មតិនៃបិតាក៏ទេដែរ ។ ម្នាលកូនសម្លាញ់ ! តាមបិតាគិតទៅឃើញថា នាងទាំងអស់គ្នាមិនអាចនឹងកំចាត់បង់នូវសេចក្តីទុក្ខព្រួយ ដែលមាននៅ

ក្នុងដួងព្រះហឫទ័យនៃបិតាឡើយ ។ កូនពាល់គ្នាសុទ្ធតែស្រី។ ហើយមានតែកូនប្រុសទេ ដែលអាចដកសេចក្តីទុក្ខចេញពីខ្លួនបិតាបាន ។

កូនស្រីច្បងក្រាបទូលស្នងឡើងថា: បពិត្រព្រះបិតា! តើហេតុដូចម្តេចក៏ព្រះអង្គលាក់សេចក្តីទុក្ខព្រួយនឹងទូលព្រះបង្គំ? សូមទ្រង់មានព្រះឧង្ការមកចុះ ចំណែកប្រុងខ្ញុំម្ចាស់មួយគឺប្រឹងតែនឹងយកជីវិតទៅបូជាថ្វាយជំនួសព្រះអង្គ ។

ព្រះពាជាមានព្រះបន្ទូលឆ្លើយថា: ម្នាលកូនស្រីសំឡាញ់បិតា! តើកូនឯងនឹងធ្វើដូចម្តេចកើត? តាំងពីកូនប្រសូតចាកផ្ទៃព្រះមាតាមក កូនឯងមានតែខ្លាវ, មានតែម្ចុល, មានតែកីជាគ្នា កូនឯងចេះតែការអម្បាះ ដេរហើយនឹងត្បាញ ។ ដើម្បីដោះទុក្ខបិតាគឺត្រូវជាអ្នកខ្លាំងពូកែចេះកាន់គ្រឿងអាវុធ ចេះកាន់ព្រះខ័នដោយត្រឹមត្រូវ ហើយឲ្យចេះជិះសេះយ៉ាងស្ទាត់ជំនាញយ៉ាងលឿនដូចជាយក្ស ។

– បពិត្រព្រះបិតា! ទោះបីយ៉ាងដូចម្តេចក៏ដោយ សូមព្រះអង្គមានព្រះបន្ទូលមកចុះ តើហេតុនៃសេចក្តីព្រួយរបស់ទ្រង់នោះដូចម្តេច? ។

– ម្នាលកូនស្រី! ហេតុនៃសេចក្តីទុក្ខបិតានោះដូច្នេះ កាលបិតានៅក្មេង, កូនស្រីគង់មិនលែងដឹងខ្លះ គ្មាននរណាហ៊ានមកប្រមាថមើលងាយដល់ព្រះនគរបិតាទេ គ្មាននរណាធ្វើឲ្យបិតាអាប់កេរ្តិ៍ឈ្មោះឡើយ ។ ឥឡូវពេលដកមកបៀតបៀនធ្វើឲ្យបិតារកកម្ចាំងនឹងលើកអាវុធ

ដើម្បីកំឡាសត្រូវមិនបាន ។ រាជអស្សពាហន៍ដែលជាព្រះរាជទ័ពាំងក្នុង
ចម្បាំងកំពាស់ៗអស់ ឃើញមាននៅសល់តែសេះកញ្ជាស់មួយដែលសព្វ
ថ្ងៃរស់នៅទាំងត្រដរ ខ្លួនអង្គុសអស់ ។ កាលពីដើម បើបិតាចេញទៅ
កន្លែងណា សត្រូវតែខ្ចាត់ខ្ចាយអស់ ចុះឥឡូវ . . . ។ ណ្តើយកុំនិយាយ
ច្រើន ! កូនស្រីដឹងឬទេ ? បិតាត្រូវចំណុះព្រះចៅរាជាធិរាជដែលមាន
បុណ្យានុភាពលើផែនដីទៅហើយ ។ តាមទំលាប់ព្រះចៅអង្គនោះគឺត្រូវ
ស្តេចចំណុះបញ្ជូនកូនប្រុសម្នាក់ឲ្យទៅនៅចំរើព្រះអង្គអស់រយៈវេលា ១០
ឆ្នាំ ហើយបិតាមានតែនាងពស់គ្នា តើធ្វើដូចម្តេច ? ។

កូនស្រីឆ្លងធ្វើយថា : បពិត្រព្រះបិតា ! ទូលព្រះបង្គំសូមយក
ខ្លួនទៅចំរើជំនួស ដើម្បីឲ្យព្រះបិតាសប្បាយព្រះហឫទ័យ ។

– ម្នាលកូនស្រីបិតា ! កែឆ៍កូនឯងត្រឡប់មកវិញឥតកើតការ
ហើយតែតែធ្វើការនេះឲ្យកាន់តែមានទុបស័គ្គខ្លាំងឡើងទេដឹង ! ។

– បពិត្របិតា ! របស់ដែលទូលព្រះបង្គំចេះ គឺព្រះអង្គនឹងមិនត្រូវ
មានសេចក្តីអៀនខ្មាស ពីព្រោះតែទូលព្រះបង្គំទេ ។ សំដីនេះគឺជាសំដី
ពិត ទូលព្រះបង្គំសូមសន្យាទុកជាមុន ។

– បើដូច្នោះ, ចូរកូនប្រុងប្រៀបរៀបចំអាត្មានឹងចេញទៅចុះ ។
លុះបានឮសំដីដូច្នោះ, នារីមានសេចក្តីសប្បាយចិត្តរកអ្វីប្រៀបគ្មាន ។
នាងចាប់រៀបចំប្រដាប់ប្រដាយ៉ាងរហ័សរួសរាន់នឹងធ្វើដំណើរ រួចនាង

ទៅរើសយកសេះដែលល្អឆើតជាងគេនៅក្នុងព្រះរាជក្រាល ហើយយកគ្រឿងសម្រៀកបំពាក់សុទ្ធតែមានដំឡៃ ព្រមទាំងផ្គុំស្បៀងសម្រាប់បរិភោគអស់រយៈពេលមួយឆ្នាំ ។

កាលណាព្រះរាជាទ្រង់ទតឃើញកូនស្រីរៀបចំស្រេចហើយ ព្រះអគ្គទ្រង់ប្រទានដំបូន្មានថា ត្រូវប្រយ័ត្នកុំឲ្យគេដឹងកេរបស់អាត្មា តើអ្នកខ្លាំងមានវិធីត្រូវទៅបំរើស្តេចជាចៅហ្វាយនាយបែបដូចម្តេច ប្រាប់ឲ្យប្រុងខ្នះអំពីការនិយាយដើមអ្នកដទៃ អំពីការនិយាយបង្កាច់ បើយើងចង់កុំឲ្យមានសេចក្តីគំនុំគុំគួន នឹងការមើលងាយអំពីសំណាក់នៃកូនស្តេចប្រទេសរាជដទៃ ។ ព្រះរាជាមានព្រះបន្ទូលទាំងចុងបំផុតថា: សូមឲ្យព្រះជាម្ចាស់តាមរក្សាកូនស្រីជានិច្ច ហើយចូរកូនកុំភ្លេចពាក្យដំបូន្មានបិតា ។

ឯនាងមាណវីកជធីតា ធ្វើដំណើរចេញទៅលឿនដូចប្រញ ព្រោះព្រះនាងមានសេចក្តីសប្បាយពេក មិនយូរប៉ុន្មានក៏បានទៅដល់ទីក្រៅក្រុង ។ ពួកអ្នកតាមបំរើនឹងរនេះផ្គុំស្បៀង កុំតែព្រះនាងទៅរង់ចាំ មុខជារង្គើផ្លូវ ព្រោះតាមនាងពុំទាន់ ។ ប៉ុន្តែព្រះរាជាជាបិតា លួចទៅចាំស្តាត់យ៉ាងឆ្ងាយពីខាងមុខនាងដោយផ្លូវម្ខាងមិនឲ្យនាងដឹង ។ ព្រះអគ្គមិត្តជាស្ថានដែក រួចដំណែងខ្នះជាចចកទៅពួនចាំក្រោមស្ពាននោះ ។ លុះព្រះរាជធីតាទៅដល់ស្ពានបុរាណនឹងគួន ព្រះរាជាស្ទុះឡើងបញ្ចេញចង្កូម

សស្ងាច ក្អែកសំឡក់ទៅរកក្តីចាំងដូចចន្ទុះមួយគូ រួចស្ទុះសំដៅទៅរកនាង ដើម្បីនឹងទាំត្រចាក់ស៊ី ។ នាងស្រែកម៉ុងម៉ាយតក់ស្លុតស្ទើរចាក់ស្មារតី ហើយប្រសិនបើសេះកុំហក់លោតស្ទុះទៅគៀនម្ខាង ប្រហែលនាងនឹងត្រូវដោយចង្កឹមចចកជាមិនខាន ។ ភ័យពេក ធីតាទាញបង្ហៀរសេះបរបំផាយវិលត្រឡប់ចូលព្រៃនគរវិញ ។ ប៉ុន្តែព្រះពជាជាបិតាវិលត្រឡប់តាមផ្លូវកាត់មកដល់មុននាង ហើយចូលមករកនាងនិយាយថា: ម្នាលកូនស្រីព្រះបិតា ម៉េចហ្ន៎! បិតាបាននិយាយប្រាប់នាងមែនឬទេ ថាសត្វរុយមិនដែលធ្វើទឹកឃ្មុំកើតទេ? ។

— បពិត្រព្រះបិតា! ការណ៍ហ្នឹងពិតដូច្នោះមែនហើយ ប៉ុន្តែខ្ញុំព្រះបង្គំមិននឹកស្មានថាការដែលទៅបំរើព្រះចៅពជាធំពជនោះ ត្រូវតវ៉ាច្បាំងជាមួយនឹងសត្វតិរច្ឆានដ៏ព្រៃសាហាវយង់ឃ្នងផងឡើយ ។

ព្រះពជាមានព្រះពជឧទ្ការថា: ឥឡូវបើដូច្នោះហើយ ចូរកូនទៅនឹងប្រាសាទខំដេរប៉ាក់ គ្បាញ រវើរវៃចុះល្អជាជាង ។ ព្រះជាម្ចាស់ប្រហែលជាអាណិតបិតាធ្វើមិនឲ្យបិតាមរណភាពទៅទាំងអាប់ក្តើរឈ្មោះទេ ។

លុះកាលកន្ទុងទៅមិនយូរប៉ុន្មាន កូនស្រីបន្ទាប់ក៏សុំខ្ចូនទៅម្តងហើយគាំងសន្យាថា: នឹងខំប្រឹងធ្វើដូចម្តេចឲ្យបានកិច្ចន្ទុះសម្រេចដល់ទីបំផុត ។ ខាងក្រោយការខំខ្ចូចសុំ នឹងការសន្យាជាច្រើនបែប ច្រើនស្មាន ព្រះពជាក៏ទ្រង់យល់ព្រមបើកឲ្យទៅ ។ ប៉ុន្តែនាងក្រមុំនេះក៏ត្រូវ

ទទួលគ្រែថ្នាក់ ហើយត្រូវលើមកព្រះនគរវិញដូចជាព្រះពោធិសត្វដែរ ហើយព្រះរាជាទ្រង់បន្ទោសថា: ម្នាលកូនស្រី ម៉េចហ្ន៎! បិតាមិនបាននិយាយប្រាប់កូនស្រីឬទេ ថាវត្ថុដែលក្តីចាំមិនមែនមាសទេ? ។

- បពិត្រព្រះបិតា! ការណ៍ហ្នឹងប្រាកដមែនហើយ បិតានិយាយត្រូវមែន ប៉ុន្តែទាស់ចរកនោះសម្បើមពេក, វាហាមាត់បែបជាចង់ត្រាក់លេបទូលព្រះបង្គំតាំងមូលតែម្តង ហើយពន្លឺភ្នែកវាស្រួចដូចប្រញាដែលបំរុងនឹងចាក់ដើមទ្រូងទូលព្រះបង្គំជាខ្ញុំ ។

ព្រះរាជាមានព្រះរាជឱង្ការទៀតថា: បើដូច្នោះ ចូរកូនអាស្រ័យនៅនឹងវាំងហើយ គិតតែពីដេរប៉ាក់ សូដណ្តាំទៅស្អាជាង ។

បីបួនថ្ងៃក្រោយមកទៀត វេលាកំពុងសោយព្រះស្ងោយ រាជធីតាក៏ទៅគាបបង្គំទូលឡើងថា: បពិត្រព្រះវររាជបិតា! សូមព្រះរាជាមេត្តាបើកឲ្យទូលព្រះបង្គំជាខ្ញុំចេញទៅល្បងមើលម្តងផង ទូលព្រះបង្គំចង់ផ្សងវាសនាម្តងដែរ ក្រែងបុណ្យកូនមាន ។

- ម្ចាស់ព្រះរាជា ម្ចាស់បិតាអើយ! បងស្រីតាំងមួយតាំងពីរបានធ្វើឲ្យបិតាពិបាកចិត្តឥតគណនាទៅហើយ, ចុះកូនឯងមករកអ្វីនឹងគេដែរ បើស៊ីតែបាយសឹងមិនចាន់ត្រង់មាត់ផង ។ ព្រះរាជាទ្រង់ប្រឹងប្រែរឃាតការដើម្បីបង្វែរបំណងទុះចេញ ប៉ុន្តែឥតអំពើ ។

ព្រះពជធីតាអង្វរទៀតថា: ខ្ញុំព្រះបង្គំខំប្រឹងលុះត្រាតែកិច្ចនោះសម្រេច ហើយប្រសិនបើព្រះជាម្ចាស់លោកមកជំទាស់ធ្វើឲ្យខ្ញុំព្រះបង្គំវិលត្រឡប់មកព្រះនគរវិញ នោះខ្ញុំព្រះបង្គំក៏មិនមានសេចក្តីអៀនខ្មាសឡើយ ។

ព្រះរាជានៅរឹងតែមិនយល់ព្រម ហើយប្រែកលជើម្បីបន្ទាចនាងប៉ុន្តែធីតាតៅនៅតែទូលសុំ លុះទីបំផុតព្រះរាជាត្រូវតែយល់ព្រមតាមសេចក្តីសុំ ។

ព្រះរាជាមានព្រះរាជឱង្ការថា: ចូរកូនល្បងវាសនាមើលចុះ បិតាចាំមើល តើកូនឯងធ្វើដូចម្តេចនឹងអាចបានទៅរួច បិតាមុខជាបានសើចទៀត ដោយកូនឯងត្រឡប់មកវិញជាក់មុខជ្រប់ជាមិនខាន ។

- បពិត្រព្រះបិតា! ព្រះអង្គទៀងតែនឹងបានទ្រង់ព្រះសំណើចនឹងខ្ញុំព្រះបង្គំ ដូចជាព្រះដេដ្ឋធីតាមុនៗជាប្រាកដ ប៉ុន្តែសូមព្រះអង្គទ្រង់ព្រះសំណើចចុះ កុំឲ្យតែខ្ញុំម្ចាស់ប្រកបដោយក្តៅឈ្នោះអាក្រក់ពីព្រោះរឿងនេះ ។

ពេញព្រះហឫទ័យនឹងការយល់ព្រមរបស់ព្រះរាជបិតា ព្រះរាជធីតាតៅ មុនដំបូងគិតរកទីប្រឹក្សានូវបណ្តាពួកនាម៉ឺនចាស់ៗ រួចនាងនឹកឃើញភ្លាម នូវរឿងចម្ងាំងនៃបិតាកាលដែលទ្រង់នៅពីក្មេង នូវសេះតាំងឡាយយ៉ាងដំនាញៗរបស់ទ្រង់ ។ ព្រះនាងតៅឯទីព្រះរាជក្រាល

ដើម្បីរកជ្រៃសើរសេនូវព្រះពុទ្ធពាជ ។ ព្រះនាងទ្រង់ទតព្រះនេត្រចំពោះ
អាជានេយ្យគាំងឡាយគាំងអស់ តោះជាមានរូបពង់ឆើតរលើបល្ល័ង្ក
ណា . ក៏គ្មានសេះណាមួយត្រូវចំណុចព្រះហ្ឫទ័យនៃព្រះនាងឡើយ ។
លុះទីបំផុត ព្រះនាងបានបែរសេះកញ្ចាស់មួយដេកនៅគៀនក្រាល
ចាស់ជក ខ្លួនមិនជាបើបី សុទ្ធតែអង្គ្គ សុទ្ធតែរមាស់ គឺជាព្រះពុទ្ធ-
អស្សពាហន៍ចាស់នៃព្រះវរបិតា, លុះឃើញអាការៈវិលវិលវារដូច្នោះ ព្រះ
នាងមានព្រះហ្ឫទ័យករុណាមិនអាចដើរចេញទៅឆ្ងាយពីសេះខ្ទុះបាន ។

ខណៈនោះសេះមានវាចាទៅកាន់ព្រះពុទ្ធធីតាថា: ម្ចាកជវមែនហើយ
ម្ចាស់ ! ទ្រង់ទតមើលខ្ញុំព្រះបង្គំប្រកបដោយសេចក្តីមេត្តាដូច្នេះ ព្រោះ
ទ្រង់មានចិត្តស្នេហាចំពោះព្រះមហាក្សត្រិយ៍ ។ កាលនៅពីកំណើ
ព្រះបរមក្សត្រិយ៍មានសេចក្តីក្លាហានខ្លាំងណាស់ មិនដឹងជាប៉ុន្មានលើក
ប៉ុន្មានគ្រា ព្រះអង្គ្គមានជ័យជំនះជាមួយនឹងខ្ញុំព្រះបង្គំ ។ ប៉ុន្តែតាំងពី
ព្រះពុទ្ធជាដល់នូវសេចក្តីជកាលណា គ្មាននរណាជិះលើខ្ញុំព្រះបង្គំ
សោះ តាំងគ្មាននរណាចេះថែតាំខ្ញុំព្រះបង្គំឡើយ បានជាទ្រង់ឃើញ
ខ្ញុំព្រះបង្គំរចោចកេមអស់លើងដូច្នោះ ។ សព្វថ្ងៃនេះកំដោយ បើតែ
ជុសលាងខ្ញុំព្រះបង្គំតែ ១០ ថ្ងៃ, សេះតាំង ១០ នេះមិនស្មើខ្ញុំព្រះបង្គំ
តែមួយឡើយ ។

លោកម៉ុញ - ឌ៉ាគ្រី អតីតតំណាងរាស្ត្រ រួបរួម

(តមក)

Couleur bleu marine = ពណ៌ឆ្នុះ

Pharmacien = ឱសថការី (ស. ឱសថការិនី)

Proviseur = នាយកវិទ្យាល័យ

Censeur de Lycée = សិក្សាធិការ្យ វិទ្យាល័យ

Sous la juridiction = ក្នុងកំណ្តាប់ច្បាប់

Sous l'autorité = ក្រោមអំណាច

Ophtalmologie = ចក្ខុរោគសាស្ត្រ

Institut ophtalmologique = វិជ្ជាស្ថានចក្ខុរោគ

(១៩-១២-៥០)

Spéléologie = គូហាសាស្ត្រ

Tunnel = ឧមង្គ (អុម-ម៉ង)

Epreuves écrites = វិញ្ញាសាសរសេរ

Epreuves orales = វិញ្ញាសាសួរ

Epreuves pratiques = វិញ្ញាសាប្រតិបត្តិ

Concierge = គេហបាល

Portier = ទ្វារបាល

Valet de pied = អ្នកបំរើក្រៅ

Valet de chambre = អ្នកបំរើកង

Saint-Siège = សន្តនិវេតន៍

(១៩-១២-៥១)

Garniture = អលង្ការណ៍ (គ្រឿងសម)

Broc = តយទឹក

Chauffe-eau = ប្រដាប់កំដៅទឹក

Piano = ប្យាណូ

Canapé = កៅអីវែង

Fauteuil = កៅអីក្អាកដៃ

Réfrigérateur = ទូទឹកកក

Console = តុរបនា

Secrétaire (Mobilier) = តុសរសេរ

Commode = មញ្ជូសា (ទូតូចមានថត)

Armoire = ទូ

(២២-១២-៥១)

Joyau = រតនវត្ថុ

Cristaux = គ្រឿងចរណៃ

Verrerie = គ្រឿងកែវ

Faïence = ហ្វូយ៉ង់

Porcelaine = ពរ្សឺឡែន

Poterie = កុម្ភការភណ្ឌ

Pinge d'office = សំពត់ជូត

Billard = ប៊ីយ៉ារដ៍

Picup = ពីគីប

Equipage = យានិក, បរិជន

Passager = យានចរ

(ល-ធ-៥០)

Corps diplomatique = អគ្គទូត

Corps consulaire = អគ្គកុងស៊ុល

Ambassadeur itinérant = អគ្គរាជទូតគោចរ

Chargé extraordinaire = ឆារីសាម័ញ្ញ

Conseiller d'Ambassade = ទីប្រឹក្សាស្ថានឯកអគ្គរាជទូត

Conseiller de Légation = ស្ថានអគ្គរាជទូត

1er Secrétaire d'Ambassade = លេខាធិការទី ១ នៃស្ថានឯកអគ្គរាជទូត

2e Secrétaire d'Ambassade = លេខាធិការទី ២ នៃស្ថានឯកអគ្គរាជទូត

Attaché d'Ambassade = អនុព័ន្ធស្ថានឯកអគ្គរាជទូត

Attaché commercial = អនុព័ន្ធស្ថានឯកអគ្គពាណិជ

Attaché culturel = អនុព័ន្ធវប្បធម៌

Attaché militaire = សេនានុព័ន្ធ

(๒๙-๑๒-๕๐)

Centre Régional = មជ្ឈមណ្ឌលភូមិភាគ

Centre de Recherches Scientifiques et Techniques = មជ្ឈមណ្ឌលនៃការស្វែងរកខាងវិទ្យាសាស្ត្រនិងតេកនិក

Centre Mondial = មជ្ឈមណ្ឌលពិភពលោក

Recommandation = អនុសាសន៍

Recommandé = អនុសិដ្ឋ

Adresse = អាសយដ្ឋាន

Stimuler = បណ្តុះបណ្តាល

Institution = ស្ថាប័ន

(๕-๔-๕๑)

Membre ex-officio = សន្និសមាជិក

Voix prépondérante = សំឡេងមានប្រៀប, សំឡេងកាត់សាញ

Contribution = ភាគទាន

(๘-๑-๕๑)

chèque = កែ្សក, មូលប្បទានប័ត្រ

Don = ទាន

Donateur = ទាយក

Donation = អំណោយ

Donatrice = ទាយិកា

Dotation = ទាយជ្ជទាន

Concession = សម្បទាន

(๑๒-๑-๕๑)

Revue «La Pensée Bouddhique» = ទស្សនាវដ្តី "ពុទ្ធចិន្តា"

Un forestier = វ្រុក្ខបាល

Chapitre = កថាភាគ

Paragraphe = កថាខ័ណ្ឌ

Alinéa = វាក្យខ័ណ្ឌ, វគ្គ

(๑๖-๑-๕๑)

(មានត)

កណ្ដាលទី ៩

អ្នកឧកញ៉ាវិបុលរាជសេនា នួ-កន ប្រែរៀបរៀង

(ត១ក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធំងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឯចូតូយើញតូកៀមលើកទាហានចេញមក ក៏ឡើងសេះដេះតម្រង់ទៅមុខទាហាន ឲ្យទាហានទាំងអស់ពួយគ្នាជាបែកឆ្វេងស្តាំ ។ តូកៀមក៏ឡើងសេះដេះតម្រង់ទៅ បញ្ជេញខ្លួនទន្ទនគំនាប់ចូតូហើយនិយាយថា ពីដើមខ្ញុំបម្រុងខ្លួនទឹងចូលទៅធ្វើការជាមួយនឹងលោកជាប្រាកដ លុះឃើញបិតាលោកលើកគ្រប់គ្រងមកដល់វិត្តខ្ញុំ។ ក៏បានគួរសមទទួលនាំទៅឈប់ស្នាក់លើទីគ្រីហាស្ថាន បានទាំងរៀបគោជនាហារដ៏ប្រសើរឲ្យពីសាជាតិពាប់អាន ហើយខ្ញុំបានចាត់ប្រៃតៀវឃើឲ្យនាំទាហានជូនដំណើរបិតាលោកទៅទៀត ប្រាថ្នាទឹងជួយការពារអន្តរាយ ហើយប្រាថ្នា

ទឹងឲ្យបានសេចក្តីគាប់ប្រសើរពីលោកផង តែថាគៀរយីជាមនុស្សទុច្ចរិត ប្រែចិត្តចេញពីខ្ញុំនាំបិតាលោកនឹងបក្សពួកទៅសម្លាប់យកទ្រព្យ ខ្ញុំនឹងបានបង្គាប់ឲ្យធ្វើដូច្នោះក៏ទេ ដែលលោកមកទាំងនឹងខ្ញុំជាគំនុំគុំគួនខ្លាំង ហើយលើកទាហានមកច្បាំងសម្លាប់អ្នកស្រុក ដែលមិនមានទោសខុសផងនោះ ខ្ញុំឃើញថាមិនគួរណាស់ សូមលោកគំរិះមើលដោយគួរសិនចុះ ។ ចូឆូព្រដូច្នោះទាំងច្របូកដេរច្របាច់ថាមាថតូកៀមជាពាក្យអាស្រូវកាសផ្សេង។ ហើយស្រែកថា "អាឯងប្រើៗបាយកលពន្យល់ឲ្យទាហានសម្លាប់បិតាអញនឹងបក្សពួកអស់ជាច្រើនដូច ហើយមកបើកមាត់និយាយតែខ្លួន សុទ្ធតែពាក្យសំខ្លួនគួរសមល្អណាស់" ហើយស្រែកប្រកាសថា នរណានឹងទទួលយកអាសាទៅចាប់ខ្លួនតូកៀមឲ្យយើងបាន ។ ហៃហ្គុនធ្វើយទទួលយកអាសាឡើងដិះសេះចេញទៅនឹងចាប់តូកៀម ចូប៉ាឃើញហើយបរសេះចេញមកតយុទ្ធគ្នានឹងហៃហ្គុនបាន ៥ ក្មេង ទទួលកើតខ្សល់ព្យុះធ្ងាក់ភ្លៀងរំលាជាខ្លាំង ពួកពលដែលកំពុងច្បាំងក៏ថយទៅឈប់តែសព្វខ្លួន ។ ឯតូកៀមកាលត្រឡប់ចូលទៅក្នុងស្រុកហើយ ក៏ប្រកាន់នឹងសេនាទាហានទាំងពួងថា ទាហានរបស់យើងនឹងតស៊ូព័ទ្ធចូឆូមិនបានទេ បើប្រឹងច្បាំងទៅកាលណា បណ្តាទាហាននឹងអាណាប្រជានុកស្លុកងឹងស្លាប់អស់ហើយ បើដូច្នេះគួរតែអ្នកពាល់គ្នានាំយកខ្លួនយើងទៅចងចំណងឲ្យជាប់ ហើយនាំទៅឲ្យចូឆូតែម្តងចុះ ទើបបានរួចរស់ជីវិតទាំងអស់គ្នា ។

កន្លែងនោះ មានឈ្មោះបិតុកពួកអ្នកស្រែកតន្លែងហៃ ពីដើម
ធ្លើដង្ហែលក់ដូរមានទ្រព្យសម្បត្តិច្រើន គ្រានាំគ្នាទៅលក់ឯស្រែក
ឡុកអៀងនោះ លុះលក់អស់ហើយក៏បរទេះត្រឡប់មកវិញ ។ មាន
ស្ត្រីម្នាក់រូបល្អស្រស់ជ្រះហៅលអាយុ ១៦ ឆ្នាំ សុំដោយសារទេះបិតុកមក
ស្រែកតន្លែងហៃផង ។ បិតុកៈយោគយល់អាណិតដឹងថាស្រី ក៏ប្រណីឲ្យឡើង
ជិះទេះ ឯខ្ញុំឯងក៏ចុះដើរទៅ ស្រីនោះនិយាយថា ខ្ញុំខ្ញុំជាអ្នកដោយ
សារនឹងអង្គុយលើរទេះឲ្យម្ចាស់ចុះដើរមិនគួរសោះ បើដូច្នេះអ្នកឡើងមក
ជិះវិញចុះ ។ បិតុកក៏ឡើងបរអង្គុយពីមុខ ស្រីនោះអង្គុយពីក្រោយ ខ្ញុំ
បិតុកនឹងបានក្រឡេកមើលឲ្យស្គាល់ស្រីនោះជាយ៉ាងម្តេចក៏ទេសោះ ។
លុះបរទៅដល់ស្រែកតន្លែងហៃ ស្រីនោះនិយាយថា "ខ្ញុំយើងមិនមែនជា
មនុស្សទេ គឺជាស្រីទេពអប្សរ ទេវតាជាធំប្រើឲ្យយើងយកភ្លើងមកដុតផ្ទះ
អ្នកឯង ទើបយើងក្លែងសុំដំរទេះដោយលបិត្តមើលឃើញថាអ្នកឯងមិនធ្វើ
អន្តរាយដល់ខ្ញុំនោះ គឺចិត្តអ្នកសុចរិតត្រង់ល្អមែន ប្រសិនជាយើង
នឹងមិនយកភ្លើងទៅដុតផ្ទះអ្នក ក៏ឃើញថាខុសនឹងបង្គាប់ទេវតាជាធំ បើ
ដូច្នេះអ្នកចូរជញ្ជូនទ្រព្យរបស់ពីក្នុងផ្ទះអ្នកចេញឲ្យអស់ក្នុងរវាយប៉ប់នេះ
យើងនឹងយកភ្លើងដុតផ្ទះចេញតាមពាក្យទេវតា" លុះនិយាយប្រាប់ដូច្នេះ
ហើយ ស្រីនោះក៏អន្តរធានបាត់ទៅ ។ បិតុកបានឃើញដូច្នេះ ក៏មាន
សេចក្តីអស្ចារ្យក្នុងចិត្តណាស់ ទើបរវៀសរវៃទៅដល់ផ្ទះហើយ ចាត់ឲ្យ

ដញ្ជូនរើយកទ្រព្យរបស់អស់ពីក្នុងផ្ទះ ។ ដល់ពេលអធ្រាត្រស្ងាត់ស្រាប់តែបណ្តាលភ្លើងឆេះផ្ទះបិតុកអស់រលីង ឯទ្រព្យរបស់ដែលដញ្ជូនចេញទៅនោះ បិតុកលើកឲ្យទៅជាទានសូមយាចកអស់គ្មានសល់ កិត្តិសព្ទនោះក៏ឮខ្ទរខ្ទាយទៅដល់តូក្រៃ ។ ចាត់ឲ្យមនុស្សទៅយកខ្ទួនបិតុកមកទុកជាទីប្រឹក្សា ។

កាលបិតុកបានឮតូក្រៃព្រមឲ្យគេចាប់ខ្ទួនទៅដូនចូធូដូច្នោះ បិតុកក៏ធ្វើយទាស់ថាលោកជាទីចៅហ្វាយស្រុកឈើដីវ សន្តានចិត្តរបស់លោកប្រកបដោយសុចរិតពិតត្រង់ ទាំងមានមេត្តាករុណាដល់ប្រជានុរាស្ត្រជាដៀងខ្លាយណាស់, ដែលលោកនឹងឲ្យចងខ្ទួនលោកទៅឲ្យចូធូនោះមិនសមគួរទេ បណ្តារាស្ត្រទាំងពួងនឹងអស់ទីពឹងពុំនាក់សោះ លោកត្រូវតែគិតកេណ្ឌកងសេនាទាហានឲ្យបានគ្រប់គ្រាន់ ហើយឲ្យទ្បើងរក្សាសែនបន្ទាយឲ្យមាំមួនចុះ បើធ្វើដូច្នោះឃើញថា ចូធូនឹងពុះពារយំលាយដោយងាយមិនបាន មួយទៀតសុំឲ្យលោកធ្វើសំបុត្រឲ្យខ្ញុំកាន់ទៅសុំកងទ័ពខុងយ៉ុងចៅហ្វាយស្រុកចាក់ហៃ យកមកជួយតតាំងច្បាំងនឹងចូធូ ១ ច្បាប់, មួយច្បាប់ទៀត ឲ្យចាត់ប្រៃសាហានកាន់សំបុត្រទៅសុំកងទ័ពតេងកៃចៅហ្វាយស្រុកឈៀងដីវមកជួយផង ទុកជាកងទ័ពសន្ធប់ខ្នងវាយទ័ពចូធូក៏គង់តែនឹងបែកមិនខាន ។ តូក្រៃបានស្តាប់ហើយយល់ឃើញត្រូវ ទើបសួរទៅបិតុកថា នរណានឹងទទួលយកអាសាកាន់សំបុត្រទៅឲ្យ

តេង់កៃ ។ គាន់តេង់ធ្វើយថាខ្ញុំបានសូមទទួលអាសា ។ តូកៀមក៏ឲ្យធ្វើ
សំបុត្រចោះត្រាប្រគល់ឲ្យបិតុកនឹងគាន់តេង់កាន់យកទៅឧណាៈនោះ ។

ឯខុងយ៉ឺងចៅហ្វាយស្រុកជ៉ាកវៃ ជាមនុស្សមានចិត្តធ្ងន់ខ្លួលាយ
រួសាយគប់ប្រសព្វពួកម៉ាកជាច្រើនណាស់ បណ្តាកស្តេកឆ្នែស្រុកមាន
សេចក្តីមេត្រីរាប់អាន ។ ខុងយ៉ឺងនោះមានគាហានមកទទួលទានអាហារ
លើផ្ទះ លុះឃើញបិតុកយកសំបុត្រទៅដល់ ក៏មើលដឹងសេចក្តីហើយថា
តូកៀមនឹងយើងជាមនុស្សស្រឡាញ់រាប់អានគ្នាមកយូរ ខាងចូឡូមិនដែល
មានរឿងអ្វីនឹងយើងដូចគ្នា បើយើងនឹងធ្វើសំបុត្រទៅហាមឃាត់ ចូឡូក៏
ប្រហែលនឹងស្តាប់ពុំខាន បើត្រឡប់ជាមិនស្តាប់យើងវិញ សុំយើងលើក
ទ័ពទៅជួយតូកៀមជាក្រោយ ។ បិតុកតបថា ចូឡូនោះខឹងគុំគួននឹងតូកៀម
ថាប្រើកលឧបាយសម្លាប់ចូកូជាបិតា បើលោកនឹងឲ្យសំបុត្រទៅឃាត់
វេលាណាខ្ញុំឃើញថា ចូឡូគង់មិនស្តាប់ ខាងនេះចង់ប្រញាប់ក៏នឹងនាំឲ្យ
យូរការ ។ ខុងយ៉ឺងធ្វើយថា អ្នកនិយាយដូច្នេះត្រូវណាស់ យើងនឹងប្រែ
បំរើយ៉ាងហ៊ាសឲ្យកាន់សំបុត្រទៅ ឯគាហានខាងនេះក៏យើងត្រូវកេណ្ឌ
បញ្ជូនឲ្យចេញទៅព្រមជាមួយគ្នាតែម្តង ។

កាលកំពុងនិយាយគ្នានោះ មានបំរើសេះមកជំរាបខុងយ៉ឺងថា កូនលៃ
ឃុំនាំពួកចោរដួតក្បាលលឿងប្រហែល ៤ - ៥ ម៉ឺន លើកចូលមកជិត
ដល់ស្រុកយើងហើយ ។ ខុងយ៉ឺងឮដូច្នាស់ក៏មានសេចក្តីភ័យណាស់រលេះ

រលាំងតាំងតែឲ្យកេណ្ឌគាហានលើកទៅតទល់នឹងពួកចោរ ។ កូនលៃខ្លើង ដឹះសេះបរចេញមកមុខគាហានហើយស្រែកហៅខុងយុ"ងថា ដែលយើង លើកទ័ពមកនេះគ្រាន់តែនឹងរកស្បៀងអាហារ បើអ្នកព្រមឲ្យស្បៀងយើង មួយម៉ឺនចាំង យើងនឹងលើកត្រឡប់កងទ័ពទៅវិញ បើអ្នកមិនព្រមឲ្យ យើងទេ យើងនឹងលើកកងទ័ពចូលប់វាយយកស្រុកនេះឲ្យបាន ហើយឲ្យ សម្លាប់ភរិយាបុត្រនឹងញាតិសន្តានមិនឲ្យមានសល់ ។

ខុងយុ"ងស្រែកតបថា ខ្ញុំយើងជាមន្ត្រីមានបណ្តាសក្តិរក្សាខប ខ័ណ្ឌសីមារបស់ព្រះមហាក្សត្រ ខ្ញុំឯងជាចោរកំណាចខ្លួចត, ដែល ឯងមកគិតកំហែងឲ្យយើងដូនស្បៀងទៅឲ្យនោះ យើងមិនត្រូវការឲ្យទេ, បើឯងខ្លាំងពូកែនឹងចង់វាយទំលាយយកស្រុកយើងក៏តាមចិត្តឯងចុះ យើង មិនខ្លាចទេ ។

កូនលៃខឹងណាស់ ដឹះសេះរាជាវចូលប្រយុទ្ធនឹងខុងយុ"ង ចុងចោ" គាហានខុងយុ"ងក៏ខ្ជើងសេះចេញទៅតទល់នឹងកូនលៃបាន ៥ ស្បែត, កូន លៃយកដាវកាប់ចុងចោ"ធ្លាក់ពីលើសេះស្លាប់, ខុងយុ"ងឃើញថានឹងទប់ទល់ ពុំឈ្នះក៏រួតរះថយគាហានចូលទៅក្នុងស្រុកវិញ ។ កូនលៃលើកពល គាហានចោរឡោមព័ទ្ធជុំវិញស្រុកនោះច្រើនថ្លៃ ឯចិត្តដែលតូរកៀមឲ្យនាំ សំបុត្រមកសុំកងទ័ព ក៏ជាប់នៅក្នុងស្រុកចា"ក់លៃដោយសេចក្តីព្រួយទុក្ខ ជាមួយនឹងខុងយុ"ង ។

លុះព្រឹកព្រាងឡើង ខុងយ៉ុងឡើងមើលលើសែនបន្ទាយ ឃើញពួកចោរព័ទ្ធជុំវិញ ខុងយ៉ុងក៏ប្រៀបប្រដូចថាហានយាមល្បាតប្រយ័ត្នការជាមាំមួនណាស់ ។

ពេលនោះមានថាហានម្នាក់ដឹងសេះពុះតារំលាយកងទ័ពចោរ ចូលមកដល់ទ្វារស្រុកស្រែកឲ្យបើកទ្វារទទួល ។ ខុងយ៉ុងគ្រឡែកឃើញមិនថាន់ហ៊ានបើកព្រោះមិនស្គាល់ច្បាស់ ។ ឯថាហានពួកចោរក៏តាមស្រែចូលមក ថាហានម្នាក់នោះក៏ប្រែមុខត្រឡប់ទៅវិញ ដេញកាប់ពួកចោរស្ងាប់ជាច្រើន ខុងយ៉ុងឃើញច្បាស់បង្គាប់ឲ្យបើកទ្វារទទួល ថាហាននោះក៏ចូលមក ខុងយ៉ុងសួរថា អ្នកឈ្មោះអ្វី? មកពីណាបានជាពុះពារំលាយពួកចោរចូលមកបាន? ។ ថៃស៊ូដូលោតចុះពីលើសេះបោះខ្លួនពីដៃចេញ ហើយនឹងគំនាប់ថាខ្ញុំបាទឈ្មោះថៃស៊ូដូ នៅស្រុកអ៊ុយគួន មាតាខ្ញុំបាទបានសរសើរដល់គុណលោកថា បានឲ្យអាវសំពត់ទឹងបាយទឹកត្រីសាច់ដល់មាតាខ្ញុំមកពីដើម ឥឡូវនេះមាតាខ្ញុំបានដឹងឮថា ពួកចោរមកចោមព័ទ្ធស្រុកលោកទើបគាត់ប្រើខ្ញុំបាទឲ្យមកជួយច្បាំង ក្រាបថ្វាយទឹងតបស្នងសងគុណ បានជាខ្ញុំបាទពុះតារំលាយពួកចោរចូលមកនេះ ខ្ញុំបាទសម្លាប់អស់ពួកចោរជាច្រើន ។ ខុងយ៉ុងបានឮច្បាស់ក៏នឹកឃើញបាន ហើយតបថា "កាលអ្នកនៅពីតូចនោះ យើងសំគាល់ថាទឹងមានសតិប្រាជ្ញាគួរជាថាហានបាន បានជាយើងយកវេសន៍ទៅឲ្យ

ដើម្បីចង់ជាមេត្រីគុណនឹងមាតារបស់អ្នក, ដែលមាតាប្រើអ្នកមកដួយធ្វើ
យើងគ្រានេះ យើងមានសេចក្តីសោមនស្សត្រេកអរណាស់ ” និយាយ
ហើយក៏យកគ្រឿងនឹងអាវឲ្យ ។ ថៃស៊ូដួងទួលយកគ្រឿងនឹងអាវ
ដោយអំណរ ហើយតំនាប់ដំរាបថា ខ្ញុំបាទនឹងសុំតាហាន ១ ពាន់ លើក
ចេញទៅវាយពួកចោរត្រាតែបែកឲ្យបាន ។

ខុនយ៉ុងឃាត់ហាមថា ខ្លួនអ្នកមានថ្លើដែខ្លាំងពូកែមែនហើយ តែថា
វេលានេះ ពួកចោរច្រើនខ្លាំងពូកែណាស់ ក្រែងអ្នកតទល់ពុំបាន ។ ថៃ-
ស៊ូដួរបថា លោកមានគុណនឹងមាតាខ្ញុំបាទជាច្រើន ទោះបីខ្ញុំបាទនឹងស្លាប់
ក្នុងតង់ខ្ញុំក៏ពុំស្តាយជីវិត ខ្ញុំបាទគិតឲ្យបានតែតបគុណលោកដែលមាន
ឧបការៈនឹងមាតាខ្ញុំបាទប៉ុណ្ណោះ បើខ្ញុំបាទត្រឡប់ទៅវិញហើយម៉ាតាដឹង
ថាខ្ញុំបាទពុំបានធ្វើការអ្វីសោះ ទៅសខ្ញុំបាទក៏មានច្រើន ។ ខុនយ៉ុងតបថា
ត្រូវហើយ យើងចង់បានអ្នកទុកជាទីប្រឹក្សាខើបហាមឃាត់ដូច្នេះ ព្រោះ
តាហានអ្នកស្រុកយើងតិចណាស់ ឯទៀតគេមានសតិប្បញ្ញាបានកួនអ្វី,
តែវហ៊ុយទុកជាកំឡាំង បើបានទៀតមកជួយច្បាំងជាទំនងប្រសើរ ពួក
ចោរក៏គង់នឹងបែកពុំខាន តែថានឹងរកអ្នកឯណាកាន់សំបុត្រពុះពារ
ចូលយៅគ្នាន ។ ថៃស៊ូដួរបថា បើលោកមិនឲ្យខ្ញុំបាទចេញទៅច្បាំងទេ
នឹងឲ្យខ្ញុំបាទនាំសំបុត្រទៅវិញ ខ្ញុំបាទនឹងនាំចេញទៅឲ្យទៀតី ។

ខុនយ៉ុងក៏តាំងធ្វើសំបុត្រជាសេចក្តីថា “ខុនយ៉ុងចៅហ្វាយស្រុកចាំក
ហៃឲ្យពារមកដល់ទៀតីចៅហ្វាយស្រុកផេងដួនកួន ដ្បិតវេលានេះកួន

ហៃ នាំពួកចោរកំណាចប្រហែលបួនរយនាក់មកឡោមព័ទ្ធខែត្រខ្ញុំដុំវិញ អ្នកចូរមានចិត្តគិតមេត្តាដល់ខ្ញុំ លើកទ័ពមកច្បាំងសម្លាប់ពួកចោរដោះទ័ពខ្ញុំពីក្រៃឲ្យបាន ខ្ញុំនឹងអ្នកក៏នឹងមានផ្លូវមេត្រីនឹងគ្នាតទៅ" លុះធ្វើសំបុត្រហើយក៏ប្រគល់ឲ្យថៃស៊ីដូ ។ ខ្លួលសំបុត្រភ្លាម ក៏ត្រៀមខ្លួនពាក់គ្រឿងដំរេះ កាន់ខ្លួនបរចេញតាមទ្វារស្រុកទៅដល់មុខបន្ទាយទ័ពចោរ ។ ក្លួនហៃឃើញក៏លើកទាហានចេញស្រមកជេញចាប់ថៃស៊ីដូ ។ ក៏បង្រិះពុះពារទ័ពចោរតនឹងអាវុធឥតរួញរា ពួកចោរពិការស្លាប់នឹងគណនាពុំបាន ។ ថៃស៊ីដូចេះតែកាប់ឆ្ការបំពារឆ្ពុះឆ្ងាយទៅ លុះទៅដល់ស្រុកផេងឆ្លួនក្លួនចូលទៅគំនាប់ឡៅពីហើយដួនសំបុត្រទៅឡៅពីមើល ។ ឡៅពីដឹងក្នុងសេចក្តីសំបុត្រនោះនៅមិនទាន់ឆ្លើយថាម្តេច ក៏លួចសំឡឹងមើលរូបភាពថៃស៊ីដូ ឃើញមាំមួនសួនសមជាទាហានហើយសួរថា អ្នកឈ្មោះអ្វី? ថៃស៊ីដូឆ្លើយថា ខ្ញុំបាទឈ្មោះថៃស៊ីដូ នឹងបានជាញាតិសាលោហិតស្និទ្ធស្នាលនឹងឧងយ៉ុងក៏ទេ, ដែលខ្ញុំបាទទទួលយកអាសាមកនេះ ព្រោះឧងយ៉ុងមានគុណនឹងមាតាខ្ញុំបាទពីដើម ។ ឡៅពីបានស្តាប់ក៏ចាប់ចិត្តស្រឡាញ់ហើយសរសើរថៃស៊ីដូថា ជាអ្នកមានចិត្តកតញ្ញូនឹងមាតា ហើយសួរថា ដែលឧងយ៉ុងកប់អានឲ្យមកសុំកងទ័ពយើងទៅជួយនោះ យើងមុខជានឹងលើកទៅតាមត្រូវការ ។ ពេលនោះឡៅពីឲ្យក្លួនអ៊ូ តៀវហ៊ុយប្រមូលសេនាទាហានបាន ៣ ពាន់ ហើយនាំថៃស៊ីដូលើកចេញទៅស្រុកចាក់ហៃ ។

ឯកូនហៃនាយចោរ លុះឃើញកងទ័ពលើកមកពីក្រោយដឹងថា ជាទ័ពលើកមកជួយខុងយ៉ឹង ក៏ប្រៀបប្រដូចទាហានជាកខៅតទល់ ។ ឡៅពីបរពលចូលខៅជិតហើយ ឲ្យកូនអ៊ូ តៀវហ៊ុយ នឹងថៃស៊ូជួ បរសេះស្រួតខៅមុខទាហាន ។ កូនហៃក្រឡេកឃើញកងទ័ពដែលលើកមកនោះតិច ក៏ប្រមាថមើលងាយមិនសូវនឹងប្រឹងសង្កាត់ប្រយ័ត្នការ បរសេះចេញខៅតសង្កាត់មុខទាហាន ។ ថៃស៊ូជួបរសេះបំពានចេញខៅទទួលឃើញកូនអ៊ូបរសេះស្ទុះលឿនខៅមុខខ្លួនក៏ទាញសេះទប់ ឯកូនអ៊ូចូលខៅស៊ប់តគ្នានឹងកូនហៃបាន ៣០ ស្នៀត កូនអ៊ូយកដាវវែងកាប់ត្រូវកូនហៃដាច់ពាក់កណ្តាលខ្លួនធ្លាក់ពីលើសេះស្លាប់ ។ កូនអ៊ូថៃស៊ូជួក៏ដេញកាប់ទ័ពចោរជាកោឡាហល ឡៅពីនឹងតៀវហ៊ុយចូលច្របល់ពីក្រោយខៀត ។ ឯខុងយ៉ឹងបានឮសំឡេងកងទ័ពគឹកកងក៏ឡើងមើលសែនបន្ទាយ ឃើញកងទ័ពឡៅពីដេញកាប់សម្លាប់ពួកចោរបែកបាក់ខ្ចាត់ខ្ចាយ ឧបមាដូចខ្លាដេញចាំហ្វូងប្រើសត្រាយកណ្តាលត្រាញ់ ខុងយ៉ឹងក៏មានសេចក្តីត្រេកអរពន់ប្រមាណស្ទុះខៅបរពលខ្លប់ពីក្រោយ ពួកចោរបែកបាក់ស្លាប់ពិការខ្លះរត់រួច ខ្លះមកនៅនឹងឡៅពី ។

ខុងយ៉ឹងឲ្យអញ្ជើញឡៅពី កូនអ៊ូ តៀវហ៊ុយនឹងថៃស៊ូជួ ចូលមកក្នុងស្រុក ហើយរៀបតែងតុលៀងភោជនាហារ ។ កាលកំពុងបរិភោគខុងយ៉ឹងឲ្យបិតុកក្រោកឡើងគំនាប់ឡៅពី ហើយខុងយ៉ឹងពណិនារឿន

ដែលតួកៀមប្រើបិតុកកាន់សំបុត្រមកសុំកងទ័ព ទៅជួយច្បាំងនឹងចូឆូ ខ្លួលកងទ័ពកួនលៃមេះចារមកឡោមព័ទ្ធចេញទៅពុំបាន។ ជាបិតុកកំពង់ ទៅកងទ័ពនេះ ។

ឡៅពីតបថា តួកៀមជាមនុស្សពិតត្រង់ល្អណាស់, ដែលនឹងក្លែងកលឲ្យកើតហេតុទាំងនេះ ក៏គឺតែកម្មរបស់តួកៀមឯង ។ ពុងយ៉ុងឆ្លើយថា ឥឡូវនេះចូឆូស្មានថា តួកៀមប្រើឧបាយ បានជាទៅគុំគួន នឹងសងសឹកតួកៀមវិញ ឯកងទ័ពចូឆូលើកមកនោះច្រើនអនេកណាស់ បើឲ្យសព្វាយដល់ពួកអ្នកស្រុកសិងវិនាសអស់ទាំងប្រុសស្រី ខ្លួនអ្នកជាពួជព្រះពជវង្សព្រះចៅហៀនតេ គួរហើយនឹងទំនុកបំរុងឲ្យបណ្តាភស្តុតាងពួងមានសេចក្តីសុខក្សេមក្សាន្ត ខ្ញុំសូមអញ្ជើញអ្នកលើកទ័ពទៅជាមួយនឹងខ្ញុំ ដើម្បីនឹងជួយតួកៀម ដែលចូឆូលើកទ័ពមកប្រទូសព្យាយនោះ ។ ឡៅពីបានស្តាប់ឆ្លើយតបថា ដែលអ្នកនិយាយមកនេះគួរសមហើយតែថាយើងខ្លាចក្រែងមិនឆ្លងការព្រោះទាហានយើងតិចណាស់ បើនឹងលើកទៅតតាំងគង់នឹងចាញ់ចូឆូ ។ ពុងយ៉ុងឆ្លើយថា ដែលខ្ញុំបង្គំនឹងលើកទ័ពទៅជួយតួកៀមនោះ មិនមែនព្រោះឃើញលាភសក្ការៈ ឬព្រោះគាប់ចិត្តអ្នកនោះក៏ទេ ចំពោះឃើញថាតួកៀមជាមនុស្សសុចរិតពិតត្រង់ នឹងផែនដី មានសេចក្តីមេត្តាអាណិតអាណាប្រជានុកស្តួរទៅជាស៊ីឆ្ងួចខ្លួនអ្នកជាពួជព្រះពជវង្សព្រះចៅហៀនតេ យល់ឃើញថានរណាជា

មនុស្សកតញ្ញូនឹងផែនដីហើយមានទុក្ខធុរៈពិត គួរនឹងជួយអាណិតឬទ្ធិ
ចិត្តមិនរវៃវិញ ? ។

ឧត្តរតបថា ចិត្តរបស់ខ្ញុំដែលបានដឹងឮដូច្នេះនឹងបានកន្តើយ
ព្រងើយក៏ទេ តែវេលានេះសុំឲ្យអ្នកលើកតាហានទៅមុនចុះ ខ្ញុំនឹងវិលទៅ
ខ្ចីតាហានកងស៊ុនចានឲ្យបាន ២-៣ ពាន់ផ្សំគ្នា ហើយលើកតាមអ្នកទៅ
ជាក្រោយ ។ ពុទ្ធយ៉ងឆ្លើយថា ដែលអ្នកនឹងលើកទៅតាមក្រោយនោះកុំ
ឲ្យបញ្ឆោតយើង ។ ឧត្តរតបថា "អ្នកដែលដឹងឮគេនិយាយថាខ្ញុំធ្លាប់
បញ្ឆោតកូតកអ្នកណាខ្លះ ? បើយើងទៅខ្ចីតាហានគេបានក្តីមិនបានក្តី
យើងក៏លើកទៅតាមអ្នកជាប្រាកដ" ហើយក៏លាពុទ្ធយ៉ងតម្រង់ទៅរក
កងស៊ុនចាននៅស្រុកប៉ាក់បេង ។ ពុទ្ធយ៉ងក៏ឲ្យបិតុកស្រួតទៅប្រាប់
គូកៀមថា នឹងលើកទ័ពទៅជួយ, បិតុកទទួលពាក្យហើយលាពុទ្ធយ៉ង
ត្រឡប់ទៅ ។

ខណៈនោះមានមនុស្សមកប្រាប់ថៃស៊ីជូថា ឧត្តរអ៊ីវឲ្យហៅទៅជួប ។
ថៃស៊ីជូចូលទៅដំរាបពុទ្ធយ៉ងថា ដែលមាតាខ្ញុំបានប្រើឲ្យមកតបស្នងសង
គុណលោកនោះ ខ្ញុំបានក៏បានធ្វើការសម្រេចហើយ ឥឡូវនេះឧត្តរអ៊ីវ
ចេញហ្វាយស្រុកអៀងដីវ ប្រើបំរើឲ្យនាំសំបុត្រមកហៅខ្ញុំបានថាឲ្យទៅ
ដើម្បីនឹងប្រឹក្សាការពាក់ការ បើខ្ញុំបានមិនទៅទេនឹងខូចផ្លូវមេត្រីរាប់អាន
គ្នា ហេតុនេះខ្ញុំបានសូមលាលោកទៅសិន ។ ពុទ្ធយ៉ងបានស្តាប់ក៏ចាប់

ចិត្តអាល័យថៃស៊ីដូណាស់ ទើបចូលទៅយកមាសប្លាក់ នឹងសំពត់អាវ ឲ្យជាគំនាប់ថៃស៊ីដូ។ ថារបស់ទាំងនេះសូមលោកទុកចែកចាយឲ្យគាហានចុះ ហើយលាខុងយ៉ឺងទៅរកមាតា ពណ៌នាប្រាប់សេចក្តីឲ្យមាតាស្តាប់គ្រប់ប្រការ ។ មាតាបានស្តាប់មានសេចក្តីសោមនស្សណាស់ទើបថា ដែលឯងអើរៅហ្វាយស្រុកអៀងជីរឲ្យមករកកូននោះចូរទៅជាប្រញាប់ចុះ ។ ថៃស៊ីដូលាមាតាចេញទៅដល់ស្រុកអៀងជីរ ។

ឯឡៅពីកាលទៅដល់ស្រុកប៉ាក់បេង ចូលទៅរកកងស៊ុនចានជួបហើយនិយាយថា ឥឡូវនេះចូរឆ្លើកទ័ពទៅច្បាំងនឹងតូកៀមចៅហ្វាយស្រុកឈីជីវ, ខ្ញុំមកសុំខ្លីគាហានអ្នក ២ - ៣ ពាន់ ដើម្បីលើកទៅជួយតូកៀមឆ្លើសគ្រាមតនឹងចូរួ ។ កងស៊ុនចានបានស្តាប់ឆ្លើយតបថា ចូរួហើយនឹងអ្នកមិនជាខោសទាស់គ្នាពីអ្វីសោះ អ្នកនឹងលើកទៅជួយខាងតូកៀមនោះ ខ្ញុំមិនយល់ព្រមផងទេ ។ ឡៅពីតបថា ខ្ញុំបានទទួលពាក្យនឹងខុងយ៉ឺងទៅហើយ បើត្រឡប់ជាមិនទៅវិញ ខុងយ៉ឺងនឹងថាខ្ញុំចរចាមិនពិត ។ កងស៊ុនចានឆ្លើយថា បើអ្នកបានជាទទួលពាក្យគេមកហើយខ្ញុំនឹងឲ្យគាហានសេះតែត្រឹម ២ ពាន់ចុះ ។ ឡៅពីតបថា ខ្ញុំនឹងសុំជូឡុងទៅផង ។ កងស៊ុនចានក៏ព្រមឲ្យ ។ ឡៅពីមានសេចក្តីត្រេកអរណាស់ទើបនាំយកជូឡុងនឹងគាហានកងស៊ុនចានចំនួន ២ ពាន់ ឲ្យជូឡុងជាកងទ័ពក្រោយ ។

(មានត)

ភាគទី ២

សម័យនគរធំ

អ្នកឧកញ៉ាទេពពិទូរ ឈឹម - ក្រសែម រៀបរៀង

(តទៅ)

តាំងពីឆ្នាំ ព. ស. ១៧៣៣ ដល់ ព. ស. ១៧៦៣ ប្រទេសចាម្ប៉ា ប្រាថ្នាក់មកជាសម្បត្តិរបស់ប្រទេសកម្ពុជា ដោយស្នាព្រះហស្តរបស់ព្រះបាទជ័យវរ្ម័នទី ៧ ។ តែការដែលទ្រង់តាំងព្រះវិញ្ញាននន្ទ៍ឲ្យនៅគ្រងខែត្របណ្តាវង្គ៍នោះ ទុកជាគ្គន់កន្តុងផ្លូវរាជ្យប្បសាសនោបាយ ព្រោះការដែលចាប់កតញ្ញូវែកមិនខ្ជាប់ រមែងត្រឡាប់ទាំងប្រាណវិញ ឬថាអ្នកដឿទុកចិត្តសត្វសាហាវ ច្រើនតែបានទទួលទោសទុក្ខស្នងមកវិញ ។ រឿងព្រះវិញ្ញាននន្ទ៍ ក៏មិនឈ្លៀងពីសំដីនេះ ទោះបីព្រះបាទជ័យវរ្ម័នទ្រង់ចាញ្ចឹមតាំងពីតូច ទ្រង់បង្ហាត់បង្រៀនវិទ្យាសាស្ត្រនឹងយុទ្ធសាស្ត្រ ទ្រង់ព្រះរាជទានយសជា យុវរាជ ព្រមទាំងគ្រឿងសព្វាយុធយ៉ាង រហូតដល់ទៅឲ្យគ្រងស្រុកធំ ១ ក៏នៅតែមិនស្កប់ចិត្ត ឬមិនសាំងខ្មែត ។ ក្នុងឆ្នាំ គ. ស. ១២០៣ ពួកចាម្ប៉ាបានបង្កហេតុបះបោរ បណ្តេញព្រះមហាឧបរាជខ្មែរចេញពីក្រុងវិជ័យ ។ ព្រះវិញ្ញាននន្ទ៍ឃើញបាននូវកាសក៏ស្រាវគ្រតគ្រាប្រទេសចាម្ប៉ាទាំងមូល ដោយមិនបានទទួលព្រះរាជានុញ្ញាត

ខុញ្ញាតពីព្រះបាទជយវរ្ម័នជាអម្ចាស់របស់ខ្លួន ។ ព្រះបាទជយវរ្ម័នទី ៧ កាលទ្រង់ជ្រាបរឿងបះបោរនោះហើយ ទើបតែស្រាប់តាត់ឲ្យព្រះជយ-ឥន្ទ្រវរ្ម័ន (ក្សត្រិយ៍ឈ្មោយ) ចេញទៅកម្រាប តែកាលទៅដល់ក្រុងវិដ័យ ក៏ត្រូវព្រះវិញ្ញានខ្លួនធ្វើគត់បង់ ។ ព្រះមហាក្សត្រិយ៍មិនព្រមលះលែងចាម្ប៉ាទើបទ្រង់សូកស្តេចចាម្ប៉ា ១ អង្គ សឹងត្រូវជាបិតុលៈរបស់ព្រះវិញ្ញានខ្លួនឲ្យដេញព្រះវិញ្ញានខ្លួនចេញពីប្រទេសចាម្ប៉ា ។ គាំងពីឆ្នាំ គ. ស. ១២០៣ ដល់ ១២២០ ប្រទេសចាម្ប៉ាធ្លុកដូចជាខែត្រ ១ របស់ប្រទេសកម្ពុជា ព្រោះទ្រង់មិនតាំងក្សត្រិយ៍ចាម្ប៉ាឲ្យគ្រប់គ្រងដូចមុន។ ។

ក្រោយដែលកម្រាបចាម្ប៉ាកបជាបហើយ ព្រះបាទជយវរ្ម័នបានស្តេចលើកទ័ពទៅកម្រាបប្រទេសផ្សេងៗ បែកខាងលិចនឹងខាងជើង ។ តាមសិលាចារឹកខ្មែរ ១ នៅសាយហ្វុង មុខក្រុងវៀងចន្ទន៍ នឹងប្រវត្តិ-សាស្ត្ររបស់ចិន ១ ខាក់ទៀតថា ព្រះបាទជយវរ្ម័នបានស្តេចលើកទ័ពទៅត្រួតបច្ចន្តរដ្ឋម៉ាលយូ ១ ភាគ បែកខាងអាយដែលធ្លាប់ជាអាណានិគមរបស់ខ្មែរតាំងអំពីដើមរៀងមក ទ្រង់បានរៀបចំការគ្រប់គ្រង ឲ្យអនុវត្តន៍ទៅតាមប្រពៃណីដើម គឺឲ្យមានព្រះឧបកដឈរគ្រប់គ្រង នៅក្រោមឥទ្ធិពលខ្មែរតមក ។

លំដាប់អំពីនោះ បានស្តេចលើកទ័ពទៅកម្រាបប្រទេសកូមាដែលជាប្រទេសធ្លាប់នៅក្រោមអំណាចខ្មែរដែរ តែកន្លងពេលមុននេះ ប្រទេស

កម្ពុជាបានធ្វើសឹកជាមួយប្រទេសចាម្ប៉ាជាញឹកញយ ប្រហែលជាពួកនេះ
ឃើញបានឧកាស ក៏ប្រកាសតាំងខ្លួនជាឯករាជ្យឡើង ទើបព្រះបាទ
ជយវរ្ម័នលើកទ័ពហួងទៅកម្ចាប ហើយទ្រង់បានតាំងក្សត្រិយ៍កូមាឲ្យ
នៅគ្រប់គ្រងជាប្រទេសរាជ ។

តអំពីនោះ ឃានស្តេចលើកទ័ពចេញទៅត្រួតបច្ចន្តរដ្ឋប៉ែកខាងជើង
គឺតាំងពីវៀងចន្ទន៍ ហួងព្រះបាង រហូតទៅទល់ប្រទេសចិន ហើយទ្រង់
បានតាំងព្រះរាជវង្ស ១ អង្គព្រះនាម "រាជេន្ទ្រវរ្ម័ន" ជាឧបរាជនៅគ្រប់
គ្រងរដ្ឋនេះ ។ វេលានោះ ព្រះរាជេន្ទ្រវរ្ម័ន ប្រហែលជាតាំងរាជធានីនៅ
វៀងចន្ទន៍ ។

តាមដែលបានពោលមកនេះ ឃើញថា ព្រំប្រទល់នៃព្រះរាជអា-
ណាចក្រកម្ពុជា កុងរជ្ជកាលព្រះបាទជយវរ្ម័ន ទី ៧ នោះធំទូលាយ មាន
បរិមាណប្រហែលគ្នានឹងរជ្ជកាល ព្រះសូរ្យវរ្ម័ន ទី ២ គឺ :

ខាងកើត រួមប្រទេសចម្ប៉ាចូលមកផង ;

ខាងត្បូង ដល់សមុទ្រចាំ"ស៊ីហ្វិត ;

ខាងនិរតី ដល់ពាក់កណ្តាលប្រទេសម៉ាលយូ ;

ខាងលិច ដល់ប្រទេសកូមា ;

ខាងជើង ទល់ប្រទេសចិន ។

ក្នុងកាលក្រោយ ដែលខ្ញុំត្រាបនឹងរៀបចំរដ្ឋបាលនេះហើយ មរណទុក្ខយ៉ាងធ្ងន់ ប៉ានឆ្អាក់មកត្រូវព្រះអង្គ គឺព្រះនាងជយាជវេរី អគ្គមហេសីរបស់ព្រះអង្គ សោយព្រះវិលាល័យចាកចោលព្រះអង្គទៅ ។ ក្រោយនោះ ខ្ញុំបានឲ្យធ្វើព្រះពាជពិធីអភិសេក ព្រះនាងឥន្ទ្រទេវី សឹងត្រូវជាព្រះដេដ្ឋភគិនីរបស់ព្រះនាងជយាជវេរី ឲ្យឡើងជា ព្រះអគ្គ-មហេសីតមក តែព្រះនាងនេះ គ្មានព្រះពាជទុរាស ឬព្រះពាជធីតាទេ ។

ព្រះគុណសម្បត្តិនៃព្រះនាងឥន្ទ្រទេវី

ព្រះនាងឥន្ទ្រទេវី ខ្ញុំបានសិក្សាអក្សរសាស្ត្ររបស់ជាតិ នឹងអក្សរ សាស្ត្រភាសាសំស្ក្រឹត រាំងខ្ញុំបានសិក្សាតតិជម្ពីក្នុងព្រះពុទ្ធសាសនា ។ ប្រាកដក្នុងសិលាចារឹកថា ព្រះនាងនេះ ពូកែលើសលប់គ្មានអ្នកណា ស្មើបានក្នុងវិទ្យាសាស្ត្រនឹងបរមត្ថ, ព្រះមហាក្សត្រិយ៍ខ្ញុំបានតាំង ព្រះនាងជា បរិនាយកាចារ្យ បង្ហាត់បង្រៀនសិស្សទាំងឡាយនៅក្នុងវត្ត ព្រះពុទ្ធសាសនា ។ សិលាចារឹកនៅវិមានអាកាសក្នុងមហានគរ សំដែងថា: ព្រះនាងគង់នៅក្នុងអារាម ១ ឈ្មោះ នរេន្ទ្រាស្រម[1] ជាទីដំរាំ នៃការសិក្សា ។ ព្រះនាងបានបង្ហាត់បង្រៀនពួកស្ត្រី នឹងកុមារីពាជបរិពារ ជាយ៉ាងច្រើន ពាល់ៗ ថ្ងៃ; មានអ្នកចេះដឹងតាមព្រះនាងច្រើនអនេក សូម្បី

---

១ បានប្រែទៅនៅទីដទៃទៀតថា ព្រះនាងជាគ្រូបង្រៀនទៅនរេន្ទ្រាស្រម, នាគេន្ទ្រ ចំងាំ តំលកោត្តរ ជា ៣ កន្លែង ។

ព្រះនាងជយភដ្ទវៅ កំបានសិក្សាក្នុងសំណាក់ព្រះនាងដែរ ។ ព្រះនាងកំល្បីព្រះកិត្តិយស ទទឹងជាទីគោរពរបស់សិស្សទាំងឡាយ, ព្រះនាងជាអ្នកធ្វើឲ្យសិស្សស្ត្រីអំបាលនោះ បានទទួលនូវសេចក្តីសុខ ហាក់ដូចជាទេពធីតាឈ្មោះសរស្វតី ចៃដន្យគាគមករស្រោចស្រង់ ។ ការដែលព្រះនាងបង្ហាត់បង្រៀនទាំងប៉ុន្មាន ឧបមាដូចជាទឹកទិព្យដ៏ប្រសើរដែលបង្ហូរចេញមកជាសេចក្តីចេះដឹងយ៉ាងជ្រាលជ្រៅ, ព្រះនាងមានព្រះពជហឫទ័យដេកដួលខ្ជាប់នៅក្នុងផ្លូវធម៌អាថ៌ ។ សូម្បីព្រះនាងបានជាអគ្គមហេសីក៏មិនរវៀងទៅតាមយសស័ក្តិនេះ ។ តែព្រះពុទ្ធសាសនាដែលព្រះនាងទទួលប្រតិត្តប្រតិបត្តិនេះ គឺជាលទ្ធិមហាយាន ។ ឯការសាសំស្លឹតគេសង្កេតឃើញថា ព្រះនាងមានសេចក្តីចេះដឹងយ៉ាងជ្រាលជ្រៅពិតប្រាកដ ដោយមានសិលាចារឹកយ៉ាងធំ នៅវិមានអាកាសជាស្នាព្រះហស្តដែលព្រះនាងចារឹកទុក ។

ការព្រះសាសនាចំពោះការកសាង – ព្រះចាន់ជយវរ្ម័នគ្រាយដែលទ្រង់បានរៀបចំការផែនដីឲ្យបានធំទូលាយ ទទឹងសាន្តគ្រាណារៀបរយហើយ ទ្រង់ក៏ចាប់ផ្តើមការកសាងយ៉ាងសំបើម ។ ដំបូងទ្រង់បានបដិសង្ខរណៈក្រុងយសោធរបុរៈ (នគរធំ) គឺសាងកំពែងទទឹងគូដុំវិញកំពែងជាថ្មី ឲ្យមាំមួនទទឹងធំទូលាយចេញទៅ ។ តាមហាត់ដោយថ្មីនេះទុកឲ្យបាយ័នជាកណ្តាលក្រុង មានមាត់ទ្វារនៅកំពែងគ្រប់ ៥ អន្លើ គឺទិស

ទាងកើតពីរ ទិសត្រៃពីនេះមួយ។ ។ តំពែងនោះវាស់ដោយដុំវិញចំនួន ១២ គីឡូម៉ែត្រ ។ វាស់ដោយសង្កាត់ជា ៤ ដងចតុរស (គឺបណ្តាយ ៣ គីឡូម៉ែត្រ ទទឹង ៣ គីឡូម៉ែត្រ, ទ្រង់ឲ្យឈ្មោះកំពែងនេះថា "ជយគិរិ" ឲ្យឈ្មោះគូដុំវិញកំពែងថា "ជយសិន្ធុ" តែសព្វថ្ងៃនេះអ្នកស្រែមាបហៅថា "កសិន" ល្អៀងចេញពីឈ្មោះដែលពិត ។

ប្រាសាទកណ្តាលក្រៃង តាមសិលាចារឹកយើញឈ្មោះ "កុំកណ្តាល" ក៏មាន ហៅ "យសោធរគិរិ" ក៏មាន ។ ប្រាសាទនេះគេសង្កេតយើញថា មានការបដិសង្ខរណៈជាច្រើនលើក តែមានបញ្ហាថា ក្សត្រិយ៍អង្គណាជា អ្នកសាងជាដំបូង? ។ តាមយោបល់របស់អ្នកប្រាជ្ញគាំងឡាយដែលបាន ពិនិត្យនឹងស្រាវជ្រាវក្នុងបច្ចុប្បន្ននេះបែកគ្នាជា ២ ន័យគឺ អ្នកខ្លះថាសាង តាំងពីកន្លែងកាលព្រះបាទយសោវរ្ម័ន; អ្នកខ្លះថា ព្រះបាទជយវរ្ម័នទី ៧ ទ្រង់សាងឡើង ដោយអាងថា "នៅប្រាសាទនេះត្រង់ជ្រុងឦសានមាន រូបព្រះពោធិសត្វលោកេស្វរៈ១ជាសំគាល់ ព្រោះថាព្រះបាទជយវរ្ម័នទី ៧ ទ្រង់កាន់អានព្រះពុទ្ធសាសនាលទ្ធិមហាយាន កាលទ្រង់សាងប្រាសាទ នេះឡើង ទើបឲ្យសាងរូបព្រះពោធិសត្វនេះ; ឯព្រះបាទយសោវរ្ម័នទ្រង់ កាន់អានសាសនាព្រាហ្មណ៍ គង់ជាមិនសាងរូបក្នុងព្រះពុទ្ធសាសនា" ។

តំណឹងបុណ្យប្រកេនព្រះឆ្នាន

ចំពោះព្រះសង្ឃ ៨៨ រូបដែលប្រឡងជាប់សញ្ញាប័ត្រ

សាលាបាលីជាន់ខ្ពស់

ផ្សាយពីសមាគមមិត្តសាលាបាលី

ពត៌ងចប់

សុន្ទរកថា

ព្រះពោធិវង្ស ហួត-តាត បាងហ្វាងសាលាបាលីជាន់ខ្ពស់

សូត្រក្នុងឱកាសប្រគេនព្រះឆ្នាទៀយដល់សិស្សសាលាបាលីជាន់ខ្ពស់

នៅថ្ងៃទី ២៥ កម្ពុ: ១៩៥១

សូមថ្វាយព្រះពរព្រះកុណាជាម្ចាស់ជីវិត !

សូមថ្វាយបង្គំសម្តេច !

ថ្វាយព្រះពរ, ចំរើនពរ ចំពោះទ្រង់,

ឯកទត្តម, ព្រះតេជព្រះគុណ,

នឹងអស់លោក - អ្នកចាំងឡាយ !

អម្បាញ់មិញនេះ លោកអធិបតីនៃសមាគមមិត្តសាលាបាលីបាន ថ្លែងសេចក្តីថ្វាយព្រះកុណាជាម្ចាស់ជីវិតរួចហើយ អំពីកិច្ចការដ៏ប្រសើរ ដែលសមាគមបានធ្វើ ចំពោះសាលាបាលីជាន់ខ្ពស់ ដែលជាមន្ទីរសិក្សា វិជ្ជាផ្នែកមួយក្នុងព្រះពុទ្ធសាសនា ប្រកបដោយសេចក្តីប្រៀបធៀប គួរ ឲ្យពុទ្ធសាសនិកជនចាំងឡាយមានសេចក្តីពេញចិត្តដោយច្រើន ។

ឥឡូវនេះ អាត្មាភាពតាងនាមសាលាចាលីជាន់ខ្ពស់ សូមសំដែងសេចក្តីរីករាយដ៏លើសលប់ដោយគោរព ចំពោះព្រះករុណាជាម្ចាស់ជីវិតដែលទ្រង់ស្តេចយាងមកជាព្រះរាជាធិបតី ក្នុងពិធីចែកព្រហ្មទេយ្យ ដែលជាបុណ្យផ្នែកមួយ អាចជួយអប់រំកម្លាំងការសិក្សាក្នុងព្រះពុទ្ធសាសនានាសាណានេះ ព្រោះពិធីបុណ្យមានសភាពដូច្នេះនេះ ជាសិរីសួស្តីហើយជាកិត្តិយសដ៏ឧត្តម ដល់សាលាចាលីជាន់ខ្ពស់ ក្នុងបច្ចុប្បន្ននេះនឹងតទៅអនាគត ។

ម្យ៉ាងទៀត សាលាចាលីជាន់ខ្ពស់ សូមទទួលអំណរយ៉ាងក្រៃលែងចំពោះសមាគមមិត្តសាលាចាលី ដែលបានគាំផ្តើមចាត់ចែងធ្វើកល្យាណកិច្ចគឺការចែករង្វាន់នេះជាកិច្ចគួរឲ្យសរសើរ ព្រោះតាំងពីថ្ងៃដែលសាលាចាលីជាន់ខ្ពស់នេះកើតឡើង មានអាយុ ៣៦ ឆ្នាំហើយ, ពិធីចែករង្វាន់ចំពោះសិស្ស ដែលបានប្រឡងចេញពីសាលាមានសភាពដូច្នេះ ទើបនឹងមានត្រឹម ៣ ដងប៉ុណ្ណោះ គឺពីក្នុង គ. ស. ១៩៤២ ពុទ្ធិកសមាគមកម្ពុជវដ្ឋ បានចាត់ចែងធ្វើពិធីចែករង្វាន់ម្តង, កន្លងពីនោះមក ៩ ឆ្នាំ គឺក្នុង គ. ស. ១៩៥០ សមាគមមិត្តសាលាចាលីបានចាត់ចែងធ្វើម្តងទៀតជាលើកទីពីរ, ដល់មកក្នុង គ. ស. ១៩៥១ គឺក្នុងពេលនេះសមាគមដដែលបានចាត់ចែងធ្វើម្តងទៀត ជាលើកទី ៣ ។ សមាគមដែលបានបំពេញកិច្ចដ៏ប្រសើរដូចខាងលើនេះ ជាហេតុនាំឲ្យកើតប្រយោជន៍ច្រើនយ៉ាងគឺ:

១ - ទឹងនាំឲ្យចិត្តរបស់សិស្សដែលទើបទឹងប្រឡងជាប់ មានជ័តិជ្ញាមោដ្ឋគ្រប់រូប ហើយទឹងបានជាបច្ច័យនាំឲ្យសិស្សទាំងនោះខំអប់រំចំណេះវិជ្ជាឲ្យបានកើនចម្រើនទៅមុខទៀត ។

២ - សិស្សក្នុងសាលាគ្រប់ថ្នាក់ក្នុងបច្ចុប្បន្នទាំងក្នុងអនាគត ទឹងសង្ឃឹតនុហាតរៀនសូត្រជាកំយោភាពដោយឥតប្រហែសធ្វេស ដោយសំគាល់ដឿជាក់ក្នុងចិត្តថា ពុទ្ធបរិស័ទទាំងឡាយមានសេចក្តីជ្រះថ្លាអបអរសាទរជាច្រើន ចំពោះការរៀនសូត្រព្រះបរិយត្តិធម៌ ដោយយល់ថាការសិក្សាព្រះបរិយត្តិធម៌ជាកម្ទាំង ១ ផ្នែក ក្នុងការដឹកនាំសាធារណជនឲ្យពេញចិត្តកើតសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនាបាន ។

៣ - ទឹងបានជាទិដ្ឋានុគតិ គឺជាតម្រាប់តម្រាយជាផ្លូវសម្រាប់ពុទ្ធសាសនិកជនដើរតាមពេលក្នុងអនាគត ។

ក្នុងឱកាសដ៏ប្រសើរនេះ, សាលាចុលីជាន់ខ្ពស់ សូមព្រះពរជាន អភ័យទោស សូមព្រះពរជាឧកាសថ្លែងសេចក្តីក្រើនរំឭកប្រសិទ្ធ ចំពោះព្រះសង្ឃជាសិស្សនៃសាលាចុលីជាន់ខ្ពស់ ដើម្បីខុតជាអនុស្សាវរីយ៍របស់សិស្សត្រៅក្នុងអនាគត ។

អស់លោកជាសិស្សទាំងឡាយ !

អស់លោកដែលបានប្រឡងចេញពីសាលា ហើយបានខួលខ្លួលខ្លួលសមដូចបំណងនេះ ខុតជាចប់អស់ការណីយកិច្ចរបស់លោកគ្រប់រូប

ក្នុងសាលានេះហើយ ។ សេចក្តីសម្រេចសមតាមប្រាថ្នានេះឯង គឺជាផលនៃសេចក្តីប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការរៀនសូត្រអស់ ៤ ឆ្នាំ ដោយឥតមានប្រហែសឡេស ។ ប៉ុន្តែលោកចាំឯង្ហាយកុំភ្លេចឮសំគាល់ថា "ការសិក្សារបស់អាត្មាចប់ហើយត្រឹមបានទទួលសញ្ញាប័ត្រនេះ ហើយបោះបង់ការសិក្សាចោលលែងរវល់តទៅទៀត" ដូច្នេះឡើយ ព្រោះការសិក្សាក្នុងសាលាចំនួន ៤ ឆ្នាំនេះ គ្រាន់តែជាគ្រឹងដឹកមុខឲ្យស្គាល់ផ្លូវដែលត្រូវដើរទៅមុខទៀតប៉ុណ្ណោះទេ នៅមានការណីយកិច្ចបន្ទាប់ពីនេះទៅទៀតច្រើនណាស់ ដែលជាមធ្យោបាយសម្រាប់ធ្វើការចេះដឹងឲ្យបានពីរកំណត់ឡាយឡើង មធ្យោបាយនោះគឺការយកចិត្តទុកដាក់ក្នុងការត្រិះរិះពិនិត្យពិចារណា ស្រាវជ្រាវរកហេតុផលនៃវិជ្ជាចំពោះខ្លួនឯងតទៅទៀត ។

ម្យ៉ាងទៀត, ចំណេះវិជ្ជាដែលអស់លោកបានសិក្សារៀនសូត្របាន សម្រេចដូចប្រាថ្នាពិតមែនហើយ ប៉ុន្តែបើអស់លោកមិនគិតស្វែងរកធម៌ជាចំរ៉ៅមកជួយអប់រំ ជួយទប់ទល់ផងទេ ចំណេះវិជ្ជានោះនឹងលើកស្ទួយខ្លួនលោកឲ្យឋិតនៅក្នុងឋានៈដ៏ខ្ពង់ខ្ពស់ តួឲ្យគេគោរពរាប់អាន ក៏ពុំបានដែរ ។ សេចក្តីសំខាន់ក្នុងរឿងនេះ បានដល់អាថារសីល ពោលគឺគំនិតមារយាទប្រុសណ្តាប់ធ្នាប់ដ៏សមរម្យនោះឯង ។ អស់លោកគង់បានដឹងហើយថា មនុស្សយើងគោះបើចេះដឹងច្រើនអម្បាលម៉ានក៏ដោយ តែបើ

ខ្ញុះអាចារសីល គឺកិរិយាមារយាទដ៏ថ្លៃថ្លាហើយ មុខជានឹងទប់ខ្លួនឲ្យបិតនៅជាស្ងាត់ ឬនឹងកែខ្លួនឲ្យទៅជាមានតម្លៃថ្លៃថ្លាសមរម្យ តាមចំណេះនោះពុំបានឡើយ នឹងនាំឲ្យអាប់ឧន (ថោកថយសាបរលាប) ជាងមនុស្សសាមញ្ញទៅទៀតក៏សឹងមានដែរ ដូចពាក្យបុរាណលោកពោលទុកថា "អង្គាសសុទ្ធ ចំអិនឲ្យនៅ ពិសីហើយទៀ ត្រូវជាតតមារយាទ" ។ អាចារសីល គឺកិរិយាមារយាទ សណ្តាប់ធ្នាប់ដ៏ល្អនេះទុកជាទឹកនឹងដីជាតិ សម្រាប់ស្រោចស្រង់ចំណេះវិជ្ជា កុំឲ្យស្ងួតស្រោន ឲ្យបានលូតលាស់ជានិច្ច ឲ្យបានដុះដាលចម្រើនឡើងដោយប្រពៃ; ពុំនោះសោតទុកដូចជាកាដន៍ដ៏ធំមួន សម្រាប់ដំកល់ចំណេះវិជ្ជាឲ្យបានគង់នៅ កុំឲ្យធ្លាក់ពត់រាយក៏បាន ។ ក្នុងគម្ពីរជាតក ខុទ្ទកនិកាយលោកបានបែងទុកមកដោយការចាត់យកអាចារសីល គឺកិរិយាមារយាទជាថ្នាក់ទី ១ ថាបុគ្គលដែលនឹងតាំងខ្លួនជាមេដាបា ត្រូតត្រាគ្រប់គ្រងវង្សត្រកូលពួកក្រុម ឬសិស្សគណឲ្យបានសេចក្តីសុខក្សេមក្សាន្ត ទូលំទូលាយទៅបាននោះ គោងអាស្រ័យធម៌ ៣ ប្រការ គឺ:

១ - អាចារសីល = កិរិយាមារយាទល្អ,

២ - បញ្ញា = សេចក្តីដឹងកិច្ចការសព្វអន្ទើ ត្រូវទាំងការវែងឆ្ងៃវឆ្ងាស,

៣ - ពាហុសច្ចៈ = ការរៀនសូត្រចេះដឹងច្រើន ។

ដូច្នេះ, អស់លោកគ្រូបង្រៀនត្រូវស្ងួនភ្ងាន់ក្នុងការយោគយល់ឲ្យពេញលេញមុនទៀត គឺត្រូវហាត់ កាយ វាចា ចិត្ត ឲ្យបានចុះសៀបរបរសមរម្យ ឲ្យស្របគ្នាទៅតាមបញ្ញាធិឆ៌ាហុសច្បៈ ដែលអស់លោកបានសន្សំរួចមកហើយ នោះទើបបានឈ្មោះថាជាបណ្ឌិតជាតិ ពេញលក្ខណៈដែលអស់លោកត្រូវទទួលការៈ ធ្វើការស្នងគ្រូបានការល្អជាលំដាប់តទៅ ។

ម្យ៉ាងទៀត, ក្នុងសុន្ទរកថារបស់លោកអធិបតី នៃសមាគមមិត្តសាលាបាលីមានសេចក្តីច្រើបធ្វើបមួយអន្ទើថា "ព្រះមហាក្សត្រទុកដូចជាមហាប្រថព៌, សាលាបាលីជាន់ខ្ពស់ ទុកដូចជាព្រឹក្សាលតាជាតិ, ព្រះសង្ឃជាសិស្សទុកដូចជាបុប្ផាមានក្លិនក្រអូប. ទាយកទាយិកា ទុកដូចជាកសរជាតិគឺឃុំប្រកន្ធ ដែលតែងតែក្រេបយកលំអងកេសរនៃបុប្ផាទាំងនោះឯង" ។ ពាក្យនេះ អស់លោកទាំងអស់ក៏បានស្តាប់យល់សេចក្តីជាក់លាក់ហើយ គឺលោកជាសិស្សគ្រប់រូបទុកដូចជាផ្កាយ៉ាងវិសេសដែលបរិបូណ៌ដោយក្លិនក្រអូបនឹងលំអងកេសរ ។ តាមអត្ថបទនេះត្រូវអស់លោកទាំងឡាយ ដំកល់ខ្លួននៅក្នុងអប្បមាទធម៌ហើយទុកជាក់ខ្លួនក្នុងហានៈយ៉ាងណាឲ្យសមរម្យជាផ្កាក្រអូបប្រកបដោយលំអងកេសរ អស់កាលជានិច្ចតទៅ គ្មានបានកសរជាតិគឺខុសកខុសិកា ចូលមកប្រសំយទទួលយកខុជារសផង ។

ដូច្នេះ សុំឲ្យអស់លោកជាសិស្សគ្រប់រូប គិតហើយគិតទៀតពិចារណាហើយពិចារណាទៀត ហើយត្រូវរក៏ប្រយ័ត្នកុំឲ្យខ្លួនអស់

លោកដែលប្រៀបដូចផ្កាមានក្លិនក្រអូបក្សាយទៅជាផ្កាចារផ្កាវល្លិសដែលមានតែពណ៌ឥតក្លិននោះឡើយ ។

ក្នុងទីបំផុតនេះ សាលាចាលីជាន់ខ្ពស់ សូមទទួលភាគផលនៃការសិក្សារៀនសូត្រព្រះបរិយត្តិធម៌ដែលគិក្ខុសាមណេរបានទំបំពេញមកដោយទឹកចិត្តដ៏បរិសុទ្ធអស់កាលជាយូរឆ្នាំមកហើយនោះ ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិត សូមទ្រង់បានប្រកបដោយសិរីសុវត្ថិមង្គលគ្រប់ប្រការ សូមទ្រង់បានប្រកបដោយព្រះជន្មាយុយឺនយូរគង់ព្រះសិរីរាជសម្បត្តិអស់កាលជាអង្វែង! តាំងសម្តេច ទ្រង់ ឯកទត្តម ព្រះតេជព្រះគុណ នូវអស់លោក - អ្នក ដែលជាពុទ្ធបរិស័ទទួទៅក្នុងកិច្ចមង្គលជរដ្ឋកំសូមឲ្យបានប្រកបដោយសេចក្តីសុខ - ចំរើន អស់កាលជាអង្វែងតទៅ កុំបីអាក់ខានឡើយ! ។

ព្រះពន្ធសុន្ទរកថា

ក្នុងវិកាលពិធីប្រគេនព្រហ្មទាន

ដល់សិស្សសាលាចាលីជាន់ខ្ពស់ នៅថ្ងៃទី ២៥ ខែ កុម្ភៈ គ. ស. ១៩៥១

លោកគ្រូ!

អស់លោក!

ក្នុងឧកាសប្រគេនត្រហ្វាននេះ ខ្ញុំព្រះករុណា - ខ្ញុំ មានសេចក្តីសោមនស្សពន់ពេកណាស់ ដោយឃ្លាតមកជួយសរសើរព្រះសង្ឃជាសិស្សានុសិស្ស ដែលប្រឡងបានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ។

ខ្ញុំព្រះករុណា ខ្ញុំ ឃ្លាតដឹងថា ការរៀនយកសញ្ញាប័ត្រសាលាបរិយត្តិជាន់ខ្ពស់នេះ មិនមែនជាការងាយស្រួល គឺជាការខំអត់ធ្មត់សង្វាត ដឹងច្បាប់ខ្លួនរៀងពបដពបមកជាច្រើនឆ្នាំហើយ ទើបបានសម្រេចផល ។ ដូច្នេះ ការប្រឡងបានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់នេះ ជាការគួរឲ្យសរសើរណាស់ ។

ខ្ញុំព្រះករុណា - ខ្ញុំ សង្ឃឹមថាលោកដែលប្រឡងបានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ដែលជនទាំងឡាយតែងសំគាល់លោកជាបណ្ឌិតទៅអនាគត ដោយលោកមានចំណេះវិជ្ជាដ៏ប្រពៃ ដើម្បីនឹងយកវិជ្ជានោះធ្វើឲ្យបានផលប្រយោជន៍ខ្ទេចខ្ទីនឡើងចែមទៀត ជាប្រយោជន៍ដល់ប្រទេសជាតិ ព្រមទាំងជាការតបស្នងសងគុណដល់ពួកពុទ្ធបរិស័ទទាំងឡាយ ដែលបានជួយឧបត្ថម្ភលោករៀងមក ក្នុងការរៀនសូត្រនេះនឹងយកព្រះទ័យទុកដាក់ណែនាំសិស្សានុសិស្ស នឹងឧបាសក ឧបាសិកាក្នុងក្រុមលោករៀងរាល់ក្រុម ឲ្យបានចេះដឹងច្រើន នឹងប្រតិបត្តិកិរិយាឲ្យសមប្រកបតាមពុទ្ធសាសនោវាទ ជាប្រយោជន៍ខាងពុទ្ធចក្រនឹងអាណាចក្រតទៅ ។

ពិធីប្រគេនព្រហ្មាននេះ ជាការមួយយ៉ាងសំខាន់ នាំឲ្យបណ្តាជនានុជនច្រើនឆាប់បានស្គាល់សិស្សានុសិស្ស ដែលរៀនសូត្រមានល្បីកេរ្តិ៍ឈ្មោះ ហើយនាំសំរើបទឹកចិត្តសិស្សានុសិស្ស ដែលចាប់រៀនឡើងពីដើមឆាំកងថ្នាក់នីមួយៗ ឲ្យខំរៀនប្រជ្ញាចង់បានសញ្ញាប័ត្រផង ប្រជ្ញាចង់បានកេរ្តិ៍ឈ្មោះផង ។

ដូច្នេះខ្ញុំករុណា - ខ្ញុំ សូមអរគុណដ៏ពន្លឹកជល់អស់លោក - អ្នកដែលបានចំណាយបច្ច័យជាកម្លាំងក្នុងការរៀបចំធ្វើពិធីប្រគេនព្រហ្មាននេះជាយ៉ាងអនេក ។

លុះចប់ព្រះរាជសុន្ទរកថានេះហើយមហាជនបានទះដៃទទួល ព្រះរាជអំណរ, ទើបព្រះសង្ឃសូត្រជយន្តោនឹងមង្គលទាំងពួង ជាកិច្ចបង្ហើយបុណ្យប្រគេនព្រហ្មាននេះ ។ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងបានទ្រង់ស្តេចយាងត្រឡប់ទៅគាន់ព្រះបរមរាជវាំងវិញ ។

ចប់

ប្រយោជន៍ជាតិវែង ប្រយោជន៍ខ្លួនឃងខ្លី
មនុស្សល្ងង់ច្រើនចំប្រយោជន៍ខ្លួន
មនុស្សប្រាជ្ញច្រើនសួនប្រយោជន៍ញាតិ
ប្រយោជន៍ខ្លួនជូនផលប៉ុនអង្គជាតិ
ប្រយោជន៍ញាតិវាត់ផលធំជូលាយ ។

កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែមិថុនា លេខ ៦

ព. ស. ២៤៨៤ — គ. ស. ១៩៤១



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពុទ្ធសាសនានិងគ្រឹស្តសាសនា (សន្ទនាទី ១ លោក រ៉ាជ្ជបណ្ឌិតម៉ាក្សត៍) (តទៅ)	លោក ភ័យ - ប៊ុក	៤០៣
ពន្ធីអាស៊ីទ្វីប (តទៅ)	លោក ភ័យ - ប៊ុក	៤០៩
ពុទ្ធសាសនាសៅប៊ិទេសជប៉ុន	លោក ប៊ូ - ប៊ូ	៤១៦
សារណាកថា	លោកអាចារ្យ នង - សមិទ្ធិ	៤២៤
ផ្នែកអក្សរសាស្ត្រ		
ការបណ្តុះនិស្ស័យ (តទៅ)	ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៊ុម	៤៣២
អ៊ីឡេណា - សំម្បរីណា	លោកផេង - ដ្រីវ	៤៤២
សព្ទបាវ៉ាងប្រែជាខ្មែរ (តទៅ)	ពុទ្ធសាសនបណ្ឌិត្យ	៤៥២
រឿងសាមកុក (តទៅ)	ឧកញ៉ា ឆ្ង - ពន	៤៥៩
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តទៅ)	ឧកញ៉ា ឈឹម - ក្រសោម	៤៧៣
កំណាត់ខ្មែរបុរាណ		
បញ្ជីឈ្មោះតាមហៅអធិការដែលទើបតាំងថ្មី (តទៅ)	ក្រសួងធម្មការ	៤៧៩

ចេញផ្សាយមួយឆ្នាំមាន ១២ លេខ តម្លៃលក់ ១ លេខ ១,០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages

Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite)	M. RAY-BUC	403
La Lumière de l'Asie (suite)	M. RAY-BUC	409
Le bouddhisme au Japon	M. BOU-PO	416
SARANAKATHA	Achar NONG-SAMITH	424

PARTIE LITTERAIRE

Education morale (suite)	Préah Moha PEUNG-PAM	432
Histoire d'Hélène-Simiana	M. PHENG-CHRIEU	442
Erratum des mots traduits par la Commission Culturelle	M. MENH-NAKRY	452
Histoire de SAMKOK (suite)	Oknha NOU-KAN	459
Histoire du Royaume du Cambodge (suite	Oknha CHHIM-KRASEM	473

NOTES ET CHRONIQUES

Nomination des Chau-Athicar (suite)	Ministère des Cultes	479

Prix d'abonnement annuel comprenant 12 numéros: 145800

ពុទ្ធសាសនានិងគ្រិស្តសាសនា

សន្និសិទលោកវេជ្ជបណ្ឌិត មីគ្លូត៍

លោក ភ័យ-ប៊ុក គ្រូមការ នៅពុទ្ធសាសនបណ្ឌិត្យកុំពេញ

ប្រែពីទស្សនាវដ្តី «ហ្វ្រង់អាស៊ី» ខែមិថុនា ឆ្នាំ ១៩៤០

(តមក)

ចំណែកខាងបូតាប្រទេស, ពួកទស្សនវិទូជាគ្រូខាងសាសនាដែលមានជីវិតរស់នៅជានិរន្តរកាលចំពោះលទ្ធិរបស់ខ្លួន មានសាវកចោមរោមជាបរិវារ ដែលមានប្រាថ្នាប្រតិបត្តិតបត្តិទៅតាមលទ្ធិដែលខ្លួនបានសិក្សា ។ លទ្ធិនេះ គឺមិនមែនជាការស្វះស្វែងខាងផ្លូវប្រាជ្ញាជាធម្មតាទេ គឺជាលទ្ធិដែលមានតម្លៃត្រង់ការប្រតិបត្តិដើម្បីឲ្យសម្រេចនូវលទ្ធផល ។ តើមានផលប្រយោជន៍អ្វីត្រង់ការស្មូរថា ព្រះពុទ្ធសាសនាជាទស្សនវិជ្ជាឬជាសាសនវិជ្ជា ? ព្រះពុទ្ធសាសនាជាផ្លូវមួយ, ជាអរិយមគ្គមួយ, មគ្គដែលនាំឲ្យព្រះសម្មាសម្ពុទ្ធត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ, វិធីប្រតិបត្តិមួយដើម្បីនឹងសម្រេចឲ្យឃានលទ្ធផល មធ្យោបាយមួយដើម្បីនឹងទៅកាន់ស្ថានរំលត់ទុក្ខទាំងពួង ដោយបំពេញកិច្ចការខាងផ្លូវធម៌ ព្យាយាមយ៉ាងម៉ឺងម៉ាត់ ។

ដែលនាំឲ្យយល់ថា ព្រះសម្មាសម្ពុទ្ធជាអ្នកមិច្ឆាទិដ្ឋិចំពោះអាទិទេព (Atbée) ដោយហេតុថា ព្រះអង្គទ្រង់មិនដែលបានវិសជ្ជនាទៅកាន់សាវក

ដែលមានពាក្យបុច្ឆាទៅកាន់ព្រះអង្គ អំពីដើមកំណើតនៃពិភពលោក, ធម្មជាតិនៃអាទិទេព, សភាពដែលមានជីវិតរស់នៅក្នុងស្ថានព្រះនិព្វាន ។ គឺមិនមែនថាព្រះអង្គមិនជ្រាបច្បាស់នូវបញ្ហាទាំងនោះទេ តែដោយព្រះអង្គទ្រង់បានត្រាស់សម្ងាសម្ពោធិញ្ញាណ ទ្រង់បានយល់ច្បាស់នូវធម្មជាតិនៃវត្តទាំងអស់គ្មានសេសសល់ តែទ្រង់ព្រះតម្រិះថាការសិក្សាចំពោះវិជ្ជាទាំងនេះ មិនជាប្រយោជន៍ មិនអាចនាំសត្វលោកឲ្យចាកចេញពីសេចក្តីទុក្ខបានឡើយ ។ ព្រះអង្គមិនមែនទូន្មានសត្វឲ្យរៀនសូត្រនូវកម្មវត្តនៃវិជ្ជាទាំងនោះ តែទ្រង់ឲ្យរំរេកមធ្យោបាយ ដើម្បីនឹងដំណើរការឲ្យសម្រេចដល់នូវវិជ្ជានោះគឺមគ្គសច្ច, ដោយទ្រង់ព្រះយោបល់ថាមគ្គសច្ចនេះ អាចបង្ហាញឲ្យពួកសាវកដោះស្រាយនូវបញ្ហាទាំងលើឲ្យបានសព្វគ្រប់ ។

ព្រះសម្ងាសម្ពុទ្ធទ្រង់មានព្រះបន្ទូលជាញឹកញយអំពីអាទិទេពដែលប្រទេសឥណ្ឌាបាននិយមគោរពកុងកាលនោះ; ព្រះអង្គទ្រង់យល់ថាជាទេវតាជាន់ខ្ពស់ស្ថិតនៅនាស្ថានដ៏ឧត្តម តែត្រូវនៅក្នុងអំណាចនៃអនិច្ចតាធម៌ទើងកម្ចាត់ចេញមិនបាន ។ ហេតុម្តេចក៏បានជាសូមពរញឹកញយអំពីអាទិទេពមួយដែលស្ថិតនៅក្រៅពិភពលោក ហើយអាទិទេពនេះថាជាអ្នកមេបង្កើតនូវលោកដែលមានសភាពទេ ថាមិនមែនកើតមកពីទេទេ ? (គឺថាវត្តទាំងអស់មិនដែលកើតមកឯង ។ ទេ តែវត្តុ

ដែលមានមកក្នុងលោក គឺមានមកពីអតីតកាលយូរណាស់មកហើយ ex-nihilis) ។ យើងមិនអាចដឹងបានឡើយពីហេតុនៃលោក; ការស្វែងរកឬស្រាវជ្រាវនូវបញ្ហានេះជាការឥតប្រយោជន៍, មិនអាចនឹងជួយយើងឲ្យបានសម្រេចទៅតាមវត្ថុបំណងរបស់យើងឡើយ កិច្ចដែលត្រូវធ្វើគឺការតស៊ូនឹងទុក្ខ, ការចេញចាកទុក្ខ នឹងការដែលមានប្រាជ្ញាក្លឹស្វាង (សម្រេចនូវធម៌ដ៏ប្រពៃ) ។

តែនៅចាំងពីខាងក្រោយអហេតុកលទ្ធិ (ធម៌ជាអហេតុក : ជនសាមំញ្ញមិនអាចយល់បាន, agnosticisme) ដែលគេច្រើនពោលថា ជាលក្ខណៈនៃព្រះពុទ្ធសាសនា នៅមានគំនិតមួយទៀតមានអត្ថដ៏សុខុម-គម្ភីរភាព ដែលពួកអ្នកនិពន្ធខាងបច្ចិមប្រទេសមិនបានដឹង ប្តូរបំភ្លេចចោលជាអសារបង់ ។ យើងមិនត្រូវភ្លេចទេ ថាព្រះពុទ្ធសាសនាកើតឡើងហើយ, ចំរើនវ័យរុឌ្ឍនាការជាលំដាប់រស់នៅក្នុងរស្មីប្រាជ្ញានៃគម្ពីរឧបនិស័ទ (Upanishad) ដែលជាគម្ពីរប្រកបដោយអច្ឆរិយភាព ពណ៌នាអំពីចិន្តាខាងព្រហ្មញ្ញសាសនា បើកទ្វារវិបស្សនាបញ្ញាឲ្យក្លឹស្វាងយល់ធម៌បាន ។ គម្ពីរនេះមានគុណសម្បត្តិជាអនេកប្បការ ដោយបានប្រមូលនូវសញ្ញាណដែលស្ថិតនៅពត់ពយតាមគម្ពីរវេទ មកដំកល់ទុកជាវិធីប្រតិបត្តិ គឺយល់ថាមានអហេតុកធាតុ (Absolu) មានសភាពឧត្តមផុតហួសនិស្ស័យនឹងដឹងបាន ហើយជាសច្ចធម៌មួយឯកឯង ។ ប្រជាក្លឹស្តូ

នីមួយៗ គោរពទេវតាតែរៀងៗ ខ្លួនដែលមានទេវលក្ខណៈប្រកបដោយ
គុណសម្បត្តិ នឹងបាបធម៌ដូចមនុស្សជាតិ (Anthropomorphiques)
ដែលមានសភាពស្របគ្នានឹងគតិជាតិនៃនានាប្រទេស ។ ដូចជាទេវតានៃ
ប្រទេសឥណ្ឌា ឬអាទិទេពនៃប្រទេសអ៊ីស្រាអែល (Israël) អាទិទេព
មានទេវចរិយាដូចជាតិជ្វីហ្វ (Juif) ដែលមានកិច្ចត្រៃដំណួយការពារប្រជា-
ករស្តេ, បំផ្លាញបច្ចាមិត្តហើយមានបាបធម៌ដូចមនុស្សសាមញ្ញ អាទិទេព
មានចរិយាឫស្សាពេញចិត្តខាងការទទួលនូវសក្ការបូជា ឬពលិកម្ម. ខាង
ព្យាបាទនឹងធ្វើទណ្ឌកម្មចំពោះអ្នកដែលមិនប្រតិបត្តិតាម ។ តែចំពោះ
ផែនការណ៍ខាងមនុស្សជាតិពីលើអាទិទេពទាំងនោះ មានអហេតុកជាតុ
ប្រកបដោយរិមុត្តិសុខគ្មានលក្ខខ័ណ្ឌ, ឯកភាព, គ្មានសភាពផ្សេងគ្នាដែល
មានរូបបដិមាករប្រតិស្ឋានជាអាទិទេព ទុកសម្រាប់ឲ្យជនជាតិគោរព ;
អាទិទេពបដិមាករនេះ គឺជារូបដែលកើតឡើងដោយសភាពឯកទេស ឬ
ជាតុកភាពប្រកបដោយមនោសញ្ចេតនាវចនាជាបុគ្គលាធិដ្ឋាន ។

ព្រះពុទ្ធសាសនាក៏ជាបច្ចាស់នូវអហេតុកជាតុនោះដែរ ។
អហេតុកជាតុនេះ មានសំដែងទុកនៅក្នុងគម្ពីរព្រះនិយបិដកខាងហីន-
យាន, តែព្រះសារីបុត្តជាមហាសាវ័កនៃព្រះសម្មាសម្ពុទ្ធលោកបានទេស-
នាចំពោះព្រះកិកុសង្ឃថា : "ម្នាលអាវុសោទាំងឡាយ គេតែងឃើញ
មានសភាពមួយដែលគ្មានកើត, គ្មានចំរើន, គ្មានស្ថាបនា, គ្មានទម្រង់ ;

ម្នាលអាវុសោទាំងឡាយ បើគ្មានធាតុអ្វីដែលមានសភាពគ្មានកើត គ្មានចំរើន គ្មានស្ថាបនា គ្មានទម្រង់ទេ, ឆ្លៀវឆ្លាសចេញចាកសភាពកើត, ចម្រើន, ស្ថាបនា, ទម្រង់ ក៏គ្មានដែរ" ។

សញ្ញាណនៃអហេតុកធាតុនេះ បានចម្រើនជាកិរិយាភាពឡើងជាលំដាប់ចំពោះការវិវត្តន៍ខាងព្រះពុទ្ធសាសនា រហូតដល់សុក្រិតភាពផ្នែកខាងពុទ្ធសាសនាមហាយាន ។ គឺចំពោះគណៈមហាយាន "យោគសារៈ" ដែលពាក្យអហេតុកធាតុទៅជាបញ្ហាមួយ ដែលនាំមកប្រុច្ឆាវិសជ្ជនាជាធម្មិបវមេត្តេ មានអត្ថដ៏សុខុមគម្ភីរភាព តាមន័យប្រកបដោយចិន្តាដ៏ខ្ពស់បំផុត មិនអាចមានលោកអ្នកប្រាជ្ញណា ពោលពីអហេតុកធាតុឲ្យមានអត្ថដ៏ជ្រាលជ្រៅជាងពួកគណៈនេះទៀតឡើយ ។

ចំណែកពួកបច្ចិមប្រទេសមិនបានជ្រាបច្បាស់នូវអត្ថដ៏សុខុមខាងធម្មិបវមេត្តេនៃព្រះពុទ្ធសាសនា ជ្រាបបានតែលក្ខណៈប្រកបដោយវិចារណញ្ញាណខាងព្រះវិនៃបិដកជាភាសាបាលី ដោយហេតុថាពួកនោះយល់បានតែសភាពកក់ស្ពុចស្ពើង ដែលពណ៌នាកងគម្ពីរខាងលើនេះ ។ ការយល់ខុសប្រែបនេះមានចំពោះតែពួកបច្ចិមប្រទេស ដែលនិយមសិក្សាព្រះពុទ្ធសាសនាទៅតាមសម័យថ្មី ហើយបានយកគំនិតដែលគេអាចតាំងជាបញ្ហាប្រុច្ឆាវិសជ្ជនាទៅជាវិធានការ កំណត់ទុកថាជាសម្ភាមតិតែមួយឯកឯង ។ ពួកខាងបូណប្រទេសតែងយល់នូវសភាវៈអ្វីៗ បានឆ្ងាយវែងទូលាយជាង

ពួកបច្ចិមប្រទេស ហើយមិនសូវមានយោបល់ចំទាស់ចំពោះសញ្ញាណនៃ
ពុទ្ធសាសនាខាងហីនយាន និងមហាយាន មិនដូចពួកខាងបច្ចិមប្រទេស
ច្រើនតែពោលទំនាស់ចំពោះបញ្ហាខាងសាសនា ។ ពួកខាងមហាយាន
យល់ថា គម្ពីរបាលីជាគម្ពីរប្រកបដោយសម្មាមតិដ៏វិសេស ហើយអនុម័ត
បញ្ចូលគម្ពីរនេះទៅក្នុងគម្ពីរនៃលទ្ធិរបស់ខ្លួន; ពួកនេះគិតថាការពន្យល់នូវ
ព្រះបរមពុទ្ធោវាទថាគម្ពីរបាលីដែលមានសភាពតែមួយយ៉ាងគឺ អន្តេការ:
(Exotèrique) ។ ព្រះសម្មាសម្ពុទ្ធទ្រង់មិនដែលទេសនាជាពាក្យទ្វិស្តែ
ទ្រង់ច្រើននិយមប្រែទម្រង់ប្រកបដោយមនោសញ្ចេតនាតម្រង់បញ្ចូល
ទៅហារណ៍ផ្សេងៗ តាមប្រពៃណីនៃប្រទេសឥណ្ឌា ។ តមក, មានធម៌
ខ្លះដែលព្រះអង្គទ្រង់មិនបានសំដែង, ហើយ បើតាមព្រះពុទ្ធដីកាថា
ជាធម៌មានសារ: ប្រយោជន៍ ជាធម៌ដែលព្រះអង្គទ្រង់ទេសនានោះទៅ
ទៀត ។ ជាតិនីមួយៗ បានយកវិជ្ជាដែលព្រះអង្គមិនបានសំដែងទៅរចនា
ដោយស្នាមសព្វៗខ្លួន ហើយបានយកពុទ្ធោវាទទៅនិយមប្រែតាមប្រ-
ពៃណីអស់ហើយ បើតាមវិចារណញ្ញាណ មិនត្រូវបដិសេធនូវប្រពៃណី
នោះទេឬយ ។ ពាក្យថា "ពុទ្ធសាសនា" នេះគ្រាន់តែជាពាក្យ
ប៉ុណ្ណោះ ។ បើតាមពិត, ពួកពុទ្ធសាសនិកជនមានជាច្រើន ហើយ
ក្នុងពុទ្ធសាសនិកជនម្នាក់ៗ តែងនិយមប្រតិបត្តិតាមព្រះពុទ្ធសាសនារបស់
ជាតិមានសភាពប្លែកៗគ្នា ។

(អាគត)

វគ្គទី ៦

La Lumière de l'Asie

លោក ស៊ីរ-អេតវ៉ាន អាណូលត៍ តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

ត(មក)

តមក, មានភគ:ខាងកិត្តិគុណ គឺ **អរូបរាគ:** *ដែលមានលក្ខណ:ជា អតិជនភាព ហើយមានលំអអាចបំភ័ន្តគំនិតពួកបណ្ឌិតបាន, ជាមាតានៃ កម្មិកភាពប្រកបដោយវិសារទ:, ពេញចិត្តខាងសង្គ្រាម, ខាងការ ខ្មឿយហត់ ។ រួចទើប* **មាជ្ញោ** *មកដល់ដែលមានសភាពក្រអឺតក្រទម ជាបិសាចខាងអំនួត; ហើយតមក មានសភាពដែលពេញចិត្តចំពោះខ្លួន ខាងវាចាបញ្ញោះគឺ ទុច្ចរិត: មានពួកតាលរូបអាក្រក់ពន់ពេក:ចាមពេមជា បរិវ៉ារខ្លះ លួនខ្លះ ហើរដូចជាសត្វគីឡក់ខ្លះប្រចៀវខ្លះ ។ ក្រៅពីនោះ, មានសេចក្តីលង់ជាមេខាងខ្វាចចំពោះអយុត្តិធម៌ គឺ* **អវិជ្ជា**[1] *ជាមេអាប គួរឲ្យខ្ពើមរអើមពន់ពេក ។ អវិជ្ជាមកដល់ធ្វើឲ្យកាន់តែងងឹតខ្លាំង ចំណែកខាងគិរីតាំងប៉ុន្មានរំជួលដល់ចាត់ក្រែម ព្យុះសង្ឃរាបកបោក*

---

១ អវិជ្ជាមានន័យថា លង្ងលុះភ័ន្តច្រឡំ ។ "អវិជ្ជា" បើតាមអ្នកប្រាជ្ញតាមលោកកូឡឺ ប្រុក (Colebrook) ថាគឺសភាវប្រមាទដែលយល់ថា វត្ថុមិនស្ថិតថេរ ថាស្ថិតថេរ:ទាំងឿ ។

ស្រែកសរសើរជាខ្លាំង, ពពកធ្លាយភ្លៀងធ្លាក់មកយ៉ាងធំអស្ចារ្យ; តារាធ្លាក់ចុះពីនភាល័យ, ព្រះឆវណីញ័រកម្រើកសព្វកន្លែងដូចជាគេយកភ្លើងទៅដុតដំបៅធំរបស់វាដូច្នោះ; នៅលើអាកាសងងឹត មានផ្លេកបន្ទោរភ្លឺជាលរាលាសពេញ ហើយមានសូរសព្ទស្ទាបហ៊ោឮសូរសៀងបែបហួប, ពាក្យគោលគឹកកងរំពង, សម្រែកលួចេញពីមុខពាលទុច្ចរិតចក្រក្បែតក្រឡេកមើលមកមានថ្ងាសធំសម្បើមអស្ចារ្យគួរឲ្យខ្លាច ហើយមានពួកយមរាជ ទ្រង់ទ្រាយមាំក្រអាញនៅស្ថាននរកចាកចេញពីព្រះរាជនិវេសនដ្ឋានផ្សែង។ ឋានទាំកងពលយោធាជាច្រើនមកតស៊ូនឹងព្រះបរមពោធិសត្ត ។ តែព្រះបរមពោធិសត្តទ្រង់ឥតមានព្រះទ័យញាប់ញ័រសោះឡើយ ទ្រង់គង់ជាសូប់ដោយមានទសបារមីធម៌ជាអាវុធ ប្រៀបដូចជាទីក្រុងធំ ដែលមានក្លោងទ្វារទឹងកំពែងការពារយ៉ាងមាំមួនដូច្នោះ; ហើយរុក្ខជាតិពិសិដ្ឋ (L'arbre Sacré) គឺព្រះពោធិព្រឹក្សនៅកណ្តាលព្យុះសង្ឃរានោះ ក៏ឥតមានកម្រើកសោះឡើយ, ហើយមានសន្ធឹកភ្លឺស្វាងរុងរឿង ស្ថិតនៅស្ងៀមស្ងាត់ ដូចជាពេលដែលព្រះចន្ទខាងសុក្កបក្ខកន្ត សាយណ្ហសម័យ គ្មានព្រះពាយុធ្វើឲ្យផ្ទុះពីអជ្ឈាសន្ទូវឹកសន្ធឹម មានសភាពភ្លឺចាំងចែងដូចជាឰដ៏មុត្តា; ហើយពាក្យសូរសំឡេងលាន់រំពងនោះឮកាន់តែធ្លាយទៅខាងត្រៃមូលសាខានៃអជ្ឈាសនិត្រាជ ។

ដល់យាមទីបី, ព្រះឆវណីក៏សូប់ស្ងៀម, ពួកសេនាមារក៏ហោះហើរទៅលើអាកាសបាត់ ហើយព្រះពាយុបក់រំពើយៗត្រាមព្រះចន្ទដែល

មានពពកចាំងបាត់ ។ កន្លងពេលនោះ ព្រះបរមពោធិសត្វក៏បានត្រាស់ជា
ព្រះសម្មាសម្ពុទ្ធ; ព្រះអង្គបានជ្រាបច្បាស់នូវដីវភាពដែលស្ថិតនៅក្នុងឆកតព
គាំងអស់ ព្រមទាំងហេតុប្បច្ច័យ ហើយដឹងភាពនៃសត្វលោកនេះ មាន
ចំនួនចុះរយហាសិប ដោយព្រះប្រាជ្ញាដែលមានសភាពក្លឹស្វាងចាំងចែង
ពីលើជាតិសត្វលោក ដែលស្ថិតនៅក្នុងអនិច្ចតាធម៌ ។ ប្រៀបដូចអ្នក
ដំណើរម្នាក់ដែលបានទៅដល់កំពូលភ្នំមួយ ហើយក្រឡេកមើលមកខាង
ផ្លូវដើរ មានសភាពវៀចកោងបត់បែន ដែលខ្លួនទើបនឹងដើរមកអម្បាញ់-
មិញនេះ ឃើញគុហាជ្រលងភ្នំ, គុម្ពោតព្រៃដែលមើលពីចម្ងាយដូចជា
វត្តខ្មៅមួយដុំ, ថ្កុតបឹងមានទឹកភ្លឺពណិខៀវបៃបចចង់បំភ័ន្តគំនិតអ្នកមើល
ហើយនឹងដង្កូកជាច្រើនដែលបានឆ្លងរួចមកហើយ, ហាត់ឡើយដិតផុត
ខ្យល់អស្សាសៈ បស្សាសៈ, កំពូលភ្នំខ្ពស់គួរឲ្យស្ញើបពន់ពេក ដែលខ្លួន
ព្យាយាមឡើងមកមានចិត្តអិលដិតជ្រាក់, ខាងក្រោមឃើញវាលមាន
ព្រះសុរិយាចាំងចែងរស្មីភ្លឺ, ជ្រោះ, រអាងនឹងបឹង, ហើយឆ្ងាយជាប់
ភ្នែកក្តៅ, មានវាលដែលទំនាប់ដើរកាត់ពីបឋមមកគាល់តែមកដល់
កំពូលគីរី ដែលមានពពកខៀវផ្ទៃមេឃអណ្តែតពីលើនាល៍យានេះជា-
បរិយោសាន ។ ឯព្រះសម្មាសម្ពុទ្ធដែលព្រះអង្គបានត្រាស់ហើយ ទ្រង់ក៏
ពិចារណានូវវដ្តសង្សារគឺខ្សែដីវភាពដែលត ។ គ្នាពីមុនមក តាំងពីវាល
ទំនាបដែលដីវភាពមានលក្ខណៈជានិមិត្តកៈ រហូតមកដល់ទីស្ថានកាន់តែ

ខ្ពស់ ។ ល្អើង ដែលថាមើលមិនាំងដប់រង់ចាំអ្នកដំណើរដើម្បីនឹងទទួលធ្វើជាមគ្គុទ្ទេសក៍ នាំទៅកាន់មហាមេឃជាអវសាន ។ ព្រះសម្ពុទ្ធបានជ្រាបច្បាស់ថា ជីវភាពថ្មីត្រូវប្រែតកាត់នូវជីវភាពអតីតដែលសាបព្រោះ, ថាក្រោយដែលបានឈប់សម្រាកមួយស្របក់ ជីវភាព៌នោះក៏ត្រាច់តទៅទៀត, រក្សាទុកនូវផលបុណ្យដែលបានធ្វើរួចមកហើយយកទៅផ្តល់ផ្តើនឹងជាបពីអតីត ;; ថាយ៉ាងដូចម្តេចកង៌ជីវភាពនៃសត្វនីមួយៗ បុណ្យដែលធ្វើឲ្យចំរើនខាងបុណ្យ, ជាបដែលធ្វើនាំឲ្យកើតជាបជាថ្មី; ព្រោះមរណភាពគ្រាន់តែបញ្ឈប់គណនីនៃជ្រាក់ចំណាយ (ជាប) នឹងជ្រាក់ចំណូល (បុណ្យ) ហើយតាមវិធីលេខនព្វន្តត្រឹមត្រូវជាអស្ចារ្យ, ជានបូកវួមហើយលើកនូវបុណ្យនឹងជាបដែលចោះពុំម្តងប់ពិត ជ្រាត្យ័ក្សតមានភ័ន្តច្រឡំយកទៅបញ្ចូលនឹងជីវភាពថ្មី ដែលធ្វើដំណើរជាបបមតៗទៅទៀត. ហើយដែលប្រមូលរួបរួមហើយបុះគណនីអំពីបិន្ដានឹងកម្មកភាពអតីត, សង្គ្រាមព្រមទាំងជោគជ័យ, និស្ស័យ, នឹង៌ាសនាពីអតីតជាតិ ។

ហើយកង៌ពេលអធ្រាត្រ, ព្រះទ័យនៃព្រះបរមពោធិសត្វ ជានល្អើងដល់អភិញ្ញា ដែលជាញាណក្នុងស្មារុងរឿងជាអស្ចារ្យ អាចជ្រាបច្បាស់នូវធម៌ទាំងអស់, ភព, លោកនេះនឹងលោកកុត្តរភព, ហួងតារាផ្សេង ។, ព្រះសុរិយានឹងលោកធាតុជាច្រើនមិនអាចនឹងគណនាបានដែលវិលទៅតាមវិធីត្រឹមត្រង់តមានខ្ចោះ ប្រកបដោយអច្ឆរិយភាពទៅ

តាមក្រុមរួបរួមគ្នា តែមានលក្ខណៈផ្សេងពីគ្នា ហើយមានសមាសភាព
មួលចូលតែមួយឯកឯង ពិតមែនតែដោយឡែកៗ ពីគ្នា ។ លោកធាតុ
ទាំងនេះជាកោះប្រាក់នៃមហាសាគរ មានពណ៌ខៀវផ្ទៃមេឃ, គ្មាន
ត្រើយ, គេមិនអាចយល់ឃើញ ដែលមានទឹកមិនចេះស្រកស្រុត ហើយ
មានរលកបោកបក់ចូលទៅក្នុងទឹកដោយនាចនៃអនិច្ចតាធម៌ជានិរន្តរកាល ។
ព្រះអនាវរណញ្ញាណឃើញឥតយល់ច្បាស់ ន្ទូវព្រះអាកាសដែលមានព្រះ-
ពជគមនាគមន៍ ប្រកបដោយអទស្សនីយភាពដ៏សុខុមចំពោះបរិវារជាច្រើន
ដែលវិលជុំវិញខ្លួនឯង ព្រមទាំងចក្រវាឡមានវិត្ថារនុភាព ដែលនៅ
ក្រោមព្រះបញ្ជានៃហ្វូងតារាឯទៀត ឃើញជាតារាមួយផ្ទេរទៅតារាមួយ
ទៀតនូវរស្មីដ៏រាកាដែលកើតពីទឹកណ្តាល រំលេចកាន់វណ្តមណ្ឌលប្រ-
ប្រកបដោយអនន្តមាត្រ (infini) នេះហើយដែលញាណព្រះសម្មាសម្ពុទ្ធ
ឃើញជាក់ច្បាស់ដោយព្រះប្រាជ្ញាចក្ខុ ព្រមទាំងមណ្ឌលធំតូចនៃ
ចក្រវាឡទាំងឡាយ នឹងគណនានៃកប្ប[1] នឹងមហាកប្ប ដែលជា
កាលវិធី (mesure du temps) ឥតមានអ្នកណាកំណត់ ឬអាចយល់ឃើញ
ដែលគេហៅថាកាលសម្រាប់លោកដែលចំរើន វិនាស (បើច្រឡំនិងជា
អ្នកណាមួយអាចរាប់ដំណក់ទឹកក្នុងស្ទឹងគង្គា ពីប្រភពហូរដល់សមុទ្រ

---

១ កប្ប គឺមួយថ្ងៃក្នុងស្ថានព្រហ្មតុរដា ៤-៣២០ លានឆ្នាំមនុស្សដល់បុងកប្បមួយ។
លោកនេះត្រូវលោយចូលទៅនឹងអាទិទេវនិមិ (divinité) ។

ជាន) ដែលមានសត្វលោកនៅក្នុងមហាមេរុយជានបំពេញការណ៍យកចិត្ត
ដ៏ប្រសើរបួចបុះអាប់អោនរហូតដល់មរណភាពជាអវសាន, ពីសតវត្ស
មួយទៅសតវត្សមួយ ។ ព្រះបរមគ្រូជាម្ចាស់ក៏ជានខតយល់ឮដំណើនឆ
កំពូលចំពោះអនន្តមាត្រ ដែលមានពណ៌ខៀវឆ្អែមេរុយ ហើយជានពិនិត្យ
គ្រប់បៃបយ៉ាង គ្រប់លោកធាតុទាំងមូល នឹងអនន្តចក្រវាឡ ព្រមទាំង
ចលនានៃចក្រវាឡនីមួយ ។ ដែលមានចំហាយផ្សាយភ្លើចេញ; ច្បាប់
មានសភាពមិនប្រែប្រួល ព្យាយាមប្រតិបត្តិដោយសូប់សាត់ ដែលមាន
ឆន្ទៈចង់ឲ្យស្រមោលវិត្តន៍ទៅកាន់ពន្លឺ, មរណៈទៅកាន់ជីវៈ បំពេញ
ធម្មធាតុដែលមានប្រហោង, ប្រឡោះ (អាកាស), រចនាឲ្យមានទម្រង់,
ធាតុណាដែលគ្មាន, ប្រែសភាពល្អទៅកាន់សោភ័ណ, ពីសោភ័ណ
ទៅកាន់សុក្រិត, ដោយមានបង្គាប់ប្រកបដោយសន្តិ, ដែលគ្មានបុគ្គល
ណាចាត់ចែងរៀបចំ តែគ្មានបុគ្គលណាអាចដំនាស់នឹងសេចក្តីបង្គាប់
នោះបាន, ព្រោះច្បាប់នោះស្ថិតនៅខ្ពស់លើពួកសត្វបុគ្គល ឬ ព្រះវិណា-
ស្រពទៅទៀត ច្បាប់នោះ ជានិច្ចតាភាព (immuable) អចិន្ត្រេយ្យភាព
(ineffable) ព្រមទាំងឧត្តមភាព គឺជាអំណាចអស្ចារ្យមួយដែលប្រតិស្ថាន
កើតឡើង, ឆ្លើឲ្យវិនាស, បង្កើតជាថ្មីឡើងទៀត, ត្រួតត្រាធម្មជាតិទាំង
អស់តាមវិធានការខាងគុណធម៌ដែលប្រមូលមកឲ្យតាមចាស្អ ពិតហើយ
មានប្រយោជន៍ ដោយយល់ថា អ្នកណាចូលទៅបម្រើអំណាចនោះ

ដោយចិត្តស្មោះស្ម័គ្រ គេទុកជាល្អ, រីឯអ្វីដែលដំណាស់ក្នុងការបម្រើនេះ គេទុកជាអាក្រក់: ព្រោះហេតុដូចនេះ ឯឆ្កែដែលប្រតិបត្តិការទៅតាមធម្មជាតិរបស់ខ្លួន ប្រពឹត្តល្អ, បក្សាស្វាំងដែលនាំយកអំពាដែលប្រឡាក់ដោយលោហិតទៅឲ្យកូនបរិភោគ ប្រពឹត្តល្អ, ដំណាក់ទឹកសន្សែមនឹងតាពដែលមានស្មៅ ចាំងភ្លឺដូចគ្នាហើយធ្វើសហការជួយទ្រទ្រង់កិច្ចនៃលោកធាតុ ហើយមនុស្សជាតិដែលរស់នៅហើយ ធ្វើមរណភាពទៅវិញ, ស្លាប់ព្រោះទុគ្គមហេតុ. បើមនុស្សទាំងនោះបម្រុងប្រពឹត្តទៅតាមសីលធម៌ហើយនឹងធន្ទ: ដ៏ម៉ាំមួនមិនត្រឹមតែជួយទ្រទ្រង់គ្នាទៅវិញទៅមក ថែមទាំងមិនប្រពឹត្តអកុសលកិច្ចត្រង់ការឃាត់ហាមមិនឲ្យសត្វលោកតូចធំដែលរងទុក្ខក្នុងវដ្តសង្សារ មិនឲ្យវិវត្តន៍ចំរើនទៅបាន ។

តែដល់មកយាមទីបួន ព្រះសម្មាសម្ពុទ្ធបានជ្រាបច្បាស់នូវហេតុដែលនាំឲ្យកើតទុក្ខ. ទុក្ខដែលរួបរួមនឹងបាបអកុសលកំងរមិនឲ្យប្រាប់ប្រពឹត្តទៅតាមធម៌ ប្រៀបដូចជាផ្សែងនឹងអាចម៍ដែកសន្ធប់ភ្លើងដែលនាយសុវណ្ណការបានដុត ។ ព្រះអង្គទ្រង់ទតឃើញនូវទុក្ខសច្ច ដែលជាអរិយសច្ចទី ๑ ហើយយល់ថាទុក្ខជាស្រមោលនៃជីវភាព ជាធម៌មានហេតុមានបច្ច័យទាក់ទងគ្នានឹងជីវភាពនេះ ហើយគេអាចបោះបង់ចោលនូវទុក្ខនេះបាន លុះត្រាតែផុតរលត់ជីវិត ព្រមទាំងរលាយនូវសភាពផ្សែងៗរបស់ជីវភាព គឺ: បដិសន្ធិ វុឌ្ឍិធម៌ ជរ ស្នេហា បដិយ: តាមច្ចន្ត: ទុក្ខ សត្វ នឹងកម្មកាព ។ (មានត)

ពុទ្ធសាសនានៅប្រទេសជប៉ុន

កាលសម័យអតីតនិងសម័យបច្ចុប្បន្ន

ឃុនបណ្ឌាធរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

ស្រង់ចេញពីប្បាបធម្មចក្ក ភាសាខ្មែរ របស់ក្រសួងពុទ្ធសាសនបណ្ឌិត្យកម្ពុជា

លេខ ម. ៤២៣ / ១ ទំព័រ ៨៣១ - ៨៣៧

គ្រប់ៗប្រទេសក្នុងលោក គោរសម័យណាក៏ដោយ សុទ្ធតែមានសាសនាជាគ្រឿងចង្អុលផ្លូវ ឲ្យប្រទេសមានដំណើរឈានលៀនទៅមុខជាធម្មតា ពពួកជនរបស់ប្រទេស ខ្វះការរាប់អានកាន់សាសនាមិនបានឡើយ ។ បើប្រទេសណាគ្មានសាសនាហើយ ប្រទេសនោះក៏គ្មានសេចក្តីសុខសប្បាយនឹងគ្មានអារ្យធម៌ ។ សាសនាមិនមែនគ្រាន់តែជាគ្រឿងជម្រះសេចក្តីអាក្រក់របស់មនុស្សប៉ុណ្ណោះទេ អាចជាគ្រឿងដឹកនាំអារ្យធម៌ឲ្យចូលមកកាន់ប្រទេសនឹងប្រជាជនទៀតផង សាសនាចាត់ថាជាគោលសំខាន់មួយយ៉ាងក្នុងផ្លូវជាទីកើតអារ្យធម៌ ។ គ្រប់សាសនាដែលកើតឡើងក្នុងប្រទេសខ្លួនក្តី ផ្សាយពីប្រទេសដទៃចូលមកក្តី សុទ្ធតែមានពន្លឺរស្មីនៃអារ្យធម៌នឹងវឌ្ឍនធម៌ជាប់តាមបំភ្លឺមកផងជាជាងប្រ ខុសគ្នាតែចំនួនច្រើនឬតិចប៉ុណ្ណោះ ។

កាលប្រទេសជប៉ុន អ្នកប្រាជ្ញខាងឆ្លាយនាំគ្នាសន្និដ្ឋានថាសាសនាជាគ្រឿងចង្អុលប្រាប់អារ្យធម៌យ៉ាងល្អ បើនិយាយថាជាតិជប៉ុនបានចំរើនរុងរឿងឡើងព្រោះតែសាសនាក៏មិនខុស រាប់តាំងពីសម័យព្រៃ

នាយរហូតមកដល់សព្វថ្ងៃនេះក៏ដូចគ្នា សាសនាជាករណីយកិច្ចរបស់ជាតិយ៉ាងសំខាន់បំផុត ។ តោលចំពោះសាសនាដែលសំខាន់បំផុតរបស់ជាតិជប៉ុន មាន ២ យ៉ាងគឺ សាសនាជិនតោ ១ សាសនាពុទ្ធៈ ១ ។ សាសនាទាំង ២ នេះ មានប្រាកដនៅក្នុងប្រទេសជប៉ុនជាយូរអង្វែងមកហើយ ប្រជាជនក៏មានសេចក្តីនិយមរាប់អានសាសនាទាំង ២ នេះដោយច្រើន ។ មានសាសនា ២ ទៀត គឺលទ្ធិខុងជូ ១ សាសនាគ្រិស្ត ១ ទាំង ២ នេះមិនមែនជារបស់សំខាន់នៃជាតិជប៉ុនទេ ប្រជាជនក៏មិនសូវនិយមរាប់អានឡើយ ។ បណ្តាជនជប៉ុនមានសេចក្តីនិយមរាប់អានក្នុងលទ្ធិសាសនាផ្សេងៗគ្នា, អ្នកណាមានសេចក្តីជឿក្នុងសាសនាណា ក៏បែរទៅកាន់ផ្លូវសាសនានោះទៅតាមគំនិតរៀងខ្លួន ។ ព្រោះតែការយល់ឃើញខុសគ្នាដូច្នេះហើយ បានជាបណ្តាលឲ្យកើតការស្អប់ខ្ពើមគ្នាខ្លះក៏មាន ។ សាសនាជិនតោនឹងសាសនាពុទ្ធៈ មានសេចក្តីចំរើនប្រហែលគ្នា ជាគូប្រណាំងប្រជែងគ្នាអស់រៀលយូរមកហើយទាំងកើតមកជាប់គ្នា ។ ដូច្នេះ ខ្ញុំនឹងនាំមកពោលរួមគ្នាក្នុងទីនេះតែម្តង ដើម្បីឲ្យឃើញថា សាសនាទាំងពីរនេះជាប់ទាក់ទងគ្នាដូចម្តេច ។

ដើមដំបូង ប្រជាជនជប៉ុននាំគ្នានិយមរាប់អានកាន់សាសនាជិនតោជាចំនួនច្រើន, ទើលុះខាងក្រោយសាសនាពុទ្ធៈបានចំរើនផ្សាយចូលទៅក្នុងប្រទេសជប៉ុន ប្រជាជនក៏នាំគ្នាបែរមកនិយមរាប់អានកាន់សាសនាពុទ្ធៈតែតែច្រើនៗឡើងតាមលំដាប់ ទាល់តែជាហេតុឲ្យសាសនាជិនតោ

ពោយរៀងសាបសូន្យទៅ ។ តាមពិត សាសនាជិនគោជាសាសនា
ដើមកំណើតរបស់ជាតិជប៉ុន ទាំងកើតឡើងក្នុងប្រទេសជប៉ុនតែម្តង ជា
សាសនាចាស់របស់ជាតិជប៉ុនមុនសាសនាណា ។ ទាំងអស់ តែមិនច្បាស់
ថាកើតឡើងក្នុងជាន់ណាវេលាណាទេ ។ ជិនគោបានប្រៀនប្រដៅថា
"មនុស្សយើងកាលស្លាប់ទៅហើយ ក៏ដូចជាការផ្លាស់រូបកាយ ឬផ្លាស់
គ្រឿងសម្លៀកបំពាក់ចាប៉ុណ្ណោះ វិញ្ញាណមិនមែនសាបសូន្យបាត់ទៅទេ
គង់នៅចាំថែរក្សាគ្រួសារជាប់ជានិច្ច ព្រោះវិញ្ញាណជារបស់មិនចេះសាប
សូន្យ", ទេនេះឯងជាការណែនាំដ៏សំខាន់ឲ្យជាតិជប៉ុនមានសេចក្តីក្លាហាន ។
ក្រៅពីនេះ ជិនគោមានប្រៀនប្រដៅឲ្យគោរពបុព្វបុរសរបស់គេទៀត
ពោលដោយត្រង់ គឺព្រះពុទ្ធជាម្ចាស់ផែនដីរបស់គេនោះឯង ។ តាមគតិ
របស់សាសនានេះប្រកាន់ថា កោះជប៉ុននៅសព្វថ្ងៃ គឺជាចំណែកមួយរបស់
ដួងព្រះអាទិត្យ ដែលបែកខ្ញែកមកហើយក៏ក្លាយទៅជាកោះឡើង ខាង
ក្រោយបានប្រទានព្រះពុទ្ធនឹងព្រះពុទ្ធិនីឲ្យមកនៅកាន់កោះជប៉ុន តមក
ទៀត ព្រះពុទ្ធនឹងព្រះពុទ្ធិនីជាអ្នកឲ្យកំណើតដល់ប្រជាជនជប៉ុន ។
បើនិយាយដោយត្រង់គឺគេប្រកាន់ថា ព្រះរាជាតែងស្រឡាយមកអំពី
ព្រះអាទិត្យ, ឯប្រជាជនតែងស្រឡាយមកអំពីព្រះរាជា, ព្រះរាជាក៏គឺជា
បុព្វបុរសដ៏ខ្ពង់ខ្ពស់បំផុតរបស់គេនោះឯង ។ កាលគេស្រឡាញ់ទឹងគោ-
រពបុព្វបុរសរបស់គេ ក៏ត្រូវតែក្លាហានហ៊ានផ្តាច់សត្រូវគ្រប់យ៉ាង ដើម្បី

ទើងបូជាគុណបុព្វបុរសរបស់គេ; ផលល្អឬអាក្រក់ដូចម្តេចកាលបើតើតមានឡើងដល់បុព្វបុរសរបស់គេ ក៏ដូចជាតើតមានឡើងដល់ខ្លួនគេដែរ ។ អាស្រ័យហេតុនេះ ជនជាតិជប៉ុនទើបជាអ្នកមានសម្ព័ន្ធសាមគ្គីនឹងគ្នាល្អជាទីបំផុត ព្រោះគេយល់ឃើញថាខ្លួនគេជាប់សែស្រឡាយម៉ក់ជាមួយគ្នា, ចាត់ថាសាសនាជិនគោនេះជាគ្រឿងចង្អុលផ្លូវនៃអារ្យធម៌ឲ្យដល់ជាតិជប៉ុនជាយ៉ាងល្អ ។ អ្នកស្រុកជប៉ុនមានសេចក្តីក្លាហាន ស្រឡាញ់ជាតិស្រឡាញ់ព្រះមហាក្សត្រ ក៏ព្រោះតែគតិខាងផ្លូវសាសនាជិនគោនៅចាំអប់រំលើកតំកើងបង្កើនឲ្យលឿនៗមុខ ដូច្នេះបានជាសាសនាជិនគោតាំងនៅក្នុងសេចក្តីនិយមរាប់អានរបស់ជនជាតិជប៉ុនជាច្រើន ។ ខាងពុទ្ធសាសនាវិញ ជាតិជប៉ុនបានប្រកាន់ថាជាសាសនាដ៏សំខាន់របស់គេដូចគ្នា ប៉ុន្តែជាសាសនាដែលមានគតិឬសេចក្តីយល់ឃើញជាបដិបក្ខនឹងសាសនាជិនគោជាច្រើន សូម្បីដូច្នោះពុទ្ធសាសនាក៏នៅតែចំរើនរុងរឿងក្រៃលែងជាងសាសនាជិនគោ ។ ប្រជាជនដែលមានសេចក្តីស្រឡាញ់រាប់អានកាន់សាសនាជិនគោ មានប្រមាណត្រឹម ១៦ លាននាក់ប៉ុណ្ណោះ ចំណែកដែលកាន់សាសនាពុទ្ធ:មានដល់ ៤៨ លាន ៥ សែននាក់ ច្រើនជាងសាសនាជិនគោ ៣២ លាន ៥ សែន ។ អ្នកប្រាជ្ញខាងឯណាយនាំគ្នាសន្និដ្ឋានថា សាសនាពុទ្ធ:បានចង្អុលផ្លូវដំណើរចូលទៅកាន់សេចក្តីរុងរឿងឲ្យដល់ជាតិជប៉ុនមិនមែនតិចទេ ដូចក្នុងកាល ព. ស. ១០៩៥ ពាក់

ជាគ្រែដំបូងដែលសាសនាពុទ្ធ:បានផ្សាយទៅដល់ប្រទេសជប៉ុន ដោយ
មានព្រះពាជាម្ចាស់ផែនដីនៃប្រទេសកោលីបានធ្វើព្រះពុទ្ធរូបទៅថ្វាយព្រះ
បាទកិម្មេអិជាម្ចាស់ផែនដីជប៉ុន ។ តពីនោះមកមិនយូរប៉ុន្មាន ព្រះពាជា
បានបញ្ជូនព្រះសង្ឃចូលទៅផ្សាយព្រះពុទ្ធសាសនាទៀត ។ ព្រះសង្ឃ
ដែលទ្រង់បញ្ជូនទៅនេះឯងបានយាយកវិជ្ជាសេដ្ឋវិទ្យាសិល្បកម្ម វិសូកម្ម
ចូលទៅផ្សាយឲ្យដល់អ្នកស្រុកជប៉ុនជាយ៉ាងល្អ រហូតដល់ការងាំដំណាំក៏
ដូចគ្នា, ចាត់ថាពុទ្ធសាសនាបានដឹកនាំឲ្យជាតិជប៉ុន ភ្ញើបា្រស់ក្នុងវិទ្យា
ការនោះមិនមែនតិច ចាត់ថាជាវិថីនៃអារ្យធម៌ដ៏សំខាន់មួយចំណែក ។

ប៉ុន្តែក្នុងដានដំបូង ដែលព្រះពុទ្ធសាសនានឹងមានសភាពត្រជាក់
ត្រដំផ្សាយបរិបូណ៌ក្នុងប្រទេសនេះបានល្អ ពុទ្ធសាសនិកជនត្រូវធ្វើការ
ធ្ងន់ៗអស់រយៈជាច្រើនឆ្នាំ ត្រូវធ្វើការតស៊ូមាប់គ្នាក្នុងរវាងបរិស័ទរបស់
សាសនាជិនតោតាល់តែចេញខ្លះឈាម ។ សង្គ្រាមរបស់សាសនាទាំង ២
នេះបានធ្វាញ់គ្នាអស់រយៈជាយូរអង្វែង ក្នុងទីបំផុតសាសនាដែលមាន
រសធម៌ដ៏ត្រជាក់ត្រដំក្នុងផ្លូវបតិសុខ ប្រាសចាកការបៀតបៀនគ្នានឹងគ្នា
តាំងសម្បូណ៌ទៅដោយសិល្បវិទ្យាការដ៏មានតុជារស គឺព្រះពុទ្ធសាសនា
បានតាំងទុកនៅសេចក្តីមានជ័យ អាចគ្របសង្កត់ទឹកចិត្តជាតិជប៉ុនពេញ
តាំងប្រទេស ។ ពុទ្ធសាសនាមានអ្នកនិយមរាប់អានផ្សាយទៅក្នុងប្រទេស
ជប៉ុនគ្រឹមណា រស្មីរបស់ជិនតោក៏ចេះតែពេយរឿងយ៉ុះទៅគ្រឹមណោះ

ធ្វើឲ្យបរិស័ទរបស់ជនគោក្តីក្រហាយមិនតិច, គ្រាតមកជនគោកំណាន
ទៅកាន់សេចក្តីសាបសូន្យតាមលំដាប់ ។

លុះមកដល់រជ្ជសម័យរបស់ព្រះនាង ស៊ុយកោ ម្ចាស់ផែនដីដប៉ុន
កង ព. ស. ១១៣៦ ដល់ ១១៧១ បានកើតការផ្លាស់ប្តូរសាសនាមួយ
គ្រា ដោយប្រកាន់យកសេចក្តីពប់អានរបស់មហាជនជាធំ ។ ដូច្នេះឯង
សាសនាពុទ្ធ: ដែលនៅកង្វះសេចក្តីនិយមរបស់មហាជន ទើបបានត្រូវ
លើកឡើងជាសាសនាផ្លូវរាជការរបស់ដប៉ុន ជាសាសនារបស់ជាតិដូច
សាសនាជនគោដែលជាសាសនាដើមរបស់ដប៉ុន ។ កង្វះវេលានេះមាន
ក្សត្រដប៉ុនជាច្រើនបានចេញបួសកង្វះព្រះពុទ្ធសាសនា ហើយយកព្រះ
ទ័យទុកដាក់ទំនុកបម្រុងព្រះពុទ្ធសាសនាជាយ៉ាងល្អ; សេចក្តីចំរើនលូត
លាស់របស់ពុទ្ធសាសនាបានដំណើរទៅយ៉ាងរៀបរយតៗមក ។

លុះមកដល់រជ្ជសម័យរបស់ព្រះបាទមស្សុហិតោ កង្វះរាង ព. ស.
២៤១០ ដល់ ២៤៥៥ នោះ ព្រះអង្គមានព្រះរាជប្បាថ្នានឹងរៀបចំ
ប្រទេសរបស់ព្រះអង្គឲ្យសមនឹងពាក្យថា "ដប៉ុន" គឺត្រូវការឲ្យគ្រប់ៗ
យ៉ាងកង្វះប្រទេសដប៉ុនជារបស់ជាតិដប៉ុនដោយត្រង់ រួមទាំងការសា-
សនាផង ដូច្នោះទើបបានកើតការផ្លាស់ប្តូរឡើងមួយគ្រាទៀត ដោយ
លើកយកសាសនាជនគោ ដែលជាសាសនាដើមរបស់ដប៉ុន ទាំងកើត
ឡើងកង្វះប្រទេសដប៉ុន ជាសាសនាផ្លូវរាជការតមក ។ សូម្បីដូច្នោះ

សាសនាពុទ្ធៈក៏គង់តែនៅកន្លែងសេចក្តីនិយមរាប់អានរបស់ប្រជាជនជប៉ុន ជាចំនួនច្រើនជាងសាសនាដទៃគេ ជាង ២ ភាគ ចាត់ជាសាសនាពុទ្ធៈ បានជាចំណែកមួយ ដែលអប់រំធម្មចរិយាដ៏ពិតប្រាកដឲ្យដល់ជាតិជប៉ុន នាំជប៉ុនចូលកាន់វិថីនៃអារ្យធម៌ដ៏ល្អ សមគួរដែលអ្នកស្រុកជប៉ុននឹងត្រូវនឹកវង្វេកដល់ជានិច្ច ។ កន្លងមកឬនេះ ព្រះពុទ្ធសាសនាក៏ជាសាសនាដែលសំខាន់របស់ជាតិជប៉ុន ប្រាកដថាវេលានេះវត្តពុទ្ធសាសនាក្នុងប្រទេសជប៉ុន មានចំនួនដល់ ៧០,០០០ វត្ត (៧ម៉ឺនវត្ត) សំដែងឲ្យឃើញថាពុទ្ធសាសនាក្នុងប្រទេសជប៉ុនចំរើនរុងរឿងមិនមែនតិចទេ ។

ក្រៅពីសាសនាដទៃគេនឹងសាសនាពុទ្ធៈ នៅមានលទ្ធិខុងជូដែលបានផ្សាយទៅដល់ប្រទេសជប៉ុនដែរ ។ តាមពិត លទ្ធិនេះបានផ្សាយទៅដល់ប្រទេសជប៉ុនមុនសាសនាពុទ្ធៈ ប្រាកដថាបានផ្សាយចូលទៅដល់កន្លែងរាង ព.ស. ៨២៩ ។ លទ្ធិនេះមានដើមកំណើតកើតនៅកន្លែងប្រទេសចិនជាមុន ទាល់ក្រោយទើបបានផ្សាយទៅដល់ប្រទេសជប៉ុន ប៉ុន្តែមានបណ្តាជនទទួលរាប់អានតិចគ្នា សូម្បីពាក្យប្រដៅរបស់សាសនានេះមិនទំនាស់នឹងសាសនាដទៃគេក៏មែនហើយ ប៉ុន្តែអ្នកផ្សាយសាសនាមិនសូវខំប្រឹងច្រែងប្រែង ឬក៏ខ្វះភាពគតិរបស់សាសនា ទើបមិនអាចនឹងទាញទឹកចិត្តរបស់ប្រជាជនឲ្យបែរមកនិយមរាប់អានបាន ។ ក្នុងសម័យនេះលទ្ធិខុងជូហាក់ដូចជាសាបសូន្យអស់ទៅហើយ មិនប្រាកដថាមានមនុស្ស

ពាប់អានច្រើនឬតិច ។ ខាងផ្លូវពាណិជ្ជការ ជាប៉ុន្តែក៏មិនបានប្រកាន់សាសនាឡើងដូចជាសាសនាសំខាន់របស់ជាតិទេ; សាសនាឡើងក៏ចេះតែរោយរៀរសាបសូន្យទៅរាល់ថ្ងៃដូចជាបាត់រស់ទៅហើយ ។

មានសាសនាមួយទៀតគឺ សាសនាគ្រិស្ត ។ បានផ្សាយទៅដល់ប្រទេសជប៉ុនដូចគ្នា ប៉ុន្តែទើសខាក់លំបាកច្រើន ព្រោះអ្នកស្រុកជប៉ុនមិនស្រឡាញ់ពាប់អាន ។ គ្រិស្តសាសនាគ្រាន់តែផ្សាយទៅដល់ប្រទេសជប៉ុនប៉ុណ្ណោះ មិនបានធ្វើឲ្យប្រទេសជប៉ុនមានសេចក្តីរុងរឿងទេ ទើបមិនបានតាំងនៅក្នុងសេចក្តីនិយមពាប់អានរបស់ប្រជាជន ដូចជាពុទ្ធសាសនានឹងសាសនាជិនតោ ដែលមានប្រាកដនៅក្នុងប្រទេសជប៉ុនសព្វថ្ងៃនេះ ។

សាសនាពុទ្ធៈនឹងសាសនាជិនតោបានបណ្តុះឧបនិស្ស័យរបស់ប្រជាជនជប៉ុនឲ្យមានសេចក្តីសាមគ្គីព្រមព្រៀងគ្នា មានទឹកចិត្តតែមួយដូចគ្នា មានធម្មៈស្មើគ្នាដូច្នេះ បានជាបណ្ឌិតស្ត្រជប៉ុនមានសិទ្ធិនឹងនិយាយបានពេញមាត់ថា "ដែលជាតិគេបានចំរើនដល់គំនួសជាន់ខ្ពស់ ខាល់តែក្លាយទៅជាមហាប្រទេសក្នុងភូមិភាគអាស៊ីឦបនេះ ក៏ព្រោះតែសាសនាចាំងពីរបានឲ្យផល" ហើយនាំគ្នាប្រកាន់យ៉ាងខ្លាប់ខ្ជួនថា "ព្រះពុទ្ធជាម្ចាស់ផែនដីរបស់គេក៏គឺជាប់លោហិតរបស់គេ" ។ ព្រោះហេតុនោះតាំងពីកកើតមានជាតិជប៉ុនឡើងក្នុងលោក មិនដែលមានការផ្លាស់ប្តូរវង្សក្សត្រឡើយ ហើយក៏ចេះតែចំរើនរុងរឿងរហូតដល់សព្វថ្ងៃនេះ ។

លោកអាចារ្យ ឆង-សាមិទ្ធ ពុទ្ធរក្ខិតោ

គ្រូបង្រៀនចាលីនៅសាលាចាលីវង្គលង្កា ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសម្តេចព្រះសង្ឃនាយកខែប្រែទេសកម្ពុជា កាលពីថ្ងៃ ១៣ រោច
ខែស្រាពណ៌ឆ្នាំកុរឯកស័ក ព. ស. ២៤៩១ (២២-១-៤៧)

នមត្ថុ រតនត្តយស្ស

សូមនមស្សការចំពោះព្រះរតនត្រ័យដោយសរឆ្ងប

សព្វត្តភាយ និវារណត្ថំ

ដើម្បីការពារនូវសេចក្តីអន្តរាយគ្រប់យ៉ាង ។

តអំពីបទនមស្សការនេះទៅ ខ្ញុំសូមដែងធម្មទេសនាអំពីពាក្យថា "ទីឃឹ" តាមសមគួរដល់កាលវេលា ។

បណ្តាមនុស្សក្នុងសកលពិភពលោក ត្រូវតែមានការពឹងពាក់ប្រស័យជាប់ទាក់ទងគ្នាទៅវិញទៅមកជាធម្មតា គឺកូនត្រូវទីពឹងឪពុកម្តាយ។ ត្រូវទីពឹងកូន, ប្អូនប្រុសស្រីត្រូវទីពឹងបងប្រុសស្រី។ ត្រូវទីពឹងប្អូនប្រុសស្រី, អ្នកក្រត្រូវទីពឹងអ្នកមាន។ ត្រូវទីពឹងអ្នកក្រ. ពស្តេត្រូវទីពឹងនាម៉ឺន។ ត្រូវទីពឹងពស្តេជាដើម, ឬក៏នាម៉ឺនត្រូវទីពឹងព្រះមហាក្សត្រ, ឯពួកសត្វត្រូវទីពឹងព្រះធម៌, សត្វក្នុងទន្លេត្រូវទីពឹងឪពុកម្តាយ

ទើបរួចអំពីសេចក្តីទុក្ខដូចប្រទះនឹងសេចក្តីសុខ ក្នុងលោកនេះនឹងលោកខាងមុខតាមសមគួរដល់ឋានៈ នឹងកាលៈទេសៈរបស់ខ្លួន ។

អធិប្បាយពាក្យថាទីពឹង

ពាក្យថា "ទីពឹង" ដែលលោកបញ្ញត្តប្រើក្នុងភាសាខ្មែរនេះ ត្រូវនឹងពាក្យបាលីថា "សរណៈ" សំគាល់សេចក្តីថា "ទីពឹង ទីពួក ឬមូលសម្រាប់ជក" ។

ពាក្យ "ទីពឹង" នេះ ក្នុងភាសាបាលីហៅផ្ទាស់ប្តូរគ្នាច្រើនសព្ទៈ ចួនកាលហៅថា "សរណៈ", ចួនកាលហៅថា "ទីបៈ", ចួនកាលហៅថា "នាថៈ" ។ អ្នកដល់នូវទីពឹងនោះហៅថា "សរណង្គតោ, នាថង្គតោ, ទីបង្គតោ" ប្រែថា "អ្នកដល់ឬអ្នកប្រកបដោយទីពឹង" ។ ពាក្យថា "សរណៈ, នាថៈ, ទីបៈ" អម្បាលនេះ គ្រាន់តែផ្សេងគ្នាដោយតួអក្សរ តែសំគាល់សេចក្តីជាមួយគ្នា សំដៅត្រង់ផលប្រយោជន៍ដែលឲ្យសម្រេចសេចក្តីសុខកាយសប្បាយចិត្ត សមប្រកបតាមសេចក្តីជ្រាបជ្រួតគ្នា ។ ឯទីពឹងនោះមាន ៣ យ៉ាង គឺ : ១ - អាទិសរណៈ = ទីពឹងត្រង់ខាងដើម, ២ - មជ្ឈសរណៈ = ទីពឹងត្រង់កណ្តាល, ៣ - បរិយោសានសរណៈ = ទីពឹងត្រង់ទីបំផុត ។

ទីពឹងត្រង់ខាងដើម - មាតាបិតាឧត្តមជាទីពឹងខាងដើមរបស់កូនប្រុសស្រីគ្រប់គ្នា ។ ធម្មតាកូនប្រុសស្រីទាំងឡាយត្រូវតែមានមាតាបិតា

ជាទីពឹងទីពឹងកម្ដុជាមួយសម្រាប់ជីវិត គឺបុត្រធីតាត្រូវតែពឹងពាក់ប្រែស្រ័យ
ចំពោះមាតាបិតារបស់ខ្លួនជាអាទិ៍ តាំងតែពីបដិសន្ធិវិញ្ញាណមកចាប់
បដិសន្ធិកន្លងផ្ទៃជាដំបូងរហូតប្រសូតចាកគភ៌ ។ មាតាបិតាកាលបើ
ដឹងជាទារកមកដល់កន្លងគភ៌កាលណាហើយ ក៏ស៊ូត្រៀតត្រៀមបីគភ៌នោះ
បំពេញចំប៉ាន់ឲ្យមានសាច់ស្បែកឈាមសរសៃដ៏វិតសង្ខារស់នៅស្រួល ។
ចំណែកខាងសាច់ស្បែកឈាមសរសៃរបស់លោកដែលទារកជញ្ជក់ជញ្ជប់
បៀមបៅ ក៏ចេះតែស្រកស្រួតស្ងួតអស់អាយុរៈកាលពេលកាលវេលា,
កម្ងាន់កំហែង ក៏ថមថយខ្សោនខ្សុកខ្សួលហត់ហត់ល្ហិតល្ហៃពាបពាប់ទៅ
ទឹងកន្ទេល មានសេចក្ដីទុក្ខក្រៃមក្រៃជាំជាំនៅក្នុងខ្លួនស្ទើរតែក្សីណាក្ស័យ
ជីវិតសង្ខារត្រាតែគ្រប់ខែ ៩ ឬ ខែ ១០ ទើបប្រសូតមក ។ កាលបើប្រសូត
មកក៏បានបីបាច់ថែរក្សាបីបាច់ថែរក្សាបីបាច់ថែរក្សា

ចេះគោរពបូជាចំពោះព្រះមហាពោធិសត្ត ជាសម្មតិទេព ដ៏វិសេសបូជា
សរណៈជាម្ចាស់របស់ប្រជាជាតិគ្រប់គ្នា យ៉ាងនេះហៅថាអាទិសរណៈ
ប្រែថា មាតាបិតាជាទីពឹងទាងដើមរបស់កូនប្រុសស្រី ។

ទីពឹងត្រង់កណ្តាល – ព្រះមហាក្សត្រគ្រប់ព្រះអង្គជាទីពឹងទីពួក
ត្រង់កណ្តាលរបស់ប្រជាជនគ្រប់គ្នា ទាំងខាងក្នុងនឹងខាងក្រៅព្រះរាជ-
នគរ ។ ធម្មតានគរមួយៗ លុះតែតែមានព្រះមហាក្សត្រជាអធិបតី
ព្រះមហាក្សត្រជាបិតា ព្រះមហាក្សត្រជាសម្មតិទេពឬជាសរណៈទីពឹង
ទីពួក ទើបនគរនោះសម្បូណិសប្បាយដោយវត្ថុផ្សេងៗ នឹងជាទីរីករាយ
សប្បាយដល់ប្រជាជនគ្រប់គ្នា លឿនសិរីមង្គលកាន់តែរុងរឿងអស់កាល
ជានិច្ច ប្រាសចាកទុក្ខទោសអន្តរាយទាំងអស់ ដូចប្រទេសចក្កវត្តិសុខ
ចំរើនគ្រប់ប្រការ ។ ព្រោះហេតុនោះ ព្រះសាស្តាចារ្យទ្រង់សាងនគរ
របស់ព្រះអង្គឲ្យមានរបៀបរៀបរយយ៉ាងត្រកាល មានព្រះទ័យត្រជាក់
ត្រជុំដូចទឹកស្រះអនោតត្ត មានព្រះទ័យស្មោះស្ម័គ្រប្រកបដោយទស-
ពិធរាជធម៌សព្វគ្រប់ប្រការ ព្រះអង្គជាទីពឹង ជាទីពំនាក់ក្តីអាស្រ័យ
ប្រកបដោយព្រះធម៌សព្វគ្រប់ប្រការ ប្រកបដោយមហាករុណា ជាអ្នក
សម្រេចសេចក្តីប្រាថ្នាដល់សត្វសត្វគ្រប់ប្រាណ, ដល់ពេលជាអវសាន
ព្រះអង្គក៏បានលះបង់ព្រះរាជបុរីដ៏ថ្លៃថ្លា ដែលបរិបូណ៌ដោយមហាសម្បត្តិ
ទ្រង់លះកាត់ព្រះរាជបុត្រ ព្រមទាំងព្រះរាជវង្សានុវង្ស នឹងមហាសម្បត្តិ

ប្រកបដោយតែវ ៧ ប្រការនឹងស្មើតច្បាំត្រែ ព្រះអង្គទ្រង់លះកាត់ជាច់អាល័យ ឥតមានសេចក្តីប្រាថ្នា យាត្រាចេញទៅសាងមហាកិនិស្ក្រមសមំនៅក្នុងព្រៃស្ងាត់ស្ងៀងតែមគ្គផលជាបរមត្ថ មហាប្រសើរ ទ្រង់ផ្ទុំបង្ហុយបង្ហើរចោលនូវលតាវល្លិដែលដុះលូនធ្វើប្រទាក់គ្នាគឺមិច្ឆាទិដ្ឋិ, រំលើងបង់នូវទីទៅអាស្រ័យនៃលតាវល្លិគឺបញ្ចកាមគុណ, កាត់បង់នូវៈណាកៈ ទោសៈ មោហៈ តាំងឡាយ, ហាមបង់នូវក្រែសៃនៃតណ្ហា, បំផ្លាញទ្វារបើកផ្លូវត្រូវ ដោះពួកប្រជាជនឲ្យរួចអំពី ចំណោមនៃសេចក្តីទុក្ខប្រគល់សេចក្តីសុខបញ្ចូលក្នុងវដ្តនគរបស់ព្រះអង្គ ។ យ៉ាងនេះហៅថា មជ្ឈសៈរណៈ = ទីពឹងត្រង់កណ្តាល ។

ទីពឹងត្រួងទីបំផុត – បណ្តាមនុស្សទេព្តាក្នុងសកលពិភពហាន ត្រូវមានសាសនាសម្រាប់ប្រដៅគ្រប់ប្រាណ ដល់អាសានយើងនឹងបានសេចក្តីសុខឥតទុក្ខភ័យចរៃរោរពុះបន្ទុបគ្រប់ប្រការ ត្រូវមានសាសនាជាប្រមុខ, សាសនាជាមូលសម្រាប់ជ្រកបានត្រជាក់ក្នុងលោកនេះនឹងលោកខាងមុខ សាសនាជាបន្ទាត់ សាសនាជាប្រទីបសម្រាប់ត្រាលំភ្លឺ សាសនាជាបង្គួរបស់សកលរដ្ឋ ឬសកលលោក ។ ដូចជាយន្តតាំងឡាយដែលប្រកបដោយគ្រឿងទ្រូសម្ភារៈផ្សេងៗ បើគ្មានបង្គួរសម្រាប់ដម្រងដែរ ក៏មិនអាចបើកឲ្យលឿនទៅកាន់ទីប្រាថ្នាបាន យ៉ាងណាមិញ; សកលលោក បើគ្មានសាសនាក៏មិនអាចលឿនទៅបាន លុះតែមានសាសនាជាបង្គួរ ទើបលឿនទៅកាន់អាវុធមិជានិច្ចបាន ដូច្នោះដែរ ។

ហេតុនេះ ប្រជាជនចូរស្រឡាញ់សាសនាគ្រប់គ្នាចុះ ។ សាសនា
នោះមាន ២ យ៉ាង គឺ: ១- ពាហិរសាសនា = សាសនាខាងក្រៅ,
២- ពុទ្ធសាសនា = សាសនាព្រះពុទ្ធ ។ ក្នុងទីនេះ សូមសម្តែង
តែអំពីពុទ្ធសាសនាដែលជាសាសនាឯកក្នុងលោក ។

"ពុទ្ធ" ក្នុងទីនេះ ចានដល់អរិយជន ១ អង្គ ដែលកើតនៅក្នុងមជ្ឈ-
មប្រទេស ជាខត្តិយត្រកូល អរិយជាតិ ឬថាអរិយៈ ជាគោត្តមគោត្រ ។
ព្រះអង្គជាបុគ្គលអស្ចារ្យក្នុងលោកគ្មានអ្នកណាមួយប្រៀបផ្ទឹមស្មើ គ្រាស់
ដឹងសព្វគ្មានចន្លោះ មនុស្សសត្វទេពតាតែងគោរពបូជាកោតខ្លាច ថ្វាយ
ព្រះនាមថា "ព្រះពុទ្ធ:" ។

ពាក្យប្រៀនប្រដៅរបស់ព្រះអង្គហៅថា "ពុទ្ធសាសនា" អ្នក
ប្រតិបត្តិតាមពុទ្ធឱវាទហៅថា ពុទ្ធសាសនិកនិកាយ "ពួកអ្នកកាន់
សាសនាព្រះពុទ្ធ ឬ ពួកអ្នកចូលសាស្ត្រព្រះពុទ្ធ" ។

អ្នកកាន់សាសនាព្រះពុទ្ធ ត្រូវបានប្រយោជន៍គឺសេចក្តីសុខក្នុង
ជាតិនេះនឹងជាតិខាងមុខ; ប្រយោជន៍ក្នុងជាតិនេះ ត្រូវទទួលសម្បត្តិ
៣ យ៉ាងគឺ បានរូបសម្បត្តិល្អ មកពីរក្សាសីល ១, មានទ្រព្យសម្បត្តិ
ច្រើន មកពីឲ្យទាន ១, មានប្រាជ្ញាច្រើន មកពីចំរើនមេត្តាភាវនា ១ ។

មួយទៀតបុណ្យនឹងបាបនេះ រមែងជាប់ដឹងជាមជាមួយនឹងចិត្ត
សម្រេចមកអំពីចិត្ត ដល់ពេលស្លាប់ទៅនឹងតាមឲ្យផលក្នុងជាតិខាងមុខ

ទៀត ដូចជាម៉ាស៊ីនសម្រាប់ថត បើម៉ាស៊ីនល្អ - អាក្រក់ - ធំ - តូច រូបថតក៏ល្អ - អាក្រក់ - ធំ - តូចតាមម៉ាស៊ីននោះដែរ; ម៉ាស៊ីនទុកដូចជាតួចិត្ត ស្រមោលរូបថតទុកដូចជាគុណបុណ្យនឹងបាប; រូបរបស់អ្នកណានៅជារបស់អ្នកនោះមិនផ្លាស់ប្តូរ គ្រាន់តែមួយរូបចាស់មួយរូបថ្មីប៉ុណ្ណោះ ។ មិនត្រឹមតែប៉ុណ្ណោះ តាមទៅប្រគល់សេចក្តីសុខទុក្ខ ចំរើនវិនាសអាក្រក់ល្អ តាមលំដាប់ជាតិទៀត ដូចបុរាណាកាសិតថា "ដូចជាស្រមោល អនុវាលតាមបុរាណ ពុំដែលចៀសបាន ត្រង់ក្តីសល់វល់" ។ មែនពិត ស្រមោលទោះបីគេដេរស្តីបណ្តេញបំបរ ឬលួងលោមអង្វរថា "សូមឲ្យស្រមោលឯងត្រឡប់វិញ" ដូច្នេះ ដោយពាក្យពីរោះក្តី. ពុំពីរោះក្តី ស្រមោលក៏មិនស្តាប់ ចេះតែទៅតាមបុរាណ បើមនុស្សដេកស្រមោលក៏ដេក បើមនុស្សដើរ ស្រមោលក៏ដើរតាម គ្រប់វិយោបថយ៉ាងណាមិញ បុណ្យនឹងបាបក៏ដូច្នោះដែរ ស្រមោលទុកដូចជាបុណ្យបាប, មនុស្សដេកដើរឈរអង្គុយ ទុកដូចជាមនុស្សស្លាប់ឬនៅរស់នៅឡើយ រមែងតាមប្រគល់ឲ្យផលបុណ្យផលបាប ដល់មនុស្សនោះក្នុងជាតិនេះនឹងជាតិខាងមុខជានិច្ច ។ ព្រោះហេតុនោះ សាធុជនទាំងឡាយត្រូវនាំគ្នាខ្ជិលខ្ជាយលះអំពើបាប បំពេញអំពើបុណ្យ ដើម្បីជាទីពឹងឬជានិស្ស័យបច្ច័យរាល់សនារបស់ខ្លួនតទៅជាតិមុខទៀត ។ នេះហៅថា បរិយោសានសរណៈ= ទីពឹងត្រង់ទីបំផុត ។

មែនពិត មនុស្សក្នុងសកលពិភពលោក ត្រូវតែស្វែងរកទីពឹងទាំង ៣ ប្រការនេះ, មុនដំបូងត្រូវទៅពឹងព្រះពុទ្ធម្ចាស់ ទី ២ ត្រូវទៅពឹងព្រះមហាក្សត្រ ទី ៣ ត្រូវទៅពឹងសាសនា គឺថាត្រូវស្រឡាញ់មាតាបិតាសាសនាមហាក្សត្រៃបស់ខ្លួន ។

ឯមាតាបិតា, សាសនា, មហាក្សត្រ លោកទុកជាបុព្វការី របស់ប្រជាជនគ្រប់គ្នា ព្រោះលោកមានគុណូបការៈជាអនេកអនន្តធ្ងន់ពន់ប្រមាណណាស់ សូម្បីតែទឹកនត្រមហាសមុទ្រក្តី ផែនក្រឡាម្ហាប្រថពីក្តី ក៏នឹងយកមកថ្លឹងឲ្យត្រឹមស្មើនឹងគុណនោះពុំបាន ។ អ្នកណាមួយមិនគោរពប្រតិបត្តិស្រឡាញ់រាប់អានមាតាបិតាសាសនាមហាក្សត្រៃបស់ខ្លួនទេ អ្នកនោះគេហៅថា ស្អប់ប្តូរត់ចិត្ត ឬហៅថា អកតញ្ញូ ជាអ្នកមិនដឹងគុណនៃជាតិទឹកដីសាសនាមហាក្សត្រៃបស់ខ្លួនដោយពិត ។ ព្រោះមាតាបិតាលោកជាអ្នកបង្កើតកូន ឬជាអ្នកសាងជាតិកំណើតឲ្យកូន, ព្រះមហាក្សត្រជាអ្នកសាងឲ្យប់សម្រាប់ប្រជាជាតិ ឯព្រះលោកនាថជាអ្នកប្រកាសព្រះធម៌ទុកសម្រាប់ប្រជាជនក្នុងត្រៃភព ។

សំដែងមកក្នុង សារណកថា សន្ទតថាចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

ដោយអំណាចនៃធម៌ទេសនានេះ សូមសត្វទាំងឡាយជាន់ខ្ពស់ សេចក្តីក្សេមក្សាន្តគ្រប់ប្រាណទៅហោង ។

ចប់

ការបណ្តុះនិស្ស័យ

ព្រះមហាឧត្តមវិជា ធីលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីវគ្គបច្ចុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាធុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ ពិនិត្យកែ

(តមក)

មនុស្សយើងនឹងទៅជាមនុស្សល្អបាន ត្រូវតែកសាងឡាក់ឋាន គោលទីតាំងដូចិ កាលវ័យនៅក្មេង ត្រូវតាំងចិត្តសិក្សាវិជ្ជាឲ្យបានច្រើន ហើយឲ្យចេះពិតៗផង កុំធ្វើចិត្តនៅធាវប្រញាប់ខុមុនស្រេកឡើយ; កាលធំឡើងត្រូវព្យាយាមស្វែងរកទ្រព្យតាមផ្លូវសុចរិត តាំងគេហស្ថានផ្ទះសំបែងឲ្យមានទីតាំងមាំមួន ប្រព្រឹត្តខ្លួនតែក្នុងសីលធម៌ ធ្វើខ្លួនឲ្យជាមនុស្សសុភស្តម្ភមានបក្សពួកគឿនកត្តិល្អច្រើន ដំណើរជីវិតទៅឲ្យសមគួរដល់ឋាន: របស់ខ្លួន កុំធ្វើចិត្តស្រាល ឋានបន្ទិចកំប៉ុបទៅឡើងហួសឋាន:របស់ខ្លួន ដែលជាហេតុនាំឲ្យឋាន:នោះរលំរលាយបាត់ទៅវិញ ត្រូវប្រព្រឹត្តតាមគោលខាងក្រោមនេះ គឺ:

ក – ត្រូវមានផ្ទះសំបែងឲ្យមាំមួន – គឺមានទីនៅអាស្រ័យជាស្ប្បាយ: ពេញលេញ ហើយលំនៅនោះនៅក្នុងកម្មសិទ្ធិរបស់ខ្លួនឯង ឬជាទីដែលមនុស្សដទៃឲ្យនៅអាស្រ័យឬក៏យើងជួលនៅអាស្រ័យបិតថោកក៏ដោយ តែកាលមាននរណាមួយ ដែលគ្មានទីពាល់ត្រជាប់ខាត់ឆន់នឹងយើង យើង

ក៏អាចជួយអនុគ្រោះឲ្យគ្នាទៅវិញទៅមកបានដោយងាយ កុំជាមនុស្សចេះតែដើរ
ទៅផ្តេសផ្តាស មិនមានទីលំនៅប្រាកដប្រជា ។

ខ. - ត្រូវមានគ្រួសារមាំមួន - បើបុរសត្រូវមានភរិយា បើជាស្ត្រី
ត្រូវមានស្វាមីឲ្យពិតប្រាកដ ចងមេត្រីស្រឡាញ់រួមភ័ក្ត្រគ្នាដោយសុចរិត
ស្មោះត្រង់ ពង្រាប់អានលើកដំកើងគ្នាជាគូសាងបារមី នាំគ្នាជួយបណ្តុះបាន:
ឲ្យមានគោលខ្លឹមាំង ចិញ្ចឹមគ្នាទៅវិញទៅមកដោយត្រឹមត្រូវតាមប្រពៃណី
រហូតដល់អស់ជីវិត ។ កុំជាមនុស្សមានភរិយាស្វាមី គ្រាន់តែដើម្បី
បំពេញសេចក្តីត្រេកត្រអាល ឬដើម្បីបង្កើនទ្រព្យសម្បត្តិគ្នាអស់ហើយ
ក៏លះលែងគ្នា, ទាំងកុំជាមនុស្សមានភរិយាស្វាមីដោយប្រាថ្នានឹងយក
ប៉ាយបរិភោគកងពេលថ្ងៃៗនោះឡើយ ។ បើជាមនុស្សមិនមានភរិយា
ស្វាមីទេ ក៏ត្រូវមានវង្សញាតិឬមនុស្សបំរើកងផ្ទះយ៉ាងមាំមួនជារបៀប
រៀបរយ, កុំជាមនុស្សអនាថាប្រាសចាកក្រុមគ្រួសារ ។

គ. - ត្រូវមានរបរគ្រាដីរកម្ម ហ្មត់ចត់ប្រាកដប្រជា - កាលនៅកង
ទ័ណា ត្រូវគិតគាំងខ្លួនរបស់ខ្លួនឯង ឲ្យមានគោលខ្លឹមាំងកងទ័នោះ
កុំប្រាថ្នាចំពោះសេចក្តីឧបត្ថម្ភ ផងឡើមអំពីអ្នកដទៃតែ១ ចំណែកឡើយ,
ត្រូវគាំងចិត្តបរិភោគតែអាហារដែលកើតឡើង ដោយសារញើសក្លែ
របស់ខ្លួនឯង ។ ការទៅប្រជុំជួយបរិភោគអាហារដោយសារការងារ
របស់អ្នកដទៃតែម្យ៉ាង មិនប្រពៃឡើយ, ត្រូវគាំងខ្លួនឲ្យមានគោលខ្លឹមាំង

ឲ្យមានផ្ទះសម្បែងជារបស់ខ្លួន ឲ្យមានទីដីជារបស់ខ្លួន. ត្រូវធ្វើការអាជីវៈដែលជាគោលនៃទ្រព្យ ដូចជាធ្វើស្រែចំការ ច្បារដំណាំ ឲ្យមាំទាំជាដើម ប្រកបការងាររបស់ខ្លួនតាមកំឡាំងខ្លួន ឲ្យជាដុំជាកំភួន ដើម្បីញុំាងកោតទ្រព្យឲ្យកើតឡើងដល់ខ្លួននឹងប្រទេសជាតិ ធ្វើឲ្យខ្លួននឹងគ្រួសារបានៅជាស្រួល បរិភោគជាស្រួល មានមុខមាត់ជាកិត្តិយសឡើង ។

ឃ. – ត្រូវដំកល់ខ្លួនទុកឲ្យត្រូវ – គោលសំខាន់នៃការដំកល់ខ្លួនឲ្យត្រូវនោះ នៅត្រង់ការមិនធ្វើអំពើដែលគាប់ចិត្តតែមនុស្សម្នាក់ឬខ្លួនឯងម្នាក់, នៅត្រង់ការព្យាយាមធ្វើអំពើដែលមនុស្សល្អធ្វើច្រើន, នៅត្រង់ការធ្វើអំពើដែលគាប់ចិត្តរបស់មនុស្សល្អច្រើនគ្នា ។ ហេតុនេះយើងត្រូវប្រតិត្តខ្លួនឲ្យល្អ ឲ្យមានសីលធម៌ ឲ្យសុចរិត មិនឲ្យខុសច្បាប់ទំលាប់ផែនដី នឹង ឲ្យជាបុណ្យកុសលដំកល់ខ្លួនទុកឲ្យត្រង់ កុំឲ្យឆ្ងៀងខុសគោលធម៌ ដូចជាកុំប្រតិត្តខ្លួនឲ្យជាមនុស្សមុខរឹង ចិត្តយោរយៅជាដើម កុំឆបោក កុំខ្ជិលច្រញ្របស់ចោរ កុំខ្ជិលសុីឈ្នួលគេដើម្បីធ្វើការដែលមានទោស កុំខ្ជិលសំណូក កុំធ្វើមាសប្លាក់ក្លែងក្លាយ កុំពិញ្ញលក់របស់ក្រៃគឺរបស់ត្រង់ពន្លឹះត្រង់គយ កុំបំបាត់ភស្តុ កុំបំបាត់ការងារ កុំជាមនុស្សមួម្ងូលេងសុក លេងស្រីនឹងល្បែងខាងពួនដែលជាអបាយមុខ ចូរព្យាយាមបង្កើនការងារដែលល្អៗក្នុងមុខក្រសួង នឹង ព្យាយាមអប់រំ

វិជ្ជាដែលចេះស្រាប់ហើយឲ្យទៅគង់វង្ស នឹង ទំហែមវិជ្ជាថ្មីឲ្យរឹងរឹតតែចំរើនឡើងជាកិយ្យាការ ។

កាលយើងតាំងខ្លួនឲ្យមានផ្លូវសម្បើម ជាទីសំណាក់អាស្រ័យមាំមួន មានគ្រួសារមាំពាំ មានការអាជីវៈជាគោលសំខាន់នឹងដកល់ខ្លួនឲ្យត្រូវយ៉ាងនេះហើយ យើងក៏នឹងទៅជាមនុស្សល្អ មានគោលជាទីតាំងបាន ។ តែបើយើងមិនមានហាន:ដូចពណ៌នាមកនេះទេ សូម្បីយើងនិយាយថា "ខ្ញុំជាមនុស្សល្អ" ក៏នឹងទៅជាមនុស្សល្អមិនបានឡើយ ។

៨ - អ្នកល្អ តែងចេះគ្រប់គ្រងខ្លួនឯង - គឺចេះជាស់តឿនខ្លួនឲ្យដឹងខុសត្រូវចំពោះខ្លួនឯង កាលធ្វើខុសក៏ដឹងថាខុស តិះដៀលខ្លួនឯងកុងកាលដែលភ្លែងធ្វើឲ្យខុស នឹង ចេះប្រមាណខ្លួនថា មានជាតិត្រកូលយសស័ក្តិឥស្សរិយសម្បត្តិ សមត្ថភាព ចំណេះវិជ្ជានឹងគុណធម៌ត្រឹមប៉ុណ្ណា ហើយក៏តាំងខ្លួនឲ្យសមគួរដល់ហាន:នោះៗ ទាំងចេះកប់អានខ្លួនឯង មិនជិះជាន់ខ្លួនឯង មិនដុំរុញខ្លួនឲ្យធ្លាក់ទៅកុងទីអាក្រក់ ចេះជួយខ្លួនឲ្យផុតចាកសេចក្តីអាក្រក់ មិនធ្វើអាក្រក់ទាំងកុងទីចំពោះមុខទាំងកុងទីកំបាំងមុខ ប្រកាន់អំពើអាក្រក់ថាជាការមើលងាយសង្កត់សង្កិនខ្លួនឲ្យធ្លាក់ចុះទៅកាន់ទីទាប ធ្វើខ្លួនឲ្យជាទីមើលងាយនៃមនុស្សដទៃ, ចេះទទួលខុសត្រូវខ្លួនឯង ធ្វើខ្លួនឲ្យតាំងទៅកុងបង្គាប់របស់ខ្លួនឯង, ត្រួត

គ្រាខ្លួនឯងជានិច្ចដើម្បីការពារខ្លួន នឹង ចេះពិចារណាពីគ្រោះមើលឲ្យ
ឃើញថា អ្វីគួរ អ្វីមិនគួរ ។

តាមពិត អ្នកដែលមានសមត្ថភាព អាចត្រួតត្រាប្រទេសបានពេញ
ទាំងផែនដី ក៏នៅតែមិនទាន់សំខាន់ស្មើនឹងអ្នកដែលត្រួតត្រាខ្លួនឯងបាន
ដែរ, ការឈ្នះខ្លួនឯងនេះប្រសើរណាស់ ត្រូវនឹងព្រះពុទ្ធភាសិតថា
អត្តា ហវេ ជិតំ សេយ្យោ ''ការយកឈ្នះខ្លួនឯងបាន ជាការ
ប្រសើរណាស់'' ។

ដូច្នេះ យើងត្រូវតែធ្វើខ្លួនឲ្យជាអ្នកល្អខាងការចេះគ្រប់គ្រងខ្លួនឯង
ផង កុំធ្វើខ្លួនឲ្យជាមនុស្សចោកខាប គឺកុំសេពគប់តែនឹងមនុស្សមិន
ប្រាជ្ញ ជាអ្នកដើរផឹក ដើរស៊ីដក់ផ្តេសផ្តាស ជាអ្នកលេងល្បែង
ភ្នាល់នឹងលេងស្រី, ត្រូវធ្វើខ្លួនឲ្យជាមនុស្សល្អ ប្រកបអំពើដែលគួរប្រកប
រៀអំពើដែលគួររៀរ, ធ្វើ និយាយ គិតអ្វី ក៏ឲ្យជាទីទុកចិត្តនឹងលួមដឿ
លួមកាន់យក ឬមិនជាទីរង្កៀសសង្ស័យរបស់មនុស្សដទៃ, កុំធ្វើខ្លួនឲ្យជាទី
មើលងាយនៃមនុស្សពាលពួកនឹងជាទីនាំឲ្យខូចកេរ្តិ៍ឈ្មោះ ឬគុណធម៌របស់
ខ្លួន, កុំនិយាយកុហក ក្លែងបំលាក់ទោសឬរំលោភលើអ្នកដទៃ ដើម្បីតែខ្លួន
ឲ្យផុតចាកពីរុក្ខណាមួយ ឬក៏ដើម្បីរក្សាកិត្តិយសរបស់ត្រកូលរបស់គណៈ
ឬរបស់ជាតិ កុំឲ្យកើតសេចក្តីវិនាស ព្រោះខ្លួនឯងបាននោះឡើយ ។

បើយើងជាអ្នកតូច គួរធ្វើខ្លួនឲ្យសមនឹងភាពជាអ្នកតូច ដឿស្តាប់
ពាក្យបង្គាប់របស់អ្នកបង្គាប់បញ្ជា, កុំចាប់ថ្នាក់អ្នកធំ ក្នុងកាលដែលលោក

ភ្លាត់ខុស, អត់ធន់ចំពោះសេចក្តីខ្សឹយហត់, សូម្បីខ្លួនយើងចេះដឹងច្រើន ជាងឬប៉ុនទឹងអ្នកធំក៏ដោយ ក៏កុំប្រព្រឹត្តច្រេងច្រែងជាងកណ្តាលដំនុំឬក៏ក់យឫកអំណាចស្មើនឹងអ្នកធំឡើយ, ចើនឹងសាកសួរប្រឹក្សា ឬសូមមតិឬក៏បញ្ចេញគំនិតរបស់ខ្លួនចំពោះអ្នកធំ ក៏ចូរកាំងប្រយ័ត្ន កុំណែនាំឲ្យអ្នកធំឡើងជំនោរអួតគុណសេចក្តីល្អ ហើយមើលងាយគេឬថ្នាក់ថ្នមឡើងហួសយសសក្តិនោះឡើយ ព្រោះជាហេតុបង្កែរចិត្តអ្នកធំឲ្យចេះស្អប់គេឯងលែងមានមេត្តាករុណាចំពោះអ្នកដទៃ, ចូរយើងសំដែងខ្លួនជាអ្នកសុប់សៀមប្រជៀងាយ មានកិរិយាវាចាសម្ងាត់ឲ្យអ្នកធំចេះស្រឡាញ់រាប់អាន មានមេត្តាករុណាថ្នាក់ថ្នមសេចក្តីចំរើនចំពោះអ្នកដទៃ ទឹង ជួយលើកដំកើងសរសើរអ្នកដទៃដោយសុចរិតពិត។ ។

៩ អ្នកល្អ តែងចេះគ្រប់គ្រងមនុស្សដទៃ - មនុស្សយើងតែងទៅរួមគ្នាជាពួកគណៈជានិច្ច ។ ក្នុងពួកគណៈមួយៗ រមែងមានទាំងអ្នកធំទាំងអ្នកតូច ហើយតែងមានសុខទុក្ខ វិនាសចំរើន ជាប់ទាក់ទងនឹងគ្នា ។ អ្នកតូចត្រូវនៅក្នុងការគ្រប់គ្រងរបស់អ្នកធំ មានអ្នកធំជាទីពឹង ។ អ្នកធំត្រូវគ្រប់គ្រងអ្នកតូច ទឹងអាស្រ័យអ្នកតូចជាកំឡាំង ។ តែការគ្រប់គ្រងអាចនឹងរៀបរយបាននោះ លុះតែអាស្រ័យមធ្យោបាយដ៏ប្រពៃផង ។ អ្នកល្អរមែងចេះគ្រប់គ្រងមនុស្សដទៃ ។ យើងនឹងទៅជាមនុស្សល្អ ត្រូវចេះគ្រប់គ្រងមនុស្សដោយឧបាយដ៏ឈ្លាសវៃដូចតទៅនេះ:

ក. - បើយើងមាននាទីជាអ្នកគ្រប់គ្រងមនុស្ស ចូរគាំងខ្លួនជាអ្នកធំប្រាសចាកអគតិ មានសេចក្តីខ្មៀងត្រង់ជាគោលរបស់ចិត្ត មានមេត្តាករុណា មុទិតា ឧបេក្ខាជាផ្ទៃនៃអធ្យាស្រ័យ, ធ្វើការណាមួយ ចំពោះនរណា ។ ចូរកុំលំអៀងព្រោះស្រឡាញ់ស្អប់ខ្ពាចនឹងលង់ខ្វៅ, កុំប្រកាន់ថាគេថាយើងឡើយ ព្រោះជាហេតុនាំឲ្យទៅជាមនុស្សត្រកឹតត្រមម, កុំប្រើអំណាចនេះនាវតួងតាង កុំគុំគួនឬញុះញង់ឲ្យអ្នកតូចបែកបាក់គ្នា ចូរធ្វើយុត្តិធម៌ឲ្យបានស្មើភាគគ្នាកុំរវាងអ្នកតូច ចូរអត់ធ្មត់ចំពោះអ្នកតូច ឬអ្នកដែលស្មើគ្នា កុំធ្វើឫកធំខាល់តែអ្នកតូចមកនៅចំពោះមុខមិនបាន ចូរចេះសម្រាលទុក្ខធុរៈអ្នកតូចនឹងមានកលខុបាយដ៏ប្រពៃ ល្មមឲ្យអ្នកតូចដែលនៅគ្រាមបង្គាប់បញ្ជាគោរពរាប់អានបាន ។

ខ. - កុំបៀតបៀនអ្នកតូច ត្រូវយកចិត្តគេមកប្រៀបនឹងចិត្តយើង គិតដល់ខ្លួនគេខ្លួនយើង កុំសំឡឹងឃើញតែលាភសក្ការៈដែលបានមកដោយធ្វើឲ្យអ្នកតូចក្តៅក្រហាយចិត្ត កុំទំលាក់កំហុសរបស់ខ្លួនទៅលើអ្នកតូច កុំបង្ខិនបង្ខោច បង្ខូចប្រយោជន៍ឬសេចក្តីសុខរបស់អ្នកដទៃ កុំធ្វើការព្រោះសំឡឹងឃើញប្រយោជន៍ផ្ទាល់ខ្លួន ត្រូវគិតដល់ប្រយោជន៍របស់អ្នកដទៃផង ត្រូវធ្វើតែកិច្ចការណា ដែលប្រយោជន៍របស់ខ្លួនក៏សម្រេចប្រយោជន៍របស់អ្នកដទៃក៏មិនខូច គឺធ្វើការងារដែលមិនប៉ះពាល់ទៅលើសេរីភាពរបស់អ្នកដទៃ ។

គ. - ត្រូវឲ្យមានចិត្តអាណិតមេត្តាចំពោះអ្នកធំអ្នកតូច ទាំងកាន
ពាក្យពាំងកាន់ការងារដទៃ។ រហូតដល់ញាតិសន្តាន អ្នកស្រុក អ្នក
ភូមិ ពន្យារផងទាំងពួង កុំឲ្យបែកបាក់គ្នាឬប្រកួតប្រកាន់គ្នា ចេះថ្នម
ចិត្តរបស់គេ មិនធ្វើទៅតាមតែទំនើងចិត្តខ្លួន ជាមនុស្សចិត្តធ្ងន់ មិនជា
មនុស្សត្រចៀកពាក់ ចិត្តស្មោលធាប់ទឹង ។

ឃ. - ត្រូវចេះធ្វើខ្លួនឲ្យសមគួរ គឺចេះដាក់ខ្លួន នឹង ចេះប្រតិបត្តិ
ខ្លួនចំពោះអ្នកធំអ្នកតូចនឹងអ្នកស្មើគ្នា រហូតដល់ញាតិសន្តាន មនុស្សបំរើ
មិត្តសំឡាញ់នឹងកៀនកក្តិកនស្រុកឲ្យសមគួរដល់ហាន: គឺនរណាគួរនឹង
ធ្វើសិទ្ធស្មាល ដៀស្តាប់បង្គាប់ ឬគួរចៀសវាង នរណាគួរបង្គាប់បញ្ជា-
ប្រើឲ្យធ្វើកិច្ចការថ្នាក់ណា ហើយកំចាត់ឲ្យធ្វើតាមសមគួរដល់ភូមិជាន់
របស់បុគ្គលនោះ។ ។

ង. - ត្រូវចេះរក្សាចិត្តអ្នកតូច ដូចយ៉ាងសំដែងមេត្តា ករុណា
ឲ្យបានរបៀបរៀ និយាយប្រស័យរាក់ទាក់ ធ្វើទឹកមុខរីករាយស្រស់ស្រាយ
ញញឹមញញែមជាដើមទៅរកអ្នកតូច ដើម្បីឲ្យគេបាននូវសេចក្តីរីករាយចិត្ត,
កុំធ្វើឫក ឬដំឡើងអំណាចសំដែងសេចក្តីកាចសាហាវ ចូរថែរក្សាទឹកចិត្ត
គេ ឲ្យចំធ្វើការងារតាមនាទីដោយសេចក្តីពេញចិត្តនឹងប្រាថ្នាប្រយោជន៍
សេចក្តីរុងរឿង ស្មោះត្រង់ចំពោះមុខគ្រូសួងពិតៗ ។

កិច្ចទាំង ៥ យ៉ាងនេះជាទំនៀមរបស់អ្នកល្អ; យើងគ្រប់គ្នា មិនថា
ជាន់ណាថ្នាក់ណាឡើយ បើប្រតិបត្តិតាមដោយត្រឹមត្រូវហើយ ក៏ក្លាយ

ទៅជាអ្នកល្អបានទាំងអស់គ្នា ព្រោះយើងធ្លាប់បានឮមកខ្លះហើយថា "អ្នកល្អត្រឡប់ធ្លាក់ខ្លួនទៅជាមនុស្សអាក្រក់ក៏មាន មនុស្សអាក្រក់ត្រឡប់តាំងខ្លួនឡើងជាមនុស្សល្អបានក៏មាន" ។ ត្រូវនឹងបុពណសុភាសិតថា "ឃ្មោកលិចអម្បែងអណ្តែត" ។ ពាក្យនេះមិនខុសពីអ្នកដែលកើតកង្វក្តក្តួលខាប ហើយត្រឡប់តាំងខ្លួនឲ្យជាអ្នកខ្ពស់ល្អ មានគេរាប់អានច្រើននោះទេ ព្រោះគេបានបែព្រឹត្តឲ្យត្រូវត្រង់តាមច្បាប់ប្រពៃណីនៃត្រកូលអ្នកល្អ ប្រៀបដូចអម្បែង ពិតមែនតែជារបស់លិចទឹក តែកាលបើមានប្រហោងធំនៅខាងក្នុងឬមានរបស់អណ្តែតទឹកនៅខ្ទុងផង ក៏អាចអណ្តែតបាន ។ ចំណែកអ្នកដែលកើតកង្វក្តក្តួលខ្ពស់ហើយត្រឡប់ទៅជាមនុស្សថោកទាបវិញនោះ ក៏ព្រោះតែខ្លួនបែព្រឹត្តឲ្យខុសច្បាប់ទំលាប់របស់ត្រកូលអ្នកល្អ ប្រៀបដូចឃ្មោក សូម្បីជារបស់អណ្តែតទឹក តែបើធ្លុះធ្លាយមានប្រហោងជុំវិញ ល្មមទឹកចូលទៅបានហើយ ក៏លិចទៅកន្លែងទឹកមិនខានដែរ ។

ដូច្នេះ មនុស្សប្រុស - ស្រីទាំងឡាយ ! ពេលនេះ សូមលោកនឹកកង្វល់ខ្លួនលោកថា "យសសក្តិដូចយល់សប្តិ រូបនោមលោមពណ៌ដូចផ្កាឈើ ជីវិតដូចផ្កែបន្ទោរ" ត្រូវកុំកាន់យកបរបស់អម្បាលនេះជាគ្រឿងអាងថា ខ្លួនជាអ្នកល្អ នឹង កុំបណ្តែតបណ្តោយខ្លួនដោយអាងថាជាមនុស្សថោកទាបឡើយ ។ ចូរមានមារយាទល្អ មានចិត្តល្អ មានសេចក្តី

ស្មោះត្រង់ មានសេចក្តីសុចរិត រក្សាកិត្តិយស ស្រឡាញ់សន្តិសុខ តាំងគោលចារឹក នឹង ចេះគ្រប់គ្រងខ្លួនរហូតដល់អ្នកដទៃឲ្យបានកុំភាន ។ ច្បាប់នេះ បើលោកអ្នកធ្វើតាមបានពេញលេញល្អហើយ ក៏នឹងប្រកាសខ្លួនឲ្យមនុស្សក្នុងលោកដឹងថា "ខ្លួនលោកអ្នកជាមនុស្សល្អ មាននិស្ស័យជាអ្នកល្អ" ពិតមែន ។

សូមក្រុមញាតិ	ជាតិខ្មែរ	សែឆ្ងាយជិត
ទំនៃគិត	ធ្វើច្បាណា	ឲ្យបានល្អ
ហើយជួយផ្សាយ	រឿងនេះ	ទៅតៗ
អ្នកចង់ល្អ	បានដឹង	គង់ធ្វើតាម ។
តាំងអ្នកធំ	ក៏សូម	តាំងចិត្តស
ច្រឹត្តល្អ	រៀវៃ	ដែលលោកហាម
ដើម្បីជន	សម្ងួយ	ងាយធ្វើតាម
គោលបំភាម	ដែលយើង	ណែនាំអើយ !!!

(មានត)

អ័ង្គ្លេណា ៖ សិមប៉ាណា

រឿងព្រៃឥណ្ឌូ

លោក ធែង - ជ្រីវ សង្ស្កាបារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង (តមក)

នាងសៅសួរថា : ចុះត្រូវថែបងឯង តើយ៉ាងដូចម្តេច? ។

– សូមទ្រង់ព្រះមេត្តាប្រាំស! ឲ្យគេលាងខ្លួនព្រះបង្គំពាល់ព្រឹកទឹងទឹកថ្ងាមុនថ្ងៃរះ ឲ្យគេបែងបបរលាយទឹកដោះពាល់ព្រឹកដល់ខ្លួនព្រះបង្គំបរិភោគ ទឹងកំទេចឆ្អឹងមួយស្លាបព្រាពាល់ថ្ងៃផង ។

– បើខ្ញុំដឹងប្រាកដថាបងមនោម័យឯងនឹងអាចជួយខ្ញុំកុងកិច្ចការនេះបាន នោះខ្ញុំក៏មានបំណងចង់ថែដូចបងនិយាយប្រាប់ដែរ ។

សេះឆ្លើយថា : បពិត្រព្រះនាងជាម្ចាស់! សូមទ្រង់ពិសោធមើលនោះទ្រង់នឹងមិនស្តាយក្រោយឡើយ ។

នាងសៅទំថែទាំយកចិត្តទុកដាក់ តាមរបៀបដែលសេះប្រាប់ ។ លុះដល់ថ្ងៃទី ១០ សេះនោះត្រឡែងខ្លួន ដំឡើងកេសរ មានកាយធាត់ធំហើយរហ័សដូចមុនៗ ។

បពិត្រព្រះនាងសំឡាញ់! សូមព្រះជាម្ចាស់ញ៉ាងបុណ្យទឹងជ័យជំនះឲ្យសម្រេចដល់ទ្រង់ជាកុំខាន ព្រោះទ្រង់បានថែទាំខ្លួនព្រះបង្គំនឹងអនុញ្ញាតឲ្យខ្លួនព្រះបង្គំបំពេញកិច្ចនៃខ្លួនព្រះបង្គំម្តងទៀតក្នុងលោក,

ហេតុដូច្នេះ សូមទ្រង់ប្រោសមកចុះ តើឥឡូវនេះទ្រង់មានរាល់អ្វី ? ទូលព្រះបង្គំត្រូវធ្វើអ្វី ? ។

- ខ្ញុំត្រូវការចង់ទៅនៅបំរើព្រះចៅកាធិភដ ជាចៅហ្វាយនាយនឹង ត្រូវការកេរឹបក្បាត្រមាំងមគ្គុទ្ទេសក៍ ។ តើបណ្តានាម៉ឺនតូចធំទាំងអស់ ខ្ញុំត្រូវរើសយកអ្នកណា ? ។

សេះធ្វើយថា: បើទ្រង់ស្តេចយាងទៅជាមួយនឹងទូលព្រះបង្គំ សូមទ្រង់កុំព្រួយបារម្ភអ្វីឡើយ មិនបាច់ចាំរកអ្នកណាទៀតទេ ។ ទូលព្រះបង្គំនឹងបំរើទ្រង់ដូចកាលដែលទូលព្រះបង្គំបំរើព្រះវរបិតាដែរ ។ តិចតួចដែលសំខាន់គឺត្រូវព្រះនាងគោងតែស្តាប់ទូលព្រះបង្គំប៉ុណ្ណោះជាការស្រេច ។

នាងភៅកំចាប់ប្រដាប់អីវ៉ាន់ភ្លាម ដើម្បីនឹងធ្វើដំណើរ ។ ព្រះនាងទ្រង់ព្រះកន្សែងស្អាត តែកិច្ចតាក់តែងលំអកាយយ៉ាងកណ្តាល នាងយាងទៅកាន់សំណាក់ព្រះវរបិតាហើយសូមថ្វាយបង្គំលាថា: ឋពិតព្រះរាជបិតា ! សូមព្រះជាម្ចាស់ជួយរក្សាទូរព្រះអង្គ នឹង សូមឲ្យផ្តល់នូវសេចក្តីសុខកាយសប្បាយព្រះហឫទ័យដល់ទ្រង់ជានិរន្តរ៍ ។

- ម្នាលកូនស្រីសំឡាញ់ព្រះបិតា ! សូមឲ្យដំណើរនៃនាងជាសុខ ប៉ុន្តែប្រយ័ត្នកុំភ្លេចបណ្តាំបិតា ។ បើមានគ្រោះថ្នាក់អ្វីមកដល់ ត្រូវកូនស្រីនឹកដល់ព្រះជាម្ចាស់ ព្រោះសេចក្តីល្អនឹងជំនួយទាំងប៉ុន្មានកើតឡើងតែពីព្រះអង្គ ។ នាងភៅទូលសេចក្តីសន្យាទាំងអស់ហើយក៏លាចេញទៅ ។

ព្រះពាជាធ្វើដូចមុនទៀត ។ ព្រះអង្គស្តេចទៅតាមផ្លូវមាន៏មុននាង ៗ ហើយឈប់ចាំនាងត្រង់ស្ពានផែកដីដែល ។ ប៉ុន្តែកំពុងធ្វើដំណើរ, សេះបាននិយាយប្រាប់នាង អំពីកលល្បិចដែលព្រះពាជបិតាបំរុងទុក ពិសោធន៏ល្បងចំពោះសេចក្តីភ្លាហាននៃនាង តើព្រះនាងអាចដោះខ្លួនរួច ឬពុំរួច តើព្រះនាងអាចនឹងទាញយកកេរ្តិ៍ឈ្មោះបានឬទេ ? ។ លុះបានដល់ស្ពាន ចចកសុះមកកេនាង ចចកទុះសម្លីមណាស់គួរស្បែង ក្អែកដំត្រឡប់លឿនថ្លៃ មាត់ហាចឆ្កែង អណ្តាតក្រហមដៅដូចក្តៅឆ ចង្កួមសស្វាច ហើយស្រែកគំហកជាក់ ។ តាមទំនង៏ចចកទេះដូចអត់អាហារមួយថ្ងៃរួចមកហើយ ។ ប៉ុន្តែ ខណៈដែលចចកសុះចំប្រាមកកេនាង ៗ ទាំង៏ក្រចកយ៉ាង៏មុតនោះ ព្រះពាជធីតាគោះសេះឲ្យលោតរំលងចចកនឹងជាវនៅដៃ, ហើយបើកុំតែចចកបើកផ្លូវឲ្យ សមក៏មានខ្លួនជាប់ជាកំណាត់មិនខាន ព្រោះនាង៏បានថ្វាយសេចក្តីទុកចិត្តទៅព្រះជាម្ចាស់ស្រេចអស់រលើង នាង៏មិនធ្លាក់លើងទេ ទោះបីម្តេចម្តាត្រូវតែញ៉ាំង៏កិច្ចបំណង៏ឲ្យសម្រេច ។

ព្រះពាធីតាឆ្ងង៏ស្ពានរួចយ៉ាង៏សង្ហាតតកោតញ៉ញ៉ើត ដូចបុរសអាជានេះឯ ។ ព្រះពាជាតាំង៏ព្រះហ្ឫទ័យក្លាហានជាច្រើ រត់តាមផ្លូវមាន៏ចាំស្កាត់នាង៏ពីខាង៏មុខទៀត ។ ព្រះពាជានិម្មិតស្ពានប្រាក់ ហើយតំណែង៏ព្រះកាយជាសង្ឃ នៅចាំនាង៏ត្រង់ពីនោះ ។

សេះបានឈប់នាងសៅហើយជាស្រេច អំពីរបស់គ្នដែលនាងត្រូវឆ្លងប្រទេសនឹងៗបាយដែលនាងត្រូវដោះខ្លួនឲ្យរួច ដើម្បីធ្វើខ្លួនឲ្យបានដល់ទីបំផុតបែបណា ។

លុះបានដល់ស្ពានឈូកក់ សត្វសិង្ហលេចភ្នែតឡើង ក្រចកដូចកណ្តៀវ ម្មាត់ហាយ៉ាងធំបំរុងលេបទាំងសេះទាំងអ្នកជិះ ចង្កូមឆ្ងាយវែងដូចក្តក់ដំរី ។ ពៃព្រឹក្សាចំការស្រែសឹងរំតើបញាប់ញ័រដោយសំរែកសត្វសិង្ហទាំងអស់ ។ ក្បាលវាគួរស្បែងប្រកបដោយកេសរបះឡើងក្រញាងស៊ុបខ្លួបអាចធ្វើឲ្យគួសត្រូវភ័យស្លុតស្ទើរឃាត់ស្មារតី ។ ប៉ុន្តែនាងសៅមានសេះជាអ្នកបញ្ជោរចិត្តលើកជាវគ្រីរឹងសិង្ហឥតរួញរា បើប្រសិនជាកុំតែវាត់ចូលជែកគ្រាមស្ពានទាន់ កុំអីវាមុខជាមានកាយជាប់ជាពិបិកំណាត់មិនខាន ។ ខណៈនោះ នាងឆ្លងស្ពានឈ្លក់ហួសទៅ សូមអរគុណចំពោះព្រះជាម្ចាស់ ហើយនឹកក្តងចិត្តថាមិនដឹងជាមានអ្វីទៅចាំយាយីខាងមុខទៀតទេ ។

នាងសៅដែលតាំងពីប្រសូតមក មិនដែលចេញពីកំផែងប្រាសាទសោះស្រាប់តែស្រឡាំងកាំងនឹងឥដ្ឋារម្មណ៍នៃធម្មជាតិ ដែលមានទៅពាសពេញទាំងវាល ។ ជួនកាលព្រះរាជធីតាក្តកព្រះហឫទ័យចង់ចុះពីសេះទៅប្រលេះបុប្ផាផ្សេងៗ យកមកធ្វើជាផ្កងប្រដាប់កាយ ព្រោះតែដែលនាងបានឃើញក្នុងទីនេះ គឺសុទ្ធតែផ្កាទាំងអស់, ជួនកាលព្រះនាងចង់ឈប់

សម្រាកព្រះកាយក្រោមម្លប់ឈើ ដើម្បីទំនែងនឹងព្រះសណ្តាប់ធ្វើសំខ្មៀង
នៃបក្សីយ៉ាងពីរោះប្លែក បើអ្នកណាបានស្តាប់មុខជានឹងដេកលក់មួយ
រំពេច, ដូនកាលនាងចង់ទៅរកផ្លែ ដែលមានទឹកថ្លាត្រជាក់ដូចកញ្ចក់
ហើយហូរចេញមកពីថ្មចង្កេះភ្នំ ; ព្រះនាងសព្វព្រះហឫទ័យទតព្រះនេត្រ
មើលទឹកហូរពេនចុះពេនឡើងដូចពស់វារ នឹង ទ្រនំព្រះសណ្តាប់ធ្វើសូរ
ដែលរាប់ខ្ទឹងឡើងធ្វើសកាពស្មៅគាំងឡាយ ។ ប៉ុន្តែសេះពុំព្រមឲ្យព្រះ
នាងឈប់ ចេះតែបង្ខំឲ្យព្រះនាងប្រញាប់ទៅមុខទៀត ហើយនិយាយ
ច្រាបថា ព្រះរាជបិតានឹងទៅធ្វើការពិសោធន៍ម្តងទៀត ។ សេះបាន
ពន្យល់ច្រាបព្រះនាងទៀត អំពីទំនងដែលនាងត្រូវធ្វើដើម្បីឲ្យបានឆ្ងន
ផុតនូវឧបស័គ្គនោះ ។

នាងភ្ញៀងស្តាប់ដំបូន្មានសេះគាំងអស់ ហើយសព្វព្រះហឫទ័យ
ធ្វើតាមគ្មានខ្វះកន្លែងណា ព្រោះនាងបានសង្កេតទៅឃើញថា សុទ្ធតែ
បានសេចក្តីចំរើនគាំងអស់ ។

ព្រះរាជាសុះទៅពីខាងមុខជាថ្មីទៀត ទ្រនំនិមិត្តស្តានមាស ក្រឡា
ព្រះកាយជានាគរាជក្បាលដប់ពីរ ហើយពួនទៅក្រោមស្តានរង់ចាំនាង ។
កាលដែលនាងភ្ញៅមានបំណងចង់ឆ្លងស្តាន នាគសុះឡើងរាំងផ្លូវគាំងក្អែក
គួរខ្លាច ហើយយកកន្ទុយគ្រវីទៅមក ព្រួសភ្លើងចេញតាមមាត់ អណ្តាត
ក្រហមឆេះស្រួចដូចព្រួញ ។ នាងភ្ញៅតក់ស្លុតស្ទើរបាត់ស្មារតីព្រឺព្រះ

សិរសោ ព្រះកេសាឡើងក្រញាង ។ សេះលុះឃើញព្រះនាងបាត់សតិ ដូច្នោះ ក៏លើកព្រះនាងឡើងវិញ ហើយចាប់ខ្លួរកិច្ចដែលត្រូវធ្វើ ។ ព្រះពជធីតាជីងខ្លួនឡើងវិញក៏ញាក់សេះភ្លាម គាន់បង្ក្រៀយ៉ាងខ្លាប់ ដោយដៃខាងឆ្វេង ដៃស្តាំគាន់ជាវាំបាយសេះដាក់នាគ ។

ការតយុទ្ធគ្នាតាំងនៅអស់មួយម៉ោង ។ សេះនាំនាងពៅសុះទៅ ខាងបម្រៀងជានិច្ច ដើម្បីឲ្យនាងពៅមានឧកាសអាចកាប់ក្បាលនាគបាន ប៉ុន្តែបច្ចាមិត្តក៏ឆ្លាតប្រសប់ការពារខ្លួនណាស់ដែរ ។ លុះទីបំផុត នាងពៅ សម្រេចផ្តាញ់នាគបាន ដោយធ្វើឲ្យនាគត្រូវរបួសពីរបីកន្លែង នាគពជ ក៏ក្លាយខ្លួនជាមនុស្សវិញ ។

នាងពៅឃើញព្រះពជានៅឥម្មុ ហើយមិនសុខចិត្តដឿថាជា ព្រះពជបិតាមែន ។ ប៉ុន្តែព្រះពជាចាប់នាងឧបថើបត្រង់ថ្ងាសហើយ មានព្រះពជឧដ្ឋារថា:

បិតាពិនិត្យទៅឃើញថា កូនឯងពិតជាស្រីក្សាហានមែនហើយ, កូនឯងចេះរើសយកសេះនេះមក បើកុំដូច្នោះ កូនឯងទៀងតែត្រូវប់ទៅ វាំងវិញដូចជាបង ។ ឯទៀតមិនខាន ។ បិតាមានសេចក្តីសង្ឃឹមខ្លួកជាស្រេច ថាកូនស្រីនឹងញ៉ាំងកណ្តាលកិច្ច ដែលកូនត្រូវធ្វើដោយចិត្តស្ម័គ្រ ចានសម្រេចដល់ទីបំផុត ។ ហើយចូរកូនកុំភ្លេចបណ្តាំបិតាឲ្យសោះ ចាំងចូរធ្វើតាមសេះកុំបីខ្ជោយឡើយ ។ បើធ្វើដូច្នោះហើយ យើងនឹង ចានជួបគ្នាវិញជាប្រាកដ ។

នាងគៀកក្រាបបង្គំទូលស្នងព្រះឧត្តារវិញថា: បពិត្រព្រះពជបិតា! សូមព្រះជាម្ចាស់ស្តាប់ពាក្យព្រះអង្គចុះ ហើយសូមឲ្យព្រះកុមារខ្ញុំឲ្យប្រកបដោយសេចក្តីសុខតរៀងទៅ ។ នាងចាប់ព្រះហស្តព្រះរាជាចុម្ពិត (ថើប) ហើយដនទាំងពីរក៏បែកគ្នាទៅ ។

ខាងក្រោយការធ្វើដំណើរយ៉ាងយូរ នាងគៀបានដល់គិរីបពិតទាំងឡាយដ៏ខ្ពស់ ។ ហើយខ្ញុំទតឃើញយក្សពីរកំពុងតែច្បាំងគ្នាទៅកន្លែងនោះ ។ យក្សទាំងពីរនេះច្បាំងគ្នា ៩ ឆ្នាំហើយ តែទៅមិនទាន់ដឹងចាញ់ឈ្នះនៅឡើយ គឺជាការតយុទ្ធស្មើរស ។ លុះអសុរីទាំងពីរក្រឡេកឃើញព្រះនាងកាលណា រាបានសន្និដ្ឋានថា ព្រះនាងជាយុវជនខ្លាំងពូកែ; រួចអាមួយស្រែកអង្វរថា បពិត្រព្រះអង្គម្ចាស់! បពិត្រព្រះអង្គម្ចាស់! សូមព្រះអង្គអាណិតជួយច្បាំងទូលព្រះបង្គំ; លុះកិច្ចនេះសម្រេចហើយ ទូលព្រះបង្គំនឹងបំរើខ្ញុំវិញជាមិនខាន ។ យក្សមួយទៀតស្រែកអង្វរថា: បពិត្រព្រះអង្គម្ចាស់! សូមខ្ញុំជួយទូលព្រះបង្គំវិញ, លុះបានឈ្នះហើយ ទូលព្រះបង្គំនឹងថ្វាយសេះមួយយ៉ាងដំនាញឈ្មោះសុរាបកា ។

នាងគៀសួរសេះថា: ឃើងត្រូវជួយយក្សណាល្អ? ។ សេះទូលថា: ត្រូវជួយយក្សមួយដែលសន្យានឹងថ្វាយសេះឈ្មោះសុរាបកា ។ សេះនោះមានវិជ្ជាគុណពាងខ្លាំងណាស់ ព្រោះវាត្រូវជាប្អូន

ទូលព្រះបង្គំ ។ ព្រះពាជធីតាបរសេះបំផ្ទាយសំរុកចូលទៅកាប់យក្សតែមួយដាវ យក្សនោះដាច់ខ្នងជាពីរបីកំណាត់ ស្ងាប់មួយរំពេច ។

យក្សមួយដែលរួចពីគ្រោះកាច ស្ទុះមកឧបវាតព្រះនាង ហើយសូមអរព្រះគុណ ។ រួចក៏នាំព្រះនាងទៅដើម្បីនឹងថ្វាយទូរសេះឈ្មោះសុរ្យាបភាតាមពាក្យសន្យា ។ អ្នកទាំងអស់គ្នាក៏បានទៅដល់រាំងយក្ស ។ ម្ចាយយក្សដែលឃើញកូនរួចរស់ជីវិត ក៏មានសេចក្តីត្រេកអរក្រៃលែងប្រៀបគ្មាន ហើយសំដែងសេចក្តីអរគុណជាអនេកប្បការ ចំពោះព្រះអគ្គ្ជម្ចាស់ហាវហានដែលបានស្រង់ជីវិតកូននៃអាត្មា ។

ព្រះពាជធីតាសុំកន្ទែងឈប់សម្រាកព្រះកាយបន្តិច ព្រោះនឿយហត់អស់កំលាំងដោយធ្វើដំណើរផ្លូវឆ្ងាយ ។ គេក៏ថ្វាយបន្ទប់មួយដ៏សមគួរដល់ព្រះនាង ហើយទុកព្រះនាងឲ្យនៅផ្ទាំតែឯកឯង ។ ខណៈនោះព្រះនាងធ្វើកលជាមើលថែសេះសិន ព្រះនាងលួចសួរសេះថា: តើនឹងមានគ្រោះថ្នាក់អ្វីដល់ព្រះនាងដែរឬទេ? ។ សេះក៏បានឱ្បាបប្រាប់សព្វគ្រប់ទូរទុបាយកលផ្សេងៗដែលត្រូវធ្វើ ។

នាងយក្ខិនីម្ចាយយក្សមានសេចក្តីពិការពេក ហើយនិយាយប្រាប់កូនថា: ព្រះអគ្គ្ជម្ចាស់ហាវហានដែលជួយស្រង់ជីវិតកូនឯង ប្រហែលជាស្ត្រីទេ ហើយស្ត្រីដែលមានរិទ្ធិដូច្នេះល្អយកធ្វើជាប្រពន្ធណាស់ ។ ប៉ុន្តែកូនគាត់ធ្វើយថា: កង៌លោកនេះមិនមានស្ត្រីណាអាចកាន់ព្រះខ័ន

ចូលច្បាំងយ៉ាងអង់អាចដូចជាបុរសជាតិឡើយ ។ នាងយក្ខិនីចង់ធ្វើសេចក្តីសង្ស័យឲ្យលេចចេញច្បាស់ដឹងឯង ។ ពេលវាត្រី នាងយក្ខិនីយកផ្កាទៅលួចដោតនៅនាក្បាលដំណេកកូនរបស់ខ្លួនទីឯងនាងវេ ព្រោះថាបើផ្កានោះស្វិតគឺជាតួអង្គបុរស បើផ្កានោះស្រស់ជាតួអង្គស្ត្រី ។

ព្រះរាជធីតាតាមដំបូន្មានរបស់សេះ ទ្រង់តើនឡើងពេលមុនថ្ងៃរះ គឺជាវេលាដែលគេពាល់គ្នាកំពុងដេកស្រួល ក៏ទ្រង់យាងដោយចំអើតព្រះបាទយ៉ាងសន្សឹមៗ ហើយទ្រង់ចូលក្នុងបន្ទប់យក្ស យកផ្កាដែលដោតនៅឯក្បាលព្រះក្រឡាបន្ទំរបស់ព្រះនាង ទៅដោតឯក្បាលដំណេកយក្ស យកផ្កាឯក្បាលដំណេកយក្សមកដោតទុកឯក្បាលក្រឡាព្រះបន្ទំរបស់ព្រះអង្គវិញ រួចព្រះនាងទ្រង់ត្រឡប់ផ្លូវទៅវិញយ៉ាងស្រួល ។

លុះព្រឹកឡើងនាងយក្ខិនីភ្ញាក់ពីព្រលឹម ក្រែកសូវរត់ទៅមើលផ្កាដែលនៅឯក្បាលដំណេកកូនរបស់ខ្លួនឃើញស្វិត រួចរត់ទៅមើលផ្កាដែលនៅឯក្បាលក្រឡាព្រះបន្ទំនៃព្រះរាជធីតាក៏ឃើញស្វិតដូចគ្នា ។ នាងយក្ខិនីនឹកឆ្ងល់ពេក ប៉ុន្តែគាត់នៅតែមិនទាន់អស់ចិត្ត ហើយច្បាប់កូនថា: ច្បាកដជាមិនមែនប្រុស, អញស្តាប់សំដីដែលនិយាយមើលពាងបែបហ្នឹង មើលទៅសក់ធ្លាក់សំយាកមកលើស្មា គន់មើលទៅលំអនៃទឹកមុខ នឹងក្អែកធំក្រឡេតបែបហ៎ស ដៃតូចជើងឆ្នាះដូចស្រីទេពអប្សរ គឺជាស្ត្រីច្បាកដ ប៉ុន្តែដែលឯងមើលពុំយល់ដោយសារនាងទ្រង់ប្រដាប់ចម្បាំងប៉ុណ្ណោះ ។ តមក ជនពាំងពីរគឺតធ្វើការតិះសោធន៍ម្តងទៀត ។

ខាងក្រោយដែលគេជួនអុណាសុវត្ថិដល់គ្នាទឹងគ្នាតាមទំនៀមហើយ, កូនយក្សនាំនាងទៅសៀលក្នុងសួនច្បារ ។ វាបង្ហាញផ្លាផ្សែងៗដល់ព្រះនាង ព្រមទាំងអញ្ជើញព្រះនាងឲ្យបេះផ្លែទឹងចើបលេងកំសាន្ត ព្រោះសុទ្ធតែជាផ្លាមានក្លិនក្រអូប ។ ប៉ុន្តែព្រះនាងនឹកដល់បណ្តាំសេះ ក៏ទ្រង់សួរទៅយក្សវិញថា: ចុះហេតុអ្វីក៏នាំយើងមកកាន់សួនច្បារតាំងពីព្រលឹមអីម្ល៉េះ ដើម្បីរមិលមើលផ្លាដូចជាស្រី ព្រោះកិច្ចជាប្រថមគឺត្រូវយើងទៅមើលសេះឯក្រោល តើវាសុខសប្បាយទេឬដូចម្តេច? ។

កូនយក្សយកពាក្យមានេះមកច្រាប់ម្តាយ ប៉ុន្តែនាងយក្ខិនីនៅតែមិនព្រមចុះចាញ់ ហើយនាងម្តាយសម្រេចកូនឲ្យលាការពិសោធន៍ជាទីបំផុតមួយទៀតមើល ។ គឺថាត្រូវនាំព្រះអង្គម្ចាស់ទៅក្នុងបន្ទប់ដែលជាក់ទុកសុទ្ធតែគ្រឿងអាវុធ ហើយសូមឲ្យព្រះអង្គម្ចាស់ជ្រើសរើសយកអាវុធណាមួយ, ប្រសិនបើការជ្រើសរើសនេះធ្លាក់ទៅលើអាវុធណាដែលលំអដោយគ្រឿងពេជ្រ-មាសនោះ កុំបាច់សង្ស័យ គឺជាកជាការរើសនៃស្ត្រី ។

ខាងកត្តកិច្ច កូនយក្សនាំព្រះអង្គម្ចាស់ហាវហានទៅក្នុងបន្ទប់ជាក់អាវុធតាំងពីឡាយ ។ ក្នុងទីនោះ មានអាវុធជាក់ដរមែបជាដួរគ្រប់បែបគ្រប់យ៉ាង ខ្លះជាអាវុធលាតសាម័ញ្ញ ខ្លះជាអាវុធប្រដាប់ដោយគ្រឿងត្បូងពេជ្រដាំជាលំអ ។ (មានត)

សព្ទចាក់ផ្តែជាខ្មែរ

របស់

គណៈកម្មការវប្បធម៌

ពុទ្ធសាសនបណ្ឌិត្យ ជ្រើស

សូមកែតាម

សព្ទចាក់ផ្តែជាខ្មែរ ដែលមានចុះផ្សាយក្នុងកម្ពុជសុរិយា ឆ្នាំ ១៩៤៩-៥០, មានសព្ទខ្លះត្រូមជំនុំវប្បធម៌ត្រូវកែប្រែជាថ្មី សព្ទខ្លះ ចោះពុម្ពខុសភ្លាត់ ។ ដើម្បីទុកជាច្បាប់ត្រឹមត្រូវ ទាំងជាប្រយោជន៍ ដល់ផ្លូវសិក្សាតទៅ សូមកែតាមដូចតទៅនេះ :

កម្ពុជសុរិយា

លេខ ៧ ខែកក្កដា ឆ្នាំ ១៩៤៩

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
Conseil d'état	Conseil d'Etat	៥០៩	១៦
ក្រសួងរដ្ឋមន្ត្រី	ក្រសួង	៥១០	១
Chef- de Serdice	Chef de Service	៥១០	៦
Chef de Bueau	Chef de Bureau	៥១០	៨
អក្ខរាវិរុទ្ធនៃពាក្យ	អក្ខរាវិរុទ្ធនៃពាក្យ	៥១២	១០

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
១៧-៤-៤៩	១៧-២-៤៩	៤១២	១៣
Fanatiste	Fanatique	៤១៣	៧
សន្ទិសិទ្ធិ	សន្ទិសិទ	៤១៤	៤
សុខុមប្រាណ	អតិសុខុមប្រាណ	៤១៤	១១
សុខុមទស្សន៍	អតិសុខុមទស្សន៍	៤១៤	១២

លេខ ៨ ខែសីហា ឆ្នាំ ១៩៤៩

កងចលនៈ	កងចល័ន	៤៨២	១០
បិត្តនឹងជឹង	បិត្តនឹងធឹង	៤៨២	១៦
អគ្គពិនិត្យនៃជាតិ	អគ្គពិនិត្យនៃប្រជាជាតិ	៤៨៣	២
អនុសេនីយ	អនុសេនីយត្រី	៤៨៤	១០
Séconde maître	Second maître	៤៨៦	១
វរសេនាឯក	វរនាវីឯក	៤៨៦	១៣
វរសេនាទោ	វរនាវីទោ	៤៨៦	១៤
វរសេនាត្រី	វរនាវីត្រី	៤៨៦	១៥
Le feu ការបាញ់	Feu ! បាញ់ !	៤៨៨	៣
Compagne	Campagne	៤៨៨	៤
បាំឆ្នក់	ពួនបាំឆ្នក់	៤៨៨	៨

លេខ ៩ ខែកញ្ញា ឆ្នាំ ១៩៤៩

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
អ្នកកាន់កាប់ការ	អ្នកកាន់កាប់ការ - បណ្ណា-		
	ធិការ	៦៧៦	៣
Camarad	Camarade	៦៨០	៨
Sympathi	Sympathie	៦៨១	១
ការពិសាធន៍	ការពិសោធន៍	៦៨១	៤
បរិមាត្រា	បរិមាត្រ	៦៨១	៧
វិជ្ជមាត្រា	វិជ្ជមាត្រ	៦៨១	៨

លេខ ១០ ខែតុលា ឆ្នាំ ១៩៤៩

autipathic	autipathie	៧៣៥	៧
អធិការនាយការធ៍បឋម-			
សិក្សា	អធិការធ៍បឋមសិក្សា	៧៣៥	១១
គ្រូបង្ហាត់សាលាទិកនិក	គ្រូបង្ហាត់សាលាតិកនិក	៧៣៦	៣
សមភាព	សមភាគ	៧៣៨	៧
សមភាគ	វិសមភាគ	៧៣៨	៨
Distincion honorifique	Distinction houorifique	៧៤២	៤

លេខ ១១ ខែវិច្ឆិកា ឆ្នាំ ១៩៤៩

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
ការប្រគល់វិញ្ញាបនប័ត្រ ជានប្រើអស់ហើយ	ការប្រគល់វិញ្ញាបនប័ត្រ ដែលប្រើអស់ហើយ	៨២៨	២
Le S. E. C. I. R. Certifie que l'Opération ne donne bien	Le S. E. C. I. R. certifie que l'opération ne donne pas droit.	៨២៨	១២
Cette prorogation devra Obligatoirement être demandée deux Semaines un moins	Cette prorogation devra obligatoirement âtre demandée deux semaines au moins		
Port ou Bureau duonier	Port ou Bureau Douanier	៨២៩	៨
វិជ្ជាហាន:	វិជ្ជាហាន	៨៣០	១៣
កណ្ណកេត	កណ្ណកេត	៨៣១	៧

លេខ ១២ ខែធ្នូ ឆ្នាំ ១៩៤៩

merveilleux	Le merveilleux	៩០៧	៥
Est autorisé ouvrir à	Est autorisé à ouvrir à	៩១២	៣
(. . . មានបទបញ្ញត្តិ កងំចំពូក ៨	អ្នកទទួលអនុញ្ញាតត្រូវ ប្រតិបត្តិតាម. . . ចំពោះ បទបញ្ញត្តិកងំចំពូក ៨. . .	៩១២	៨

កម្ពុជសុរិយា

លេខ ២ ខែកុម្ភៈ ឆ្នាំ ១៩៥០

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
Vendredi 17-9-49	Vendredi 17-9-48	៦៦	២
ច្រាជ្រ	ច្រាជ្រ, បណ្ឌិត	៨៥	១៥
ច្រាជ្រា	ច្រាជ្រ, គតិបណ្ឌិត	៨៥	១៦
Service de la flotte	Service de la Flottille	៨៦	១៤
ស. វេជ្ជបណ្ឌិត	ស. វេជ្ជបណ្ឌិតា	៨៧	៣
ចាន់ច្រាសប្រធាន	យើង		
	ចាន់ច្រាសព្រះរាជទាន	៨៨	១៤
Direction des Atelliers de la flotte	Direction des Ateliers de la Flottille	៩១	១០
Identification	Identificateur	៩២	១៣
អធិការគង្គា នឹងរុក្ខា	អភិបាលគង្គា នឹងរុក្ខា	៩៣	៧
Inspecteur des Eaux et Forèts (mot ajouté)	អធិការគង្គា នឹងរុក្ខា	៩៣	៧

(ពាក្យថែម)

លេខ ៥ ខែឧសភា ឆ្នាំ ១៩៥០

ប្រកែតិនិន	ប្រតិនិន	៣២៩	១៥

លេខ ៦ ខែមិថុនា ឆ្នាំ ១៩៥០

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
លទ្ធិសុទិដ្ឋិ	លទ្ធិសុទិដ្ឋិនិយម	៤១២	១៣
លទ្ធិទុទិដ្ឋិ	លទ្ធិទុទិដ្ឋិនិយម	៤១២	១៤
អ្នកសុទិដ្ឋិ	អ្នកសុទិដ្ឋិនិយម	៤១៣	៣
អ្នកទុទិដ្ឋិ	អ្នកទុទិដ្ឋិនិយម	៤១៣	៤
អ្នកកត់កិនសត្វ	កត់កិនសត្វ	៤១៣	១៨
traqueur	trayeur	៤១៦	២

លេខ ៨ ខែសីហា ឆ្នាំ ១៩៥០

Amlassadeur	Ambassadeur	៥៨១	១៦

លេខ ៩ ខែកញ្ញា ឆ្នាំ ១៩៥០

ហេតុគហបតី	គហបតី	៦៦០	៣

លេខ ១០ ខែតុលា ឆ្នាំ ១៩៥០

	១៦-៩-៤៩	៧៣១	៦
អត្តាចិនភាព	អត្តាធិនភាព	៧៣១	៧
សេចក្តីស្តាយ... មមៃ	សេចក្តីស្តាយគ្រោយ		
គ្រោយ	" មមៃ	៧៣២	៦

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
ឈុទ	ឈុត	៧៣២	១២
Immigrtion ក្រុមត្រួតត្រាជនចូលស្រុក	Immigration ក្រុមអន្តោប្រវេសន៍	៧៣៥	១០

លេខ ១១ ខែវិច្ឆិកា ឆ្នាំ ១៩៥០

ផែនដី	ផែនដី	៨២៥	៦
ពាណិជ្ជកម្ម	បទពាណិជ្ជកម្ម	៨២៦	៥
អាជ្ញា	បទអាជ្ញា	៨២៦	៦
សង្គ្របិកសមាជិក	សង្គ្រាមិកសមាជិក	៨២៦	៩
La légion étrangérs	La Légion Etrangère		
កងសារបរទេស	កងអាសាចរទេស	៨២៨	៤
hamonie	harmonie	៨២៨	១៤

លេខ ១២ ខែធ្នូ ឆ្នាំ ១៩៥០

ផ្តុតផ្តង់	សិស្សផ្តុតផ្តង់	៩០២	២
យកចិត្តទុកជាក់	សិស្សយកចិត្តទុកជាក់	៩០២	៣
Rasemblement	Rassemblement	៩០២	១០
បញ្ជាការសេនាធិការ	បញ្ជាការសេនាធិការ	៩០២	១៨
គ្រូប្រឹងប្រែង	គ្រូប្រឹតប្រែង	៩០៤	១

កណ្ឌទី ៩

ឧកញ៉ាវិបុលរាជសេនា ទូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវែឆ្លាសបើបានអាន
ទឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

ឡៅពី កួនអ៊ិ នឹងតៀហ៊ុយនាំទាហាន ៣ ពាន់ចូយ ជាទ័ពមុខ ស្រូតរូតទៅដល់ស្រុកឈីដាវ ។ ចំណែកបិតុកចូលទៅដល់ក្រុងឈីដាវទើប យកសេចក្តីទៅជំរាបតូកៀមថា ខុងយុ"ងបានបញ្ជូនឡៅពិឲ្យលើកទ័ពមក ជួយលោក ខុងយុ"ងនឹងឡៅពីនោះនឹងលើកទាហានតាមមកជាក្រោយ ។

ឯតាន់តេងដែលទៅសុំកងទ័ពតេងកៃនោះ ក៏ត្រឡប់មកជ្រាប់ តូកៀមថា តេងកៃនឹងលើកមកជួយ ។ តូកៀមបានឮដូច្នោះ ក៏បាន ធូរស្បើយក្នុងចិត្ត ។ ឯខុងយុ"ងចៅហ្វាយស្រុកប៉ាក់ហៃ នឹងតេងកៃចៅ ហ្វាយស្រុកឈៀងដាវ ក៏នាំទាហានលើកទៅដល់ស្រុកឈីដាវ ឃើញ

កងទ័ពចូឆូតាំងរាយប្រតិតដិតជាប់គ្នា ។ ខុងយ៉ុងនឹងគេងកែកឲ្យតាំងបន្ទាយពីក្រោយទ័ពចូឆូ ២ ប៉ែក ប៉ងនឹងមើលកលសឹក ។ ចូឆូឃើញដូច្នោះគិតថា "ឥឡូវមានកងទ័ពមកតាំងនៅពីក្រោយ ២ ប៉ែក បើនឹងលើកវាយបំបែកទៅមុខ ក្រែងពីក្រោយលើកគំហុកខ្ជាប់មកទៀត" គិតហើយក៏បែងគាហានឲ្យមានពួក បែរទៅមុខផងបែរមកក្រោយផងតាំងសងខាង ។

កាលឡៅពីលើកគាហានទៅដល់ស្រុកឈីដីវហើយ ឃើញកងទ័ពខុងយ៉ុងនឹងគេងកែ តាំងបន្ទាយកាយប្រតិតគ្នានឹងទ័ពចូឆូ ២ ប៉ែក ដូច្នោះ ក៏ចូលទៅជួបនឹងខុងយ៉ុង។ មានអំណរណាស់ និយាយនឹងឡៅពីថា ចូឆូលើកគាហានមកធ្វើសង្គ្រាមជាច្រើនហួសប្រមាណ ខ្លួនចូឆូក៏ជាមនុស្សមានសតិប្រាជ្ញាដ៏ឆាញ់ស្ទាញស្ទាត់ក្នុងការពិជ័យសង្គ្រាម, ដែលយើងនឹងលើកគាហានចូលកាច់យកដោយឆាប់ខាន់ចិត្តនោះ ឃើញនឹងបង់ការ, ត្រូវតែរារាំងបង្ខំដ៏មើលកលការណ៍សិន បើឃើញបានចំណាប់ហើយ សឹមយើងលើកចូលទៅច្បាំងនឹងចូឆូ ។

ឡៅពីគិតថា ដែលអ្នកនិយាយនោះត្រូវណាស់ តែខ្ញុំវែកឆន្ទនឹងតាំងនៅយូរមិនបាន ព្រោះស្បៀងអាហារក្នុងស្រុកឈីដីវតិចពេក ពួកអ្នកស្រុកក៏អត់ឃ្លាន; បើដូច្នេះខ្ញុំឲ្យកងអ៊ូនឹងដូរឡុងនាំគាហាន ៤ ពាន់មករួមនឹងអ្នក ឯខ្លួនខ្ញុំនឹងត្រៀវហ៊ុយនាំគាហានជាង ១ ពាន់ ពារំលាយកង

ខ្ញុំតបចូលទៅឲ្យដល់ស្រុកឈើដីវិតម្ដង ប្រយោជន៍ទឹងបានទិយាយប្រឹក្សាការទើងតូកៀម ហើយទឹងប្រមាណមើលស្បៀងអាហារក្នុងស្រុកដែលមាននៅនោះច្រើនប្លុងតិច ទឹងបានសម្រេចគិតគ្នាតទៅទៀត ។ ទុងយ៉ុងក៏យល់ព្រមផង ។ ខណៈនោះ ឡៅពីទឹងគៀវហ៊ុយនាំភាហានចូលទៅដល់មុខបន្ទាយចូនូ ។ ភាហានចូនូឃើញក៏លើកគ្នាមកពាំងពីមុខ ។ កងខ្ញុំតាំងសងខាងក៏តាំងតែចូលលុកតប្រយុទ្ធគ្នាទៅវិញទៅមក ប៊ីដូចលេកកងមហាសមុទ្រ ។

ឯអ៊ីកិមភាហានឯកនោះបរសេះចេញមកមុខភាហាន ហើយស្រែកសួរឡៅពីទឹងគៀវហ៊ុយថា ឯងមកនេះទឹងទៅណា? ភាហានឯងជាង ១ ពាន់ប៉ុណ្ណេះ ទឹងស្អាំថ្ងូដៃភាហានយើងឬ? ។ គៀវហ៊ុយបានឮឈឺចិត្តណាស់ មិនបានឆ្លើយទូងថាដូចម្ដេច បរសេះសុុះផ្ងួចទៅប្រយុទ្ធទឹងអ៊ីកិមបាន ១០ ស្បៀត ។ ឡៅពីកាន់គ្រប់បរសេះចូលទៅជួយគៀវហ៊ុយពីក្រោយ ។ អ៊ីកិមកម្ចាំងខ្លាំងក៏ចយត្រឡប់ គៀវហ៊ុយដេញជាប់តាប់ភាហានចូនូស្ទាប់ជាច្រើនណាស់ ។ ឡៅពីទឹងគៀវហ៊ុយនាំភាហានទៅដល់មាត់ទ្វារស្រុក ។

ឯតូកៀមឡើងពិនិត្យមើលលើសែនបន្ទាយ ឃើញកងខ្ញុំតដេញគ្នាទំលាយចូលមកដល់មាត់ទ្វារ ក៏ឃើញទន់ដ័យក្រហមជាសំគាល់មានអក្សរជាទង់ថា "ឡៅពីចៅហ្វាយស្រុកផេងឆ្នូនកួន" តូកៀមមានអំណរ

ពន់ប្រមាណ បង្គាប់ឲ្យពាហានសុះទៅបើកទ្វារទទួលឡៅពីចូលទៅក្នុងស្រុក ទើបអញ្ជើញឲ្យអង្គុយហើយរៀបតុលៀងអាហារ ។ ឡៅពីនឹងតៀវហ៊ុយទៅអស់ពលសេនា បរិភោគារួចហើយ, ឡៅពីដំកបតូកៀមថា ដែលយើងចូលមកនេះ ឃានកាប់ឆ្ការតោរំលាយកងទ័ពបួនវិនាសអស់ជាច្រើន ។ តូកៀមឃានស្តាប់ក៏ឃានសេចក្តីត្រែកអរណាស់តាំងតែគយគន់មើលរូបពង់ឡៅពីយើញសមគួរជាពូជព្រះពាជវង្ស តាំងពោហារសំដីដែលចរចាកេះកាយសុកាតបែបជាអ្នកចិត្តល្អ, តូកៀមចាត់ប្រើចិតុក ឲ្យចូលទៅយកត្រាសម្រាប់ចៅហ្វាយស្រុកឈីដីវចេញមកជាបញ្ជាប់ ហើយប្រគល់ឲ្យឡៅពីៗ យើញដូច្នោះ ក៏ទឹកភ័យស្រដីតបទៅថា ដែលលោកយកត្រាសម្រាប់ខៃតមកឲ្យខ្ញុំនេះ ដោយហេតុគេទប្រការម្តេច? ។ តូកៀមតបថា សព្វថ្ងៃនេះព្រះចៅហៀនតេឃានត្រង់ពាជសម្បត្តិ ព្រះជន្មវស្សាក៏ទ្រង់ទៅជាព្រះពាជកុមារណាស់ នាហ៊ឺនមុខមន្ត្រីដែលគ្មានចិត្តជាសុចរិតទៀងត្រង់នោះ ក៏រមែងធ្វើការជាចលាចលផ្សែង។ ផែនដីមានតែសេចក្តីក្តៅក្រហាយមកជារឿយ។ ខ្លួនខ្ញុំក៏ចាស់ជរា ទំងធ្វើការបំរុងផែនដីតទៅទៀតពុំឃាន ខ្ញុំយើញថាអ្នកជាពូជព្រះពាជវង្សខ្ពង់ខ្ពស់មានកេរ្តិ៍ឈ្មោះជាអ្នកមានសតិប្បញ្ញា ហើយមេត្តាពាប់អានបណ្តាពស្តេតាសការតាំងពួនឲ្យឃានសេចក្តីសុខក្សេមក្សាន្ត, ខ្ញុំឃានតាំងចិត្តគិតជាស្រេច ទើបលើកត្រានេះជូនឆ្លងឲ្យលោកទទួលធ្វើជាទៅ-

ហ្វាយស្រុកឈើដីវែតទៅ ដើម្បីនឹងបានគិតកំចាត់សត្រូវរាជសម្បត្តិឲ្យ
ខ្ចាត់ខ្ចាយចេញ, បើអ្នកតេញចិត្តជាប្អូនដ ខ្ញុំនឹងធ្វើសំបុត្រចូលទៅ
គ្រាបទូលព្រះចៅហៀនតេ សូមឲ្យទ្រង់បានជ្រាប ។

ឡៅពីបានស្តាប់ក៏នុនគំនាប់តូកៀមហើយថា ខ្លួនខ្ញុំជាតូដព្រះពាជវង្ស
ពិតមែន, តែថាគំនិតនឹងសតិប្បញ្ញាតិចណាស់; តាំងពីចូលធ្វើពាជការ
មិកថាន់បានគុណតាប់ប្រសើរយ៉ាងណាទេ, សព្វថ្ងៃធ្វើត្រឹមតែចៅហ្វាយ
ស្រុកចត្វា គិតថាចំណេះរបស់ខ្លួនមិនឆ្លងនៅឡើយ; ដែលខ្ញុំលើកខា-
ហានមកនេះ ព្រោះចិត្តជ្រាបថានឹងជួយលោកដែលចង្អាងនឹងចូងប្អូណ្ណោះ,
ឬលោកនៅមិនជឿស្មោះថា ខ្ញុំមកដណ្តើមយកស្រុកឈើដីវែនោះមិនមែន
ទេ បើខ្ញុំគិតដូច្នោះ ក៏សូមឲ្យទៅតាប្រហារជីវិតខ្ញុំចុះ ។

តូកៀមតបថា ដែលខ្ញុំនឹងលើកស្រុកឲ្យអ្នកនេះ ជាសេចក្តីសុចរិត
មិនមែននឹងគិតសង្ស័យអាល័យស្តាយ ឬឧបាយបញ្ឆោតដូចម្តេចក៏ទេ ។
តូកៀមលួងលោមអង្វរប្រគល់ស្រុកឈើដីវែឲ្យឡៅពីដូច្នេះ ជាច្រើនដង
ច្រើនគ្រាណាស់ ឡៅពីនៅមិនព្រមទទួលសោះ ។ បិតុកនិយាយ
នឹងតូកៀមថា ទ័ពចូលមកទល់ជិតនឹងកំពែងស្រុកហើយ ឡៅពី
ចានមកជួយធ្វើការសឹក ហើយលោកគិតទៅប្រគល់ស្រុកឲ្យយូរការ
ដូច្នេះមិនស្រួលទេ ឲ្យលោកខំរិះគិតគ្នាធ្វើការសង្គ្រាមឲ្យសម្រេចសិន
សុំគិតប្រគល់ស្រុកទេសឲ្យឡៅពីជាក្រោយចុះ ។

ទៀតពីនិយាយនឹងតូកៀមថា ខ្ញុំសុំសរសេរសំបុត្រទៅយាត់ហាមចូឆូឲ្យលើកទ័ពត្រឡប់ទៅវិញ, បើចូឆូមិនស្តាប់សឹមគិតលើកកងទ័ពចេញទៅច្បាំងខាងក្រោយ ។ តូកៀមក៏យល់ព្រមផង ទៀតពីក៏សរសេរសំបុត្រចាត់ឲ្យទាហានកាន់យកទៅឲ្យចូឆូជាច្រើនគ្នា ហើយឲ្យលបយកទៅឲ្យខុងយ៉ុងនឹងគេងវៃថា ឲ្យត្រៀមទាហានទុកឲ្យមាំមួនកុំអាលចេញច្បាំង; ទាហានក៏នាំសំបុត្រនោះចេញទៅ ។ ពួកទាហានចូឆូនាំបំរើចូលទៅដល់ចូឆូក្នុងបន្ទាយ, ចូឆូទទួលសំបុត្រមើលឃើញសេចក្តីថា "ទៀតពីសុំឲ្យពរមកដល់ចូឆូ ឲ្យគិតដល់គ្រាដែលនៅធ្វើការជាមួយគ្នានៅគយហៅលោគួនហើយយើងទាំងសងខាងក៏និងសគ្នាទៅ មិនបានគតប្រទះគ្នាមកទល់នឹងសម័យនេះ ខ្ញុំក៏មានចិត្តគិតដល់អ្នកមិនភ្លេចសោះ; ដែលបិតាអ្នកអនិច្ចកម្មនោះ ព្រោះតែវាឃើប្រទូសរ៉ាយពីខ្លួនវា តូកៀមមិនមែនទៅចូលរួមគំនិតជាមួយនឹងវាក៏ទេ, ដែលអ្នកមកទីនឹងតូកៀមហើយថែមលើកកងទ័ពមកសម្លាប់អស់បណ្តាអ្នកស្រុកដែលនៅទំនេរនោះ ជាសេចក្តីក្តៅក្រហាយខុសឆ្ងាយចាកផ្លូវយុត្តិធម៌ អ្នកក៏ជាមន្ត្រីកងរាជការមានតំរេះថ្ងាជ្រាស់ហើយ គួរឲ្យគិតមើលចុះ សព្វថ្ងៃនេះលំឈឺយគុយតីបានជានាហ្នឹងធំនៅក្នុងស្រុកទៀងហាន់ ព្រះចៅហៀនតេនឹងនាហ្នឹងមុខមន្ត្រីទ្វីរាជការ នៅអស់បណ្តារាស្ត្រមានតែសេចក្តីក្តៅក្រហាយជាច្រើន ចំណែកខាងអាណាខែត្រក្រៅក៏នៅតើតពួកចោរដួតកាឈលលឿង តែងតែធ្វើទុក្ខបុកម្នេញ

បណ្តាក ស្តេចរឿយៗ ដោយហេតុមន្ត្រីធំពុំមែនត្រឹមតែសុចរិតដូចមិ, អ្នកចូរគិតអាណិតដល់បណ្តាកស្តេចខ្ញុំផែនដីដែលត្រួយទុក្ខ គួរណាស់តែនឹងជួយទប្បត្តិ លើកកងទ័ពទៅបង្ក្រាបពួកអាចោរកំណាច ឲ្យរួបខ្លួចតបះតេដះរបស់អ្នក មិនគួរនឹងលើកយកធុរៈជាកិច្ចផ្ទាល់ខ្លួនមកគួនទឹងនឹងតូរកៀម ដែលជាមនុស្សស្លូតត្រង់សោះ ពីព្រោះតែបិតារបស់អ្នកសូន្យបង់ជីវិត អ្នកត្រូវគិតឲ្យជាក់ច្បាស់ដោយបញ្ញា បើឃើញថាតូរកៀមប្រព្រឹត្តទុច្ចរិតពុំពិតដូចខ្ញុំថាទេ សុំឲ្យអ្នកលើកទ័ពមកចាប់តូរកៀមសម្លាប់ចុះ; ដែលខ្ញុំទាំសេចក្តីមកជំរាបប៉ុណ្ណោះ សូមឲ្យអ្នកឈ្វេងយល់ដល់ទៅខ្ញុំផង" ។

ឯបូរគូរកាលបានឃើញសេចក្តីសំបុត្រដូច្នោះ ក៏បណ្តាលទ្រូវសេចក្តីក្រោធពិរោធជាពន្លឺក ហើយបែរទៅប្រឹក្សានឹងគុយកែថា យើ! អាឡៅពីចំជាចិត្តព្រហើនណាស់ ហ៊ានឲ្យសំបុត្រមកហាមឃាត់យើង បើយើងកេទៅហើយឃើញថា ក៏ប្រើឲ្យកាលល្ងង់បញ្ឆោតយើងមែន នោះគួរតែឲ្យកាត់ក្បាលបំរើដែលកាន់សំបុត្រនេះចេញ ហើយរៀបទ័ពជាប្រញាប់ទៅវាយយកស្រុកឈីជីវឲ្យខាងតែបាន ។ គុយកែធ្វើយថា ឡៅពីជាមនុស្សស្លូតត្រង់ជាបំផុត, ដែលនឹងទៅសម្លាប់បំរើកាន់សំបុត្រនោះមិនគួរសោះ សុំឲ្យលោកធ្វើយតបសំបុត្រទៅយកចិត្តឡៅពីសិន, តទៅមុខសឹមលើកទ័ពទៅវាយយកស្រុកឈីជីវនឹងបានដោយស្រួល ។

ចូឆ្លក់យល់ព្រមផងទើបឲ្យឃាត់ខ្លួនចំរើនោះទុក ហើយត្រឹះរកសេចក្តី
ដែលនឹងធ្វើសំបុត្រតបទៅទៀតវិញ ។

ចំណែកខាងលីចុ៉ា កាលតេចេញអំពីលីឈុយគុយគីពីក្រុងតៀន
ហាន់ទៅដល់ស្រុកឡាំយ៉ុង ចូលទៅអាស្រ័យនឹងអ្នកសុតៗ មិន
ខ្វល; លីចុ៉ាក៏ចូលទៅនៅនឹងអ្នកសៀវចៅហ្វាយស្រុកគីជីវ; លីចុ៉ា
បានធ្វើសេចក្តីគាប់ប្រសើរទុកដល់អ្នកសៀវមួយគ្រា តែលីចុ៉ាធ្វើអាក្រក់
ដល់ពួកគាហានស្និទ្ធរបស់អ្នកសៀវ។ ទឹងណាស់ គិតនឹងសម្លាប់លីចុ៉ា។
ក៏តេទៅនៅនឹងតៀវអៀនចៅហ្វាយស្រុកសៀងតុង ។

ឯចុំងស៊ីជានាហ្មឺននោះក្នុងក្រុងទៀងហាន់ ជាមិត្តស្និទ្ធស្នាលនឹង
លីចុ៉ា លុះឮថាលីចុ៉ាទៅនៅស្រុកសៀងតុង ក៏លបនាំកវិយាបុត្រនឹង
ស្ត្រីគ្រប័ក្សពួករបស់លីចុ៉ាទៅឲ្យលីចុ៉ាឯស្រុកសៀងតុង ។ លីឈុយ
គុយគី ដឹងការបង្គាប់ឲ្យចាប់ចុំងស៊ីសម្លាប់បង់ ហើយធ្វើសំបុត្រទៅ
ដល់តៀវអៀនឲ្យចាប់លីចុ៉ាសម្លាប់, លីចុ៉ាដឹងខ្លួនក៏តេទៅនៅនឹងតៀវ-
មេ៉ាចៅហ្វាយស្រុកតាន់លីវ ។

ចំណែកតាន់កុងដែលទៅហាមឃាត់ចូឆ្លូវៗមិនស្តាប់, តាន់កុងទៅនៅ
នឹងតៀវឲ្យដែលជាប្អូនតៀវមេ៉ានៅស្រុកតាន់លីវនោះ តៀវបៀវក៏នាំតាន់កុង
ទៅរកតៀវមេ៉ាជាបង ។ តាន់កុងជំរាបតៀវមេ៉ាថា ចូឆ្លូបានជាធំនៅខាង
ប្រជុំវៃត្រទិសឯកើតមានៈសនាគាហានជាច្រើន ឥឡូវចោលស្រុកគុនជីវ

លើកទៅវាយយកស្រុកឈើដីវ៉ ខ្ញុំយល់ឃើញថាស្រុកគុនដីវ៉នោះគ្មាន
នរណាមានថ្ងៃដែងខ្លាំងតូចកៃទៅក្បាច្រៀបគ្រប់គ្រងទេ សុំឲ្យលោកចាត់លីចុ៉ាឲ្យ
លើកកងទ័ពទៅវាយយកស្រុកគុនដីវ៉ ក៏ងឹងបែកបានដោយងាយ, ប៉ើ
បានស្រុកគុនដីវ៉ហ៊ាយ ស្រុកតាន់លីវ៉នៅខាងទិសឯកើតនេះ ក៏ងឹងផុតរួច
ពីអំណាចចូចូជាប្រាកដ ប៉ើងឹងគិតការធំតទៅមុខក៏ស្រួលមិនលំបាក ។
តៀវមៅបានស្តាប់ក៏តេញចិត្ត ទើបចាត់សេនាឲ្យលីចុ៉ជាមេទ័ព
ហើយឲ្យយកតាន់កុងទៅជាមួយ ។ លីចុ៉លើកកងទ័ពជាប្រញាប់ទៅ
វាយស្រុកគុនដីវ៉បានហើយ លើកទាហានទន្ទ្រានវាយយកខៃត្រង់ណា
ក្បែរផ្លូវទៅដល់ស្រុកចុ៉ក់អៀង នៅសល់តែស្រុកអៀងសៀ ១ ស្រុកតង
ហៃ ១ ស្រុកហួនគួន ១ ទាំង ៣ ស្រុកនេះ ឆៀយ៉ុកងឹងស៊ុនហុករក្សា
ទុកបាន ។ ឯចោយិនទាហានចូចូដែលនៅកងស្រុកគុនដីវ៉នោះ បែក
រត់ទៅងឹងទៅរកចូចូ ។ មានបំរើសេះស្រួតទៅដល់ចូចូមុន យកសេចក្តី
ទាំងពួងដំណចូចូបានដឹងគ្រប់សព្វ ។ ចូចូដឹងហើយក៏មានចិត្តបរិតក្ក
ណាស់ប្រឹក្សាងឹងទាហានទាំងពួងថា ដែលលីចុ៉លើកទ័ពទៅវាយ
យកស្រុកគុនដីវ៉នោះយើញថា គ្រប់គ្រងបរស់យើងប្រហែលងឹងវិនាស
ខ្ចាត់ខ្ចាយអស់ហើយ បើដូច្នេះត្រូវតែយើងលើកកងទ័ពត្រឡប់ទៅច្បាំង
ងឹងលីចុ៉វិញ ។

គុយតែធ្វើយថា ដែលលោកងឹងលើកទ័ពត្រឡប់ទៅវិញនោះគួរ
ណាស់ ព្រោះឡៅពីក៏មានសំបុត្រមកឃាត់ហាមលោកផង លោកត្រូវ

មានសំបុត្រតបទៅវិញដើម្បីចង់មេត្រីទុកតទៅ សេចក្តីដែលឡៅតាយាត់ហាមទាំងប៉ុន្មាន លោកក៏បានទទួលស្តាប់គ្រប់ប្រការរួចសឹមលើកពលសេនាទៅស្រុកគុនជីវ ។ ចូឆួបានស្តាប់ឃើញត្រូវ ក៏ទៅធ្វើសំបុត្រតាមពាក្យគុយតែនិយាយ ហើយប្រគល់ឲ្យទាហានឡៅពីនាំទៅ; ចូឆួក៏លើកទ័ពត្រឡប់ទៅស្រុកគុនជីវ ។

បំរើនាំសំបុត្រវិលទៅដល់ស្រុកឈីជីវហើយ ក៏ជូនសំបុត្រនោះឲ្យឡៅពីទៅមុខតូកៀម ឡៅពីនឹងតូកៀមមើលដឹងសេចក្តីហើយ ក៏មានអំណរក្នុងចិត្តណាស់ ។ តូកៀមឲ្យបំរើទៅអញ្ជើញខុងយ៉ុង ១ តេងតៃ ១ គួនអ៊ូ ១ ជូឡុង ១ ឲ្យចូលមក ហើយពត់ឲ្យរៀបតុលៀងអាហារ អញ្ជើញឡៅពីឲ្យអង្គុយកន្លែងសមគួរហើយនុនគំនាប់ជំរាបឡៅពីថា ខ្លួនខ្ញុំចាស់ជរាហើយ បើនឹងផ្ទេរផ្ទុកការស្រុកឲ្យបុត្រទាំងពីរក៏ពុំបាន ព្រោះវាគ្មានសតិប្បញ្ញាសោះ ខ្ញុំសូមឲ្យអ្នកទទួលធ្វើជាចៅហ្វាយស្រុកឈីជីវចុះ ឯចំណែកខ្លួនខ្ញុំសុំនៅក្រែវាជការជួយចាត់ការទំនុកបំរុងតទៅ ។ ឡៅពីបានស្តាប់តូកៀមនិយាយដូច្នោះ ទើបពាក្រែងនឹងសេនាទាហានទាំងពួងថា ពីថ្ងៃមុនខុងយ៉ុងបបួលយើងឲ្យមកជួយការពារតូកៀម យើងឃើញថ្ងូរមេត្រីពប់អានបានលើកទ័ពមកជួយ តទ្បាយនេះតូកៀមនឹងលើកស្រុកឈីជីវឲ្យដល់យើង បណ្តាពួកទាំងអស់បានជឹងក៏នឹងតរហាន់ខ្លាថា យើងជាមនុស្សលោភចង់បានទ្រព្យនឹងបេះសក្តិ ។

បិតុកដំរាបទៀតថា សូវថ្ងៃនេះកើតចលាចលផ្សែងៗ ស្រុកខ្ញែងហាន់គាន់តែរៀវរោយនឹងសាបសូន្យអស់ហើយ បើអ្នកឯណាមានសតិប្បញ្ញាក៏ចូរទុស្សាហ៍ខំរិះគិតក្នុងគ្រានេះចុះ ឥឡូវនេះតូកៀមព្រមចិត្តស្រុះស្រួលលើកស្រុកជូនលោក ហេតុម្តេចលោកធ្វើកន្តើយព្រងើយដូច្នេះ ឯស្រុកឈឺជីវនេះមានខ្ចីណាឡើងក៏ច្រើន បើនឹងប្រមាណអ្នកដែលមានទ្រព្យសម្បត្តិគ្រប់តំបន់ ក៏មានដល់ម៉ឺនរយថ្លាយ លោកចូរទទួលយកចុះនឹងបានគិតការតទៅ ។ ទៀតពីធ្វើយថា អ្នកកុំបង្ខំឡើយ យើងមិនទទួលយកទេ ។

តាន់តេងនិយាយនឹងទៀតពីថា តូកៀមនេះជាមនុស្សជាមានភេគមែន, លោកចូរអាណិតដល់ភ្នែស្តេចាំងពួន ព្រមទទួលយកស្រុកឈឺជីវទៅ ។ ទៀតពីធ្វើយថា អ្នងសៀវចៅហ្វាយស្រុកឈឺជីវនោះ ជាពូជនាហ្នឹងតមក ៤ ដំណមនុស្សហើយ។ មានស្រុកឡើងជាច្រើន ហេតុម្តេចអ្នកមិនលើកស្រុកនេះឲ្យ ។

ខុងយ៉ុងធ្វើយថា អ្នងសៀវនោះឧបមាដូចជាសពនៅក្នុងស្នប កប់តែថ្ងៃ ២ ដែលនឹងគ្រែមទៅវិញ ចាំងសតិប្បញ្ញាក៏មិនសូវមាន នឹងកប់អានឲ្យធ្វើជាធំតទៅដូចម្តេចបាន; ឥឡូវបុណ្យមកដល់ហើយ ហេតុម្តេចលោកមិនព្រមទទួល ។ ទៀតពីក៏នៅតែមិនព្រមទទួលសោះ ។

តូកៀមបានឮទៀតពីចេះតែប្រកែក ក៏ស្រែកឲ្លាយំថា បើអ្នកមិនទទួលធ្វើចៅហ្វាយស្រុកនេះទេ ហាក់បីដូចជាអ្នកគ្មានមេត្តាខ្ញុំសោះ

ឡើយ បើកាលណាខ្ញុំនឹងស្លាប់ក៏មិនបានស្លាប់ទៅដោយស្រួល ព្រោះ
រំជួលកង្វល់នឹងរឿងនេះ ។

កូនអ្ញ គៀវហ៊ុយនិយាយទៅឡាតីទៀតថា តូកៀមត្រមែបគល់
ស្រុកឲ្យលោកដោយសុចរិត ហេតុម្តេចលោកមិនអាណិត ទាល់តែកើត
ទោមនស្សយ៉ាងនេះ? ។ ឡាតីក៏នៅតែមិនព្រមទទួលទៀត ។

តូកៀមនិយាយថែមទៀតថា ប្អែកមិនព្រមទទួលធ្វើជាចៅហ្វាយ
ស្រុកនេះ ចូរតែរិះអាណិតទៅនៅវត្តស្រុកសៀវដាយចុះ ស្រុកនោះ
ក៏ឡើងស្គាប់បង្គាប់ស្រុកឈឺដ៏វែនេះ បើខ្ញុំមានទុក្ខក្តៅគ្រហាយវេលាណា
នឹងបានពឹងពាក់អាស្រ័យនឹងអ្នកផង ។ មនុស្សទាំងពួងដែលនៅជួបជុំ
កងទ័ពនោះ បាននាំគ្នាជួយនិយាយអង្វរឲ្យឡាតីទទួលយកស្រុកសៀវ
ដាយ ។ តូកៀមមានសេចក្តីត្រេកអរណាស់ ដើរយកមាសប្រាក់
សំពត់អាវមកចែកឲ្យឡាតីនឹងពាហានទុងយ៉ាន តេងកែជាច្រើន ។

ក្នុងពេលនោះ ជូឡាងនិយាយនឹងឡាតីថា លោកមកជួយទុក្ខធុរៈ
តូកៀមឃើញថាសម្រេចហើយ ខ្ញុំនឹងសុំលាលោកទៅវគងស៊ុនបាន
វិញ ។ ឡាតីត្អូញហើយឃាប់ដៃជូឡាងជាប់ ហើយយំនិយាយផ្តែផ្តាំគ្នាជា
អនេកប្រការ ។ ជូឡាងក៏លាឡាតីប្រមូលពាហាន ២ ពាន់លើកចេញ
ទៅស្រុកប៉ាត់បេង ។

ឯទុងយ៉ាងនឹងតេងកែ ក៏លាឡាតីនឹងតូកៀមលើកពាហានចេញ
ទៅកាន់ស្រុករៀងខ្លួន ។ តូកៀមធ្វើសំបុត្របើកវែត្រាត់ឲ្យជូនដំណើរ

ឡៅតាំងៅឈរក្បាស្រុកសៀវផាយ ។ កាលឡៅតាំងៅឈរក្បាស្រុក
នោះ បណ្តាកស្តេតាំងឡាយកោះពយស្រឡាញ់ឡៅតាជាច្រើន ។

កាលចូធូលើកទ័ពៅដល់កណ្តាលផ្លូវបានប្រទះនឹងចោយ៉ាន ដំពប
ឲ្យការណ៍ថា លីចោ"ដែលជាមេទ័ពលើកមកនោះ រួចពង្រាបដែនបាន
ព្រោយជាអ្នកមានកម្លាំងខ្លាំងពូកែ បានតាន់កុងតាំងខុកជាទីប្រឹក្សា លុះ
ក្រោយបានស្រុកគុនដីវហើយ ក៏លើកទ្រូងៅក្រោយស្រុកក្បែរផ្លូវរៀងៅដល់
ស្រុកចុ"ក់អៀង, ឯស៊ុនហុកនឹងគៀយ"កត្រូវលីចោ"ចាត់ឲ្យនៅក្បាស្រុក
ខុកចាំង ៣ តំបន់ ។ ចូធូបានស្តាប់ហើយឆ្លើយតបថា "លីចោ"នោះជា
អ្នកមានថ្វីដៃខ្លាំងពូកែពិតមែនហើយ តែមិនជាអ្នកស្ងាត់កុងការចាំងពួងទេ
អ្នកកុំបីជាខុកឡើយ" លុះនិយាយគ្នាហើយ ក៏ឲ្យស្រួតលើកទាហាន
ៅដល់ស្រុកតេងកួន ហើយឲ្យឈប់តាំងបន្ទាយជាមាំមួនកុងទីនោះ ។

ឯលីចោ"កាលពួកគិត្តិសពួថា ចូធូលើកទ័ពៅតាំងបន្ទាយនៅស្រុក
តេងកួនដូច្នោះ ទើបចាត់ឲ្យលីហងនឹងស៊ីឡាន់ឃុំទាហានមួយហ្មឺនៅ
នៅក្បាស្រុកគុនដីវ ។ តាន់កុងបានពួដូច្នោះ ក៏សួរលីចោ"ថា ស្រុក
គុនដីវនេះជាទីសំខាន់ លោកនឹងឲ្យលីហងនឹងស៊ីឡាន់ៅនៅក្បានោះ
តើខ្លួនលោកនឹងៅនៅឯណា ? ។ លីចោ"ឆ្លើយថា យើងនឹងលើក
ៅតាំងលំទ័ពចូធូឯស្រុកចុ"ក់អៀង ប្រយោជន៍នឹងបានការពារស្រុក
ខុកឲ្យធំទូលាយ ។ តាន់កុងថា លោកនឹងខុកចិត្តឲ្យលីហងនឹងស៊ីឡាន់

នៅក្បែរស្រុកគុនដីវ ខ្ញុំយល់ឃើញថា មុខជាចាញ់ប្រៀបតែម្តង ព្រោះ
ភ្នំថៃសាន់នៅទិសឯត្បូងស្រុកគុនដីវនោះ ចម្ងាយប្រហែល ៨០០ សិន
(៣២, គ. ម.) មានប្រកបំពោះចុះតែដើងអ្នកមួយ ដើរតាមបន្ទោះ
ភ្នំជាផ្លូវកាត់ឲ្យត្រង់ គង់តែចូរឆ្លងឆ្លុតស្រុតលើកតម្រង់តាមផ្លូវនោះមក សុំ
ឲ្យលោកចាត់ទាហានមួយម៉ឺនទៅបង្កប់ចាំទៅសងខាងប្រកភ្នំនោះ បើ
កងទ័ពមុខចូរឆ្លើកមកដល់ទីនោះ ត្រូវឲ្យអស់ទាហានសម្ងំសម្ងាត់ បើ
កាលណាចូរឆ្លើកមកដល់ សឹមឲ្យលើកចេញស្កាត់ខ្នប់ទាំងសងខាង
កងទ័ពមុខនៃចូរឆ្លងឆ្លុតត្រឡប់វិលទៅដួយក៏មិនទាន់ ដូច្នេះយើញថានឹង
ចាប់ចូរឆ្លុតបានដោយងាយ ។

លីចុ"ជានស្តាប់ឆ្លើយតបថា "ដែលយើងនឹងតាំងកងទ័ពចូរឆ្លុតទៅ
ស្រុកចុ"ក់អៀងនោះ សេចក្តីគិតរបស់យើងឃើញថា មានផ្លូវនឹងតាំង
ច្បាំងគ្នាជាច្រើនកន្លែង មិនចាប់ឆ្លងតែបន្ទោះទាហានទៅបង្កប់កងទីនោះនាំ
ឲ្យតែវេរវល់ទេ" ថាហើយលីចុ"ក៏ចាត់ចែងទាហានត្រៀមទុកតទ័ពផ្ចាប់
ស្រុកចុ"ក់អៀង ។

ចូរឆ្លុតដឹងដំណឹងច្បាស់ ក៏គិតស្រឡះលើកទាហានទៅតាមប្រកផ្លូវ
ភ្នំថៃសាន់ ។ គុយតែគិតទាន់ឃាត់ហាមចូរឆ្លុតថា ទីភ្នំថៃសាន់នោះ
មានចំពោះតែផ្លូវដើរ ខ្លាចលីចុ"ទៅបង្កប់ទាហាននៅទីនោះ ហេតុនេះ
សុំឲ្យលោកឈប់បង្អង់សិន ចាំឲ្យចំរើសេះទៅស៊ើបល្បាតមើល ។

ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា

ភាគទី ២

សម័យនគរធំ

ឧកញ៉ាវេតពិទូរ ឈឹម - ក្រសែម រៀបរៀង

(តទៅ)

(រជ្ជកាលព្រះបាទជយវរ្ម័នទី ៧)

តែបើមើលព្រះពុទ្ធសាសនាក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី ១ ក៏ឃើញថា ព្រះបាទយសោវរ្ម័នជាអ្នកសាងក្រុងនគរធំ ឲ្យឈ្មោះថា "ស្រីយសោធរបុរៈ", សាងប្រាសាទកណ្តាល ឲ្យឈ្មោះថា "យសោធរតារី", សាងប្រាសាទនៅស្ថាន១នៅលើភ្នំបាខែង ឲ្យឈ្មោះថា "យសោធរេស្វរៈ", សាងស្រះធំ ១ ត្រៃកំពែងក្រុង ឲ្យឈ្មោះថា "យសោតដាក" ។ ឈ្មោះទាំងនេះ ឃើញសុទ្ធតែភ្ជាប់ព្រះនាមរបស់ព្រះអង្គផង, ព្រោះហេតុដូច្នេះ ប្រាសាទយសោធរតារី គេទើបយល់ថា ព្រះបាទយសោវរ្ម័នទ្រង់សាងជាដំបូងជាប្រាកដ ។ ឯរឿងដែលថា ព្រះបាទយសោវរ្ម័នទ្រង់កាន់តែសាសនាព្រាហ្មណ៍នោះ ក៏មិនពិតដូច្នោះទាំងអស់ទេ ព្រោះប្រាកដថា ទ្រង់បានសាងវត្តក្នុងព្រះពុទ្ធសាសនា ១ ឲ្យឈ្មោះថា "សោគតាស្រម" ។ តាមសេចក្តីនេះ គួរឲ្យយល់ថា ទ្រង់កាន់ទាំងសាសនាព្រាហ្មណ៍ទាំងព្រះពុទ្ធសាសនា ។

តាមផែនទី ក្រុងយសោធរបុរៈនោះ មានលក្ខណៈដែលនាំឲ្យយើងយល់ឃើញយ៉ាងជាក់លាក់ថា ទ្រង់ធ្វើជាតំណាងពិភពលោកទាំងមូល ដោយគ្រាន់តែបង្ហើមឲ្យតូចចុះប៉ុណ្ណោះ គឺប្រាសាទយសោធរគីរី (ភ្នំបាយ័ន) តាំងនៅចំកណ្តាលផ្នែកក្រុងនោះ ជាតំណាងភ្នំព្រះសុមេរុ ដែលតាំងនៅកណ្តាលលោក, កំពែងជុំវិញក្រុង ជាតំណាងកណ្តាប់ចក្រវាឡ, គូរជុំវិញកំពែង ជាតំណាងមហាសមុទ្រ ដែលនៅអមលោកទាំងមូល ។ ការធ្វើព្រះបរមពជកំងបែបនេះ ពាក់ថាជាពជប្រវេណីរបស់ព្រះមហាក្សត្រិយ៍ខ្មែរ, សឹងមានមកតាំងពីបុរាណកាល, បើយើងពិនិត្យមើលលក្ខណៈកសាងព្រះពជនិវេសន៍នៅឥណ្ឌា ក៏មានទំនងដូចគ្នានេះដែរ ។

ប្រាសាទយសោធរគីរី គេហៅអំពីជាតំណាងភ្នំព្រះសុមេរុហើយ គឺជា "គារវស្ថាន", ប្រកបដោយព្រះពជឥស្សរគារកុងរដ្ឋកាលព្រះបាទយសោវរ្ម័នទី ១ ថា ប្រាសាទនេះជាទីប្រតិស្ឋានរូបព្រះកម្រៃតែងជគតពជ (រូបសិវលិង្គមាស) ដែលជាអនុស្សាវរីយ៍ក្រោម, ។ មកកុងរដ្ឋកាលព្រះបាទជយវរ្ម័នទី ៧ នេះ ប្រកបដោយ ជាទីប្រតិស្ឋានព្រះពុទ្ធពជ (ព្រះពុទ្ធរូបជាតំណាងអង្គព្រះបាទជយវរ្ម័ន) ដែលជាពជសារៈគន្ធាវរីយ៍ក្រោមហើយនឹងជាទីប្រតិស្ឋានព្រះបរមបិតរ (គឺព្រះបរមអដ្ឋិនៃព្រះមហាក្សត្រិយ៍តាំងពីមុន) ។ ដូច្នេះ គប្បីដឹងថា ទីនេះជាទីគោរពរបស់ព្រះមហាក្សត្រិយ៍តាំងពីមុនក្នុងសម័យនគរធំ ។ មុខ ៤ នៅកំពូលប្រាសាទនោះ ជាគ្រឿងសំដែងព្រហ្មវិហារធម៌របស់ព្រះមហាក្សត្រិយ៍ ។

រាជាភិសេក- រយៈកន្លងមក ๔ ឆ្នាំ តាប់ពីឆ្នាំដែលព្រះបាទជយវរ្ម័នទ្រង់បានគ្រាបគ្រងភ្នំង នឹង បានត្រង់ពជបល្ល័ង្ក គឺមកក្នុងឆ្នាំ ព.ស. ๑๗๒๐ ប្រទេសកម្ពុជាបានដល់នូវសេចក្តីសុខក្សេមក្សាន្តហើយ ទើបទ្រង់ត្រាស់ព្រះរាជបញ្ជា ឲ្យធ្វើព្រះរាជពិធីបរមរាជាភិសេកនៅត្រាមច័ត្រដំរ តាមទក្ខិយរាជប្រពៃណី ព្រមទាំងធ្វើពិធីសម្ពោធ្យក្រុងស្រីយសោធរបុរៈ ដែលទ្រង់បានបដិសង្ខរណ៍ឡើងជាថ្មី ក្នុងរវាង ๔ ឆ្នាំនោះផង ។ ព្រះបរមរាជាភិនយសោធរបុរៈកន្លងវេលានោះ ពេញទៅដោយសេចក្តីល្អនឹងរុងរឿងហាក់ដូចជាឋានសួគ៌ ។

ក្រោយដែលធ្វើព្រះរាជពិធីបរមរាជាភិសេកហើយ ព្រះបាទជយវរ្ម័នបានចាប់កសាងតៅទៀតនូវប្រាសាទសិលាជាច្រើន នៅតំបន់នគរធំ រៀងទៅតាមថ្នល់ធ្លា គឺប្រាសាទដែលហៅតាមពាក្យសាមញ្ញថា: តាព្រហ្ម, បន្ទាយក្តី (បន្ទាយកុដី), ព្រះខ័ន, នាគព័ន្ធ, តាសោម, ក្រោលគោ, តានៃ ។ ក្រៅពីនេះ ទ្រង់បានសាងនៅខេត្តក្រៅខ្លះទៀត ។ តាមដែលបានដឹងកន្លងវេលានេះ ប្រាសាទបន្ទាយឆ្មារ នៅខាងទិសពាយ័ព្យនៃប្រាសាទវត្តនគរក្នុងខេត្តកំពង់ចាម្ប៉ា នឹងប្រាសាទតាព្រហ្ម នៅក្នុងខេត្តបាទី ។ ប្រាសាទអំបាលនេះ ទ្រង់សាងឡើងដើម្បីអ្វី? ។ តាមការបស់ប្រាសាទ នឹងតាមសិលាចារឹកខ្លះ អាចជាគ្រឿងបញ្ជាក់ ឲ្យយើងដឹងបានខ្លះថា: -

ប្រាសាទតាព្រហ្ម – នៅខាងកើតនគរធំ មានសិលាចារឹកសំដែងថា សាន់ឡើងក្នុងឆ្នាំ ព.ស. ១៧២៩ សម្រាប់ប្រតិស្ឋានព្រះបរមរូបនៃព្រះវរាជជននីរបស់ព្រះអង្គ ដែលលើកឡើងជា ព្រះប្រជ្ញាបារមិតា ទឹងរូបសម្ដេចព្រះគ្រូ ព្រមទាំងព្រះរូបឯទៀតចំនួន ២៦០ រូប ហើយទ្រង់ជាក់គ្រឿងជង្ហាយថ្វាយនៅក្នុងប្រាសាទនេះ គឺចានជាមាស ១ ទម្ងន់ជាង ៥០០០ គីឡូក្រាម (បើតាមដំឡៃសព្វថ្ងៃ ប្រមាណ ១០ លានរៀល ឬជាង ១០ លានរៀល) ទឹងចានជាមប្រាក់ជាមានទម្ងន់ស្មើគ្នានេះ ១ ទៀត, ពេជ្រទាំងគ្រាប់ធំ ៣៥ គ្រាប់, ត្បូងមុក្តា ៤០.៦២០ គ្រាប់, ត្បូងយ៉ាំងល្អបែបឯទៀត ៤.៥៤០ គ្រាប់, ផ្កាលមាសយ៉ាងធំ ១, រនាំងស្រុកបិន ៨៦៧, គ្រែធ្វើដោយសំពត់ព្រៃ ៥១២, កូស ៥២៣ ។ ផ្នែកស្បៀងអាហារក៏មានគ្រប់យ៉ាង គឺអង្ករ ប៊ើរ ទឹកដោះគោ ស្ករក្រាម ប្រៃ គ្រាប់ផលានុផលផ្សេងៗដែលសម្រាប់ប្រើការបូជាពលិថ្ងៃ ទឹងរបស់ដែលប្រើបូជាក្នុងថ្ងៃពិធីបុណ្យជាពិសេស គឺគ្រាប់ផលានុផល ប៊ើរ ទឹកដោះគោ ទឹកឃ្មុំប្រៃ ក្រមួនខ្មីមចន្ទន៍ កប្បូរ គ្រឿងចិរ ៦.៣៨៧ គូ ។ របស់ទាំងនេះសម្រាប់ថ្វាយព្រះរូបទាំងអស់ មានបញ្ជីដែលឃ្លាំងត្រូវបើកចំណាយឲ្យរៀងរាល់ឆ្នាំ ។ ទ្រង់តែងតាំងក្លាក់ជាវរាជការ ជាអ្នកគ្រប់គ្រងនៅក្នុងប្រាសាទនេះ

ទីដ៏អ្នកបំពើការ - ភូមិចំណុះ គឺមនុស្សអ្នកធ្វើការថែរក្សាប្រាសាទនេះចំនួន ៧៤. ៣៦៥ នាក់ អ្នកនៅជាប់ក្នុងតំបែនប្រាសាទចំនួន ១២. ៦៤០ នាក់, មានភូមិចំណុះប្រាសាទនេះចំនួន ៣ ១៤០ ភូមិ ។ ក្នុងមនុស្សអំបាលនេះ មានអធិការ ៨ នាក់, មានមេគណ ២.៧៤០ នាក់, អ្នកគាល់បំពើព្រះបរមរូបជាប់ ២.២០២ នាក់, មានស្ត្រីរបាំ ៦១៥ នាក់ សម្រាប់លេងរបាំថ្វាយជាអាចិណ្ណ ។

ការដែលព្រះបាទជយវរ្ម័ន ទ្រង់បំពេញបុញ្ញកិរិយាវត្ថុដ៏ធំប៉ុន្មាននេះ ដោយទ្រង់មានសេចក្តីគោរព ក្នុងព្រះរាជជននីជាយ៉ាងក្រៃលែង ។ ក្នុងបុរាណសិលាចារឹកមានសេចក្តីប្រណិធាន សូមឲ្យព្រះរាមតារបស់ទ្រង់ បានសម្រេចនូវការៈជាព្រះពុទ្ធនៅអនាគត ។

ប្រាសាទបន្ទាយក្តី ជាវត្ត ឬជាធម្មសភា ក្នុងព្រះពុទ្ធសាសនាលទ្ធិមហាយាន ។ គេសង្កេតឃើញរូបភាពក្នុងរឿងពុទ្ធប្រវត្តិជាច្រើនអន្លើ ។

ប្រាសាទតាគព័ន្ធ ពីដើមប្រហែលជាឲ្យឈ្មោះថា ស្រះអនោតត្ត, តែសព្វថ្ងៃនេះគេហៅថា ប្រាសាទតាគព័ន្ធ តាមដែលរូបនាគព័ន្ធព័ន្ធប្រាសាទដែលនៅកណ្តាលស្រះនោះ ។ ស្រះមេនគឺគេធ្វើតំណាងស្រះអនោតត្ត ដែលមានរឿងដំណាលថា នោះក្នុងព្រៃហិមពាន្ត ទឹកស្រះនេះគេនិយមថា មានសព្វគុណសក្តិសិទ្ធិអស្ចារ្យ មានផ្លូវហូរចេញទៅតាម

ក្បាលមនុស្ស ក្បាលពពែសីហ៍ ក្បាលដំរី ទំនងក្បាលគោ ដ៏មាននៅក្នុងគ្រឹះទាំង ៤ ទិស, អ្នកសញ្ជ្ញារៀមភរមែនទៅឆ្ងូតទឹកដំរះមទ្ទិលនៅទីនោះ ។

ប្រាសាទព្រះខ័ន នៅមិនទាន់ដឹងច្បាស់ថា សាងឡើងសម្រាប់អ្វី តែមិនមែនសម្រាប់ដាក់ព្រះខ័ន ដូចអ្នកខ្លះយល់នោះទេ ។ តាមផ្លូវសន្និដ្ឋានឃើញថា ជាស្ថានក្នុងព្រះពុទ្ធសាសនា ប្រហែលគ្នានឹងបន្ទាយក្តី ។ ប្រាសាទតូចៗ ដែលនៅរៀនតាមថ្នល់ផ្លូវនោះ ជាទីសំចតរបស់ប្រជាជនដែលសញ្ជ្ញារៀមភរ ។

ប្រាសាទបន្ទាយឆ្មារ នៅវត្តនគរ (កំពង់ចាម្ប៉ា) ត្រង់សាងទុកអនុស្សាវរីយ៍ទីរឭកដល់គុណបំណាច់ របស់ព្រះពាជកុមារព្រះនាមស្រីន្ទ្រកុមារ[1] (លោកេសេស) ជាព្រះពាតុរសរបស់ព្រះអង្គនឹងសេនា ៤ នាក់ទៀត ដែលជាកៀនចំបាំងជាមួយគ្នា គឺបាំងកម្ពុជរតនាហ៍ ក្នុងវដ្ឋកាលព្រះបាទយសោវរ្ម័នទី ២ នឹង បាំងកម្ពុជចាម្ប៉ា ក្នុងកាលក្រោយតៗមក ។

ប្រាសាទតាព្រហ្ម នៅចាទី នោះមិនទាន់ដឹងច្បាស់ថា សាងឡើងសម្រាប់អ្វី ។ (មានត)

---

១ ក្នុងសិលាចារឹកព្រះបាទយសោវរ្ម័នទី ២ ថាព្រះពាជកុមារនេះព្រះនាម ស្រីវិរិន្ទ្រកុមារ ។

បញ្ជីឈ្មោះគ្រូអធិការដែលតាំងថ្មី

របស់គ្រែសួងធម្មការ

(តទៅ)

សញ្ញាប័ត្រលេខ ៧៣៦ ចុះថ្ងៃពុធ ៣ កើតខែមិគសិរ ឆ្នាំឆ្លូវឯកស័ក ព.ស. ២៤៨២ តាំងលោកគ្រូ ប៉ែន - រឿល នាមឆាយា ធម្មត្តេរ កើតឆ្នាំរោង អាយុ ៥០ វស្សា ១៩ ជាគ្រូសូត្រធ្វើវត្ត - ឃុំ - ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧៣៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហាយ - យ៉ន នាមឆាយា ធម្មជោត កើតឆ្នាំឆ្លូវ អាយុ ៣៧ វស្សា ១៦ ជាគ្រូសូត្រស្តាំវត្តឫស្សីសុវណ្ណ ឃុំអន្លង់គ្មោត ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧៣៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ នន់ - ខាន់ នាមឆាយា និលសុវណ្ណ កើតឆ្នាំឆ្លូវ អាយុ ៣៧ វស្សា ១៦ ជាគ្រូសូត្រធ្វើវត្ត - ឃុំ - ស្រុកខែត្រ - ដដែល ។

សញ្ញាប័ត្រលេខ ៧៣៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទិត - ញឹម នាមឆាយា ធម្មសុវណ្ណ កើតឆ្នាំឆ្លូវ អាយុ ៣៣ វស្សា ១៩ ជាគ្រូសូត្រស្តាំវត្តបន្ទាយក្រែម ឃុំបឹងកន្ធត ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧៤០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សេក - អឿង នាមឆាយា ព្រហ្មត្តេរ កើតឆ្នាំមមី អាយុ ៣៦ វស្សា ១៦ ជាគ្រូសូត្រធ្វើវត្ត - ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧៤១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កែត - គាត នាមធាយា ព្រហ្មត្ថេរ កើតឆ្នាំរកា អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្តវតនវង្ស៏ ឃុំក្បាលគ្រាច - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ជ័យ - ឆៃ នាមធាយា បញ្ញាវិន័យ កើតឆ្នាំ . . . អាយុ ២៧ វស្សា ៨ ជាគ្រូសូត្រឆ្វេងវត្ត ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ យិន - ឆៃ នាមធាយា ធម្មត្ថេរ កើតឆ្នាំ . . . អាយុ ៣៤ វស្សា ១៤ ជាគ្រូសូត្រស្តាំ វត្តកំលមហាព្រហ្ម ឃុំ ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាក់-យិន នាមធាយា បទុមត្ថេរ កើតឆ្នាំវក អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់ - នៅ នាមធាយា តន្ធជោត កើតឆ្នាំម្សាញ់ អាយុ ៤៥ វស្សា ២៥ ជាគ្រូសូត្រស្តាំ វត្តសម្តេចយស ឃុំស្នាអន្សា ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ចាប នាមធាយា ព្រហ្មសុវណ្ណ កើតឆ្នាំមមែ អាយុ ៤៣ វស្សា ២៣ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

(មានត)